# បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក

## អំណាចនៃភក្ដីភាពក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់

ហ្គារី ឃីស៊ី
GARY KEESEE

# បដិវត្តន៍ហិរញ្ញវត្ថុ
# របស់អ្នក

អំណាចនៃភក្តីភាពក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់

ហ្គារី ឃីស៊ី
GARY KEESEE

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក**
***អំណាចនៃភក្ដីភាពនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់***

ច្បាប់ដើមជាភាសាអង់គ្លេសត្រូវបានបោះពុម្ពផ្សាយក្រោមចំណងជើងថា
Your Financial Revolution
រក្សាសិទ្ធិ © ឆ្នាំ ២០១៥ ដោយលោក Gary Keesee
បោះពុម្ពផ្សាយដោយ Free Indeed Publishers
ចែកផ្សាយដោយព័ន្ធកិច្ច Faith Life Now
ប្រអប់សំបុត្រលេខ 779
New Albany, OH 43054
1.888.391.LIFE
លោកអ្នកអាចទាក់ទងមកព័ន្ធកិច្ច Faith Life Now Ministries តាមគេហទំព័រ
www.faithlifenow.com

អត្ថបទគម្ពីរត្រូវបានដកស្រង់ពីព្រះគម្ពីរបរិសុទ្ធ © ១៩៥៤ ដោយសមាគមព្រះគម្ពីរកម្ពុជា។ រក្សាសិទ្ធិគ្រប់យ៉ាង។ ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន © ២០០៥ ដោយសមាគមព្រះគម្ពីរកម្ពុជា។ រក្សាសិទ្ធិគ្រប់យ៉ាង។ ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ © ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត។ រក្សាសិទ្ធិគ្រប់យ៉ាង។

សៀវភៅនេះត្រូវបានរក្សាសិទ្ធិគ្រប់យ៉ាងក្រោមច្បាប់ថតចម្លងអន្តរជាតិ។ មាតិកា និង/ឬក្របសៀវភៅនេះនឹងមិនត្រូវបានផលិតឡើងវិញជាផ្នែកទាំងមូល ឬមួយផ្នែកណាមួយនៅក្នុងទម្រង់គ្រប់យ៉ាង ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីគ្រឹះស្ថានបោះពុម្ពផ្សាយឡើយ។
លេខ ISBN: 978-0-9729035-9-2

ប្រែសម្រួលជាភាសាខ្មែរដោយ ខៃរ៉ូស ត្រេនស្លេសិន KairosTranslation.com
បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា

# បញ្ជីមាតិកា


**អារម្ភកថា**...1

**សេចក្ដីលំនាំ**...3

**ជំពូកទី១** ព្រះរាជ្យរបស់ព្រះជាម្ចាស់ ...17

**ជំពូកទី២** អ័ព្ទពណ៌ខៀវ...71

**ជំពូកទី៣** ឱព្រះជាម្ចាស់អើយ សូមមេត្តាទូលបង្គំផង!...81

**ជំពូកទី៤** ត្រីធំ...121

**ជំពូកទី៥** ជម្រើសនរណា?...133

**ជំពូកទី៦** ព្រះពររបស់ព្រះអម្ចាស់...181

**ជំពូកទី៧** ទ្វារនៃផែនដី...207

**ជំពូកទី៨** អំណាចនៃភក្ដីភាពនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់...219

**ជំពូកទី៩** អ្នកយកម្ហូបអាហារឲ្យគេបរិភោគទៅ!...231

**ជំពូកទី១០** ចូរប្រមូល កុំខិតខំធ្វើការយ៉ាងវេទនា!...249

**ជំពូកទី១១** ហោះស្រួលជាងដើរ!...259

# អារម្ភកថា

ខ្ញុំតែងចង់សរសេរអំពីដំណើរជីវិតដែលព្រះជាម្ចាស់បានប្រទានមកខ្ញុំ និង ឌ្រិនដានៅក្នុងពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ជីវិតរបស់យើងបានផ្លាស់ប្តូរច្រើនណាស់! យើងបានឃើញពីការអស្ចារ្យជាច្រើនដែលព្រះយេស៊ូបានធ្វើនៅក្នុងព្រះគម្ពីរកើតឡើងនៅចំពោះមុខយើងនាពេលប៉ុន្មានឆ្នាំកន្លងមកនេះដូចជា មនុស្សស្លាប់រស់ឡើងវិញ មនុស្សខ្វិនអាចក្រោកឡើង ដើរ ហើយត្រលប់ទៅធ្វើការបាននៅថ្ងៃបន្ទាប់ មនុស្សជាច្រើនត្រូវបានប្រោសឲ្យជាសះស្បើយ ហិរញ្ញវត្ថុត្រូវបានស្តារឡើងវិញសម្រាប់មនុស្សរាប់រយរាប់ពាន់នាក់។ ប៉ុន្តែអ្វីដែលអស្ចារ្យជាងគេនោះគឺ យើងបានឃើញវាកើតឡើងនៅក្នុងគ្រួសាររបស់យើង និងជីវិតរបស់យើងផ្ទាល់។

គោលដៅរបស់ខ្ញុំគឺនាំលោកអ្នកទៅក្នុងដំណើរមួយ ជាដំណើរក្នុងការស្វែងរក ដែលខ្ញុំសង្ឃឹមថានឹងផ្លាស់ប្តូរជីវិតរបស់លោកអ្នកដូចជាជីវិតរបស់ខ្ញុំដែរ។ សាច់រឿងទាំងអស់មិនអាចរៀបរាប់អស់នៅក្នុងសៀវភៅតែមួយក្បាលនោះទេ។ នេះជាសៀវភៅដំបូងនៅក្នុងស៊េរីដែលនឹងដឹកនាំលោកអ្នកទៅកាន់បដិវត្តន៍ហិរញ្ញវត្ថុ ហើយនឹងចាប់ផ្តើមបង្ហាញពីអាថ៌កំបាំងមួយចំនួនពីព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលបានផ្លាស់ប្រែជីវិតរបស់ខ្ញុំ។ សម្រាប់រូបខ្ញុំផ្ទាល់ វាជាដំណើរមួយដ៏គួរឲ្យរំភើប និងជាដំណើរមួយដែលគ្មានទីបញ្ចប់។ យើងទាំងអស់គ្នានៅតែបន្តរៀន ព្រោះចំណេះដឹងនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺជាចំណេះដឹងដែលគ្មានទីបញ្ចប់។

ខ្ញុំពិតជាអរព្រះគុណដល់ព្រះជាម្ចាស់ខ្លាំងណាស់។ សេចក្តីមេត្តាករុណារបស់ទ្រង់តែងតែងថ្មីជារៀងរាល់ថ្ងៃ ហើយទ្រង់ជាព្រះដែលអត់ធ្មត់ និងលើកលែង

ទោស ព្រមទាំងដឹកនាំយើងទៅក្នុងផ្លូវនៃការសង្គ្រោះ។ ខ្ញុំមិនអាចនាំលោកអ្នកមកក្នុងដំណើរនេះបានទេ បើមិនបាននិយាយពីឌ្រិនដាជាឧត្ដមភរិយារបស់ខ្ញុំ។ នាងមានដួងចិត្តសម្រាប់ព្រះជាម្ចាស់ ហើយសេចក្ដីស្រឡាញ់ និងភាពអត់ធ្មត់ដែលនាងមានចំពោះខ្ញុំ ផ្ដល់ឲ្យខ្ញុំនូវចិត្តក្លាហានដើម្បីប្រឈមមុខជាមួយភាពខ្សោយដែលខ្ញុំមាន ព្រមទាំងស្វែងរកព្រះជាម្ចាស់សម្រាប់ចម្លើយផ្សេងៗដែលខ្ញុំពិតជាត្រូវការជាខ្លាំង។ ខ្ញុំពិតជាមានអំណរណាស់ដែលបានចែករំលែកជាមួយលោកអ្នកបងប្អូនអំពីសៀវភៅ៖

បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក

*អំណាចនៃភក្ដីភាពនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់*



# សេចក្ដីលំនាំ

*ខ្ញុំឆ្ងាយចេញពីសេចក្ដីសុខទៅ ខ្ញុំបានភ្លេចសេចក្ដីចម្រើនហើយ*

- បរិទេវ ៣៖១៧ (ព្រះគម្ពីរបរិសុទ្ធ)

ខ្ញុំបានភ្ញាក់ពីដំណេកដោយមានអារម្មណ៍មិនស្រួល គឺមិនស្រួលទាល់តែសោះ! នៅពេលដែលខ្ញុំភ្ញាក់ឡើង មានភាពភ័យខ្លាចនៅរួបរឹតជុំវិញចិត្តគំនិតរបស់ខ្ញុំយ៉ាងខ្លាំង។ អណ្ដាតរបស់ខ្ញុំស្ពឹក។ ទាំងដៃ ជើង និងមុខរបស់ខ្ញុំស្ពឹកទាំងអស់។ ខ្ញុំបានដាស់ឌ្រិនដាហើយព្យាយាមប្រាប់នាងពីអ្វីដែលកើតឡើង ប៉ុន្តែខ្ញុំមិនអាចបញ្ជាផ្ទៃមុខ និងអណ្ដាតរបស់ខ្ញុំបានឡើយ។ បន្ទាប់មកខ្ញុំកត់សម្គាល់ថាបេះដូងរបស់ខ្ញុំលោតញាប់ណាស់ ហើយដង្ហើមក៏លឿនដែរនៅពេលដែលខ្ញុំព្យាយាមប្រាប់នាងពីស្ថានភាពរបស់ខ្ញុំ។ នាងក៏ភ្ញាក់ឡើង ហើយចាប់ផ្ដើមអធិស្ឋានឲ្យខ្ញុំភ្លាម ហើយអារម្មណ៍ភ័យខ្លាចចម្លែកៗក៏រសាត់ទៅបន្តិចម្ដងៗ។ ខ្ញុំក៏បានសម្រាកនៅលើគ្រែ ខណៈពេលដែលឌ្រិនដាទៅយកអ្វីមកឲ្យខ្ញុំញ៉ាំ។ ខ្ញុំពិតជាច្របូកច្របល់ និងភ័យខ្លាចពីអ្វីដែលបានកើតឡើងនៅលើរាងកាយរបស់ខ្ញុំ នៅពេលដែលខ្ញុំកំពុងអធិស្ឋាន។ រលកនៃភាពស្លន់ស្លោបានបោកបក់មកលើខ្ញុំ ជាភាពភ័យខ្លាចដែលខ្ញុំមិនដែលមានពីមុនមកក្នុងជីវិត ដែលបានវាយប្រហារក្នុងចិត្តខ្ញុំ។

ខ្ញុំបានរស់នៅជាប់បំណុល និងតែងតែមានតម្រូវការលុយកាក់ ហើយតែងធ្វើឲ្យខ្ញុំភ័យខ្លាច។ វាហាក់ដូចជាធម្មតាទៅហើយនៅក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំបានស្ថិតនៅក្រោមភាពតានតឹង (ស្ត្រេស) យ៉ាងខ្លាំង សម្រាប់រយៈពេលប៉ុន្មានឆ្នាំចុងក្រោយ

នេះទាក់ទងនឹងស្ថានភាពហិរញ្ញវត្ថុដ៏យ៉ាប់យ៉ឺនរបស់ខ្ញុំ។ ខ្ញុំធ្វើការខាងផ្នែកលក់ដែលទទួលចំណូលតាមកម្រៃជើងសារ ហើយមិនសូវរកបានប្រាក់ច្រើនប៉ុន្មានទេ។ យើងជួលផ្ទះតូចមួយ ដែលត្រូវបានសង់ឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៨០០ ដែលហាក់ដូចជាមិនដែលត្រូវបានជួសជុលកែលម្អសោះតាំងពីសង់រួច។ ខ្ញុំហាក់ដូចជានិយាយបំផ្លើសបន្តិច ប៉ុន្តែផ្ទះនោះមិនស្ថិតក្នុងស្ថានភាពល្អស្អាតទេ។ នៅស៊ុមបង្អួច មានប្រហោងហើយមានរុក្ខជាតិដុះកាត់វាទៅក្នុងបន្ទប់ទទួលភ្ញៀវរបស់យើង។ បង្អួចភាគច្រើនសុទ្ធតែបែកបាក់ ហើយយើងបានយកក្រដាសកាតុងបិទស្កុតជាប់នៅលើវា។ ទោះបីយើងស្ថិតនៅក្នុងស្ថានភាពយ៉ាប់យ៉ឺនក្តី ក៏ឌ្រិនដាអាចធ្វើឲ្យវានៅតែជាផ្ទះដ៏រីករាយរបស់យើងដែរ។ ទោះបីជានាងប៉ិនប្រសព្វក្តី ក៏យើងមិនអាចបិទបាំងការពិតបានថា មានបញ្ហាធ្ងន់ធ្ងរមួយចំនួននៅក្នុងផ្ទះរបស់យើង។

របស់ទាំងអស់សុទ្ធតែបាក់បែកដូចគ្នា! ឡានរបស់យើងក៏ចាស់ណាស់ដែរ ជើងជិះវាបានជាង ៣២០,០០០គីឡូម៉ែត្រ ហើយវាពិបាកបញ្ឆេះណាស់។ កូនប្រុសយើងទាំងពីរគេងនៅលើពូក ដែលគេបោះចោលពីផ្ទះថែទាំមួយ ហើយកម្រាលព្រំលើឥដ្ឋក្នុងបន្ទប់គេងរបស់គេ ក៏យើងរើសយកមកពីតាមផ្លូវក្នុងកន្លែងដាក់សំរាមដែរ។ ការបញ្ចាំរបស់របរបានក្លាយរបៀបរស់នៅរបស់យើង ហើយយើងខ្ចីអ្នកណាដែលយើងគិតថាអាចឲ្យយើងខ្ចីបាន។ យើងរស់នៅដើម្បីចិញ្ចឹមតែក្រពះ រកមើលក្រែងមានអ្វីដែលយើងអាចលក់បាន ហើយស្វែងរករបៀបណាមួយដើម្បីរស់ ទាំងសង្ឃឹមថាថ្ងៃស្អែកអ្វីៗនឹងប្រសើរឡើង។

ខ្ញុំបានចាយលុយទាំងអស់ ដែលមាននៅក្នុងកាតឥណទានទាំង១០របស់ខ្ញុំ ហើយត្រូវគេកាត់ផ្តាច់កាលពីប៉ុន្មានខែមុន ទាំងជាប់បំណុលជាមួយក្រុមហ៊ុនហិរញ្ញវត្ថុចំនួនបី ដែលនៅសល់២៨% ត្រូវសងត្រលប់ទៅវិញ។ ការទូទាត់លើថ្លៃឡានរបស់ខ្ញុំ (ខ្ញុំនៅតែជំពាក់បំណុលគេ ទោះបីជាឡានរបស់ខ្ញុំចាស់ក៏ដោយ) យឺតចំនួន ១២០ថ្ងៃ ហើយជិតដល់ថ្ងៃគេរឹបអូសផង។ សម្រាប់ការទូទាត់វិក្កយបត្រផ្សេងៗ ខ្ញុំតែងតែបង់យឺតជានិច្ច។ ខ្ញុំក៏ត្រូវគេប្តឹង និងដាក់សិទ្ធិរឹបអូសទ្រព្យសម្បត្តិ

ប្រឆាំងនឹងខ្ញុំ ហើយមនុស្សជាច្រើនទូរស័ព្ទមកទារប្រាក់មុនពេលដែលខ្ញុំបើកភ្នែកឡើងជារៀងរាល់ព្រឹក។ ខ្ញុំបានជំពាក់បំណុលពន្ធអាករ (IRS Money) ហើយពួកគេក៏បានដាក់សិទ្ធិរឹបអូសទ្រព្យសម្បត្តិរបស់ខ្ញុំសម្រាប់ពន្ធដែលខ្ញុំមិនទាន់បង់ដែរ។ ឌ្រិនដានិងខ្ញុំជំពាក់ឪពុកម្ដាយយើង ២៦,០០០ ដុល្លារ ហើយពួកគាត់ហត់នឿយក្នុងការជួយពួកយើងណាស់។ ទូរទឹកកករបស់យើងកម្រមានម្ហូប ឬគ្រឿងទេសពេញណាស់។ អគ្គិសនីរបស់យើង ក៏តែងតែមានការគំរាមផ្ដាច់ជាញឹកញាប់ពីក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីសម្រាប់ការប្រើប្រាស់ប្រចាំខែដែរ ហើយខ្ញុំបានឈានដល់កម្រិតមួយដែលអស់ផ្លូវដើរ (ទាល់ច្រក)។

ឥឡូវនេះស្ត្រេសកំពុងតែជះឥទ្ធិពលលើរូបរាងកាយខ្ញុំ ដែលខ្ញុំមិនយល់ទាល់តែសោះ។ បន្ទាប់ពីបានជួបពិគ្រោះជាមួយគ្រូពេទ្យមួយចំនួន ពួកគេបាននិយាយថាខ្ញុំធ្លាប់មានបទពិសោធន៍តក់ស្លុតខ្លាំង ហើយគេបានឲ្យលេបថ្នាំរំងាប់អារម្មណ៍ (ទុក្ខព្រួយ ការពិបាកចិត្ត)។ ជាអកុសល ភាពតក់ស្លុតខ្លាំងនេះនៅតែបន្តហើយកើតមានឡើងជាញឹកញាប់ រហូតឈានទៅដល់កម្រិតមួយដែលខ្ញុំខ្លាចលែងចង់ចេញពីផ្ទះ។ ក្នុងរយៈពេលប៉ុន្មានថ្ងៃនៃភាពភ័យខ្លាចដ៏អាប់អួរនេះ ខណៈពេលដែលខ្ញុំស្វែងរកចម្លើយ ខ្ញុំចាប់ផ្ដើមសម្គាល់ឃើញថា អាហារមួយចំនួនដែលមានស្ករ ម្សៅ ឬជាតិកាហ្វេអ៊ីន បានធ្វើឲ្យខ្ញុំរឹតតែភ័យស្លន់ស្លោឡើង ហើយឥឡូវនេះ ខ្ញុំភ័យលែងចង់បរិភោគអាហារ ព្រមទាំងប្រយ័ត្នប្រយែងពីអាហារគ្រប់យ៉ាងដែលខ្ញុំបរិភោគ។ ជីវិតរបស់ខ្ញុំចាប់ផ្ដើមជាប់ចំណងម្យ៉ាងដែលខ្ញុំមិនអាចរើចេញបាន ហើយថែមទាំងធ្វើឲ្យហិរញ្ញវត្ថុរបស់ខ្ញុំកាន់តែយ៉ាប់ថែមទៀត។

ប្រពន្ធរបស់ខ្ញុំ បានគិតថានឹងត្រូវបាត់បង់ប្ដីរបស់នាង ហើយបន្ទាប់ពីខ្ញុំបានជា នាងបានសារភាពប្រាប់ខ្ញុំថា នាងបានរៀបផែនការអំពីអ្វីដែលនាងត្រូវធ្វើដើម្បីថែរក្សាកូនរបស់យើង។ ខ្ញុំបានស្រែកទៅកាន់ព្រះជាម្ចាស់សម្រាប់ចម្លើយ ខណៈពេលដែលខ្ញុំមិនដែលមានបទពិសោធន៍ ឬចំណេះដឹងពីអ្វីដែលខ្ញុំកំពុងតែតយុទ្ធនេះទេ។ គ្រូពេទ្យល្បីៗជាច្រើន បាននិយាយថាជំងឺដែលខ្ញុំមាននេះ គឺមិនអាច

ព្យាបាលបានទេ ហើយខ្ញុំនឹងត្រូវលេបថ្នាំជារៀងរហូត។ គ្រូពេទ្យផ្សេងទៀតបាននិយាយថា ខ្ញុំស្ថិតនៅក្នុងស្ថានភាពដែលនឹងវិវដ្តជាជំងឺទឹកនោមផ្អែម ទាំងនិយាយថាគេអាចប្រើករណីរបស់ខ្ញុំជាករណីសាកល្បង ដើម្បីតាមដានជំងឺនៅពេលដែលខ្ញុំកាន់តែចាស់ទៅៗ។

ទោះបីជាខ្ញុំជាគ្រិស្តបរិស័ទក៏ដោយ ខ្ញុំមិនដែលមានបទពិសោធន៍ពីសង្គ្រាមខាងវិញ្ញាណ ឬរបៀបប្រឆាំងនឹងមារសត្រូវឡើយ។ តាមពិតនៅពេលនោះ ខ្ញុំមិនបានដឹងថាខ្ញុំកំពុងតែតយុទ្ធជាមួយវិញ្ញាណអារក្សទេ។ ខ្ញុំគិតថា ខ្ញុំគ្រាន់តែមានបញ្ហាផ្នែករាងកាយប៉ុណ្ណោះ ហើយសុំព្រះជាម្ចាស់ប្រោសខ្ញុំឲ្យបានជា។ ក្នុងនាមជាគ្រិស្តបរិស័ទម្នាក់ ខ្ញុំគ្រាន់តែដឹងថា ព្រះជាម្ចាស់ជាចម្លើយរបស់ខ្ញុំ ប៉ុន្តែនៅក្នុងពេលនោះ ខ្ញុំមានអារម្មណ៍ថាព្រះជាម្ចាស់ពិតជានៅឆ្ងាយខ្លាំងណាស់។ គ្រូពេទ្យបានវិនិច្ឆ័យរោគខ្ញុំពីជំងឺជាច្រើនផ្សេងៗគ្នា សម្រាប់ស្ថានភាពដែលខ្ញុំមាន ហើយអ្វីៗទាំងអស់គឺសុទ្ធតែទាក់ទងនឹងបញ្ហាផ្លូវចិត្ត ព្រមទាំងអាចព្យាបាលបានតែតាមរយៈការប្រើថ្នាំមួយចំនួនប៉ុណ្ណោះ។ ដូចដែលខ្ញុំបាននិយាយពីមុន គ្មានអ្វីដែលនឹងបានជាទេ គ្រាន់តែជាការព្យាបាលដែលជួយសម្រួលដល់បញ្ហាផ្លូវចិត្តរបស់ខ្ញុំប៉ុណ្ណោះ។ ខ្ញុំបានរងផលប៉ះពាល់ពីថ្នាំផ្សេងៗ តែទោះជាយ៉ាងណាក៏ដោយ ក៏វាមិនបានជួយអ្វីខ្ញុំដែរ។ តាមពិត ខ្ញុំជឿថាវាបានបន្ថែមរោគសញ្ញាផ្សេងៗដល់ខ្ញុំទៀត។ វាបានធ្វើឲ្យខ្ញុំដូចជារស់នៅក្នុងភាពអាប់អួរ ការឈឺចុកចាប់ និងគំនិតភ័យខ្លាចផ្សេងៗ ដែលខ្ញុំមិនអាចគ្រប់គ្រងខ្លួនឯងបាន។ ខ្ញុំមិនបានចម្លើយអ្វីទេ និងគ្មានអ្វីដែលអាចជួយខ្ញុំដែរ។ បញ្ហានេះបានបន្តអស់ពីរបីសប្តាហ៍ ហើយសេចក្តីអស់សង្ឃឹមក៏កាន់តែកើនឡើងខណៈពេលដែលរោគសញ្ញា និងភាពភ័យខ្លាចបានគ្រប់គ្រងលើជីវិតរបស់ខ្ញុំ។

ប៉ុន្តែនៅយប់មួយ មានការទម្លុះទម្លាយកើតឡើងខណៈពេលដែលខ្ញុំបានស្វែងរកព្រះជាម្ចាស់សម្រាប់ចម្លើយ។ ខ្ញុំបានរកឃើញគន្លឹះសំខាន់មួយដើម្បីសេរីភាពរបស់ខ្ញុំ។ ខ្ញុំបានចូលរួមក្រុមជំនុំតាមផ្ទះដែលធ្វើឡើងនៅល្ងាចថ្ងៃពុធ។ នៅក្នុងកំឡុងពេលថ្វាយបង្គំ និងសរសើរតម្កើងព្រះជាម្ចាស់ ខ្ញុំស្រាប់តែមានអារម្មណ៍ភ័យ

ស្លន់ស្លោជាខ្លាំង។ ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីទេ ហើយក៏អស់សង្ឃឹមខ្លាំងណាស់។ ខ្ញុំដឹងថាខ្ញុំត្រូវការការអធិស្ឋាន ដូច្នេះខ្ញុំក៏បានដើរទៅខាងមុខ។ ទោះបីជាខ្ញុំកំពុងតែរំខានការថ្វាយបង្គំនោះក៏ដោយ ក៏ខ្ញុំមិនខ្វល់ដែរ។ ខ្ញុំកំពុងតែចូលរួមនៅក្នុងក្រុមជំនុំធំមួយ ហើយលោកគ្រូគង្វាលក៏មិនស្គាល់ខ្ញុំដែរ ប៉ុន្តែមានសមាជិកក្រុមថ្វាយបង្គំម្នាក់ស្គាល់ខ្ញុំ។ ខណៈពេលដែលខ្ញុំកំពុងតែដើរឡើងលើឆាកទាំងភាពអស់សង្ឃឹម អ្វីៗទាំងអស់ក៏ឈប់ ហើយគ្រប់ក្រសែភ្នែកទាំងអស់បានសម្លឹងមកខ្ញុំ។ សមាជិកក្រុមថ្វាយបង្គំនោះក៏បានឆ្លើយតបភ្លាមៗ ខណៈពេលដែលគាត់បានឃើញក្រុមសន្តិសុខកំពុងតែដើរតម្រង់មកដើម្បីស្ទាក់ខ្ញុំ។

ខណៈពេលដែលគាត់ប្រាប់ពីស្ថានភាពរបស់ខ្ញុំទៅកាន់គ្រូគង្វាល ខ្ញុំអាចឃើញថាគ្រូគង្វាលបានបញ្ចេញទឹកមុខធូរស្រាល។ គាត់បានដើរមករកខ្ញុំ ហើយអធិស្ឋានឲ្យខ្ញុំ។ មិត្តរបស់ខ្ញុំបានប្រាប់គ្រូគង្វាលថាខ្ញុំឈឺ។ គ្រូគង្វាលក៏មើលមកកាន់ខ្ញុំ ហើយនិយាយថា «គាត់មានវិញ្ញាណនៃភាពពិការ»។ នាពេលនោះ គាត់បានដាក់ដៃលើក្បាលរបស់ខ្ញុំ ហើយបញ្ជាវិញ្ញាណនោះឲ្យចេញ។ នៅគ្រានោះ មានអ្វីដែលអស្ចារ្យបានកើតឡើង គឺខ្ញុំមានសេរីភាព។ ដែលជាលើកដំបូង ក្នុងរយៈពេលប៉ុន្មានខែមកហើយ ខ្ញុំមានអារម្មណ៍ធម្មតា គ្មានការឈឺចាប់ គ្មានភាពភ័យខ្លាច ជាអារម្មណ៍សន្តិភាពយ៉ាងជ្រាលជ្រៅបំផុត។ ខ្ញុំគ្មានពាក្យអ្វីនឹងថ្លែងក្រៅពីពាក្យថាអរគុណទេ។ ខ្ញុំពិតជារំភើប នឹកមិនដឹងថាត្រូវពន្យល់យ៉ាងណា។ ខ្ញុំមានអារម្មណ៍ថាវិលមុខ ហើយស្រាលដូចជាសំឡី និងពោរពេញដោយអំណរ។

បន្ទាប់ពីចេញចប់វេនថ្វាយបង្គំ ឪ្រិនដានិងខ្ញុំបានទៅហាងលក់ភីហ្សាជាមួយមិត្តភក្តិមួយចំនួនដើម្បីអបអរសាទរ។ ខណៈពេលដែលខ្ញុំអង្គុយនៅទីនោះញ៉ាំភីហ្សា ខ្ញុំនឹកចាំពីបទចំរៀងមួយបទដែលកំពុងចាក់ផ្សាយនៅលើវិទ្យុ ហើយភ្លាមនោះខ្ញុំចាប់ផ្តើមមានអារម្មណ៍នៃភាពភ័យខ្លាចមកសន្ធប់លើខ្ញុំដូចជាភ្លួយ។ វាត្រលប់មកវិញ។ នៅពេលនោះ ខ្ញុំបានដឹងថាវាជាវិញ្ញាណ។ គ្រូគង្វាលបាននិយាយថាវិញ្ញាណនៃភាពពិការ ប៉ុន្តែខ្ញុំមិនដឹងថាគាត់ចង់មានន័យយ៉ាងដូចម្ដេចនោះទេ ខ្ញុំ

ដូចជាច្រទាំបន្តិច។ ខ្ញុំគិតថា ខ្ញុំបានជារួចទៅហើយនៅក្នុងវេនថ្វាយបង្គំនោះ ប៉ុន្តែជាក់ស្តែងខ្ញុំមិនទាន់បានជានៅឡើយទេ។ នៅថ្ងៃបន្ទាប់ ខ្ញុំបានតយុទ្ធជាមួយនឹងភាពភ័យស្លន់ស្លោម្តងទៀត ប៉ុន្តែខ្ញុំមិនអាចឈប់គិតពីអ្វីដែលបានកើតឡើងនៅក្នុងក្រុមជំនុំពីយប់មុនឡើយ។ នៅពេលដែលគ្រូគង្វាលបានអធិស្ឋានឲ្យខ្ញុំ គាត់មិនបានអធិស្ឋានថាខ្ញុំនឹងបានជានោះទេ។ គាត់បានប្រើប្រាស់សិទ្ធិអំណាចនៅលើវិញ្ញាណអាក្រក់។ ការដែលស្ថានភាពរបស់ខ្ញុំបានឆ្លើយតបទៅកាន់គ្រូគង្វាលក្នុងលក្ខណៈបែបនោះ បង្ហាញថាវាមិនមែនជាជំងឺទេ តែវាជាវិញ្ញាណអាក្រក់វិញ។ (ជាថ្មីម្តងទៀត លោកអ្នកអាចឃើញថាខ្ញុំពិតជាមិនទាន់ចាស់ទុំក្នុងអង្គព្រះគ្រិស្តនៅឡើយទេ ដែលមិនស្គាល់ពីការនេះ។) នៅកំឡុងពេលនោះ ខ្ញុំដឹងតិចតួចបំផុតពីសង្គ្រាមខាងវិញ្ញាណ ហើយខ្ញុំក៏បានដឹងដែលថាអារក្សពិតជាមាន។ ខ្ញុំបានជួបវាម្តងហើយ។

នៅក្នុយវ័យជំទង់ ខ្ញុំបានជួយគ្រប់គ្រងហាងភីហ្សាមួយក្នុងចំណោមហាងភីហ្សាពីររបស់ឪពុកម្តាយរបស់ខ្ញុំ។ នៅយប់មួយ មានបុរសម្នាក់បានចូលមកក្នុងហាង ហើយប្រាប់ខ្ញុំថាគាត់កំពុងតែធ្វើកម្មវិធីផុសផុលមួយនៅតាមផ្លូវឯព្រះវិហារមេតូឌីស្ទមួយនៅក្នុងតំបន់។ គាត់បានអញ្ជើញខ្ញុំឲ្យទៅចូលរួម ព្រមទាំងបានបញ្ចប់ការអញ្ជើញរបស់គាត់ជាមួយនឹងឃ្លាថា «ព្រះយេស៊ូកំពុងតែធ្វើកិច្ចការដដែលដូចដែលទ្រង់បានធ្វើនៅក្នុងព្រះគម្ពីរ»។ ពេលនោះវាធ្វើឲ្យខ្ញុំចាប់អារម្មណ៍។ ខ្ញុំបានធំធាត់ឡើងនៅក្នុងក្រុមជំនុំ។ ខ្ញុំបានថ្វាយដួងចិត្តទៅកាន់ព្រះអម្ចាស់កំឡុងពេលវិស្សមកាលសាលាព្រះគម្ពីរនៅពេលខ្ញុំរៀនថ្នាក់ទី៥។ ប៉ុន្តែខ្ញុំមិនដែលបានឃើញឫទ្ធានុភាពរបស់ព្រះជាម្ចាស់ប្រោសនរណាម្នាក់ឲ្យបានជាក្នុងរយៈពេលប៉ុន្មានឆ្នាំនោះទាល់តែសោះ គឺគ្មានអ្វីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍នោះឡើយ ទោះបីជាខ្ញុំដឹងថាមានព្រះជាម្ចាស់ក៏ដោយ។ ដូច្នេះជីវិតរបស់ខ្ញុំបានឃ្លាតឆ្ងាយពីព្រះអម្ចាស់ក្នុងឆ្នាំសិក្សារបស់ខ្ញុំ។ យូរៗម្តងក្នុងកំឡុងពេលប៉ុន្មានឆ្នាំនោះ ខ្ញុំនឹងធ្វើការប្តេជ្ញាចិត្តថ្មីក្នុងការចូលរួមក្នុងក្រុមជំនុំ ប៉ុន្តែចំណាប់អារម្មណ៍របស់ខ្ញុំមិនដែលនៅបានយូរទេ។

សម្រាប់បុរសម្នាក់នេះវិញ ហាក់ដូចជាខុសគ្នា។ ព្រះយេស៊ូនៅតែបន្តធ្វើអ្វីដូចដែលទ្រង់បានធ្វើនៅក្នុងព្រះគម្ពីរ? ខ្ញុំចាប់អារម្មណ៍នូវពាក្យសម្ដីរបស់គាត់។ មានបុគ្គលិករបស់ខ្ញុំមួយចំនួនចូលរួមក្នុងក្រុមជំនុំនោះ ហើយពួកគេបានលើកទឹកចិត្តខ្ញុំឲ្យទៅ ដូច្នេះខ្ញុំសម្រេចចិត្តថាទៅ។

យប់ដំបូងដែលខ្ញុំទៅទីនោះ ខ្ញុំមានអារម្មណ៍ពីព្រះវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងរបៀបមួយដែលខ្ញុំមិនធ្លាប់ជួបពីមុនមក។ វាហាក់ដូចជាខ្ញុំអាចដឹងពីព្រះវត្តមានរបស់ព្រះជាម្ចាស់ គឺជាក់ស្ដែងណាស់។ សារដែលបុរសនោះបាននិយាយពិតជាមានអានុភាពណាស់ ហើយនៅពេលដែលគាត់សួរថាមាននរណាចង់ថ្វាយខ្លួន ឬថ្វាយជីវិតសាជាថ្មីទៅកាន់ព្រះយេស៊ូដែរឬទេ ខ្ញុំបានលើកដៃ។ អស្ចារ្យណាស់! វាជាយប់ដ៏អស្ចារ្យមួយ។ ខ្ញុំពិតជារំភើបណាស់។ ខ្ញុំចង់ប្រាប់មនុស្សគ្រប់គ្នាថា ព្រះជាម្ចាស់ពិតជាអស្ចារ្យណាស់។

នៅសម័យនោះ គ្មានអ៊ីនធើណិត គ្មានស៊ីឌី ឬកាសែត ហើយយើងមានទូរទស្សន៍តែបីប៉ុស្ដិ៍ប៉ុណ្ណោះ។ ទីក្រុងរបស់យើងក៏តូចដែរ ដូច្នេះគ្មានអ្វីត្រូវធ្វើច្រើនទេពីមួយម៉ោងទៅមួយម៉ោង។ ដូច្នេះក្មេងជំទង់តែងតែអង្គុយនិយាយគ្នាលេងនៅហាងលក់ភីហ្សាជាច្រើនម៉ោង អាចរហូតដល់យប់ដើម្បីកម្សាន្ត។ ហាងយើងបិទនៅម៉ោង ១ព្រឹក សម្រាប់យប់ថ្ងៃសុក្រ និងថ្ងៃសៅរ៍ ហើយចំណតរបស់យើងចតពេញដោយក្មេងជំទង់ៗ។ ជាច្រើនដង ខ្ញុំត្រូវតែទៅដេញពួកគេឲ្យចេញ ដោយសារតែពួកគេធ្វើឲ្យអតិថិជនរបស់ខ្ញុំពិបាករកកន្លែងចត។ មានយប់ជាច្រើនដែលមានការឈ្លោះគ្នា ហើយចាំបាច់ត្រូវប៉ូលីសមកបំបែក និងបញ្ជូនក្មេងទាំងនោះទៅផ្ទះវិញ។ ប៉ុន្តែឥឡូវនេះខ្ញុំមានគំនិតមួយ។ ក្មេងជំទង់ទាំងនោះត្រូវតែឮពីព្រះយេស៊ូ។ ដូច្នេះខ្ញុំក៏បានចេញទៅក្រៅ ហើយប្រាប់ពួកគេថាប្រសិនបើមាននរណាចង់នៅ ខ្ញុំនឹងបង្រៀនព្រះគម្ពីរនៅក្នុងហាងភីហ្សាបន្ទាប់ពីយើងបិទហាង។ ប្រសិនបើមិនប្រកាន់នោះទេ យើងនឹងចាប់ផ្ដើមនៅម៉ោង ១៖៣០ព្រឹក ដោយសារតែយើងត្រូវតែសម្អាតហាង និងបិទហាងពីម៉ោង ១ ដល់ ១៖៣០ ព្រឹក។ ខ្ញុំមិនដឹងថាមានប៉ុន្មាន

នាក់នឹងមកទេ ប៉ុន្តែលោកអ្នកដឹងឬទេ? មានក្មេងជំទង់មួយចំនួនបានមកចូលរួម ហើយក៏មានបុគ្គលិករបស់ខ្ញុំពីរបីនាក់ដែរ។ នៅយប់ដំបូងដែលខ្ញុំដឹកនាំការប្រជុំនោះ មានក្មេងជំទង់ម្នាក់បាននិយាយថា ខ្លួនចង់បម្រើព្រះគ្រិស្ត ហើយបានសួរខ្ញុំថាតើគាត់ត្រូវធ្វើអ្វី។ ពេលនេះ សំណួរនេះជាបញ្ហាយ៉ាងពិសេសមួយសម្រាប់ខ្ញុំ ខណៈពេលខ្ញុំមិនគិតផ្នែកនោះនៅឡើយទេ។ សូមចាំថា ខ្ញុំមិនដឹងអ្វីទាំងអស់ក្នុងព្រះគម្ពីរ ប៉ុន្តែខ្ញុំបានអានខគម្ពីរមួយ ដែលហាក់ដូចឆ្លើយតបទៅនឹងការខ្វល់ខ្វាយរបស់ខ្ញុំ។

*អ្នកណាអង្វររកព្រះនាមព្រះអម្ចាស់ អ្នកនោះនឹងទទួលការសង្គ្រោះ។*

\- កិច្ចការ ២៖២១

វាហាក់ដូចជាសាមញ្ញណាស់ អ្វីដែលខ្ញុំបានសម្រេចចិត្តហើយ ខ្ញុំនឹងធ្វើ។ នៅពេលដែលយើងបំបែកក្រុម ក្មេងជំទង់ម្នាក់នេះបានមករកខ្ញុំជាមួយនឹងសំណួរនេះ ហើយខ្ញុំបានប្រាប់គេឲ្យអង្គុយចុះលើកៅអី ព្រមទាំងនិយាយឈ្មោះព្រះយេស៊ូ។ ខ្ញុំគិតថាវាគ្រាន់ជាការរឿងសាមញ្ញដើម្បីធ្វើ ប៉ុន្តែខ្ញុំអង្គុយនៅទីនោះអស់រយៈពេល២នាទី ហើយគាត់មិនបាននិយាយអ្វីទេ។ ដូច្នេះខ្ញុំបាននិយាយពីការណែនាំរបស់ខ្ញុំម្តងទៀត ដោយគិតថាគាត់មិនបានឮខ្ញុំ។ ហាក់ដូចជាគ្មានអ្វីកើតឡើង តែបន្ទាប់មកខ្ញុំសម្គាល់ឃើញថា ខ្លួនគាត់កំពុងតែញ័រ។ ខ្ញុំអាចនិយាយបានថា សភាពរបស់គាត់ហាក់ដូចជាមានបញ្ហាក្នុងការនិយាយព្រះនាមព្រះយេស៊ូចេញពីមាត់គាត់។ ភ្លាមនោះហាក់ដូចជាជញ្ជាំងត្រូវបានទម្លុះ គឺគាត់បាននិយាយឈ្មោះព្រះយេស៊ូ ហើយសេចក្តីសុខសាន្តក៏បានបង្ហូរមក។ ជាការប្រសើរណាស់ វាអាចទៅរួច! នោះហើយជាផែនការរបស់ខ្ញុំ នៅគ្រប់ពេលដែលមាននរណាម្នាក់ចង់ថ្វាយជីវិតទៅកាន់ព្រះអម្ចាស់។ ខ្ញុំនឹងឲ្យគេអង្គុយនៅលើកៅអី ហើយនិយាយឈ្មោះព្រះយេស៊ូ។ វាស្ទើរតែគ្មានអ្វីប្លែកនោះទេ ពួកគេមិនអាចចាប់ផ្តើមហៅព្រះនាមទ្រង់បានភ្លាមៗទេ។ ពួកគេនឹងចាប់ផ្តើមញ័រ ហើយបន្ទាប់មក វាហាក់ដូចជាពិបាក តែភ្លាមនោះពួកគេក៏បាននិយាយព្រះនាមទ្រង់ចេញមក ហើយនឹងមានសេចក្តីសុខសាន្តក្នុងចិត្តផង។

នៅថ្ងៃមួយ ខណៈពេលដែលខ្ញុំនៅខាងក្រោយបន្ទប់កំពុងលាយម្សៅ ខ្ញុំបានឮសំឡេងគោះទ្វារក្រោយ។ នៅពេលដែលខ្ញុំបើកទ្វារ ខ្ញុំចាំពីក្មេងជំទង់ពីរនាក់ ដែលកំពុងតែឈរ ជាក្មេងដែលខ្ញុំបាននិយាយជាមួយអំពីព្រះគ្រិស្តពីមុន។ ខ្ញុំក៏អញ្ជើញពួកគេឲ្យចូល ហើយមានក្មេងម្នាក់បាននិយាយថា គាត់ចង់ថ្វាយជីវិតទៅកាន់ព្រះជាម្ចាស់។ ដូច្នេះខ្ញុំក៏ឲ្យគាត់អង្គុយលើកៅអីដូចរាល់ដង គាត់ក៏ចាប់ផ្តើមញ័រ ហើយបាននិយាយព្រះនាមព្រះយេស៊ូ។ នៅពេលដែលខ្ញុំសម្លឹងទៅលើ ខ្ញុំបានឃើញក្មេងជំទង់ម្នាក់ទៀតរត់ចេញពីខ្ញុំទៅជ្រុងម្ខាងទៀតនៃបន្ទប់ មើលទៅហាក់ដូចជាសត្វជាប់ទ្រុង។ គាត់ព្យាយាមរត់បុកជញ្ជាំង ហាក់ដូចជាព្យាយាមរត់គេចចេញពីខ្ញុំ។ វាពិតជាចម្លែកខ្លាំងណាស់ ខ្ញុំសឹងតែរកពាក្យអ្វីនិយាយមិនចេញ។

ខណៈពេលដែលខ្ញុំឈរសម្លឹងមើលគាត់ ភ្លាមនោះខ្ញុំនឹកឃើញថា «ខ្ញុំឆ្ងល់ថា តើនេះជាអារក្សមែនទេ»។ ឥឡូវនេះ ខ្ញុំគ្មានបទពិសោធន៍ជាមួយអារក្សនោះទេ ប៉ុន្តែខ្ញុំបានអានខ្លះពីអារក្សនៅក្នុងព្រះគម្ពីរ។ ខ្ញុំស្ទើរតែមិនអាចពន្យល់បានពីសកម្មភាពប្លែកៗរបស់គាត់។ ដូច្នេះ ខ្ញុំបាននិយាយថា «ព្រះយេស៊ូ តើនេះជាអារក្សមែនទេ?» រំពេចនោះ វាហាក់មានស្បៃបើកចេញពីមុខខ្ញុំ ខ្ញុំអាចឃើញពីអារក្សដែលកំពុងស្ថិតនៅក្នុងក្មេងម្នាក់នេះ។ អារក្សនេះវាមានកម្ពស់ប្រហែល១ម៉ែត្រ ហើយវាកំពុងតែតោងជាប់នឹងក្មេងម្នាក់នេះទាំងយួរជើងទាំងពីរឡើង។ មនុស្សតែងតែសួរខ្ញុំថា «តើវាមានរូបរាងយ៉ាងណា?» វាស្រដៀងនឹងស្វា ប៉ុន្តែខុសពីស្វា។ វាមានរោមច្រើនដូចស្វា ហើយដៃវែងដូចស្វា ប៉ុន្តែមានភ្នែកក្រហមសម្លឹងចុះឡើង និងមានមុខគួរឲ្យខ្លាច។ នៅពេលដែលខ្ញុំឃើញភ្នែកនោះភ្លាម ខ្ញុំបានស្រែកទៅកាន់ព្រះអម្ចាស់យ៉ាងខ្លាំង។ សម្អប់ដែលខ្ញុំមើលឃើញនៅក្នុងភ្នែកទាំងនោះ គឺលើសពីអ្វីដែលខ្ញុំអាចទ្រាំបានទៅទៀត។ ពាក្យមួយដែលល្អបំផុតដើម្បីពណ៌នាពីអ្វីដែលខ្ញុំបានឃើញនៅក្នុងភ្នែកនោះគឺសម្អប់។ ភ្លាមនោះខ្ញុំដឹងថា វាមិនគ្រាន់តែស្អប់នោះទេ ហើយថែមទាំងខឹងខ្ញុំខ្លាំងដែរ។

ឥឡូវតើខ្ញុំគួរធ្វើយ៉ាងណា? ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីទៀតនោះទេ បន្ទាប់ពីខ្ញុំបានឃើញវា។ ប៉ុន្តែខ្ញុំបានគិតថា ប្រសិនបើនាមរបស់ព្រះយេស៊ូនាំយើងទៅព្រះរាជ្យរបស់ទ្រង់ នោះនឹងមានអំណាចលើអារក្សនេះ ដូច្នេះខ្ញុំបាននិយាយខ្លាំងៗថា «នៅក្នុងព្រះនាមព្រះយេស៊ូ»។ ភ្លាមនោះស្បែក៏បិទជិត។ ប្រសិនបើអ្នកចាំពីទូរទស្សន៍ស-ខ្មៅ នៅពេលដែលអ្នកបិទវា នោះនឹងមានស្រមោលនៃរូបភាពដែលអ្នកកំពុងតែមើលនោះ រសាត់ទៅបន្តិចម្តងៗចេញពីកញ្ចក់ទូរទស្សន៍។ នោះហើយជាលក្ខណៈរបស់វា។ ខ្ញុំមិនអាចមើលឃើញវានោះទេ ប៉ុន្តែខ្ញុំនៅតែអាចមើលឃើញភាពអាប់អួររសាត់បាត់ទៅដូចជាគ្របស្បែជិត ហើយក្មេងជំទង់នោះក៏បានរត់ចេញទៅបាត់។

មែនហើយ ខ្ញុំបានដឹងថាអារក្សមានពិតមែន។ វាជាការប្រសើរជាងប្រសិនបើខ្ញុំនិយាយបែបនេះ នៅពេលដែលខ្ញុំដឹងថាបញ្ហារបស់ខ្ញុំជាវិញ្ញាណអាក្រក់ ខ្ញុំបានដោះស្រាយជាមួយវា ហើយបានរស់នៅក្នុងសេរីភាពចាប់តាំងពីពេលនោះមក។ ប៉ុន្តែវាមិនកើតឡើងភ្លាមៗទេ។ វាពិតជាគួរឲ្យសោកស្តាយណាស់ បន្ទាប់ពីបានចូលរួមនៅក្នុងក្រុមជំនុំប៉ុន្មានឆ្នាំមកនេះ ខ្ញុំមិនដែលចំណាយពេលរៀនពីអត្តសញ្ញាណរបស់ខ្ញុំនៅក្នុងអង្គព្រះគ្រិស្ត និងរៀនអំពីការប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្ញុំប្រឆាំងនឹងសត្រូវឡើយ។ ប៉ុន្តែឥឡូវនេះខ្ញុំបានដឹង ឬយ៉ាងហោចណាស់សង្ស័យថា ខ្ញុំត្រូវដោះស្រាយជាមួយវិញ្ញាណអាក្រក់ ហើយខ្ញុំក៏ត្រូវបានលើកទឹកចិត្តថាខ្ញុំអាចរៀនពីរបៀបយកឈ្នះវាបាន។ ខ្ញុំបានដឹងច្បាស់ថា អារក្សនឹងឆ្លើយតបមកកាន់សិទ្ធិអំណាចរបស់ខ្ញុំ ប៉ុន្តែបានភាន់ច្រឡំដោយសារតែវាមិនបានឆ្លើយតប។ ពីរបីថ្ងៃក្រោយមក ខ្ញុំមានបទពិសោធន៍វិជ្ជមានមួយទៀត ដែលបញ្ជាក់ថាបញ្ហារបស់ខ្ញុំពិតជាមកពីវិញ្ញាណអាក្រក់។

ខ្ញុំនៅក្នុងបន្ទប់គេងកំពុងតែអធិស្ឋានតាមការណែនាំនៃព្រះវិញ្ញាណ ហើយបានប្តេជ្ញាថានឹងចំណាយពេលវេលាគ្រប់គ្រាន់ក្នុងការអធិស្ឋាន ដើម្បីទទួលបានចម្លើយពីអ្វីដែលកំពុងតែកើតឡើង។ នៅក្នុងកំឡុងពេលអធិស្ឋាន ខ្ញុំក៏ចាប់ផ្តើមមានអារម្មណ៍ធូរស្រាល និងមានសេរីភាពម្តងទៀត ដូចនៅពេលដែលគ្រូគង្វាលអធិស្ឋានឲ្យខ្ញុំ។ នៅពេលនោះ មានសេរីភាពបានប្រហែលតែពីរម៉ោងប៉ុណ្ណោះ នៅ

ក្នុងយប់នោះមុនពេលដែលវាត្រលប់មកវិញ ប៉ុន្តែឥឡូវនេះ ខ្ញុំប្រាកដច្បាស់ណាស់ វាជាវិញ្ញាណហើយបានឆ្លើយតបចំពោះការអធិស្ឋានរបស់ខ្ញុំ។ ខ្ញុំបានព្យាយាម អធិស្ឋានម្ដងទៀត ប៉ុន្តែគ្មានអ្វីនោះទេ។ ហេតុដូច្នេះហើយ ទើបខ្ញុំចាប់ផ្ដើមអានអ្វី គ្រប់យ៉ាងដែលទាក់ទងនឹងសង្គ្រាមខាងវិញ្ញាណ ហើយចំណាយពេលអនុវត្តពីអត្ត សញ្ញាណរបស់ខ្ញុំក្នុងព្រះគ្រិស្ដ។ ប៉ុន្តែវានៅតែមិនចុះចាញ់ងាយៗនោះទេ។ មានតែ ពេលមួយនោះទេ នៅពេលដែលខ្ញុំអធិស្ឋាន ដែលខ្ញុំបានឃើញវិញ្ញាណឆ្លើយតប នឹងសិទ្ធិអំណាចរបស់ខ្ញុំ។ ខ្ញុំហាក់ភាន់ច្រឡំ ហើយចាប់ផ្ដើមចង់ទូលសួរព្រះអ ម្ចាស់ពីអ្វីដែលត្រូវធ្វើ។ ទោះបីជាខ្ញុំមិនទាន់មានសេរីភាពទាំងស្រុងក៏ដោយ ប៉ុន្តែខ្ញុំ លែងមានភាពភ័យស្លន់ស្លោ ហើយភាពខ្វិនផ្សេងៗក៏បានបាត់ទៅអស់ហើយ។ ដូច្នេះខ្ញុំមានជ័យជម្នះមួយចំនួនរួចទៅហើយ។ ខ្ញុំនៅតែតយុទ្ធជាមួយជំងឺធ្លាក់ទឹក ចិត្ត និងគំនិតអាក្រក់ផ្សេងៗ ប៉ុន្តែខ្ញុំមានទំនុកចិត្តថាខ្ញុំនឹងខ្លាំងជាងមុន។ ខ្ញុំ ចំណាយពេលជារៀងរាល់ថ្ងៃរំឭកពីអ្វីដែលព្រះគម្ពីរចែង និងសិទ្ធិអំណាចរបស់ខ្ញុំ នៅក្នុងអង្គព្រះគ្រិស្ដ។

នៅរសៀលមួយ ខ្ញុំកំពុងតែតយុទ្ធជាមួយអារម្មណ៍នៃភាពភ័យខ្លាចស្រដៀង នឹងពេលមុនដែរ ខណៈកំពុងធ្វើការនៅក្នុងការិយាល័យ។ ខ្ញុំបានព្យាយាមអធិស្ឋាន និងបញ្ជាវិញ្ញាណនៃភាពភ័យខ្លាចឲ្យចេញ ប៉ុន្តែដូចសព្វដង វាគ្មានឥទ្ធិពលឡើយ។ ភ្លាមនោះ ខ្ញុំបានឮព្រះសូរសៀងរបស់ព្រះអម្ចាស់។ ទ្រង់បានប្រាប់ខ្ញុំឲ្យបញ្ជា វិញ្ញាណឲ្យចេញ ហើយនិយាយឲ្យឮៗ និងជាមួយសិទ្ធិអំណាច។ បន្ទាប់មកទ្រង់ មានបន្ទូលពីអ្វីមួយមកកាន់ខ្ញុំ ដែលបានផ្លាស់ប្ដូរទស្សនៈរបស់ខ្ញុំចំពោះសិទ្ធិ អំណាចខាងវិញ្ញាណ។ ទ្រង់មានបន្ទូលថា កុំយកចិត្តទុកដាក់នឹងអារម្មណ៍របស់ខ្ញុំ នៅពេលដែលខ្ញុំបញ្ជាឲ្យវាចេញ ប៉ុន្តែឈរមាំជាមួយព្រះបន្ទូលរបស់ទ្រង់ ហើយមិន មែនដោយសារអ្វីដែលខ្ញុំមើលឃើញ ឬមានអារម្មណ៍នោះឡើយ។ ខ្ញុំកំពុងតែធ្វើការ នៅការិយាល័យរបស់ខ្ញុំ ដូច្នេះខ្ញុំមិនអាចគ្រាន់តែក្រោកឈរ ហើយស្រែកដាក់អារក្ស បាននោះទេ ព្រោះមានបុគ្គលិកផ្សេងៗនៅទីនោះដែរ។ ដូច្នេះ ខ្ញុំបានក្រោកឡើង ហើយដើរទៅបន្ទប់ទឹក រួចនិយាយយ៉ាងខ្លាំងថា «នៅក្នុងព្រះនាមព្រះយេស៊ូគ្រិស្ដ ខ្ញុំ

ចងឯង គឺវិញ្ញាណនៃភាពភ័យខ្លាច។ អ្វីដែលឯងកំពុងតែធ្វើគឺខុសហើយ ហើយយើងបញ្ជាឯងឲ្យចេញឥឡូវនេះ ក្នុងព្រះនាមព្រះយេស៊ូ។» គ្មានអ្វីកើតឡើងសោះ ខ្ញុំមានអារម្មណ៍ថាគ្មានអ្វីបានផ្លាស់ប្តូរសោះ។ ប៉ុន្តែខ្ញុំចាំពីអ្វីដែលព្រះអម្ចាស់មានបន្ទូលមកកាន់ខ្ញុំ «កុំយកចិត្តទុកដាក់នឹងអារម្មណរបស់ខ្ញុំ»។ អញ្ចឹង ខ្ញុំក៏បានអរព្រះគុណព្រះជាម្ចាស់ សម្រាប់សិទ្ធិអំណាចដែលទ្រង់ប្រទានឲ្យខ្ញុំលើវិញ្ញាណនេះ ហើយចាប់ផ្តើមសរសើរតម្កើងព្រះជាម្ចាស់ថាខ្ញុំមានសេរីភាព។ ខ្ញុំក៏ត្រលប់មកការិយាល័យរបស់ខ្ញុំវិញ ហើយចាប់ផ្តើមធ្វើការ។ ខណៈពេលដែលខ្ញុំអង្គុយនៅទីនោះ ទោះបីជាខ្ញុំមានអារម្មណ៍ថាគ្មានអ្វីផ្លាស់ប្តូរក៏ដោយ ខ្ញុំគ្រាន់តែអរព្រះគុណព្រះអង្គថា ខ្ញុំមានសេរីភាពគ្រប់ពេលដែលភាពភ័យខ្លាចថាវានឹងវាយប្រហារអារម្មណ៍របស់ខ្ញុំ។ ខណៈពេលដែលខ្ញុំកំពុងតែធ្វើការលើឯកសាររបស់អតិថិជន ភ្លាមនោះខ្ញុំមានអារម្មណ៍ពីព្រះវត្តមានរបស់ព្រះជាម្ចាស់មកសណ្ឋិតលើខ្ញុំ ហើយខ្ញុំបានឃើញពពកខ្មៅចេញពីខ្ញុំ រួចរសាត់បាត់ភ្លាមតាមជញ្ជាំងការិយាល័យ។

ខ្ញុំមានសេរីភាពហើយ!

វិញ្ញាណអារក្សនៃភាពភ័យខ្លាចនោះក៏បាត់ទៅ ហើយប្រសិនបើវាមកវិញ ខ្ញុំក៏ដឹងពីរបៀបត្រូវដោះស្រាយជាមួយវាដែរ។ ខ្ញុំពិតជារំភើបខ្លាំងណាស់! ខ្ញុំបានទូរស័ព្ទទៅកាន់ខ្រិនដា ហើយប្រាប់នាងពីអ្វីដែលបានកើតឡើង។ នាងបាននិយាយថា នាងនឹងមកដល់បន្តិចទៀត ហើយយើងនឹងអបអរដោយញ៉ាំបាយថ្ងៃត្រង់ជាមួយគ្នានៅក្នុងហាងម្ហូបចិនមួយ (ជាចំណូលចិត្តរបស់ខ្ញុំ)។ ខ្ញុំនឹងត្រូវបន្តឈរប្រឆាំងនឹងវិញ្ញាណនៃភាពភ័យខ្លាចនោះជាច្រើនដងបន្ទាប់ពីថ្ងៃនោះមក ដោយសារតែអារក្សវាមិនបោះបង់ភ្លាមៗទេ ហើយទោះបីជាវិញ្ញាណបានចេញទៅក៏ដោយ បញ្ហាហិរញ្ញវត្ថុរបស់ខ្ញុំក៏នៅតែដដែល។ ដូច្នេះ ភាពភ័យខ្លាចតែងតែព្យាយាមត្រលប់មកក្នុងចិត្តរបស់ខ្ញុំទាក់ទងនឹងហិរញ្ញវត្ថុរបស់ខ្ញុំ ហើយខ្ញុំត្រូវតែរៀនពីរបៀបដោះស្រាយជាមួយចិត្តគំនិតរបស់ខ្ញុំ និងរបៀបនៅជាប់ក្នុងសេចក្តីសុខសាន្ត។

មានការតយុទ្ធផ្សេងៗទៀត ដែលខ្ញុំត្រូវតយុទ្ធ និងរៀននៅក្នុងជីវិតរបស់ខ្ញុំមានមេរៀនខាងវិញ្ញាណជាច្រើនទៀតអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលខ្ញុំត្រូវរៀន

ប៉ុន្តែមូលហេតុដែលខ្ញុំចង់ប្រាប់រឿងនេះ គឺចង់ឲ្យលោកអ្នកដឹងថាខ្ញុំយល់ពីរបៀបដែលបញ្ហាហិរញ្ញវត្ថុជះឥទ្ធិពលលើមនុស្ស និងជីវិតរបស់ពួកគេ ហើយបើកឲ្យមានគំនិតអាក្រក់ផ្សេងៗចូលមក។

ខ្ញុំចង់បញ្ជាក់ថា លោកអ្នកដឹងថាខ្ញុំក៏ធ្លាប់បានឆ្លងកាត់វាដែរ។

ដូច្នេះមិនថាមានភាពរញ៉េរញ៉ៃបែបណាដែលលោកអ្នកកំពុងជួបប្រទះនោះទេ នៅថ្ងៃនេះគឺនៅមានសង្ឃឹម។ ជាការប្រសើរ ប្រសិនបើខ្ញុំបានបានស្គាល់ពីព្រះរាជ្យរបស់ព្រះជាម្ចាស់ច្បាស់ជាងនេះនៅក្នុងជីវិតរបស់ខ្ញុំ។ វាពិតជាគួរឲ្យស្ដាយណាស់ដែលឌ្រិនដានិងខ្ញុំបានរស់នៅក្នុងបញ្ហាហិរញ្ញវត្ថុអស់រយៈពេល៩ឆ្នាំ ដែលតាមការពិតយើងមិនគួរស្ថិតនៅក្នុងស្ថានភាពនោះសោះ!

ជាអកុសល ភាពរញ៉េរញ៉ៃខាងហិរញ្ញវត្ថុរបស់យើង មិនស្ថិតនៅលើខ្សែរពន្លឺនៃរ៉ាដាទេ ប៉ុន្តែវាជារ៉ាដាតែម្ដង។ នោះជារបៀបដែលយើងរស់នៅ។ រយៈពេល៩ឆ្នាំនោះពោរពេញទៅដោយការសុំគេដើម្បីបន្តរស់នៅ ការប្រមាថដែលយើងចាំមិនភ្លេច និងកាលៈទេសៈផ្សេងៗ។ មានព្រឹត្តិការណ៍ផ្សេងៗដែលខ្ញុំគួរតែបំភ្លេចចោល។ សូមអរគុណដល់ភរិយារបស់ខ្ញុំ! នាងបានស៊ូទ្រាំខ្លាំងណាស់ក្នុងរយៈពេលប៉ុន្មានឆ្នាំនោះ។ នេះជាមូលហេតុដែលខ្ញុំព្យាយាមផ្ដល់អ្វីគ្រប់យ៉ាងដែលខ្ញុំអាចធ្វើបានដល់នាង។

ដូចជាអ្វីដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំពីរបៀបដោះស្រាយជាមួយវិញ្ញាណនៃភាពភ័យខ្លាច ទ្រង់ក៏ចាប់ផ្ដើមបង្រៀនខ្ញុំពីរបៀបដោះស្រាយជាមួយនឹងហិរញ្ញវត្ថុរបស់ខ្ញុំដោយប្រើទស្សនៈខាងវិញ្ញាណ។ អ្វីដែលព្រះជាម្ចាស់បានបង្រៀនឌ្រិនដានិងខ្ញុំ ហើយនិងអ្វីដែលទ្រង់បានបង្ហាញមកកាន់យើងទាក់ទងនឹងហិរញ្ញវត្ថុរបស់យើងគឺជាជីវិតដែលផ្លាស់ប្ដូរនិងរំភើបជាខ្លាំង ដែលយើងត្រូវចំណាយពេញមួយជីវិតជួយដល់មនុស្សឲ្យរកឃើញគោលការណ៍ដូចគ្នានេះ។

ឌ្រិនដានិងខ្ញុំបានងើបឡើងពីភាពក្រីក្រតោកយ៉ាក និងអស់សង្ឃឹម រហូតដល់មានលទ្ធភាពទិញឡានដោយប្រាក់សុទ្ធ សង់ផ្ទះនៅក្នុងក្ដីស្រមៃដោយមិនជាប់បំណុល ចាប់ផ្ដើមក្រុមហ៊ុនមួយចំនួន និងបើកកម្មវិធីទូរទស្សន៍ចាក់ផ្សាយជា

រៀងរាល់ថ្ងៃមួយឈ្មោះថា Fixing the Money Thing ក្នុងគ្រប់ល្វែងម៉ោងទាំងអស់នៅលើផែនដីនេះ។ ឌ្រិនដាក៏មានកម្មវិធីទូរទស្សន៍ចាក់ផ្សាយប្រចាំសប្តាហ៍ដែលមានឈ្មោះថា Drenda នៅលើប៉ុស្តិ៍ ABC Family ដើម្បីជួយដល់ក្រុមគ្រួសារមួយចំនួនឲ្យដឹងពីរបៀបរស់នៅ និងលើកទឹកចិត្តដល់ស្ត្រីៗ។ យើងមានអារម្មណ៍ថា ព្រះជាម្ចាស់ដឹកនាំយើងឲ្យចាប់ផ្តើមក្រុមជំនុំ Faith Life Church ជាកន្លែងដែលយើងបង្រៀនមនុស្សរាប់ពាន់នាក់ពីព្រះរាជ្យរបស់ព្រះជាម្ចាស់រៀងរាល់សប្តាហ៍។ ឥឡូវនេះ យើងត្រូវចំណាយប្រាក់រាប់លានដុល្លារក្នុងមួយឆ្នាំ ដើម្បីធ្វើអ្វីដែលយើងកំពុងតែធ្វើនេះ និងជាង ២០០,០០០ដុល្លារក្នុងមួយខែ សម្រាប់កម្មវិធីទូរទស្សន៍ ក៏ដូចជាការសរសេរនេះ។ ពិតណាស់ អ្វីៗទាំងអស់នេះនឹងមិនអាចទៅរួចទេប្រសិនបើព្រះជាម្ចាស់មិនបានបង្រៀនយើងពីអ្វីយើងចង់បង្រៀនលោកអ្នក នៅក្នុងសៀវភៅជាស៊េរីមួយនេះ។ ខ្ញុំមិនចង់ឲ្យអ្នកគ្រាន់តែមើលមកកាន់សៀវភៅនេះ ដូចសៀវភៅហិរញ្ញវត្ថុផ្សេងទៀតនោះទេ។ វាមិនមែនជាសៀវភៅបង្រៀនលោកអ្នកពីរបៀបរៀបគម្រោងថវិកា ទោះបីជាការរៀបគម្រោងថវិកាចាំបាច់ ហើយយើងសូមលើកទឹកចិត្តលោកអ្នកឲ្យធ្វើបែបនេះក៏ដោយ។ វាមិនមែនជាការយកសៀវភៅដែលបង្រៀនឲ្យចាយត្បិតត្បៀត និងប្រយ័ត្នប្រយែងដែលដាក់លក់នៅលើទីផ្សារមកសរសេរសាឡើងវិញនោះទេ។

អត់ទេ នេះជាសៀវភៅស្តីពីបដិវត្តន៍មួយ ជាបដិវត្តន៍ប្រឆាំងនឹងអាណាចក្រខ្មៅងងឹត និងប្រឆាំងនឹងភាពក្រីក្រ។ វាជាសៀវភៅអំពីការបោះចោលការគ្រប់គ្រងរបស់រដ្ឋាភិបាលដែលពុករលួយ និងការចាប់យករបៀបរស់នៅថ្មី។ ចម្លើយរបស់ខ្ញុំគឺមិនជាដំបូន្មានខាងហិរញ្ញវត្ថុទូទៅទេ។ ខ្ញុំបានដឹងថា ខ្ញុំត្រូវការការងើបឡើងវិញនៃហិរញ្ញវត្ថុរបស់ខ្ញុំទាំងស្រុងគឺ៖

# បដិវត្តន៍ហិរញ្ញវត្ថុ!

# ជំពូកទី១

# ព្រះរាជ្យរបស់ព្រះជាម្ចាស់

ខ្ញុំបានជម្រាបប្រាប់លោកអ្នករួចមកហើយ នៅក្នុងសេចក្ដីលំនាំពីរបៀបដែលជីវិតរបស់ខ្ញុំបានយាយីដោយភាពភ័យខ្លាច។ ដូច្នេះ ខ្ញុំជឿថាជាការសំខាន់ដែលយើងចាប់ផ្ដើមការធ្វើដំណើររួមគ្នានេះដោយសេចក្ដីប្រកាសដែលលោកអ្នកពិតជាចាំបាច់យល់នេះថា៖ **ចូរកុំរៀនរស់នៅដោយភាពភ័យខ្លាច**! ភាពភ័យខ្លាចបើកទ្វារសម្រាប់ឥទ្ធិពលគ្រប់បែបយ៉ាងរបស់អារក្ស រួមមានទាំងការច្របូកច្របល់ និងការគាបសង្កត់របស់ពួកវា ដូចដែលយើងបានឃើញពីអ្វីដែលបានកើតឡើងនៅក្នុងជីវិតរបស់ខ្ញុំ និងជីវិតរបស់មនុស្សរាប់លាននាក់ផ្សេងទៀត។ ខ្ញុំជឿជាក់ថាភាពបាក់ស្បាតខាងផ្នែកថវិកា ជាកត្តាចម្បងដែលបើកទ្វារសម្រាប់ភាពភ័យខ្លាចនៅក្នុងជីវិតរបស់មនុស្ស។ រូបខ្ញុំផ្ទាល់បានជួយដល់មនុស្សជាច្រើននៅលើផ្នែកថវិកាជាង ៣៤ឆ្នាំមកហើយ តាមរយៈក្រុមហ៊ុនរៀបចំផែនការថវិការបស់ខ្ញុំ ហើយខ្ញុំបានរកឃើញថា ខ្ញុំមិនមែនជាមនុស្សតែម្នាក់ដែលធ្លាប់បានតយុទ្ធនឹងបញ្ហាខាងផ្នែកថវិកានៅក្នុងជីវិតរបស់ខ្លួនឡើយ។

តាមការពិត ដោយផ្អែកលើការសិក្សាស្រាវជ្រាវរបស់ខ្ញុំ ខ្ញុំបានរកឃើញថាប្រជាជនអាមេរិកប្រមាណ២៣% មិនបានទាំងសងបំណុលអប្បបរមានៃបំណុល

ដែលពួកគេត្រូវសង ហើយកំពុងតែរអិលធ្លាក់ទៅក្នុងវិនាសកម្មខាងផ្នែកថវិកា។[1] ចំនួននេះស្មើនឹងមួយភាគបួននៃប្រជាជនសរុបនៅក្នុងប្រទេស! ប្រជាជនអាមេរិក ៤៧ លាននាក់ដែលស្មើនឹង ១ ភាគ ៦ នៃប្រជាជនសរុបកំពុងទទួលអាហារបរិភោគ តាមរយៈជំនួយគូប៉ុងអាហាររបស់រដ្ឋ ហើយក្នុងចំណោមក្រុមគ្រួសារ១០ មាន៨ រក ប្រាក់ចំណូលបានត្រឹមតែដើម្បីរស់ប៉ុណ្ណោះ។[2] ខ្ញុំក៏មិនបានរៀបរាប់ពីបំណុលចំនួន ១៨ ទ្រីលាន[3]ដុល្លារដែលប្រទេសយើងជំពាក់គេ ហើយសងគេមិនចេះអស់មិនចេះ ហើយ ព្រមទាំងបំណុលផ្សេងៗដែលស្មើនឹងទឹកប្រាក់ជាង ១២០ទ្រីលានដុល្លារ ដែលប្រទេសយើងបានបង្កើតឡើងដោយពុំមានយន្តការផ្នែកហិរញ្ញវត្ថុច្បាស់លាស់ ដើម្បីទូទាត់នៅលើថ្លៃចំណាយផ្សេងៗឡើយ។[4] យើងរស់នៅក្នុងប្រទេសមួយដែល មានបញ្ហាហិរញ្ញវត្ថុធ្ងន់ធ្ងរជាច្រើន! អ្វីដែលខ្ញុំបានរកឃើញនៅក្នុងជីវិតរបស់ខ្ញុំគឺថា បញ្ហាថវិកាដែលមិនបានដោះស្រាយ និងភាពតានតឹង (ស្រ្តេស) ខាងផ្នែកថវិកានាំ ឲ្យមនុស្សចាត់ទុកភាពភ័យខ្លាចជារបៀបរស់នៅមួយរបស់ខ្លួន។

ប៉ុន្តែ មានដំណោះស្រាយសម្រាប់បញ្ហានេះ! លោកអ្នកអាចមានសេរីភាព បាន! ព្រះគម្ពីរចែងយ៉ាងច្បាស់ពីប្រធានបទនេះ៖ ព្រះយេស៊ូបានយាងមកប្រកាស ដំណឹងល្អទៅកាន់ជនក្រីក្រ!

---

[1] Tracy Turner, "Debt Is People's Biggest Worry…Finance Problems Rank Higher Than Terrorism and Disasters." *The Columbus Dispatch, 2006.*

[2] Brad Plumer, "*Why are 47 million Americans on food stamps? It's the recession — mostly.*" *The Washington Post, 2013.*

[3] មួយទ្រីលានស្មើនឹង ១ លាន ១លានដង។

[4] Glenn Kessler, "Does the Nation have 128 Trillion in Unfunded Liabilities." *Washington Post, 2013.*

*ព្រះវិញ្ញាណនៃព្រះអម្ចាស់យេហូវ៉ា ទ្រង់សណ្ឋិតលើខ្ញុំ ពីព្រោះព្រះយេហូវ៉ាទ្រង់បានចាក់ប្រេងតាំងខ្ញុំឲ្យផ្សាយដំណឹងល្អដល់មនុស្សទាល់ក្រ។*

- អេសាយ ៦១៖១ (ព្រះគម្ពីរបរិសុទ្ធ)

តើអ្វីទៅជាដំណឹងល្អដល់មនុស្សទាល់ក្រ? គឺដំណឹងដែលថាគាត់អាចមានសេរីភាពបាន! នៅថ្ងៃនេះ លោកអ្នកប្រហែលជាមិនដឹងសោះថាការនេះនឹងកើតឡើងដោយរបៀបណា។ មានពេលម្តងនៅក្នុងជីវិតរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍ថាគ្មានជំនួយទាំងស្រុង។ ខ្ញុំមានអារម្មណ៍ចម្លែកណាស់ពេលដែលគិតថា ខ្ញុំមានលុយ ១០០ដុល្លារដែលជាលុយរបស់ខ្ញុំ មិនជំពាក់នរណាម្នាក់ ហើយប្រសិនបើរឿងនោះមិនគួរឲ្យតក់ស្លុត ឬក្រៀមក្រំទេ ខ្ញុំពិតជាសើចពេលគិតដល់រឿងនោះមិនខាន។ នៅក្នុងពេលប្រាំបួនឆ្នាំដែលខ្ញុំរស់នៅក្នុងជីវភាពត្រឹមតែឲ្យបានរស់ពីមួយថ្ងៃទៅមួយថ្ងៃ បានប៉ះពាល់ដល់អារម្មណ៍របស់ខ្ញុំជាខ្លាំង។ ភាពតានតឹងខាងផ្នែកថវិកាបានរារាំងយើងមិនឲ្យទទួលបានអ្វីៗដែលល្អ។ នៅពេលដែលខ្ញុំមើលទៅកាន់ស្ថានភាពក្នុងក្រុមគ្រួសារខ្ញុំនាពេលប៉ុន្មានឆ្នាំនោះ ខ្ញុំពិតជាអាម៉ាស់ណាស់។ ខ្ញុំតែងតែបើកទ្វារចុះពីឡាន ហើយកូនៗដ៏គួរឲ្យស្រឡាញ់របស់ខ្ញុំរត់មករកខ្ញុំបន្ទាប់ពីបានចំណាយពេលជាច្រើនម៉ោងធ្វើការនៅការិយាល័យ។ ពួកគេតែងរត់មកឱបជើងខ្ញុំយ៉ាងជាប់ ហើយនិយាយថា «ប៉ាៗ!» នៅពេលនោះ ខ្ញុំមិនបានទាំងឆ្លើយ ឬមើលទៅកាន់ពួកគេផង។ ខ្ញុំពិតជាតប់ប្រមល់និងបាក់ទឹកចិត្តជាខ្លាំង រហូតដល់ខ្ញុំមិនបានចាប់អារម្មណ៍លើអ្វីដែលសំខាន់សម្រាប់ជីវិតខ្ញុំផង។

**វិញ្ញាណនៃព្រះអម្ចាស់យេហូវ៉ា ទ្រង់សណ្ឋិតលើខ្ញុំ ពីព្រោះព្រះយេហូវ៉ាទ្រង់បានចាក់ប្រេងតាំងខ្ញុំឲ្យផ្សាយដំណឹងល្អដល់មនុស្សទាល់ក្រ។**

**- អេសាយ ៦១៖១**

នៅពេលនោះ ផ្នត់គំនិតរបស់ខ្ញុំបានរំឭកខ្ញុំពីអ្វីម្យ៉ាងដែលខ្ញុំបានរៀនកាលនៅពេលរៀនហែលទឹក។ ប្រសិនបើមានមនុស្សលង់ទឹក ហើយស្រែកឲ្យលោកអ្នកជួយ ចូរប្រយ័ត្នប្រសិនបើលោកអ្នកចុះទៅជួយគាត់។ ហេតុអ្វីទៅ? ដោយសារតែគាត់ស្លុតស្មារតី ហើយចង់រស់ពេក រហូតដល់គាត់ចាប់ទាញលោកអ្នកទៅក្រោមទឹកទាំងអចេតនា។ នោះឯងគឺជាចិត្តគំនិតរបស់ខ្ញុំ គឺដូចជាមនុស្សរុក្ខជាតិដែលគ្មានវិញ្ញាណ គ្មានជីវិតកំពុងតែឆ្លងកាត់ស្ថានភាពប្រចាំថ្ងៃទាំងគ្មានអារម្មណ៍អ្វីបន្តិចសោះ។ ក្នុងនាមជាស្វាមី ខ្ញុំបានបរាជ័យលើការល្បងល។ ក្នុងនាមជាឪពុក ខ្ញុំក៏បានបរាជ័យលើការល្បងលដែរ។ ក្នុងនាមជាអ្នកផ្គត់ផ្គង់ក្រុមគ្រួសារ ខ្ញុំបានបរាជ័យលើការល្បងលង។ ជីវិតរបស់ខ្ញុំគឺគ្រាន់តែមាននូវទម្លាប់នៃជីវិតដែលគ្មានអារម្មណ៍ គ្មានក្តីស្រមៃ និងមានតែការខូចចិត្ត។

ទីក្រុងកូឡុំបឹស រដ្ឋអូហៃយ៉ូនៅសម័យនោះគឺមានការកើនឡើងជាខ្លាំងនៃតម្លៃអចលនទ្រព្យ។ នៅគ្រប់តំបន់ តម្លៃផ្ទះបានឡើងថ្លៃជាលំដាប់ ហើយដោយសារហេតុនេះហើយ ទីក្រុងដែលយើងរស់នៅបានក្លាយជាកន្លែងតាំងពិពណ៌លំនៅស្ថានជាច្រើនឆ្នាំជាប់ៗគ្នា។ ប្រសិនបើលោកអ្នកមិនប្រាកដថាការតាំងពិពណ៌នេះជាអ្វី សូមអនុញ្ញាតឲ្យខ្ញុំធ្វើការពន្យល់សិន។ ការតាំងពិពណ៌លំនៅស្ថានជាការតាំងបង្ហាញនូវផ្ទះគំរូៗជាច្រើនផ្សេងៗគ្នា ដែលក្រុមហ៊ុនអភិវឌ្ឍន៍លំនៅស្ថានសង់ដើម្បីបង្ហាញពីរចនាបថ និងសមត្ថភាពដ៏ពិសេស ក៏ដូចជាគ្រឿងប្រើប្រាស់ក្នុងផ្ទះ និងគ្រឿងសង្ហារឹមសម្រេចរបស់ពួកគេ។ សម្រាប់មនុស្សគ្រប់ៗគ្នានៅក្នុងតំបន់នោះ ព្រឹត្តិការណ៍នេះពិតជាសំខាន់ណាស់ ហើយមានមនុស្សរាប់ពាន់នាក់បានចូលរួម និងរីករាយដែរ។ ប៉ុន្តែ ខ្ញុំខ្លាចការតាំងពិពណ៌លំនៅស្ថានណាស់។ ដោយរស់នៅក្នុងជីវភាពក្រីក្រ ខ្ញុំមិនចង់ឲ្យឌ្រិនដាទៅចូលរួម និងមើលផ្ទះទាំងនោះឡើយ។ ខ្ញុំមានអារម្មណ៍មិនសប្បាយចិត្តទាល់តែសោះអំពីការបរាជ័យខាងផ្នែកថវិកាដែលខ្ញុំមាន ហើយខ្ញុំពិតជាមិនចង់ឲ្យប្រពន្ធរបស់ខ្ញុំមានអារម្មណ៍មិនល្អដែរ។ នៅពេលនេះទើបខ្ញុំដឹងថា ទស្សនៈរបស់ខ្ញុំពេលនោះជាការឆោតល្ងង់មែនទែន ប៉ុន្តែនិយាយឲ្យត្រង់ខ្ញុំ

ពិតជាបានគិតបែបនោះមែន។ ខ្ញុំគិតថា ប្រសិនបើនាងទៅចូលរួមព្រឹត្តិការណ៍នោះ នាងប្រាកដជាចង់បានផ្ទះថ្មីមួយមិនខាន។ ដូច្នេះពីមួយឆ្នាំទៅមួយឆ្នាំ ខ្ញុំនិយាយថា «ទេ!» ប៉ុន្តែជាចុងក្រោយ ខ្ញុំក៏សុខចិត្ត និងសម្រេចចិត្តថាទៅជាមួយនាង។

ដូចដែលលោកអ្នកអាចស្រមៃដល់ ផ្ទះនានានៅក្នុងពិពណ៌លំនៅស្ថានពិតជាស្អាតខ្លាំងណាស់។ បើប្រៀបធៀបទៅនឹងផ្ទះកសិដ្ឋានដែលយើងរស់នៅវិញ វាធ្វើឲ្យផ្ទះរបស់យើងដែលសង់នៅឆ្នាំ១៨០០ ប្រៀបបាននឹងកូនខ្ទមដែលដល់ពេលត្រូវកម្ទេចចោលអញ្ចឹង។ បន្ទាប់ពីយើងបានដើរមើលផ្ទះពីរបីដំបូង ហើយនៅពេលដែលយើងកំពុងដើរតាមខឿនផ្លូវ ស្រាប់តែខ្ញុំបាត់ឌ្រីនដា។ ខ្ញុំក៏ងាកទៅរកមើលនាង ហើយក៏មិនសប្បាយចិត្តនៅពេលដែលឃើញនាងឈរនៅខាងមុខផ្ទះដែលយើងទើបនឹងដើរចេញមក។ មានទឹកភ្នែកហូរជោកជន់នៅលើមុខរបស់នាង។ ខ្ញុំក៏បានដើរទៅរកនាងវិញ ហើយសួរសំណួរដ៏ឆោតល្ងង់ថា «តើមានរឿងអីហ្នឹង?» គឺប្រៀបបាននឹងខ្ញុំមិនដឹងថាមានរឿងអីអញ្ចឹង។ នាងបានមើលមកខ្ញុំហើយសួរថា «តើពេលណាទើបយើងមានផ្ទះមួយខ្ទងនៅ?» ក្នុងចិត្តខ្ញុំគិតថា «ផ្ទះមួយខ្ទង? ដូចផ្ទះម៉ូតនេះឬ? ផ្ទះទាំងនេះតម្លៃពី៥០ម៉ឺនដុល្លារទៅ៧០ម៉ឺនដុល្លារ។» ខ្ញុំនៅតែត្រដេបត្រដបក្នុងការរកវិធីបង់ថ្លៃឈ្នួលផ្ទះ៣០០ដុល្លារជារៀងរាល់ខែ នៅលើផ្ទះកសិដ្ឋានចាស់នោះ។ ខ្ញុំដឹងថានេះជារឿងដ៏ក្រៀមក្រំ ប៉ុន្តែខ្ញុំមើលមិនឃើញច្រកចេញពីជីវិតបែបនេះឡើយ ហើយខ្ញុំពុំបានផ្តល់ក្តីសង្ឃឹមអ្វីសោះទៅកាន់ភរិយាដ៏ពិសេស និងជាទីស្រឡាញ់របស់ខ្ញុំដែរ។ ភាពភ័យខ្លាច និងបរាជ័យបានរួបរឹតចិត្តគំនិត និងទស្សនៈរបស់ខ្ញុំ។ នេះប្រាកដជាមិនមែនជាខ្ញុំទេ! តើមានអ្វីកើតឡើងចំពោះអំណរ និងសុភមង្គលរបស់ខ្ញុំ? ខ្ញុំហាក់ដូចជាមិនអាចឆ្លងផុតភាពតប់ប្រមល់ផ្នែកថវិកាសោះ។

មានពេលមួយ គឺនៅម៉ោង២ឬ៣ទៀបភ្លឺ ខ្ញុំគេងមិនលក់សោះ។ ខ្ញុំឈឺថ្គាម និងមុខជាខ្លាំង ដូចគេយកម្ជុលមកចាក់ខ្ញុំអញ្ចឹង។ ខ្ញុំពិតជាឈឺខ្លាំងណាស់។ រយៈពេល៣៦ម៉ោងមុននេះ ធ្មេញរបស់ខ្ញុំត្រូវបានត្បារសសៃចេញដើម្បីបញ្ឈប់ដំបៅក្លាយដែលធ្វើឲ្យមុខខ្ញុំហើមដូចគេផ្លុំ។ វាពិតជាឈឺចាប់ និងនៅមិនសុខទាល់តែ

សោះ។ ខ្ញុំបានលេបថ្នាំទីលេណុលបួនម៉ោងម្តងដើម្បីបន្ថយការឈឺចាប់ ប៉ុន្តែហាក់ដូចជាមិនបានធូរស្បើយឡើយ។ នៅពេលកំពុងអង្គុយនៅក្នុងបន្ទប់ទទួលភ្ញៀវទាំងគេងមិនលក់ ហើយទើបលេបថ្នាំបំបាត់ការឈឺចាប់ទៀត ខ្ញុំស្រាប់តែក្រលេកមើលប្រអប់ថ្នាំទីលេណុល រួចអានសេចក្តីណែនាំ។ ខ្ញុំអានមិនមែនដោយសារតែខ្ញុំមិនដឹងពីរបៀបប្រើប្រាស់ថ្នាំទីលេណុលទេ ប៉ុន្តែគឺដោយសារអផ្សុកពេក គឺដូចជាយើងមើល និងអានសំបកដបទឹកម្ទេស នៅពេលញ៉ាំគុយទាវពេលព្រឹកអញ្ចឹង។ វាមិនមែនដោយសារតែយើងចាប់អារម្មណ៍ទេ ប៉ុន្តែដោយសារតែដបហ្នឹងនៅចំពោះមុខយើង។ មែនហើយ គឺលេប២គ្រាប់នៅរាល់៤ម៉ោងម្តង ប៉ុន្តែតើសេចក្តីណែនាំនោះប្រាប់ថាយ៉ាងម៉េចទៀត? គឺហាមលេបលើសពី១០គ្រាប់នៅក្នុងពេល២៤ម៉ោង? នៅក្នុងចិត្តខ្ញុំស្រាប់តែបូកចំនួនថ្នាំដែលមនុស្សម្នាក់បានលេបអស់ប្រសិនបើគាត់លេបវារៀងរាល់៤ម៉ោងម្តង គឺដូចដែលខ្ញុំបានធ្វើនៅក្នុងពេល២ថ្ងៃកន្លងមកនេះ ហើយចម្លើយគឺ១២គ្រាប់ក្នុងមួយថ្ងៃ ដែលមានន័យថាលើសពីចំនួនអតិប្បរមា២គ្រាប់ហើយ។ ភ្លាមៗនោះភាពភ័យខ្លាចបានរួបរឹតខ្ញុំភ្លាម។

នៅក្នុងពេលប្រាំបួនឆ្នាំដែលខ្ញុំបានរស់នៅត្រឹមតែចម្អែតក្រពះ ទាំងបរាជ័យក្នុងនាមជាស្វាមី បរាជ័យក្នុងនាមជាឪពុក និងបរាជ័យក្នុងនាមជាអ្នកផ្គត់ផ្គង់បានធ្វើឲ្យខ្ញុំមានភាពប៉ះទង្គិចខាងផ្លូវអារម្មណ៍។ គ្រូពេទ្យបានឲ្យខ្ញុំលេបថ្នាំបន្ថយទុក្ខព្រួយដើម្បីសាកល្បង និងជួយដល់ខ្ញុំ។ ប៉ុន្តែ ពុំមានអ្វីអាចជួយដល់ខ្ញុំបានឡើយ។ នៅពេលដែលខ្ញុំអង្គុយនៅទីនោះនាពេលយប់នោះ ទាំងមានដំបៅនៅលើធ្មេញ ខ្ញុំមិនបានគេងពីរថ្ងៃមកហើយ ហើយការឈឺចាប់ក៏ខ្លាំងមែនទែនរហូតដល់ខ្ញុំគេងមិនលក់ម្តងទៀត។ នៅពេលដែលខ្ញុំបានអានសំបកថ្នាំទីលេណុល ខ្ញុំបានយល់ថាខ្ញុំមានរឿងមួយទៀតដែលត្រូវខ្វល់ខ្វាយ គឺការលេបថ្នាំទីលេណុលច្រើនលើសកម្រិត។ ខ្ញុំមិនបានដឹងសោះថា ការលេបថ្នាំទីលេណុលច្រើនជ្រុល អាចនឹងនាំឲ្យខ្ញុំមានបញ្ហាអ្វីនោះទេ ប៉ុន្តែខ្ញុំប្រាកដថាវាមិនមានគ្រោះថ្នាក់ទេ ដោយហេតុថានរណាក៏អាចទិញថ្នាំនេះនៅឯឱសថស្ថានបានដែរ។ ខ្ញុំបានស្វែងយល់ថា គេចាំបាច់ត្រូវ

ដាក់សេចក្ដីជាស់តឿននៅលើប្រអប់ថ្នាំបែបនេះ ដើម្បីធ្វើឲ្យមេធាវីរបស់គេស្ងប់ចិត្ត និងបំពេញតាមច្បាប់តម្រូវប៉ុណ្ណោះ។ ខ្ញុំមិនជឿថា ការលេបថ្នាំពីរគ្រាប់ជ្រុលអាចបណ្ដាលឲ្យមានបញ្ហាធំដុំបានឡើយ។ ប៉ុន្តែវិញ្ញាណនៃភាពភ័យខ្លាចបានរួបរឹតនៅលើចិត្តគំនិតរបស់ខ្ញុំ។ វាបានយកការពិតនោះ ហើយចាប់ផ្ដើមគប់គំនិតដែលថា «ចុះប្រសិនបើ» មកលើខ្ញុំ។ ដូច្នេះ ដើម្បីឲ្យខ្ញុំបានធូរចិត្ត ខ្ញុំបានគិតថានឹងទូរស័ព្ទទៅកាន់មណ្ឌលគ្រប់គ្រងជាតិពុល ដើម្បីបញ្ជាក់ឲ្យច្បាស់។ ខ្ញុំប្រាកដថា ពួកគេនឹងគ្រាន់តែនិយាយថា នោះមិនមានបញ្ហាធំដុំអ្វីទេ។

ស្ត្រីដែលបានទទួលទូរស័ព្ទបាននិយាយហាក់ដូចជានាងជាអ្នកជំនាញ។ នាងបានសួរខ្ញុំថា តើអាចឲ្យនាងជួយខ្ញុំដោយរបៀបណា ហើយខ្ញុំបានពន្យល់ប្រាប់នាងថាខ្ញុំបានលេបថ្នាំទីលេណុលនៅរាល់ ៤ ម៉ោងម្ដង សម្រាប់រយៈពេល ៣៦ ម៉ោងកន្លងមកនេះ។ ហេតុនេះហើយ ជំនួសឲ្យលេបថ្នាំ ១០ គ្រាប់ក្នុងមួយថ្ងៃ ដែលនៅលើប្រអប់ថ្នាំបានណែនាំថាកុំឲ្យលើសពីនោះ ខ្ញុំបានលេបដល់ទៅ ១២ គ្រាប់។ ខ្ញុំបានប្រាប់នាងថា ខ្ញុំទូរស័ព្ទមកនេះដើម្បីបញ្ជាក់ថា ការលេបថ្នាំ ២ គ្រាប់ច្រើនជាងនឹងមិនបណ្ដាលឲ្យមានបញ្ហាធ្ងន់ធ្ងរអ្វីទេ។ ខ្ញុំក៏ផ្អាកនិយាយសិន ហើយបានឮសំឡេងក្ដារចុចកុំព្យូទ័រ។ បន្ទាប់មក ខ្ញុំបានឮពាក្យទាំងនេះ ហើយខ្ញុំនឹកចាំមិនភ្លេចពីអ្វីដែលនាងបាននិយាយមកកាន់ខ្ញុំ «លោក យើងមិនធ្លាប់ឃើញនរណានៅរស់បន្ទាប់ពីបានលេបថ្នាំច្រើនអញ្ចឹងទេ។» តើខ្ញុំស្ដាប់នាងមិនច្រទ្បំទេឬ? ប្រាកដណាស់ គឺប្រាកដជាច្រឡំ! ដូច្នេះ ខ្ញុំបានពន្យល់ទៅកាន់នាងម្ដងទៀតថា ខ្ញុំគ្រាន់តែលេបថ្នាំពីរគ្រាប់ច្រើនជាងធម្មតានៅក្នុងពេល២៤ម៉ោងប៉ុណ្ណោះ ហើយខ្ញុំបានធ្វើបែបនេះអស់រយៈពេល២ថ្ងៃហើយ។

នៅលើកនេះ នាងបានឆ្លើយដោយសំឡេងម៉ឺងម៉ាត់ថា «លោក ដូចដែលខ្ញុំបានជម្រាបប្រាប់រួចមកហើយថា យើងមិនធ្លាប់ឃើញនរណានៅរស់បន្ទាប់ពីបានញ៉ាំថ្នាំច្រើនដល់ថ្នាក់ហ្នឹងទេ។ សូមលោកមកបន្ទប់សង្គ្រោះបន្ទាន់**ឥឡូវនេះ**!» នៅពេលដែលខ្ញុំប៉ុនប៉ងនឹងពន្យល់ទៅកាន់នាងម្ដងទៀតពីអ្វីដែលបានកើតឡើង

ដោយហេតុថាខ្ញុំច្បាស់ក្នុងចិត្តថានាងស្តាប់ច្រឡំ នាងបាននិយាយកាត់ខ្ញុំ ហើយថា «លោកអាចបើកឡានមកមន្ទីរពេទ្យខ្លួនឯងក៏បាន បើមិនអញ្ចឹងទេខ្ញុំឲ្យឡានសង្គ្រោះបន្ទាន់ទៅយកលោក។» ខ្ញុំពិតជាតក់ស្លុតណាស់! ខ្ញុំនិយាយរដិបរដុបថា «ខ្ញុំនឹងបើកឡានទៅខ្លួនឯង។» នាងសួរថា «តើលោកនឹងទៅមន្ទីរពេទ្យណា?» ខ្ញុំបានប្រាប់នាង ហើយនាងក៏ដាក់ទូរស័ព្ទចុះ។

ខ្ញុំបានឈរនៅទីនោះទាំងភាំងស្មារតី។ ខ្ញុំមានការប្រជុំដ៏សំខាន់មួយនៅម៉ោង ៩ព្រឹក ហើយពេលនោះគឺម៉ោង៣ទៀបភ្លឺហើយ។ ខ្ញុំបានដើរទាំងអូសជើងទៅកាន់បន្ទប់គេង ហើយដាស់ឌ្រិនដាទាំងប្រាប់នាងពីអ្វីដែលបានកើតឡើង។ នាងបានមើលមកកាន់ខ្ញុំទាំងទឹកមុខធុញផង អាណិតផង។ ស្វាមីរបស់នាងបានប្រព្រឹត្តចម្លែកៗក្នុងពេលពីរបីខែកន្លងមកនេះ ហើយនាងក៏ធុញទ្រាន់ក្នុងការជួយគ្រប់គ្រងស្ថានការណ៍ក្នុងផ្ទះដែរ។ នៅពេលនេះ រឿងនេះក៏កើតឡើងជាន់គ្នាទៀត? នាងនិយាយថា «ហ្គារីគឺលើសត្រឹមតែពីរគ្រាប់ប៉ុណ្ណោះ។ បងប្រាកដជាដឹងថា វាមិនអាចធ្វើឲ្យបងស្លាប់ទេ។ សូមទូរស័ព្ទទៅគេវិញទៅ»។ ប៉ុន្តែ ភាពភ័យខ្លាចបានកំពុងតែផ្តល់ហេតុផលមិនសមស្រប និងធ្វើទុក្ខបុកម្នេញខ្ញុំ «ស្ត្រីនោះនិយាយថា វាអាចនឹងសម្លាប់បងបាន។ បងចាំបាច់ត្រូវទៅមន្ទីរពេទ្យ»។ ខ្ញុំអាចមើលឃើញទឹកមុខថា «បងប្រាកដជាកំប្លែងលេងនឹងអូនមិនខាន» នៅលើកែវភ្នែកប្រពន្ធរបស់ខ្ញុំ នៅពេលដែលខ្ញុំងាកដើរចេញពីបន្ទប់គេង។

នៅពេលដែលខ្ញុំបើកឡានទៅដល់មន្ទីរពេទ្យ មានបុរសពីរនាក់ពាក់អាវធំពណ៌សកំពុងតែរង់ចាំខ្ញុំនៅមាត់ទ្វារបន្ទប់សង្គ្រោះបន្ទាន់។ នៅពេលដែលខ្ញុំចតឡាន ពួកគេក៏ដើរសំដៅមករកខ្ញុំ ហើយសួរថា «តើលោកឈ្មោះហ្គារី ឃីស៊ីមែនទេ?» ពួកគេបានប្រញាប់ប្រញាល់យកខ្ញុំទៅបន្ទប់ព្យាបាល។ នៅពេលដែលខ្ញុំដើរកាត់ក្តារខៀនឈ្មោះអ្នកជំងឺនៅបន្ទប់សង្គ្រោះបន្ទាន់ ខ្ញុំបានឃើញឈ្មោះខ្លួនឯងនៅលើក្តារនោះរួចទៅហើយ។ គេសរសេរថា «ហ្គារី ឃីស៊ី - លេបថ្នាំលើសកម្រិត»។ ខ្ញុំសឹងតែមិនជឿសោះ។ និយាយសង្ខេបឲ្យខ្លី នៅពេលដែលគ្រូពេទ្យជួសឈាមខ្ញុំ

គាត់បានដើរចូលមកក្នុងបន្ទប់ ហើយពោលថា «ហេតុអ្វីបានជាលោកមកទីនេះ? កម្រិតជាតិថ្នាំទីលេណុលដែលមាននៅក្នុងឈាមលោកមិនទាន់ខ្ពស់គ្រប់គ្រាន់ល្មមនឹងព្យាបាលការឈឺក្បាលបានផង។» នៅពេលដែលខ្ញុំបានប្រាប់គាត់ពីសាច់រឿងរបស់ខ្ញុំជាមួយនឹងមណ្ឌលគ្រប់គ្រងជាតិពុល គាត់ក៏ចាប់ផ្ដើមសើចកខឹក។ ខ្ញុំគិតថាមិនមានអ្វីគួរឲ្យអស់សំណើចទេ ហើយខ្ញុំក៏គិតថា វាគ្មានអ្វីកំប្លែងបន្តិចសោះ នៅពេលដែលវិក្កយបត្រទឹកប្រាក់ ២០០០ ដុល្លារបានមកដល់ផ្ទះខ្ញុំនៅពេលក្រោយមក។ អារក្សបានដាក់អន្ទាក់ខ្ញុំ ហើយលួចពីខ្ញុំម្ដងទៀតហើយ។

**ព្រះរបស់ខ្ញុំនឹងបំពេញសេចក្ដីត្រូវការគ្រប់យ៉ាងរបស់បងប្អូន ស្របតាមសិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះអង្គ ដោយរួមក្នុងអង្គព្រះគ្រិស្តយេស៊ូ។**

\- **ភីលីព ៤:១៩**

ខ្ញុំរៀបរាប់សាច់រឿងនេះប្រាប់ដល់លោកអ្នក ជាមួយនឹងសេចក្ដីលំនាំដើម្បីជួយលោកអ្នកឲ្យមើលឃើញថាជីវិតរបស់ខ្ញុំមានស្ថានភាពបែបណា នៅមុនពេលដែលខ្ញុំបានរកព្រះរាជ្យរបស់ព្រះជាម្ចាស់ឃើញ។ មែនហើយ ខ្ញុំជាគ្រិស្តបរិស័ទ។ មែនហើយ ខ្ញុំថ្វាយតង្វាយមួយភាគដប់។ មែនហើយ ខ្ញុំបានដឹកនាំថ្វាយបង្គំនៅក្នុងក្រុមជំនុំមួយរយៈដែរ។ មែនហើយ ខ្ញុំស្រឡាញ់ព្រះជាម្ចាស់។ ប៉ុន្តែមានបញ្ហាកើតឡើង គឺបញ្ហាធំណាស់! ខ្ញុំបានប្រាប់លោកអ្នកពីរបៀបដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំអំពីរបៀបតយុទ្ធនឹងវិញ្ញាណនៃភាពភ័យខ្លាច និងរបៀបដែលខ្ញុំមានសេរីភាពពីកាលៈ
ទេសៈនានាដែលបាននាំឲ្យខ្ញុំតយុទ្ធនឹងភាពភ័យខ្លាចកាលពីដើមដំបូង គឺស្ថានភាពថវិការបស់ខ្ញុំដែលគ្មានសង្ឃឹមទាល់តែសោះ! ខ្ញុំនៅតែមានសម្ពាធតានតឹងជារៀងរាល់ថ្ងៃក្នុងការរកប្រាក់ និងបង់ថ្លៃចំណាយផ្សេងៗ បន្ថែមលើប័ណ្ណឥណទានចំនួនដប់ដែលខ្ញុំមាន ត្រូវបានចាយអស់ទឹកប្រាក់ និងលុបចោល ជាប់ក្នុងកម្ចីពីក្រុមហ៊ុនហិរញ្ញវត្ថុចំនួនបី បំណុលពន្ធអាករ IRS លុយដែលខ្ញុំជំពាក់សាច់ញាតិ រួម

ទាំងសាលក្រម និងការដែលក្រុមហ៊ុនជាច្រើនមានសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិរបស់ខ្ញុំ។

ដូចដែលខ្ញុំបាននិយាយពីខាងដើម ជីវិតក្រុមគ្រួសារយើងមានភាពរញ៉េរញ៉ៃខ្លាំងមែនទែនខាងផ្នែកថវិកា។ ខ្ញុំបានរស់នៅដោយភាពថប់បារម្ភ និងភាពច្របូកច្របល់ផ្លូវចិត្ត។ ទោះបីជាខ្ញុំជាគ្រិស្តបរិស័ទ យើងអស់លុយរលីងពីខ្លួន ហើយខាងធនាគារក៏បិទប័ណ្ណឥណទានរបស់ខ្ញុំម្តងមួយៗ។ ពេលនោះ ទ្រព្យសម្បត្តិរបស់ខ្ញុំត្រូវគេដាក់ពាក្យកាន់កាប់ ឥណទានក៏ត្រូវបានដាក់ជាមោឃៈ ហើយម្ចាស់បំណុលក៏ទូរស័ព្ទមកខ្ញុំទៀត។ នៅក្នុងពេលដែលយើងជួបនឹងបញ្ហាដ៏លំបាកបំផុតខាងផ្នែកថវិកា អាជីវកម្មរបស់យើងក៏មិនបានរកប្រាក់ចំណូលច្រើន យើងមិនអាចមានលទ្ធភាពទិញម្ហូបអាហារបានឡើយ។ ក្រុមគ្រួសាររបស់ខ្ញុំតែងអង្គុយផ្ដុំគ្នានៅជុំវិញចង្ក្រានអុសក្នុងបន្ទប់ក្រុមគ្រួសារយើង ដើម្បីឲ្យមានភាពកក់ក្ដៅ ដោយសារយើងមិនមានលទ្ធភាពទិញប្រេងកាត។ យើងក៏តែងរកមើលនៅក្រោមកៅអី និងសាឡុងក្រែងលោឃើញកាក់ដែលបានជ្រុះតាមកន្លៀតៗ ដោយសង្ឃឹមថានឹងរកបានប្រាក់ល្មមគ្រប់គ្រាន់នឹងទិញអាហារកុមារនៅឯភោជនីយដ្ឋាន McDonald's[1] ដើម្បីឲ្យកូនៗយើងចែកគ្នាញ៉ាំ។

ខ្ញុំពូកែគួរសមក្នុងការប្រកែក ឬគេចពីម្ចាស់បំណុលនៅពេលដែលពួកគេទូរស័ព្ទមក ប៉ុន្តែមានថ្ងៃមួយម្ចាស់បំណុលរបស់ខ្ញុំម្នាក់បានជួលមេធាវីដើម្បីទារប្រាក់ពីខ្ញុំ។ បុរសម្នាក់នេះបានទូរស័ព្ទមកខ្ញុំ ហើយនិយាយគ្មានក្បាលគ្មានកន្ទុយសោះ។ គាត់គ្រាន់តែនិយាយថា «ខ្ញុំត្រូវការលុយនៅក្នុងពេលបីថ្ងៃ បើមិនដូច្នេះទេ ខ្ញុំនឹងដាក់ពាក្យប្ដឹងលើលោកជំនួសអតិថិជនរបស់ខ្ញុំហើយ។» ខ្ញុំគ្មានជម្រើសអ្វីផ្សេងឡើយ គឺចប់តែម្ដង។ ខ្ញុំគ្មានលុយដែលអាចប្រើបាននៅក្នុងប័ណ្ណឥណទានខ្ញុំបានពឹងពាក់មិត្តភក្តិអស់ហើយ មកដល់ចំណុចនេះខ្ញុំដឹងថាចប់ហើយ។ ខ្ញុំបានលូនទៅ

---

[1] McDonald ជាភោជនីយដ្ឋានអាហាររហ័សស្រាប់ ស្រដៀងទៅនឹង Lucky Burger ដែរ។

ក្នុងបន្ទប់គេង រួចទម្លាក់ខ្លួនទទឹងគ្រែ និងស្រែកទៅកាន់ព្រះជាម្ចាស់។ ភ្លាមៗនោះ ខ្ញុំបានឮព្រះសូរសៀងរបស់ព្រះអម្ចាស់។ អត្ថបទគម្ពីរមួយដែលខ្ញុំបានអានជាច្រើនលើកច្រើនសាបានលេចឡើងនៅក្នុងគំនិតខ្ញុំ។

*ព្រះរបស់ខ្ញុំនឹងបំពេញសេចក្ដីត្រូវការគ្រប់យ៉ាងរបស់បងប្អូន ស្របតាមសិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះអង្គ ដោយរួមក្នុងអង្គព្រះគ្រិស្តយេស៊ូ។*
ភីលីព ៤៖១៩

ខ្ញុំបានឆ្លើយតបទៅកាន់ព្រះអម្ចាស់ថា ខ្ញុំដឹងពីខគម្ពីរនោះប៉ុន្តែសេចក្ដីត្រូវការរបស់ខ្ញុំមិនត្រូវបានបំពេញទេ! ទ្រង់បានឆ្លើយសំណួរខ្ញុំភ្លាមៗថា «មែនហើយ ប៉ុន្តែនោះមិនមែនជាកំហុសរបស់យើងទេ។ កូនមិនដែលចំណាយពេលរៀនពីរបៀបដែលព្រះរាជ្យរបស់យើងដំណើរការទាល់តែសោះ។ តាមពិត ក្រុមជំនុំជាច្រើនរបស់យើងកំពុងតែរស់នៅដូចជាជនជាតិអ៊ីស្រាអែលក្នុងសម្ពន្ធមេត្រីចាស់ គឺរស់នៅជាខ្ញុំបម្រើ។ ពួកគេរស់នៅក្នុងបំណុល និងរស់នៅដោយជាប់ចំណងខាងផ្នែកថវិកា។ យើងចង់ឲ្យប្រជាជនរបស់យើងមានសេរីភាព។»

ខ្ញុំក៏បានរត់ចុះទៅជាន់ខាងក្រោម ហើយឱបឌ្រិនដា រួចប្រាប់នាងពីអ្វីដែលព្រះអម្ចាស់បានមានបន្ទូលមកកាន់ខ្ញុំភ្លាម។ ខ្ញុំបានកែប្រែចិត្តគំនិតនៅចំពោះមុខនាងពីការដែលមិនបានស្វែងរកព្រះជាម្ចាស់ និងរៀនពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើរការ។ តាមពិត នៅពេលនោះយើងពិតជាមិនបានដឹងថាព្រះជាម្ចាស់ចង់សំដៅលើអ្វី នៅពេលដែលទ្រង់មានបន្ទូលថា យើងមិនបានដឹងពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើរការ។ សំខាន់បំផុតនោះ យើងទៅចូលរួមនៅក្នុងក្រុមជំនុំទៀងទាត់ ថ្វាយតង្វាយមួយភាគដប់ពីប្រាក់ចំណូលរបស់យើងសឹងតែគ្រប់ពេលវេលា ហើយយើងស្រឡាញ់ព្រះជាម្ចាស់។ យើងស្មានថា យើងមានចិត្តគំនិតបែបព្រះរាជ្យរបស់ទ្រង់ហើយ។ ទោះជាយ៉ាងនេះក្ដី បញ្ហាដែលខ្ញុំបានរកឃើញគឺ បាទមែនហើយ ខ្ញុំនឹងបានទៅស្ថានសួគ៌មែន ប៉ុន្តែខ្ញុំមិនចេះពីរបៀបនាំយកនូវឫទ្ធានុភាព និងសិទ្ធិអំណាចនៃស្ថានសួគ៌ចូលមកកាន់ជីវិតរបស់ខ្ញុំ ហើយឲ្យវាប៉ះ

ពាល់ដល់កាលៈទេសៈធម្មជាតិរបស់ខ្ញុំឡើយ។ ដូច្នេះ យើងក៏បានចាប់ផ្ដើមសិក្សាព្រះគម្ពីរ ហើយព្រះជាម្ចាស់បានចាប់ផ្ដើមមានបន្ទូលមកកាន់យើង ហើយជួយឲ្យយើងរៀនពីអ្វីដែលទ្រង់សំដៅលើ នៅពេលដែលទ្រង់មានបន្ទូលថាព្រះរាជ្យ។ អ្វីដែលយើងបានរៀនគឺគួរឲ្យភ្ញាក់ផ្អើលណាស់! វាប្រៀបបាននឹងការដែលបើកភ្លើងភ្លឺចែសនៅក្នុងបន្ទប់ដ៏ងងឹតអញ្ចឹង។ នៅលើកដំបូងក្នុងឆាកជីវិតរបស់យើង យើងបានរកឃើញចម្លើយទាក់ទងនឹងជីវិតខាងផ្នែកថវិកាដែលយើងបានជួបប្រទះ!

## ព្រះជាម្ចាស់អើយតើទ្រង់ចង់មានន័យយ៉ាងណា នៅពេលមានបន្ទូលថាព្រះរាជ្យ?

នៅពេលដែលព្រះជាម្ចាស់បានប្រាប់ខ្ញុំថា ខ្ញុំមិនដែលរៀនពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើរការ ខ្ញុំច្របូកច្របល់ណាស់។ ព្រះរាជ្យ? ឌ្រិនដានិងខ្ញុំមិនយល់ទាល់តែសោះ។ យើងបានអធិស្ឋាន និងទូលសួរព្រះជាម្ចាស់ឲ្យបង្រៀនយើងនៅពេលដែលទ្រង់មានបន្ទូលថា «ព្រះអម្ចាស់អើយ សូមបង្រៀនយើងផង ថានៅពេលដែលទ្រង់មានបន្ទូលថាព្រះរាជ្យ ទ្រង់ចង់សំដៅលើអ្វី!» ដូច្នេះ រឿងដំបូងដែលខ្ញុំត្រូវរៀនគឺអ្វីទៅជាព្រះរាជ្យ។ ខ្ញុំគិតថា គោលគំនិតនេះមានការពិបាកសម្រាប់ប្រជាជនលោកខាងលិចយល់ ជាពិសេសរស់នៅក្នុងប្រទេសអាមេរិកដែលកាន់របបប្រជាធិបតេយ្យ និងមានការបញ្ចេញមតិដោយសេរី។ ព្រះរាជ្យរបស់ព្រះជាម្ចាស់មិនមែនជាប្រជាធិបតេយ្យឡើយ តែជាព្រះរាជ្យដែលមានស្ដេចសោយរាជ្យ។ សិទ្ធិអំណាចនៃស្ដេចនេះហូរមកនៅទូទាំងព្រះរាជ្យទាំងមូលជាមួយនឹងសិទ្ធិអំណាចដែលទ្រង់បានផ្ទេរដល់មន្ត្រីរាជការ និងប្រជារាស្ត្រផ្សេងៗគ្នាដែលបំពេញមុខងារតាមព្រះរាជ្យនោះ។ ការដែលគ្រាន់តែមានប្រជាជនធម្មតាមួយក្រុម ពុំមែនជាព្រះរាជ្យឡើយ។ លោកអ្នកអាចមានមនុស្សធម្មតាមួយលាននាក់ប្រមូលផ្ដុំគ្នា ហើយក៏នៅតែមិនមែនជាព្រះរាជ្យដែរ។ ព្រះរាជ្យជាមនុស្សមួយក្រុមដែលរួមផ្ដុំគ្នាដោយច្បាប់ឬរាជរដ្ឋាភិបាល។ និយមន័យនៃពាក្យថា ព្រះរាជ្យ នៅក្នុងវចនានុក្រមគឺ «ព្រះរាជ្យជារដ្ឋ ឬរដ្ឋាភិបាលដែលមានក្សត្រា ឬក្សត្រីសោយរាជ្យជាប្រមុខ។»

ទោះបីជាយើងអបអរសាទរការដែលព្រះយេស៊ូបានយាងមកលើផែនដី នៅក្នុងបុណ្យណូអែល យើងក៏បានបរាជ័យក្នុងការយល់ថាទ្រង់បាននាំនូវរាជរដ្ឋាភិបាលមួយមកជាមួយនឹងអង្គទ្រង់ផ្ទាល់។ ព្រះគម្ពីរចែងពីរាជរដ្ឋាភិបាលនេះនៅក្នុងគម្ពីរអេសាយ ៩:៦-៧៖

*ដ្បិតមានព្រះរាជបុត្រមួយអង្គប្រសូតមកសម្រាប់យើង ព្រះជាម្ចាស់បានប្រទានព្រះបុត្រាមួយព្រះអង្គមកយើងហើយ។ បុត្រនោះទទួលអំណាចគ្រប់គ្រង គេនឹងថ្វាយព្រះនាមថា: “ព្រះដ៏គួរស្ងើចសរសើរ ព្រះប្រកបដោយព្រះប្រាជ្ញាញាណ ព្រះដ៏មានឫទ្ធិចេស្ដា ព្រះបិតាដ៏មានព្រះជន្មគង់នៅអស់កល្បជានិច្ច ព្រះអង្គម្ចាស់នៃសេចក្ដីសុខសាន្ត”។ ព្រះរាជបុត្រនោះនឹងលាតសន្ធឹងអំណាច ព្រះអង្គនឹងធ្វើឲ្យរាជបល្ល័ង្ករបស់ព្រះបាទដាវីឌ និងនគររបស់ព្រះអង្គមានសេចក្ដីសុខសាន្តរហូតតទៅ។ ព្រះអង្គយកសេចក្ដីសុចរិត និងយុត្តិធម៌មកពង្រឹងនគររបស់ព្រះអង្គឲ្យគង់វង្ស ចាប់ពីពេលនេះ រហូតអស់កល្បជាអង្វែងតរៀងទៅ ដ្បិតព្រះអម្ចាស់នៃពិភពទាំងមូលសម្រេចដូច្នេះ មកពីព្រះអង្គមានព្រះហឫទ័យស្រឡាញ់យ៉ាងខ្លាំងចំពោះយើង។*

ព្រះយេស៊ូគឺជាប្រមុខនៃរាជរដ្ឋាភិបាលនេះ ហើយនៅពេលដែលយើងទទួលព្រះយេស៊ូជាព្រះសង្គ្រោះនៃជីវិតរបស់យើង យើងនឹងក្លាយជាចំណែកនៃរាជរដ្ឋាភិបាលរបស់ទ្រង់។ យើងក្លាយជាប្រជារាស្ត្រ ឬពលរដ្ឋរបស់ទ្រង់។ យើងមិនគ្រាន់តែក្លាយជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែគឺតាមពិត យើងក្លាយជាសមាជិកនៃក្រុមគ្រួសាររបស់ព្រះជាម្ចាស់ដោយក្នុងនាមជាបុត្រា និងបុត្រីរបស់ព្រះអង្គ។

*រីឯអស់អ្នកដែលបានទទួលព្រះអង្គ គឺអស់អ្នកដែលជឿលើព្រះនាមព្រះអង្គ ព្រះអង្គប្រទានឲ្យគេអាចទៅជាបុត្ររបស់ព្រះជាម្ចាស់។ អ្នកទាំងនោះពុំមែនកើតពីលោហិត ពីចំណង់តណ្ហា ឬពីបំណងមនុស្សឡើយ គឺកើតពីព្រះជាម្ចាស់វិញ។*

- យ៉ូហាន ១៖១២-១៣

*ហេតុនេះបងប្អូនលែងជាជនបរទេស ឬជាអាណិកជនទៀតហើយ គឺបងប្អូនជាជនរួមជាតិជាមួយប្រជាជនដ៏វិសុទ្ធ និងជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់។*

- អេភេសូ ២៖១៩

ក្នុងនាមជាសមាជិកនៃក្រុមគ្រួសាររបស់ព្រះជាម្ចាស់ យើងក្លាយជាសមាជិកនៃក្រុមគ្រួសាររបស់ទ្រង់។ ហេតុដូច្នេះហើយ យើងក៏ជាម្ចាស់ ឬមានចំណែកនៅលើអ្វីៗដែលព្រះជាម្ចាស់កាន់កាប់ដែរ។ ប៉ុន្តែ យើងថែមទាំងក្លាយជាពលរដ្ឋនៃរាជរដ្ឋាភិបាលដ៏ឧត្តមរបស់ទ្រង់។ ដើម្បីយល់កាន់តែច្បាស់ពីអ្វីដែលខ្ញុំចង់សំដៅលើនេះ សូមអនុញ្ញាតឲ្យខ្ញុំនិយាយពីការដែលរស់នៅជាពលរដ្ឋនៃសហរដ្ឋអាមេរិកសិន។ ក្នុងនាមជាពលរដ្ឋនៃសហរដ្ឋអាមេរិក លោកអ្នកមានសិទ្ធិស្របច្បាប់។ សិទ្ធិស្របច្បាប់របស់លោកអ្នកត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ហើយនៅក្នុងច្បាប់នានាដែលត្រូវបានអនុម័តនៅក្នុងរដ្ឋាភិបាលរបស់យើង។ ច្បាប់ និងអត្ថប្រយោជន៍ទាំងនេះគឺមានសម្រាប់ពលរដ្ឋគ្រប់ៗរូប មិនថាពួកគេជានរណាឡើយ។ សិទ្ធិទាំងនោះមិនផ្អែកលើអារម្មណ៍របស់យើង ឬភាពឆ្លាតវៃរបស់យើងទេ។ អត់ទេ គឺសិទ្ធិទាំងនោះត្រូវបានកំណត់ដោយច្បាប់ ជាសិទ្ធិស្របច្បាប់ដែលមានសម្រាប់ពលរដ្ឋគ្រប់ៗរូបដែលហៅប្រទេសអាមេរិកជាមាតុភូមិរបស់ខ្លួន។ វាអាចទៅរួចក្នុងការដែលពលរដ្ឋមិនបានដឹងពីសិទ្ធិស្របច្បាប់របស់ខ្លួន ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ពួកគេមានសិទ្ធិដោយព្រោះថាពួកគេជាពលរដ្ឋនៃសហរដ្ឋអាមេរិកប៉ុណ្ណោះ។

នេះជាចំណុចគួរពិចារណា ហើយខ្ញុំសង្ឃឹមថាវានឹងផ្លាស់ប្តូរទស្សនៈរបស់លោកអ្នកទាំងស្រុងស្តីអំពីព្រះជាម្ចាស់ និងរបៀបដែលលោកអ្នកបានទទួលពីព្រះអង្គ។ នៅសហរដ្ឋអាមេរិកនេះ ប្រសិនបើយើងឃើញថាមានអ្វីម្យ៉ាង ឬនរណាម្នាក់កំពុងតែព្យាយាមដកយកសិទ្ធិស្របច្បាប់ចេញពីយើង ឬយើងត្រូវបានប្រព្រឹត្តដោយមិនស្មើភាព យើងអាចទទួលបានយុត្តិធម៌ (យុត្តិធម៌គឺសំដៅលើការអនុវត្តច្បាប់ ឬរដ្ឋបាលនៃច្បាប់) ជាដំណើរការដែលនឹងអនុវត្តនូវសិទ្ធិស្របច្បាប់របស់យើង។ យើងនឹងទៅតុលាការ ហើយចៅក្រមមិនខ្វល់ពីរូបសម្បត្តិរបស់យើង ឬយើងមាន ឬក៏ក្រយ៉ាងណានោះទេ។ គាត់មើលទៅលើច្បាប់។ គាត់គឺត្រូវកាត់ក្តីដោយយោងទៅតាមច្បាប់នៅគ្រប់ពេលវេលាទាំងអស់។ នេះជាសន្តិសុខ និងភាពកក់ក្តៅដែលយើងមាន៖ ដែលយើងមានសិទ្ធិស្របច្បាប់ ហើយរដ្ឋាភិបាលរបស់យើងនឹងអនុវត្តនូវសិទ្ធិស្របច្បាប់របស់យើងទៅតាមដំណើរការនៃយុត្តិធម៌ នៅក្នុងសហរដ្ឋអាមេរិក។ ដោយចងចាំពីសេចក្តីនេះ ចូរយើងមើលកាន់តែលម្អិតពីគម្ពីរអេសាយជំពូក ៩ ដែលថែងអំពីរាជរដ្ឋាភិបាលថ្មីដែលព្រះយេស៊ូកំពុងតែនាំមកកាន់ផែនដីនេះ។

*ព្រះរាជបុត្រនោះនឹងលាតសន្ធឹងអំណាច ព្រះអង្គនឹងធ្វើឲ្យរាជបល្ល័ង្ករបស់ព្រះបាទដាវីឌ និងនគររបស់ព្រះអង្គមានសេចក្តីសុខសាន្តរហូតតទៅ។ ព្រះអង្គយកសេចក្តីសុចរិត និងយុត្តិធម៌មកពង្រឹងនគររបស់ព្រះអង្គឲ្យគង់វង្ស...*

\- អេសាយ ៩៖៧

អត្ថបទគម្ពីរថែងថា ព្រះរាជ្យរបស់ព្រះជាម្ចាស់ត្រូវបានពង្រឹង និងទ្រទ្រង់ឲ្យនៅគង់វង្សតាមរយៈយុត្តិធម៌ ដែលជារដ្ឋបាលនៃច្បាប់របស់ព្រះជាម្ចាស់។ រដ្ឋបាលគឺសំដៅលើដំណើរការនៃការអនុវត្ត ឬពង្រឹងសិទ្ធិស្របច្បាប់របស់លោកអ្នក។ សិទ្ធិ

ស្របច្បាប់របស់លោកអ្នកជាអ្វីដែលព្រះជាម្ចាស់ហៅថាសេចក្ដីសុចរិត ឬអ្វីដែលទ្រង់មានបន្ទូលថាត្រឹមត្រូវគឺជាច្បាប់របស់ទ្រង់។ ដើម្បីប្រាកដថាលោកអ្នកមាននូវអ្វីដែលទ្រង់មានបន្ទូលថាត្រឹមត្រូវនៅក្នុងព្រះរាជ្យទ្រង់ អ្វីដែលជារបស់លោកអ្នកស្របច្បាប់ក្នុងនាមជាពលរដ្ឋនៃព្រះរាជ្យនោះ ព្រះជាម្ចាស់បានប្រទានឲ្យលោកអ្នកអាចមានផ្លូវចូលទៅកាន់ភាពយុត្តិធម៌ ជាដំណើរការ ឬការធានាអះអាងថាលោកអ្នកនឹងមាននូវអ្វីដែលទ្រង់បានសន្យាមកកាន់លោកអ្នក។ ព្រះជាម្ចាស់បានបង្ហាញព្រះហឫទ័យរបស់ទ្រង់ឲ្យយើងស្គាល់តាមរយៈព្រះបន្ទូលរបស់ទ្រង់ គឺព្រះគម្ពីរ។ ដូច្នេះយើងអាចស្គាល់ពីសិទ្ធិរបស់យើងនៅក្នុងព្រះរាជ្យរបស់ទ្រង់។ នេះជាដំណឹងល្អ! អ្វីៗដែលលោកអ្នកបានអាននៅក្នុងព្រះគម្ពីរ គឺផ្សារភ្ជាប់ទៅនឹងអ្វីដែលព្រះជាម្ចាស់បានសន្យាមកកាន់លោកអ្នក គឺជារបស់លោកអ្នកស្របច្បាប់ក្នុងនាមជាពលរដ្ឋនៃព្រះរាជ្យរបស់ទ្រង់!

គម្ពីរ២កូរិនថូស ១៖២០ ចែងយ៉ាងច្បាស់ថា ព្រះបន្ទូលសន្យាទាំងប៉ុន្មាន គឺ **ព្រះបន្ទូលសន្យាទាំងឡាយ**បានសម្រេច ដែលយើងអាចពោលពាក្យថា «បាទ/ចាស៎» និង «អាម៉ែន»។ ព្រះជាម្ចាស់បានសម្រេចព្រះទ័យហើយ។ ព្រះបន្ទូលសន្យាជារបស់លោកអ្នកស្របច្បាប់ហើយ។

*ព្រះគ្រិស្តបានធ្វើឲ្យព្រះបន្ទូលសន្យាទាំងប៉ុន្មានរបស់ព្រះជាម្ចាស់បានសម្រេចសព្វគ្រប់ទាំងអស់។ ហេតុនេះហើយបានជាយើងពោលពាក្យ «អាម៉ែន» ទៅកាន់ព្រះជាម្ចាស់ តាមរយៈព្រះគ្រិស្ត ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ។*

– ២កូរិនថូស ១៖២០

គ្រឹះមូលដ្ឋានដ៏សំខាន់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺយុត្តិធម៌ និងសេចក្តីសុចរិត ពុំមានអ្វីផ្សេងឡើយ។ ដូច្នេះ សូមគិតពីវាតាមរបៀបនេះ៖ «ប្រសិនបើខ្ញុំស្គាល់ពីច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ (ព្រះហឫទ័យរបស់ទ្រង់) ហើយខ្ញុំដឹងថាខ្ញុំមានសិទ្ធិចូលទៅកាន់យុត្តិធម៌ នោះដំណើរការនៃការអនុវត្តច្បាប់ដែលធានាអះអាងដល់ខ្ញុំពីអ្វីដែលច្បាប់ចែង នោះខ្ញុំក៏មានទំនុកចិត្ត ហើយមិនភ័យខ្លាចឡើយ។

**ព្រះរាជ្យដំណើរការដោយច្បាប់ ហើយច្បាប់មិនផ្លាស់ប្តូរឡើយ។**

*នេះជាសេចក្តីក្លាហានដែលយើងមានចំពោះព្រះអង្គ គឺថា បើយើងសូមអ្វីតាមបំណងរបស់ព្រះអង្គ នោះព្រះអង្គនឹងស្តាប់យើង។ បើយើងដឹងថា ព្រះអង្គស្តាប់យើងគ្រប់អ្វីដែលយើងសូម នោះយើងក៏ដឹងដែរថា យើងបានអ្វីដែលយើងសូមពីព្រះអង្គហើយ។*

- ១យ៉ូហាន ៥៖១៤-១៥

នៅពេលដែលខនេះចែងថាទ្រង់ស្តាប់យើង គឺមិនសំដៅលើការដែលព្រះអង្គស្តាប់សំឡេងរបស់យើង ដូចជាតាមរលកសំឡេងនោះទេ តែខនេះសំដៅលើការដែលទ្រង់ធ្វើការកាត់ក្តី។ សូមគិតពីចៅក្រមម្នាក់ដែលស្តាប់នូវករណីណាមួយ ហើយធ្វើយ៉ាងណាឲ្យប្រាកដថាមានយុត្តិធម៌នៅក្នុងករណីនោះ។ បន្ទប់សវនាការ និងចៅក្រមមានវត្តមាននៅទីនោះដើម្បីប្រាកដថា ពលរដ្ឋគ្រប់ៗរូបទទួលបាននូវយុត្តិធម៌។ ការសម្រេចចិត្តរបស់ចៅក្រម គឺមិនអាស្រ័យលើអារម្មណ៍របស់គាត់ឡើយ ប៉ុន្តែអាស្រ័យលើច្បាប់ដែលគាត់ទទួលខុសត្រូវលើការអនុវត្តសម្រាប់ពលរដ្ឋម្នាក់ៗ។ ចៅក្រមនៅទីនោះដើម្បីប្រាកដថាមានយុត្តិធម៌ (ការអនុវត្តច្បាប់) កើតឡើង ដោយយោងទៅតាមច្បាប់ជាលាយលក្ខណ៍អក្សរ។ នៅក្នុងករណីរបស់ព្រះជាម្ចាស់ បល្ល័ង្ករបស់ទ្រង់ (កន្លែងនៃសិទ្ធិអំណាច) និងឫទ្ធានុភាពរបស់ទ្រង់គឺមាន

វត្ថុមានដើម្បីប្រាកដថាមានយុត្តិធម៌ (ការអនុវត្តតាមព្រះហឫទ័យរបស់ទ្រង់) ចំពោះមនុស្សគ្រប់ៗរូបដែលចូលមកកាន់ព្រះយេស៊ូ និងព្រះរាជ្យរបស់ទ្រង់។

សូមអានសេចក្តីប្រកាសខាងលើម្តងទៀតសន្សឹមៗ ហើយអនុញ្ញាតឲ្យវាជះឥទ្ធិពលដល់ទស្សនៈដែលលោកអ្នកកំពុងតែមានអំពីព្រះជាម្ចាស់។ មនុស្សភាគច្រើនមានអារម្មណ៍ថា ព្រះជាម្ចាស់សម្រេចព្រះទ័យដោយផ្អែកលើករណីផ្សេងៗគ្នា ប៉ុន្តែនេះពុំមែនជាការពិតឡើយ។ ទ្រង់ជាស្តេចដែលសោយរាជ្យលើព្រះរាជ្យ ជាមួយនឹងច្បាប់ដែលមិនផ្លាស់ប្តូរ។ ទាំងបច្ចុប្បន្ន និងអនាគត ទ្រង់មិនធ្វើការសម្រេចព្រះទ័យក្រៅពីដែនច្បាប់របស់ទ្រង់ឡើយ។ ហេតុដូច្នេះហើយ យើងអាចដឹងចម្លើយរបស់ទ្រង់មុនពេលដែលយើងទូលសុំ ហើយយើងអាចប្រាកដជាក់ច្បាស់ថា យើងមាននូវអ្វីដែលច្បាប់របស់ទ្រង់ចែង មុនពេលដែលយើងមើលឃើញវា ដោយសារទ្រង់មានឫទ្ធានុភាពដើម្បីធ្វើការអនុវត្តច្បាប់របស់ព្រះអង្គ។

នៅពេលដែលខ្រិនដានិងខ្ញុំបានចាប់ផ្តើមរៀនពីសិទ្ធិស្របច្បាប់របស់យើងនៅក្នុងព្រះរាជ្យ វាបានផ្លាស់ប្តូររបៀបដែលយើងគិតអំពីព្រះជាម្ចាស់ និងព្រះគម្ពីរជាខ្លាំងពន់ពេកក្រៃ។ ជាលទ្ធផលដែលចេញពីការយល់ដឹងថ្មីសន្លាងរបស់យើងគឺយើងទទួលបានជីវិតដែលផ្លាស់ប្រែ។ យើងលែងជាអ្នកសុំទានទៀតហើយ។ យើងលែងជាអ្នកអង្វរទៀតហើយ។ យើងបានរៀននូវអ្វីដែលព្រះជាម្ចាស់បានមានបន្ទូលថា ទ្រង់បានប្រទានមកកាន់យើងដោយស្របច្បាប់ក្នុងនាមជាពលរដ្ឋនៃព្រះរាជ្យរបស់ទ្រង់។ យើងគ្រាន់តែត្រូវការបន្តរៀនពីរបៀបចាប់យកនូវអ្វីដែលជារបស់យើងស្របច្បាប់ ហើយស្រាយវាឲ្យកើតឡើងនៅលើភពផែនដីប៉ុណ្ណោះ។ សូមគិតពីការបើកមូលប្បទានបត្រ (សែក) ប្រាក់។ ទោះបីជាលោកអ្នកមានលុយច្រើននៅក្នុងគណនីរបស់លោកអ្នកក្តី ក៏លោកអ្នកត្រូវធ្វើទៅតាមដំណើរការស្របច្បាប់ដើម្បីបើកសាច់ប្រាក់ពីមូលប្បទានបត្រនោះ។ មាននូវដំណើរការនៅគ្រប់ប្រព័ន្ធច្បាប់ទាំងអស់ដែលយើងត្រូវបើកយកអ្វីមួយ ទោះបីជាវាជាកម្មសិទ្ធិរបស់យើងហើយក្តី។

*ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ប្រទានឲ្យយើងមានអ្វីៗទាំងអស់ សម្រាប់ជីវិតរស់នៅ និងសម្រាប់គោរពប្រណិប័តន៍ព្រះអង្គ។ ឫទ្ធានុភាពនោះនាំយើងឲ្យស្គាល់ព្រះអង្គ ដែលបានត្រាស់ហៅយើង ដោយសារសិរីរុងរឿងរបស់ព្រះអង្គផ្ទាល់ និងដោយសារព្រះបារមីរបស់ព្រះអង្គ។*

- ២ ពេត្រុស ១៖៣

នេះជាព្រះរាជ្យ! អស់អ្នកដែលជាពលរដ្ឋនៃព្រះរាជ្យមានសិទ្ធិស្មើៗគ្នា។ ជាការសំខាន់ដែលយើងត្រូវយល់សេចក្ដីនេះ៖ ព្រះរាជ្យដំណើរការដោយច្បាប់ ហើយច្បាប់មិនផ្លាស់ប្ដូរឡើយ។ ហេតុអ្វីបានជាសេចក្ដីនេះសំខាន់? វាសំខាន់ដោយហេតុថាប្រសិនបើព្រះរាជ្យដំណើរការ ឬប្រតិបត្តិការដោយផ្អែកលើច្បាប់ដែលចេះតែផ្លាស់ប្ដូរ នោះពុំមានការគោរពទៅលើមនុស្សម្នាក់ៗនៅក្នុងព្រះរាជ្យឡើយ។ ផ្ទុយទៅវិញមនុស្សគ្រប់ៗរូបនៅក្នុងព្រះរាជ្យមានសិទ្ធិដូចៗគ្នាក្នុងការរីករាយទៅនឹងប្រតិបត្តិការនៃច្បាប់របស់ព្រះរាជ្យសម្រាប់ខ្លួនគេ ដូចជាពលរដ្ឋដទៃទៀតដែរ។

នេះជាចំណុចដែលពិបាកយល់បន្តិចនៅក្នុងពិភពគ្រិស្តបរិស័ទ។ គ្រិស្តបរិស័ទភាគច្រើនគិតថា ព្រះជាម្ចាស់សម្រេចព្រះទ័យនូវអ្វីដែលទ្រង់ចង់ធ្វើនៅក្នុងជីវិតរបស់មនុស្សម្នាក់ៗតាមតែព្រះហឫទ័យទ្រង់។ ពាក្យមួយទៀតគឺ គេគិតថាព្រះជាម្ចាស់ជ្រើសរើសប្រទានពរដល់មនុស្សមួយចំនួន ហើយមិនប្រទានពរដល់មួយចំនួនទៀត។ ពួកគេគិតថា ព្រះជាម្ចាស់បណ្ដោយឲ្យរឿងរ៉ាវផ្សេងៗកើតឡើងចំពោះមនុស្សដែលពុំអាចគ្រប់គ្រងស្ថានការណ៍បាន។ ពួកគេគិតថា ព្រះជាម្ចាស់នឹងប្រោសមនុស្សមួយចំនួនឲ្យបានជា ហើយទុកមួយចំនួនទៀតឲ្យនៅឈឺ។ គ្រិស្តបរិស័ទភាគច្រើនបានអង្វរករ ឬសុំទានព្រះជាម្ចាស់ឲ្យប្រទានមកកាន់ពួកគេ នៅពេលដែលតាមពិតទ្រង់បានធ្វើនូវអ្វីដែលទ្រង់អាចធ្វើបាន ដើម្បីជួយដល់ពួកគេ

ហើយ។ ទ្រង់បានប្រទានព្រះរាជ្យដល់ពួកគេហើយ គឺរួមទាំងអ្វីៗទាំងប៉ុន្មាននៃព្រះរាជ្យតែម្តង!

នៅពេលដែលព្រះជាម្ចាស់បានចាប់ផ្តើមមានបន្ទូលមកកាន់ខ្ញុំអំពីថវិការបស់ខ្ញុំ ហើយដែលខ្ញុំត្រូវរៀនថែមទៀតអំពីព្រះរាជ្យរបស់ទ្រង់ ទ្រង់បានប្រទានអត្ថបទគម្ពីរនេះមកកាន់ខ្ញុំ។

*អ្នករាល់គ្នាដែលជាជនក្រខ្សត់អើយ! អ្នកមានសុភមង្គលហើយ ដ្បិតអ្នករាល់គ្នាបានទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់។*

- លូកា ៦:២០

ពេលនោះព្រះជាម្ចាស់កំពុងតែប្រាប់ខ្ញុំថា ចម្លើយសម្រាប់ថវិការបស់ខ្ញុំគឺជាព្រះរាជ្យរបស់ទ្រង់ ហើយលោកអ្នកអាចបន្ថែមលើពាក្យដែលខ្ញុំនិយាយនេះ គឺការដែលខ្ញុំត្រូវដឹងពីរបៀបប្រើប្រាស់ច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅលើផែនដីនេះ ដូចដែលព្រះយេស៊ូបានធ្វើដែរ។ ខ្ញុំសូមសារភាពថា ពីដំបូងឡើយខ្ញុំមិនបានដឹងថាវាមានន័យដូចម្តេចទេ។ ប៉ុន្តែនៅពេលដែលខ្ញុំគិតពីអ្វីដែលព្រះជាម្ចាស់បានប្រាប់មកកាន់ខ្ញុំ ខ្ញុំបានទទួលស្គាល់ថា តាមពិតនគរនានាសុទ្ធតែប្រតិបត្តិដោយច្បាប់។ ដំណើរការ និងឥទ្ធិពលនៃច្បាប់ជាក់លាក់អាចត្រូវបានស្គាល់ និងរាប់បញ្ចូលនៅលើដំណើរការតាមរបៀបដូចៗគ្នា នៅគ្រប់ពេលវេលាដោយសារតែច្បាប់មិនប្រែប្រួលឡើយ។ ខ្ញុំមិនធ្លាប់គិតបែបនេះចំពោះភពខាងវិញ្ញាណឡើយពីពេលមុន។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើវាអញ្ចឹងមែន ហើយព្រះរាជ្យរបស់ព្រះជាម្ចាស់ពិតជាដំណើរការបែបនោះមែន នោះខ្ញុំអាចដឹងថា ខ្ញុំអាចរៀនពីច្បាប់ទាំងនោះបានដោយអនុវត្តវា ហើយទទួលប្រយោជន៍ពីច្បាប់ទាំងនោះដែលប្រតិបត្តិការនៅក្នុងជីវិតរបស់ខ្ញុំ។

ខ្ញុំបានទទួលស្គាល់ថា ច្បាប់ដែលគ្រប់គ្រងនៅលើផែនដីនេះមិនផ្លាស់ប្ដូរឡើយ។ តាមពិត មុខងារដ៏ស្ថិតស្ថេរ និងមិនចេះប្រែប្រួលរបស់វាអាចអាស្រ័យលើការដែលបញ្ជូននរណាម្នាក់ទៅស្ថានព្រះច័ន្ទ ឬអាចឲ្យយន្តហោះហោះបាន។ ប៉ុន្តែ គ្រិស្តបរិស័ទភាគច្រើនមិនបានចូលទៅកាន់ព្រះជាម្ចាស់ ដោយមានការយល់ដឹងបែបនេះទេ។ ផ្ទុយទៅវិញពួកគេបានសុំទាន ហើយស្រែកយំនៅពេលដែលពួកគេត្រូវការអ្វីមួយ ដោយព្យាយាមបញ្ចុះបញ្ចូលព្រះជាម្ចាស់ឲ្យយល់ពីសេចក្ដីត្រូវការរបស់គេ ដូចជាព្រះជាម្ចាស់ហ្នឹងត្រូវជ្រើសរើសថែទាំពួកគេអញ្ចឹង។

ឧទាហរណ៍ ប្រសិនបើខ្ញុំត្រូវទៅប្រកាសព្រះបន្ទូលនៅក្នុងសន្និបាតនៃក្រុមជំនុំណាមួយ តើសមាជិកនៃក្រុមជំនុំនោះនឹងអធិស្ឋានឲ្យមានភ្លើងបំភ្លឺនៅក្នុងព្រឹត្តិការណ៍នោះដែរឬទេ? តើពួកគេនឹងតមអាហារ ហើយអធិស្ឋាន ដោយសុំអង្វរព្រះជាម្ចាស់ថា «ព្រះជាម្ចាស់អើយ ទ្រង់ជ្រាបថាការជួបជុំនេះសំខាន់ប៉ុណ្ណា ហើយយើងត្រូវការភ្លើងបំភ្លឺយ៉ាងណា។» ដូចដែលគេទូលសុំដោយយំខ្សឹកខ្សួល និងសម្រែកថ្ងូចថ្ងូរនៅពេលអធិស្ឋានដែរឬទេ? ខ្ញុំមិនគិតដូច្នេះទេ។ តាមពិត ខ្ញុំគិតថាគេមិនបានខ្វល់ទេថា នឹងមានភ្លើងបើកបំភ្លឺដែរឬអត់ នៅពេលដែលគេរៀបចំផែនការជួបជុំនោះ។ ប្រសិនបើគេមកចូលរួមសន្និបាតនៅយប់នោះ ហើយដោយប្រការណាមួយភ្លើងមិនទាន់បើកបំភ្លឺ តើលោកអ្នកគិតថាគេនឹងទូរស័ព្ទទៅក្រុមហ៊ុនអគ្គិសនីដោយអង្វរកពួកគេឲ្យបើកភ្លើងឬ? អត់ទេ។ ប្រសិនបើពួកគេធ្វើអញ្ចឹងមែន អ្នកតំណាងក្រុមហ៊ុននោះប្រាកដជាស្ដាប់មួយភ្លែត ហើយងាកទៅមិត្តរួមការងាររបស់គាត់ ទាំងពោលថា «មានមនុស្សមិនគ្រប់ទឹកទូរស័ព្ទមកក្រុមហ៊ុនយើង។» គាត់នឹងបន្ថែមថា «អ្នកស្រី យើងបើកភ្លើងហើយ។ បញ្ហាគឺនៅខាងអ្នកស្រីទេ។»

នៅពេលដែលខ្ញុំប្រាប់ពីសាច់រឿងនេះទៅកាន់អ្នកដែលស្ដាប់ខ្ញុំនៅតាមអង្គសន្និបាត គេគ្រប់គ្នាសុទ្ធតែសើច។ តើលោកអ្នកដឹងថាហេតុអ្វីទេ? ដោយហេតុថាពួកគេដឹងថា ការដែលទូរស័ព្ទទៅក្រុមហ៊ុនអគ្គិសនីទាំងយំខ្សឹកខ្សួលប្រាប់ពួកគេឲ្យបើកភ្លើងជារឿងឆោតល្ងង់ណាស់។ មនុស្សភាគច្រើននឹងដឹងពីអ្វីដែលខ្លួនត្រូវធ្វើ។

ពួកគេនឹងគ្រាន់តែបើកកុងតាក់ភ្លើង។ គឺសាមញ្ញដូច្នេះឯង! គេមិនចាំបាច់យំក្អុកក្អួល មិនចាំបាច់ពិបាកចិត្ត គឺពួកគេគ្រាន់តែបើកកុងតាក់ប៉ុណ្ណោះ។ តើលោកអ្នកចង់ដឹងទេថា ហេតុអ្វីបានជាពួកគេមិនមានភាពតានតឹងលើការបើកភ្លើង? ដោយសារតែពួកគេ**រំពឹង**ថាភ្លើងនឹងភ្លឺ នៅពេលដែលបើកកុងតាក់។ ពួកគេរំពឹងថា ភ្លើងនឹងភ្លឺដោយសារតែពួកគេដឹងពីរបៀបដែលអគ្គិសនីដំណើរការ។ ពួកគេយល់ពី**ច្បាប់**ដែលគ្រប់គ្រងលើអគ្គិសនី ហើយពួកគេដឹងថាច្បាប់នោះមិនដែលផ្លាស់ប្តូរឡើយ។

ប៉ុន្តែ ប្រសិនបើលោកអ្នកត្រលប់ទៅកាន់ពេលវេលាជាង ១០០០ ឆ្នាំមុន ហើយប្រាប់មនុស្សម្នាក់ថា លោកអ្នកនឹងបំភ្លឺទីក្រុងទាំងមូលដោយប្រើអំពូលភ្លើងកែវតូចៗ ពួកគេនឹងគិតថាលោកអ្នកបាត់បង់ស្មារតីជាមិនខាន។ ហើយប្រសិនបើពួកគេឃើញទីក្រុងត្រូវបានបំភ្លឺដោយអំពូលភ្លើងតូចៗ ពួកគេនឹងហៅការនោះថាជាការអស្ចារ្យ។ អ្វីៗដែលមនុស្សមិនអាចពន្យល់បាន គេហៅថាជាការអស្ចារ្យ។ ប៉ុន្តែវាមិនមែនជាការអស្ចារ្យទេ វាគ្រាន់តែជាច្បាប់របស់អគ្គិសនីដែលដំណើរការសម្រាប់មនុស្សគ្រប់ៗរូប រួមទាំងអ្នកដែលចំណាយពេលសិក្សាពីដំណើរការនៃអគ្គិសនីដែរ។

យើងទើបតែបានរៀនពីរបៀបដែលអគ្គិសនីដំណើរការ ឬលោកអ្នកអាចនិយាយបានថា យើងតម្រូវចិត្តគំនិតរបស់យើងជាថ្មី ទៅតាមច្បាប់ដែលគ្រប់គ្រងលើអគ្គិសនី។ ដូច្នេះ យើងរំពឹងថា វានឹងដំណើរការ ហើយមិនភ្ញាក់ផ្អើលឡើយប្រសិនបើយើងឃើញវាមិនដំណើរការ។ ដោយការដែលយើងយល់ពីច្បាប់ដែលគ្រប់គ្រងលើអគ្គិសនី ហើយសរសេរវាចូល យើងក៏អាចពហុគុណអំពូលភ្លើងដើម្បីបំភ្លឺនៅជុំវិញពិភពលោកទាំងមូល។ តើដោយរបៀបណាទៅ? គឺយើងអាចធ្វើវាបានដោយបង្រៀនអ្នកដទៃពីរបៀបដែលច្បាប់ទាំងនេះដំណើរការ និងអនុញ្ញាតឲ្យពួកគេរីករាយនូវអត្ថប្រយោជន៍នៃពន្លឺដែរ។ កិច្ចការទាំងនេះអាចកើតឡើងបាន ដោយសារយើងយល់ពីច្បាប់ដែលគ្រប់គ្រងលើអគ្គិសនី។ វាក៏ជាគោលការណ៍ដូចគ្នាទៅនឹងច្បាប់ខាងវិញ្ញាណដែរ។ ប្រសិនបើយើងមិនយល់ពីច្បាប់ខាងវិញ្ញាណទេ នោះយើង

មិនមានសមត្ថភាពដើម្បីរីករាយនឹងអត្ថប្រយោជន៍របស់វា ឬពហុគុណវានៅពេលដែលយើងត្រូវការច្បាប់ទាំងនោះឡើយ។

នៅពេលដែលយើងឃើញយន្តហោះហោះ យើងមិននិយាយថា «អស្ចារ្យណាស់ នោះជាការអស្ចារ្យ» ទេ។ អត់ទេ គឺយើងរំពឹងឲ្យយន្តហោះហោះ ព្រោះថាយើងយល់ពីរបៀបដែលយន្តហោះហោះ ហើយមូលហេតុអ្វីបានជាវាហោះបាន។ ហើយជាថ្មីម្តងទៀត ប្រសិនបើយើងងាកទៅពេលវេលាជាង ១០០០ ឆ្នាំមុន ហើយយន្តហោះស៊េរីថ្មីប្រភេទ Airbus 380 ជាយន្តហោះដែលមានពីរជាន់ ហោះនៅលើពួកគេក្នុងកម្ពស់ត្រឹមចុងឈើ តើមនុស្សនឹងនិយាយយ៉ាងដូចម្តេច? ពួកគេនឹងថានោះជាការអស្ចារ្យ! ខ្ញុំយល់ស្របថាយន្តហោះ 380 ជាយន្តហោះដែលគួរឲ្យចាប់អារម្មណ៍មានទម្ងន់ជាង ៥.៤៤ លានគីឡូក្រាម អាចផ្ទុកមនុស្សបានជាង ៨០០ នាក់ មានល្បឿនរហូតដល់ ៩០០ គីឡូម៉ែត្រក្នុងមួយម៉ោង និងអាចហោះបានដល់ទៅជាង ១៤៥០០ គីឡូម៉ែត្រ។ វាក៏គួរឲ្យសរសើរដែរ ហើយលោកអ្នកអាចជាចង់គិតថានេះជាការអស្ចារ្យ។ ប៉ុន្តែនេះពុំមែនជាការអស្ចារ្យឡើយ។ យើងអាចសួរក្រុមវិស្វករដែលបានសង់យន្តហោះប្រភេទ 380 នេះពីរបៀបដែលវាហោះ ហើយពួកគេនឹងប្រាប់យើងនូវគ្រប់ទាំងច្បាប់នៃរូបវិទ្យាដែលពួកគេបានប្រើប្រាស់ក្នុងការឲ្យយន្តហោះនោះហោះបាន ព្រមទាំងអាចប្រាប់យើងពីខ្មៅ និងគ្រឿងតូចធំទាំងប៉ុន្មាននៅក្នុងយន្តហោះនោះ។ ក្រុមវិស្វករមិនបានឈរនៅផ្លូវយន្តហោះ នៅពេលយន្តហោះធ្វើការហោះហើរជាលើកដំបូង ហើយនិយាយថា «អស្ចារ្យណាស់ មើលចុះ! ខ្ញុំសឹងតែមិនជឿថាយន្តហោះនោះអាចហោះបាន» នោះទេ។ ជាថ្មីម្តងទៀត យើងក៏មានទំនុកចិត្តនៅពេលឡើងជិះយន្តហោះ ដោយសារយើងស្គាល់ពីសមត្ថភាពហោះហើររបស់វា គឺផ្អែកទៅលើច្បាប់រូបវិទ្យាដែលមិនផ្លាស់ប្តូរ។ ដរាបណាយន្តហោះនៅក្នុងដែនប៉ារ៉ាម៉ែត្រនៃច្បាប់ទាំងនេះ នោះវានឹងហោះជានិច្ច។ សូមចាំដូច្នេះថា៖ ច្បាប់មិនប្រែប្រួលឡើយ!

យើងនឹងមិនឡើងជិះយន្តហោះ ប្រសិនបើច្បាប់ចេះតែប្រែប្រួលមិនមានស្ថេរភាពនោះ។ ប្រសិនបើយើងទិញសំបុត្រយន្តហោះ ហើយក្នុងសំបុត្រនោះមានសរសេរថា «លោកអ្នកជាអ្នកទទួលខុសត្រូវលើហានិភ័យទាំងឡាយដែលកើតឡើងពីការធ្វើដំណើរនៅលើយន្តហោះនេះ ព្រោះច្បាប់នៃការលើកវត្ថុពីទំនាញផែនដីដំណើរការមិនទៀងទាត់។ ថ្ងៃខ្លះច្បាប់នេះមានប្រសិទ្ធិភាព ហើយថ្ងៃខ្លះវាមិនមានប្រសិទ្ធិភាពទេ។ ពុំមាននរណាដឹងច្បាស់ឡើយ។ ដូច្នេះ បើលោកអ្នកមានអារម្មណ៍ថាមានសំណាងល្អមែនទេ? សូមធ្វើដំណើរដោយសុវត្ថិភាព។» នៅពេលណាជាលើកចុងក្រោយដែលលោកអ្នកខ្លាចថា លោកអ្នកនឹងអណ្តែតហោះចេញពីកៅអីនៅលើយន្តហោះ? មិនដែលគិតបែបនេះសោះ? ហេតុអ្វីបានជាមិនដែល? ដោយព្រោះតែលោកអ្នកដឹងថាច្បាប់ទំនាញផែនដីមិនប្រែប្រួលឡើយ។

សេចក្តីខាងលើដែលខ្ញុំបានរៀបរាប់នេះ គឺសុទ្ធតែជាច្បាប់រូបវិទ្យានៅលើភពផែនដីដែលព្រះជាម្ចាស់បានបង្កើតមក។ ប៉ុន្តែ ដឹងថាយ៉ាងណាទេ? ច្បាប់ខាងវិញ្ញាណនៃព្រះរាជ្យរបស់ទ្រង់ក៏ដំណើរការដូចគ្នាដែរ។ ច្បាប់ទាំងនោះមិនផ្លាស់ប្តូរទេ! មុនពេលដែលព្រះជាម្ចាស់បានមានបន្ទូលមកកាន់ខ្ញុំអំពីព្រះរាជ្យរបស់ទ្រង់ ខ្ញុំយល់បានយ៉ាងច្បាស់ពីរបៀបដែលច្បាប់រូបវិទ្យានៅលើផែនដីដំណើរការ ប៉ុន្តែខ្ញុំគិតថាព្រះរាជ្យរបស់ព្រះជាម្ចាស់មានភាពខុសគ្នា។ ខ្ញុំស្មានថា ព្រះជាម្ចាស់គ្រាន់តែធ្វើនូវអ្វីដែលទ្រង់ចង់ធ្វើទៅកាន់មនុស្សមួយចំនួនដោយរើសមុខប៉ុណ្ណោះ។ ប៉ុន្តែខ្ញុំបានរកឃើញថានោះមិនមែនជាការពិតទេ។ នៅពេលដែលខ្ញុំបានឃើញច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់មិនផ្លាស់ប្តូរ ហើយយើងអាចរៀនបាន យល់បាន និងអនុវត្តបាន ខ្ញុំក៏បានយល់ថាហេតុអ្វីបានជាព្រះយេស៊ូចេះតែមានបន្ទូលថា «ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺមានលក្ខណៈបែបនេះឯង»។ ទ្រង់ក៏បានប្រៀបប្រដូចព្រះរាជ្យទៅនឹងអ្វីមួយដែលនៅក្នុងភពខាងឯធម្មជាតិ ដើម្បីឲ្យមនុស្សអាចយល់ពីរបៀបដែលវាដំណើរការ។ រំពេចនោះ ហាក់ដូចជាមានគេបើកភ្លើងបំភ្លឺក្នុងគំនិតខ្ញុំអញ្ចឹង គឺខ្ញុំយល់ច្បាស់តែម្តង! ខ្ញុំធ្លាប់តែគិតថា «ប្រសិនបើព្រះជាម្ចាស់ប្រទានព្រះរាជ្យរបស់

ទ្រង់មកកាន់យើង ហើយទ្រង់ពិតជាបានធ្វើដូច្នោះមែន ហើយព្រះរាជ្យដំណើរការដោយច្បាប់ដែលមិនអាចប្រែប្រួល នោះខ្ញុំអាចរៀនច្បាប់ទាំងនោះ ហើយអនុវត្តវានៅក្នុងជីវិតរបស់ខ្ញុំ។»

*«កុំខ្លាចអី ក្រុមដ៏តូចរបស់ខ្ញុំអើយ! ព្រះបិតារបស់អ្នករាល់គ្នាសព្វព្រះហឫទ័យប្រទានព្រះរាជ្យមកឲ្យអ្នករាល់គ្នាហើយ។*

- លូកា ១២៖៣២

ថ្ងៃនោះជាថ្ងៃដែលខ្ញុំបានក្លាយជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ! ខ្ញុំបានមើលឃើញព្រះគម្ពីរតាមទស្សនៈមួយខុសពីមុនទាំងស្រុង។ ខ្ញុំបានចាប់ផ្តើមសួរសំណួរនៅពេលដែលខ្ញុំអានព្រះគម្ពីរថា៖ «ហេតុអ្វីបានជាត្រីទាំងនេះពហុគុណ? ហេតុអ្វីបានជាអ្នកនោះបានជាសះស្បើយ? ហេតុអ្វីបានជានំបុ័ងនោះពហុគុណដែរ?។ល។ នៅពេលដែលខ្ញុំមើលទៅកាន់ព្រះគម្ពីរដោយទស្សនៈបែបនោះ និងទូលសួរព្រះជាម្ចាស់ឲ្យបង្ហាញខ្ញុំពីច្បាប់ដែលមាននៅទីនោះ **គឺអស្ចារ្យណាស់**!

នៅពេលដែលព្រះអម្ចាស់មានបន្ទូលមកកាន់ខ្ញុំនៅថ្ងៃដែលមេធាវីបានទូរស័ព្ទមកខ្ញុំ ហើយទ្រង់បានប្រាប់ខ្ញុំថាបញ្ហារបស់ខ្ញុំកើតឡើងដោយព្រោះថាខ្ញុំមិនដែលចំណាយពេលរៀនពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើរការ ខ្ញុំក៏ចាប់ផ្តើមរត់ចុះទៅជាន់ក្រោម ហើយកែប្រែចិត្តគំនិតនៅចំពោះភរិយាក្នុងការដែលមិនបានស្វែងរកព្រះអម្ចាស់ ហើយបណ្តោយឲ្យយើងធ្លាក់ក្នុងភាពរញ៉េរញ៉ៃនេះដូចដែលខ្ញុំបាននិយាយពីខាងដើមមក។ ប៉ុន្តែ យើងមិនបានដឹងថា តើវាមានន័យយ៉ាងណាក្នុងការទុកចិត្តលើព្រះរាជ្យសម្រាប់ចម្លើយរបស់យើងឡើយ។ ជាថ្មីម្តងទៀត យើងបានចូលរួមនៅក្នុងក្រុមជំនុំ យើងនឹងបានទៅស្ថានសួគ៌ពេលស្លាប់ទៅ ហើយយើងស្រឡាញ់ព្រះជាម្ចាស់។ យើងមិនយល់ទាល់តែសោះ ថាព្រះជាម្ចាស់ចង់មានន័យយ៉ាងណា

នៅពេលដែលទ្រង់មានបន្ទូលថា «ព្រះរាជ្យ» នៅពេលនោះ។ យើងមានបញ្ហាធំ ហើយយើងមិនដឹងពីរបៀបរកលុយដែលមេធាវីបាននិយាយថា យើងមានពេលបីថ្ងៃដើម្បីរកឲ្យបាន ឬរបៀបដោះស្រាយជាមួយពាក្យបណ្តឹងដែលគេនឹងដាក់ដើម្បីប្តឹងយើង ប្រសិនបើយើងមិនមានលុយនៅក្នុងពេលបីថ្ងៃនោះទេ។

ដូច្នេះ នេះជាការល្បងលដ៏ល្អមួយ។ វាជាបទពិសោធន៍ដំបូងរបស់ខ្ញុំជាមួយនឹងបញ្ហាលុយកាក់ ហើយខ្ញុំចង់ឲ្យព្រះអម្ចាស់បង្ហាញខ្ញុំថាទ្រង់សំដៅលើអ្វី នៅពេលដែលមានបន្ទូលថា «ព្រះរាជ្យ»។ ដូច្នេះ សូមអនុញ្ញាតឲ្យខ្ញុំប្រាប់លោកអ្នកពីអ្វីដែលបានកើតឡើង។ សូមចាំថា មេធាវីបាននិយាយថាខ្ញុំមានពេលបីថ្ងៃដើម្បីរកប្រាក់សងកូនក្តីគាត់ ដែលជាក់ស្តែងខ្ញុំគ្មានប្រាក់សោះ! សេចក្តីអស់សង្ឃឹមនោះហើយដែលបាននាំឲ្យខ្ញុំចូលទៅក្នុងបន្ទប់គេង ហើយស្រែកទៅកាន់ព្រះជាម្ចាស់ គឺខ្ញុំកំពុងជួបនឹងបញ្ហាធំ! ជាការពិតណាស់ នោះគឺជាពេលដែលព្រះជាម្ចាស់មានបន្ទូលមកកាន់ខ្ញុំអំពីព្រះរាជ្យ ដែលជាដំណោះស្រាយរបស់ខ្ញុំ។ ហើយខ្ញុំសូមបញ្ជាក់ម្តងទៀតថា ខ្ញុំមិនយល់ទាល់តែសោះថាទ្រង់ចង់សំដៅលើអ្វីនៅពេលដែលទ្រង់មានបន្ទូលដោយពាក្យនោះ ប៉ុន្តែខ្ញុំក៏សុខចិត្តរៀនពីអ្វីដែលទ្រង់មានបន្ទូលដែរ។

ពីរថ្ងៃក្រោយមក នៅពេលល្ងាចមួយខ្ញុំកំពុងធ្វើដំណើរទៅជួបនឹងអតិថិជនម្នាក់អំពីការធានារ៉ាប់រងអាយុជីវិតរបស់គាត់។ មួយទៀតសោត នៅប៉ុន្មានថ្ងៃនោះខ្ញុំតែងចតឡាននៅម្តុំកាច់ជ្រុងផ្ទះអតិថិជនរបស់ខ្ញុំ គឺមិនដែលចតនៅខាងមុខផ្ទះគាត់ឡើយ។ ឡាន ១២កៅអីដែលខ្ញុំបើកនោះ មានបញ្ហាបន្តិចបន្តួច។ នៅពេលដែលទើបបញ្ឆេះដំបូង វាហុយផ្សែងសក្បុសនៅពាសពេញផ្លូវ ហើយខ្ញុំមិនមែនមានន័យថា ផ្សែងតែបន្តិចនោះទេ។ ខ្ញុំតែងតែមានអារម្មណ៍ថា វានឹងមិនជួយដល់ការរកស៊ីឡើយ ប្រសិនបើខ្ញុំចតឡាននៅផ្លូវឡានដែលអតិថិជនខ្ញុំចេញចូល ហើយនៅពេលបើកចេញពីផ្ទះគាត់ ឡានរបស់ខ្ញុំហុយផ្សែងក្បុសនោះ។ ខ្ញុំសន្មតថា កេរ្តិ៍ឈ្មោះរបស់ខ្ញុំនៅលើវិស័យហិរញ្ញវត្ថុអាចនឹងរងផលប៉ះពាល់ខ្លះៗប្រសិនបើរឿងនោះកើតឡើង ព្រោះថាខ្ញុំកំពុងតែសុំពួកគេឲ្យដាក់ទុនប៉ុន្មានលានដុល្លារជាមួយនឹងខ្ញុំ។

ម្យ៉ាងវិញទៀត ប្រសិនបើខ្ញុំជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុដ៏ល្អ ហេតុអ្វីបានជាខ្ញុំបើកឡានចាស់ៗ សូម្បីតែបញ្ឆេះក៏មិនចង់ឆេះបែបនេះ? នៅយប់នោះក៏មិនខុសពីសព្វមួយដងដែរ។

នៅពេលដែលខ្ញុំកំពុងតែដើរចេញពីផ្ទះអតិថិជន ខ្ញុំតក់ស្លុតជាខ្លាំងដោយបានឃើញអតិថិជនរបស់ខ្ញុំដើរតាមពីក្រោយខ្ញុំរហូតមកដល់ឡានរបស់ខ្ញុំ។ គាត់មិនចង់បានអីនោះទេ គឺយើងគ្រាន់តែជជែកគ្នាប៉ុណ្ណឹង។ ប៉ុន្តែ ខ្ញុំហាក់ដូចជាបារម្ភថាគាត់នឹងបន្តនៅទីនោះ រហូតដល់ខ្ញុំបញ្ឆេះឡាន។ យើងបន្តជជែកគ្នា ដោយសង្ឃឹមថាគាត់នឹងលាខ្ញុំ ហើយខ្ញុំអាចបញ្ឆេះឡានចេញទៅភ្លាម នៅពេលដែលគាត់ដើរទៅ។ ប៉ុន្តែគាត់មិនបានដើរចេញឡើយ។ ជាចុងក្រោយ គាត់លាខ្ញុំមែន ប៉ុន្តែគាត់គ្រាន់តែថយទៅខាងក្រោយឡាន ហើយឈរនៅទីនោះ។ ខ្ញុំដឹងថាខ្ញុំគ្មានជម្រើសអ្វីផ្សេងឡើយ។ ខ្ញុំក៏បានបញ្ឆេះឡាន ដោយសង្ឃឹមថានៅលើកនេះវានឹងមិនបង្ហុយផ្សែងពណ៌ស ប៉ុន្តែបំណងរបស់ខ្ញុំមិនបានក្លាយជាការពិតទេ ព្រោះភ្លាមៗនោះឡានក៏បញ្ចេញផ្សែងសក្បុសរហូតដល់អាចធ្វើឲ្យភ្នែកអ្នករលាកបាន។

បុរសនោះក៏បានធ្វើសញ្ញាឲ្យខ្ញុំពន្លត់ម៉ាស៊ីនឡានយ៉ាងប្រញាប់ប្រញាល់។ គាត់បានដើរសំដៅមកបង្អួចឡានវិញ ហើយសុំឲ្យខ្ញុំលើកគម្របម៉ាស៊ីនឡើង។ គាត់ថែមទាំងពន្យល់មកកាន់ខ្ញុំថា គាត់ធ្វើការក្រៅម៉ោងជាជាងជួសជុសរថយន្ត ហើយគាត់ចង់ជួយពិនិត្យមើលឡានរបស់ខ្ញុំ។ មួយនាទីក្រោយមក គាត់ក៏ត្រលប់មកជួបខ្ញុំហើយនិយាយថា «ដូចដែលខ្ញុំបានស្មាន ឡាននេះខូចក្បាលកន្លាស់ប៊ីសស្តង់។ សូមបើកឡានទៅផ្ទះ ហើយជួសជុលវាភ្លាម។» ខ្ញុំក៏បានអរគុណគាត់នៅពេលដែលខ្ញុំបើកចេញទៅ ប៉ុន្តែខ្ញុំមិនចាប់អារម្មណ៍នឹងការពិនិត្យរបស់គាត់ទេ ព្រោះខ្ញុំគ្មានលុយដើម្បីជួសជុលឡាន។

ការិយាល័យរបស់ខ្ញុំនៅត្រឹមជាង ១០គីឡូម៉ែត្រពីផ្ទះអតិថិជននោះ ហើយនៅពេលដែលខ្ញុំបើកត្រលប់ទៅការិយាល័យវិញ អារម្មណ៍ខូចចិត្តដដែលក៏បានមកគ្របលើខ្ញុំម្តងទៀត។ ប៉ុន្តែនៅពេលដែលខ្ញុំកំពុងតែបើក ខ្ញុំក៏នឹកចាំពីអ្វីដែលព្រះអ

ម្ចាស់មានបន្ទូលមកកាន់ខ្ញុំ ហើយខ្ញុំចាប់ផ្ដើមនិយាយជាមួយព្រះអង្គនៅក្នុងឡាន ថា «ព្រះអម្ចាស់អើយ ខ្ញុំបានប្រាប់ហើយថាខ្ញុំមិនមានលុយជួសជុលឡាននេះទេ។ ខ្ញុំនៅតែជំពាក់លុយគេថ្លៃទិញឡាននេះ ហើយខ្ញុំមិនអាចលក់វាទាំងខូចអញ្ចឹងទេ។ ខ្ញុំគ្រាន់តែមិនដឹងថាត្រូវធ្វើអ្វីឡើយ។ ប្រហែលជាប្រសើរជាង ប្រសិនបើឡាននេះ ឆេះអស់ ព្រោះក្រុមហ៊ុនធានារ៉ាប់រងនឹងចេញថ្លៃខូចខាត ហើយខ្ញុំក៏នឹងលែងជិះ ឡានខូចនេះទៀតដែរ។»

ប្រហែលជា ៥ គីឡូម៉ែត្រពីការិយាល័យរបស់ខ្ញុំ ខ្ញុំបានឃើញមានពពុះនៅលើ គម្របឡាន ដែលខ្ញុំមិនបានឃើញនៅមុននោះ។ ខ្ញុំក៏តាមមើល ហើយឃើញថា ពពុះនោះបានរីកធំឡើងៗ រហូតដល់ពេលដែលខ្ញុំចតឡាននៅចំណតឯការិយា-ល័យ ពពុះនោះក៏បានផ្ទុះឡើងក្លាយជាពពុះដែលមានអណ្ដាតភ្លើង។ ខ្ញុំតក់ស្លុតណាស់ ហើយនៅពេលនេះ គម្របឡានខាងមុខមានអណ្ដាតភ្លើងឆាបឆេះឡើងរហូតដល់ជាង២ម៉ែត្រពីគម្របឡាន។ ខ្ញុំក៏បានរត់ទៅឯអគារការិយាល័យ ហើយទូរស័ព្ទទៅកាន់នាយកដ្ឋានឡានទឹកភ្លាម។ នៅថ្ងៃបន្ទាប់មក ឡាននោះត្រូវបានទូទាត់ដោយក្រុមហ៊ុនធានារ៉ាប់រង ហើយពួកគេបានចេញមូលប្បទានបត្រមួយដែលបានចេញសងថ្លៃឡានរួចរាល់ ហើយមាន ប្រាក់ខ្លះនៅសល់ដែលយើងអាចសងទៅកាន់មេធាវីដែលបានទូរស័ព្ទមកកាន់យើង នៅបីថ្ងៃមុននោះ។ ឌ្រិនដានិងខ្ញុំពិតជាស្ញប់ស្ញែងណាស់។ យើងមិនដឹងថាត្រូវគិត យ៉ាងណានោះទេ។ យើងបានដឹងថា ព្រះជាម្ចាស់បានធ្វើការសម្រាប់យើង ហើយ មានអ្វីម្យ៉ាងបានផ្លាស់ប្ដូរ។ ប៉ុន្តែ ការប្ដេជ្ញារបស់យើងចំពោះព្រះរាជ្យ នឹងត្រូវទទួល

**នៅត្រង់ចំណុចនេះ យើងបានបញ្ជាក់ពីខ្លួនយើងថា ប្រព័ន្ធរបស់ព្រះជាម្ចាស់ពិតជាដំណើរការមែន ហើយយើងបានប្ដេជ្ញាក្នុងការរៀន និងប្រើប្រាស់ប្រព័ន្ធរបស់ព្រះជាម្ចាស់ នៅក្នុងព្រះរាជ្យពីពេលនោះតទៅមុខ។**

ការល្បងលនៅក្នុងរបៀបថ្មីមួយដែលរៀបចំផ្លូវរបស់យើងក្នុងពេលជាច្រើនឆ្នាំខាងមុខ។

បន្ទាប់ពីឡានឆេះហើយ យើងពិតជារំភើបណាស់ ប៉ុន្តែក៏បានដឹងភ្លាមៗដែរថា យើងគ្មានឡានសម្រាប់ជិះឡើយ។ ទោះបីជាយើងទទួលសំណងថ្លៃឡាន ហើយសងក្រុមហ៊ុនប័ណ្ណឥណទាន និងមេធាវីនោះរួចរាល់ យើងគ្មានប្រាក់នឹងទិញឡានថ្មីទេ។ ដោយបានឮពីដំណឹងនៃការបាត់បង់ឡានរបស់យើង ឪពុករបស់ខ្ញុំក៏បានទូរស័ព្ទមកកាន់យើង ហើយប្រាប់យើងថាគាត់ចង់ជួយយើងទិញឡានថ្មី។ យើងពិតជារំភើបណាស់ នៅពេលដែលបានឮដំណឹងនេះ។ ដូច្នេះ ឪពុករបស់ខ្ញុំ ហើយនិងខ្ញុំក៏បានទៅក្រុមហ៊ុនលក់ឡាននៅក្នុងតំបន់ ហើយរកបានឡានមួយដែលឌ្រិនដានិងខ្ញុំពេញចិត្ត។ ឪពុករបស់ខ្ញុំនិយាយថា គាត់នឹងឲ្យប្រាក់ ៥០០០ ដុល្លារ ដើម្បីទិញឡាននេះ។ ដោយឡាននេះមានតម្លៃ ១៧០០០ ដុល្លារ ដូច្នេះមានន័យថា យើងត្រូវចេញ ១២០០០ ដុល្លារ។ ខ្ញុំបានបំពេញទម្រង់បែបបទខ្ចីប្រាក់ទិញរថយន្តទាំងស្វាក់ស្ទើរ ដោយមានឪពុករបស់ខ្ញុំចុះហត្ថលេខាជាមួយ។ ពួកគេប្រាប់ថានឹងផ្ដល់ដំណឹងដល់ខ្ញុំនៅពេលព្រឹកបន្ទាប់។

នៅយប់នោះយើងគេងមិនលក់ឡើយ។ យើងបានដឹងថា យើងមិនមានលទ្ធភាពសងប្រាក់កម្ចីនោះទេ។ ព្រះអម្ចាស់ទើបតែបានមានបន្ទូលមកកាន់ខ្ញុំពីការធ្វើរឿងបែបនេះ។ ប៉ុន្តែ បើគ្មានឡានទេ នោះខ្ញុំកាន់តែរងសម្ពាធក្នុងការចុះញ៉ម ហើយបោះបង់ចោល។ បន្ទាប់ពីរាត្រីដែលយើងមិនបានលក់និទ្រាសោះ ឌ្រិនដានិងខ្ញុំបានព្រមព្រៀងគ្នាថា យើងមិនអាចចុះហត្ថលេខាលើទម្រង់បែបបទខ្ចីប្រាក់បានទេ។ ខ្ញុំបានទូរស័ព្ទទៅប៉ារបស់ខ្ញុំ ហើយក៏អរគុណគាត់សម្រាប់ទឹកចិត្តដ៏សប្បុរសរបស់គាត់ ប៉ុន្តែខ្ញុំបានប្រាប់គាត់ថាយើងពុំអាចទទួលបានទេ។ បន្ទាប់មក ខ្ញុំក៏បានទូរស័ព្ទទៅក្រុមហ៊ុនលក់ឡាន ហើយប្រាប់ពួកគេដូចគ្នា។ ពួកគេក៏បានខកចិត្តដែរ ព្រោះកម្ចីត្រូវបានអនុម័តនៅព្រឹកនោះ ហើយគេត្រៀមឡានដើម្បីឲ្យយើងទៅទទួល

ហើយ។ ទោះបីជាយើងគ្មានតម្រុយអ្វីសោះពីរបៀបដែលព្រះជាម្ចាស់នឹងជួយដល់យើងឲ្យមានឡាន យើងក៏មានអារម្មណ៍សុខសាន្តអំពីការសម្រេចចិត្តនោះដែរ។

នៅក្នុងពេលនោះឌ្រិនដាបានលក់វត្ថុបុរាណមួយចំនួនដែលនាងបានទិញពីការលក់ឡៃឡុង។ នាងបានទុកសារមួយឲ្យបុរសម្នាក់ អំពីការទិញគ្រឿងសង្ហារឹមដែលដាក់តាំងតាមបន្ទប់ៗ ដែលគាត់បានដាក់លក់មួយខែមុនពេលដែលឡានឆេះ ប៉ុន្តែមិនដែលបានទាក់ទងគាត់បានសោះ។ ប៉ុន្មានថ្ងៃបន្ទាប់ពីឡានឆេះ គាត់បានទូរស័ព្ទមក ហើយព្រមលក់គ្រឿងសង្ហារឹមដែលមានពេញនៅក្នុងបន្ទប់បីធំៗឲ្យទៅឌ្រិនដាក្នុងតម្លៃក្រោម ១000ដុល្លារ។ បន្ទាប់មក ឌ្រិនដាក៏បានធ្វើការព្រមព្រៀងជាមួយនឹងក្រុមហ៊ុនលក់ដេញថ្លៃ ដើម្បីលក់គ្រឿងសង្ហារឹមឲ្យនាង ហើយនាងអាចចរចារពីកម្រៃជើងសារដែលនាងត្រូវទទួលបានពីការដេញថ្លៃ។ សម្រាប់កម្រៃជើងសារ ជាជាងទទួលជាសាច់ប្រាក់ នាងបានចរចារថាយកឡានមួយទឹកដែលមានគុណភាពល្អរបស់ក្រុមហ៊ុននោះ។ ដូច្នេះ នៅពេលនោះយើងក៏រួចពីបំណុលឡានសងក្រុមហ៊ុនប័ណ្ណឥណទាន និងរួចពីកម្ចីទិញឡានមួយទៀតដែរ។

អស្ចារ្យណាស់! នេះជារបៀបដែលព្រះរាជ្យដំណើរការ។ នៅត្រង់ចំណុចនេះ យើងបានបញ្ជាក់ពីខ្លួនយើងថា ប្រព័ន្ធរបស់ព្រះជាម្ចាស់ពិតជាដំណើរការមែន ហើយយើងបានប្តេជ្ញាក្នុងការរៀន និងប្រើប្រាស់ប្រព័ន្ធរបស់ព្រះជាម្ចាស់នៅក្នុងព្រះរាជ្យពីពេលនោះតទៅមុខ។ លោកអ្នកប្រហែលជាចោទសួរថា «តើយើងបានប្រើប្រាស់គោលការណ៍បែបណា?» គោលការណ៍ធំជាងគេគឺជាការដែលមិនទុកចិត្តលើបំណុល ប៉ុន្តែអរព្រះគុណព្រះជាម្ចាស់សម្រាប់អ្វីដែលយើងត្រូវការ និងអនុញ្ញាតឲ្យទ្រង់បង្ហាញយើងពីរបៀបច្រូតកាត់វា។

ឧប្បទ្ទវហេតុរថយន្តបានធ្វើឲ្យខ្ញុំចាប់អារម្មណ៍ ហើយក៏បណ្តាលឲ្យមានឧប្បទ្ទវហេតុមួយទៀតកើតឡើងនៅពីរបីខែមុននោះ ប៉ុន្តែនៅពេលនោះ ខ្ញុំមិនបានយល់នូវអ្វីដែលព្រះជាម្ចាស់កំពុងតែបង្ហាញមកកាន់ខ្ញុំឡើយ។ នៅក្នុងចិត្តគំនិតខ្ញុំមិនបានយល់ពីតម្រុយនៃគោលការណ៍នៅក្នុងព្រះរាជ្យសោះឡើយ។

ខ្ញុំចូលចិត្តបរបាញ់សត្វក្ដាន់ ប៉ុន្តែជាច្រើនឆ្នាំនេះ ខ្ញុំបានបរបាញ់ទាំងដៃទទេ។ ខ្ញុំធ្លាប់បានចេញទៅបរបាញ់ អង្គុយនៅក្រោមអាកាសធាតុត្រជាក់ ហើយទៅបរបាញ់ជាច្រើនថ្ងៃ ដោយពុំបានប្រទះអ្វីសោះ។ វាមិនមែនដោយសារតែខ្ញុំចូលចិត្តបរបាញ់ទេ ប៉ុន្តែដោយសារខ្ញុំមានកូនតូចៗដែលខ្ញុំត្រូវចិញ្ចឹម ហើយក៏ត្រូវការសាច់សត្វដែរ។ ទោះបីជាខ្ញុំធ្លាប់បានទទួលជោគជ័យខ្លះពីមុន តែវាបានកើតឡើងជាច្រើនឆ្នាំមកហើយ។ ខ្ញុំកម្រនឹងមានរដូវកាលណាមួយដែលបរបាញ់ដោយបានជោគជ័យ ហើយយកសាច់សត្វមកផ្ទះណាស់។ ថ្ងៃមួយ នៅពេលដែលខ្ញុំកំពុងតែគិតពីរដូវបរបាញ់ក្ដាន់ដែលកាន់តែខិតជិតមកដល់ ខ្ញុំបានឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ថា «ហេតុអ្វីបានជាកូនមិនឲ្យយើងបង្ហាញកូនពីរបៀបដែលយើងអាចប្រទានសត្វក្ដាន់ដល់កូននៅឆ្នាំនេះ?» តើនោះមានន័យដូចម្ដេច? នៅពេលអធិស្ឋានពីព្រះបន្ទូលទាំងនេះ ខ្ញុំមានអារម្មណ៍ពេញចិត្តពីការដែលបានសាបព្រោះគ្រាប់ពូជខាងផ្នែកថវិកា ឬអំណោយណាមួយក្នុងគោលបំណងបរបាញ់ឲ្យបានសត្វក្ដាន់នោះ។ ខ្ញុំមានអារម្មណ៍ថាព្រះអម្ចាស់មានបន្ទូលមកកាន់ខ្ញុំថា នៅពេលដែលខ្ញុំសាបព្រោះសម្រាប់សត្វក្ដាន់ នោះខ្ញុំត្រូវជឿថាខ្ញុំបានទទួលវាមុនដែលខ្ញុំពិតជាបានវាទៅទៀត ដោយយោងតាមគម្ពីរម៉ាកុស ១១៖២៤៖

> *ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្វីក៏ដោយ ឲ្យតែអ្នករាល់គ្នាអធិស្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជាម្ចាស់នឹងប្រទានឲ្យអ្នករាល់គ្នាជាពុំខាន។*

ថ្វីបើជាគ្រិស្តបរិស័ទ ខ្ញុំបានតែងតែថ្វាយ និងគាំទ្រដល់ក្រុមជំនុំរបស់ខ្ញុំ តែការសាបព្រោះដោយមានចេតនា និងគោលបំណងច្បាស់លាស់ ហើយជឿថាខ្ញុំបានទទួលនៅពេលដែលខ្ញុំអធិស្ឋាន ជារឿងមួយដ៏ថ្មីសម្រាប់ខ្ញុំ។ ខ្ញុំបានចេញមូលប្ប

ទានបត្រមួយ ហើយសរសេរថា «សម្រាប់សត្វក្ដាន់របស់ខ្ញុំនៅឆ្នាំ១៩៨៧»។ ខ្ញុំបាន ដាក់ដៃលើវា ហើយផ្ញើវាទៅកាន់ព័ន្ធកិច្ចមួយដែលខ្ញុំបានទុកចិត្តលើ ព្រមទាំង ប្រកាសថាខ្ញុំទើបតែបានទទួលក្ដាន់របស់ខ្ញុំ នៅពេលដែលខ្ញុំផ្ញើវាទៅ។ ដោយរស់ នៅក្នុងក្រុងថុលសា (Tulsa) រដ្ឋអូក្លាហូម៉ាជាទីក្រុងមួយដែលពុំសូវជឿនលឿននៅ សម័យនោះ ខ្ញុំពុំសូវមានកន្លែងដើម្បីបរបាញ់ទេ ប៉ុន្តែមានមិត្តភក្តិរបស់ខ្ញុំម្នាក់ពីក្រុម ជំនុំ បានអញ្ជើញខ្ញុំឲ្យទៅផ្ទះលោកយាយរបស់គាត់នៅឯជនបទដើម្បីចូលរួមបុណ្យ ដឹងគុណ (Thanksgiving)។ គាត់បាននិយាយថា មានក្ដាន់ពីរបីក្បាលនៅក្បែរៗ ផ្ទះ។ ដូច្នេះ ក្រុមគ្រួសាររបស់យើងក៏បានធ្វើដំណើរនៅពេលព្រឹកនាថ្ងៃបុណ្យដឹង គុណ ដើម្បីចូលរួម និងរីករាយថ្ងៃដែលមានអាហារសម្បូណ៌ហូរហៀរ និងការរួម ប្រកបគ្នាហើយក៏ទៅបរបាញ់សត្វក្ដាន់ដែរ។

មិត្តភក្តិរបស់ខ្ញុំមិនបានដឹងថា គាត់ត្រូវប្រាប់ខ្ញុំថាគួរទៅកន្លែងណាទេ ប៉ុន្តែ មានវាលស្មៅមួយដែលមានព្រៃនៅជុំវិញ ហើយគាត់បានឲ្យយោបល់ថា ខ្ញុំទៅឯ វាលស្មៅនោះ ហើយអង្គុយនៅក្បែរដើមឈើធំមួយដែលនៅទីនោះ។ មកដល់ត្រឹម នេះ ខ្ញុំចង់ឲ្យលោកអ្នកយល់ពីរូបភាពនោះ។ ខ្ញុំកំពុងអង្គុយនៅលើវាលស្មៅដែល មានចំបើង ដោយសារស្មៅនៅទីនោះត្រូវគេកាត់ ហើយមានដើមឈើធំមួយនៅចំ កណ្ដាល។ ដូច្នេះ ខ្ញុំបានអង្គុយចុះដោយផ្អែកខ្នងទៅនឹងដើមឈើនោះ ហើយបែរ មុខទៅរកព្រៃដែលមានចម្ងាយប្រមាណជា១២០ម៉ែត្រពីខ្ញុំ។ នៅពេលដែលខ្ញុំគិត អំពីស្ថានភាពនោះ ខ្ញុំគឺគ្រាន់តែអង្គុយនៅក្បែរដើមឈើលើវាលស្មៅមួយ។ នេះមិន មែនជាស្ថានការណ៍ដ៏សមគួរឡើយ។

ខ្ញុំអង្គុយបានប្រមាណជា ៣០ ទៅ ៤០ នាទីនៅពេលព្រឹកនោះ ដោយខ្ញុំពុំបាន ដឹងខ្លួន មានសត្វក្ដាន់មួយក្បាលបានរត់កាត់វាលពីក្រោយខ្ញុំសំដៅទៅក្នុងព្រៃនៅ ខាងមុខខ្ញុំ។ មានដើមឈើនៅចន្លោះរវាងខ្ញុំនិងក្ដាន់ ដូច្នេះវាមិនឃើញខ្ញុំ ហើយខ្ញុំក៏ មិនបានឃើញវាដែរ។ សត្វក្ដាន់បានរត់តម្រង់ទៅរកដើមឈើ ដែលនៅតាមផ្លូវរបស់ វាឆ្ពោះទៅឯព្រៃ ដោយមិនបានឃើញខ្ញុំអង្គុយនៅទីនោះឡើយ។ នៅពេលដែលក្ដាន់

នោះបានរត់មកដល់ដើមឈើនោះ វាបានដឹងក្លិនរបស់ខ្ញុំ ហើយក៏ឈប់ដោយចង់ដឹងថាខ្ញុំនៅឯណា។ សត្វក្ដាន់ក៏បានមើលនៅជុំវិញដើមឈើ ហើយវាឃើញខ្ញុំ ខ្ញុំក៏ឃើញវានៅពេលព្រមគ្នា ក្នុងចម្ងាយប្រមាណជា៥ម៉ែត្រពីគ្នាប៉ុណ្ណោះ។ ខ្ញុំមិនប្រាកដថា នរណាភ្ញាក់ជាងនរណាទេ ប៉ុន្តែដោយមិនបង្អង់យូរ ក្ដាន់នោះបានរត់ដោយល្បឿនលឿនបំផុតតាមដែលវាអាចធ្វើបាន។ ដោយបញ្ចេញខ្យល់យ៉ាងឮតាមច្រមុះ វាបានរត់សំដៅទៅក្នុងព្រៃយ៉ាងពេញទំហឹង។ ខ្ញុំនៅតែអង្គុយនៅទីនោះដោយរាវរកកាំភ្លើង ហើយព្យាយាមមើលវានៅក្នុងកែវយឺតកាំភ្លើង ខណៈដែលសត្វក្ដាន់រត់យ៉ាងពេញទំហឹងពីខ្ញុំទៅ។

នៅពេលនេះ ការដែលព្យាយាមតម្រង់ទៅសត្វក្ដាន់កន្ទុយសដែលកំពុងរត់យ៉ាងពេញទំហឹង ហើយធ្វើការបាញ់ព្រាវ មិនមែនជារឿងងាយស្រួលឡើយ។ និយាយតាមការពិត ខ្ញុំមិនធ្លាប់បាញ់ក្ដាន់ដែលកំពុងរត់ពីមុនឡើយ។ ខ្ញុំចាំបានច្បាស់ថា ខ្ញុំសឹងតែមិនអាចឆ្លុះសត្វក្ដាន់នោះជាប់ក្នុងកែវយឺតកាំភ្លើង នៅពេលដែលវាកំពុងតែលោតយ៉ាងខ្ពស់ ព្រោះសត្វក្ដាន់កន្ទុយសតែងធ្វើដូច្នេះនៅពេលដែលរត់ពេញទំហឹង។ ប៉ុន្តែ នៅពេលដែលខ្ញុំកេះកៃ ក្ដាន់នោះក៏ដួលចុះ ហើយមិនកម្រើកឡើយ។ ខ្ញុំតក់ស្លុតណាស់! វាបានកើតឡើងត្រឹមតែមួយពព្រិចភ្នែក។ នៅពេលដែលខ្ញុំវាស់ក៏ឃើញថា កន្លែងដែលខ្ញុំបាញ់ត្រូវវានោះមានចម្ងាយប្រមាណ១០០ម៉ែត្រ។

នៅពេលឮស្នូរកាំភ្លើង មិត្តភក្តិរបស់ខ្ញុំក៏បានចេញមកហើយសាទរនឹងខ្ញុំដែលបាញ់បានសត្វក្ដាន់ កាលដែលគាត់បានឃើញវាដេកស្ដូកស្ដឹងនៅទីនោះ។ ខ្ញុំមិនទាន់បានប្រាប់មិត្តភក្តិរបស់ខ្ញុំនូវអ្វីដែលព្រះអម្ចាស់បានមានបន្ទូលមកកាន់ខ្ញុំអំពីរបៀបដែលខ្ញុំនឹងទទួលបានក្ដាន់នោះឡើយ ប៉ុន្តែនៅពេលនោះខ្ញុំក៏មើលមុខគាត់ហើយថា «ខ្ញុំគិតថា ខ្ញុំបាញ់បានសត្វក្ដាន់នេះមិនមែនដោយសារសមត្ថភាពប្រមាញ់ដ៏ជំនាញរបស់ខ្ញុំទេ»។ បន្ទាប់មក ខ្ញុំក៏ដកយកក្រដាសមួយសន្លឹកដែលខ្ញុំបានសរសេរនៅថ្ងៃដែលខ្ញុំបានផ្ញើមូលប្បទានបត្រចេញពីអាវបរបាញ់របស់ខ្ញុំ។ ខ្ញុំ

គ្រាន់តែបានសរសេរថា «ខ្ញុំជឿថា ខ្ញុំបានទទួលក្តាន់របស់ខ្ញុំនៅឆ្នាំ ១៩៨៧ នៅក្នុងព្រះនាមព្រះយេស៊ូ។» ខ្ញុំបានដាក់កាលបរិច្ឆេទ និងពេលវេលាដែលខ្ញុំបានអធិស្ឋានបែបនោះដែរ។ ខ្ញុំក៏បានលើកយកក្រដាសមកបង្ហាញមិត្តរបស់ខ្ញុំ ដើម្បីឲ្យគាត់បានឃើញ ហើយក៏បានចាប់ផ្តើមប្រាប់គាត់អំពីអ្វីដែលព្រះអម្ចាស់បានប្រាប់ខ្ញុំឲ្យធ្វើ។

ហេតុការណ៍នេះបានទាក់ទាញចំណាប់អារម្មណ៍របស់ខ្ញុំ។ ខ្ញុំដឹងយ៉ាងប្រាកដថាគឺមកពីព្រះជាម្ចាស់។ ប៉ុន្តែមិនដឹងជាយ៉ាងម៉េច ខ្ញុំមិនយល់ថាខ្ញុំកំពុងប្រើប្រាស់ច្បាប់នៃព្រះរាជ្យ។ តាមពិតពាក្យថា «ព្រះរាជ្យ» មិនទាន់ជាពាក្យដែលខ្ញុំបានគិតដល់នៅឡើយទេ។ ការប្រមាញ់បានក្តាន់នោះជារឿងដ៏អស្ចារ្យ ប៉ុន្តែតើវានឹងកើតឡើងម្តងទៀតដែរឬទេ? ប្រសិនបើមិនបានយល់ពីច្បាប់នៃព្រះរាជ្យទេ ខ្ញុំក៏មិនដឹងពីរបៀប ឬច្បាប់អ្វីដែលបាននាំឲ្យក្តាន់បង្ហាញខ្លួនដែរ។ ដូច្នេះ ខ្ញុំក៏បានកត់ចំណាំវាទុកថាមកពីព្រះជាម្ចាស់ ហើយក៏ចង់ធ្វើការសាកល្បងម្តងទៀតដែរ នៅរដូវប្រមាញ់សត្វក្តាន់នៅឆ្នាំក្រោយ។ ប៉ុន្តែ មុនពេលដែលរដូវកាលនោះចូលមកដល់ ឡានក៏ឆេះអស់។ នៅពេលដែលឡានឆេះអស់ ហើយខ្ញុំទទួលបានឡានមួយទៀតដោយឥតគិតថ្លៃ ព្រះជាម្ចាស់បានឲ្យខ្ញុំចាប់អារម្មណ៍លើទ្រង់ទាំងស្រុង។ នៅពេលនេះ ខ្ញុំពិតជារំភើបក្នុងការដេញតាមក្តាន់របស់ខ្ញុំនៅឆ្នាំក្រោយណាស់។ ខ្ញុំចង់សាកល្បងនូវទ្រឹស្តីរបស់ខ្ញុំ និងរៀនថែមទៀតអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ រដូវសត្វក្តាន់នៅមិនយូរទៀតឡើយ!

ខ្ញុំបាញ់បានសត្វក្តាន់ទីមួយនោះនៅរដ្ឋអូក្លាហូម៉ា នារដូវស្លឹកឈើជ្រុះឆ្នាំ ១៩៨៧។ ប៉ុន្តែនៅខែកក្កដា ឆ្នាំ១៩៨៨ យើងបានរើផ្ទះទៅរស់នៅរដ្ឋអូហៃយ៉ូ ជាកន្លែងដែលខ្ញុំធ្លាប់រស់នៅកាលពីតូច។ ទោះបីជាខ្ញុំបានធំធាត់ឡើងនៅទីនោះក្តី តែខ្ញុំបានចាកចេញពីទីនោះនៅជាង១២ឆ្នាំមុន។ នៅពេលដែលខ្ញុំធំឡើងនៅទីនោះ ខ្ញុំមិនដែលប្រមាញ់ក្តាន់នៅរដ្ឋអូហៃយ៉ូបានសម្រេចឡើយ។ ទោះបីជាខ្ញុំបានព្យាយាមប្អូនដប់ដងក៏ដោយ ក៏ខ្ញុំបាញ់មិនដែលត្រូវសូម្បីតែម្តង។ នៅពេលដែលយើងបានរៀបចំឥវ៉ាន់រួចរាល់នៅក្នុងផ្ទះល្វែងដែលយើងបានជួលនៅរដ្ឋអូហៃយ៉ូហើយ ខ្ញុំបាន

យល់ថា ខ្ញុំមិនស្គាល់កន្លែងបរបាញ់ទេ។ កាលនៅពីក្មេង ខ្ញុំបានបរបាញ់ទន្សាយនៅក្បែរផ្ទះឪពុករបស់ខ្ញុំ គឺនៅតាមអូរនៅជិតនោះ។ ខ្ញុំបានដាក់អន្ទាក់ក្នុងពេលប៉ុន្មានឆ្នាំកាលនៅពីតូច តែខ្ញុំមិនធ្លាប់បានឃើញក្តាន់ ឬតម្រុយណាមួយដែលបង្ហាញថាមានក្តាន់នៅក្នុងតំបន់នោះឡើយ។ មានថ្ងៃមួយ ពេលដែលខ្ញុំនៅរៀនឯមហាវិទ្យាល័យ បងប្រុសរបស់ខ្ញុំបានទូរស័ព្ទមកខ្ញុំទាំងរំភើប។ គាត់និយាយថាគាត់បានឃើញសត្វក្តាន់មួយក្បាលនៅតាមបណ្តោយអូរក្បែរផ្ទះរបស់ឪពុកខ្ញុំ។ យើងទាំងពីរនាក់បានភ្ញាក់ផ្អើលគួរសម។

ដោយនឹកចាំពីការសន្ទនានោះ ខ្ញុំបានសម្រេចចិត្តថានឹងដើរទៅផ្នែកដែលមានដីទំនាបនៅថ្ងៃដំបូងនៃរដូវបរបាញ់។ ខ្ញុំបានទូរស័ព្ទទៅបងប្រុសរបស់ខ្ញុំ ហើយសុំដំបូន្មានពីគាត់ពីកន្លែងដែលគួរទៅនៅតាមអូរនោះ។ ទោះបីជាគាត់បានចាកចេញពីតំបន់នោះពីរបីឆ្នាំមកហើយ គាត់ពិតជាចាំនូវដើមម៉ាផលធំមួយដែលដុះនៅមាត់អូរអមជាមួយនឹងដើមឈើផ្សេងៗទៀតនៅក្នុងព្រៃ ហើយគិតថានោះអាចជាកន្លែងដ៏ល្អ។ ដោយហេតុថា ខ្ញុំបានដើរចុះឡើងៗនៅឯអូរនោះកាលពីនៅតូច ខ្ញុំស្គាល់ពីគ្រប់ច្រកល្ហកនៅឯអូរនោះ ហើយក៏យល់ច្បាស់ថាគាត់ចង់ឲ្យខ្ញុំទៅណាដែរ។

ឌ្រិនដានិងខ្ញុំបានពហុគុណនូវអ្វីដែលព្រះជាម្ចាស់បានបង្ហាញមកកាន់យើងនៅក្នុងឆ្នាំមុន កាលដែលយើងនៅរដ្ឋអូក្លាហូម៉ា គឺសាបព្រោះគ្រាប់ពូជ ហើយសរសេរវាទុក ព្រមទាំងជឿថាយើងបានទទួលនៅពេលដែលយើងអធិស្ឋាន ដោយយោងតាមគម្ពីរម៉ាកុស ១១៖២៤។ នៅពេលនោះ រដ្ឋអូហៃយ៉ូមានច្បាប់កំណត់ឲ្យប្រមាញ់បានក្តាន់ត្រឹមតែពីរប៉ុណ្ណោះ ទាំងក្តាន់ញី និងក្តាន់ឈ្មោល ប៉ុន្តែយើងគិតថាយើងសាបព្រោះសម្រាប់តែក្តាន់មួយក្បាល ហើយចាំចេញទៅបាញ់ក្តាន់មួយទៀតនៅពេលក្រោយ។ ឌ្រិនដានិងខ្ញុំបានសាបព្រោះគ្រាប់ពូជសម្រាប់សត្វក្តាន់ ហើយជឿថាយើងបានទទួលនៅពេលដែលយើងអធិស្ឋាន។ អស្ចារ្យណាស់ នៅក្នុងពេល ៤០នាទីនៃព្រឹកថ្ងៃទីមួយនៃរដូវបរបាញ់សត្វក្តាន់ ខ្ញុំមិនបានបាញ់បានមួយទេ គឺបាញ់បានដល់ទៅពីរ។ យើងបានរកឃើញគោលការណ៍អស្ចារ្យមែន!

មួយខែក្រោយមក ខ្ញុំបានយល់សប្តិអំពីគំនិតអាជីវកម្មមួយ។ អាជីវកម្មនេះគឺអាចប្រើប្រាស់នូវចំណេះដឹងហិរញ្ញវត្ថុទាំងប៉ុន្មានដែលខ្ញុំបានទទួលពីអាជីវកម្មធានារ៉ាប់រង ប៉ុន្តែនៅក្នុងសុបិននោះវាមានគោលបំណងផ្សេង។ ខ្ញុំមិនសូវយល់ពីវាទាំងស្រុងទេ ប៉ុន្តែខ្ញុំប្រាកដថាព្រះជាម្ចាស់កំពុងតែដឹកនាំខ្ញុំឲ្យចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួន ហើយចាកចេញពីក្រុមហ៊ុនដែលខ្ញុំបានធ្វើការរយៈពេល៨ឆ្នាំនោះ។ នៅពេលដែលខ្ញុំយល់សុបិននេះ ខ្ញុំនៅតែធ្វើការជាអ្នកលក់ធានារ៉ាប់រង និងសន្តិសុខជីវិតនៅឡើយ។

នៅសប្តាហ៍ដែលខ្ញុំបានយល់សប្តិ ខ្ញុំបានមានផែនការទៅជួបនឹងក្រុមគ្រួសារមួយដើម្បីនិយាយពីការធានារ៉ាប់រង ហើយទោះបីជាយើងបាននិយាយពីការធានារ៉ាប់រងអាយុជីវិតក្តី ខ្ញុំបានដឹងថាតម្រូវការ ឬបញ្ហាពិតប្រាកដរបស់ពួកគេគឺមិនមែនជាការធានារ៉ាប់រងអាយុជីវិតទេ។ ពួកគេមានបញ្ហាថវិកាប្រចាំខែ ហើយក៏ជំពាក់បំណុលគេដែរ។ ផ្នែកមួយនៃការរៀបផែនការជាធម្មតារបស់ខ្ញុំសម្រាប់អតិថិជន គឺសូមឲ្យពួកគេបំពេញបញ្ជីទិន្នន័យមួយដែលមានទិន្នន័យហិរញ្ញវត្ថុរបស់ពួកគេនៅលើនោះ។ ដោយធ្វើបែបនេះអាចឲ្យខ្ញុំគណនាដឹងថា ពួកគេត្រូវការប័ណ្ណធានារ៉ាប់រងអាយុជីវិតដែលមានតម្លៃប៉ុន្មាន។ នៅយប់នោះ ខ្ញុំពិបាកចិត្តសម្រាប់ក្រុមគ្រួសារនោះណាស់។ ខ្ញុំចង់ជួយពួកគេ ប៉ុន្តែខ្ញុំមិនដឹងជួយដោយរបៀបណា។ ខ្ញុំក៏អង្គុយចុះ ដោយមើលទិន្នន័យរបស់ពួកគេ ហើយក៏បានចាប់ផ្តើមរិះរកជម្រើសខ្លះៗ។ នៅពេលដែលខ្ញុំធ្វើការជាមួយនឹងម៉ាស៊ីនគិតលេខហិរញ្ញវត្ថុរបស់ខ្ញុំ ខ្ញុំបានប្តូរពីការគិតបែបធានារ៉ាប់រងអាយុជីវិត ហើយចាប់ផ្តើមរិះរកវិធីជួយពួកគេពួកគេឲ្យមានភាពធូរស្រាលនៅលើគម្រោងថវិកាប្រចាំខែ ដោយកាត់

**ខ្ញុំបានភ្ញាក់ផ្អើលណាស់ដោយព្រោះក្រុមគ្រួសារនេះអាចចាកចេញផុតពីបំណុលនៅក្នុងពេលមិនដល់ ៧ ឆ្នាំផង រួមទាំងបំណុលផ្ទះរបស់ពួកគេ ដោយមិនចាំបាច់បង្កើនប្រាក់ចំណូល។**

បន្ថយការចំណាយមួយចំនួន។ តាមរយៈការរៀបចំចំណុចពីរបី ហើយលេងជាមួយម៉ាស៊ីនគិតលេខ ខ្ញុំបានភ្ញាក់ផ្អើលណាស់ដោយព្រោះក្រុមគ្រួសារនេះអាចចាកចេញផុតពីបំណុលនៅក្នុងពេលមិនដល់៧ឆ្នាំផង រួមទាំងបំណុលផ្ទះរបស់ពួកគេ ដោយមិនចាំបាច់បង្កើនប្រាក់ចំណូល។

នៅត្រង់ចំណុចនេះ ខ្ញុំបានធ្វើការនៅលើវិស័យហិរញ្ញវត្ថុជាង ៨ ឆ្នាំមកហើយ ហើយខ្ញុំមិនដែលឮនរណាម្នាក់និយាយថា ការនេះអាចកើតឡើងរួចទេ។ ខ្ញុំបានគិតគូរពីករណីនេះចុះឡើងៗតាមរបៀបផ្សេងៗ ហើយនៅតែឃើញចម្លើយដដែលគឺៈ ក្នុងពេល ៦.២ឆ្នាំ ពួកគេអាចនឹងមានសេរីភាពពីបំណុលទាំងស្រុង។ បន្ទាប់មក ខ្ញុំក៏បានទៅបើកទូរដាក់ឯកសារ ហើយចាប់ផ្ដើមមើលទិន្នន័យរបស់អតិថិជនដទៃទៀត។ ខ្ញុំបានធ្វើការគណនាដដែល ហើយក៏រកឃើញចម្លើយដដែលគឺៈ មិនដល់ ៧ ឆ្នាំទេ ពួកគេអាចនឹងចេញពីបំណុលបាន។ និយាយតាមត្រង់ ខ្ញុំពិតជាភ្ញាក់ផ្អើលណាស់ពេលបានឃើញទិន្នន័យនេះ។

ខ្ញុំគិតថា អតិថិជនរបស់ខ្ញុំនឹងទទួលការលើកទឹកចិត្តនៅពេលឃើញចម្លើយនេះ ដូច្នេះ ខ្ញុំក៏បានវាយអត្ថបទជាបទបង្ហាញដ៏ស្អាតមួយ ហើយបង្ហាញនូវអ្វីដែលខ្ញុំបានរកឃើញនៅពេលដែលខ្ញុំជួបពួកគេទាក់ទងនឹងតម្រូវការធានារ៉ាប់រងអាយុជីវិតរបស់ពួកគេ។ ខ្ញុំពិតជាមានអារម្មណ៍សោកស្ដាយសម្រាប់ក្រុមគ្រួសារនេះណាស់។ ខ្ញុំបានដឹងថា ភាពតានតឹងខាងផ្នែកថវិកាបានប៉ះពាល់ដល់គ្រប់ផ្នែកទាំងអស់នៃជីវិតរបស់យើង ហើយក៏ចង់ឲ្យពួកគេដឹងថាពុំទាន់អស់សង្ឃឹមត្រឹមហ្នឹងទេ។ ដូច្នេះ ខ្ញុំក៏បានធ្វើបទបង្ហាញនូវអ្វីដែលខ្ញុំបានវាយបញ្ចូលក្នុងកុំព្យូទ័រទៅកាន់អតិថិជន ហើយនៅពេលដែលខ្ញុំបង្ហាញពីតួលេខ ពួកគេអង្គុយនៅទីនោះទាំងស្រឡាំងកាំង។ បន្ទាប់ពីខ្ញុំបានបង្ហាញពួកគេថាពួកគេអាចមានសេរីភាពពីបំណុលបានលឿនប៉ុណ្ណា បុរសជាប្ដីបានក្រោកឈរឡើងទាំងមានទឹកភ្នែករលីងរលោង ហើយចាប់ផ្ដើមអរគុណខ្ញុំ។ តាមពិតទៅ វាដូចជាកម្មវិធីទូរទស្សន៍ដែលលោកអ្នកឃើញក្រុមគ្រួសារមួយត្រូវឆ្នោត ឬរង្វាន់ធំនៅលើល្បែងកម្សាន្តណាមួយ។ ពួកគេសឹងតែមិន

ជឿពីអ្វីដែលខ្ញុំបានកំពុងតែប្រាប់ដល់ពួកគេ។ វាជាបទពិសោធន៍ដ៏រំជួលចិត្តមួយសម្រាប់ពួកគេ ហើយក៏សម្រាប់ខ្ញុំដែរ។

នៅពេលដែលខ្ញុំគិតពិចារណាពីល្ងាចនោះ ខ្ញុំនៅតែមានគំនិតថា ការដែលអាចគ្រាន់តែរៀបចំនូវទ្រព្យសម្បត្តិ និងតួលេខរបស់អតិថិជន ខ្ញុំអាចបង្ហាញពួកគេពីរបៀបរួចផុតពីបំណុលក្នុងពេលមិនដល់ ៧ឆ្នាំ។ ខ្ញុំបានឃើញពីឥទ្ធិពល និងសេចក្តីសង្ឃឹមដែលវាបានផ្តល់ដល់ពួកគេ។ ខ្ញុំក៏បានស៊ើរើឯកសារអតិថិជនភាគច្រើនដើម្បីពិនិត្យមើលថាតើមានអតិថិជនប៉ុន្មាននាក់ដែលអាចរាប់បញ្ចូលជា «អ្នកដែលមានសេរីភាពពីបំណុលក្នុងពេលមិនដល់៧ឆ្នាំ» នោះ ហើយក៏ភ្ញាក់ផ្អើលដោយឃើញថា ៨៥% នៃអតិថិជនរបស់ខ្ញុំស្ថិតក្នុងក្រុមមនុស្សនោះ។ ប៉ុន្តែ តើនរណានឹងប្រាប់ពួកគេពីការនេះ? បន្ទាប់ពីយប់ដែលខ្ញុំបានប្រជុំជាមួយអតិថិជន ហើយបន្ទាប់ពីបានស៊ើរើឯកសាររបស់អតិថិជនចាស់ៗជាច្រើននាក់មក ខ្ញុំបានទទួលស្គាល់ថា ខ្ញុំអាចចាប់ផ្តើមអាជីវកម្មមួយដោយបង្ហាញមនុស្សពីរបៀបរួចផុតពីបំណុលជាមួយនឹងផែនការរបស់ខ្ញុំ។

នៅពេលនោះ ខ្ញុំមិនទាន់មានសេរីភាពពីបំណុលខ្លួនឯងផង ប៉ុន្តែខ្ញុំពិតជាអាណិតអាសូរអ្នកដែលមានអារម្មណ៍តានតឹងខាងផ្នែកថវិកា ហើយបេសកកម្មនេះទាក់ទាញចិត្តខ្ញុំខ្លាំងជាងការលក់ធានារ៉ាប់រងអាយុជីវិត។ ខ្ញុំក៏បានចាប់ផ្តើមបង្ហាញអតិថិជនធានារ៉ាប់រងរបស់ខ្ញុំនូវលិខិតស្នាមបែបដដែល ហើយពួកគេគ្រប់ៗរូបសុទ្ធតែភ្ញាក់ផ្អើល។

បើគិតតាមបែបគំរូផែនការអាជីវកម្ម ខ្ញុំមានបញ្ហាពីរបីដែលត្រូវដោះស្រាយ។ ទីមួយ វាត្រូវចំណាយពេលយូរណាស់ក្នុងការគណនាដោយដៃ ហើយវាយបញ្ចូលវាទៅក្នុងកុំព្យូទ័រក្នុងទម្រង់ជាបទបង្ហាញ។ ទីពីរ តើខ្ញុំនឹងរកប្រាក់បានដោយរបៀបណាតាមរយៈការធ្វើកិច្ចការបែបនេះ? មិនយូរប៉ុន្មាន ខ្ញុំបានចចារព្រមព្រៀងជាមួយនឹងអ្នកសរសេរកម្មវិធីកុំព្យូទ័រម្នាក់ ហើយក៏បានសរសេរកម្មវិធីដែលខ្ញុំអាចប្រើដើម្បីបង្កើតជាផែនការនោះឲ្យបានរហ័សជាងមុន។ ទាក់ទិននឹងបញ្ហាទីពីរវិញ ខ្ញុំបានដឹង

ថាខ្ញុំមិនអាចគិតលុយពីមនុស្ស ក្នុងការដែលជួយគេឲ្យចាកចេញពីបំណុលឡើយ ព្រោះពួកគេពុំទាន់មានលុយនៅឡើយទេ។ ខ្ញុំក៏បានចាប់ផ្ដើមអធិស្ឋានពីការនេះ។

មានថ្ងៃមួយ ខ្ញុំមានគំនិតបែបនេះ។ ខ្ញុំពិតជាមានអារម្មណ៍ថា ព្រះជាម្ចាស់បានប្រទានគំនិតមួយដល់ខ្ញុំពីរបៀបដំណើរការក្រុមហ៊ុនរបស់ខ្ញុំដោយជួយមនុស្សមិនគិតប្រាក់ ហើយនៅក្នុងពេលជាមួយគ្នាអាចរកប្រាក់ចំណូលសម្រាប់ខ្លួន។ នៅក្នុងផែនការរបស់ខ្ញុំ ខ្ញុំនឹងរកមើលនូវអ្វីដែលគេហៅថាលុយដែលបាត់ ជាលុយដែលអតិថិជនមានហើយ ប៉ុន្តែគាត់មិនទាន់បានឃើញ។ ឧទាហរណ៍ ខ្ញុំនឹងធ្វើការប្រៀបធៀបរវាងឡាន ផ្ទះ ជីវិត និងអត្រាធានារ៉ាប់រងសុខភាព ដោយរកមើលសម្រាប់ការសន្សំ។ ខ្ញុំនឹងប្រៀបធៀបអាត្រាបង់រំលោះការទិញផ្ទះ ដើម្បីឲ្យឃើញថាការផ្លាស់ប្ដូរកម្ចីជាការសមហេតុផលដែរឬទេ។ ខ្ញុំក៏នឹងពិនិត្យមើលលើកត្តាជាច្រើនទៀតដូចគ្នានោះ ទោះបីជាខ្ញុំមិនបានធ្វើការនៅលើគ្រប់ផ្នែកជាមួយអាជីវកម្មដែលខ្ញុំបានធ្វើការស្រាវជ្រាវក្ដី។ នៅពេលប្រជុំនៅឯផ្ទះអតិថិជន ខ្ញុំនឹងបង្ហាញពួកគេពីការសន្សំ ហើយនឹងបញ្ជូនពួកគេឲ្យទៅរកក្រុមហ៊ុនណាមួយដែលអាចអនុវត្តនូវគំនិតរបស់ខ្ញុំ ឬអ្នកតំណាងណាមួយដែលអាចធ្វើការជាមួយនឹងក្រុមហ៊ុនដែលខ្ញុំបានរកឃើញ ដែលមានតម្លៃថោកជាងសម្រាប់ពួកគេ។ ភ្លាមៗនោះ ខ្ញុំបានដឹងថាក្រុមហ៊ុនទាំងនោះអាចនឹងឲ្យថ្លៃកម្រៃជើងសារលើការណែនាំសម្រាប់អតិថិជនទាំងនោះមកដល់ខ្ញុំ។

និយាយរួម ខ្ញុំបានធ្វើកិច្ចការគ្រប់បែបយ៉ាងក្នុងការលក់ តំណាងឲ្យក្រុមហ៊ុននិងផលិតផលរបស់ពួកគេទៅកាន់អតិថិជនរបស់ខ្ញុំហើយ។ អ្វីដែលពួកគេត្រូវធ្វើគឺគ្រាន់តែចុះឈ្មោះអតិថិជនប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំក៏បានចាប់ផ្ដើមទាក់ទងទៅអ្នកលក់ អ្នកតំណាង និងអ្នកជំនាញផ្សេងៗដែលខ្ញុំបានណែនាំទៅកាន់អតិថិជនរបស់ខ្ញុំ ហើយប្រាប់ពួកគេពីអ្វីដែលខ្ញុំកំពុងតែធ្វើ ហើយសួរពួកគេថាតើខ្ញុំសមនឹងទទួលបានកម្រៃជើងសារនៃការណែនាំសម្រាប់អតិថិជនទាំងនោះដែរឬទេ។ ពួកគេគ្រប់ៗគ្នាសុទ្ធតែយល់ព្រម។ ដូច្នេះនេះជាអ្វីដែលខ្ញុំបានធ្វើ។ ខ្ញុំបានលាឈប់ពីក្រុមហ៊ុនចាស់ ហើយចាប់ផ្ដើមក្រុមហ៊ុនរបស់ខ្ញុំផ្ទាល់ ដោយជួយមនុស្សឲ្យចាកចេញពី

បំណុល។ អាជីវកម្មនេះក៏បានចាប់ផ្តើមឡើង ហើយនៅក្នុងដំណើរការនោះ វាបានរកប្រាក់ចំណូលល្មមគ្រប់គ្រាន់សម្រាប់ខ្ញុំខ្រិនដា និងខ្ញុំអាចមានសេរីភាពពីបំណុលនៅក្នុងពេលពីរឆ្នាំកន្លះ! យើងពិតជារំភើបណាស់! (ប្រសិនបើលោកអ្នកចាប់អារម្មណ៍ក្នុងការឲ្យយើងជួបរៀបចំផែនការឲ្យដោយឥតគិតថ្លៃ សូមទូរស័ព្ទមកលេខ 1-800-815-0818។ យើងនៅតែធ្វើវាមកទល់ថ្ងៃនេះ គឺ២៨ឆ្នាំមកហើយ!)

រៀងរាល់ថ្ងៃ សុទ្ធតែជាថ្ងៃថ្មីដែលព្រះជាម្ចាស់នៅតែបង្ហាញយើងថែមទៀតអំពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើការ។ នៅពេលដែលខ្ញុំកំពុងជួបជាមួយអតិថិជនម្នាក់ទៀត ព្រះជាម្ចាស់បានមានបន្ទូលមកកាន់ខ្ញុំពីការជួលបុគ្គលិក ហើយកសាងអាជីវកម្មខ្នាតតូចរបស់ខ្ញុំឲ្យក្លាយជាអាជីវកម្មពេញលក្ខណៈ។ នៅពេលដែលខ្ញុំជួលបុគ្គលិកឲ្យធ្វើការជាមួយយើង អាជីវកម្មរបស់យើងក៏បានចាប់ផ្តើមចម្រុងចម្រើនឡើងធំទៅៗ។ ខ្ញុំបានប្រាប់លោកអ្នកនៅក្នុងសេចក្តីលំនាំពីរបៀបដែលយើងបានចាប់ផ្តើមយកប្រាក់សុទ្ធទៅទិញឡាន និងពីរបៀបដែលយើងបានសង់ផ្ទះក្នុងក្តីសុបិន។ នៅក្នុងពេលដែលខ្ញុំប្រជុំអាជីវកម្មប្រចាំខែជាមួយនឹងបុគ្គលិកដែលខ្ញុំទើបតែជ្រើសរើស ខ្ញុំបានតែងចែករំលែកពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយមនុស្សចាប់ចិត្តក្នុងការស្តាប់ឮថែមទៀតពីព្រះរាជ្យរបស់ព្រះជាម្ចាស់តាមរយៈក្រុមហ៊ុនរបស់ខ្ញុំ និងរបៀបអនុវត្តនូវព្រះរាជ្យនោះមកកាន់ជីវិតរបស់គេផ្ទាល់ ក៏ដូចជាការដែលគេចូលមកដោយចាប់អារម្មណ៍ពីឱកាសអាជីវកម្មដែរ។

មេរៀនដែលព្រះជាម្ចាស់បានបង្ហាញមកកាន់ខ្ញុំគឺអស្ចារ្យណាស់ ហើយជាការពិត ខ្ញុំបានរៀនពីមេរៀនភាគច្រើននៅពេលដែលខ្ញុំចេញទៅបរបាញ់ក្នុងមួយឆ្នាំៗ។ យ៉ាងហោចណាស់ សាច់រឿងរបស់ខ្ញុំអំពីការបរបាញ់គឺពិតជាធ្វើឲ្យខ្ញុំរំជួលចិត្តណាស់។ ខ្ញុំនឹងមិនជឿរឿងទាំងនោះទេ ប្រសិនបើមិនបានឃើញផ្ទាល់នឹងភ្នែក។ រឿងរ៉ាវទាំងប៉ុន្មានបានបង្រៀនខ្ញុំនូវអ្វីដែលថ្មីអំពីព្រះរាជ្យដែលខ្ញុំពុំធ្លាប់ឃើញពីមុនមក។ ខ្ញុំនឹងចែកចាយពីសាច់រឿងមួយចំនួនជាមួយលោកអ្នកនៅក្នុងសៀវភៅនេះ ប៉ុន្តែប្រសិនបើលោកអ្នកពិតជាចង់អានសាច់រឿងទាំងប៉ុន្មានស្តីពីការបរបាញ់របស់

ខ្ញុំមែន លោកអ្នកអាចទទួលបានសៀវភៅរបស់ខ្ញុំមួយក្បាលដែលមានចំណងជើងភាសាអង់គ្លេសថា Faith Hunt (ការបរបាញ់ដោយជំនឿ) ពីគេហទំព័ររបស់ខ្ញុំ។

រឿងនេះបានកើតឡើងនៅពេលពីរបីឆ្នាំដំបូង ដែលខ្ញុំបានធ្វើការប្រមាញ់សត្វក្ដាន់ដោយប្រើចំណេះដឹងដែលខ្ញុំទើបនឹងបានយល់ស្ដីអំពីព្រះរាជ្យ។ ដូចដែលខ្ញុំបានចែកចាយជាមួយនឹងលោកអ្នកហើយ ព្រះជាម្ចាស់បានបង្រៀនខ្ញុំពីរបៀបសាបព្រោះដើម្បីឲ្យបានសត្វក្ដាន់ ហើយជឿថាខ្ញុំបានទទួលហើយនៅពេលអធិស្ឋាន។ ដោយគ្មានករណីលើកលែង ខ្ញុំតែងប្រមាញ់សត្វក្ដាន់នៅពេលពី ៣០ទៅ ៤៥នាទីជារៀងរាល់ឆ្នាំ។ មួយវិញទៀត វាបានកើតឡើងជាង ២៨ឆ្នាំមកហើយមកដល់ពេលនេះ។ យ៉ាងណាមិញ មានឆ្នាំមួយនោះនៅពេលដែលខ្ញុំចេញទៅបរបាញ់ដូចសព្វមួយដង ខ្ញុំមានទំនុកចិត្តទាំងស្រុងថាសត្វក្ដាន់នឹងបង្ហាញខ្លួន។ នៅក្នុងពេលពីរបីនាទីបន្ទាប់មក ខ្ញុំបានឃើញក្ដាន់មួយក្បាលកំពុងតែដើរចូលទៅក្នុងដីរបស់អ្នកជិតខាងខ្ញុំប្រមាណជា ១៨០ម៉ែត្រពីខ្ញុំ។ ខ្ញុំបានដឹងថា ប្រសិនបើក្ដាន់ដើរចូលទៅក្នុងព្រៃនោះ ខ្ញុំនឹងរកវាលែងឃើញហើយ ហើយខ្ញុំក៏ដឹងថាវាជាក្ដាន់ដែលព្រះជាម្ចាស់បានប្រទានឲ្យខ្ញុំដែរ។ នៅសម័យនោះ ខ្ញុំមិនទាន់ចេះប្រមាញ់ដោយប្រើព្រួញ ការផ្លុំហៅក្ដាន់ ឬរបៀបបញ្ចេញសំឡេងដើម្បីហៅក្ដាន់ឡើយ។ ខ្ញុំដឹងថាសត្វក្ដាន់ជាចម្រូតរបស់ខ្ញុំ ប៉ុន្តែខ្ញុំបានត្រឹមតែឈរមើលដោយមិនអាចធ្វើអ្វីបានសោះនៅពេលដែលក្ដាន់កំពុងដើរចូលទៅក្នុងព្រៃដែលស្ថិតនៅលើដីរបស់អ្នកជិតខាងខ្ញុំ។ ភ្លាមៗនោះខ្ញុំបានឮនៅក្នុងវិញ្ញាណខ្ញុំថា «ចូរប្រាប់សត្វក្ដាន់ឲ្យមករកអ្នក»។ «ស្អីគេ? ប្រាប់ឲ្យក្ដាន់មករកខ្ញុំ? តើមានន័យថាម៉េច?» ខ្ញុំមិនប្រាកដទេ ដូច្នេះ ខ្ញុំក៏និយាយឮៗ ប៉ុន្តែមិនឮពេកដល់ថ្នាក់ក្ដាន់ឮសំឡេងរបស់ខ្ញុំទេ គឺខ្ញុំថា «ក្ដាន់ ខ្ញុំបញ្ជាឲ្យឯងឈប់ដើរបែរក្រោយ ហើយមកឈរនៅក្រោមកន្លែងដែលយើងអង្គុយប្រមាញ់នេះ។ ពេលនោះ ខ្ញុំកំពុងប្រមាញ់ដោយប្រើព្រួញនិងធ្នូ ហើយខ្ញុំហៅវាឲ្យមកក្រោមដើមឈើដែលខ្ញុំអង្គុយនោះ ព្រោះខ្ញុំចង់ឲ្យវាមកជិតខ្ញុំមែនទែន។ ខ្ញុំជឿថា ប្រសិនបើជំនឿនឹង

នាំសត្វក្តាន់នោះឲ្យមករកខ្ញុំមែន នោះខ្ញុំក៏អាចឲ្យវាមកក្រោមដើមឈើរបស់ខ្ញុំ ដែលខ្ញុំអាចបាញ់វាបានល្អដែរ។

អស្ចារ្យណាស់ នៅពេលដែលខ្ញុំនិយាយពាក្យទាំងនោះ សត្វក្តាន់ក៏ឈប់ភ្លាម។ វាបែរក្រោយ ហើយចាប់ផ្តើមដើរសំដៅមកដើមឈើរបស់ខ្ញុំតែម្តង។ ខ្ញុំភ្ញាក់ផ្អើលជាខ្លាំង នៅពេលដែលសត្វក្តាន់ដើរពីចម្ងាយ ១៨០ម៉ែត្រមកកាន់ដើមឈើរបស់ខ្ញុំ ។មែនហើយ វានៅឈរស្ងៀមក្រោមដើមឈើដែលខ្ញុំអង្គុយនោះតែម្តង ដែលខ្ញុំនៅអង្គុយពីលើវាជាង៣.៥ម៉ែត្រប៉ុណ្ណោះ។ ខ្ញុំមិនបានពាក់អាវបន្លំខ្លួន មិនបានបាញ់ក្លិនទាក់វា មិនបានផ្លុំហៅវា គឺមានតែខ្ញុំ និងព្រះជាម្ចាស់ប៉ុណ្ណោះ។ ប៉ុន្តែ សត្វក្តាន់នោះឈរនៅខាងក្រោមខ្ញុំផ្ទាល់។ ខ្ញុំគិតថា នរណាក៏អាចបាញ់ចំដែរ។ ខ្ញុំក៏យកសត្វក្តាន់នោះត្រលប់ទៅផ្ទះទាំងសប្បាយរីករាយ ប៉ុន្តែខ្ញុំមិនបានបំភ្លេចនូវអ្វីដែលខ្ញុំទើបតែបានឃើញឡើយ។ តើសត្វក្តាន់នោះពិតជាបានមករកខ្ញុំ ដោយព្រោះតែខ្ញុំបាននិយាយ និងបញ្ជាវាឲ្យមកឬ? ដូចជាអញ្ចឹងឯង។

កសិដ្ឋានដែលយើងបានជួលនៅរដ្ឋអូហៃយ៉ូមានផ្ទៃដីជាង ៣៦ហិកតា ហើយមានព្រៃខ្លះៗ មានអូរដែលមានគុម្ពោតព្រៃ និងមានវាលស្មៅដែរ។ នៅក្នុងរដូវរងារ ហើយជាពិសេសពេលដែលមានព្រិលធ្លាក់មកលើដី យើងចូលចិត្តចេញទៅបរបាញ់សត្វទន្សាយ។ រដ្ឋអូហៃយ៉ូមានរដូវប្រមាញ់មាន់ទោរដែលប្រព្រឹត្តទៅតំណាលគ្នានឹងរដូវបរបាញ់ទន្សាយ ប៉ុន្តែយើងកម្រនឹងឃើញសត្វមាន់ទោរក្នុងកសិដ្ឋានរបស់យើងណាស់។

មានថ្ងៃមួយនោះ យើងបានចេញទៅបរបាញ់សត្វទន្សាយ ហើយយើងកំពុងដើរតាមជ្រលងអូរ ក៏ស្រាប់តែឃើញមានទោរឈ្មោលមួយក្បាលកំពុងតែទំលើមែកឈើ។ ខ្ញុំក៏ដើរទៅជិតមាន់នោះ ហើយបាញ់ភ្លាម។ ខ្ញុំបានដឹងថា នៅនាទីដែលខ្ញុំបានកេះកៃ ខ្ញុំបាញ់ត្រូវចុងស្លាបមាន់ប៉ុណ្ណោះ។ មាន់ទោរនោះក៏ធ្លាក់ចុះមកលើដី ហើយនៅពេលដែលវាធ្លាក់មកដល់ដីភ្លាម វាក៏រត់យ៉ាងលឿន។ សត្វមាន់ទោរអាចរត់ដល់ទៅ៥៦គីឡូម៉ែត្រក្នុងមួយម៉ោង ហើយមាន់មួយក្បាលនេះគឺរត់លឿនណាស់

អស់មួយទំហឹងរបស់វា។ នៅពេលនោះ មានពំនូកព្រិលថ្មីៗធ្លាក់គ្របដណ្ដប់នៅពាសពេញដី ហើយបក្សីនោះកំពុងតែរត់នៅលើវាលស្មៅមួយ ដែលមានសណ្ឋានទ្រេតបែបជាជ្រលងភ្នំ ដូច្នេះខ្ញុំអាចមើលឃើញរាល់ទាំងជំហានដែលបក្សីនេះព្យាយាមរត់ឲ្យបានរួចខ្លួន។

ខ្ញុំបានឈរនៅទីនោះមួយភ្លែត ដោយគិតថាសត្វមាន់នេះប្រាកដជារត់ទៅបាត់មិនខាន ប៉ុន្តែនៅក្នុងវិញ្ញាណរបស់ខ្ញុំ ស្រាប់តែនឹកឃើញរឿងមួយភ្លាម។ ខ្ញុំបាននឹកចាំពីអ្វីដែលបានកើតឡើងនៅពេលដែលខ្ញុំបញ្ជាឲ្យសត្វក្ដាន់នោះឈប់ ហើយដើរមករកខ្ញុំ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំគួរតែសាកធ្វើវានៅពេលនោះ ដូច្នេះខ្ញុំក៏ស្រែកឮៗថា «មាន់ទោរ នៅក្នុងព្រះនាមព្រះយេស៊ូ **ចូរឈប់**!» ភ្លាមៗនោះ ខ្ញុំលែងឃើញថាមាន់នោះដើរទៅខាងមុខ ឬខាងក្រោយ។ ខ្ញុំអាចមើលឃើញវាលស្មៅទាំងមូល ហើយសត្វមាន់ទោរបានឈប់នៅពេលដែលខ្ញុំស្រែកនោះ។ កូនប្រុសរបស់ខ្ញុំឈ្មោះថាធីមបាននៅជាមួយខ្ញុំ ហើយគាត់ពោលថា «ប៉ា សត្វមាន់ទោរឈប់ពេលដែលប៉ាស្រែក។» ប៉ុន្តែ តើវានៅឯណា? ធីម និងខ្ញុំបានដើរតាមដានជើងរបស់វានៅឯវាលស្មៅ ហើយវាគ្រាន់តែក្រាបនៅទីនោះ គឺនៅលើពំនូកព្រិល។ សឹងតែពាក់កណ្ដាលក្បាលរបស់វាកប់នៅក្នុងព្រិល ប៉ុន្តែខ្លួនវាទាំងមូលគឺនៅលើពំនូកព្រិល។ ដោយសារតែបាំងគុម្ពស្មៅ ដូច្នេះទើបយើងបានបាត់ដានរបស់វា។ តើវាងាប់ឬ? ខ្ញុំក៏លើកសត្វមាន់ឡើង ហើយរំពេចនោះវាក៏ទះស្លាបទាំងគូដែលសុទ្ធតែព្រិលធ្លាក់លើ ហើយក៏ស្រែកឡើង។ សត្វមាន់នេះនៅរស់ទេតើ! នៅពេលដែលយើងពិនិត្យមើលវា ខ្ញុំបានឃើញថាខ្ញុំគ្រាន់តែបាញ់បញ្ជិត ផែបស្លាបស្ដាំរបស់វាប៉ុណ្ណោះ។ ធីម និងខ្ញុំមើលមុខគ្នាទាំងភ្ញាក់ផ្អើល។ គ្មាននរណាជឿពីអ្វីដែលយើងទើបតែបានឃើញឡើយ គឺគ្មានទាល់តែសោះ។

ដូចដែលខ្ញុំបាននិយាយពីខាងដើម រដ្ឋអូហៃយ៉ូមានច្បាប់កំណត់ឲ្យបរបាញ់បានសត្វក្ដាន់តែពីរប៉ុណ្ណោះ ទាំងញីនិងឈ្មោល ប៉ុន្តែគេអាចបាញ់ក្ដាន់ឈ្មោលបានតែមួយប៉ុណ្ណោះក្នុងមួយឆ្នាំ។ រដ្ឋអូហៃយ៉ូកំពុងកាត់បន្ថយចំនួនសត្វក្ដាន់នៅក្នុងរដ្ឋ

ដោយអនុញ្ញាតឲ្យប្រជាជនធ្វើការបរបាញ់សត្វក្ងាន់ញីច្រើនជាង។ ដូច្នេះ ខ្ញុំនឹងសាបព្រោះគ្រាប់ពូជរបស់ខ្ញុំសម្រាប់ក្ងាន់ឈ្មោលមួយក្បាល និងក្ងាន់ញីមួយក្បាល ហើយដូចជាទៀងម៉ោងណាស់ គឺក្ងាន់ឈ្មោលនឹងមកដល់នៅក្នុងពេលពី ៣០ ទៅ ៤០ នាទីនៅពេលខ្ញុំចេញទៅបរបាញ់ថ្ងៃដំបូង នៅក្នុងរដូវកាលបរបាញ់នោះ ហើយនៅពេលចេញទៅបរបាញ់លើកក្រោយទៀត ក្ងាន់ញីក៏មកម្ដង។ ថ្ងៃមួយ ខ្ញុំនឹកភ្នកថា «ចាំបន្តិច សត្វក្ងាន់កំពុងតែដើរមកតាមលំដាប់លំដោយដែលខ្ញុំបានសរសេរចូលនៅពេលដែលខ្ញុំសាបព្រោះគ្រាប់ពូជរបស់ខ្ញុំ។» តើនេះអាជាការពិតដែរឬទេ? តើនឹងមានអ្វីកើតឡើង ប្រសិនបើខ្ញុំបញ្ច្រាសលំដាប់លំដោយនោះវិញ? ជារឿយៗ ខ្ញុំនឹងសាបព្រោះគ្រាប់ពូជសម្រាប់សត្វក្ងាន់ឈ្មោលមុន និងក្ងាន់ញីក្រោយ ហើយវាបង្ហាញខ្លួនតាមលំដាប់លំដោយបែបនេះមែន។ នៅលើកនេះ ខ្ញុំបានសាបព្រោះសម្រាប់សត្វក្ងាន់ញី និងក្ងាន់ឈ្មោល ជាជាងក្ងាន់ឈ្មោល និងក្ងាន់ញីដូចលើកមុនៗ។ សត្វក្ងាន់ក៏មកម្ដងទៀត ប៉ុន្តែនៅលើកនេះក្ងាន់ញីមកមុន ហើយក្ងាន់ឈ្មោលមកតាមក្រោយ។ ខ្ញុំបានប្ដូរវាសាចុះសាឡើងក្នុងពេលពីរបីឆ្នាំ ដោយសាកល្បងនូវទ្រឹស្ដីរបស់ខ្ញុំ ហើយវាបានផលគ្រប់ពេល។ នៅពេលដែលខ្ញុំឃើញហេតុការណ៍ទាំងនេះកើតឡើង ខ្ញុំពិតជាកោតស្ញប់ស្ញែងនឹងព្រះរាជ្យ ហើយដឹងថាខ្ញុំបានយល់ពីព្រះរាជ្យតែបន្តិចប៉ុណ្ណោះ។ រឿងមួយដែលខ្ញុំដឹងច្បាស់គឺ ព្រះអម្ចាស់បានបង្ហាញខ្ញុំថា ខ្ញុំមានសិទ្ធិអំណាចច្រើនជាងមុនទាក់ទងនឹងរបៀបដែលជីវិតរបស់ខ្ញុំកំពុងតែដើរទៅណា គឺច្រើនជាងអ្វីដែលខ្ញុំនឹកស្មាន។

ខ្ញុំសូមបើករង្វង់ក្រចកមួយភ្លែត នៅពេលនេះគឺជារដូវបរបាញ់សត្វក្ងាន់នៅឆ្នាំ ២០១៥ (ពេលដែលខ្ញុំបោះពុម្ពសៀវភៅនេះ)។ ខ្ញុំបានសាបព្រោះសម្រាប់សត្វក្ងាន់ឈ្មោលដែលមានស្នែងបួនគន្លាក់ ឬធំជាងនេះ និងសត្វលាញីដែលមានអាយុមួយខួប ហើយនិងក្ងាន់ឈ្មោលដែលមានអាយុកន្លះខួបដើម្បីធ្វើជាអាហារ។ ដូចជាសព្វមួយដង សត្វក្ងាន់ដែលមានស្នែងប្រាំមួយគន្លាក់បានដើរតម្រង់មកដើមឈើដែលខ្ញុំអង្គុយ ហើយនៅពេលបន្ទាប់មកទៀត ខ្ញុំបាញ់បានក្ងាន់ញីដែលមានអាយុជាងមួយ

ខួប ជាក្ដាន់តែមួយដែលបានដើរមកកាន់ដើមឈើរបស់ខ្ញុំ។ ខ្ញុំដឹងថា នៅលើកក្រោយក្ដាន់ឈ្មោលដែលមានអាយុកន្លះខួបក៏នឹងបង្ហាញខ្លួនដែរ។ ខ្ញុំដឹងថា រឿងនេះស្ដាប់ទៅដូចជាចម្លែកណាស់ ហើយខ្ញុំគ្រាន់តែប្រាប់លោកអ្នកពីហេតុការណ៍ដែលខ្ញុំបានឃើញ។

ប៉ុន្តែ មានពេលបរបាញ់ម្ដងដែលបានធ្វើឲ្យខ្ញុំយល់សេចក្ដីនេះយ៉ាងច្បាស់រហូតធ្វើឲ្យខ្ញុំភ័យ។ ខ្ញុំបានសាបព្រោះគ្រាប់ពូជសម្រាប់ក្ដាន់ឈ្មោលដែលមានស្នែងបួនគន្លាក់ ឬធំជាងនេះ និងក្ដាន់ឈ្មោលដែលមានអាយុកន្លះខួប (តាមច្បាប់បរបាញ់ ក្ដាន់ឈ្មោលដែលមានអាយុកន្លះខួបក៏រាប់ស្មើនឹងក្ដាន់ញីដែរ ព្រោះស្នែងរបស់វាមិនទាន់ដុះផុតរោមនៅឡើយ ហើយមានសណ្ឋានដូចជាឡេវអាវ។ ខ្ញុំបានចេញទៅខាងក្រៅដូចសព្វមួយដង ហើយនៅក្នុងពេល ១៥ នាទី ខ្ញុំក៏បាញ់បានក្ដាន់ឈ្មោលដែលមានស្នែងប្រាំបីគន្លាក់នៅក្នុងរដូវប្រមាញ់ដោយប្រើព្រួញ។ នៅពេលដែលខ្ញុំចេញទៅបរបាញ់នៅពេលបន្ទាប់ ខ្ញុំប្រាកដថាកូនក្ដាន់ឈ្មោលក៏នឹងនៅទីនោះដែរ។

ពីរសប្ដាហ៍ក្រោយមក ខ្ញុំបានចេញទៅម្ដងទៀត ហើយនៅពេលដែលខ្ញុំអង្គុយនៅលើដើមឈើដើម្បីចាំមើល ខ្ញុំបានឃើញក្ដាន់ឈ្មោលមួយក្បាលដែលមានស្នែងប្រាំបីគន្លាក់ និងមានរាងសមសួនកំពុងតែដើរនៅតាមវាលស្មៅខ្ទង់២៧០ម៉ែត្រពីខ្ញុំ។ វាកំពុងដើរសំដៅមកដើមឈើខ្ញុំតែម្ដង។ វាមិនបត់ទៅឆ្វេង ឬទៅស្ដាំទេ គឺដើរកាត់វាលនោះ ហើយមកឈប់នៅក្រោមឈើខ្ញុំប្រមាណជា ២០វិនាទី។ បន្ទាប់មក វាក៏បែរក្រោយ ហើយត្រលប់ទៅកាន់វាលស្មៅនោះវិញ នៅតាមផ្លូវដដែលដែលវាបានដើរមកទីនេះ។ សូមចាំថា ច្បាប់នៅរដ្ឋអូហៃយ៉ូអនុញ្ញាតឲ្យបាញ់សត្វក្ដាន់ឈ្មោលបានតែមួយប៉ុណ្ណោះ ហើយខ្ញុំបានក្ដាន់ឈ្មោលដែលមានស្នែងប្រាំបីគន្លាក់រួចមកហើយ ដូច្នេះខ្ញុំបានត្រឹមអង្គុយមើលក្ដាន់នោះដោយមិនអាចបាញ់វាឡើយ។ នៅពេលនោះ ខ្ញុំច្របូកច្របល់ណាស់។ នេះជាលើកទីមួយហើយដែលខ្ញុំចេញទៅបរបាញ់ ហើយមានក្ដាន់មួយក្បាលដើរសំដៅមកក្បែរខ្ញុំ ដែលមិនមែនជាសត្វក្ដាន់

ដែលខ្ញុំបានសាបព្រោះ។ របៀបដែលសត្វក្តាន់នោះប្រព្រឹត្តដោយដើរកាត់វាលស្មៅនោះតម្រង់មករកខ្ញុំ ហើយឈរក្រោមដើមឈើដែលខ្ញុំអង្គុយនោះ បន្ទាប់មកក៏ដើរត្រលប់ទៅកាន់វាលស្មៅវិញនៅតាមផ្លូវដដែលដែលវាបានដើរមកគឺជារឿងចម្លែកណាស់។ វាដូចជាមាននរណាបញ្ជាវាឲ្យធ្វើកិច្ចការនោះអញ្ចឹង។ ខ្ញុំបានរង់ចាំពេញមួយព្រឹក ប៉ុន្តែកូនក្តាន់មិនបានបង្ហាញខ្លួនឡើយ។

នៅយប់នោះ ពេលដែលអង្គុយនៅក្នុងការិយាល័យ ខ្ញុំដូចជាមិនអស់ចិត្តសោះពីរឿងនេះ។ មានរឿងមិនប្រក្រតីកើតឡើង។ កូនក្តាន់ដែលមិនទាន់ដុះស្នែងគួរតែបង្ហាញខ្លួន។ ហើយហេតុអ្វីបានជាក្តាន់ឈ្មោលដែលមានស្នែងប្រាំបីគន្លាក់បង្ហាញខ្លួនទៅវិញ? នៅពេលដែលខ្ញុំអង្គុយនៅទីនោះ ខ្ញុំបានចាប់ផ្តើមអធិស្ឋានតាមការណែនាំនៃព្រះវិញ្ញាណ ដោយសួរព្រះជាម្ចាស់ឲ្យបង្ហាញខ្ញុំពីអ្វីដែលបានកើតឡើង។ ខ្ញុំបានឮព្រះសូរសៀងទ្រង់មានបន្ទូលមកកាន់ខ្ញុំថា «ចូរមើលទៅកាន់គ្រាប់ពូជរបស់កូនមើល៍»។ មើលគ្រាប់ពូជរបស់ខ្ញុំ? ខ្ញុំបានដឹងថាខ្ញុំបានសាបព្រោះក្នុងចំនួនប៉ុន្មាន។ ធនាគារធ្វើការថតចម្លងមូលប្បទានបត្ររបស់ខ្ញុំ ដូច្នេះខ្ញុំក៏យករបាយការណ៍ហិរញ្ញវត្ថុមកមើល ហើយក៏បានមើលមូលប្បទានបត្រដែលខ្ញុំបានសរសេរនៅពេលដែលបានសាបព្រោះសម្រាប់ក្តាន់របស់ខ្ញុំ។ ខ្ញុំស្មានថា ខ្ញុំបានសាបព្រោះគ្រាប់ពូជសម្រាបក្តាន់ឈ្មោលពីរក្បាល គឺមួយក្បាលមានស្នែងបួនគន្លាក់ ឬធំជាងនេះ ហើយមួយទៀតជាកូនក្តាន់ដែលគេអាចរាប់ថាជាក្តាន់ញីដូចដែលខ្ញុំបាននិយាយពីខាងដើម។ ប៉ុន្តែនៅក្នុងមូលប្បទានបត្ររបស់ខ្ញុំសរសេរថា «ក្តាន់ឈ្មោលពីរក្បាលដែលមានស្នែងបួនគន្លាក់ ឬធំជាងនេះ និងកូនក្តាន់មួយក្បាល» ទោះបីជាខ្ញុំចង់មានន័យថាក្តាន់ពីរក្បាល ដែលមួយក្បាលមានចុងស្នែងបួន ឬធំជាងនេះ ហើយមួយទៀតជាកូនក្តាន់ឈ្មោលមួយ តែនៅលើមូលប្បទានបត្រនោះមិនបានសរសេរដូច្នេះឡើយ។ វាសរសេរថា «ក្តាន់ឈ្មោលពីរក្បាលដែលមានស្នែងបួនគន្លាក់ ឬធំជាងនេះ និងកូនក្តាន់មួយក្បាល។» តើសរុបមកមានក្តាន់ប៉ុន្មានក្បាល? គឺបីក្បាល ហើយក្តាន់ទីពីរមានស្នែងបួនគន្លាក់ ឬធំជាងនេះដូចជាក្តាន់ទីមួយ

អញ្ចឹង។ នៅពេលដែលឃើញដូច្នោះ ខ្ញុំបានអង្គុយនៅទីនោះទាំងភាំងស្មារតី។ ក្តាន់ស្មែងប្រាំបីគន្លាក់នោះគឺត្រូវបានចាត់ឲ្យមកមែន។ វាត្រូវមកទីនោះដោយសារតែច្បាប់នៃព្រះរាជ្យ។ ខ្ញុំក៏បានស្ទុះក្រោកឡើង ហើយចាប់ផ្តើមស្រែក និងរត់ឆ្វេឆ្វានៅជុំវិញផ្ទះ។ អស្ចារ្យណាស់!!!!

នៅព្រមពេលជាមួយគ្នា អ្វីដែលខ្ញុំបានឃើញក៏ធ្វើឲ្យខ្ញុំភ័យដែរ។ ប្រសិនបើអ្វីដែលខ្ញុំបានឃើញ គឺពិតជាអ្វីដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការជាក់ស្តែង និងច្បាស់លាស់ដូចនោះមែន នោះខ្ញុំត្រូវតែប្រុងប្រយ័ត្នជាងមុន។ ដោយមិនបានប្រយ័ត្នប្រយែង ខ្ញុំបានអនុញ្ញាតឲ្យហេតុការណ៍មួយចំនួនដែលខ្ញុំមិនចង់ឲ្យកើតឡើងបានកើតឡើង គឺវាបានកើតឡើងដោយសារតែខ្ញុំបានស្រាយវាដោយយោងតាមច្បាប់ខាងវិញ្ញាណ។ នៅពេលនេះទើបខ្ញុំទទួលស្គាល់ថា មនុស្សជាច្រើនរួមទាំងខ្ញុំដែរ កំពុងតែជួបនឹងកិច្ចការនានាដែលពួកគេមិនចង់ឲ្យកើតឡើង ប៉ុន្តែគឺពួកគេខ្លួនឯងបានធ្វើឲ្យកិច្ចការទាំងនោះកើតឡើង។ សូមចាំថា ដោយសារព្រះបន្ទូលរបស់ទ្រង់ ព្រះយេស៊ូបានសម្លាប់ដើមឧទុម្ពរមួយ ហើយហៅឡាសារឲ្យរស់ឡើងវិញពីក្នុងផ្នូរ។ ហេតុការណ៍ទាំងពីរបានប្រើប្រាស់ច្បាប់ដដែលសម្រាប់គោលបំណងផ្សេងៗ។ នៅពេលក្រោយដែលខ្ញុំចេញទៅបរបាញ់ កូនក្តាន់ឈ្មោលនោះបានបង្ហាញខ្លួនដូចដែលខ្ញុំបានសាបព្រោះមែន។

ហេតុការណ៍ដែលបានកើតឡើងជាបន្តបន្ទាប់នេះ បានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល ហើយបានជះឥទ្ធិពលលើទស្សនៈរបស់ខ្ញុំចំពោះព្រះរាជ្យជាខ្លាំង។ នៅពេលនេះ ខ្ញុំដឹងយ៉ាងប្រាកដថា ព្រះរាជ្យគឺមានសណ្ឋានជាក់លាក់ណាស់។ ប៉ុន្តែ តើយើងត្រូវភ្ញាក់ផ្អើលនឹងការនោះឬ? ច្បាប់ទាំងឡាយដែលមាននៅលើភពផែនដីមានភាពជាក់លាក់ដូច្នោះឯង។ ខ្ញុំអាចនិយាយថា ខ្ញុំគ្រាន់តែមិនធ្លាប់ទទួលស្គាល់ថាច្បាប់ខាងវិញ្ញាណដំណើរការដូចជាច្បាប់ខាងរូបរាងកាយដែរ គឺវានាំឲ្យគោលការណ៍ខាងវិញ្ញាណកើតមានជារូបរាងឡើង។ ខ្ញុំគួរតែបានដឹងពីវាជាយូរមកហើយ ប៉ុន្តែខ្ញុំមិន

បានដឹងសោះបើនិយាយឲ្យត្រង់។ នៅពេលនេះទើបខ្ញុំដឹងថា ព្រះរាជ្យគឺមានភាពជាក់លាក់ គឺជាក់លាក់ណាស់។

ប្រហែលជាលោកអ្នកចង់ដឹង ដូច្នេះខ្ញុំនឹងប្រាប់រឿងមួយទៀតពីការបរបាញ់ (ខ្ញុំពេញចិត្តនឹងមេរៀនដែលខ្ញុំបានរៀនពីការបរបាញ់ ដូច្នេះលោកអ្នកត្រូវតាមខ្ញុំឲ្យទាន់)។ នៅពេលដែលខ្ញុំបានឃើញថាព្រះរាជ្យមានភាពជាក់លាក់ប៉ុណ្ណា ខ្ញុំក៏បានសម្រេចចិត្តថាធ្វើការពិសោធន៍ដែលកាន់តែជាក់លាក់ជាងមុនទៀត។ នៅឆ្នាំនេះ ខ្ញុំបានសម្រេចចិត្តថាសាបព្រោះសម្រាប់ក្តាន់ឈ្មោលដែលមានស្នែងប្រាំពីរគន្លាក់។ ជាទូទៅ ក្តាន់មាននូវចំនួនគន្លាក់ដូចៗគ្នានៅលើស្នែងម្ខាងៗ ដូចជាក្តាន់ដែលមានស្នែងបួនគន្លាក់ គឺមានពីរគន្លាក់នៅលើស្នែងម្ខាងៗ។ល។ ប៉ុន្តែស្នែងរបស់សត្វក្តាន់ឈ្មោលក៏អាចមិនស្មើគ្នាដោយកត្តាផ្សេងៗដែរ ដែលនាំឲ្យវាមានចំនួនគន្លាក់ខុសៗពីគ្នានៅលើស្នែងម្ខាងៗ។ តែជាទូទៅ ដូចដែលខ្ញុំបាននិយាយ ជាទូទៅគឺមានចំនួនដូចគ្នានៅលើស្នែងម្ខាងៗ។

**នៅពេលនេះ ខ្ញុំដឹងយ៉ាងប្រាកដជាក់ច្បាស់ថា ព្រះរាជ្យគឺមានសណ្ឋានជាក់លាក់ណាស់។**

ខ្ញុំចង់ស្រាយជំនឿរបស់ខ្ញុំសម្រាប់អ្វីម្យ៉ាងដែលជាក់លាក់ និងមិនមែនជារឿងធម្មតា ដែលហេតុនេះហើយទើបខ្ញុំធ្វើការពិសោធន៍។ ខ្ញុំបានរៀនថា ប្រសិនបើលោកអ្នកកាន់តែមានភាពជាក់លាក់ ហើយប្រសិនបើលោកអ្នកបានរង់ចាំកាន់តែយូរ នោះព្រះវិញ្ញាណដ៏វិសុទ្ធនឹងកាន់តែមានបន្ទូលណែនាំដល់លោកអ្នកយ៉ាងជាក់លាក់ក្នុងការដែលធ្វើឲ្យវាកើតឡើង។ ដូច្នេះ នៅថ្ងៃដំបូងនៃរដូវកាលបរបាញ់ដោយព្រួញ ខ្ញុំបានដឹងថាខ្ញុំមិនត្រូវចេញទៅឡើយ។ ខ្ញុំបានដឹងថា វាមិននៅទីនោះឡើយ។ តាមពិត ខ្ញុំបានរង់ចាំនៅពេញមួយខែ គឺខែតុលា ហើយខ្ញុំបានដឹងនៅក្នុងវិញ្ញាណថា «អត់ទេ គឺវាមិនទាន់មកដល់ទីនោះនៅឡើយទេ។» វាគួរឲ្យមួរម៉ៅណាស់ ដែលខ្ញុំបានឃើញស្លឹកឈើជ្រុះចម្រុះពណ៌ ព្រៃមានពណ៌ក្រហម បៃតងធ្វើឲ្យខ្ញុំពិតជាចង់ចេញទៅបរបាញ់ណាស់។ ប៉ុន្តែ ខ្ញុំនៅតែរង់ចាំ។

បន្ទាប់មក វាបានកើតឡើង។ នៅយប់មួយ ពេលដែលខ្ញុំកំពុងអង្គុយនៅក្នុងបន្ទប់ទទួលភ្ញៀវដោយជជែកគ្នាជាមួយនឹងឪពុកម្ដាយក្មេកខ្ញុំដែលបានមកលេងយើងពីរដ្ឋចកជៀរ ខ្ញុំបានឮសំឡេងរបស់វា។ ខ្ញុំក៏រៀបចំចេញទៅនៅព្រឹកស្អែក។ ក្ដាន់ដែលមានស្នែង៧គន្លាក់នឹងនៅទីនោះ! ខ្ញុំបានប្រាប់ក្រុមគ្រួសារខ្ញុំថា ខ្ញុំនឹងទៅបាញ់ក្ដាន់ដែលខ្ញុំត្រូវបាននៅព្រឹកស្អែក។ ខ្ញុំបានក្រោកឡើងទាំងរំភើប ហើយខ្ញុំនឹងបាញ់វាឲ្យបានមុនពេលមេឃងងឹត។ ខ្ញុំបានបរបាញ់ដោយប្រើស្នា ដោយអង្គុយនៅលើដើមឈើមួយដែលអាចមើលឃើញវាលភក់ក្នុងរយៈចម្ងាយជាង ៤ហិកតាដែលនៅជុំវិញព្រៃនោះ។ វាជាកន្លែងដ៏ស្រស់ស្អាត។ នៅពេលដែលលោកអ្នកកំពុងតែអង្គុយនៅទីនោះ មានហ្វូងសត្វទាហើរចូលមក ហើយយើងអាចឃើញសត្វកាស្ទ័ររួមទាំងសត្វសំពោចនៅក្បែរគុម្ពោតព្រៃផង។ មានព្រៃរបោះនៅមាត់វាលភក់នោះ ហើយវាជាកន្លែងមួយដែលសត្វក្ដាន់ចូលចិត្តមកដេកជាងគេនៅលើដីរបស់ខ្ញុំ។ នៅពេលដែលខ្ញុំរង់ចាំនៅលើដើមឈើ ពុំមានអ្វីកើតឡើងសោះ។ ខ្ញុំបានរង់ចាំអស់ ៤៥ នាទី ហើយរហូតដល់មួយម៉ោង តែពុំមានឃើញអ្វីសោះ។

ខ្ញុំបានឮសំឡេងបើកបិទទ្វារឡាន នៅឯផ្ទះរបស់ខ្ញុំម្ខាងទៀតនៃវាល ហើយខ្ញុំដឹងថាជាឪពុកម្ដាយក្មេកខ្ញុំកំពុងតែចេញដំណើរទៅរដ្ឋចកជៀរវិញ។ ខ្ញុំបានសន្យាថាហូបអាហារពេលព្រឹកជាមួយពួកគាត់ ហើយខ្ញុំនឹងជាអ្នកចម្អិន។ ដើមឡើយ ខ្ញុំមានផែនការថាបាញ់ក្ដាន់ឲ្យបាននៅពេលព្រឹកព្រលឹម ហើយក៏ធ្វើដំណើរទៅផ្ទះវិញដើម្បីចម្អិនអាហារពេលព្រឹក។ ប៉ុន្តែ ក្ដាន់មិនទាន់បានទៅដល់ទីនោះនៅឡើយទេ ខ្ញុំក៏ចុះពីលើដើមឈើទាំងស្ទាក់ស្ទើរ ហើយត្រលប់ទៅផ្ទះវិញ។ ខ្ញុំបានដឹងដោយបទពិសោធន៍ថា នៅលើដីរបស់ខ្ញុំនឹងមានក្ដាន់មកក្នុងតំបន់វាលភក់នោះនៅពេលថ្ងៃរះបន្តិច នាពេលព្រឹក ព្រោះវាជាកន្លែងដែលក្ដាន់ឧស្សាហ៍មកដេកដូចដែលខ្ញុំបានប្រាប់ពីខាងដើម។ អូហ៎ មែនហើយ ខ្ញុំដឹងថាក្ដាន់នោះនឹងមកទីនោះនៅពេលណាមួយ ប៉ុន្តែខ្ញុំមិនអាចរង់ចាំបានទៀតទេ។ ខ្ញុំចាំបាច់ត្រូវមកម្ដងទៀតនៅថ្ងៃផ្សេងហើយ។

ខ្ញុំបានជម្រាបសួរមនុស្សក្នុងផ្ទះ ហើយក៏ចាប់ផ្ដើមចម្អិនអាហារពេលព្រឹក។ ខ្ញុំជាអ្នកដែលតែងតែចម្អិនអាហារពេលព្រឹកនៅឯផ្ទះ ហើយក៏បានធ្វើដូច្នេះជាយូរមកហើយ។ ខ្ញុំមានរូបមន្តពិសេសរបស់ខ្ញុំ ក្នុងការចម្អិននំពុម្ពស្រូវសាឡីដែលមានឱជារសឈ្ងុយឆ្ងាញ់ដោយមានដាក់ស៊ុត សាច់ក្រក និងឈីសគ្រីម ប៉ុន្តែគ្រឿងផ្សំដ៏សំខាន់ដែលធ្វើឲ្យអាហារពេលព្រឹកមានឱជារសឈ្ងុយឆ្ងាញ់គឺទឹកស៊ីរ៉ូម៉ាផលសុទ្ធ។ អូហៃយ៉ូជារដ្ឋមួយដែលមានទឹកស៊ីរ៉ូម៉ាផលឆ្ងាញ់ ហើយមនុស្សនៅជុំវិញតំបន់របស់ខ្ញុំសុទ្ធតែធ្វើ និងលក់ទឹកស៊ីរ៉ូម៉ាផល។ ខ្ញុំមិនប្រើទឹកស៊ីរ៉ូក្លែងក្លាយ ឬមិនសុទ្ធនៅក្នុងផ្ទះទេ គឺប្រើតែរបស់សុទ្ធប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំចម្អិនអាហារពេលព្រឹក ហើយបង្អួចនៅផ្ទះបាយបែរមុខទៅរកព្រៃ និងវាលភក់។ ភ្លាមៗនោះ ខ្ញុំបានឃើញក្ដាន់មួយក្បាលកំពុងរត់កាត់វាលស្មៅ សំដៅមករកវាលភក់។ ខ្ញុំស្រែកថា «ក្ដាន់របស់ខ្ញុំមកហើយ!» ខ្ញុំបានប្រាប់អ្នកនៅក្នុងផ្ទះឲ្យចម្អិនម្ហូបតពីខ្ញុំ ដោយសារខ្ញុំត្រូវដេញតាមក្ដាន់នោះ!

តាមរយៈការមើលសត្វក្ដាន់រត់កាត់វាលនោះពីពេលមុនៗ ខ្ញុំដឹងយ៉ាងច្បាស់ថាវាកំពុងតែរត់ទៅណា ហើយដើម្បីទៅដល់ទីនោះ វានឹងដើរសំដៅទៅដើមឈើដែលខ្ញុំតែងអង្គុយ។ ខ្ញុំបានដឹងថា ប្រសិនបើខ្ញុំអាចទៅដល់ដើមឈើនោះពីផ្លូវក្រោយ ហើយឡើងទៅដល់កន្លែងអង្គុយប្រមាញ់មុនពេលដែលក្ដាន់នោះទៅដល់ ខ្ញុំអាចនឹងបាញ់វាត្រូវ។ ដើម្បីទៅឲ្យដល់ទីនោះ ហើយឡើងទៅលើដើមឈើមុនពេលដែលក្ដាន់ទៅដល់ ខ្ញុំត្រូវតែចេញពីផ្ទះ**នៅពេលនេះ**! ខ្ញុំរត់ចេញពីផ្ទះតាមទ្វារដោយកញ្ឆក់យកស្នា ហើយរត់វៀងទៅខាងក្រោយនៃវាលស្មៅ ព្រមទាំងព្យាយាមមិនបង្កជាសំឡេងអ្វីទាំងអស់ រួចខ្ញុំក៏ទៅដល់ដើមឈើដែលខ្ញុំអង្គុយ ហើយឡើងយឺតៗទៅខាងលើដើមឈើ។ នៅពេលទៅដល់ ខ្ញុំមិនទាន់បានឃើញតម្រុយពីក្ដាន់សោះ។

នៅពេលដែលខ្ញុំឡើងទៅដល់កន្លែងអង្គុយ ហើយអង្គុយចាំ ខ្ញុំបានឃើញក្ដាន់នោះកំពុងតែរត់កាត់វាលភក់ ដោយសំដៅមកកាន់ដើមឈើដែលខ្ញុំអង្គុយលើនោះ។

ក្ដាន់ឈ្មោលនោះមិនបានយកចិត្តទុកដាក់នឹងអ្វីទាំងអស់ ក្រៅពីក្ដាន់ញីដែលវាកំពុងតែរត់តាម ហើយវាមិនបានឃើញ ឬហិតក្លិនខ្ញុំដឹងឡើយ។ ក្ដាន់ញីបានរត់ត្រឹកៗនៅក្រោមដើមឈើដែលខ្ញុំអង្គុយ ហើយសំដៅទៅកាន់វាលភក់ ហើយក្ដាន់ឈ្មោលក៏រត់តាមផ្លូវដដែល។ ស្ថានការណ៍នោះគឺល្អឥតខ្ចោះតែម្ដង។ ពេលនោះដែលក្ដាន់ឈ្មោលនៅឆ្ងាយពីខ្ញុំជាង២០ម៉ែត្រ ខ្ញុំបានតម្រង់ស្នាយ៉ាងប្រុងប្រយ័ត្ន ហើយក៏បាញ់ទៅ។ ខ្ញុំបានដឹងនូវវិនាទីដែលខ្ញុំបាញ់ថា ខ្ញុំបានរាលកៃ។ ខ្ញុំសូមនិយាយតាមត្រង់ៈ ខ្ញុំសឹងតែដកដង្ហើមមិនដល់គ្នា ដោយសារតែរត់តាមផ្លូវក្រោយនៃវាលដែលនៅជុំវិញវាលភក់ គឺព្យាយាមទៅដល់មុនក្ដាន់ឈ្មោលដែលនៅទីនោះ។

ខ្ញុំពិតជាខកចិត្តណាស់ដែលឃើញផ្លែស្នាហើរទាបពេក គឺមិនត្រូវសោះ ហើយខ្ញុំដឹងថាខ្ញុំបានបាញ់ខុសកន្លែងសំខាន់។ នៅពេលដែលខ្ញុំបាញ់ ក្ដាន់នោះបានលោតទៅក្នុងព្រៃរបោះក្រាស់ឃ្មឹកនៅក្បែរវាលភក់ ហើយវាក៏បានដើរចេញទៅបាត់ពីភ្នែកខ្ញុំបន្តិចម្ដងៗ។ អ្វីដែលខ្ញុំបានអង្កេតពីការប្រមាញ់លើកមុនៗគឺថា នៅពេលដែលយើងប្រើស្នា ជួនកាលក្ដាន់មិនបានដឹងថាមានអ្វីកើតឡើងទេពេលដែលផ្លែស្នាធ្លាក់។ មានពេលជាច្រើនលើក វាគ្រាន់តែដើរចេញទៅធម្មតា ប្រសិនបើវាមិនបានឃើញ ឬធំក្លិនមនុស្សទេនោះ។ ខ្ញុំក៏បានដឹងថា ជារឿយៗក្ដាន់ដែលមានរបួសនឹងដេកនៅក្នុងគុម្ពោតព្រៃ ហើយដើរមិនសូវបានឆ្ងាយឡើយ។ ដោយហេតុថាក្ដាន់នេះមិនបានឃើញខ្ញុំ វាពិតជាបានធ្វើដូច្នោះមែន។ ខ្ញុំក៏បានចុះពីដើមឈើលបៗ ហើយដើរទៅផ្ទះនៅតាមផ្លូវដែលខ្ញុំបានដើរមកនោះ ជាផ្លូវវាងដើម្បីកុំបំផ្អើលសត្វក្ដាន់។

នៅពេលដែលខ្ញុំទៅដល់ផ្ទះ មនុស្សគ្រប់គ្នាបានចាប់ផ្ដើមសួរខ្ញុំថា តើមានអ្វីកើតឡើង ហើយតើខ្ញុំបាញ់បានក្ដាន់ដែរឬទេ។ ខ្ញុំបានប្រាប់មនុស្សគ្រប់គ្នាពីអ្វីដែលទើបតែកើតឡើង ហើយសុំឲ្យកូនប្រុសៗរបស់ខ្ញុំមកជួយដេញសត្វក្ដាន់ចេញពីព្រៃរបោះជាមួយខ្ញុំ ដោយសង្ឃឹមថាខ្ញុំអាចមានឱកាសបាញ់វាម្ដងទៀត។ យើងបានព័ទ្ធ

ជុំវិញបរិវេណព្រៃរបោះនោះ ហើយចាប់ផ្តើមដើរកាត់វាបន្តិចម្តងៗ។ ភ្លាមៗនោះ ខ្ញុំបានឃើញកូនប្រុសរបស់ខ្ញុំម្នាក់បានកំពុងតែដេញសត្វក្តាន់ ហើយវាក៏បានរត់យ៉ាងលឿនខ្ទាញ់នៅក្នុងព្រៃរបោះខ្ពស់ៗ។ វានៅខាងមុខខ្ញុំខ្ទង់៧០ម៉ែត្រ ដោយឆ្លងពីខាងស្តាំទៅខាងឆ្វេងដៃខ្ញុំ។

រំពេចនោះ ក្តាន់នោះក៏បានជួបនឹងកូនប្រុសរបស់ខ្ញុំម្នាក់ទៀតនៅឯជាយវាលស្មៅ។ ដោយដឹងថា នេះមិនមែនជាមនុស្សដដែលដែលបានដេញវា ហើយវាពិតជាមិនដឹងថាត្រូវរត់ទៅផ្លូវណាដើម្បីឲ្យបានរួចជីវិត វាក៏បានឈប់មួយភ្លែតដើម្បីគិតគូររកដំណោះស្រាយ។ ខ្ញុំដឹងថា ខ្ញុំមានឱកាសតែម្តងនេះប៉ុណ្ណោះ ប្រសិនបើខ្ញុំចង់បាញ់វាឲ្យបាន។ វាមិនទាន់បានឃើញខ្ញុំនៅឡើយទេ។ នៅពេលនេះ វាកំពុងតែឈរនៅចំហៀងខ្ញុំខ្ទង់ ៧០ ម៉ែត្រដោយមើលសំដៅទៅរកកូនប្រុសរបស់ខ្ញុំ។ ស្នាមានកម្លាំងខ្លាំងល្មមគ្រប់គ្រាន់ក្នុងការសម្លាប់ក្តាន់មួយក្បាលនៅក្នុងចម្ងាយនោះ ប៉ុន្តែផ្លែស្នានឹងអាចធ្លាក់នៅប៉ុន្មានសង់ទីម៉ែត្រ ឬដេស៊ីម៉ែត្រមុនពេលហោះទៅចំក្តាន់។ ខ្ញុំមិនធ្លាប់បាញ់ស្នានៅក្នុងចម្ងាយនោះពីមុនទេ ហើយនេះក៏មិនមែនជាស្នាស៊េរីថ្មីដែលអាចបាញ់បានចម្ងាយ ១២០ម៉ែត្រក្នុងមួយវិនាទីដែរ។ វាអាចបាញ់បានត្រឹមខ្ទង់ ៣៥ ទៅ ៤៥ ម៉ែត្រប៉ុណ្ណោះ។

ដោយហេតុថាក្តាន់នៅចំហៀងខ្ញុំ ហើយកំពុងតែឈរស្ងៀម ខ្ញុំបានសម្រេចចិត្តថាបាញ់។ ខ្ញុំបានលើកស្នាឡើង តម្រង់ទៅឯក្តាន់ទាំងប៉ាន់ស្មាន ហើយក៏កេះកៃទៅ។ ខ្ញុំបានសម្លឹងមើលផ្លែស្នាហោះសំដៅទៅរកសត្វក្តាន់ ហើយជាការភ្ញាក់ផ្អើលខ្ញុំបានឃើញព្រួញបានហោះទៅចំសត្វក្តាន់ត្រង់កញ្ចឹងក (សុំអភ័យទោស ប្រសិនបើព័ត៌មានលម្អិតនេះធ្វើឲ្យលោកអ្នកមានអារម្មណ៍មិនសូវស្រួល)។ ពេលនេះ ផ្លែព្រួញក៏នៅជាប់នឹងកញ្ចឹងកសត្វក្តាន់ ធ្លុះពីម្ខាងទៅម្ខាង។ ខ្ញុំក៏បានដើរយឺតៗសំដៅទៅក្នុងគុម្ពោតព្រៃ ត្រង់កន្លែងដែលក្តាន់ដួល។ វាគឺនៅត្រង់នោះឯង! ខ្ញុំបានបាញ់វាត្រូវ ហើយក៏បានក្តាន់របស់ខ្ញុំដែរ។

នៅពេលដែលកូនប្រុសរបស់ខ្ញុំឈ្មោះថាធីម ចូលរួមជាមួយខ្ញុំ ខ្ញុំកាន់តែចាប់អារម្មណ៍នៅលើស្នែងរបស់ក្តាន់ជាងអ្វីៗផ្សេងទៀត នៅលើកនេះ។ ខ្ញុំមិនបានមានឱកាសរាប់គន្លាក់ស្នែងទេ ប៉ុន្តែនៅពេលដែលយើងរាប់ យើងក៏ឃើញថាមានគន្លាក់ចំនួន៧។ ដោយពិនិត្យមើលសត្វក្តាន់កាន់តែជិត យើងបានឃើញថាតាមពិតវាមានគន្លាក់ប្រាំបី ប៉ុន្តែមានចុងស្នែងមួយបានបាក់ ហើយធ្វើឲ្យវានៅសល់តែប្រាំពីរ។ ធីម ហើយនិងខ្ញុំគ្រាន់តែឈរនៅទីនោះទាំងកោតស្ញប់ស្ញែង និងសរសើរព្រះអម្ចាស់។ ព្រះរាជ្យរបស់ទ្រង់គឺពិតជាអស្ចារ្យណាស់! នៅខណៈដែលធីម ហើយនិងខ្ញុំឈរនៅទីនោះ យើងក៏ទទួលស្គាល់ថា «តើនរណានឹងព្រមជឿយើង? តើមាននរណាដឹងថាព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការដោយរបៀបនេះដែរឬទេ?»

ខ្ញុំគិតថាលោកអ្នកបានយល់ពីចំណុចសំខាន់ហើយ។ ព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការដោយច្បាប់ជាក់លាក់ដែលត្រូវបានកំណត់ ហើយអាចទុកចិត្តបានក្នុងការបំពេញមុខងារតាមរបៀបដដែលនៅរាល់លើក។ កាលពីដំបូងឡើយ ខ្ញុំពិតជារំភើបណាស់នៅពេលដែលបានដឹងថាច្បាប់ទាំងនេះនឹងមានប្រសិទ្ធិភាពសម្រាប់កិច្ចការទាំងឡាយ រួមទាំងថវិកាដែរ។ ខ្ញុំអាចរៀនបានពីច្បាប់ទាំងនេះ។ ខ្ញុំអាចក្លាយជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ ហើយខ្ញុំអាចស្វែងយល់ពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើរការ។ ព្រះជាម្ចាស់នឹងជួយដល់ខ្ញុំជាក់ជាមិនខាន។

# ជំពូកទី២
# អ័ព្ទពណ៌ខៀវ

នៅពេលដែលឌ្រិនដានិងខ្ញុំបានចាប់ផ្តើមមើលឃើញព្រះរាជ្យដំណើរការ និង បំពេញមុខងារនៅក្នុងជីវិតរបស់យើង យើងក៏បានមានសេរីភាពពីបំណុលទាំងស្រុង ហើយយើងចង់ប្រាប់មនុស្សគ្រប់គ្នាដែលយើងជួបអំពីអ្វីដែលយើងបានរៀន។ យើងបានប្រាប់មនុស្សគ្រប់រូបដែលស្តាប់យើង នៅពេលដែលយើងបានចាប់ផ្តើមក្រុមជំនុំ ហើយខ្ញុំបើកដំណើរការអាជីវកម្មរបស់ខ្ញុំ។ ប៉ុន្តែ ខ្ញុំមានអារម្មណ៍នៅក្នុងវិញ្ញាណរបស់ខ្ញុំថាមានអ្វីម្យ៉ាងទៀត ហើយខ្ញុំមិនដឹងថាយ៉ាងម៉េចទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាមានច្រើនថែមទៀតដែលព្រះជាម្ចាស់កំពុងតែដឹកនាំខ្ញុំឲ្យធ្វើ ដើម្បីចែករំលែកពីព្រះរាជ្យរបស់ទ្រង់ជាមួយមនុស្ស។

នៅពេលមួយឆ្នាំ ២០០៥ នៅក្នុងវិញ្ញាណរបស់ខ្ញុំហាក់ដូចជាមានអារម្មណ៍ជំរុញឲ្យធ្វើសន្និបាតមួយដែលហៅថាសន្និបាតបដិវត្តន៍ថវិកា ជាសន្និបាតដែលមានការជួបជុំប្រាំដងជាប់ៗគ្នា ដែលខ្ញុំមានអារម្មណ៍ថា ខ្ញុំអាចនឹងមានពេលគ្រប់គ្រាន់ដើម្បីពន្យល់បង្ហាញពីគោលការណ៍ហិរញ្ញវត្ថុនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលបានផ្លាស់ប្រែជីវិតរបស់ខ្ញុំ។ ដោយបានចម្រើនវ័យឡើងនៅក្នុងក្រុមជំនុំមេតូឌីស្ទ ជួនកាលយើងបានជួបនឹងការផុសផុលពេញមួយសប្តាហ៍។ ខ្ញុំបានឃើញពីហេតុការណ៍បែបនេះនៅក្នុងវិញ្ញាណ គឺការជួបជុំប្រាំផងដែលខ្ញុំអាចមានពេលគ្រប់គ្រាន់

ក្នុងការដឹកនាំមនុស្សឲ្យបានយល់ពីគោលគំនិតនិងគោលការណ៍នានាដែលព្រះជាម្ចាស់បានបង្រៀនដល់ខ្ញុំនៅខាងផ្នែកហិរញ្ញវត្ថុ។ រហូតមកទល់ពេលនោះ ខ្ញុំមិនដែលបានចងក្រងគោលការណ៍ទាំងនេះក្នុងទម្រង់ជាប្រព័ន្ធឡើយ។ ប៉ុន្តែនៅក្នុងវិញ្ញាណរបស់ខ្ញុំ ខ្ញុំនៅតែមើលឃើញខ្លួនឯងរៀបចំអង្គសន្និបាតដែលមានប្រាំវេននៅលើប្រធានបទហិរញ្ញវត្ថុ។

នៅពេលដែលខ្ញុំកំពុងអធិស្ឋានពីវា ខ្ញុំក៏បានជួបនឹងលោកឡារីដោយចៃដន្យ។ លោកឡារីជាមិត្តដែលខ្ញុំខានជួបជាយូរមកហើយ។ គាត់បានប្រាប់ខ្ញុំពីសន្និបាតមួយដែលនឹងកើតឡើងនៅប្រទេសអាល់បានី ហើយដែលគាត់បានរៀបចំ។ គាត់បានអញ្ជើញខ្ញុំឲ្យទៅបង្រៀននៅសន្និបាតនោះដែរ។ លោកឡារីបានបម្រើបេសកកម្មនៅប្រទេសអាល់បានីជិត ១២ ឆ្នាំមកហើយ ហើយគាត់បាននាំការផ្លាស់ប្តូរដ៏ធំសម្បើមនៅក្នុងប្រទេសនោះ។ ខ្ញុំមិនដែលគិតថានឹងធ្វើដំណើរឆ្ងាយយ៉ាងនោះទេ។ ខ្ញុំមិនសូវជាធ្វើដំណើរច្រើន ហើយក៏មិនធ្លាប់ទៅប្រទេសអាល់បានីដែរ។ ខ្ញុំថែមទាំងមិនប្រាកដថា ប្រទេសអាល់បានីនៅឯណាឡើយ។ លោកឡារីបានលើកចិត្តខ្ញុំថា គាត់នឹងរៀបចំអង្គសន្និបាតជាលក្ខណៈថ្នាក់ជាតិ ដែលនឹងមានគ្រូគង្វាលជាច្រើនពីប្រទេសនោះចូលរួម ហើយគាត់គិតថាចំណេះដឹងរបស់ខ្ញុំស្តីអំពីថវិកានៃព្រះរាជ្យនឹងជួយជាប្រយោជន៍ដល់មនុស្សជាច្រើន។ លោកឡារីបាននិយាយទៀតថា ខ្ញុំនឹងមានពេលបង្រៀនពីពីរទៅបីវគ្គនៅក្នុងសន្និបាតនោះ។ ទោះបីជាវាមិនមែនជាពេលប្រាំវគ្គក៏ដោយ ក៏ខ្ញុំនៅតែរំភើបក្នុងការបង្រៀននៅលើប្រធានបទនោះក្នុងពេលប៉ុន្មានវគ្គដែលខ្ញុំមានដែរ។ ដូច្នេះ ខ្ញុំក៏ប្រាប់គាត់ថាខ្ញុំនឹងទៅ។

នៅពេលដែលខ្ញុំចុះពីលើយន្តហោះនៅប្រទេសអាល់បានី លោកឡារីបានមកជម្រាបសួរខ្ញុំដោយសេចក្តីប្រកាសដ៏ពិរោះថា «លោកហ្គារី មានគ្រូអធិប្បាយម្នាក់ដែលខ្ញុំបានអញ្ជើញបានលុបចោលការបង្រៀននៅនាទីចុងក្រោយ ហើយលោកនឹងបង្រៀននៅក្នុងវគ្គចំនួនប្រាំ» ខ្ញុំរំភើបជាខ្លាំង។ គឺហ្នឹងហើយ! ខ្ញុំដឹងថានេះជាការ

រៀបចំរបស់ព្រះជាម្ចាស់ ហើយពេលនេះខ្ញុំមានឱកាសនឹងបានឃើញពីរបៀបនៃអ្វីដែលខ្ញុំបានឃើញនៅក្នុងវិញ្ញាណលេចចេញជារូបរាងហើយ។ ខ្ញុំបានរៀបចំសន្លឹកមេរៀនដាក់ជាប់ជាមួយខ្ញុំ ប៉ុន្តែមិនបានរៀបចំវាជាលក្ខណៈ៥មេរៀនឡើយ។ ដូច្នេះជារៀងរាល់ថ្ងៃនៅក្នុងអង្គសន្និបាតខ្ញុំឡើងទៅបង្រៀន ហើយនៅពេលចប់ ខ្ញុំក៏ទៅអធិស្ឋាននៅក្នុងវិញ្ញាណ ហើយសរសេរមេរៀនសម្រាប់វគ្គសន្និបាតបន្ទាប់ទៀត។ នៅក្នុងវគ្គនីមួយៗ ព្រះជាម្ចាស់បានចាក់ប្រេងតាំងលើខ្ញុំយ៉ាងអស្ចារ្យណាស់។

មុនពេលដែលខ្ញុំបន្តវែងឆ្ងាយទៀត ខ្ញុំសូមជម្រាបលោកអ្នកថា ប្រទេសអាល់បានីធ្លាប់ជាប្រទេសក្រីក្រជាងគេនៅពេលដែលខ្ញុំទៅនោះ។ ប្រាក់ខែជាមធ្យមគឺជាង ៥០០ ដុល្លារក្នុងមួយខែ ហើយមនុស្សបានប្រើប្រាស់ការសូកប៉ាន់ជារបៀបដើម្បីឲ្យបានរស់រាន។ នៅពេលដែលខ្ញុំគិតពីការបង្រៀនមនុស្សនៅលើផ្នែកហិរញ្ញវត្ថុ ខ្ញុំមិនប្រាដថាគេនឹងទទួលមេរៀននោះដោយរបៀបណាទេ។ ខ្ញុំដឹងថាព្រះបន្ទូលអាចធ្វើការសម្រាប់មនុស្សគ្រប់ៗរូប ប៉ុន្តែនេះជាបទពិសោធន៍ថ្មីមួយសម្រាប់ខ្ញុំ។ នៅពេលដែលខ្ញុំបង្រៀនមេរៀនទីមួយ ខ្ញុំបានមានអារម្មណ៍ពីរនាំងដែលរារាំងមនុស្សមិនឲ្យយល់។ នៅពេលបង្រៀនមេរៀនទីពីរ ខ្ញុំអាចមានអារម្មណ៍ថា មនុស្សចាប់ផ្តើមមានចិត្តស្រេកឃ្លានខាងឯវិញ្ញាណ ហើយខ្ញុំអាចឃើញមានជំនឿរីកដុះដាលឡើងតាមរយៈទឹកមុខរបស់គេ នៅពេលដែលគេបានឮនូវដំណឹងល្អនៃព្រះរាជ្យ។ នៅរៀងរាល់ថ្ងៃពេលដែលខ្ញុំបង្រៀនដល់មនុស្ស ពួកគេកាន់តែរីករាយទៅៗ ហើយខ្ញុំអាចប្រាប់បានថា ពួកគេរំភើបអំពីព្រះរាជ្យណាស់។

នៅល្ងាចមុនដែលខ្ញុំបង្រៀនមេរៀនចុងក្រោយ ព្រះអម្ចាស់បានមានបន្ទូលមកកាន់ខ្ញុំថា ខ្ញុំត្រូវនាំមនុស្សឲ្យថ្វាយតង្វាយសម្រាប់ក្រុមជំនុំក្នុងតំបន់នានា។ ខ្ញុំមិនប្រាកដពីការនេះទេ ព្រោះជាបឋម វាមិនមែនជាការជួបជុំដែលខ្ញុំបានរៀបចំ ហើយទីពីរ ខ្ញុំមិនប្រាកដថាមនុស្សនឹងឆ្លើយតបដោយរបៀបណាទេ។ ឡារីនិងខ្ញុំបានចេញថ្លៃធ្វើដំណើរ និងថ្លៃស្នាក់នៅសម្រាប់គ្រូគង្វាលក្នុងតំបន់ ដើម្បីអាចឲ្យពួកគេមក

ចូលរួមការជួបជុំនេះបាន។ ខ្ញុំបាននិយាយជាមួយឡារីអំពីការនេះ ហើយគាត់បានប្រាប់ខ្ញុំថាសូមធ្វើបែបនេះចុះ។

ដូច្នេះនៅក្នុងវគ្គចុងក្រោយ ខ្ញុំក៏បាននាំមនុស្សឲ្យថ្វាយតង្វាយសម្រាប់អង្គសន្និបាត ហើយមានការចាក់ប្រេងតាំងខ្លាំងណាស់រហូតដល់ខ្ញុំសឹងតែឈរមិននឹង។ មនុស្សគ្រប់ៗរូបនៅក្នុងសាលប្រជុំរាំផង ស្រែកផងនៅពេលដែលពួកគេយកប្រាក់មកថ្វាយនៅខាងមុខ។ ក្រុមបដិសណ្ឋារកិច្ចដែលបានកាន់ថង់តង្វាយពេលដែលមនុស្សថ្វាយ បានយំ ហើយសឹងតែឈរមិននឹង។ ខ្ញុំមិនធ្លាប់បានឃើញហេតុការណ៍ណាដូចនេះពីមុនមកទេ គឺយ៉ាងហោចណាស់ពេលទទួលតង្វាយ។ នៅពេលដែលខ្ញុំមើលមនុស្សរាំ និងស្រែកដោយអំណរខណៈដែលគេកំពុងតែថ្វាយតង្វាយ ខ្ញុំក៏បានលង់ក្នុងការចាក់ប្រេងតាំង និងជំនឿដ៏ស្មោះសរបស់អស់អ្នកដែលថ្វាយគ្រាប់ពូជដ៏វិសេសវិសាលទាំងនេះ។

បន្ទាប់ពីការប្រជុំចប់ ឡារីបានរំជួលចិត្តជាខ្លាំងដោយសារអ្វីដែលគាត់បានឃើញ។ គាត់ក៏បានភ្ញាក់ផ្អើលដោយបានឃើញថង់តង្វាយទាំងពីរនោះ មានពេញណែនទៅដោយប្រាក់តង្វាយដែលយើងបានយកទៅកាន់អាផាតមិនរបស់គាត់ បន្ទាប់ពីចប់ការប្រជុំពេលល្ងាច។ លោកឡារីបានប្រាប់ខ្ញុំថា នៅក្នុងការជួបជុំដែលយើងបានប្រមូលប្រាក់តង្វាយពីមុន ជាទូទៅគឺមានថង់តង្វាយតែមួយប៉ុណ្ណោះដែលពេញដោយអន្លើ។ យើងក៏បានប្រញាប់ប្រញាល់ធ្វើដំណើរទៅ ហើយលាក់ថង់តង្វាយនៅពេលដែលយើងធ្វើដំណើរទៅអាផាតមិនដ៏តូចរបស់លោកឡារី នៅតាមផ្លូវដែលមានមនុស្សច្រើនកកកុញ។

នៅពេលដែលយើងទៅដល់អាផាតមិនរបស់ឡារី យើងបានអង្គុយចុះនៅក្នុងបន្ទប់ទទួលភ្ញៀវរបស់គាត់ ហើយបើកថង់តង្វាយដើម្បីរាប់ប្រាក់។ នៅពេលដែលឡារីចាក់ប្រាក់ចេញពីថង់តង្វាយ មានអ្វីម្យ៉ាងបានកើតឡើងដែលរហូតមកទល់សព្វថ្ងៃនេះ ខ្ញុំតែមិនអាចរកពាក្យមកពណ៌នាបាន។ ភ្លាមៗនោះ មានអ័ព្ទពណ៌ខៀវខ្ចីបានបំពេញនៅក្នុងបន្ទប់នោះ ហើយព្រះវត្តមានរបស់ព្រះជាម្ចាស់បានហ៊ុំព័ទ្ធជុំ

វិញយើង។ យើងអង្គុយនៅស្ងៀមក្រោមប្រេងតាំងដែលបំពេញនៅក្នុងបន្ទប់នោះ។ វាមិនដូចជាការចាក់ប្រេងតាំងផ្សេងៗទៀតដែលខ្ញុំបានទទួលនៅពេលអធិប្បាយ ឬ អធិស្ឋានសម្រាប់មនុស្សឡើយ។ ផ្ទុយទៅវិញ ប្រេងតាំងនេះមានវត្តមានរបស់ព្រះជាម្ចាស់មកជាមួយ។ វាជាប្រេងតាំងដ៏វិសុទ្ធ ហើយធ្វើឲ្យខ្ញុំមានអារម្មណ៍ថាខ្ញុំនៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ផ្ទាល់តែម្តង។ នៅពេលដែលយើងអង្គុយនៅទីនោះ ប្រេងតាំងនោះបានហូរមកខ្លាំងឡើងៗនៅក្នុងបន្ទប់។ អ្វីដែលយើងអាចធ្វើបានគឺគ្រាន់តែអង្គុយនៅទីនោះហើយយំ។ បន្ទាប់មក នៅក្នុងពំនូកប្រាក់តង្វាយដែលគលើតុតូចនោះ ខ្ញុំបានឃើញចិញ្ចៀនរៀបការរបស់បុរសម្នាក់។ នៅយប់នោះ ខ្ញុំពិតជារំជួលចិត្តណាស់ដោយបានឃើញមនុស្សម្នាក់ដែលពុំមានប្រាក់សោះ បានថ្វាយវត្ថុតែមួយដែលមានតម្លៃវិសេសវិសាលរបស់គាត់។ រំពេចនោះព្រះអម្ចាស់មានបន្ទូលមកកាន់ខ្ញុំថា៖

*«យើងត្រាស់ហៅកូនទៅកាន់ជាតិសាសន៍នានាដើម្បីបង្រៀនគេនូវគោលការណ៍ដែលយើងបានបង្រៀនដល់កូនអំពីព្រះរាជ្យ និងថវិកា។ ចិញ្ចៀននេះត្រូវបានថ្វាយមកក្នុងថង់តង្វាយដោយជំនឿដ៏ធំធេង។ ប៉ុន្តែ យើងចង់ឲ្យកូនយកវាទុកជាសេចក្តីរំឭកអំពីយប់នេះ។ ចូរដឹងដែរថា ដូចដែលចិញ្ចៀនរៀបការដែលបញ្ជាក់ពីសម្ពន្ធមេត្រី កូនក៏នឹងប្រកាសពីសម្ពន្ធមេត្រីរបស់យើងស្តីពីការផ្គត់ផ្គង់ដល់ប្រជារាស្ត្ររបស់យើងដែរ។ ចូរដឹងថា នៅកន្លែងណាដែលយើងចាត់កូនឲ្យទៅ យើងក៏នឹងផ្គត់ផ្គង់ថវិកាក្នុងការចំណាយដែរ។»*

នៅពេញមួយយប់នោះ ខ្ញុំគេងមិនលក់ទាល់តែសោះ។ យប់នោះខ្ញុំស្នាក់នៅក្នុងអាផាតមិនរបស់ឡារី ហើយមានប្រេងតាំងពីព្រះជាម្ចាស់សណ្ឋិតនៅទីនោះ។ នៅពេលធ្វើដំណើរឆ្លងកាត់សមុទ្រអាត្លង់ទិកមកស្រុកកំណើតវិញ ខ្ញុំក៏គេងមិនលក់ដែរ។ អ្វីដែលខ្ញុំអាចធ្វើបានគឺមើលទៅក្រៅបង្អួច ហើយយំក្នុងពេលជិះយន្តហោះ

ទាំង ៨ ម៉ោងតែម្ដង។ ខ្ញុំគេងមិនលក់អស់រយៈពេល ៤៦ ម៉ោង បន្ទាប់ពីព្រះអម្ចាស់មានបន្ទូលមកកាន់ខ្ញុំនៅយប់នោះ។ អស់រយៈពេលជាច្រើនខែបន្ទាប់ពីយប់នោះ នៅពេលណាដែលខ្ញុំនឹកដល់វា ខ្ញុំក៏មានអារម្មណ៍ពីព្រះវត្តមានដដែល ហើយក៏ចាប់ផ្ដើមយំ។

ខ្ញុំមិនបានប្រាប់ឡារីពីអ្វីដែលព្រះអម្ចាស់បានប្រាប់មកកាន់ខ្ញុំអំពីចិញ្ចៀននោះទេឡើយ។ ប្រាក់តង្វាយនៅក្នុងថង់តង្វាយត្រូវបានប្រគល់ទៅក្រុមជំនុំនានានៅប្រទេសអាល់បានី ហើយខ្ញុំដឹងថាគេក៏អាចលក់ចិញ្ចៀនដើម្បីបានប្រាក់បន្ថែមដែរ ប៉ុន្តែខ្ញុំបានដឹងពីអ្វីដែលព្រះអម្ចាស់បានប្រាប់ខ្ញុំអំពីវា។ ដូច្នេះ ខ្ញុំរីករាយណាស់ពេលដែលឡារីបានទូរស័ព្ទមកខ្ញុំ ហើយប្រាប់ខ្ញុំថា ព្រះអម្ចាស់បានមានបន្ទូលមកកាន់គាត់ ហើយប្រាប់គាត់ឲ្យប្រគល់ចិញ្ចៀននោះមកឲ្យខ្ញុំ។ ខ្ញុំបានយកចិញ្ចៀននេះទៅចាប់ជាប់នឹងជញ្ជាំង ហើយនៅពេលនេះវានៅក្នុងការិយាល័យរបស់ខ្ញុំ។ មានពេលជាច្រើនលើកដែលខ្ញុំបានមើលទៅកាន់ចិញ្ចៀននោះ ហើយក៏ត្រូវចងចាំនូវព្រះបន្ទូលរបស់ព្រះអម្ចាស់សម្រាប់ខ្ញុំនៅយប់នោះ នៅកាលដែលខ្ញុំបានជួបនឹងឧបសគ្គហិរញ្ញវត្ថុធំៗនៅពេលប៉ុន្មានឆ្នាំនោះ តាំងពីពេលនោះមក។ ព្រះជាម្ចាស់បានស្មោះត្រង់ជានិច្ចក្នុងការផ្គត់ផ្គង់អ្វីៗដែលខ្ញុំត្រូវការ ដើម្បីដើរតាមទិសដៅរបស់ទ្រង់ដែលបានបង្ហាញដល់ខ្ញុំនាយប់នោះ។ នារាត្រីឯប្រទេសអាល់បានីបានផ្លាស់ប្ដូរជីវិតរបស់ខ្ញុំ ប៉ុន្តែមានច្រើនថែមទៀតដែលព្រះជាម្ចាស់នឹងបង្ហាញដល់ខ្ញុំនៅពេលខាងមុខ។

នៅពេលដែលខ្ញុំធ្វើដំណើរពីប្រទេសអាល់បានីត្រលប់ទៅដល់ផ្ទះវិញ ខ្ញុំមានអារម្មណ៍ជំរុញយ៉ាងខ្លាំងក្នុងការពាំនាំនូវព្រះរាជសារស្ដីអំពីព្រះរាជ្យនេះទៅគ្រប់ទីកន្លែងដែលខ្ញុំអាចទៅបាន។ ខ្ញុំមានចិត្តឆេះឆួលយ៉ាងខ្លាំងក្នុងការចែករំលែកព័ត៌មាននេះ ហើយខ្ញុំក៏ព្រួយបារម្ភក្នុងការបង្រៀនមេរៀនទាំងប្រាំនោះម្ដងទៀត ព្រមទាំងឆ្ងល់ថាតើហេតុការណ៍ដដែលនឹងកើតឡើងដែរឬទេ។ ខ្ញុំមិនចាំបាច់រង់ចាំយូរទេ។ មានគ្រូគង្វាលម្នាក់នៅរដ្ឋអ៊ូថាបានអញ្ជើញខ្ញុំឲ្យទៅ ហើយបង្រៀនមេរៀនទាំង

ប្រាំដដែល។ គាត់បានឮពីលោកឡារីថា ហេតុការណ៍នោះបានផ្លាស់ប្រែជីវិតមនុស្សជាច្រើន ហើយគាត់ចង់ឲ្យខ្ញុំទៅ។ គាត់ជាគ្រូគង្វាលលើក្រុមជំនុំតណ្ហាតូចមួយ ដែលមានភាពក្រីក្រណាស់។ ពួកគេត្រូវការជំនួយផ្នែកហិរញ្ញវត្ថុ ហើយប្រសិនបើអ្វីដែលលោកឡារីបានប្រាប់គាត់ជាការពិត គាត់មានអារម្មណ៍ថាខ្ញុំអាចជួយដល់គាត់បាន។

ដូច្នេះខ្ញុំក៏បានធ្វើដំណើរទៅ ហើយបង្រៀននៅក្នុងការប្រជុំនាព្រឹកថ្ងៃអាទិត្យ និងល្ងាចថ្ងៃអាទិត្យ រហូតដល់ល្ងាចថ្ងៃពុធ។ មានមេរៀនប្រាំដូចកាលនៅប្រទេសអាល់បានីដែរ ហើយខ្ញុំបានទទួលការឆ្លើយតបបែបដដែលពីមនុស្ស។ មនុស្សបានស្រែក និងលោតរាំនៅក្រោមការចាក់ប្រេងតាំងដ៏ខ្លាំងសម្បើមនៅល្ងាចចុងក្រោយនៃសន្និបាតខណៈដែលគេកំពុងតែថ្វាយប្រាក់តង្វាយ។ នៅលើកនេះ ខ្ញុំមិនបានឃើញអ័ព្ទពណ៌ខៀវទេ ប៉ុន្តែខ្ញុំមានអារម្មណ៍ពីការចាក់ប្រេងតាំងដ៏ខ្លាំងក្លានៅពេញមេរៀនទាំងប្រាំដែលខ្ញុំបានបង្រៀន។ បន្ទាប់ពីបង្រៀនមេរៀនចុងក្រោយចប់ ខ្ញុំក៏បានភ្ញាក់ផ្អើលដូចជាលោកឡារីនៅប្រទេសអាល់បានីដែរ គឺដោយបានឃើញប្រាក់តង្វាយជាច្រើនដែលមានប្តីប្រពន្ធតែ ១៧ គូប៉ុណ្ណោះជាអ្នកថ្វាយ។ ខ្ញុំបានចាក់សោប្រាក់តង្វាយទាំងនោះនៅក្នុងថង់ប្រាក់ដែលមានសោ ហើយយកវាទៅឯការិយាល័យដើម្បីរាប់នៅថ្ងៃបន្ទាប់។

នាពេលព្រឹកឡើងនាថ្ងៃនោះ ខ្ញុំបានទទួលទូរស័ព្ទពីការិយាល័យ។ លេខារបស់ខ្ញុំជាអ្នកទូរស័ព្ទមក ហើយខ្ញុំអាចដឹងថាមានរឿងអ្វីមួយកើតឡើង។ នាងនិយាយរដិបរដុប ហើយស្តាប់ទៅដូចជាយំផង។ នាងនិយាយពាក្យដំបូងថា «លោកគ្រូ មានរឿងដែលខ្ញុំចង់ប្រាប់ទាក់ទងនឹងប្រាក់ដែលលោកគ្រូបានយកមក» ខ្ញុំសួរថា «អ្នកនាងត្រេសស៊ី តើនាងចង់បានន័យថាម៉េច?» បន្ទាប់មក នាងក៏បានបន្តដោយប្រាប់ខ្ញុំថា នាងបានបើកថង់ប្រាក់ដើម្បីរាប់ ហើយដាក់វាទៅក្នុងធនាគារ ប៉ុន្តែនៅនាទីដែលនាងបើកថង់ មានការចាក់ប្រេងតាំងដ៏ខ្លាំងក្លាសណ្ឋិតលើនាងនៅឯការិយាល័យ ហើយនាងបានដួលទៅលើឥដ្ឋ។ លេខារបស់ខ្ញុំម្នាក់ទៀតបាន

ឮពីការរំជើបរំជួលនេះ នាងក៏ចូលមកហើយក៏បានចាប់ផ្ដើមញ័រញាក់នៅក្រោមប្រេងតាំងដែរ។ ត្រេសស៊ីបាននិយាយថា «តើមានអ្វីកើតឡើងជាមួយនឹងប្រាក់ពីរដ្ឋអូថានោះ?» ខ្ញុំបានប្រាប់នាងថា ខ្ញុំមិនដឹងទេ។

**ប៉ុន្តែ ព្រះយេស៊ូមិនគ្រាន់តែបានបង់ថ្លៃឲ្យយើងមានសិទ្ធិទៅស្ថានសួគ៌ប៉ុណ្ណោះទេ តែទ្រង់ក៏ធ្វើឲ្យយើងអាចរស់នៅជាបុត្រា ឬបុត្រីរបស់ព្រះជាម្ចាស់ និងរីករាយជាមួយនឹងប្រយោជន៍នានានៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅលើភពផែនដីនេះដែរ។**

ប៉ុន្មានសប្ដាហ៍ក្រោយមក ខ្ញុំកំពុងតែបង្រៀនគោលការណ៍ដដែលនេះនៅក្នុងក្រុមជំនុំតូចមួយនៅរដ្ឋអូហៃយ៉ូភាគខាងត្បូង។ នៅក្នុងក្រុមជំនុំនេះ យើងបានផ្ញើមេរៀនបួនដំបូងតាមរយៈឌីវីឌី ហើយពួកគេបានមើលមេរៀនទាំងនោះក្នុងរយៈពេលបួនសប្ដាហ៍មុន។ ខ្ញុំបានធ្វើដំណើរទៅនាល្ងាចថ្ងៃអាទិត្យ ដើម្បីបង្រៀនមេរៀនទីប្រាំបង្ហើយ។ នៅលើកនេះទៀត ការចាក់ប្រេងតាំងបានហូរមកខ្លាំងមែនទែន រហូតដល់ធ្វើឲ្យយើងសឹងតែដួល។ នៅពេលដែលខ្ញុំធ្វើការប្រមូលប្រាក់តង្វាយនៅយប់នោះ ខ្ញុំក៏បានបានទទួលការឆ្លើយតបដដែលដូចដែលខ្ញុំបានឃើញនៅក្នុងការជួបជុំមុនៗ ។ មនុស្សពិតជារំភើបណាស់ក្នុងការថ្វាយ។ នៅអំឡុងពេលថ្វាយប្រាក់តង្វាយ ក្រុមជំនុំបានដាក់កន្ត្រកមួយនៅខាងមុខ ដើម្បីឲ្យមនុស្សអាចថ្វាយតង្វាយក្រៅពីប្រាក់។ នៅពេលនេះ មានអ័ព្ទពណ៌ខៀវទៀតហើយ។ មានហាក់ដូចជាកងរង្វង់ដែលមានអង្កត់ផ្ចិតប្រមាណជា ១.៥ម៉ែត្រនៅជុំវិញកន្ត្រកតង្វាយ នៅខណៈដែលមនុស្សកំពុងតែថ្វាយ។ ប្រេងតាំងគឺពិតជាខ្លាំងណាស់ រហូតដល់គេត្រូវគ្រាខ្ញុំទៅឯឡានបន្ទាប់ពីការប្រជុំចប់ ព្រោះខ្ញុំមិនអាចដើរដោយខ្លួនឯងបាន។

នៅពេលដែលរឿងនេះកើតឡើង ខ្ញុំមិនបានដឹងថាមានរឿងអ្វីកំពុងតែកើតឡើងនោះទេ ហើយខ្ញុំក៏មិនដែលបានឮថាវាកើតឡើងនៅកន្លែងណាផ្សេងទៀត

ដែរ។ ខ្ញុំបានបន្តបង្រៀននៅតាមសន្និបាតនានា ហើយការចាក់ប្រេងតាំងក៏បានបន្តហូរមកយ៉ាងខ្លាំងក្លាដែរ។ ហើយបាទ អ័ព្ទពណ៌ខៀវនោះបានកើតឡើងម្តងទៀតនៅក្នុងសន្និបាតពីរបី។ ប៉ុន្តែ ផ្នែកដែលធ្វើឲ្យខ្ញុំមានចម្ងល់បំផុតគឺការដែលប្រេងតាំងសណ្ឋិតនៅលើលុយ។ បន្ទាប់ពីចប់សន្និបាត បុគ្គលិករបស់ខ្ញុំមានការពិបាករាប់ប្រាក់តង្វាយ។ ចូរចាំថា ការចាក់ប្រេងតាំងបានហូរមកលើបន្ទប់អាផាតមិននៅប្រទេសអាល់បានីនោះ ពេលដែលលោកឡារីបានចាក់ប្រាក់តង្វាយទៅលើតុ? ប្រសិនបើលោកអ្នកប៉ះប្រាក់តង្វាយនោះ លោកអ្នកនឹងមានអារម្មណ៍ពីការចាក់ប្រេងតាំង ហើយចាប់ផ្តើមញ័រភ្លាម។ ខ្ញុំដឹងថាស្តាប់ទៅចម្លែកណាស់ តែខ្ញុំបានអង្កេតឃើញថាវាពិតជាកើតឡើងដូច្នេះមែន។

ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ ខ្ញុំមានចម្ងល់យ៉ាងខ្លាំងពីសេចក្តីនេះ ហើយសួរព្រះអម្ចាស់ពីវា។ ទ្រង់បានមានបន្ទូលមកកាន់ខ្ញុំ ហើយប្រាប់ខ្ញុំថាហេតុអ្វីបានជាការចាក់ប្រេងតាំងដ៏ខ្លាំងក្លានេះបានកើតឡើងនៅលើប្រាក់តង្វាយ។ ទ្រង់បានប្រាប់ខ្ញុំថា មនុស្សភាគច្រើនបានថ្វាយដោយសារវាជាកាតព្វកិច្ច ឬជាការកាន់តាមវិន័យ។ មនុស្សមួយចំនួនថ្វាយដោយគិតថាវាជារូបមន្ត ប៉ុន្តែពួកគេមិនមានជំនឿទាំងស្រុងឡើយនៅពេលដែលថ្វាយ។ មានមនុស្សជាច្រើនថ្វាយដោយព្រោះគេគិតថា ព្រះជាម្ចាស់នឹងខ្ញាល់នឹងពួកគេ ប្រសិនបើគេមិនថ្វាយ។ មនុស្សមួយចំនួនទៀតថ្វាយ ដោយគិតថាវាជាប្រាក់ដែលគេជំពាក់។ ទ្រង់បានប្រាប់ខ្ញុំថា នៅពេលដែលខ្ញុំបង្រៀនអំពីព្រះរាជ្យរបស់ទ្រង់ និងបង្ហាញពីគោលការណ៍ផ្នែកថវិកាដែលត្រូវបានលាក់កំបាំង ស្តីអំពីព្រះរាជ្យ មានជំនឿបានផុសឡើងនៅក្នុងដួងចិត្តរបស់មនុស្ស។ បន្ទាប់មក នៅពេលដែលពួកគេថ្វាយ ពួកគេពិតជាថ្វាយដោយជំនឿមែន ហើយនោះឯងជាស្ពានផ្សារភ្ជាប់ទៅកាន់ព្រះរាជ្យ ដែលអាចឲ្យការចាក់ប្រេងតាំងហូរមក។

ចាប់តាំងពីការធ្វើដំណើរទៅប្រទេសអាល់បានីនៅឆ្នាំ២០០៥នោះមក ជីវិតរបស់ខ្ញុំបានផ្លាស់ប្រែជាខ្លាំង។ បំណងចិត្តរបស់ខ្ញុំក្នុងការឈោងចាប់ទៅកាន់

មនុស្សដោយដំណឹងល្អស្ដីអំពីព្រះរាជ្យបានបណ្ដាលឲ្យខ្ញុំនិងខ្ញុំប្រើប្រាស់កម្មវិធីទូរទស្សន៍ ដើម្បីឈោងចាប់ដល់ជាតិសាសន៍នានាដោយដំណឹងល្អនេះ។ និយាយឲ្យចំទៅ នៅសព្វថ្ងៃនេះយើងចំណាយប្រាក់រាប់លានដុល្លារជារៀងរាល់ឆ្នាំ ដើម្បីប្រាប់មនុស្សអំពីព្រះរាជ្យដែលយើងបានរកឃើញនៅពេលជាច្រើនឆ្នាំមុន។ ប៉ុន្តែ លោកអ្នកប្រហែលជាមិនទាន់បានឮអំពីដំណឹងល្អនៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅឡើយទេ។ យើងក៏អញ្ចឹងដែរ ពីមុនមកគឺជាអ្នកជឿដែលរាប់ថាមានឈ្មោះទៅស្ថានសួគ៌ ប៉ុន្តែមិនចេះស្រាយស្ថានសួគ៌ឲ្យមានវត្តមាននៅលើផែនដី។ ប៉ុន្តែ ព្រះយេស៊ូមិនគ្រាន់តែបានបង់ថ្លៃឲ្យយើងមានសិទ្ធិទៅស្ថានសួគ៌ប៉ុណ្ណោះទេ តែទ្រង់ក៏ធ្វើឲ្យយើងអាចរស់នៅជាបុត្រា ឬបុត្រីរបស់ព្រះជាម្ចាស់ និងរីករាយជាមួយនឹងប្រយោជន៍នានានៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅលើភពផែនដីនេះដែរ។ សំខាន់ជាងនោះទៅទៀត មានមនុស្សរាប់លាននាក់ដែលយើងត្រូវឈោងចាប់ដោយដំណឹងល្អនៃព្រះរាជ្យ ហើយដើម្បីធ្វើដូច្នេះបានគឺយើងត្រូវការប្រាក់។ មនុស្សកំពុងតែចាំមើល។ ជីវិតរបស់យើងត្រូវមានលក្ខណៈខុសពីគេ!

តើជាអ្វីទៅដែលខ្ញុំបានបង្រៀននៅប្រទេសអាល់បានី ដែលបាននាំឲ្យមានការចាក់ប្រេងតាំងនោះ? តើព្រះជាម្ចាស់បានប្រាប់ខ្ញុំឲ្យទៅប្រកាសដល់ជាតិសាសន៍នានាជាអ្វីដែរ? មែនហើយ នោះគឺជាគោលបំណងនៃសៀវភៅនេះ ហើយខ្ញុំជឿជាក់ថា វានឹងផ្លាស់ប្រែជីវិតរបស់លោកអ្នកដូចដែលវាបានផ្លាស់ប្រែខ្ញុំដែរ។

ជំពូកទី៣

# ឱព្រះជាម្ចាស់អើយ សូមមេត្តាទូលបង្គំផង!

លោកដេវីបានទូរស័ព្ទមកកាន់ការិយាល័យរបស់ខ្ញុំ ហើយសួរខ្ញុំថាតើគាត់អាចទៅញ៉ាំអាហារថ្ងៃត្រង់ជាមួយខ្ញុំ នៅពេលដែលខ្ញុំកំពុងនៅក្នុងតំបន់ដែលគាត់រស់នៅនោះបានដែរឬទេ។ ខ្ញុំកំពុងតែទទួលការសម្ភាសន៍នៅឯស្ថានីយទូរទស្សន៍មួយនៅក្នុងទីក្រុងដែលនៅជិតផ្ទះគាត់ ហើយគាត់ចង់ប្រាប់ខ្ញុំថាជីវិតរបស់គាត់បានផ្លាស់ប្រែយ៉ាងណាពីមេរៀន និងកម្មវិធីទូរទស្សន៍របស់ខ្ញុំ។ ខ្ញុំមិនដែលបានជួបដេវីពីមុនមកទេ ប៉ុន្តែបាននិយាយទូរស័ព្ទជាមួយនឹងគាត់ ម្តងជាពីរដងដែរ។ ខ្ញុំនិយាយថា «បាទ ប្រាកដណាស់!» យើងត្រូវទៅញ៉ាំអាហារថ្ងៃត្រង់ដដែលហ្នឹង ហើយខ្ញុំគិតថានៅពេលដែលនៅទីនោះ ខ្ញុំចង់ជួបជាមួយគាត់ និងស្តាប់ឮពីសាច់រឿងរបស់គាត់។

នៅពេលពិសារអាហារថ្ងៃត្រង់ ខ្ញុំបានជួបនឹងលោកដេវី និងកូនប្រុសរបស់គាត់ ហើយលោកដេវីក៏បានចាប់ផ្តើមប្រាប់ខ្ញុំពីសាច់រឿងរបស់គាត់។ លោកដេវីជាគ្រូគង្វាល ហើយគាត់បានបម្រើជាគ្រូគង្វាលអស់រយៈពេលជាង ៣០ ឆ្នាំមកហើយ ប៉ុន្តែគាត់ត្រូវចាកចេញពីព័ន្ធកិច្ចដោយសារតែជំងឺស្លាប់មួយចំហៀងខ្លួនដែលបាន

ធ្វើឲ្យគាត់ពិការ។ នៅអំឡុងពេលនេះ បន្ទាប់ពីជំងឺស្លាប់មួយចំហៀងខ្លួន ជីវិតរបស់គាត់បានខ្ទេចខ្ទី។ ដោយហេតុថាគាត់មិនអាចធ្វើការបាន គាត់បានយឺតយ៉ាវក្នុងការសងបំណុលថ្លៃផ្ទះ ហើយអាចប្រឈមមុខនឹងការរឹបអូសយកផ្ទះ។ ពួកគេក៏ចាប់ផ្តើមមានការពិបាកក្នុងការបង់ថ្លៃទឹកភ្លើង និងការទិញម្ហូបអាហារដែរ។ តាមពិតលោកជេរីបាននិយាយថា បញ្ហាបានប្រែក្លាយជាធ្ងន់ធ្ងរទៅរហូតដល់ថ្ងៃមួយ គាត់អង្គុយដៃម្ខាងកាន់កាំភ្លើងខ្លី ហើយដៃម្ខាងទៀតកាន់ព្រះគម្ពីរដោយគិតថានឹងសម្លាប់ខ្លួន។

នៅពេលកំពុងអស់សង្ឃឹមបែបនេះហើយ លោកជេរីបានឃើញកម្មវិធីទូរទស្សន៍របស់យើង ហើយបានបញ្ជាទិញមេរៀនមួយចំនួនពីយើង។ គាត់បានបន្តដោយពន្យល់ថា នៅពេលដែលគាត់បានទទួលធនធាន និងមេរៀនដំបូង គាត់ត្រូវការលុយបន្ទាន់ចំនួនជាង២០០០ដុល្លារសម្រាប់ការចំណាយលើតម្រូវការសំខាន់ៗ និងម្ហូបអាហារ។ គាត់បានស្តាប់មេរៀនរបស់ខ្ញុំម្តងហើយម្តងទៀត រហូតដល់មានជំនឿបានផុសឡើងនៅក្នុងដួងចិត្តរបស់គាត់។ គាត់ក៏បានសម្រេចចិត្តជឿលើព្រះជាម្ចាស់សម្រាប់ប្រាក់ ២០០០ ដុល្លារដែលគាត់ត្រូវការនោះ។ ដូច្នេះ គាត់បានធ្វើនូវអ្វីដែលឌ្រិនដានិងខ្ញុំធ្វើជាមួយនឹងក្តាន់ទីមួយដែលខ្ញុំបានទទួល។ គាត់បានសាបព្រោះសម្រាប់ប្រាក់ ២០០០ ដុល្លារនោះ។ គាត់បានសរសេរកាលបរិច្ឆេទ និងពេលវេលានៅលើក្រដាសមួយសន្លឹក ដែលគាត់ជឿថាគាត់បានទទួលប្រាក់នោះហើយ ដោយយោងតាមគម្ពីរម៉ាកុស ១១៖២៤ ហើយផ្ញើមូលប្បទានបត្រមកកាន់ព័ន្ធកិច្ចរបស់យើង។

ខ្ញុំមិនបានដឹងថារឿងនេះបានកើតឡើងទេ ព្រោះខ្ញុំមិនបានស្គាល់ ឬនិយាយជាមួយជេរីឡើយនៅពេលនោះ។ គាត់មានប្រសាសន៍ថា នៅក្នុងពេលប្រហែលជាមួយសប្តាហ៍កន្លះ មានបុរសម្នាក់បានឈរនៅមាត់ទ្វារផ្ទះគាត់ ហើយសុំជួបគាត់។ លោកជេរីធ្លាប់ស្គាល់បុរសនោះពីមុនមក ប៉ុន្តែគាត់ថាពួកគេទាំងពីរខានជួបគ្នាយូរមកហើយ។ ពួកគេបានជជែកគ្នាបន្តិច ហើយបុរសនោះក៏ពោលឡើងថា គាត់មក

នេះតាមពិតគឺចង់ឲ្យមូលប្បទានបត្រទឹកប្រាក់ ២០០០ ដុល្លារទៅកាន់គាត់។ គាត់បន្តដោយពន្យល់ថា នៅពេលមួយសប្តាហ៍កន្លះមុន នៅថ្ងៃនេះ ម៉ោងនេះ។ល។ គាត់មានអារម្មណ៍ថាព្រះវិញ្ញាណដ៏វិសុទ្ធបានដឹកនាំគាត់ឲ្យយកប្រាក់២០០០ដុល្លារមកឲ្យលោកជែរី។

លោកជែរីឈរនៅទីនោះទាំងស្រឡាំងកាំង។ គាត់ក៏បានលូកយកកាបូបលុយពីក្នុងហោប៉ៅដែលគាត់បានទុកក្រដាសមួយសន្លឹកនោះ ដែលបានសរសេរនូវថ្ងៃ ខែ និងម៉ោងដែលគាត់បានជឿថា គាត់បានទទួលប្រាក់ ២០០០ ដុល្លារហើយ។ កាលបរិច្ឆេទ និងពេលវេលាដែលត្រូវបានសរសេរនៅលើក្រដាសរបស់លោកជែរីគឺដូចគ្នាទៅនឹងពេលដែលបុរសនោះបានប្រាប់ថា គាត់មានអារម្មណ៍ថាឲ្យប្រាក់ ២០០០ ដុល្លារដល់លោកជែរី។ លោកជែរីបានដឹងថា នេះមិនមែនជាការចៃដន្យទេ។ គាត់បានដឹងថា នេះជាការឆ្លើយតបដោយផ្ទាល់ទៅកាន់ព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយនិយាយឲ្យចំគឺជាច្បាប់នៃព្រះរាជ្យតែម្តង។

គាត់បានបន្តចែករំលែករឿងរបស់គាត់ ហើយប្រាប់ខ្ញុំថាគាត់មានកូនប្រាំពីរនាក់ ដែលសុទ្ធតែរៀបការអស់ហើយ លើកលែងតែកូនប្រុសអាយុ១៦ឆ្នាំម្នាក់ប៉ុណ្ណោះ (ជាម្នាក់ដែលនៅជាមួយគាត់ពេលពិសារអាហារថ្ងៃត្រង់នោះ)។ កូននោះបានបែកចេញពីព្រះជាម្ចាស់នៅពេលដែលគាត់បានឃើញពីអ្វីដែលឪពុករបស់គាត់បានកំពុងតែឆ្លងកាត់។ កូនប្រុសនោះខឹងនឹងព្រះជាម្ចាស់ជាខ្លាំង ដោយសារតែឪពុករបស់គាត់បានស្មោះត្រង់ជាង ៣០ ឆ្នាំមកហើយ ហើយកូនប្រុសមានអារម្មណ៍ថាព្រះជាម្ចាស់បានបោះបង់គាត់ចោល។

លោកជេរីចង់រកវិធីមួយឈោងចាប់ទៅដល់កូនប្រុស ហើយគាត់ក៏មានគំនិតមួយ។ ខ្ញុំបាននិយាយច្រើនពីការបរបាញ់សត្វក្តាន់នៅក្នុងធនធានដែលខ្ញុំសរសេរ ហើយប្រាប់ពីរបៀបដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំឲ្យប្រមាញ់ដោយជំនឿ។ ការប្រមាញ់សត្វក្តាន់ជាចំណង់ចំណូលចិត្តកូនរបស់គាត់ ដូច្នេះលោកជេរីបានពន្យល់ទៅកាន់កូនប្រុសពីរបៀបបានសត្វក្តាន់នៅរដូវស្លឹកឈើជ្រុះនោះ ទៅតាមរបៀបនៃ

ព្រះរាជ្យរបស់ព្រះជាម្ចាស់។ កូនប្រុសបានគិតពីវា ហើយចុងក្រោយគាត់ក៏យល់ព្រម។ បន្ទាប់មក លោកជេរីនិងកូនប្រុសបានស្រាយជំនឿរបស់ពួកគេ ដូចដែលលោកជេរីបានធ្វើសម្រាប់ប្រាក់ ២០០០ ដុល្លាររបស់គាត់ដែរ។ ក្មេងនោះបានទទួលក្តាន់ឈ្មោលមួយក្បាលដ៏គួរជាទីពេញចិត្តនៅក្នុងពេលប្រាំបីនាទី។ នៅពេលដែលលោកជេរី និងកូនប្រុសបានយកសត្វក្តាន់ទៅកាន់ហាងលក់សាច់ស្រស់ លោកជេរីបានចាក់ស៊ីឌីមេរៀនរបស់ខ្ញុំនៅក្នុងឡាន។ នៅពេលដែលលោកជេរីកំពុងតែយកសត្វក្តាន់ទៅក្នុងហាង កូនប្រុសបាននិយាយថាគាត់ចង់នៅក្នុងឡាន ហើយស្តាប់មេរៀនថែមទៀត។ នៅពេលដែលលោកជេរីចេញមក កូនប្រុសរបស់គាត់ពោលឡើងថា «ប៉ា ខ្ញុំគិតថាយើងបានខកខាន ឬខ្វះអ្វីម្យ៉ាងនៅពេលប៉ុន្មានឆ្នាំនេះ។ ខ្ញុំបានដឹងថាក្តាន់នោះជាលទ្ធផលនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។»

បន្ទាប់មក កូនប្រុសរបស់គាត់ក៏បានថ្វាយជីវិតសាជាថ្មីទៅកាន់ព្រះអម្ចាស់ ដោយប្រាប់ប៉ារបស់គាត់ថា ប្រសិនបើព្រះជាម្ចាស់អាចប្រទានប្រាក់ ២០០០ ដុល្លារ និងសត្វក្តាន់ នោះទ្រង់ក៏អាចប្រទានប្រាក់១៧០០០ដុល្លារដែលពួកគេត្រូវការ ដើម្បីលោះផ្ទះពីការរឹបអូសដែរ។ មកទល់ត្រឹមនេះទើបខ្ញុំបានយល់ខ្លះពីលោកជេរី។ ខ្ញុំបាននឹកចាំកាលពីសំបុត្រទីមួយដែលលោកជេរី និងកូនប្រុសបានផ្ញើមកដែលបានសរសេរថា «ជាគ្រាប់ពូជដើម្បីស្រោចស្រង់ផ្ទះពីការរឹបអូស។» ខ្ញុំដឹងថាសំបុត្រនោះខ្លី ប៉ុន្តែវាសរសេរផ្តោតលើតម្រូវការរបស់ពួកគេ។ ពួកគេមិនបាននិយាយពីអ្វីផ្សេងទៀតទេ គឺគ្រាន់តែឲ្យផ្ទះរួចផុតពីការរឹបអូសប៉ុណ្ណោះ។ ខ្ញុំក៏ចាំបានថា ពេលនោះខ្ញុំបានដាក់ដៃលើសំបុត្រនោះ ហើយយល់ស្របជាមួយពួកគេ។ ខ្ញុំអាចនឹកចាំនៅនាទីដែលខ្ញុំបានធ្វើដូច្នេះច្បាស់ណាស់។

មកទល់ត្រឹមនេះ លោកជេរីបានប្រាប់ខ្ញុំថា នៅពេលប្រហែលជាពីរសប្តាហ៍មានបុរសម្នាក់ទៀតបានមកខាងមុខផ្ទះរបស់គាត់។ នៅលើកនេះទៀតក៏ជាមនុស្សដែលលោកជេរីធ្លាប់ស្គាល់ដែរ។ បុរសនោះបាននិយាយថា គាត់បានឃើញផ្ទះនោះដាក់លក់ដោយធនាគារ ហើយសួរលោកជេរីថាគាត់ត្រូវការប្រាក់ប៉ុន្មានដើម្បីរួចផុត

ពីការរើបអូសនោះ។ លោកដេរីបានប្រាប់គាត់ថាចំនួន ១៧០០០ដុល្លារ។ បុរសនោះក៏បានសរសេរមូលប្បទានបត្រដែលមានទឹកប្រាក់ចំនួនប៉ុននោះ ហើយក៏បានចាកចេញទៅ។ លោកដេរីបានសម្លឹងមើលទៅលើមូលប្បទានបត្រ។ មកទល់ត្រឹមនេះ លោកដេរីកំពុងតែអង្គុយយំនៅទល់មុខខ្ញុំឯភោជនីយដ្ឋាន ហើយអរគុណខ្ញុំដែលបានបង្រៀនមនុស្សអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ លោកដេរីបាននិយាយថា គាត់រីករាយណាស់ដែលបានឃើញកូនៗរបស់គាត់សុទ្ធតែបានឃើញនូវព្រះហស្តរបស់ព្រះជាម្ចាស់ ហើយវាបានផ្តល់ឱកាសដល់គាត់ក្នុងការចែកចាយនូវព្រះរាជ្យរបស់ព្រះអង្គជាមួយពួកគេ។ ខ្ញុំពេញចិត្តនឹងការនេះណាស់! នេះជាសេចក្តីពិតស្តីពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយខ្ញុំពិតជាមានពរណាស់ដែលអាចចែកចាយវាជាមួយមនុស្ស និងស្តាប់ឮនូវសាច់រឿងរបស់គេ។ លោកអ្នកឃើញទេ លោកដេរីមិនត្រូវការការអាណិតអាសូរទេ។ គាត់ត្រូវការដំណោះស្រាយ ហើយគាត់បានរកឃើញដំណោះស្រាយទាំងនោះនៅក្នុងព្រះរាជ្យ។

**ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នករាល់គ្នាមានជំនឿប៉ុនគ្រាប់ម្ជូតាមួយគ្រាប់ ហើយនិយាយទៅកាន់ភ្នំនេះថា ចូររើចេញពីទីនោះ វានឹងត្រូវរើចេញ ហើយគ្មានអ្វីដែលអ្នករាល់គ្នាធ្វើមិនកើតឡើយ**

**- ម៉ាថាយ ១៧៖២០**

នៅពេលនេះ ខ្ញុំមានអារម្មណ៍ថាខ្ញុំត្រូវបញ្ជាក់អ្វីម្យ៉ាងនៅត្រង់នេះ ទាក់ទងនឹងសាច់រឿងរបស់លោកដេរី។ ទោះបីជាយើងហាក់ដូចជាឃើញថាមនុស្សបានមកគោះទ្វារផ្ទះលោកដេរី ហើយឲ្យប្រាក់ទៅគាត់ ខ្ញុំមិនចង់ឲ្យលោកអ្នកយល់ច្រឡំថា ដំណោះស្រាយផ្នែកថវិការបស់លោកអ្នកនឹងរត់មករកលោកអ្នក នៅខណៈដែលលោកអ្នកអង្គុយស៊ៀមញ៉ាំកាហ្វេនៅផ្ទះនោះទេ។ អត់ទេ គឺលោកអ្នកមានផ្នែកដែលលោកអ្នកត្រូវបំពេញ នៅក្នុងការច្រូតកាត់នូវអ្វីដែលលោកអ្នកត្រូវការ។ នៅក្នុងករណីរបស់លោកដេរី លោកដេរីបានធ្វើជាគ្រូ

គង្វាលអស់រយៈពេលជាង ៣០ឆ្នាំ។ គាត់បានសាបព្រោះទៅកាន់មនុស្សទាំងនេះអស់រយៈពេលជាយូរមកហើយ។ ហើយទីពីរ លោកដែវរីមិនអាចចេញពីផ្ទះបានដោយសារគាត់មានជំងឺស្លាប់មួយចំហៀងខ្លួន។ លោកដែវរីបានច្រូតផលពីកន្លែងដែលគាត់បានសាបព្រោះ ពីមនុស្សនៅក្នុងក្រុមជំនុំរបស់គាត់ ដែលគាត់បានសាបព្រោះចូលទៅកាន់ជីវិតរបស់គេនៅពេលប៉ុន្មានឆ្នាំនោះ។

ខ្ញុំចាំបាច់ត្រូវប្រាប់លោកអ្នកថា លោកដែវរីក៏បានជាទាំងស្រុងពីជំងឺស្លាប់មួយចំហៀងខ្លួនដែរ ហើយគាត់បានស្រកទម្ងន់អស់ជាង ៣០ គីឡូក្រាមនៅពេលដែលខ្ញុំជួបពិសារអាហារថ្ងៃត្រង់ជាមួយគាត់នៅថ្ងៃនោះ។ សូមសរសើរតម្កើងព្រះជាម្ចាស់ដែលគាត់អាចរកឃើញព្រះរាជ្យ។ លោកអ្នកប្រហែលជានិយាយថា «មែនហើយ គឺលោកដែវរីជាគ្រូគង្វាល។ ហេតុដូច្នេះគាត់ប្រាកដជាដឹងច្បាស់អំពីព្រះរាជ្យ។» ជាការពិតណាស់ គឺមិនមែនទេ ហើយខ្ញុំប្រាកដថាមិនមែនមានតែគាត់ទេ ដែលមិនបានយល់ពីព្រះរាជ្យ។ គួរឲ្យសោកស្ដាយ មានគ្រិស្តបរិស័ទជាច្រើនដែលចូលរួមក្នុងក្រុមជំនុំ មិនដឹងពីរបៀបផ្សារភ្ជាប់នឹងព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយទទួលចម្លើយឬដំណោះស្រាយដែរ។ សាច់រឿងមួយនៅក្នុងគម្ពីរម៉ាថាយបានបង្ហាញពីរបៀបដែលមនុស្សជាច្រើនគិតៈ

*កាលបានមកដល់បណ្ដាជនហើយ នោះបុរសម្នាក់បានមកលុតជង្គង់នៅពីមុខព្រះអង្គ ទូលថាៈ «លោកម្ចាស់អើយ! សូមមេត្តាដល់កូនប្រុសខ្ញុំផង ព្រោះវាឆ្កួតជ្រូករងទុក្ខខ្លាំងណាស់ ហើយវាចេះតែដួលទៅក្នុងភ្លើង និងក្នុងទឹកជាញឹកញាប់ ខ្ញុំបាននាំវាមករកពួកសិស្សរបស់លោកដែរ តែពួកគេមិនអាចប្រោសវាឲ្យជាបានទេ»។*

*ព្រះយេស៊ូមានបន្ទូលឆ្លើយថាៈ «ឱជំនាន់មនុស្សគ្មានជំនឿ និងមានចិត្តវៀចអើយ! តើឲ្យខ្ញុំនៅជាមួយអ្នករាល់គ្នាដល់ពេលណា? តើឲ្យខ្ញុំទ្រាំនឹងអ្នក*

*រាល់គ្នាដល់ពេលណា? ចូរនាំក្មេងនោះមកឯខ្ញុំនៅទីនេះ»។ ព្រះយេស៊ូបានបន្ទោសអារក្ស ហើយវាក៏ចេញពីក្មេងនោះ ក្មេងនោះក៏បានជាសះស្បើយចាប់តាំងពីពេលនោះមក។*

*បន្ទាប់មក ពួកសិស្សបានចូលមកជិតព្រះយេស៊ូដោយឡែកទូលសួរថា៖ «ហេតុអ្វីបានជាយើងមិនអាចបណ្តេញអារក្សនោះបានដូច្នេះ?» ព្រះអង្គមានបន្ទូលទៅពួកគេថា៖ «មកពីអ្នករាល់គ្នាមានជំនឿតិច ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នករាល់គ្នាមានជំនឿប៉ុនគ្រាប់មូតាមួយគ្រាប់ ហើយនិយាយទៅកាន់ភ្នំនេះថា ចូររើចេញពីទីនោះ វានឹងត្រូវរើចេញ ហើយគ្មានអ្វីដែលអ្នករាល់គ្នាធ្វើមិនកើតឡើយ។*

ម៉ាថាយ ១៧៖១៤-២០ (ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ)

នៅក្នុងសាច់រឿងនេះយើងឃើញថាមានបុរសម្នាក់ដែលពិតជាមានសេចក្តីត្រូវការជាខ្លាំង ព្រោះកូនប្រុសរបស់គាត់កំពុងរងនូវការធ្វើទុក្ខបុកម្នេញពីវិញ្ញាណអាក្រក់រហូតដល់ជិតស្លាប់។ ដោយបានស្តាប់ឮពីព័ន្ធកិច្ចរបស់ព្រះយេស៊ូ និងការដែលទ្រង់មានឫទ្ធានុភាពបណ្តេញវិញ្ញាណអាក្រក់ចេញ គាត់ក៏បានរៀបចំដើម្បីយកកូនប្រុសទៅជួបព្រះយេស៊ូ ដើម្បីឲ្យទ្រង់អាចប្រោសគាត់ឲ្យបានជា។ ទោះជាយ៉ាងនេះក្តី នៅពេលទៅដល់ទីនោះ ព្រះយេស៊ូពុំបាននៅទីនោះទេ ព្រោះទ្រង់បានឡើងទៅលើភ្នំដើម្បីអធិស្ឋាន ទាំងយកសិស្សបីនាក់ទៅជាមួយ។ សិស្សដទៃទៀតដែលនៅទីនោះ បាននិយាយថា អត់អីទេ ពួកគេបានដេញវិញ្ញាណអាក្រក់ចេញពីមនុស្សពីមុនមកហើយ ចាប់តាំងពីពេលដែលព្រះយេស៊ូប្រទានសិទ្ធិអំណាចឲ្យពួកគេធ្វើដូច្នេះនៅក្នុងព្រះនាមទ្រង់។ ដូច្នេះ ពួកគេអាចជួយដល់កូនប្រុសរបស់បុរសនោះបាន។ ប៉ុន្តែ នៅពេលដែលគេអធិស្ឋានសម្រាប់ក្មេងនោះ អារក្សមិនបានចេញឡើយ។ ទោះបីជាពួកគេបានព្យាយាមក្តី អារក្សក៏មិនចេញដែរ។ ឪពុកក៏មិន

សប្បាយចិត្ត ហើយបណ្តាជនដែលបានដើរតាមព្រះយេស៊ូក៏មានអារម្មណ៍ច្របូកច្របល់ជាខ្លាំង។

ប៉ុន្តែនៅរំពេចនោះ ព្រះយេស៊ូនិងសិស្សទាំងបីបានចុះពីលើភ្នំ ហើយមកដល់ល្មម។ ដោយបានទតឃើញពីភាពវឹកវរ ទ្រង់បានសួរថាមានរឿងអ្វីកើតឡើង។ ឪពុករបស់ក្មេងប្រុសក៏បានពន្យល់ពីរបៀបដែលគាត់បាននាំក្មេងនោះមកជួបនឹងពួកសិស្ស ប៉ុន្តែពួកគេមិនអាចដេញអារក្សឲ្យចេញបានឡើយ។ បន្ទាប់មក បុរសជាឪពុកក៏បានធ្វើកិច្ចការមួយដែលហាក់ដូចជាត្រឹមត្រូវចំពោះមនុស្សជាច្រើន ជាពិសេសគឺអ្នកដែលប្រឈមមុខនឹងបញ្ហាដែលហាក់ដូចជាទ័លច្រក។ គាត់ស្រែកទៅកាន់ព្រះយេស៊ូដោយសុំការអាណិតមេត្តាពីទ្រង់។ ទោះបីជាការសុំក្តីអាណិតមេត្តាជារឿងដែលលោកអ្នកគួរធ្វើនៅពេលទ័លច្រក នោះមិនមែនជាចម្លើយសម្រាប់បុរសនោះទេ ហើយក៏មិនមែនជាចម្លើយសម្រាប់លោកអ្នកដែរ។ បុរសជាឪពុកដោយចង់បានក្តីអាណិតមេត្តារបស់ព្រះយេស៊ូសម្រាប់ស្ថានការណ៍របស់គាត់ គាត់បានបន្តដោយរៀបរាប់ប្រាប់ពីរបៀបដែលអារក្សបានយាយីដល់កូនប្រុស ដូចជាឲ្យក្មេងនោះដួលទៅក្នុងភ្លើង និងព្យាយាមសម្លាប់ក្មេងនោះ។ ព្រះយេស៊ូបានមានបន្ទូលកាត់បុរសនោះ។ ទ្រង់មិនចង់ស្តាប់ឮពីការដែលអារក្សធ្វើទុក្ខបុកម្នេញដល់កូនប្រុសរបស់បុរសនោះទេ។ ព្រះអង្គបានស្រែកឡើងដោយក្តីមួរម៉ៅថា «ឱជំនាន់មនុស្សគ្មានជំនឿ និងមានចិត្តវៀចអើយ! តើឲ្យខ្ញុំនៅជាមួយអ្នករាល់គ្នាដល់ពេលណា? តើឲ្យខ្ញុំទ្រាំនឹងអ្នករាល់គ្នាដល់ពេលណា? ចូរនាំក្មេងនោះមកឯខ្ញុំនៅទីនេះ»។ នៅក្នុងព្រះបន្ទូលដែលទ្រង់បានប្រាប់ដោយប្រយោគតែមួយ ព្រះយេស៊ូបានពន្យល់យ៉ាងច្បាស់ពីហេតុផលដែលអារក្សមិនបានចេញពីក្មេង។

ប៉ុន្តែ មុនពេលដែលយើងជីកកាន់តែជ្រៅទៅលើព្រះបន្ទូលរបស់ព្រះយេស៊ូ យើងត្រូវបញ្ជាក់ពីគ្រឹះមូលដ្ឋានរបស់យើងសិន គឺថាព្រះជាម្ចាស់មិន ហើយមិនអាចកុហកទេ។ អ្វីដែលទ្រង់មានបន្ទូលជាការពិត។ ប្រសិនបើយើងច្បាស់ពីចំណុចនេះហើយ យើងអាចពិនិត្យមើលពីស្ថានការណ៍នោះជាមួយនឹងសេចក្តីប្រកាសបែបនេះ

«អារក្ស**ត្រូវ**តែចេញ!» ហើយប្រសិនបើពួកវាមិនចេញទេ នោះមានបញ្ហាអ្វីមួយហើយ ហើយវាមិនមែនជាបញ្ហាដែលព្រះជាម្ចាស់ត្រូវដោះស្រាយទេ តែជាយើងវិញ។ សូមចាំថា បញ្ហានៅក្នុងការទទួលពីព្រះជាម្ចាស់គឺតែងតែជាយើងដែលត្រូវដោះស្រាយ។ ព្រះយេស៊ូបានមានបន្ទូលយ៉ាងច្បាស់មកកាន់យើងពីហេតុផលដែលអារក្សមិនបានចេញ គឺការគិតបែបខុសឆ្គង និងការមិនជឿ។ យើងនឹងបកស្រាយពីហេតុផលទាំងពីរនេះ នៅពេលបន្តិចទៀតនេះ។ ប៉ុន្តែនៅត្រង់នេះ ក្នុងការពិភាក្សារវាងយើង ខ្ញុំចង់ផ្តោតលើឪពុកនិងកូននៅក្នុងសាច់រឿងខាងលើសិន។

លោកឪពុកពិតជាចង់ឲ្យកូនមានសេរីភាពណាស់។ នៅពេលដែលគ្មានអ្វីកើតឡើងជាដុំកំភួនពេលដែលពួកសិស្សបានអធិស្ឋានឲ្យគាត់ បុរសជាឪពុកក៏អស់សង្ឃឹមជាខ្លាំង។ គាត់មានអារម្មណ៍ថាពុំមានចម្លើយណាមួយឲ្យប្រាកដឡើយ។ ចម្លើយតែមួយដែលគាត់គិតថា អាចជាដំណោះស្រាយបែរជាមិនបានផលទៅវិញ។ មានរឿងតែមួយប៉ុណ្ណោះដែលគាត់អាចធ្វើបាន ហើយនោះគឺការសុំក្តីមេត្តា។ ឃ្លាថា «អង្វរសុំក្តីមេត្តា» ចង់បង្ហាញថាមនុស្សណាម្នាក់មានអំណាច ឬសិទ្ធិដើម្បីជួយដល់គាត់ ប៉ុន្តែគាត់បានជ្រើសរើសមិនជួយទៅវិញ។ ហេតុនេះហើយ ជម្រើសចុងក្រោយដែលគាត់អាចធ្វើបានគឺពន្យល់រៀបរាប់ពីការធ្វើទារុណកម្មដ៏សាហាវយង់ឃ្នងដែលក្មេងនោះបានទទួល គឺធ្វើឲ្យព្រះយេស៊ូរំជួលចិត្តនិងមានការអាណិតអាសូរនៅលើស្ថានការណ៍របស់គាត់។

និយាយឲ្យចំទៅ នេះជារបៀបដែលមនុស្សភាគច្រើនអធិស្ឋាន ដោយដឹងថាព្រះជាម្ចាស់មានឫទ្ធានុភាពដើម្បីជួយដល់គេ ប៉ុន្តែមិនប្រាកដថាទ្រង់នឹងពិតជាព្រមជួយដែរឬអត់។ គឺពួកគេអង្វរសុំក្តីមេត្តាពីទ្រង់។ ដូច្នេះ គេក៏អធិស្ឋានយូរៗ និងប្រើពាក្យពេចន៍ច្រើនហូរហែរ ព្រមទាំងរៀបរាប់យ៉ាងក្បោះក្បាយពីការឈឺចាប់ និងកាលៈទេសៈរបស់ខ្លួន។ «ព្រះបិតាអើយ ទ្រង់ជ្រាបថាខ្ញុំត្រូវការលុយនោះនៅល្ងាចថ្ងៃសុក្រ ដូច្នេះខ្ញុំអង្វរទ្រង់ សូមជួយខ្ញុំផង។» ឬ «ព្រះជាម្ចាស់អើយ សូមអង្វរចុះ ប្រសិនបើទ្រង់ប្រោសកូនប្រុសខ្ញុំឲ្យបានជា ខ្ញុំនឹងបម្រើទ្រង់អស់មួយជីវិតរបស់ខ្ញុំ។

ខ្ញុំសូមអង្វរព្រះជាម្ចាស់។» ខ្ញុំមិនមែនមើលស្រាលស្ថានការណ៍ដែលមនុស្សបានជួបប្រទះទេ ប៉ុន្តែមនុស្សបានធ្វើការកត់សម្គាល់ពីរបៀបដែលព្រះយេស៊ូបាននាំឫទ្ធានុភាពរបស់ព្រះជាម្ចាស់ដើម្បីដោះស្រាយលើស្ថានការណ៍នោះ និងរំដោះក្មេងនោះឲ្យមានសេរីភាពក្នុងពេលដ៏ខ្លី។ នេះជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងជាបំណងរបស់ទ្រង់។ ព្រះអង្គមានគ្រប់ទាំងក្ដីមេត្តាករុណា ឫទ្ធានុភាព និងសិទ្ធិអំណាច។ នៅក្នុងសាច់រឿងខាងលើ កត្តាទាំងបីក៏មិនមែនជាបញ្ហាដែរ។ យើងអាចនិយាយបានថា ការគិតខុសឆ្គង និងការខ្វះជំនឿបានរារាំងច្បាប់នៃព្រះរាជ្យនៅក្នុងករណីនេះ។

មែនហើយ មានសេចក្ដីជាច្រើនដែលយើងត្រូវនិយាយនៅត្រង់នេះ ដូចជាកូនសោជាច្រើននៃព្រះរាជ្យ និងរបៀបដែលព្រះរាជ្យដំណើរការ។ ខ្ញុំមិនចង់បកស្រាយលម្អិតពីសេចក្ដីទាំងឡាយដែលលោកអ្នកត្រូវតែដឹងនៅក្នុងជំពូកនេះទេ ប៉ុន្តែយ៉ាងហោចណាស់ខ្ញុំនឹងលើកពីចំណុចទាំងនោះមកនិយាយខ្លះ ហើយយើងនឹងសិក្សាច្បាប់ដែលយើងឃើញថាដំណើរការនៅត្រង់នេះ នៅលើកក្រោយ។

ដើម្បីឲ្យបានយល់ពីសេចក្ដីបឋមស្ដីពីច្បាប់នៃព្រះរាជ្យ យើងត្រូវយល់ពីចំណុចគ្រឹះដ៏សំខាន់នេះសិន៖ ព្រះជាម្ចាស់បានប្រទានឲ្យអដាំមានអំណាចនៅលើផែនដីទាំងស្រុង។ គាត់ត្រូវគ្រប់គ្រងត្រួតត្រានៅលើផែនដី៖

> *ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «យើងបង្កើតមនុស្ស ជាតំណាងរបស់យើង មានលក្ខណៈដូចយើង ដើម្បីឲ្យគេ<u>មានអំណាច</u>លើត្រីសមុទ្រ លើបក្សាបក្សីដែលហើរនៅលើមេឃ លើសត្វស្រុកនៅលើផែនដីទាំងមូល និងលើសត្វទាំងប៉ុន្មានដែលលូនវារនៅលើដី»។*
>
> លោកុប្បត្តិ ១៖២៦ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

ខ្ញុំគិតថាគម្ពីរហេប្រឺ ២៖៧-៨ បញ្ជាក់យ៉ាងច្បាស់ថា៖

*«ព្រះអង្គបានធ្វើឲ្យគេមានឋានៈទាបជាងទេវតាតែមួយរយៈប៉ុណ្ណោះ ព្រះអង្គប្រទានសិរីរុងរឿង និងកិត្តិយសដល់គេទុកជាមកុដរាជ្យ ព្រះអង្គបានបង្ក្រាបអ្វីៗទាំងអស់ឲ្យនៅក្រោមជើងរបស់គេ» ។ ព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ ឥតទុកឲ្យមានអ្វីមួយនៅសល់ ដែលពុំបានចុះចូលនោះឡើយ។*

យ៉ាងហោចណាស់នៅពេលនេះ ការដែលយើងយល់ថាព្រះជាម្ចាស់មិនអាចប្រើប្រាស់សិទ្ធិអំណាចរបស់ទ្រង់នៅលើភពផែនដី (នៅក្នុងរាជ្យ ឬអាណាចក្ររបស់មនុស្ស) លុះត្រាតែមនុស្សដែលមានសិទ្ធិអំណាចស្របច្បាប់នៅលើផែនដីនេះស្រាយសិទ្ធិអំណាចនៃស្ថានសួគ៌ចុះមក។

ហេតុនេះហើយបានជាព្រះយេស៊ូប្រាប់ដល់សិស្សរបស់ព្រះអង្គនៅក្នុងគម្ពីរម៉ាថាយ ១៨៖១៨ថា៖

*ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្វីៗទាំងអស់ដែលអ្នករាល់គ្នាចងនៅលើផែនដីនេះ ព្រះជាម្ចាស់នឹងចងនៅស្ថានបរមសុខ ហើយអ្វីៗដែលអ្នករាល់គ្នាស្រាយនៅលើផែនដី ព្រះជាម្ចាស់ក៏នឹងស្រាយ នៅស្ថានបរមសុខដែរ។*

ជាថ្មីម្តងទៀត ស្ថានសួគ៌ពុំមានសិទ្ធិអំណាចនៅលើភពផែនដីនេះឡើយ លុះត្រាតែតាមរយៈបុរស ឬស្ត្រីដែលស្រាយសិទ្ធិអំណាចនោះមកលើផែនដី។ ហេតុនេះហើយបានជាព្រះយេស៊ូមានបន្ទូលនៅត្រង់នេះថា ប្រសិនបើបុរស ឬស្ត្រីណាម្នាក់

**ប៉ុន្តែ មិត្តសម្លាញ់អើយ នេះមិនមែនជាលោកអ្នកទេ។ លោកអ្នកអាចទទួលបាននូវយុត្តិធម៌នៅក្នុងព្រះរាជ្យ។ មានចម្លើយសម្រាប់បញ្ហារបស់លោកអ្នក។**

ស្រាយសិទ្ធិអំណាចនៃស្ថានសួគ៌មកលើផែនដីនេះ នោះស្ថានសួគ៌ក៏ស្រាយមកដែរ។ ប្រសិនបើយើងមិនស្រាយមកទេ នោះស្ថានសួគ៌ក៏មិនអាចធ្វើបានដែរ។ ប្រសិនបើគំនិតនេះហាក់ដូចជាចម្លែកសម្រាប់លោកអ្នក សូមកុំទាន់អាលឈប់ត្រឹមនេះ។ ខ្ញុំនឹងនិយាយពីប្រធានបទនោះឲ្យបានក្បោះក្បាយនៅលើកក្រោយ។ ប៉ុន្តែ នៅពេលនេះ សូមទទួលស្គាល់សេចក្តីពិតនោះថាជាហេតុផលដែលអារក្សមិនចេញពីក្មេងប្រុសនោះសិន។ **វាមិនចាំបាច់ចេញទេ**! វាបានបំពេញតាមសិទ្ធិស្របច្បាប់របស់វា ក្នុងការបន្តនៅក្នុងក្មេងនោះ។ ជាថ្មីម្តងទៀត ព្រះយេស៊ូមានបន្ទូលថា ហេតុផលដែលអារក្សមិនចាំបាច់ត្រូវចេញ គឺដោយសារកង្វះជំនឿ ឬកង្វះសិទ្ធិអំណាច។ ព្រះជាម្ចាស់បានបាត់បង់សិទ្ធិអំណាចរបស់ទ្រង់ ដោយសារតែអ្វីដែលមនុស្សបានធ្វើ គឺនៅពេលដែលអដាំបានដេញព្រះជាម្ចាស់ចេញដោយសារការបះបោររបស់គាត់។ នៅត្រង់នេះហើយដែលមារសាតាំងបានទទួលសិទ្ធិអំណាចនៅលើមនុស្សដែរ។

*មារនាំព្រះអង្គទៅកន្លែងមួយដ៏ខ្ពស់ ហើយចង្អុលបង្ហាញនគរទាំងប៉ុន្មាននៅលើផែនដីឲ្យព្រះអង្គឃើញ ក្នុងមួយរយៈពេលដ៏ខ្លី។ មារសាតាំងទូលព្រះអង្គថា៖ «ខ្ញុំនឹងប្រគល់អំណាច ព្រមទាំងភោគទ្រព្យរបស់នគរទាំងនោះឲ្យលោក ដ្បិតអ្វីៗទាំងអស់ជាសម្បត្តិរបស់ខ្ញុំ ខ្ញុំអាចប្រគល់ឲ្យអ្នកណាក៏បានស្រេចតែនឹងចិត្តខ្ញុំ។ ដូច្នេះ ប្រសិនបើលោកក្រាបថ្វាយបង្គំខ្ញុំ សម្បត្តិទាំងនោះនឹងបានជារបស់លោកហើយ»។*

លូកា ៤៖៥៧ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

ជាលទ្ធផល ព្រះជាម្ចាស់បានបាត់បង់នីត្យានុកូលភាពរបស់ទ្រង់នៅលើភពផែនដី នៅនាទីដែលទ្រង់បានបាត់បង់មនុស្សដែលមាននូវនីត្យានុកូលភាពនោះ គឺលោកអដាំ។ ជាថ្មីម្តងទៀត ខ្ញុំនឹងបកស្រាយថែមទៀតអំពីច្បាប់ទាំងនេះនៅពេលក្រោយ គឺដូចដែលខ្ញុំបាននិយាយអញ្ចឹង ប៉ុន្តែហេតុផលសំខាន់ដែលខ្ញុំលើកយកសាច់រឿងនេះមកនិយាយគឺដើម្បីចង្អុលបង្ហាញពីចិត្តគំនិត និងភាពអស់សង្ឃឹមរបស់បុរសជាឪពុក និងរបៀបដែលគាត់បានទទូចសុំក្តីមេត្តាពីព្រះយេស៊ូ។ សូមអានប្រយោគខាងក្រោមដោយប្រុងប្រយ័ត្នៈ

ប្រសិនបើគ្មានសិទ្ធិអំណាច ឬច្បាប់ និងប្រព័ន្ធដើម្បីអនុវត្តនូវយុត្តិធម៌ និងនាំដំណោះស្រាយមកដល់មនុស្សដែលមានសេចក្តីត្រូវការទេ នោះជម្រើសដែលពួកគេអាចធ្វើបានគឺអង្វរសុំក្តីមេត្តា ឬអាណិតអាសូរ។ ខ្ញុំសូមនិយាយតាមរបៀបម្យ៉ាងទៀតថា ប្រសិនបើមនុស្សម្នាក់គ្មានដំណោះស្រាយស្របច្បាប់ចំពោះបញ្ហា ហើយពុំអាចទទួលបានយុត្តិធម៌ នោះគាត់ក៏គ្មានអ្វីមកអះអាងថាគាត់នឹងទទួលបានដំណោះស្រាយ ឬចម្លើយដែរ។ ជម្រើសចុងក្រោយដែលគាត់អាចធ្វើបាន គឺអង្វរសុំក្តីមេត្តា។

ប៉ុន្តែ មិត្តសម្លាញ់អើយ នេះមិនមែនជាលោកអ្នកទេ។ លោកអ្នកអាចទទួលបាននូវយុត្តិធម៌នៅក្នុងព្រះរាជ្យ។ មានចម្លើយសម្រាប់បញ្ហារបស់លោកអ្នក។ សូមចាំថា ព្រះរាជ្យគឺសំដៅលើរាជរដ្ឋាភិបាល ហើយព្រះរាជ្យបំពេញមុខងារដោយច្បាប់ដែលមិនលម្អៀង ហើយមានសម្រាប់ប្រជារាស្ត្រគ្រប់ៗរូបដែលរស់នៅក្រោមសិទ្ធិអំណាចនៃព្រះរាជ្យនោះ។ ដូចដែលខ្ញុំបាននិយាយពីខាងដើមនៅក្នុងសៀវភៅនេះ ព្រះរាជ្យរបស់ព្រះជាម្ចាស់ត្រូវបានសង់នៅលើអ្វីដែលច្បាប់របស់ទ្រង់ចែងថាត្រឹមត្រូវ និងសេចក្តីសុចរិត។ មានហេតុផលដែលអារក្សមិនបានចេញ ហើយហេតុផលនោះគឺមិនមែនដោយសារព្រះជាម្ចាស់ទន់ខ្សោយ ឬប្រែព្រះទ័យទេ។ ព្រះយេស៊ូបង្ហាញយើងពីការនោះ តាមរយៈការដែលទ្រង់ស្តីបន្ទោសពួកសិស្ស ហើយបណ្តេញអារក្សនោះចេញក្នុងពេលដ៏ខ្លី។

គ្រិស្តបរិស័ទភាគច្រើន នៅពេលដែលគេមិនបានឃើញសកម្មភាពនៃព្រះរាជ្យ ពួកគេក៏ប្តូរគោលលទ្ធិដែលខ្លួនជឿលើ ដោយនិយាយថា «អារក្សទាំងអស់មិនសុទ្ធតែត្រូវចេញពីមនុស្សទេ។» ពួកគេដឹងថា ព្រះជាម្ចាស់មានគ្រប់ទាំងឫទ្ធានុភាព ដូច្នេះគេក៏សន្មតថាព្រះជាម្ចាស់អាចធ្វើអ្វីក៏ដោយតាមដែលទ្រង់សព្វព្រះទ័យនៅលើផែនដីនេះ។ ដូច្នេះ ប្រសិនបើអារក្សមិនចេញមកទេ នោះមានន័យថាព្រះជាម្ចាស់បានជ្រើសរើសមិនឲ្យវាចេញ។ មិត្តសម្លាញ់អើយ ការយល់ឃើញបែបនេះគឺខុសទាំងស្រុង។ ព្រះយេស៊ូមានបន្ទូលថា នៅក្នុងករណីនេះ ជាការយល់ខុសរបស់ពួកគេ និងការមិនជឿដែលកំណត់នូវអំណាចនៃស្ថានសួគ៌។ សូមអនុញ្ញាតឲ្យខ្ញុំពន្យល់បែបនេះ។ ហេតុផលដែលអារក្សមិនចេញ គឺជារឿងស្របច្បាប់។ ខ័ណ្ឌចប់។ វាមិនចាំបាច់ត្រូវចេញទេ ព្រោះពុំមាននរណាបាននាំសិទ្ធិអំណាច និងការគ្រប់គ្រងដ៏ស្របច្បាប់របស់ស្ថានសួគ៌ឲ្យមកអន្តរាគមន៍នៅក្នុងស្ថានការណ៍នេះឡើយ។ «ប៉ុន្តែ លោកហ្គារី ពួកគេបានព្យាយាមដេញវាចេញ។» មែនហើយ ប៉ុន្តែដូចដែលខ្ញុំបាននិយាយអញ្ចឹង បើគិតតាមច្បាប់គឺវាមិនចាំបាច់ចេញទេ។ ហេតុអ្វី? ជាថ្មីម្តងទៀត ស្ថានសួគ៌ពុំមានសិទ្ធិស្របច្បាប់ដើម្បីបណ្តេញអារក្សចេញទេនៅពេលនោះ។

> **ដោយហេតុថាមនុស្សមាននីត្យានុកូលភាពនៅលើភពផែនដី រាជរដ្ឋាភិបាល និងសិទ្ធិអំណាចរបស់ព្រះជាម្ចាស់មិនអាចធ្វើចលនាបានឡើយរហូតដល់មានបុរស ឬស្ត្រីណាម្នាក់ដែលមានសិទ្ធិអំណាចគ្រប់គ្រងនៅលើផែនដីនោះ ទាំងយល់ស្រប ឬជឿជាក់ទាំងស្រុងទៅលើអ្វីដែលស្ថានសួគ៌ប្រកាស ហើយបន្ទាប់មកស្រាយនូវសិទ្ធិអំណាចនោះមកកាន់ផែនដី។**

**ឱព្រះជាម្ចាស់អើយ សូមមេត្តាទូលបង្គំផង!**

សូមអនុញ្ញាតឲ្យខ្ញុំបកស្រាយនូវអ្វីដែលខ្ញុំទើបបាននិយាយ។ ពួកគេមានគំនិតខុសឆ្គងដោយហៅអ្វីដែលខុសឆ្គងថាល្អ ឬអាចទទួលយកបាន ឬគិតផ្ទុយពីអ្វីដែលព្រះជាម្ចាស់មានបន្ទូលអំពីបញ្ហាណាមួយ។ ការមិនជឿក៏ជាបញ្ហាធំដែរ ព្រោះដើម្បីឲ្យស្ថានសួគ៌មានអំណាចនៅលើភពផែនដី យើងត្រូវការជំនឿ។ ពួកសិស្សមិនបានជឿ គឺពួកគេយល់ស្របថាអារក្សនឹងមិនចេញមកទេ។ ពួកគេមានភាពភ័យខ្លាច។

ដោយហេតុថាមនុស្សមាននីត្យានុកូលភាពនៅលើភពផែនដី រាជរដ្ឋាភិបាល និងសិទ្ធិអំណាចរបស់ព្រះជាម្ចាស់មិនអាចធ្វើចលនាបានឡើយរហូតដល់មានបុរស ឬស្ត្រីណាម្នាក់ដែលមានសិទ្ធិអំណាចគ្រប់គ្រងនៅលើផែនដីនោះ យល់ស្រប ឬជឿជាក់ទាំងស្រុងទៅលើអ្វីដែលស្ថានសួគ៌ប្រកាស ហើយបន្ទាប់មកស្រាយនូវសិទ្ធិអំណាចនោះមកកាន់ផែនដី។ ម្យ៉ាងវិញទៀត ការដែលមានដួងចិត្តយល់ស្រប ឬជឿជាក់នៅលើអ្វីដែលស្ថានសួគ៌ប្រកាសគឺហៅថាជំនឿ ហើយនៅពេលនោះពុំមាននរណាម្នាក់មានជំនឿឡើយ។ ពួកគេមានចិត្តពីរ ហើយពោរពេញដោយការមិនជឿ ហេតុដូច្នេះហើយបានជាពួកគេកាត់ផ្តាច់នូវសិទ្ធិអំណាចនៃស្ថានសួគ៌ នៅលើស្ថានការណ៍នេះ។ ប៉ុន្តែ ព្រះយេស៊ូមានជំនឿ ហើយដឹងថាអារក្សនេះនឹងចេញមកជាមិនខាន! ព្រះយេស៊ូក៏បានដេញអារក្ស ហើយវាក៏ចេញ។ «ប៉ុន្តែ លោកហ្គារី ហេតុផលដែលអារក្សចេញនៅពេលដែលព្រះយេស៊ូបណ្តេញវា គឺដោយសារទ្រង់ជាព្រះយេស៊ូ។» មែនឬ? សូមមើលគម្ពីរម៉ាកុស ៦៖៥ នៅពេលដែលព្រះយេស៊ូបានធ្វើព័ន្ធកិច្ចនៅក្នុងស្រុកកំណើតរបស់ទ្រង់។

*នៅទីនោះ ព្រះអង្គ<u>ពុំអាច</u>ធ្វើការអស្ចារ្យអ្វីឡើយ បានត្រឹមតែដាក់ព្រះហស្ត លើអ្នកជំងឺខ្លះ ដើម្បីប្រោសគេឲ្យជាប៉ុណ្ណោះ។*

លោកអ្នកប្រហែលជាចាំបាច់ត្រូវយល់ស្របថា ព្រះយេស៊ូមានឫទ្ធានុភាពដើម្បីប្រោសមនុស្សឲ្យបានជាពីជំងឺមែនទេ? បើដូច្នេះមែន លោកអ្នកក៏ត្រូវតែអាចឆ្លើយនូវសំណួរថា ហេតុអ្វីបានជាទ្រង់ពុំអាចធ្វើការដែលទ្រង់ចង់ធ្វើនៅក្នុងសាច់រឿងនោះ។ មនុស្សមានសេចក្តីត្រូវការ ប៉ុន្តែមានអ្វីម្យ៉ាងបានរារាំងទ្រង់។ ទ្រង់បានឆ្លើយទៅនឹងសំណួរនោះនៅខ ៦៖ *«ព្រះអង្គនឹកឆ្ងល់ ដោយឃើញគេគ្មានជំនឿបែបនេះ។»* ជំនឿ (ជាការយល់ស្របជាមួយនឹងស្ថានសួគ៌) ផ្តល់ឲ្យស្ថានសួគ៌នូវសិទ្ធិស្របច្បាប់នៅលើភពផែនដី។ ឧទាហរណ៍ លោកអ្នកអាចឃើញពីគោលការណ៍នេះនៅក្នុងរបៀបដែលលោកអ្នកបានទទួលការសង្គ្រោះ និងទទួលជឿលើព្រះគ្រិស្ត។

> *ដ្បិតបើចិត្តយើងជឿ យើងនឹងបានសុចរិត ហើយបើមាត់យើងប្រកាសជំនឿនោះយើងនឹងទទួលការសង្គ្រោះ។*
>
> រ៉ូម ១០៖១០ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

លោកអ្នកជឿនៅក្នុងចិត្ត (នូវអ្វីដែលស្ថានសួគ៌ថ្លែងប្រកាស) នោះលោកអ្នកបានសុចរិត។ នេះជាពាក្យស្របច្បាប់ ជាអត្ថន័យនៃការអនុវត្តតាមច្បាប់ និងជាការសង្កត់ធ្ងន់ថា នៅពេលនេះស្ថានសួគ៌មានសិទ្ធិស្របច្បាប់នៅលើភពផែនដី។ នៅពេលដែលយើងមើលពីគោលការណ៍នេះដោយទស្សនៈសាមញ្ញ ចូរឲ្យយើងចងចាំថាលោកអដាំបានទទួលនូវការត្រួតត្រាស្របច្បាប់នៅលើផែនដីនេះ ហើយមនុស្សនៅតែមានមុខតំណែងនោះ។ យ៉ាងណាមិញ សូមកុំយល់ច្រឡំជាមួយនឹងការដែលមនុស្សអសមត្ថភាពក្នុងការគ្រប់គ្រងខាងឯវិញ្ញាណ ព្រោះគាត់បានបាត់បង់ការគ្រប់គ្រងខាងឯវិញ្ញាណ ទៅឲ្យមារសាតាំងនៅក្នុងសួនអេដែន។ ព្រះជាម្ចាស់មិនអាចល្មើសនឹងមុខតំណែងស្របច្បាប់ដែលមនុស្សមាននៅលើភពផែនដីបានឡើយ។ ហេតុដូច្នេះហើយ ព្រះជាម្ចាស់ត្រូវតែស្វែងរកបុរស ឬស្ត្រីណាម្នាក់ដែលនឹង

យល់ស្របជាមួយស្ថានសួគ៌ ដើម្បីឲ្យទ្រង់អាចយាងចូលមក និងមានសកម្មភាពនៅលើភពផែនដីដោយស្របច្បាប់។

នៅក្នុងគម្ពីររ៉ូម ១០៖១០ លោកអ្នកនឹងកត់សម្គាល់ឃើញថា មានកិច្ចការពីរយ៉ាងដែលចាំបាច់ត្រូវកើតឡើងមុនពេលដែលសិទ្ធិអំណាច និងឫទ្ធានុភាពនៃស្ថានសួគ៌អាចត្រូវបានស្រាយនៅលើភពផែនដីនេះ។ កិច្ចការទីមួយ ជាអ្វីដែលខ្ញុំបាននិយាយរួចមកហើយ៖ យើងត្រូវជឿជាក់ និងយល់ស្របទាំងស្រុងនៅក្នុងចិត្តជាមួយនឹងអ្វីដែលស្ថានសួគ៌ថ្លែងប្រកាស។ នេះគឺជាជំនឿ។ ទីពីរ យើងចាំបាច់ត្រូវយល់ថាការដែលមានជំនឿតែម្យ៉ាងនឹងមិនស្រាយស្ថានសួគ៌មកទេ? ភ្ញាក់ផ្អើលពេលបានឮបែបនេះ មែនទេ? សូមអនុញ្ញាតឲ្យខ្ញុំពន្យល់។ សូមគិតពីកុងតាក់ភ្លើង។ ទោះបីជាមានអគ្គិសនីហើយក្ដី ក៏លោកអ្នកត្រូវចុចកុងតាក់ដើម្បីបើកភ្លើងដែរ។ នៅពេលដែលយើងជឿនៅក្នុងចិត្តនូវអ្វីដែលស្ថានសួគ៌ប្រកាស ធ្វើឲ្យការផ្សារភ្ជាប់ជាមួយនឹងស្ថានសួគ៌ជាការស្របច្បាប់ ឬសុចរិត។ ប៉ុន្តែ យើងក៏ត្រូវស្រាយសិទ្ធិអំណាចនោះមកលើផែនដីនេះដែរ។ ដូចជានៅក្នុងឧទាហរណ៍របស់ខ្ញុំ យើងត្រូវបើកកុងតាក់។ យើងធ្វើកិច្ចការនេះនៅពេលដែលយើងប្រកាសសារភាព និងប្រព្រឹត្តដោយសិទ្ធិអំណាចនៃស្ថានសួគ៌។

ខ្ញុំដឹងថា ខ្ញុំនិយាយដដែលៗ ប៉ុន្តែការដែលយល់ពីច្បាប់នៃព្រះរាជ្យ ជាការ**ចាំបាច់**ដើម្បីឲ្យលោកអ្នកមានសមត្ថភាពដើម្បីទទួលនូវអ្វីដែលស្ថានសួគ៌មានសម្រាប់លោកអ្នក។ លោកអ្នកនឹងទទួលអ្វីៗគ្រប់យ៉ាងពីស្ថានសួគ៌នៅក្នុងរបៀបដូចគ្នាដែលលោកអ្នកបានទទួលការសង្គ្រោះដែរ គឺដោយជឿនៅក្នុងចិត្តទៅលើអ្វីដែលស្ថានសួគ៌ប្រកាស ហើយបន្ទាប់មកប្រកាសចេញ ឬប្រព្រឹត្តទៅតាមអ្វីដែលស្ថានសួគ៌ថ្លែងប្រកាសនោះ។

ព្រះរាជ្យរបស់ព្រះជាម្ចាស់ ដូចដែលព្រះយេស៊ូបានបង្រៀន និងបង្ហាញពីវា គឺពិតជាថ្មីទាំងស្រុងសម្រាប់ពួកសិស្ស។ មានពេលជាច្រើនលើកច្រើនសា យើងអាចឃើញពួកសិស្សច្របូកច្របល់ដោយសារអ្វីដែលពួកគេបានឃើញ។ នៅក្នុងអត្ថបទ

គម្ពីរមុនដែលយើងទើបបានអាន ខ្ញុំជឿថាពួកសិស្សមានភាពភ័យខ្លាចដោយសារតែសកម្មភាពរបស់អារក្ស ហើយប្រែជាមានចិត្តពីរ។ ការនេះបាននាំឲ្យជំនឿរបស់គេគ្មានសកម្មភាព។ ខ្ញុំសន្មតថានៅពេលដែលគេដើរទៅដេញអារក្ស អារក្សទាំងនោះប្រហែលជារើ។ វាប្រហែលជាផ្តួលក្មេងនោះ ហើយរើ ឬធ្វើសកម្មភាពសម្លែងពួកគេ។ ការធ្វើបែបនេះ ប្រហែលជានាំឲ្យពួកគេមានភាពភ័យខ្លាច។ នៅត្រង់នេះ ខ្ញុំគ្រាន់តែវិភាគប៉ុណ្ណោះ ប៉ុន្តែមានរឿងមួយដែលខ្ញុំប្រាកដ។ មានអ្វីម្យ៉ាងបានកើតឡើង ដែលនាំឲ្យចិត្តរបស់គេលែងយល់ស្របជាមួយនឹងស្ថានសួគ៌ ហើយបែរជាមានការមិនជឿទៅវិញ។

**ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្វីក៏ដោយ ឲ្យតែអ្នករាល់គ្នាអធិស្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជាម្ចាស់នឹងប្រទានឲ្យអ្នករាល់គ្នាជាពុំខាន។**

**- ម៉ាកុស ១១៖២៤**

ម្យ៉ាងវិញទៀត ព្រះយេស៊ូជឿជាក់ និងយល់ស្របទាំងស្រុងទៅលើអ្វីដែលស្ថានសួគ៌បានប្រកាសអំពីស្ថានការណ៍បែបនេះ ហើយទ្រង់បានបញ្ជាអារក្សឲ្យចេញ។ ដូច្នេះ តាមដែលយើងបានឃើញ បញ្ហាដែលអារក្សមិនបានចេញ ជារឿងដែលទាក់ទងនឹងភពផែនដី មិនមែនទាក់ទងនឹងស្ថានសួគ៌ឡើយ។

ប្រសិនបើមានខគម្ពីរត្រឹមតែមួយខ ដែលខ្ញុំអាចជ្រើសរើសយកមកបង្ហាញពីការដំណើរការនៃព្រះរាជ្យនៅលើភពផែនដី ខ្ញុំនឹងជ្រើសយកម៉ាកុស ១១៖២២-២៤។ ដើម្បីជាការរៀបចំ យើងចាំបាច់មើលទៅលើខគម្ពីរពីរបីខមុនសិន ហើយយើងនឹងឃើញថាព្រះយេស៊ូបានមានបន្ទូលទៅកាន់ដើមឧទុម្ពរ ហើយវាក៏ងាប់។ គឺព្រះយេស៊ូបានដាក់បណ្តាសាវាបន្ទាប់ពីពុំបានឃើញវាមានផ្លែសោះ។ នៅថ្ងៃស្អែកឡើង ពេលដែលពួកសិស្សបានដើរកាត់ដើមឈើដដែល គេក៏ឃើញដើមឈើនោះងាប់មែន។ លោកពេត្រុសបាន

ភ្ញាក់ផ្អើលដោយសារអ្វីដែលគាត់បានឃើញ ហើយស្រែកហៅព្រះយេស៊ូទាំងតក់ស្លុត។

*ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកសិស្សថា៖ «ចូរមានជំនឿលើព្រះជាម្ចាស់ចុះ!។ ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា បើអ្នកណាម្នាក់និយាយទៅកាន់ភ្នំនេះថា "ចូរចេញពីទីនេះធ្លាក់ក្នុងសមុទ្រទៅ!" ហើយបើអ្នកនោះជឿជាក់ក្នុងចិត្ត ដោយឥតសង្ស័យថាពាក្យរបស់ខ្លួននឹងបានសម្រេច នោះព្រះជាម្ចាស់នឹងប្រទានឲ្យបានសម្រេចតាមពាក្យគេមែន។ ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្វីក៏ដោយ ឲ្យតែអ្នករាល់គ្នាអធិស្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជាម្ចាស់នឹងប្រទានឲ្យអ្នករាល់គ្នាជាពុំខាន។*

ម៉ាកុស ១១៖២-២៤ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

សូមកត់ចំណាំថា លោកពេត្រុសបានភ្ញាក់ផ្អើលពីអ្វីដែលបានកើតឡើង។ តើវាបានកើតឡើងដោយរបៀបណា? ព្រះយេស៊ូបានគ្រាន់តែមានបន្ទូលទៅកាន់ដើមឈើប៉ុណ្ណោះ។ ប៉ុន្តែ យើងបានឃើញយ៉ាងច្បាស់ថាដើមឈើបានឆ្លើយតបទៅនឹងព្រះបន្ទូលរបស់ព្រះយេស៊ូ ហើយវាក៏ងាប់។ ព្រះយេស៊ូក៏បានប្រាប់លោកពេត្រុសនូវ «សេចក្តីពិត» មួយ ជាច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ សេចក្តីពន្យល់របស់ព្រះយេស៊ូផ្តល់ឲ្យយើងយល់កាន់តែច្បាស់ពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់មានសកម្មភាពនៅលើភពផែនដី។ ជាថ្មីម្តងទៀត នៅក្នុងឧទាហរណ៍នេះយើងឃើញពីច្បាប់ដដែលដែលបំពេញមុខងារ ជាច្បាប់ដែលយើងបាននិយាយពីខាងដើមមក ជាការដែលមានបុរស ឬស្ត្រីនៅលើផែនដីបានជឿជាក់ទាំងស្រុងទៅលើអ្វីដែលស្ថានសួគ៌ប្រកាស (នៅពេលនេះពួកគេបានសុចរិតហើយ) បន្ទាប់មកក៏ប្រកាស ឬស្រាយនូវសិទ្ធិអំណាចនៃស្ថានសួគ៌។ ជាការពិតណាស់ បុរសនោះក្នុងសាច់រឿងនេះគឺជាព្រះយេស៊ូផ្ទាល់ ប៉ុន្តែព្រះអង្គបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការពន្យល់

របស់ទ្រង់ទៅកាន់ពួកសិស្សថា «អ្នកណាម្នាក់» ក៏អាចធ្វើនូវអ្វីដែលទ្រង់ទើបតែបានធ្វើដែរ។

ខ្ញុំប្រាកដថា លោកអ្នកពិតជាយល់ស្របថាប្រសិនបើមនុស្សពិតជាយល់ពីសេចក្ដីនេះ និងយល់ពីច្បាប់ដែលព្រះយេស៊ូកំពុងតែបង្រៀនពួកគេ នោះវានឹងមានផលប៉ះពាល់ដ៏គួរឲ្យកត់សម្គាល់នៅលើជីវិតរបស់គេ។ ខ្ញុំបានឃើញផលប៉ះពាល់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅលើជីវិតក្រុមគ្រួសាររបស់ខ្ញុំផ្ទាល់ ប៉ុន្តែវាក៏ជាការរំភើបដែរក្នុងការដែលឃើញព្រះរាជ្យប៉ះពាល់ដល់ក្រុមគ្រួសារដទៃទៀត នៅពេលដែលយើងបង្រៀនពួកគេពីអ្វីដែលយើងបានរៀន។ សូមអនុញ្ញាតឲ្យខ្ញុំប្រាប់ពីសាច់រឿងមួយនៅក្នុងក្រុមជំនុំរបស់ខ្ញុំ ជាកន្លែងដែលច្បាប់នេះបានលេចជាសកម្មភាពឡើង។ មានពេលជាច្រើនលើកច្រើនសា ការដែលមានចំណេះដឹងអំពីព្រះរាជ្យ និងការដំណើរការនៃព្រះរាជ្យគឺនាំឲ្យមានភាពខុសគ្នាខ្លាំងណាស់។ នៅក្នុងសាច់រឿងខាងលើបានបង្ហាញដូច្នេះឯង។

អ្នកស្រីជេននីហ្វើរបានចូលរួមនៅក្នុងក្រុមជំនុំរបស់ខ្ញុំ ហើយឮអំពីជំនឿ និងព្រះរាជ្យ។ នាងរំភើបក្នុងការរៀនពីសិទ្ធិអំណាច និងសិទ្ធិរបស់នាងនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ព្រោះនាងកំពុងតែពពោះកូនទីពីរ ហើយនាងចង់សម្រាលកូននៅផ្ទះ។ ដូច្នេះ នាងក៏បានចាប់ផ្ដើមសិក្សានូវអ្វីដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ថែងអំពីការសម្រាលកូន និងព្រះបន្ទូលសន្យានៅក្នុងព្រះរាជ្យដែលមានសម្រាប់កូនរបស់នាង។ នាងជឿជាក់ថានាងអាចសម្រាលកូននៅផ្ទះ ទាំងមានសុខភាពល្អ។ នាងបានរៀបចំឆ្មបម្នាក់ ហើយក៏បានសុំឲ្យស្ត្រីម្នាក់នៅក្នុងក្រុមជំនុំរបស់យើងដែលបានសម្រាលកូនពីរបីនាក់នៅផ្ទះមកហើយ ជួយបង្រៀនដល់នាងនៅក្នុងពេលសម្រាល។

លុះជិតដល់ពេលសម្រាលកូន នាងបានចូលរួមគ្រប់ការប្រជុំក្រុមជំនុំ ដើម្បីសិក្សាស៊ីជម្រៅនូវគោលការណ៍នៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ គោលគំនិតទាំងនេះសុទ្ធតែថ្មីសម្រាប់ជេននីហ្វើរ ហើយនៅពេលនេះ នាងពេញចិត្តក្នុងការដែលរៀន

បានថា មានដំណោះស្រាយ ឬចម្លើយដ៏ពិតប្រាកដនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។ គួរឲ្យសោកស្ដាយ នៅលើកនេះ ស្វាមីរបស់នាងត្រូវធ្វើការនៅថ្ងៃអាទិត្យ ហើយមិនអាចចូលរួមក្រុមជំនុំជាមួយនាងឲ្យបានញឹកញាប់។ យ៉ាងណាមិញ ពេលដែលកូនក្នុងផ្ទៃត្រូវប្រសូតក៏បានមកដល់។ នាងបានទូរស័ព្ទទៅកាន់ឆ្មប និងស្ត្រីដែលជាគ្រូបង្វឹករួចស្រេចទៅហើយ។

ពេលនោះគឺម៉ោងប្រមាណជា២ឬ៣ទៀបភ្លឺ ទូរស័ព្ទនៅក្បែរគ្រែរបស់ខ្ញុំក៏បានបន្លឺសំឡេងរោទ៍ឡើង។ នៅក្នុងទូរស័ព្ទ ខ្ញុំបានឮសំឡេងស្ត្រីជាគ្រូបង្វឹករបស់ជេននីហ្វើរស្រែកឡើងថា «លោកគ្រូ សូមជួយអធិស្ឋានផង ទារកបានកើតមកដោយស្លាប់បាត់ទៅហើយ!» ដោយបានឮបែបនេះ ធ្វើឲ្យខ្ញុំស្វាងចែសពីដំណេក។ គ្រូបង្វឹកនោះក៏បាននិយាយថាទើបតែមានរថយន្តសង្គ្រោះបន្ទាន់មកយកសាកសពទារិកាទៅមន្ទីរពេទ្យ។ នាងក៏បានប្រាប់ខ្ញុំថា តាមពិតក្រុមគ្រូពេទ្យបានថ្លែងថាទារិកានោះបានស្លាប់នៅពេលកើតមក។

ឌ្រិនដានិងខ្ញុំក៏ស្ទុះឡើង ហើយផ្លាស់សម្លៀកបំពាក់។ ខ្ញុំបានចាប់ផ្ដើមអធិស្ឋាននៅក្រោមការណែនាំរបស់ព្រះវិញ្ញាណ ដោយស្ដាប់ព្រះអង្គអំពីអ្វីដែលខ្ញុំគួរធ្វើ។ ខ្ញុំដឹងថាអារក្សចង់ប្រហារក្រុមជំនុំរបស់យើងតាមរយៈហេតុការណ៍មួយនេះ។ ខ្ញុំអាចស្រមៃឃើញសារព័ត៌មានចុះផ្សាយថា «ទារិកាម្នាក់បានស្លាប់បន្ទាប់ពីក្រុមជំនុំនិកាយខុសឆ្គងមួយបានលើកទឹកចិត្តឲ្យមានការសម្រាលកូននៅផ្ទះ។» យើងពិតជាមិនលើកទឹកចិត្តនៅលើប្រធានបទដែលទាក់ទងនឹងការដែលទារិកាគួរកើតនៅផ្ទះ ឬនៅមន្ទីរពេទ្យទេ ប៉ុន្តែមានស្ត្រីជាច្រើនបានជ្រើសរើសការសម្រាលកូននៅផ្ទះ។ ឌ្រិនដានិងខ្ញុំបានបន្តអធិស្ឋានក្រោមការណែនាំនៃព្រះវិញ្ញាណនៅពេលដែលយើងបើកឡានទៅកាន់មន្ទីរពេទ្យក្នុងចម្ងាយផ្លូវ២០នាទី។ នៅពេលបើកបានប្រហែលជាពាក់កណ្ដាលផ្លូវ ខ្ញុំស្រាប់តែមានអារម្មណ៍ពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានយាងមកសណ្ឋិតលើខ្ញុំ ហើយខ្ញុំដឹងថាទារិកានោះនឹងមិនអីទេ។ នៅវិនាទី

នោះ ភរិយារបស់ខ្ញុំក៏ងាកមកប្រាប់ខ្ញុំថា ព្រះអម្ចាស់ទើបតែប្រាក់នាងថាទារិកាក៏នឹងមិនមានបញ្ហាអីដែរ។

ខ្ញុំបានដឹងពីអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់ភរិយារបស់ខ្ញុំហើយនិងខ្ញុំ ដូច្នេះ នៅខណៈដែលកំពុងដើរសំដៅទៅកាន់បន្ទប់សង្គ្រោះបន្ទាន់ ខ្ញុំចង់ដឹងថាទារិកានោះយ៉ាងណាហើយ។ នៅក្នុងបន្ទប់សង្គ្រោះបន្ទាន់ ខ្ញុំបានឃើញគិលានុបដ្ឋាកយិកាបួនប្រាំនាក់កំពុងតែឈរនៅជុំវិញទារិកាដែលមានពណ៌ស៊ីជម្ពូ មានសភាពធម្មតា និងកំពុងតែយំ។ ខ្ញុំបានពិនិត្យមើលទឹកមុខរបស់ពួកគេដោយយកចិត្តទុកដាក់។ នៅក្នុងស្ថានការណ៍ភាគច្រើនដែលមានស្រ្តីៗមួយក្រុមនៅជុំវិញទារក ពួកគេតែងមានទឹកមុខញញឹម។ ប៉ុន្តែនៅពេលនេះ ពុំមាននរណាញញឹមឡើយ។ ផ្ទុយទៅវិញ គ្រប់ៗគ្នាមានទឹកមុខភ្ញាក់ផ្អើលជាខ្លាំង។

យើងបានជួបជាមួយនឹងស្ត្រីដែលបានទូរស័ព្ទមកយើង។ នាងក៏បានប្រាប់យើងម្តងទៀតថា ទារិកាត្រូវបានឆ្មបប្រាប់ថាស្លាប់ហើយកាលនៅផ្ទះដែលមានចម្ងាយផ្លូវប្រមាណជា២០នាទី។ ពេលមកដល់មន្ទីរពេទ្យ ខាងមន្ទីរពេទ្យក៏បានប្រាប់ថាទារិកានោះបានស្លាប់ហើយនៅពេលមកដល់ ប៉ុន្តែនាងក៏បានដឹងខ្លួនក្នុងមួយពព្រិចភ្នែក។ សូមសរសើរព្រះជាម្ចាស់! ខ្រិនដានិងខ្ញុំពិតជារំភើបនឹងជួបទារិកាដែលមានជីវិត និងមានសុខភាពល្អដូចជាព្រះវិញ្ញាណដ៏វិសុទ្ធបានប្រាប់យើង។

ព្រមពេលជាមួយគ្នាដែរ រថយន្តសង្គ្រោះបន្ទាន់មួយផ្សេងទៀតក៏បានដឹកជេននីហ្វើរជាម្តាយរបស់ទារកទៅកាន់ផ្នែកសម្ភព។ ជាលទ្ធផល នាងពុំបានដឹងពីស្ថានភាពរបស់ទារិកាទេ។ ខ្រិនដាជាភរិយារបស់ខ្ញុំបានដើរទៅកាន់បន្ទប់ដែលជេននីហ្វើរសម្រាក ហើយប្រាប់នាងថា «ជេននីហ្វើរ កូនរបស់នាងមិនអីទេ ហើយនាងគួរឲ្យស្រឡាញ់ណាស់។» គិលានុបដ្ឋាកយិកាដែលឈរនៅក្បែរជេននីហ្វើរក៏បានស្ទុះឈរឡើង ហើយស្រែកភ្លាត់មាត់ថា «អត់ទេ ទារកនោះត្រូវគេដាក់ក្នុងថង់សពហើយ!» ភរិយារបស់ខ្ញុំបានកែតម្រូវគិលានុបដ្ឋាកយិកានោះអំពីកំហុសរបស់នាងយ៉ាងមធ្យ័ត។ នៅសព្វថ្ងៃនេះ ទារិកានោះដែលមានឈ្មោះថាហាលី ជាយុវតីដ៏

ស្រស់ស្អាត ដែលពុំមានការប៉ះពាល់នៅលើខួរក្បាល ឬបញ្ហាសុខភាពអ្វីទាំងអស់។ សូមថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់។ ការដែលយល់ថាព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការដោយផ្អែកលើច្បាប់ខាងវិញ្ញាណ ខ្ញុំដឹងថាការនេះមិនមែនជាការចៃដន្យទេ។ ដូច្នេះ ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ (មិនមែនជាវិទ្យាសាស្ត្រគ្រិស្តបរិស័ទ ប៉ុន្តែជាអ្នកដែលសិក្សាពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការ) ខ្ញុំពិតជាចង់រកឲ្យឃើញថាតើមានអ្វីកើតឡើងឲ្យប្រាកដ។

ខ្ញុំបានដឹងថាទារិកាហាលីត្រូវគេប្រកាសជាផ្លូវការថា «ទទួលមរណៈភាពពេលប្រសូតមក» ដោយក្រុមសង្គ្រោះដែលបានមកផ្ទះនាងតាមរថយន្តសង្គ្រោះបន្ទាន់។ ដូច្នេះ តើមានអ្វីកើតឡើង? ខ្ញុំបាននិយាយជាមួយស្ត្រីជាគ្រូបង្វឹកផ្នែកសម្រាលដែលនៅទីនោះ ហើយក៏សុំឲ្យនាងរៀបរាប់ប្រាប់ខ្ញុំពីអ្វីដែលបានកើតឡើងឲ្យបានលម្អិត។ ខ្ញុំកំពុងតែរកមើលតម្រុយ។ នាងបាននិយាយថា ដំណើរការនៃការសម្រាលមានភាពរលូនរហូតដល់ទារិកាប្រសូតមក។ នាងពុំមានជីពចរ សម្ពាធឈាម សីតុណ្ហភាព និងចលនាដង្ហើមទេ ហើយមានភាពស្លេកស្លាំងនៅលើរាងកាយទាំងមូល ។ ឆ្មបបានព្យាយាមជួយទារកឲ្យដឹងខ្លួនឡើងវិញ ប៉ុន្តែពុំអាចជួយបានឡើយ។ ស្ត្រីជាគ្រូបង្វឹកបានបន្តនិយាយថា ជេននីហ្វើរមានសាច់ញាតិជាច្រើនដែលចាប់ផ្តើមភ័យតក់ស្លុត។ ប៉ុន្តែ ជេននីហ្វើរបានប្រាប់ពួកគេកុំឲ្យជ្រួលច្របល់ ហើយនាងក៏បានយកម្រាមដៃមកដាក់នៅលើមុខស្វាមី ដោយនិយាយថា «បងកុំនិយាយអ្វីទាំងអស់ ហើយកូនយើងនឹងមិនអីទេ!»

ខ្ញុំក៏បានកាត់សម្តីគ្រូបង្វឹកនៅត្រឹមនេះ ហើយសុំឲ្យនាងនិយាយសាឡើងវិញពីអ្វីដែលជេននីហ្វើរបាននិយាយប្រាប់ដល់ស្វាមី។ នាងបានប្រាប់ខ្ញុំនូវពាក្យដដែលដែលនាងទើបតែបាននិយាយ ដែលថាជេននីហ្វើរបានយកម្រាមដៃទៅដាក់នៅលើមុខរបស់ស្វាមីហើយពោលថា «បងកុំនិយាយអ្វីទាំងអស់ ហើយកូនយើងនឹងមិនអីទេ!» អស្ចារ្យណាស់! គឺហ្នឹងហើយ! នោះឯងជាពេលដ៏សំខាន់ ជាសេចក្តីប្រកាសដែលបានជួយសង្គ្រោះជីវិតទារិកាហាលី។ ខ្ញុំមានអារម្មណ៍ថាដូចជាអ្នកស៊ើបអង្កេត

ដែលទើបបានបំបែករឿងក្តីដ៏ធំមួយអញ្ចឹង! ខ្ញុំពិតជាសប្បាយចិត្តណាស់។ វាជារឿងដ៏សាមញ្ញ ប៉ុន្តែមានន័យជ្រៅ។ ជេននីហ្វើរគ្រាន់តែបានអនុវត្តនូវច្បាប់ខាងវិញ្ញាណនៅក្នុងស្ថានការណ៍នោះ ហើយវាបានសង្គ្រោះជីវិតទារិកា! នៅពេលដែលខ្ញុំគិតពិចារណាពីអ្វីដែលខ្ញុំទើបតែស្វែងយល់ គឺវាជាការសមហេតុផល។

អ្នកស្រីជេននីហ្វើរបានដឹងថា ដោយសារតែកាលវិភាគការងាររបស់ស្វាមីគាត់មិនបានកសាងឡើងនៅក្នុងជំនឿដូចជានាង ក្នុងពេលប៉ុន្មានខែមុនឡើយ។ នាងក៏បានដឹងថា នៅក្នុងនាមស្វាមីជាមេគ្រួសារ ការដែលគាត់យល់ស្របជាមួយនឹងនាទីដ៏រន្ធត់នៅពេលទារកកើតមកនោះ អាចនឹងលួចជោគវាសនាដ៏ល្អចេញពីទារកបាន។ ហេតុនេះហើយបានជាការឆ្លើយតបរបស់នាងដំបូងគេគឺប្រាប់ស្វាមីហើយមិនបណ្តោយឲ្យគាត់យល់ស្របជាមួយនឹងការស្លាប់របស់ទារក។ ផ្ទុយទៅវិញ នាងជេននីហ្វើរបានជឿជាក់ថាក្មេងនោះនឹងមានជីវិតរស់នៅ មានសុខភាពល្អ ហើយនាងបានប្រកាសពាក្យទាំងនោះដោយចិត្តក្លាហាន និងជំនឿ។

នៅពេលដែលនាងជេននីហ្វើរបានចេញពីមន្ទីរពេទ្យភ្លាម នាងបានទៅជួបក្រុមការងារប្រចាំរថយន្តសង្គ្រោះបន្ទាន់ ហើយសួរពួកគេថាតើគេបានធ្វើអ្វីខ្លះទៅកាន់ទារិកានៅពេលធ្វើដំណើរមកមន្ទីរពេទ្យនៅយប់នោះ។ ពួកគេបានសម្លឹងមើលនាងដោយទឹកមុខអឹមអៀន។

ចុងក្រោយបំផុត ម្នាក់ក្នុងចំណោមពួកគេប្រាប់ថា «មិនបានធ្វើអីទេ»

ជេននីហ្វើរក៏សួរថា «មិនបានធ្វើអីទេ តើមានន័យថាម៉េច? តើពួកលោកបានធ្វើចលនាបេះដូងដែរឬទេ?»

ពួកគេពោលថា «អត់ទេ។»

«តើពួកលោកបានធ្វើអ្វីសម្រាប់ទារកនោះដែរឬទេ?»

ពួកគេនិយាយម្តងទៀតថា «អត់ទេ»។

ពួកគេបានប្រាប់នាងថា ទារិកានោះបានស្លាប់បាត់ហើយ ហើយពួកគេពុំមានសង្ឃឹមថានាងនឹងរស់ឡើងវិញឡើយ។ ទោះជាយ៉ាងនេះក្តី ទារកនោះគ្រាន់តែ «ដឹងខ្លួន» នៅពេលដែលពួកគេទៅដល់មន្ទីរពេទ្យ! ក្រុមការងារប្រចាំរថយន្តសង្គ្រោះបន្ទាន់បានទទួលការសរសើរពីមន្ទីរពេទ្យ និងនាយកដ្ឋានពន្លត់អគ្គីភ័យសម្រាប់ពានរង្វាន់ប្រចាំឆ្នាំ គឺជារង្វាន់ដែលផ្អែកលើលទ្ធផលដែលក្រុមការងារនីមួយបានឆ្លើយតបទៅនឹងស្ថានការណ៍លំបាកៗ។ ប៉ុន្តែ ពួកគេបានសារភាពថាពួកគេពុំបានធ្វើអ្វីទាំងអស់។

ថ្មីៗនេះ យើងបានមានវត្តមានរបស់ហាលីជាភ្ញៀវនៅក្នុងកម្មវិធីទូរទស្សន៍របស់យើងជាមួយនឹងអ្នកនាងជេននីហ្វើរជាម្តាយ។ យើងគ្រប់គ្នាបានអបអរសាទរនូវព្រះរាជ្យរបស់ព្រះជាម្ចាស់ដោយក្តីត្រេកអរ និងទប់ទឹកភ្នែកមិនបាន។ យើងបានអបអរលើការដែលមានមនុស្សបានធ្វើសកម្មភាពនៅក្នុងច្បាប់ខាងឯវិញ្ញាណ និងសិទ្ធិអំណាចនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។

នៅក្នុងសាច់រឿងនេះ យើងបានឃើញនាងជេននីហ្វើរជឿជាក់ទាំងស្រុងទៅលើអ្វីដែលស្ថានសួគ៌ប្រកាស ហើយក៏ស្រាយនូវសិទ្ធិអំណាចនោះមកកាន់ស្ថានការណ៍ដោយពាក្យសម្តីរបស់នាង។ ច្បាប់នៃព្រះរាជ្យពិតជាមានប្រសិទ្ធិភាពមែន!

មានក្រុមគ្រួសារមួយទៀតនៅក្នុងក្រុមជំនុំរបស់ខ្ញុំ បានមានបទពិសោធន៍ដូចខាងក្រោមជាមួយនឹងច្បាប់ដដែលនេះនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។ មានបងប្អូនស្រីៗពីរនាក់បានសម្រេចចិត្តពិសាអាហារថ្ងៃត្រង់ជាមួយគ្នា ហើយដោយហេតុថាពួកគេទាំងពីរមានក្មេងតូចៗដែលជាកូនរបស់អ្នកទាំងពីរប្រហែលជា១២ទៅ១៣នាក់នៅជាមួយ។ នៅពេលដែលគេកំពុងពិសាអាហារថ្ងៃត្រង់ គេបានចាប់អារម្មណ៍ថា យ៉ូអែលជាក្មេងប្រុសអាយុបួនឆ្នាំបានបាត់។ ពួកគេបានរកមើលនៅជុំវិញផ្ទះទាំងមូល ហើយរកក្មេងនោះមិនឃើញទេ។ ដូច្នេះ ពួកគេគិតថាយ៉ូអែលប្រហែលជាលេងបិទពួន ប៉ុន្តែគេរកសព្វកន្លែងម្តងទៀតក៏នៅតែមិនឃើញគាត់។ រំពេចនោះ ធីណាដែលជាម្តាយរបស់ក្មេងក៏បានភិតភ័យជាខ្លាំង។ ចុះនៅអាងទឹកខាងក្រោយ

ផ្ទះ? នាងក៏បានរត់ទៅតាមទ្វារក្រោយជាមួយនឹងក្មួយស្រីអាយុ១៣ឆ្នាំ ឈ្មោះថា យើតនី។ ធីណាភ័យស្លន់ស្លោជាខ្លាំងនៅពេលដែលពួកគេបានឃើញយ៉ូអែលនៅឯបាតអាងទឹក ហើយមិនកម្រើកអ្វីសោះ។ ពុំមាននរណាបានដឹងថា គាត់បានធ្លាក់ទៅក្នុងអាងនោះយូរប៉ុណ្ណាមកហើយទេ។ ធីណាក៏បានស្រែកឲ្យគេទូរស័ព្ទទៅលេខ ៩១១ ហើយនាងក៏លោតចុះទៅក្នុងអាងទឹក និងលើកយ៉ូអែលចេញមកភ្លាម។ គាត់មិនដកដង្ហើមសោះ ព្រមទាំងមានរាងកាយស្លេកស្លាំង គ្មានចលនាអ្វីទាំងអស់។

យុវតីដែលជាក្មួយអាយុ១៣ឆ្នាំនោះ បានចម្រើនវ័យឡើងនៅក្នុងព័ន្ធកិច្ចកុមាររបស់យើង។ នាងបាននិយាយទៅមីងថា «អត់ទេមីងធីណា។ យើងមិនចាំបាច់ទូរស័ព្ទទៅ ៩១១ទេ យើងមានសិទ្ធិអំណាចនៅទីនេះ។ យើងត្រូវអធិស្ឋាន។» ដូច្នេះអ្នកទាំងពីរក៏បានចាប់ផ្ដើមអធិស្ឋាន ប៉ុន្តែនៅតែពុំមានអ្វីកើតឡើង។ ធីណាបានស្រែកម្ដងទៀត «ទូរស័ព្ទទៅ ៩១១!» យុវតីយើតនីក៏និយាយទៅកាន់មីងថា «មីងធីណា យើងត្រូវប្រកាសពីជីវិតទៅកាន់គាត់។» ដូច្នេះ នាងយើតនីក៏បាននិយាយថា «យ៉ូអែល នៅក្នុងព្រះនាមព្រះយេស៊ូ ចូរដឹងខ្លួនឡើង!» ភ្លាមៗនោះយ៉ូអែលក៏ឈ្លក់ទឹកចេញមកក្រៅ ហើយដឹងខ្លួនឡើងវិញ ទាំងមានអាការៈធម្មតាទាំងស្រុង។

នៅពេលដែលខ្ញុំគិតពីរឿងនេះ ខ្ញុំតែងតែស្ញប់ស្ញែងជានិច្ច។ ខ្ញុំមិនមែនស្ញប់ស្ញែងដោយក្មេងប្រុសនោះបានរស់ឡើងវិញទេ ប៉ុន្តែគឺស្ញប់ស្ញែងពីក្មេងស្រីអាយុ ១៣ ឆ្នាំនោះ និងការដែលនាងបានតាំងចិត្តឲ្យស្ងប់ និងមិនបានភ័យស្លន់ស្លោ។ នៅក្នុងស្ថានការណ៍ស្លាប់រស់ នាងអាចគិតឃើញថាពួកគេត្រូវធ្វើអ្វីដោយមិនចុះញមនឹងភាពភ័យខ្លាច។ នាងយើតនីបានបញ្ជាក់ថា ការដែលដឹងពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រតិបត្តិការ គឺសំខាន់លើសពីមេរៀនអធិប្បាយដ៏ពិរោះទៅទៀត។ វាទាក់ទងនឹងការស្លាប់រស់!

ជាថ្មីម្ដងទៀត សូមកត់ចំណាំពីរបៀបដែលច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រតិបត្តិការ។ ដំបូងឡើង យើតនីនិយាយថា ពួកគេត្រូវអធិស្ឋាន ហើយគេក៏បានអធិស្ឋានពិតមែន ប៉ុន្តែពុំមានអ្វីកើតឡើងសោះ។ នេះដោយហេតុថានៅពេលដែល

យើងអធិស្ឋាន យើងមិនបានស្រាយនូវសិទ្ធិអំណាច និងឫទ្ធានុភាពរបស់ព្រះជាម្ចាស់មកទេ។ ប៉ុន្តែ យើងអធិស្ឋានសុំការណែនាំពីទ្រង់។ នោះឯងជាអ្វីដែលពួកគេត្រូវការនៅវិនាទីនោះ។ លោកអ្នកក៏នឹងសម្គាល់នៅក្នុងសាច់រឿងនោះថា យើតនីបាននិយាយថា ពួកគេត្រូវប្រកាសជីវិតទៅកាន់គាត់។ នៅពេលដែលគេធ្វើដូច្នេះ ក្មេងប្រុសនោះក៏បានដឹងខ្លួនឡើង ទាំងមានសុខភាពល្អមកទល់សព្វថ្ងៃ។ ម្តងទៀត យើងឃើញថាពីមនុស្សដែលមានដួងចិត្តជឿជាក់ពីអ្វីដែលស្ថានសួគ៌ប្រកាស ប៉ុន្តែនៅតែពុំមានអ្វីកើតឡើងរហូតដល់សិទ្ធិអំណាចនោះត្រូវបានស្រាយនៅលើភពផែនដី ដោយបុរស ឬស្ត្រីដែលមានជំនឿ។

សូមអនុញ្ញាតឲ្យខ្ញុំប្រាប់រឿងមួយទៀត។ ជារឿងដែលទាក់ទងនឹងក្រុមគ្រួសាររបស់យើង។ បងប្រុសរបស់ឌ្រិនដា បានយកខេនឌីជាភរិយាទៅកាន់មន្ទីរពេទ្យដើម្បីសម្រាលកូនទីប្រាំ។ ឌ្រិនដានិងខ្ញុំក៏បានឆៀងចូលមន្ទីរពេទ្យនៅពេលព្រឹកដែលខេនឌីនៅក្នុងបន្ទប់សម្រាល ដើម្បីស្វាគមន៍សមាជិកថ្មីនៅក្នុងក្រុមគ្រួសារ។ យើងស្មានថាកូននោះបានកើតមកយូរហើយ មុនពេលយើងទៅដល់ទីនោះ ប៉ុន្តែតាមពិតគឺមិនទាន់កើតមកទេ។ នៅពេលដែលយើងដើរចូលទៅផ្នែកសម្រាល ទារកហូលលែនទើបតែត្រូវបាននាំចូលមកកាន់បន្ទប់ថែទាំទារក។ លោកអ្នកប្រហែលជាធ្លាប់បានឃើញបន្ទប់ថែទាំទារកនៅក្នុងមន្ទីរពេទ្យ គឺមានជញ្ជាំង ឬបង្អួចកញ្ចក់ដែលអាចឲ្យលោកអ្នកឃើញទារកដែលទើបនឹងកើតមក នៅពេលដែលពេទ្យបានយកគេមកដាក់នៅទីនោះ។

នៅពេលដែលគេយកទារកហូលលែនចូលមក ខ្ញុំបានសម្គាល់ឃើញថានាងមើលទៅមានសម្បុរស្វាយ។ កូនៗរបស់ចននីសុទ្ធតែមានសម្បុរស្គុះ និងសក់ពណ៌ទង់ដែង។ ដំបូងឡើង ខ្ញុំគិតថាទារិកានោះមានសម្បុរស្វាយ ប្រហែលជារឿងធម្មតាសម្រាប់ក្មេងកាលដែលកើតមក។ ប៉ុន្តែ មែនហើយ ទារិកានោះមើលទៅដូចជាមិនប្រក្រតីទេ។ ភ្លាមៗនោះ គ្រូពេទ្យក៏បានចាប់ផ្តើមរត់ឆ្លេឆ្លាចុះឡើង។ គិលានុបដ្ឋាកយិកាក៏បានទាញវាំងននបិទ ដើម្បីកុំឲ្យខ្ញុំមើលឃើញទៀត ហើយខ្ញុំដឹងថាវាជា

សញ្ញាមិនល្អទេ។ ទោះបីជាវាំងននបិទ ក៏មានប្រឡោះវាំងននដែលខ្ញុំអាចមើលឃើញថាមានអ្វីកំពុងកើតឡើងនៅក្នុងបន្ទប់នោះ។ ក្រុមគិលានុបដ្ឋាកយិកាក៏បានចាប់ផ្តើមយកឧបករណ៍ ហើយវេជ្ជបណ្ឌិតបានចាប់ផ្តើមធ្វើចលនាបេះដូងនៅលើហូលលែន។ ខ្ញុំបានដើរទៅទ្វារម្ខាងទៀតនៃបន្ទប់ថែទាំទារក ដើម្បីស្តាប់ឮឲ្យបានច្បាស់ពីអ្វីដែលគ្រូពេទ្យនិយាយ។ នៅពេលដែលខ្ញុំស្តាប់ ខ្ញុំក៏មានការភ្ញាក់ផ្អើលជាខ្លាំងព្រោះខ្ញុំបានឮពួកគេនិយាយថា ទារិកានោះពុំមានចង្វាក់បេះដូង ហើយពួកគេមិនអាចធ្វើចលនាឲ្យបេះដូងលោតបានឡើយ។ ខ្ញុំក៏ស្តាប់បន្តទៀត ហើយឮឧបករណ៍វាស់ជីពចរលោតម្តងម្កាល។ ខ្ញុំបានឮវាលោតម្តងៗនៅចន្លោះពី ១៥ ទៅ ២០ វិនាទី។ បេះដូងរបស់ទារិកាហូលលែនមិនដើរឡើយ។

**ចាំថា ច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការគ្រប់ពេលវេលាសម្រាប់មនុស្សគ្រប់គ្នា!**

គ្រូពេទ្យបានដើរចេញពីបន្ទប់ ហើយសំដៅទៅរកចននី «ចននី ស្ថានភាពហាក់ដូចជាមិនប្រសើរទេ។ ខ្ញុំសុំទោសផង ប៉ុន្តែយើងកំពុងតែព្យាយាម។» យើងមិនត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងបន្ទប់ថែទាំទារក ដូច្នេះឌ្រិនដានិងចននីបានដាក់ដៃនៅលើទ្វារនៅផ្នែកម្ខាងនៃបន្ទប់ថែទាំទារក ហើយខ្ញុំក៏បានដាក់ដៃលើទ្វារនៅម្ខាងទៀតនៃបន្ទប់ដែរ។ យើងបានចាប់ផ្តើមអធិស្ឋាន និងប្រកាសថាហូលលែននឹងរស់នៅ ហើយមិនស្លាប់ទេ។ នាងនឹងមានសុខភាពល្អ។ យើងបានបញ្ជាបេះដូងឲ្យដើរ នៅក្នុងព្រះនាមព្រះយេស៊ូ។

ភ្លាមៗនោះ គ្រូពេទ្យដែលបាននិយាយជាមួយចននីបានចេញពីបន្ទប់ថែទាំទារកដោយប្រញាប់ប្រញាល់។ គាត់បានរត់កាត់យើង ដោយមិននិយាយស្តីមួយម៉ាត់សោះ។ បីរបីនាទីក្រោយមក គាត់ក៏ប្រញាប់ប្រញាល់មកវិញជាមួយនឹងគិលានុបដ្ឋាកយិកាម្នាក់ដើរតាមក្រោយគាត់ ទាំងនិយាយឮៗថា «ឌុកទ័រ យើងមិនអាចធ្វើអញ្ចឹងបានទេ។ យើងមិនមានច្បាប់អនុញ្ញាតឲ្យធ្វើតាមប្រតិបត្តិការវេជ្ជសាស្ត្រនេះ

នៅឯមន្ទីរពេទ្យនេះបានទេ។ ខ្ញុំមិនអាចធ្វើតាមលោកគ្រូ ដើម្បីជួសឈាមនោះទេ។» គាត់មិនបានខ្វល់ពីនាងសោះ នៅពេលដែលគាត់ដើរចូលមកកាន់បន្ទប់ថែទាំទារកវិញ។ គាត់បានយកសៀវភៅណែនាំមួយមកអាន ហើយយើងអាចឃើញថាគាត់កំពុងធ្វើការសិក្សាក្នុងការធ្វើប្រតិបត្តិការវេជ្ជសាស្ត្រ។ នៅពេលនេះ ខ្ញុំក៏បានមើលតាមប្រឡោះវាំងនន នៅពេលដែលគាត់បានក្រោកឈរឡើង ហើយចាប់ផ្តើមស៊កទុយោវែងមួយចូលទៅក្នុងខ្លួនទារិកា។ នៅពេលនេះ ខ្ញុំបានយល់ថាគាត់កំពុងតែផ្តល់ឈាមដល់ទារក។

ភ្លាមៗនោះ ខ្ញុំបានឮសំឡេងបេះដូងលោតឡើង។ ល្បឿនវាបានកើតឡើងរហូតដល់កម្រិតមួយដែលក្មេងទើបនឹងកើតមាន។ រំពេចនោះ គ្រូពេទ្យក៏បានចេញមកក្រៅបន្ទប់ហើយថា «មានទេវតានៅក្នុងបន្ទប់នោះជាមួយយើង។ ព្រះជាម្ចាស់បានជួយខ្ញុំជាមួយនឹងទារកនេះ!» យើងអាចឃើញថាគាត់កំពុងតែញ័រខ្លួនប្រាណ។ បន្ទាប់មកយើងក៏បានរកឃើញថា ពេលនោះមិនមែនជាពេលដែលគាត់ត្រូវនៅប្រចាំការ ហើយគាត់ក៏បានរួមចំណែកក្នុងការសម្រាលរបស់ខេនឌីដែរ។ គាត់គ្រាន់តែឆៀងចូលមន្ទីរពេទ្យ ដើម្បីមើលអ្នកជំងឺម្នាក់ទៀត នៅពេលដែលរឿងទាំងនេះកើតឡើង។ ខ្ញុំអាចប្រាប់បានថា គ្រូពេទ្យនៅតែភ្ញាក់ផ្អើលពីអ្វីដែលបានកើតឡើង នៅពេលដែលគាត់បានប្រាប់យើងថាទារិកាហ្វូលលែនមិនបានមានចង្វាក់បេះដូងអស់រយៈពេល ៣៦ នាទី!

នៅសព្វថ្ងៃនេះ កុមារីហ្វូលលែនមានអាយុ៤ឆ្នាំ ហើយមានសុខភាពល្អជាធម្មតា។ ខ្ញុំជឿថា វាជាការដែលយើងយល់ពីច្បាប់ខាងវិញ្ញាណដែលបាននាំដំណោះស្រាយមកកាន់ស្ថានការណ៍នោះ។ ខ្ញុំនៅតែចាំជាប់ក្នុងចិត្តពេលដែលខ្ញុំបានដាក់ដៃនៅលើទ្វារបន្ទប់ថែទាំទារក ទាំងគិតក្នុងចិត្តថា «យើងនឹងមិនមានបុណ្យសពសម្រាប់ក្មួយស្រីតូចរបស់ខ្រិនដាជាដាច់ខាត! គឺវាមិនអាចកើតឡើងបានទេ!»

នៅពេលដែលយើងឈប់សិន ហើយគិតពិចារណាពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់បានប៉ះពាល់ដល់សាច់រឿងនីមួយៗដែលខ្ញុំទើបតែបានចែករំលែក

ខ្ញុំចង់ឲ្យលោកអ្នកចាំថា ច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការគ្រប់ពេលវេលា សម្រាប់មនុស្សគ្រប់គ្នា! ដូចដែលខ្ញុំបាននិយាយនៅខាងដើមនៃសៀវភៅនេះ ច្បាប់ធម្មជាតិនៅលើផែនដីដំណើរការដោយលទ្ធផលដដែលនៅគ្រប់ពេលវេលា។ វាមិនលម្អៀង ហើយនឹងមានប្រសិទ្ធិភាពសម្រាប់មនុស្សគ្រប់គ្នាដែលចំណាយពេលរៀនពីវា និងអនុវត្តវា។ អគ្គិសនីដំណើរការដូចគ្នា ទាំងនៅសហរដ្ឋអាមេរិក និងទ្វីបអាហ្វ្រិក។ វាមិនប្រែប្រួលឡើយ។

នៅពេលដែលខ្ញុំចាប់ផ្តើមយល់ថាព្រះរាជ្យរបស់ព្រះជាម្ចាស់ ជាព្រះរាជ្យមួយដែលមានច្បាប់ច្បាស់លាស់។ ថ្វីបើច្បាប់នោះត្រូវបានលាក់កំបាំងក្តី ក៏ខ្ញុំបានដឹងថាខ្ញុំបានរកឃើញចម្លើយសម្រាប់បញ្ហារបស់ខ្ញុំ។ ខ្ញុំបានទទួលស្គាល់ថា មិនមែនជាព្រះជាម្ចាស់ដែលបានលាក់បាំងពីខ្ញុំ ហើយជ្រើសរើសមិនប្រទានពរខ្ញុំ ឬជួយខ្ញុំនៅពេលជួបទុក្ខលំបាកទេ។ អត់ទេ គឺនៅពេលនេះខ្ញុំដឹងថា ព្រះជាម្ចាស់បានប្រទានអ្វីៗគ្រប់យ៉ាងដែលខ្ញុំត្រូវការនៅក្នុងជីវិតនេះមកដល់ខ្ញុំ តាមរយៈព្រះយេស៊ូគ្រិស្តដែលតាមរយៈការបូជាព្រះជន្មរបស់ទ្រង់បានឲ្យខ្ញុំមានសិទ្ធិចូលទៅកាន់អ្វីៗទាំងប៉ុន្មានដែលស្ថានសួគ៌មាន។ នៅពេលនេះ ខ្ញុំយល់ថាព្រះរាជ្យដំណើរការដោយច្បាប់ជាក់លាក់ ដែលខ្ញុំអាចរៀនបាន និងអនុវត្តវាមកកាន់ជីវិតនេះ។

ខ្ញុំបានចាប់ផ្តើមអានសាច់រឿងទាំងប៉ុន្មាននៅក្នុងព្រះគម្ពីរ ជាមួយនឹងផ្នត់គំនិតខុសប្លែកពីមុនទាំងស្រុង ដោយរកមើលតម្រុយដែលបើកសម្តែងពីច្បាប់ដទៃទៀតនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។ ខ្ញុំបានប្តេជ្ញាខ្លួនឯងក្នុងការធ្វើជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ ដើម្បីឲ្យខ្ញុំអាចរៀនបានថាហេតុអ្វីមានកិច្ចការជាក់លាក់កើតឡើងនៅក្នុងព្រះគម្ពីរ ដែលខ្ញុំបានអានជាញឹកញាប់នេះ។ អត្ថបទគម្ពីរនៅក្នុងគម្ពីរ ១យ៉ូហាននេះ ស្តាប់ទៅដូចជាកំប្លែង និងចម្លែកសម្រាប់មនុស្សជាច្រើន។ ខ្ញុំដឹងថាយើងបានអានពីមុនមកហើយ ប៉ុន្តែចូរអានម្តងទៀតដោយសារវាបញ្ជាក់ពីសេចក្តីពិតដែលជាចម្លើយរបស់អ្នក។

*ហេតុនេះហើយបានជាយើងមានចិត្តរឹងប៉ឹងនៅចំពោះព្រះភ័ក្ត្រព្រះអង្គ គឺថា ប្រសិនបើយើងទូលសូមអ្វីស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះទ្រង់នឹងព្រះសណ្ដាប់យើងជាមិនខាន។ បើយើងដឹងថា ព្រះអង្គទ្រង់ព្រះសណ្ដាប់យើង ទោះបីយើងទូលសូមអ្វីពីព្រះអង្គក៏ដោយ យើងដឹងថា យើងបានទទួលអ្វីៗដែលយើងទូលសូមនោះរួចហើយ។*

១យ៉ូហាន ៥៖១៤-១៥

ខ្ញុំពេញចិត្តនឹងអត្ថបទគម្ពីរនេះ ព្រោះអត្ថបទគម្ពីរនេះនិយាយអំពីច្បាប់ ហើយច្បាប់ផ្ដល់ឲ្យយើងមានចិត្តរឹងប៉ឹងដើម្បីទទួលបានយុត្តិធម៌។ នេះជាចិត្តរឹងប៉ឹងរបស់យើង គឺប្រសិនបើយើងទូលសុំអ្វីដោយយោងទៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ (ច្បាប់ ឬអ្វីដែលព្រះជាម្ចាស់ហៅថាត្រឹមត្រូវ) នោះទ្រង់នឹងព្រះសណ្ដាប់យើងជាមិនខាន។ ម្ដងទៀតពាក្យថា «ព្រះសណ្ដាប់យើង» នេះ មិនសំដៅលើការដែលព្រះជាម្ចាស់គ្រាន់តែឮសំឡេងរបស់យើងទេ ទោះបីជាទ្រង់ពិតជាស្ដាប់ឮយើងមែនក្ដី។ ប៉ុន្តែជាងនេះទៅទៀត វាសំដៅលើការដែលព្រះជាម្ចាស់ធ្វើការកាត់ក្ដី។ ប្រសិនបើយើងគិតអំពីចៅក្រមដែលធ្វើការកាត់ក្ដី ហើយគ្រប់គ្រងតាមច្បាប់ គឺមិនមែនតាមអារម្មណ៍របស់គាត់ (យ៉ាងហោចណាស់ នេះជាអ្វីដែលគួរតែកើតឡើង) នោះលោកអ្នកនឹងយល់អត្ថបទគម្ពីរនេះ។ ទ្រង់ស្ដាប់ឮយើង ទ្រង់ធ្វើការកាត់ក្ដី ឬស្ដាប់ឮពីរឿងក្ដីរបស់យើង ហើយយើងអាចមានទំនុកចិត្តថាយើងនឹងទទួលបានយុត្តិធម៌ ជាអ្វីដែលជារបស់យើងស្របច្បាប់។

មិត្តសម្លាញ់អើយ ខ្ញុំគិតថាលោកអ្នកពិតជាត្រូវឈប់សិន ហើយអានម្ដងទៀតសន្សឹមៗ។ ប្រសិនបើអ្វីដែលលោកអ្នកទើបតែបានអានជាការពិត ហើយវាជាការពិតមែន នោះជីវិតរបស់លោកអ្នកនឹងមានពេញទៅដោយអំណរ! មនុស្សដែលអធិស្ឋាន ទាំងពុំបានដឹងពីសេចក្ដីនេះពុំមានទំនុកចិត្តអ្វីឡើយ គឺពួកគេគ្រាន់តែ

និយាយប៉ប៉ាច់ប៉ប៉ោចនៅពេលអធិស្ឋានប៉ុណ្ណោះ។ ព្រះយេស៊ូបានមានបន្ទូលពីសេចក្តីនោះនៅក្នុងគម្ពីរម៉ាថាយ ៦៖៧-១៣៖

> *ពេលទូលទៅព្រះបិតា កុំពោលពាក្យច្រំដែលៗឥតប្រយោជន៍ ដូចសាសន៍ដទៃនោះឡើយ។ គេនឹកស្មានថា បើពោលពាក្យយ៉ាងច្រើនដូច្នេះ ព្រះរបស់គេនឹងស្តាប់គេ។*

ពាក្យថា «ច្រំដែលឥតប្រយោជន៍» សំដៅលើការនិយាយពាក្យ ឬបញ្ចេញសំឡេងដដែលៗគ្មានន័យអ្វីសោះ។ នេះជារបៀបដែលមនុស្សភាគច្រើនអធិស្ឋាន។ ពួកគេមិនដឹងសោះអំពីសិទ្ធិដែលខ្លួនអាចចូលទៅកាន់យុត្តិធម៌ ឬសូម្បីតែអ្វីដែលព្រះជាម្ចាស់បានប្រទានដល់ពួកគេដោយស្របច្បាប់នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។ លោកអ្នកមិនចាំបាច់ត្រូវអង្វរ ឬស្រែកសុំអ្វីមួយដែលលោកអ្នកមានរួចហើយនោះទេ!

ឧបមាថាមានមន្ត្រីនគរបាលម្នាក់កំពុងឈរនៅតាមផ្លូវ ហើយបញ្ជាឲ្យឡានដឹកទំនិញមួយឈប់។ គាត់ស្រាប់តែស្រែកឡើង និងអង្វរឡានឲ្យឈប់។ «សូមអង្វរ អ្នកបើកឡាន ឈប់ទៅ។ សូមមេត្តាខ្ញុំផង។ ខ្ញុំសូមអង្វរ សូមឈប់សិនទៅ។» នោះនឹងជាការប្រមាថមាក់ងាយ និងការចម្អន់ទៅដល់សហរដ្ឋអាមេរិក និងប្រព័ន្ធច្បាប់ទាំងមូល។ អត់ទេ មន្ត្រីនគរបាលនោះនឹងក្រោកឈរឡើង ទាំងពើងទ្រូង ហើយបង្គាប់ឡានឲ្យឈប់ ហើយឡាននឹងឈប់ដោយផ្អែកលើច្បាប់របស់ប្រទេស និងមុខតំណែងរបស់គាត់ក្នុងនាមជាមន្ត្រីតំណាងឲ្យរដ្ឋាភិបាលរបស់ប្រទេសទាំងមូល។

មនុស្សដែលអង្វរព្រះជាម្ចាស់ជាអ្នកដែលមិនស្គាល់ពីច្បាប់របស់ព្រះរាជ្យ ឬមុខតំណែងរបស់គេទេ។ ហេតុផលដែលមន្ត្រីនគរបាលអង្វរឡានឲ្យឈប់ជាការ

ប្រមាថដ៏ធំសម្បើមទៅដល់ប្រទេសទាំងមូល គឺព្រោះថាទង្វើបែបនោះបង្ហាញថា ប្រទេសនេះគ្មានច្បាប់ទម្លាប់ និងសិទ្ធិអំណាចជាក់លាក់ទេ។ នៅក្នុងប្រទេសបែបនេះ អ្វីដែលលោកអ្នកមានគឺភាពអាណាធិបតេយ្យប៉ុណ្ណោះ។ នៅពេលដែលគ្រិស្តបរិស័ទអង្វរ និងប្រព្រឹត្តដោយសកម្មភាពបែបនេះ វាបង្ហាញថាព្រះរាជ្យរបស់ព្រះជាម្ចាស់ជារាជ្យដែលទន់ខ្សោយ និងពុំអាចផ្តល់ដំណោះស្រាយអ្វីឡើយ។ វានាំឲ្យមនុស្សសង្ស័យពីឆន្ទៈរបស់ព្រះជាម្ចាស់ ឬសមត្ថភាពរបស់ទ្រង់ក្នុងការជួយពួកគេ ដែលតាមពិតពួកគេមានសិទ្ធិធ្វើអ្វីដែលពួកគេកំពុងតែសុំនោះ។ ព្រះយេស៊ូបានប្រទានចម្លើយយ៉ាងច្បាស់លាស់ដល់យើងទាក់ទងនឹងពាក្យអធិស្ឋានបែបសុំទាន និងរាក់កំផែលនេះគឺ **«ឈប់ធ្វើអញ្ចឹងទៀត!»**

*ពេលទូលទៅព្រះបិតា កុំពោលពាក្យច្រំដែលៗឥតប្រយោជន៍ ដូចសាសន៍ដទៃនោះឡើយ។ គេនឹកស្មានថា បើពោលពាក្យយ៉ាងច្រើនដូច្នេះ ព្រះរបស់គេនឹងស្ដាប់គេ។ កុំធ្វើដូចគេឡើយ ដ្បិតព្រះបិតារបស់អ្នករាល់គ្នាជ្រាបនូវអ្វីៗដែលអ្នករាល់គ្នាត្រូវការ មុនអ្នករាល់គ្នាទូលសូមព្រះអង្គទៅទៀត។ អ្នករាល់គ្នាត្រូវទូលព្រះអង្គដូចតទៅ:*

*ឱព្រះបិតានៃយើងខ្ញុំដែលគង់នៅស្ថានបរមសុខអើយ! សូមសម្ដែងព្រះនាមដ៏វិសុទ្ធរបស់ព្រះអង្គឲ្យមនុស្សលោកស្គាល់ សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់ សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ។ សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។ សូមអត់ទោសឲ្យយើងខ្ញុំដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នកដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។ សូមកុំបណ្ដោយឲ្យយើងខ្ញុំចាញ់ការល្បួងឡើយ តែសូមរំដោះយើងខ្ញុំឲ្យរួចពីមារកំណាច [ដ្បិតព្រះអង្គគ្រងរាជ្យ ទ្រង់មានឫទ្ធានុភាព និងសិរីរុងរឿងអស់កល្បជាអង្វែងតរៀងទៅ។ អាម៉ែន។]*

ម៉ាថាយ ៦:៧-១៣ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

សូមចាំថា ព្រះយេស៊ូកំពុងតែបង្រៀនយើងពីរបៀបអធិស្ឋាននៅក្នុងខនេះ។ គួរឲ្យសោកស្តាយ មនុស្សជាច្រើនបែរជាបានត្រឹមតែយកព្រះបន្ទូលនេះទៅដាក់តាំងលម្អនៅក្នុងផ្ទះ តែមិនបានយល់ពីអត្ថន័យនៃខទាំងនេះទេ។ អត្ថបទគម្ពីរហៅថា សេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់ ប៉ុន្តែទ្រង់កំពុងតែបង្រៀនសិស្សរបស់ទ្រង់ពីរបៀបអធិស្ឋានដោយព្រះបន្ទូលទាំងនេះ។ ទ្រង់មិនអធិស្ឋានតាមគ្រប់ពាក្យ គ្រប់ម៉ាត់ដូចដែលយើងធ្វើនៅក្នុងក្រុមជំនុំទេ។ ព្រះបន្ទូលទាំងនេះប្រៀបបាននឹងមគ្គុទ្ទេសក៍ណែនាំ។ វាជារបៀបដែលអធិស្ឋាន និងទទួលបានលទ្ធផល ហើយពុំមែនជាខគម្ពីរចងចាំដើម្បីឲ្យយើងសូត្រនោះទេ។

*«សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់ សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ»* ជាសេចក្តីណែនាំពីរបៀបអធិស្ឋាន។ យើងត្រូវអធិស្ឋានដោយពាំនាំនូវព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលមាននៅស្ថានសួគ៌ចូលមកកាន់ផែនដី និងស្ថានការណ៍របស់យើង។ ដូច្នេះ តើអ្វីទៅជាដំណោះស្រាយរបស់លោកអ្នក? គឺជឿថាអ្វីដែលព្រះជាម្ចាស់មានបន្ទូលជារបស់លោកអ្នក ហើយប្រើប្រាស់សិទ្ធិអំណាចរបស់លោកអ្នកនៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ ដើម្បីនាំស្ថានសួគ៌ចូលមកកាន់ផែនដី និងផ្គត់ផ្គង់នូវរាល់ទាំងសេចក្តីត្រូវការរបស់លោកអ្នក និងអ្នកដែលនៅជុំវិញខ្លួនលោកអ្នក។

ដូច្នេះ សូមផ្អាកមួយភ្លែត ហើយគិតពីសេចក្តីនេះ។ ប្រសិនបើលោកអ្នកដឹងដោយឥតសង្ស័យសោះថា សេចក្តីអធិស្ឋានរបស់លោកអ្នកមានប្រសិទ្ធភាព ហើយស្ថានសួគ៌ក៏គាំទ្រដែរនោះ តើវានឹងធ្វើឲ្យលោកអ្នកមានទំនុកចិត្តនៅពេលអធិស្ឋានដែរឬទេ? **មែនហើយ**!!! ដោយការដែលដឹងជាក់ច្បាស់ថា លោកអ្នកមានសិទ្ធិស្របច្បាប់អ្វីខ្លះ ក្នុងនាមជាពលរដ្ឋនៃស្ថានបរមសុខ និងការដឹងថាព្រះអង្គបានប្រទានអ្វីខ្លះមកកាន់លោកអ្នកដោយឥតគិតថ្លៃ ព្រមទាំងយល់ពីដំណើរការនៃការទទួល និងរីករាយជាមួយនឹងប្រយោជន៍នៃច្បាប់ទាំងនោះ លោកអ្នកអាចរស់នៅក្នុងរបៀបរស់

នៅមួយដ៏ថ្លៃសន្លាង គឺតាមរបៀបបែបព្រះរាជ្យរបស់ព្រះជាម្ចាស់។ តើនឹងមានអ្វីកើតឡើងចំពោះភាពភ័យខ្លាច? តើមានអ្វីកើតឡើងចំពោះភាពមិនច្បាស់លាស់? តើចំណេះដឹងបែបនោះជំរុញលោកអ្នកឲ្យមានទំនុកចិត្តចំពោះអនាគត និងទំនុកចិត្តនៅពេលជួបទុក្ខលំបាកយ៉ាងណាខ្លះ? នេះជាឥទ្ធិពលដែលព្រះរាជ្យរបស់ព្រះមាននៅលើខ្រិនដានិងខ្ញុំនៅពេលដែលយើងចាប់ផ្តើមរកឃើញ។ ជាញឹកញាប់ យើងស្ញប់ស្ញែងនឹងអ្វីដែលយើងបានឃើញ។ អត់ទេ សូមអនុញ្ញាតឲ្យខ្ញុំនិយាយបែបផ្សេង។ យើងតែងតែភ្ញាក់ផ្អើល និងស្ញប់ស្ញែងជានិច្ច! បន្ថែមពីលើនោះទៅទៀត យើងស្ញប់ស្ញែងនឹងសិទ្ធិអំណាចដែលព្រះជាម្ចាស់បានប្រទានដល់ក្រុមជំនុំ ដើម្បីបំពេញមុខងារតំណាងឲ្យ និងតាមរយៈរដ្ឋាភិបាលរបស់ទ្រង់នៅលើភពផែនដីនេះ។

> *ដ្បិត**វិន័យ**របស់ព្រះវិញ្ញាណដែលផ្តល់ជីវិតក្នុងអង្គព្រះគ្រិស្តយេស៊ូ បានរំដោះខ្ញុំឲ្យរួចផុតពីបាប និងពីសេចក្តីស្លាប់។*
>
> រ៉ូម ៨៖២ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

ការដែលបានរកឃើញថាយើងមានសេរីភាពពី «វិន័យ ឬច្បាប់នៃអំពើបាប និងសេចក្តីស្លាប់» និងបានទទួលនូវព្រះរាជ្យ និងសិទ្ធិដើម្បីចូលទៅកាន់ «ច្បាប់នៃព្រះវិញ្ញាណនៃជីវិត» ជារឿងដ៏រំភើបណាស់។ ជាថ្មីម្តងទៀត វាធ្វើឲ្យយើងកាន់តែរំភើបពិបាកនឹងថ្លែងនៅពេលដែលឃើញច្បាប់នោះបង្កើតនូវសេចក្តីសុចរិតនៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង។

ព្រះរាជ្យបានអនុញ្ញាតឲ្យខ្ញុំទទួលការប្រោសឲ្យជានៅលើរូបរាងកាយ ក៏ដូចជាផ្នែកផ្លូវចិត្តដែលខ្ញុំអាចចូលទៅកាន់សេចក្តីសង្ឃឹមថ្មីមួយ និងមានសេរីភាពពីថ្នាំបន្ថយទុក្ខព្រួយ។ វាបានអនុញ្ញាតឲ្យខ្ញុំចាកចេញពីភាពក្រីក្រ ដែលរកប្រាក់សឹងតែមិនបាន៣០០ដុល្លារក្នុងមួយខែដើម្បីបង់ថ្លៃឈ្នួលផ្ទះកសិដ្ឋានមួយដែលសង់នៅ

ឆ្នាំ ១៨០០ រហូតដល់អាចសង់ផ្ទះដ៏ស្រស់ស្អាតដែលមានផ្ទៃ ២៣៥០ ម៉ែត្រការ៉េនៅលើផ្ទៃដី ២៤ ហិកតា។ ភរិយារបស់ខ្ញុំក៏កាន់តែពេញចិត្តនឹងខ្ញុំខ្លាំងជាងមុនដែរ! ការដែលអាចជិះរថយន្តដែលមិនខូចសឹងតែរាល់ថ្ងៃជារឿងមួយដែលរំភើបណាស់។ ការដែលអាចថ្វាយប្រាក់រាប់សែនដុល្លារទៅកាន់ដំណឹងល្អជារឿងមួយដែលខ្ញុំមិនដែលនឹកស្មានដល់សោះ នៅពេលប៉ុន្មានឆ្នាំមុន។ ជីវិត និងពន្លឺនៃព្រះរាជ្យបានលេបត្របាក់ភាពងងឹត ហើយដូចដែលព្រះជាម្ចាស់មានបន្ទូលនៅក្នុងគម្ពីរលោកុប្បត្តិពេលដែលទ្រង់ទតមើលស្នាព្រះហស្តរបស់ទ្រង់ថា «ល្អប្រសើរហើយ» ខ្ញុំក៏បានមើល ទាំងកោតស្ញប់ស្ញែងថា «ល្អប្រសើរហើយ គឺល្អប្រសើរណាស់!»

ឌ្រិនដានិងខ្ញុំរំភើបណាស់រហូតដល់យើងប្រាប់មនុស្សគ្រប់គ្នាដែលស្តាប់យើងចែករំលែកអំពីព្រះរាជ្យ ព្រមទាំងប្រាប់ពួកគេអំពីសាច់រឿងរបស់យើងផង។ មនុស្សនៅក្នុងក្រុមជំនុំរបស់យើងក៏បានយល់ និងទទួលបានលទ្ធផលដូចជាយើងដែរ ហើយម្នាក់ក្នុងចំណោមពួកគេជាកូនស្រីអាយុ១២ឆ្នាំរបស់យើង។ នាងបានឃើញព្រះជាម្ចាស់ធ្វើកិច្ចការជាច្រើន ហើយក៏បានធ្វើសក្ខីភាពពីមួយពេលទៅមួយពេលអំពីច្បាប់ដែលមិនចេះសាបសូន្យដែលព្រះរាជ្យរបស់ព្រះជាម្ចាស់បង្កើតជាផលផ្លែនៅក្នុងជីវិតរបស់យើង។ ខ្ញុំដឹងថានាងបានមើល និងរៀនអំពីច្បាប់ទាំងនេះ ប៉ុន្តែមានរឿងមួយដែលបានបង្ហាញខ្ញុំថានាងពិតជាបានយល់ពីព្រះរាជ្យច្រើនយ៉ាងណា។

មានយប់មួយ ខ្ញុំបានចូលទៅក្នុងបន្ទប់របស់នាង ដើម្បីនិយាយថារាត្រីសួស្តី ហើយមានអ្វីម្យ៉ាងខុសប្លែកពីធម្មតា។ នៅលើជញ្ជាំងក្នុងបន្ទប់របស់នាង មានព្យួររូបថតឆ្កែពាមក្រាស់ពូជផូមេរ៉ានៀន (Pomeranian) មួយសន្លឹក។ នៅត្រង់នេះសម្រាប់លោកអ្នកជាឪពុកម្តាយ រូបថតបែបនេះជាសញ្ញាបង្ហាញយ៉ាងច្បាស់ត្រដែតថា កូននឹងសុំឆ្កែពីយើង។ មែនហើយ ខ្ញុំបានសម្រេចចិត្តថារារាំងមិនឲ្យការនេះកើតឡើង ព្រោះខ្ញុំមិនចង់បានឆ្កែមួយទៀតនៅក្នុងផ្ទះទេ។ ផល្លីជាបងស្រីរបស់យើស្មែន

មានឆ្កែមួយក្បាលនៅក្នុងផ្ទះហើយ ហើយពួកគេគេងនៅក្នុងបន្ទប់ជាមួយគ្នា ដូច្នេះ ឆ្កែរបស់ផល្លីតែងតែនៅក្នុងបន្ទប់ជាមួយផល្លី និងឃើស្ទែន។

ខ្ញុំបាននិយាយទៅកាន់ឃើស្ទែនដោយសុភាពថា ខ្ញុំចូលចិត្តរូបថតឆ្កែនោះ ប៉ុន្តែខ្ញុំមិនចង់បានឆ្កែក្នុងផ្ទះមួយទៀតឡើយ។ ប្រសិនបើនាងចង់ចិញ្ចឹមឆ្កែ នាងគួរចំណាយពេលជួយចិញ្ចឹមដាច់សាន់ដែលជាឆ្កែរបស់បងស្រីនាង។ នៅយប់នោះ ឃើស្ទែនមិនបាននិយាយអ្វីទេ គឺគ្រាន់តែទទួលនូវអ្វីដែលខ្ញុំបាននិយាយប៉ុណ្ណោះ។ ខ្ញុំស្មានថារឿងនោះចប់ត្រឹមហ្នឹងហើយ ប៉ុន្តែបន្ទាប់ពីយប់នោះមកនាងបាននិយាយពីរបីដង ដូចជាថា «តើវាល្អយ៉ាងណា បើយើងមានឆ្កែរោមក្រាស់?» ឬ «ឆ្កែនោះមានរោមក្រាស់ ទន់ល្អណាស់។» ហើយជាការពិតណាស់ ឃើស្ទែនក៏នឹងយករូបថតឆ្កែដែលនាងឃើញពីអ៊ីនធើណិតមកបង្ហាញខ្ញុំ។ នៅលើកនេះទៀត ខ្ញុំគ្រាន់តែនិយាយថា «ទេ»។ ខ្ញុំជាមេគ្រួសារ ហើយយើងនឹងមិនចិញ្ចឹមឆ្កែមួយទៀតនៅក្នុងផ្ទះឡើយ។

នៅលើកនេះទៀត ខ្ញុំក៏គិតថារឿងនោះចប់ហើយ រហូតជាងមួយខែក្រោយមក មានថ្ងៃមួយពេលដែលយើងចេញពីក្រុមជំនុំមកដល់ផ្ទះវិញ ឃើស្ទែនបានដើរទាំងរឹងប៉ឹងមករកខ្ញុំ ទាំងញញឹមហើយថា «ប៉ា នៅថ្ងៃនេះខ្ញុំបានឆ្កែរោមក្រាស់មួយ ដោយជំនឿដូចដែលប៉ាបានបង្រៀនអញ្ចឹង។» ខ្ញុំបានរំឭកនាងម្តងទៀតពីពាក្យដែលខ្ញុំបានប្រាប់នាងលើកមុនអំពីការដែលចិញ្ចឹមឆ្កែមួយក្បាលទៀត។ ដោយនៅតែញញឹម នាងពោលឡើងថា «ប៉ុន្តែប៉ា ម៉ាក់និយាយថាព្រះជាម្ចាស់អាចផ្លាស់ប្តូរចិត្តរបស់ស្តេចបាន។» ពាក្យដែលនាងនិយាយប្រាប់ខ្ញុំមិនមែនចេញពីការបះបោរទេ។ នាងគ្រាន់តែយល់ស្របជាមួយម្តាយ ហើយអធិស្ឋានថាព្រះជាម្ចាស់នឹងផ្លាស់ប្រែចិត្តរបស់ខ្ញុំ។ ខ្ញុំមិនដែលដឹងសោះថា តាមពិតម្តាយរបស់នាងនិងនាងបាននិយាយគ្នា ហើយម្តាយរបស់នាងបានលើកទឹកចិត្តនាងថា ព្រះជាម្ចាស់ពិតជាអាចផ្លាស់ប្តូរចិត្តខ្ញុំបាន។

ដោយផ្អែកលើការលើកទឹកចិត្តនោះ នាងបានស្រាយជំនឿរបស់នាងនៅក្រុមជំនុំឯព្រឹកថ្ងៃអាទិត្យនោះ ដោយសាបព្រោះ និងប្រកាសថានាងបានទទួលឆ្កែនោះ

ដោយជំនឿ។ ខ្ញុំក៏បានប្រកាន់ជំហរ ហើយបញ្ជាក់ដល់នាងពីសេចក្តីស្រឡាញ់របស់ខ្ញុំជាឪពុក ព្រមទាំងជជែកវែកញែក និងប្រាប់ដល់នាងថា «យើងនឹងមិនយកឆ្កែមួយទៀតមកចិញ្ចឹមនៅក្នុងផ្ទះទេ។» ខ្ញុំនិយាយថា ខ្ញុំសុំទោស ប៉ុន្តែវានឹងមិនកើតឡើងទ្បើយ។ នាងហាក់ដូចជាមិនខ្វល់ពីអ្វីដែលខ្ញុំបាននិយាយ ហើយដើរចេញបាត់ទៅទាំងញញឹម។ នៅលើកនេះទៀត ខ្ញុំក៏គិតថាបញ្ហានេះចប់សព្វគ្រប់ហើយ។

ប៉ុន្តែ ប្រហែលជាមួយខែក្រោយមក ខ្ញុំត្រូវបានអញ្ជើញឲ្យទៅបង្រៀននៅក្រុមជំនុំតូចមួយនៅរដ្ឋមីស៊ីស៊ីពី (Mississippi)។ ក្រុមជំនុំនោះជាក្រុមជំនុំតូចនៅទីជនបទ ដែលមានដីវាលរាប់សិបគីឡូម៉ែត្រនៅជុំវិញ។ នៅពេលចប់ការប្រជុំល្ងាចទីមួយ គ្រូគង្វាលបានដើរមករកខ្ញុំហើយប្រាប់ថា ព្រះអម្ចាស់បានមានបន្ទូលទៅដល់គាត់នៅពេលកំពុងប្រជុំក្រុមជំនុំ។ គាត់ពោលថា «ខ្ញុំមិនដឹងថា លោកគ្រូដឹងរឿងនេះដែរឬទេ ប៉ុន្តែខ្ញុំចិញ្ចឹមឆ្កែពូជផូមេរ៉ានៀន ហើយព្រះអម្ចាស់បានប្រាប់ខ្ញុំថាឲ្យកូនឆ្កែមួយដល់លោកគ្រូ។ កូនឆ្កែនោះមានអាយុ៦ខែហើយ ក៏ត្រៀមខ្លួននឹងរស់នៅជាមួយម្ចាស់ដែរ។» ខ្ញុំឈរនៅទីនោះទាំងចំហមាត់។ ខ្ញុំនៅតែតាំងចិត្តថាមិនទទួលកូនឆ្កែនោះទេ ដូច្នេះខ្ញុំក៏ថា «ចាំខ្ញុំប្រាប់លោកគ្រូតាមក្រោយ»។ ខ្ញុំមិនបានដឹងសោះថាគាត់ចិញ្ចឹមឆ្កែពូជអ្វីខ្លះ ហើយក៏មិនដែលនិយាយពីការដែលឃើរស្វែនចង់បានកូនឆ្កែប្រាប់ដល់គាត់ដែរ។

មិនយូរប៉ុន្មាន ខ្ញុំក៏បានបានចុះចាញ់ ហើយប្រាប់ដល់ឌ្រិនដាពីអ្វីដែលបានកើតឡើង ហើយខ្ញុំមិនចង់យកឆ្កែទៅផ្ទះទេ។ នាងបានមើលមុខខ្ញុំ ហើយថា «តើបងនឹងបដិសេធជំនឿរបស់កូនស្រីយើងឬ?» ឌ្រិនដាក៏មិនចង់ចិញ្ចឹមឆ្កែមួយទៀតនៅក្នុងផ្ទះដែរ ប៉ុន្តែនាងស្រឡាញ់ឃើរស្វែនខ្លាំងជាងអារម្មណ៍ពិបាកដែលឆ្កែអាចនឹងនាំឲ្យយើងមានទៅទៀត។ ហើយនៅពេលនេះ ព្រះជាម្ចាស់បានប្រទានឆ្កែមកជាលទ្ធផលនៃជំនឿរបស់ឃើរស្វែន តើយើងអាចបដិសេធនាងបានដោយរបៀបណាទៅ? ដូច្នេះ ខ្ញុំបានប្រាប់ទៅគ្រូគង្វាលនោះថាខ្ញុំនឹងព្រមទទួលឆ្កែ។

**ឱព្រះជាម្ចាស់អើយ សូមមេត្តាទូលបង្គំផង!**

យើងមិនបានប្រាប់ឃើស្ទែនទេ ប៉ុន្តែបានប្រាប់បងស្រីរបស់នាងឲ្យធ្វើយ៉ាងណានាំឃើស្ទែនទៅអាកាសយានដ្ឋាន នៅពេលដែលនាងទៅទទួលយើង។ ឃើស្ទែនបានទៅអាកាសយានដ្ឋាន ហើយយើងក៏បានដើរទៅ ហើយប្រគល់កូនទ្រុងមួយដល់នាង ដែលយើងបានទិញសម្រាប់ដាក់ឆ្កែ។ នៅពេលដែលឃើស្ទែនបានឃើញកូនឆ្កែផូមេរ៉ានៀននោះភ្លាម នាងបានហូរទឹកភ្នែកទាំងរំភើប។ មនុស្សគ្រប់ៗរូបនៅជុំវិញយើងបានឈប់ ហើយមើលពីអ្វីដែលបានកើតឡើង។ មិនយូរប៉ុន្មាន ក៏បានក្លាយជាមនុស្សមួយហ្វូងនៅឈរជុំវិញយើង នៅពេលដែលឃើស្ទែនកំពុងតែយំនៅទីនោះ ដោយកាន់កូនឆ្កែតូចមួយ។ ឌ្រិនដាបានប្រាប់មនុស្សគ្រប់គ្នាពីរបៀបដែលយើងបានទទួលឆ្កែ និងរបៀបដែលឃើស្ទែនបានជឿលើព្រះជាម្ចាស់សម្រាប់ឆ្កែមួយនោះ។

នេះជាពេលដែលខ្ញុំបានយល់ថា ខ្ញុំគិតថាលោកអ្នកអាចនាំឲ្យមានការផុសផុលនៅក្នុងអាកាសយានដ្ឋានប្រសិនបើលោកអ្នកគ្រាន់តែកាន់កូនឆ្កែមួយនៅក្នុងដៃ។ មនុស្សសុទ្ធតែចង់ឃើញកូនឆ្កែ ហើយមនុស្សនៅក្នុងព្រលានយន្តហោះសុទ្ធតែបានយំជាមួយនឹងឃើស្ទែន សូម្បីតែមន្ត្រីសន្តិសុខ (TSA)។ មកទល់ពេលនេះ ខ្ញុំមានអារម្មណ៍ថាខ្ញុំជាឪពុកដែលមិនល្អទាល់តែសោះ។ នៅពេលដែលខ្ញុំឃើញអំណរដែលកូនឆ្កែនោះបាននាំមកកាន់កូនស្រី និងរបៀបដែលព្រះជាម្ចាស់បាននាំកូនឆ្កែនោះមកដល់យើង ជាលទ្ធផលនៃជំនឿរបស់កូនស្រីខ្ញុំ ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាខ្ញុំបានប្រឆាំងនឹងកិច្ចការដែលនាងចាត់ទុកថាមានតម្លៃវិសេសទៅវិញ។ នាងក៏បានដាក់ឈ្មោះឆ្កែនោះថាសេកស្ពៀរ ជាឈ្មោះដ៏ពិរោះ។ វាបានក្លាយជាសមាជិកក្រុមគ្រួសាររបស់យើង។ ទោះបីជាវាជាឆ្កែមាឌតូច និងរស់នៅបែបឯករាជ្យ តែវាដើរតាមឃើស្ទែនទៅគ្រប់កន្លែងដែលនាងទៅទាំងយប់ទាំងថ្ងៃ។

ទោះបីជារឿងនេះជារឿងដ៏រំជួលចិត្ត ខ្ញុំចាំបាច់ត្រូវសួរសំណួរមួយដែលលោកអ្នកត្រូវឆ្លើយ ហើយក៏ជាគោលបំណងនៃសៀវភៅនេះដែរ។ **តើសត្វឆ្កែនោះបានបង្ហាញខ្លួនដោយរបៀបណា?** មិនធ្លាប់មាននរណាឲ្យឆ្កែមកខ្ញុំពីមុនមកទេ។

ហើយលើកនេះទៀតសោត ជាឆ្អែតជាក់លាក់ដែលកូនស្រីរបស់ខ្ញុំបានស្រាយជំនឿរបស់នាងដើម្បីឲ្យបាននោះ? តើនោះជាការចៃដន្យឬ? អត់ទេ គឺមិនមែនទេ។ វាជាលទ្ធផលផ្ទាល់ពីព្រះរាជ្យរបស់ព្រះ និងច្បាប់គ្រប់គ្រងលើព្រះរាជ្យដែលបង្កើតឲ្យមានផលផ្លែនៅក្នុងជីវិតក្រុមគ្រួសាររបស់ខ្ញុំ។ វាបានបង្កើតលទ្ធផលដូចសព្វមួយដងសម្រាប់អស់អ្នកណាដែលមានជំនឿ និងស្រាយសិទ្ធិអំណាចនៃព្រះរាជ្យនៅលើភពផែនដីនេះ។ យើងអាចទទួលស្គាល់ថា គឺជាព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលនាំឲ្យយើងទទួលបានឆ្អែតនោះ។ ប៉ុន្តែ តើព្រះរាជ្យរបស់ព្រះជាម្ចាស់ធ្វើបែបនោះដោយរបៀបណាទៅ? តើជាច្បាប់អ្វីដែលបានដំណើរការ និងនាំឲ្យរឿងនេះកើតឡើង? ខ្ញុំសង្ឃឹមថា នៅពេលដែលយើងសិក្សាពីសៀវភៅនេះ យើងនឹងទទួលបានចម្លើយច្បាស់លាស់ដែលនឹងជួយលោកអ្នកឲ្យដឹងច្បាស់ពីរបៀបដែលលោកអ្នកអាចរីករាយនឹងព្រះរាជ្យរបស់ព្រះជាម្ចាស់។ សំខាន់បំផុតនោះ លោកអ្នកជាពលរដ្ឋនៃព្រះរាជ្យនោះ ដែលមានសិទ្ធិ និងអាចទទួលបានប្រយោជន៍ស្របច្បាប់! ប៉ុន្តែជាបឋម សូមអនុញ្ញាតឲ្យខ្ញុំប្រាប់ពីឧទាហរណ៍មួយទៀតស្តីអំពីព្រះរាជ្យចេញពីជីវិតក្រុមគ្រួសាររបស់យើងសិន។

# ជំពូកទី៩

# ត្រីធំ

ខណៈពេលដែលឌ្រិនដានិងខ្ញុំបានរៀនពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងសិទ្ធិអំណាចដែលយើងមាននៅលើភពផែនដីនេះ ហើយយើងចាប់ផ្តើមដឹងកាន់តែច្បាស់អំពីការពិតថាយើងជាអ្នកកំណត់ពីរបៀបដែលយើងរស់នៅ ព្រះរាជ្យរបស់ព្រះជាម្ចាស់ជះឥទ្ធិពលដល់គ្រប់ផ្នែកទាំងអស់នៃជីវិតរបស់យើង ប៉ុន្តែយើងជាអ្នកដែលត្រូវស្រាយនូវការផ្គត់ផ្គង់លើតម្រូវការ និងការចង់បានទាំងឡាយមកក្នុងជីវិតរបស់យើង។ វាមិនបានកើតឡើងដោយខ្លួនឯងនោះទេ។ វាដូចជាកូនឆ្កែរបស់កូនស្រីយើង គ្មានអ្វីដែលតូចពេក ឬមិនសំខាន់ក្នុងការនាំយកមកក្រោមការគ្រប់គ្រងនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ឡើយ។ នៅពេលដែលយើងដឹងថា វាពិតជាគ្មានអ្វីដែលមិនអាចទៅរួច ឬនៅក្រៅពីលទ្ធភាពសម្រាប់យើង។ ភាគច្រើននៅក្នុងជីវិតរបស់ខ្ញុំខ្ញុំមិនដែលយល់ច្បាស់ថា ព្រះជាម្ចាស់បានប្រទានព្រះរាជ្យមកឲ្យយើងទេ គឺព្រះរាជ្យទាំងមូលមកដើម្បីឲ្យយើងរីករាយ។ ដូច្នេះវាពិតជារីករាយណាស់ដែលបានមើលឃើញថាព្រះរាជ្យរបស់ព្រះ ជះឥទ្ធិពលមកគ្រប់ផ្នែកទាំងអស់ក្នុងជីវិតរបស់យើង ទោះបីជាក្នុងផ្នែកតូច មិនសូវសំខាន់ក៏ដោយ។ ឧទាហរណ៍អំពីការនេះត្រូវបានបង្ហាញនៅក្នុងសាច់រឿងដូចខាងក្រោម។ ខ្ញុំហៅរឿងនេះថាត្រីយក្ស។

វាបានកើតឡើងនៅពេលដែលក្រុមគ្រួសាររបស់យើងទៅវិស្សមកាលនៅក្នុងរដ្ឋអាឡាស្កា។ ខ្ញុំតែងស្រមៃបានទៅដល់ទីនោះតាំងពីដើមមក។ យើងបានជិះយន្តហោះទៅក្រុងអាន់ឆ័ររ៉េច (Anchorage) ហើយបានជួលឡាន RV (ឡានក្រុងធំដែលមានបន្ទប់គេង បន្ទប់ទឹក និងផ្ទះបាយ) សម្រាប់រយៈពេល៣សប្តាហ៍ ព្រមទាំងបានធ្វើដំណើរជុំវិញតំបន់ឆ្នេរសមុទ្រភាគខាងលិច។ វាពិតជាស្រស់ស្អាតណាស់! នៅថ្ងៃមួយ ខណៈពេលដែលយើងធ្វើដំណើរនៅក្នុងតំបន់ខេណៃ ផេនីនស៊ុលឡា (Kenai Peninsula) យើងបានចាប់អារម្មណ៍លើត្រីដ៏ធំមួយព្យួរនៅខាងក្រៅនាវាជួលមួយនៅលើផ្ទើ។ មាននាវាជាច្រើនបានមកដល់ចុះឡើងៗនៅកំពង់ផែ ហើយមានត្រីធំៗដូចគ្នាដែលត្រូវគេព្យួរនៅទីនោះ។ សម្រាប់ខ្ញុំវាហាក់ដូចជាត្រី Flounder (ជាត្រីធំដែលមានសំប៉ែតស្រដៀងនឹងត្រីអណ្តាតឆ្កែ) ដ៏ធំមួយ។ ខ្ញុំមិនធ្លាប់បានឃើញត្រី Halibut (ត្រីធំរាងសំប៉ែត) ពីមុនមកនោះទេ ហើយក៏មិនដឹងថាជាត្រីអ្វីដែរ ប៉ុន្តែវាពិតជាធំខ្លាំងណាស់។ យើងពិតជាភ្ញាក់ផ្អើលណាស់ ខណៈពេលដែលយើងបើកកាត់ក្រុមហ៊ុនជួលនាវាពីមួយទៅមួយ ដែលមានបដាផ្សាយពាណិជ្ជកម្មអំពីការស្ទូចត្រី Halibut ។ ភ្លាមនោះ ប្រពន្ធរបស់ខ្ញុំបែរមកខ្ញុំ ហើយនិយាយថា «បង! អូនចង់ស្ទូចត្រី Halibut មួយក្បាល ហើយអូនចង់ស្ទូចត្រីនោះជាមួយនាយនាវានៅទីនេះ។» នាងចង្អុលទៅកាន់បដាផ្សាយពាណិជ្ជកម្មពីនាវានេសាទត្រី Halibut ហើយមានស្លាកសញ្ញាគ្រិស្តបរិស័ទរូបត្រីនៅលើបដានោះដែរ។

មុនដំបូង ខ្ញុំពិតជាភ្ញាក់ផ្អើលខ្លាំងណាស់! «អូនចង់ស្ទូចត្រី Halibut?» នាងមិនដែលចង់ស្ទូចត្រីពីមុនមកទេ។ ប៉ុន្តែនាងទទូចរហូតទាល់តែយើងចុះ ហើយដើរទៅការិយាល័យនោះ។ បុគ្គលិកការិយាល័យពិតជារវល់ជាមួយអតិថិជនផ្សេង ដូច្នេះយើងក៏បានដើរមើលជុំវិញនោះមួយភ្លែត អានពីអត្ថបទផ្សេងៗដែលគេបានដាក់នៅលើក្តារខៀន។ យើងបានឃើញផ្លាកសញ្ញាដែលនិយាយអំពីព្រឹត្តិការណ៍ចាប់ត្រី Halibut ដែលកំពុងតែប្រព្រឹត្តឡើង ប៉ុន្តែវាជិតដល់ពេលបញ្ចប់ទៅហើយ។ ដោយសារតែយើងមិនដឹងថាវាជាស្អី ហើយលោកអ្នកក៏ប្រហែលជាមិនស្គាល់វា

សូមអនុញ្ញាតឲ្យខ្ញុំពន្យល់។ ព្រឹត្តិការណ៍ចាប់ត្រី Halibut គឺជាការប្រកួតប្រជែងសម្រាប់អ្នកណាដែលចាប់បានត្រី Halibut ដែលធំជាងគេប្រចាំខែក្នុងចំណោមនាវាជួលទាំងអស់។ អ្នកឈ្នះនឹងទទួលបានរូបភាពរបស់ពួកគេ និងមូលប្បទានបត្រ។ ខ្រិនដានិងខ្ញុំបានពិភាក្សាគ្នាអំពីការចូលរួមប្រកួតចាប់ត្រី តាំងពីយើងដើរចេញទៅខាងក្រៅ។ វាចំណាយលុយតែពីរបីដុល្លាប៉ុណ្ណោះដើម្បីចូលរួមប្រកួត ហើយវាក៏កើតឡើងអញ្ចឹង។

ប្រពន្ធសម្លាញ់របស់ខ្ញុំខ្រិនដាបានងាកមកនិយាយប្រាប់ខ្ញុំថា នាងបានសម្រេច ចិត្តថានាងនឹងយកឈ្នះការប្រកួតនេះ ហើយនឹងធ្វើឲ្យអាជីវកម្មរបស់នាយនាវាម្នាក់នេះត្រូវបានទទួលស្គាល់ក្នុងចំណោមអាជីវកម្មជួលនាវាទាំងអស់ ដោយសារតែគាត់ជាគ្រិស្តបរិស័ទ ហើយព្រះជាម្ចាស់នឹងបានទទួលសិរីរុងរឿង។ ដូច្នេះដល់ពេលដែលយើងត្រូវទៅចុះឈ្មោះ ខ្រិនដាបានប្រកាសយ៉ាងក្លាហានថា នាងនឹងឈ្នះការប្រកួតចាប់ត្រី Halibutនេះ ដើម្បីឲ្យគេសរសេរតម្កើងព្រះជាម្ចាស់ ហើយអាជីវកម្មរបស់គាត់នឹងត្រូវបានគេទទួលស្គាល់ ដោយសារតែវាជាអាជីវកម្មគ្រិស្តបរិស័ទ។ ពិតណាស់ ចំពោះនាយនាវាវិញ លោកអ្នកអាចស្រមៃថាគាត់កំពុងគិតពីអ្វីដែរឬទេ។ មែនហើយ មនុស្សគ្រប់គ្នាតែងតែចង់ឈ្នះការប្រកួតចាប់ត្រី Halibut នេះ ហើយខ្ញុំប្រាកដណាស់ ថាគាត់ធ្លាប់ឮពីមនុស្សជាច្រើននិយាយដូច្នោះដែរ រួមទាំងទេសចរដែលគាត់បានដឹកទៅស្ទូចត្រីផង។ ទោះជាយ៉ាងណាមិញ ខ្ញុំមិនហ៊ានធានាថា គាត់ធ្លាប់ឮមនុស្សជាច្រើនបានប្រកាសថាពួកគេនឹងឈ្នះដើម្បីថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់នោះទេ។

តាមការពិត គាត់មិនបាននិយាយអ្វីច្រើនទាក់ទងនឹងគំនិតរបស់ខ្រិនដា ទាក់ទងនឹងការប្រកួតទេ។ ខណៈពេលដែលយើងចេញទៅក្រៅដើម្បីស្ទូចត្រី យើងក៏ចាប់បានត្រី Halibut ហើយខ្រិនដាបន្តសួរនាយនាវា ដែលគាត់ក៏ជាម្ចាស់ទូកដែរថា តើត្រី Halibut ធំប៉ុណ្ណាទើបអាចឈ្នះការប្រកួតនេះបាន។ គាត់គ្រាន់តែនិយាយថា វាត្រូវតែធំជាងត្រី Halibut ដែលនាងទើបតែចាប់បាននេះ ដែលជាហេតុធ្វើឲ្យ

នាងតែងតែមានសំណួរគ្រប់ពេលដែលនាងចាប់បានម្ដងៗ។ នៅពេលដែលនាងចាប់បានត្រីដែលមានទម្ងន់ ១៨.១៤ គីឡូក្រាម គាត់និយាយថាមិនទាន់ធំល្មមនោះទេ។ នៅពេលដែលនាងចាប់បានត្រីទម្ងន់ ៣១.៧៥ គីឡូក្រាម វាមិនទាន់ធំល្មមដែរ។ ពិតណាស់ មនុស្សគ្រប់គ្នាដឹងថាត្រី Halibut នេះមានឱជារសឆ្ងាញ់ប៉ុណ្ណា ដូច្នេះយើងមានគម្រោងយកត្រីដែលយើងចាប់បានទៅផ្ទះវិញ។ គេកំណត់ថា មនុស្សម្នាក់ទុកបានតែ២ទេ ដូច្នេះយើងទុកត្រីដែលមានទម្ងន់ ៣១ គីឡូ។

ថ្ងៃកាន់តែជ្រេ ល្ងាចក៏ចូលមកដល់ហើយមេឃក៏កាន់តែងងឹត។ កូនប្រុសរបស់ខ្ញុំឈ្មោះថម និងកូនស្រីរបស់ខ្ញុំឈ្មោះផល្លីបូករួមទាំងខ្ញុំ យើងទាំងអស់គ្នាសុទ្ធតែដល់កម្រិតរបស់យើងគឺម្នាក់២។ កូនរបស់ខ្ញុំពីរនាក់ទៀតគឺអេមី និងជីមត្រូវជិះយន្តហោះត្រលប់ទៅផ្ទះមុន ដើម្បីចូលរួមសន្និបាតមួយ ហើយពួកគេមិនបាននៅជាមួយយើងនោះទេ។ ឌ្រិនដាមានត្រី៣១គីឡូរបស់នាង ហើយគ្មានត្រីណានៅលើនាវារបស់យើងនឹងឈ្នះការប្រកួតនេះទេ។ ប៉ុន្តែឌ្រិនដានៅតែមានទំនុកចិត្តថានាងនឹងចាប់បានត្រីធំមួយ។ ព្រលប់ក៏ចូលមកដល់ នាយនាវាប្រាប់ឲ្យយើងទាំងអស់គ្នាម៉ូរសន្ទូចរបស់យើងឡើង ព្រោះវាដល់ពេលត្រូវត្រលប់ទៅកំពង់ផែវិញ។ ឌ្រិនដាមិនស្ដាប់តាមបង្គាប់នោះទេ ខណៈពេលដែលនាយនាវាបានជួយពួកគេដកសន្ទូចមកវិញ ហើយរៀបចំទុកដាក់។ នាងបានសុំអង្វរឲ្យនៅពីរបីនាទីទៀត ខណៈពេលដែលនាងបានប្រកាសម្ដងទៀតថានឹងចាប់ត្រី Halitbut ហើយឈ្នះការប្រកួតនេះ។ នាយនាវាក៏រង់ចាំពីរបីនាទី ហើយបន្ទាប់មកក៏ដើរទៅកាន់នាងដោយសុំទោសនាងថា «ឲ្យខ្ញុំសុំទោស! ប៉ុន្តែយើងពិតជាត្រូវត្រលប់ទៅវិញហើយ»។

មុនពេលដែលម៉ូរសន្ទូចឡើងវិញ គឺត្រឹមមួយប៉ព្រិចភ្នែកប៉ុណ្ណោះ។ វាប្រាកដជាត្រីធំមិនខានដែលស៊ីសន្ទូច ព្រោះដងសន្ទូចចាប់ផ្ដើមកោងហើយដុំសន្ទូចចាប់ផ្ដើមស្រែក។ នាយនាវាក៏បានទាញសន្ទូច ដើម្បីឲ្យស្មានដឹងថាត្រីនោះធំប៉ុណ្ណា ហើយយល់ស្របថាវាពិតជាត្រីធំមែន តែវាជាត្រីឆ្លាម។ គាត់និយាយថា គាត់ដឹងថាវាជាត្រីឆ្លាមតាមរបៀបដែលវាទាញ។ ពិតណាស់ វាត្រូវចំណាយពេលមួយសន្ទុះ

ដើម្បីទាញត្រីនោះឡើង។ វាត្រូវចំណាយកម្លាំងទាំងស្រុងរបស់នាងដើម្បីទាញត្រីនោះឡើងពីទឹក ដែលវាស្ថិតនៅក្នុងជម្រៅជាង ៩០ម៉ែត្រ។ ខណៈដែលត្រីនោះឡើងមកលើផ្ទៃទឹក មនុស្សគ្រប់គ្នាមើលឃើញថាវាពិតជាត្រី Halibut ដ៏ធំមួយ គឺធំជាងខ្លួនរបស់ឌ្រិនដាទៅទៀត។

ខណៈពេលដែលទាញត្រីមកលើនាវា នាយនាវាបាននិយាយថាត្រីនោះធំពេក ក្នុងដាក់ទំពក់ទាញមកលើទូកទាំងរស់នោះ វានឹងធ្វើឲ្យក្រឡាប់ ហើយដោយសារតែត្រីធំពេក វាធ្វើឲ្យនរណាម្នាក់អាចរងរបួស ឬប៉ះពាល់ដល់នាវា។ គាត់មានជន្លួញពិសេសមួយ ដែលត្រូវបានបង្កើតឡើងដើម្បីចាក់ត្រីធំបែបនេះ។ ជន្លួញនោះមានចុងវាដែលឆក់បាន នៅពេលដែលវាប៉ះក្បាលត្រី វានឹងឆក់ហើយសម្លាប់ត្រីនោះ។ ខណៈពេលដែលនាយនាវានោះទាញជន្លួញចាក់លើក្បាលត្រីធំនោះ ចុងឆក់នោះតម្រង់មក ត្រីកន្ត្រាក់ហើយធ្វើឲ្យចាក់ខុស។

ដោយរំញ័រជន្លួញ ត្រីនោះក៏ហែលចុះទៅក្រោមទឹកវិញអស់ពីកម្លាំងរបស់វា។ វាហែលចុះទៅក្រោមបានប្រហែល៩០ម៉ែត្រ ដុំសន្ទូចក៏ស្រែក។ យើងខ្លាចថាខ្សែនោះទប់ត្រីមិនជាប់ ឬរបូតផ្លែសន្ទូចចេញពីមាត់ត្រី ព្រោះត្រីនោះកំពុងតែខំហែលមុជទៅបាតវិញ។ ឌ្រិនដាត្រូវទាញត្រីនោះឡើងមកលើម្តងទៀត។ នាងពិតជាពិបាកក្នុងការទាញវាមកណាស់ ព្រោះនាងបានប្រឹងអស់កម្លាំងកាយដើម្បីទាញវាម្តងរួចមកហើយ ដូច្នេះខ្ញុំក៏បានឈរពីក្រោយនាង ហើយជួយទាញដងសន្ទូចនោះជាមួយនាង ហើយយើងទាំងពីរក៏បានខិតខំទាញវាបន្តិចម្តងៗ រហូតទាល់តែវាត្រឹមផ្ទៃទឹកម្តងទៀត។ ពេលនេះ នាយនាវាអាចយកវាឡើងមកលើនាវាបាន ហើយយើងពិតជាភ្ញាក់ផ្អើលនឹងទំហំរបស់វាខ្លាំងណាស់។

យើងក៏យកត្រី Halibut ទៅទីប្រជុំជន ជាកន្លែងដែលមានជញ្ជីងធំល្មមដើម្បីថ្លឹងវា។ ត្រីនោះមានទម្ងន់ ៥៥.៨០គីឡូក្រាម ហើយមានប្រវែងវែងជាងឌ្រិនដាទៅទៀត។ បុរសដែលថ្លឹងត្រីនោះ បាននិយាយថាត្រីហ្នឹងហើយ នៅពេលនោះវាជាត្រីដែលធំជាងគេដែលចូលរួមការប្រកួត ប៉ុន្តែការប្រកួតនៅសល់ពីរអាទិត្យទៀត

ហើយយើងមិនដឹងច្បាស់ថាតើត្រីនោះនឹងឈ្នះឬក៏អត់ទេ។ ប៉ុន្តែច្បាស់ណាស់ នៅថ្ងៃមួយមានមូលប្បទានបត្របានមកដល់ ដែលមានឈ្មោះខ្រិនដានៅលើនោះ ហើយមានសារព័ត៌មានមួយច្បាប់បានចុះផ្សាយដោយដាក់រូបនាងនៅលើនោះដែរ។ យើងពិតជាភ្ញាក់ផ្អើលខ្លាំងណាស់!

នៅលើកនេះ យើងឃើញថាព្រះរាជ្យរបស់ព្រះជាម្ចាស់បានធ្វើការម្តងទៀត! ខ្ញុំក៏ត្រូវសួរខ្លួនឯងម្តងទៀតថា «តើនាងអាចស្ទូចវាបានដោយរបៀបណា?» ខ្ញុំគ្រាន់តែដឹងថា នាងធ្លាប់ស្ទូចត្រីបានតែពីរដងប៉ុណ្ណោះ តាំងពីយើងរៀបការមក ហើយការស្ទូចត្រីមិនមែនជាចំណង់ចំណូលចិត្តរបស់នាងឡើយ។ ខ្ញុំនៅតែភ្ញាក់ផ្អើលនៅឡើយ ពេលដែលនាងចង់ចាប់ត្រី Halibut នៅកន្លែងដំបូង។ ប៉ុន្តែនាងមានហេតុផលរបស់នាង ថានាងនឹងយកឈ្នះការប្រកួតនោះ ហើយនាងពិតជាឈ្នះមែន! ខណៈពេលដែលយើងរៀបចំចេញមកជាមួយនាយនាវានៅរដ្ឋអាឡាសស្កា យើងបានចែករំលែកជាមួយគាត់ពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងរបៀបដែលយើងចាប់ត្រីនោះ។ ទោះបីជាពេលនោះ យើងមិនទាន់ឈ្នះការប្រកួតនៅឡើយក៏ដោយ ក៏នៅពេលដែលយើងចាកចេញពីនាយនាវានៅថ្ងៃនោះ ត្រីនោះពិតជាធំល្មមដែលធ្វើឲ្យគាត់ភ្ញាក់ផ្អើល។ ពិតមែនហើយ ចុងក្រោយយើងនៅតែជាអ្នកឈ្នះដដែល។

លោកអ្នកប្រហែលជាគិតថារឿងរបស់យើង ឬក៏ខ្ញុំគួរតែនិយាយថារឿងត្រីយក្សរបស់ខ្រិនដាបានបញ្ចប់ត្រឹមនេះហើយ។ ខ្ញុំដឹងថា មនុស្សនឹងគិតថានេះគ្រាន់តែសំណាងល្អប៉ុណ្ណោះ ចុះប៉ុន្តែបើពីរដងវិញ? មែនហើយ ប្រហែលជា៥ឆ្នាំក្រោយមក ខ្រិនដានិងខ្ញុំបានអញ្ជើញគ្រូគង្វាលម្នាក់ដែលជាមិត្តរបស់យើងទៅស្ទូចត្រីសាល់ម៉ុន។ យើងមិនបានត្រលប់មកវិញតាំងពីដំណើរវិស្សមកាលជាមួយគ្រួសារកាលពីលើកមុន ហើយយើងបានរកលេសដើម្បីត្រលប់មកវិញតាំងពីពេលនោះឯង។ យើងក៏ជួលឡាន RV ម្តងទៀត ដោយមានគម្រោងក្នុងការចាប់ត្រីសាល់ម៉ុន ដោយសារតែត្រីសាល់ម៉ុនសាច់ក្រហមហៀលលឿនណាស់។ ខណៈដែលយើងកំពុងតែស្ទូចត្រីសាល់ម៉ុន យើងក៏បាននិយាយអំពីការចាប់ត្រី Halibut និងត្រីរបស់

ខ្រិនដា។ មិត្តរបស់យើងមិនដែលស្ទូចត្រី Halibut ពីមុនមកនោះទទេ ដូច្នេះយើងក៏និយាយថា «តោះ ទៅស្ទូចម្តងអញ្ចឹង»។ យើងក៏សម្រេចចិត្តថាយើងចង់ទៅកន្លែងដដែល ជាមួយនាយនាវាដដែល ប្រសិនបើគាត់នៅបើកអាជីវកម្មរបស់គាត់។

ខណៈពេលដែលយើងបើកទៅកន្លែងចាស់ យើងឃើញថាគាត់លែងនៅទីនោះហើយ ក៏គិតថាប្រហែលយើងត្រូវជួលនាយនាវាផ្សេង។ ប៉ុន្តែមុនជួលនាវាផ្សេង យើងគិតថាយើងគួរតែមើលអ៊ីនធើណែត មើលថាតើយើងអាចរកឈ្មោះគាត់ឃើញដែរឬទេ ប៉ុន្តែយើងមិនចាំឈ្មោះនាវា ឬក៏ក្រុមហ៊ុនរបស់គាត់ឡើយ។ បន្ទាប់ពីស្វែងរករួចហើយ យើងក៏អាចរកឃើញកាសែតដែលនិយាយអំពីត្រីរបស់ខ្រិនដាដែលមានរូបនាងកាលពី៥ឆ្នាំមុន។ វាបានប្រាប់ពីឈ្មោះនាវា និងក្រុមហ៊ុននោះ ដូច្នេះយើងក៏ទូរស័ព្ទទៅកាន់គាត់ ហើយអាចរៀបចំដំណើរស្ទូចត្រីបាន។ ក្រុមហ៊ុននោះនៅតែបើកដដែល ប៉ុន្តែគាត់ដោយគ្រាន់តែរើអាជីវកម្មរបស់គាត់ប្រហែល៨គីឡូម៉ែត្រឆ្ងាយជាងមុនបន្តិច។

ខណៈពេលដែលយើងចូលទៅកន្លែងនោះ ស្ត្រីម្នាក់នៅតុទទួលភ្ញៀវដែលជាភរិយារបស់នាយនាវា និងជាម្ចាស់ផងនោះ បានសម្លឹងមើលយើង ហើយនិយាយថា «ម្ចាស់ពានរង្វាន់ត្រី Halibut!» យើងបានជជែកគ្នាលេងប្រហែល២-៣នាទី អំពីត្រី Halibut ដ៏ធំនោះ ហើយសួរសុខទុក្ខគ្នាក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ។ ខណៈពេលនោះស្ថិតក្នុងកំឡុងវិបត្តិសេដ្ឋកិច្ច ហើយអាជីវកម្មរបស់គាត់ក៏មិនសូវល្អប៉ុន្មានដែរ។ គាត់បាននិយាយថាមិនសូវមានមនុស្សធ្វើដំណើរកម្សាន្ត ឬចាយលុយរបស់ពួកគេលើការស្ទូចត្រីដូចសព្វដងទេ ហើយប្តីរបស់នាងក៏បាក់ទឹកចិត្តដែរ។ យើងក៏រំឭកនាងពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយនាងបាននិយាយថាប្តីរបស់នាងលែងមានចំណាប់អារម្មណ៍ក្នុងការបម្រើព្រះជាម្ចាស់ទៀតហើយ។

នៅពេលដែលយើងឡើងលើនាវា គាត់ក៏នៅទីនោះដែរ ហើយគាត់នៅចងចាំពីខ្រិនដា និងត្រីធំរបស់នាង។ ខ្រិនដាបានដើរតម្រង់ទៅគាត់ ហើយបានសួរគាត់ពី

របរស្ទូចត្រីរបស់គាត់ ហើយគាត់និយាយថា ពួកគេចាប់បានតែត្រីតូចប៉ុណ្ណោះបើប្រៀបធៀបនឹងត្រីដែលនាងបានចាប់សម្រាប់ការប្រកួត។ ប៉ុន្តែគាត់បាននិយាយថា ត្រីធំៗទាំងនោះលែងរស់នៅតំបន់នេះទៀតហើយ ដោយសារតែទឹកឥឡូវរាក់ពេក ហើយគាត់បានពន្យល់ពីមូលហេតុដែលបានផ្ទឹទីតាំងអាជីវកម្មរបស់គាត់ ដោយសារតែកន្លែងដែលគាត់ធ្លាប់ស្ទូចត្រី និងកន្លែងដែលខ្រិនដាធ្លាប់ចាប់ត្រីធំនោះ ជ្រៅខ្លាំងណាស់ ហើយសុទ្ធតែត្រីឆ្លាមទៀតផង។ ត្រីឆ្លាមនឹងស៊ីនុយ មុនពេលដែលវាធ្លាក់ដល់បាតទៅទៀត ហើយវាធ្វើឲ្យគាត់ចំណាយប្រាក់អស់ច្រើនលើនុយ និងខាតពេលវេលាច្រើនដែរ។

ដូច្នេះយើងក៏សួរគាត់ថា តើគាត់ចាប់បានត្រីធំប៉ុណ្ណានៅក្នុងតំបន់ថ្មីនេះ ហើយគាត់និយាយថា គាត់មិនដែលឃើញត្រីលើសពី ៩-១៣គីឡូក្រាមទេនៅក្នុងខែនេះ។ ដូច្នេះខ្រិនដាមើលទៅកាន់គាត់ ហើយនិយាយថា «មិនអីទេ ខ្ញុំនឹងចាប់ត្រីធំមួយនៅថ្ងៃនេះ គឺត្រីធំជាងគេដែលលោកខានឃើញក្នុងមួយរយៈពេលនេះ ដើម្បីឲ្យលោកដឹងថាព្រះជាម្ចាស់ពិតជាស្មោះត្រង់។» ប៉ុន្តែគាត់ក៏និយាយឌឺនាង។ ស្ទើរតែពេញមួយថ្ងៃ យើងចាប់បានតែត្រីទម្ងន់ ៩គីឡូក្រាមដូចនាយនាវានិយាយតែប៉ុណ្ណោះ ហើយពេញមួយថ្ងៃនេះ នាយនាវាតែបន្តនិយាយឌឺដងដាក់ខ្រិនដាអំពី «ត្រីធំ» នៅពេលដែលនាងកំពុងចាប់។ អ្វីៗកើតឡើងដូចដំណើរកម្សាន្តកាលពីលើកមុន។

ល្ងាចក៏ឈានចូលមកដល់ នាយនាវាប្រាប់យើងឲ្យមូលសន្ទូចឡើង ហើយខ្រិនដាមិនខ្វល់ឡើយ ព្រមទាំងនិយាយថានាងសុំ១-២នាទីទៀតដើម្បីចាប់ត្រីធំ។ នាយនាវាក៏ចាំនាងបន្តិច ហើយគាត់ក៏ប្រាប់នាងថា យើងត្រូវដល់ពេលត្រលប់ទៅវិញហើយ។ ភ្លាមនោះដងសន្ទូចរបស់នាងក៏ធ្លាក់ចុះទៅក្រោម។ សង្ខេបរឿងឲ្យខ្លី នាងស្ទូចបានត្រីទម្ងន់ជាង៣២គីឡូក្រាម។ នាយនាវាក៏ភ្ញាក់ផ្អើលម្តងទៀត។

នៅពេលដែលយើងទៅបរិភោគអាហារបន្ទាប់ពីស្ទូចត្រីរួច ហើយបាននិយាយទៅកាន់នាយនាវាដែលកំពុងបរិភោគអាហារពេលល្ងាចនៅទីនោះដែរ។ នៅពេល

ដែលគាត់បានឮថាឌ្រិនដាចាប់បានត្រីជាង ៣២ គីឡូក្រាម គាត់ស្ទើរតែមិនជឿទេ។ តើអ្នកស្ទូចត្រីនៅកន្លែងណា? ឆ្នាយប៉ុណ្ណាដែរ? គាត់ចង់ដឹងថាយើងចាប់បានត្រីធំនោះមកពីកន្លែងណា។ បន្ទាប់ពីចាកចេញពីភោជនីយដ្ឋានមក យើងក៏ជិះកាត់កន្លែងស្ទូចត្រីនោះ ដើម្បីដឹកត្រីនោះយកទៅផ្ទះ។

មុនពេលដែលយើងចាកចេញពីទីនោះ យើងក៏មានឱកាសចែករំលែកពីព្រះរាជ្យរបស់ព្រះជាម្ចាស់ម្តងទៀត។ ខ្ញុំមើលទៅកាន់នាយនាវា ហើយនិយាយថា «អ្នកត្រូវតែស្វែងយល់ពីរបៀបដែលនាងចាប់បានត្រីធំពីរនោះ។ ច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ក៏មានប្រសិទ្ធិភាពសម្រាប់ថវិកាដែរ។» ពេលនោះ យើងបានទាក់ទាញចំណាប់អារម្មណ៍របស់គាត់ ហើយគាត់ជាអ្នកដែលចាប់អារម្មណ៍តិចបំផុត។ យើងក៏បានឲ្យសៀវភៅរបស់ខ្ញុំមួយក្បាល គឺសៀវភៅ Fixing the Money Thing រួចក៏ចាកចេញមក។

តើការចាប់បានត្រីធំពីរនោះជាឱកាស ឬក៏ជាលទ្ធផលនៃច្បាប់នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់? វាជាជម្រើសរបស់លោកអ្នក ប៉ុន្តែខ្ញុំនិងឌ្រិនដាបានសម្រេចជាយូរមកហើយ។ ចាប់ពីដំណើរកម្សាន្តស្ទូចត្រី ការមានសេរីភាពពីបំណុល ឬទទួលបានការជាសះស្បើយ បទពិសោធន៍របស់យើងជាមួយព្រះរាជ្យរបស់ព្រះជាម្ចាស់ពិតជាគួរឲ្យស្ញប់ស្ញែងណាស់ ព្រមទាំងធ្វើឲ្យជីវិតផ្លាស់ប្តូរផង។ នេះក៏រួមបញ្ចូលទាំងបទពិសោធន៍ផ្សេងៗទៀតជាមួយព្រះរាជ្យរបស់ព្រះជាម្ចាស់ដែរ។ ខាងក្រោមនេះជាលិខិតមកពីស្ត្រីម្នាក់ដែលបានឮសាច់រឿងរបស់ឌ្រិនដា៖

ជូនចំពោះលោកហ្គារី និងអ្នកស្រីឌ្រិនដា

ខ្ញុំបានគិតថា បន្ទាប់ពីអានសៀវភៅរបស់អ្នកទាំងពីរដែលនិយាយពីរឿងឌ្រិនដាស្ទូចបានត្រី Halibut និងទទួលបានពាន់រង្វាន់រួចមក ខ្ញុំក៏គួរតែចែករំលែកសាច់រឿងទាក់ទងនឹងត្រីជាមួយអ្នកទាំងពីរផងដែរ។ ថ្មីៗនេះ យើងទើប

តែត្រលប់មកពីដំណើរកម្សាន្តនៅឆ្នេរសមុទ្រ កូកៅ/ខេប ខាណាវើរ៉ាល់ (Cocao/Cape Canaveral) រដ្ឋផ្លរីដា។ ប្ដីរបស់ខ្ញុំឈ្មោះរ៉ូបឺតចង់ទៅជិះទូកទៅសមុទ្រដែលមានជម្រៅជ្រៅដើម្បីស្ទូចត្រី ដោយមានបំណងចង់យកត្រីខ្លះត្រលប់ទៅរដ្ឋកូឡូរ៉ាដូវិញ។ យើងបានរៀបចំដំណើរកម្សាន្តរបស់យើងប្រហែលពីរបីខែមកហើយ ដូច្នេះគាត់បានប្រាប់ខ្ញុំថាគាត់ចង់ទៅស្ទូចត្រី ខ្ញុំក៏រំភើបដែរហើយនិយាយថា «តោះ ចាំយើងទៅស្ទូច! ហើយជឿលើព្រះជាម្ចាស់ថាវានឹងក្លាយជាការស្ទូចត្រីដ៏អស្ចារ្យមួយ!» ខ្ញុំបានសួរទៅបប់ (ជាឈ្មោះកាត់សម្រាប់ឈ្មោះរ៉ូបឺត) ថា តើមានត្រីអ្វីខ្លះ ដែលយើងអាចស្ទូចបាននៅក្នុងរដ្ឋផ្លរីដា ត្រង់កន្លែងដែលយើងនឹងទៅស្ទូចនោះ។ គាត់ក៏បានរៀបរាប់ឈ្មោះត្រីទាំងប៉ុន្មានមកកាន់ខ្ញុំ ខ្ញុំក៏ជ្រើសរើសអធិស្ឋាន ហើយជឿថាយើងនឹងចាប់បានត្រី Snapper ធំពណ៌ក្រហមមួយ។

ថ្ងៃនោះក៏បានមកដល់ ហើយយើងកំពុងតែរង់ចាំទទួលការណែនាំរបស់យើងពីនាយនាវា និងនាវិក។ ខ្ញុំបានប្រកាសថា ខ្ញុំនឹងចាប់ត្រី Snapper ធំមួយ ហើយខ្ញុំពិតជារំភើបណាស់នៅពេលដែលនាយនាវាកំពុងតែផ្ដល់កាណែនាំ។ ខ្ញុំពិតជាខកចិត្តខ្លាំង នៅពេលដែលឮនាយវានានិយាយថា ថ្មីៗនេះមានត្រីមួយចំនួនដែលយើងមិនអាចយកទៅបានមានដូចជាត្រី Bass ត្រី Flounder និងត្រី Snapper ពណ៌ក្រហម! យ៉ាប់មែន! មិនគួរឲ្យជឿសោះ។

ពិតមែនហើយ ខ្ញុំនឹងមិនបង់ឱកាសដែលខ្ញុំអាចអនុវត្តជំនឿរបស់ខ្ញុំនេះចោលទេ។ ខ្ញុំនិយាយថា «ព្រះអង្គ ខ្ញុំជឿថាខ្ញុំនឹងស្ទូចបានត្រី Snapper ធំពណ៌ក្រហម សូមឲ្យវាក្លាយជាការពិតផង គឺខ្ញុំនឹងស្ទូចបានមួយ ហើយនឹងយកវាទៅផ្ទះដែរ!

នៅពេលដែលយើងនៅលើទូក ខ្ញុំនិយាយទៅកាន់កូនស្រីរបស់ខ្ញុំឈ្មោះរ៉ាជែលអាយុ ៨ ឆ្នាំថា «ចាំថា កូនអាចអធិស្ឋាន និងជឿថាព្រះជាម្ចាស់ប្រទាន

ឲ្យកូនចាប់បានត្រីមួយក្បាលនៅថ្ងៃនេះ។ កូនជឿអត់?» នាងញញឹម ហើយងក់ក្បាល។ ខ្ញុំក៏និយាយដូចគ្នាទៅកាន់កូនស្រីអាយុ ២១ ឆ្នាំ ដែលមានឈ្មោះថាយ័រដាន់ដែរ។ នាងមើលមកខ្ញុំទាំងភ្ញាក់ផ្អើល ប៉ុន្តែនាងក៏យល់ស្រប។ ខ្ញុំមើលមកកាន់បប់ ហើយនិយាយថា «បង សូមជឿថាយើងនឹងចាប់បានត្រីធំមួយ!»

រយៈពីរបីម៉ោងក្រោយមក គ្មានអ្វីមកប៉ះខ្សែសន្ទូចរបស់យើងសោះ។ ភ្លាមនោះ មានអ្វីមួយមកប៉ះខ្សែសន្ទូចរបស់រ៉ាជែល ហើយនាងពិតជារំភើបណាស់។ នាងក៏ហៅប៉ារបស់នាងឲ្យទៅជួយ។ ពីរបីនាទីក្រោយមក ពួកគេក៏ទាញបាន ត្រីឆ្លាម Atlantic មួយក្បាល! អស្ចារ្យណាស់! រ៉ាជែលបានឃើញលទ្ធផលពីជំនឿរបស់នាង! ដូច្នេះយើងក៏បានសរសើរដល់នាង។ នាងពិតជាស៊ូទ្រាំមែន!

ខ្ញុំក៏ចាប់ផ្ដើមគិតថាប្រហែលស្ទូចមិនបានត្រីទេ ប៉ុន្តែខ្ញុំក៏ឈប់គិតបែបនោះហើយប្រកាសថាថា ខ្ញុំស្ទូចបានត្រីមួយហើយ។ ខ្ញុំក៏អង្គុយចុះ ហើយសម្រាក ព្រមទាំងឮព្រះជាម្ចាស់មានបន្ទូលថា «ប្រសិនបើកូនគ្រាន់តែសម្រាក ហើយអនុញ្ញាតឲ្យយើងយកត្រីនោះមកឲ្យកូន នោះកូននឹងបានវា។» មែនហើយ ខ្ញុំបានដឹងថា ខ្ញុំមិនមែនជាអ្នកស្ទូចត្រីអ្វីទេ អញ្ចឹងខ្ញុំក៏មិនអាចពឹងលើសមត្ថភាពរបស់ខ្ញុំដដែលហ្នឹង។ ខ្ញុំអង្គុយចុះ ហើយដកដង្ហើមធំទាំងទំនុកចិត្តមកពីព្រះជាម្ចាស់ ព្រមទាំងរង់ចាំ។ ប្រហែលជា២០-៣០នាទីក្រោយមក មានអ្វីមួយមកទាក់នឹងខ្សែសន្ទូចរបស់ខ្ញុំ យ៉ាងហោចណាស់ខ្ញុំគិតថាមានអ្វីមួយមកទាក់ ប៉ុន្តែវាពិតជាត្រីមួយក្បាលមែន។

ប្ដីរបស់ខ្ញុំ ក៏ចាប់ផ្ដើមបង្រៀនខ្ញុំ ហើយបន្ទាប់មកនាយនាវាក៏ធ្វើដូចគ្នា។ គាត់បានប្រាប់ខ្ញុំពេលដែលខ្ញុំកំពុងតែហូតសន្ទូចដែលជាប់ត្រីនោះថា ខ្ញុំស្ទូចបានត្រី Snapper ធំមួយ។ ខ្ញុំពិតជារំភើបខ្លាំងណាស់ ដែលគាត់បានដឹងមុន

ពេលដែលលេចរូបរាងត្រីនោះមកទៅទៀត! ប្រាកដណាស់ ខណៈពេលដែលខ្ញុំកំពុងតែទាញសន្ទូចរបស់ខ្ញុំឡើង ក៏ឃើញមានត្រី Snapper ពណ៌ក្រហមដ៏ធំមួយ! ខ្ញុំអរគុណព្រះជាម្ចាស់ជាខ្លាំង ជាមួយនឹងអំណរ និងសេចក្តីរីករាយក្រៃលែង។ ខ្ញុំបានដឹងថា ខ្ញុំមានការទម្លុះទំលាយកើតឡើងនៅក្នុងជំនឿរបស់ខ្ញុំ។ ខ្ញុំគ្រាន់តែនឹកចាំពីទំនុកចិត្តរបស់ឌ្រិនដា និងគំនិតដែលខ្ញុំអាចមានជំនឿ និងការជឿដូចគ្នា។ ខ្ញុំបានស៊ូទ្រាំ ហើយក៏ឃើញលទ្ធផលពីការស៊ូទ្រាំនេះ។

ខ្ញុំសូមអរគុណសម្រាប់ព័ន្ធកិច្ចរបស់អ្នក និងសម្រាប់ការនិពន្ធសៀវភៅឡើង រួមទាំងសៀវភៅ The Faith Hunt។ ខ្ញុំសូមថ្លែងអំណរគុណ និងអរព្រះគុណព្រះជាម្ចាស់សម្រាប់ព័ន្ធកិច្ចរបស់អ្នក ដែលបានជួយខ្ញុំឲ្យចូលទៅកាន់ព្រះពរដ៏ធំជាងនេះ។ ខ្ញុំរំពឹងរង់ចាំសម្រាប់អនាគតជាមួយនឹងជំនឿ និងសេចក្តីរំភើបកាន់តែខ្លាំង។ ខ្ញុំដឹងថាបទពិសោធន៍មួយនេះក៏បានធ្វើព័ន្ធកិច្ចមកកាន់គ្រួសាររបស់យើងដែរ!

ដោយសេចក្តីគោរពពីខ្ញុំ

S.T.

## ជំពូកទី៥

# ជម្រើសនរណា?

នៅក្នុងសាច់រឿងមុនៗ យើងបានឃើញថានៅលើភពផែនដីនេះ ព្រះរាជ្យរបស់ព្រះជាម្ចាស់បានប្រទាននូវសត្វឆ្កែ ត្រី ប្រាក់សម្រាប់លោះផ្ទះដែលហៀបនឹងត្រូវគេរឹបអូស ប្រទានប្រាក់ដើម្បីទិញឡាននិងផ្ទះដែលយើងត្រូវការនៅក្នុងជីវិត ជួយសង្គ្រោះអាយុជីវិតកូនៗបីនាក់ ហើយមានច្រើនថែមទៀត។ សាច់រឿងទាំងអម្បាលម៉ាននេះបានកើតឡើងដោយសារតែព្រះរាជ្យរបស់ព្រះជាម្ចាស់។ សូមអនុញ្ញាតឲ្យខ្ញុំនិយាយបែបផ្ទាល់ខ្លួនជាងនេះគឺ ព្រះរាជ្យនៃព្រះ**របស់យើង**! យើងមិនគួរភ្ញាក់ផ្អើលទេ ព្រោះព្រះរាជ្យរបស់ទ្រង់ឧត្តមអស្ចារ្យលើសពីអ្វីដែលយើងអាចនឹកស្មានដល់។

គម្ពីរពេត្រុស ខ្សែទី២ ជំពូក១ ខ៣ ចែងថា៖

*ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ប្រទានឲ្យយើងមានអ្វីៗទាំងអស់ សម្រាប់ជីវិតរស់នៅ និងសម្រាប់គោរពប្រណិប័តន៍ព្រះអង្គ។*

នៅក្នុងសាច់រឿងទាំងប៉ុន្មានដែលយើងបានមើល ខ្ញុំសូមសួរសំណួរដ៏សំខាន់មួយ «តើនោះជាជម្រើសរបស់នរណា?» ខ្ញុំចង់មានន័យបែបនេះ៖ តើព្រះជាម្ចាស់នៅសុខៗ ស្រាប់តែប្រទានឆ្កែឲ្យទៅឃើស្វែន ឬត្រីទៅឌ្រិនដាជាភរិយារបស់ខ្ញុំឬ? តើនេះគ្រាន់តែជាព្រឹត្តិការណ៍ដែលព្រះជាម្ចាស់បានសម្រេចព្រះទ័យឲ្យបានកើត

ឡើងទៅតាមព្រះហឫទ័យដ៏ខ្ពង់ខ្ពស់របស់ទ្រង់សម្រាប់យើងឬ? ឬក៏មានហេតុផលដទៃទៀតដែលកិច្ចការទាំងនេះបានកើតឡើង? ខ្ញុំគិតថាចម្លើយទៅនឹងសំណួរនេះនឹងធ្វើឲ្យមនុស្សជាច្រើនភ្ញាក់ផ្អើល។ រូបខ្ញុំផ្ទាល់ក៏មានការភ្ញាក់ផ្អើលដែរ។

ដើម្បីឆ្លើយតបនឹងសំណួរនេះ ចូរយើងមើលសាច់រឿងមួយនៅក្នុងព្រះគម្ពីរដែលមាននៅក្នុងលូកា ជំពូក ៨៖

*ប៉ុន្តែពេលព្រះអង្គកំពុងយាងទៅ បណ្ដាជនបានប្រជ្រៀតព្រះអង្គ ហើយមានស្ត្រីម្នាក់មានជំងឺធ្លាក់ឈាមអស់រយៈពេលដប់ពីរឆ្នាំមកហើយ (នាងបានចំណាយទ្រព្យសម្បត្តិរបស់នាងទាំងអស់លើពួកគ្រូពេទ្យ) តែគ្មានអ្នកណាម្នាក់អាចព្យាបាលនាងជាឡើយ។ កាលបានចូលមកជិតពីខាងក្រោយ នាងបានពាល់រំយោលអាវរបស់ព្រះអង្គ ហើយនាងក៏បានឈប់ធ្លាក់ឈាមភ្លាម។*

*ព្រះយេស៊ូមានបន្ទូលថា៖ «តើនរណាបានពាល់ខ្ញុំ?» ពេលមនុស្សគ្រប់គ្នាកំពុងតែបដិសេធ លោកពេត្រុសក៏ទូលថា៖ «លោកគ្រូអើយ! បណ្ដាជនកំពុងប្រជ្រៀតជុំវិញលោក» ប៉ុន្តែព្រះយេស៊ូមានបន្ទូលថា៖ «មានអ្នកណាម្នាក់បានពាល់ខ្ញុំ ដ្បិតខ្ញុំដឹងថា អំណាចបានចេញពីខ្ញុំ»។*

*កាលស្ត្រីនោះដឹងថា នាងលាក់មិនជិត ក៏មកក្រាបទាំងភ័យញ័រនៅពីមុខព្រះអង្គ ហើយនាងរៀបរាប់ប្រាប់នៅចំពោះមុខមនុស្សទាំងអស់អំពីមូលហេតុដែលនាងបានពាល់ព្រះអង្គ និងអំពីរបៀបដែលនាងបានជាភ្លាមៗ*

*រួចព្រះអង្គមានបន្ទូលទៅនាងថា៖ «កូនស្រីអើយ! ជំនឿរបស់អ្នកបានធ្វើឲ្យអ្នកជាសះស្បើយហើយ ចូរទៅដោយសុខសាន្តចុះ»។*

លូកា ៨៖៤២-៤៨ (ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ)

ព្រះគម្ពីរបានបញ្ជាក់យ៉ាងច្បាស់ថា មានមនុស្សមកប្រជ្រៀតគ្នានៅជុំវិញព្រះអង្គ ហើយសូម្បីតែលោកពេត្រុសក៏មានការភ្ញាក់ផ្អើលនឹងសំណួររបស់ព្រះយេស៊ូថា «នរណាពាល់ខ្ញុំ?» ដែរ។ ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ ខ្ញុំចង់ដឹង គឺខ្ញុំពិតជាចាំបាច់ដឹងថា ហេតុអ្វីបានជាស្ត្រីនេះបានជា ហើយអ្នកដទៃទៀតពុំបានជា? ហេតុអ្វីបានជាការចាក់ប្រេងតាំងហូរទៅលើនាងតែម្នាក់ ហើយមិនហូរទៅលើអ្នកដទៃទៀតដែលបានប៉ះពាល់ព្រះអង្គនៅពេលនោះ? ចម្លើយគឺនៅត្រង់នេះ ប៉ុន្តែមុនពេលដែលខ្ញុំឆ្លើយសំណួរនោះ ចូរយើងសួរសំណួរមួយទៀត។ តើព្រះយេស៊ូមានចេតនាក្នុងការធ្វើព័ន្ធកិច្ចទៅកាន់នាងឬ? តើទ្រង់បានដាក់ដៃនៅលើនាងដែរឬទេ? ចម្លើយគឺទេ។ តាមពិត ព្រះយេស៊ូមិនបានទាំងជ្រាបថានាងនៅទីនោះផង។ ទ្រង់ចាំបាច់ត្រូវសួរថាតើនរណាបានទាញយកការចាក់ប្រេងតាំង ព្រោះទ្រង់មិនបានឃើញនាងទេ។ ដូច្នេះ តើនោះជាជម្រើសរបស់នរណាដែលនាងបានជាសះស្បើយនៅថ្ងៃនោះ?

សូមអនុញ្ញាតឲ្យខ្ញុំសួរបែបនេះវិញ។ តើព្រះជាម្ចាស់បានជ្រើសរើសប្រោសនាងឲ្យបានជានៅពេលនោះ ឬតើជាការសម្រេចចិត្តរបស់នាងក្នុងការទទួលពីព្រះជាម្ចាស់? នេះជាសំណួរដ៏សំខាន់ ព្រោះមានមនុស្សជាច្រើន «កំពុងតែរង់ចាំ» ឲ្យព្រះជាម្ចាស់ធ្វើកិច្ចការអ្វីម្យ៉ាងនៅក្នុងជីវិតរបស់គេ។ ខ្ញុំជឿថា ការដែលព្រះយេស៊ូមិនបានជ្រាបថានាងនៅទីនោះ បញ្ជាក់ថានេះជាការសម្រេចចិត្តរបស់នាងក្នុងការទទួល ហើយមិនមែនជាការសម្រេចចិត្តរបស់ព្រះយេស៊ូក្នុងការប្រោសនាងឲ្យបានជាឡើយ។

បើដូច្នេះមែន ការនេះបើកឲ្យយើងឃើញនូវការបើកសម្ដែងដ៏សំខាន់អស្ចារ្យ ហើយការបើកសម្ដែងនោះគឺដូច្នេះឯង៖ ព្រះជាម្ចាស់មិនជ្រើសរើសប្រោសមនុស្សមួយចំនួនឲ្យជា ហើយទុកមួយចំនួនទៀតឲ្យនៅឈឺទេ។ ទ្រង់បានប្រោសប្រទានឲ្យយើងអាចចូលទៅកាន់ការជាសះស្បើយតាមរយៈឋានៈស្របច្បាប់របស់យើងនៅក្នុងព្រះរាជ្យរបស់ទ្រង់ហើយ។ ដូច្នេះ តាមការជាក់ស្ដែង គឺយើងជាអ្នកជ្រើសរើស។

ប៉ុន្តែខ្ញុំចង់ដឹងថា តើនាងធ្វើយ៉ាងណាទើបបានទទួលឫទ្ធានុភាពនោះ? តើនាងបាន «សម្រេចចិត្ត» ទទួលការជាសះស្បើយដោយរបៀបណាទៅ? ព្រះយេស៊ូបានប្រាប់យើងយ៉ាងច្បាស់ពីរបៀបដែលនាងបានចូលទៅកាន់សិទ្ធិអំណាច និងឫទ្ធានុភាពនៃព្រះរាជ្យ។ ទ្រង់មានបន្ទូលថា «កូនស្រីអើយ! ជំនឿរបស់នាងបានសង្គ្រោះនាងហើយ សូមអញ្ជើញទៅដោយសុខសាន្តចុះ»។ ប្រយោគមួយនេះប្រាប់យើងនូវអ្វីៗដែលយើងត្រូវការដើម្បីស្គាល់ និងឆ្លើយសំណួរថា ហេតុអ្វីបានជានាងបានទទួលការជាសះស្បើយ ហើយអ្នកដទៃទៀតមិនបានទទួលវានៅថ្ងៃនោះ? ក្នុងនាមយើងជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ ចូរយើងពិនិត្យមើលកាន់តែលម្អិតនៅលើសាច់រឿងនេះ ក្រែងលោយើងបានតម្រុយខ្លះដែលជួយយើងឲ្យយល់ពីហេតុផលដែលនាងបានទទួល។

ជាបឋម ព្រះយេស៊ូហៅនាងថា «កូនស្រី» ដែលមានន័យថា នាងជាចំណែកនៃប្រជាជាតិអ៊ីស្រាអែល។ នោះមានន័យថា នាងមានសម្ពន្ធមេត្រីជាមួយព្រះជាម្ចាស់។ ឬលោកអ្នកអាចនិយាយបានថា នាងមានសិទ្ធិស្របច្បាប់នៅចំពោះស្ថានសួគ៌ ក្នុងនាមជាពលរដ្ឋអ៊ីស្រាអែល និងក្នុងការទទួលពីព្រះជាម្ចាស់។ តថភាពនេះមិនអាចជាហេតុផលតែម្យ៉ាងដែលនាងបានទទួលការជាសះស្បើយទេ ព្រោះមនុស្សគ្រប់ៗគ្នានៅថ្ងៃនោះដែលកំពុងតែប្រជ្រៀតគ្នាជុំវិញព្រះយេស៊ូក៏មានសិទ្ធិស្របច្បាប់ដូចគ្នា។ ប្រាកដជាមានអ្វីម្យ៉ាងដែលបានបណ្ដាលឲ្យឫទ្ធានុភាពនៃស្ថានសួគ៌ហូរមក។ បន្ទាប់មក ព្រះយេស៊ូប្រាប់យើងពីហេតុផលមួយទៀតដែលនាងបានទទួល។ តាមការពិត ព្រះយេស៊ូបានមានបន្ទូលថា នេះជាហេតុផលដែលនាងបានទទួលការជាសះស្បើយ។ ទ្រង់មានបន្ទូលថា ជំនឿរបស់នាងបានធ្វើឲ្យនាងជាសះស្បើយហើយ។

ដូច្នេះ នៅពេលនេះយើងបានដឹងពីហេតុផលដែលនាងអាចទទួលការជាសះស្បើយ។ ទីមួយ មានសិទ្ធិស្របច្បាប់ដើម្បីទទួលវា ព្រោះនាងជាកូនចៅលោកអប្រាហាំ ហើយទីពីរ ជំនឿរបស់នាងជាកុងតាក់ដែលបានអនុញ្ញាតឲ្យឫទ្ធានុភាព

នោះហូរមកលើរូបកាយរបស់នាងនៅពេលនោះតែម្តង។ ការដែលនាងជាពូជពង្ស របស់លោកអប្រាហាំ មានន័យថានាងឈរនៅចំពោះមុខស្ថានសួគ៌ដោយក្រោម សម្ពន្ធមេត្រីដែលព្រះជាម្ចាស់បានចងជាមួយលោកអប្រាហាំ អាចប្រៀបទៅនឹងក្រុម ហ៊ុនអគ្គិសនីដែលបើកឲ្យមានអគ្គិសនី ហើយតខ្សែភ្លើងចូលមកក្នុងផ្ទះរបស់លោក អ្នក។ ប៉ុន្តែ នោះមិនមានន័យថាអំពូលរបស់លោកអ្នកនឹងភ្លឺទេ។ លោកអ្នកក៏ ចាំបាច់ត្រូវបើកកុងតាក់ ដើម្បីឲ្យអំពូលភ្លើងភ្លឺ។ ដូច្នេះ នៅពេលនេះអ្វីដែលយើងត្រូវ ការគឺរកឲ្យឃើញថា តើកុងតាក់នៅត្រង់ណា ឬតើកុងតាក់ជាអ្វី។ ព្រះយេស៊ូបាន ហៅការនោះថាជាជំនឿរបស់នាង ប៉ុន្តែតើជំនឿជាអ្វី ហើយតើខ្ញុំបើកវាដោយរបៀប ណា? នេះជាសំណួរដ៏សំខាន់ដែលយើងចាំបាច់ពិចារណា។

## តើជំនឿជាអ្វី?

ជំនឿជាពាក្យមួយដែលគ្រិស្តបរិស័ទឧស្សាហ៍និយាយណាស់។ ហើយខ្ញុំជឿ ថា មានគ្រិស្តបរិស័ទជាច្រើនមិនបានដឹងថាតើជំនឿជាអ្វី ហេតុអ្វីបានជាយើងត្រូវ ការជំនឿ របៀបដែលដឹងថាតើពួកគេរស់នៅក្នុងជំនឿឬយ៉ាងណា និងរបៀបដែលរក ឃើញជំនឿឡើយ។ ប្រសិនបើជំនឿជាកុងតាក់ ហើយជួយឲ្យស្ត្រីនេះបានជាសះ ស្បើយ នោះយើងត្រូវមើលទៅកាន់ជំនឿយ៉ាងលម្អិតលម្អន់! យើងរកឃើញនិយម ន័យនៃជំនឿនៅគម្ពីររ៉ូម ៤៖១៨-២១។ អូហ៎ ខ្ញុំដឹងថាលោកអ្នកប្រាកដជាគិតយ៉ាង ណាហើយ គឺលោកអ្នកគិតថា «អត់ទេ លោកគ្រូហ្គារី។ ហេព្រើ ១១៖១ ទើបជានិយម ន័យនៃជំនឿ។»

*រីឯជំនឿ គឺជាការជឿជាក់លើអ្វីដែលបានសង្ឃឹម និងជាការប្រាកដអំពីអ្វី ដែលមើលមិនឃើញ។*

ហេព្រើ ១១៖១ (ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ)

មែនហើយ នោះជាចម្លើយបែបទំនៀមទម្លាប់ ប៉ុន្តែប្រសិនបើលោកអ្នកមើលទៅកាន់អត្ថបទគម្ពីរ ហេប្រឺ ១១៖១ កំពុងតែប្រាប់យើងពីអត្ថប្រយោជន៍នៃជំនឿ គឺមិនមែនជានិយមន័យនៃជំនឿឡើយ។ ខ្ញុំជឿថាអត្ថបទគម្ពីរនៅក្នុងគម្ពីររ៉ូមនឹងផ្តល់រូបភាពដ៏ច្បាស់លាស់អំពីនិយមន័យនៃជំនឿ។

*នៅពេលគាត់អស់សង្ឃឹម គាត់បានមានសង្ឃឹមឡើងវិញដោយសារគាត់មានជំនឿ ដូច្នេះហើយ គាត់បានត្រលប់ជាឪពុករបស់ជនជាតិជាច្រើន ស្របតាមសេចក្តីដែលបានសន្យាថា៖ «ពូជពង្សរបស់អ្នកនឹងបានដូច្នេះ»។ ទោះបីរូបកាយរបស់គាត់មានអាយុជិតមួយរយឆ្នាំ ដែលចាត់ទុកដូចជាស្លាប់ ហើយផ្ទៃរបស់សារ៉ាមិនអាចមានកូនក៏ដោយ ក៏ជំនឿរបស់គាត់មិនចុះខ្សោយឡើយ។ គាត់មិនបានសង្ស័យលើព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ដោយចិត្តមិនជឿនោះដែរ គឺគាត់កាន់តែមានជំនឿខ្លាំងឡើងថែមទៀត ទាំងថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ ហើយគាត់ជឿប្រាកដថា អ្វីដែលព្រះជាម្ចាស់បានសន្យា ព្រះអង្គក៏អាចធ្វើបានដែរ។*

រ៉ូម ៤៖១៨-២១ (ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ)

ចូរឲ្យយើងស្វែងយល់ពីស្ថានភាពនៃសាច់រឿងនេះ។ លោកអប្រាហាំ និងអ្នកស្រីសារ៉ាមិនអាចមានកូនបាន។ ខ្ញុំមិនមែនមានន័យថា ពួកគេមិនទាន់មានកូនហើយគួរតែព្យាយាមបន្តទៀតនោះទេ។ ខ្ញុំមានន័យថា អ្នកទាំងពីរមានអាយុជិត ១០០ ឆ្នាំ ហើយគឺហួសអាយុដែលមានកូនហើយ។ រូបកាយរបស់គេមិនអាចមានកូនបានទេ គឺមិនអាចទៅរួចឡើយ! ប៉ុន្តែ ព្រះជាម្ចាស់បានសន្យាទៅកាន់អប្រាហាំថាគាត់នឹងមានកូនម្នាក់ ទោះបីជាស្ថានភាពធម្មជាតិមិនអាចកើតឡើងក្តី។ ព្រះ

**«រីឯជំនឿ គឺជាការជឿជាក់លើអ្វីដែលបានសង្ឃឹម និងជាការប្រាកដអំពីអ្វីដែលមើលមិនឃើញ។»**

**- ហេប្រឺ ១១:១**

គម្ពីរចែងថា លោកអប្រាហាំជឿប្រាកដថាព្រះជាម្ចាស់មានឫទ្ធានុភាពនឹងធ្វើនូវអ្វីដែលទ្រង់មានបន្ទូល មិនថាស្ថានភាពខាងធម្មជាតិបង្ហាញអ្វីៗផ្សេងពីព្រះបន្ទូលទ្រង់ក៏ដោយ។ ដូច្នេះ នេះជានិយមន័យនៃជំនឿនៅក្នុងការសិក្សារបស់យើង៖ «ការជឿប្រាកដថាព្រះជាម្ចាស់មានឫទ្ធានុភាពធ្វើអ្វីដែលទ្រង់បានសន្យា។» ខ្ញុំសូមនិយាយបែបនេះ៖ **ជាការដែលយល់ស្របជាមួយនឹងស្ថានសួគ៌** មិនគ្រាន់តែមានអារម្មណ៍យល់ស្របទេ ប៉ុន្តែគឺជឿប្រាកដយល់ស្របទាំងស្រុង។ ដួងចិត្តរបស់យើងយល់ស្រប និងជឿជាក់អំពីអ្វីដែលព្រះជាម្ចាស់បានមានបន្ទូល មិនថាភពខាងធម្មជាតិបង្ហញអ្វីផ្សេងក៏ដោយ។

## និយមន័យរបស់យើងអំពីជំនឿ

ជំនឿជាការដែលជឿប្រាកដទាំងស្រុងអំពីអ្វីដែលព្រះជាម្ចាស់មានបន្ទូល! វាជាការដែលដួងចិត្ត និងគំនិតរបស់យើងយល់ស្របជាមួយស្ថានសួគ៌។ ដួងចិត្តរបស់យើងជឿប្រាកដ មានទំនុកចិត្ត និងនៅស្ងៀម។

## ហេតុអ្វីបានជាយើងត្រូវការជំនឿ?

ហេតុអ្វីបានជាព្រះជាម្ចាស់មិនគ្រាន់តែប្រោសអ្នកជំងឺគ្រប់រូបដែលនៅមន្ទីរពេទ្យឲ្យបានជា នៅពេលដែលទ្រង់ចង់ធ្វើការទៅ? ហេតុអ្វីបានជាទ្រង់មិនអាចបញ្ឈប់សង្គ្រាម? ហេតុអ្វីបានជាទ្រង់មិនអាចចាត់ទេវតាឲ្យមកប្រកាសដំណឹងល្អដល់យើង? ខ្ញុំប្រាកដថាលោកអ្នកពិតជាធ្លាប់បានឮសំណួរទាំងនេះពីមុនមក។ ចម្លើយគឺថាទ្រង់មិនអាចទេ។ ពាក្យនេះមិនមែនមានន័យថា ព្រះជាម្ចាស់អសមត្ថ

ភាពក្នុងការធ្វើដូច្នេះទេ ប៉ុន្តែទ្រង់មិនមានសិទ្ធិអំណាច ឬដែនសមត្ថកិច្ចដើម្បីធ្វើដូច្នេះ។ «លោកហ្គារី តើលោកកំពុងតែនិយាយថាព្រះជាម្ចាស់មិនអាចធ្វើអ្វីៗដែលទ្រង់ចង់ធ្វើមែនទេ?» ខ្ញុំដឹងថាពាក្យនេះស្តាប់ទៅគួរឲ្យចម្លែកណាស់ ប៉ុន្តែចូរយើងមើលទៅកាន់ព្រះគម្ពីរដើម្បីរកឃើញចម្លើយចំពោះសំណួរនេះ។

*ប៉ុន្តែមានម្នាក់បានធ្វើបន្ទាល់នៅកន្លែងមួយថា៖ «តើមនុស្សជាអ្វី បានជាព្រះអង្គនឹកចាំពីគេ តើកូនមនុស្សជាអ្វី បានជាព្រះអង្គយកព្រះហឫទ័យទុកដាក់ចំពោះគេ?*

*ព្រះអង្គបានធ្វើឲ្យគេទាបជាងពួកទេវតាតែបន្តិចប៉ុណ្ណោះ ព្រះអង្គបានប្រទានសិរីរុងរឿង និងកិត្តិយសដល់គេទុកជាមកុដ ព្រះអង្គបានបង្ក្រាបអ្វីៗទាំងអស់ឲ្យនៅក្រោមជើងរបស់គេ»។*

ហេប្រឺ ២៖៦-៨ (ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ)

យើងអាចឃើញតាមរយៈអត្ថបទគម្ពីរនេះថា ព្រះជាម្ចាស់បានប្រទាននូវដែនសមត្ថកិច្ចពេញលេញដល់មនុស្សនៅលើភពផែនដី ជាកន្លែងដែលទ្រង់បានដាក់មនុស្សឲ្យរស់នៅ។ ពុំមានអ្វីដែលនៅក្រៅដែនសមត្ថកិច្ចរបស់មនុស្សឡើយ។ គាត់បានត្រួតត្រានៅលើភពផែនដីនេះដោយដែនសមត្ថកិច្ច និងសិទ្ធិអំណាចផ្តាច់មុខ។ ការដែលគាត់មានសមត្ថភាពត្រួតត្រាដោយសិទ្ធិអំណាចបែបនេះ គឺត្រូវបានគាំទ្រដោយរាជរដ្ឋាភិបាលដែលបានដាក់គាត់នៅទីនេះ។ និយាយឲ្យចំ គាត់បានត្រួតត្រាដោយសិទ្ធិអំណាចនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលត្រូវបានផ្ទេរមកដល់ខ្លួន។ គាត់ពាក់មកុដនៃរាជរដ្ឋាភិបាលនោះ ដែលតំណាងឲ្យសិរីរុងរឿងរបស់ព្រះជាម្ចាស់ ការចាក់ប្រេងតាំង និងមុខតំណែងកិត្តិយសដែលគាត់មាន។

ដើម្បីឲ្យយើងបានឃើញពីរូបភាពនេះកាន់តែច្បាស់ សូមគិតអំពីស្តេចមួយអង្គនៅលើផែនដី។ ថ្វីបើទ្រង់ជាស្តេចដែលមានលក្ខណៈជាមនុស្ស ហើយពុំមានអំណាចអស្ចារ្យក្តី (ដោយព្រោះទ្រង់ក៏ជាមនុស្សដែរ) តែទ្រង់គ្រងមកុដដែលបញ្ជាក់ថាទ្រង់មិនគ្រាន់តែតំណាងឲ្យអង្គទ្រង់ផ្ទាល់ ប៉ុន្តែក៏តំណាងឲ្យព្រះរាជ្យនគរទាំងមូល និងរាជរដ្ឋាភិបាលរបស់ទ្រង់ដែរ។ ព្រះបន្ទូលរបស់ទ្រង់មានអំណាច ដោយព្រោះនៅពេលដែលទ្រង់មានបន្ទូលគឺមានអំណាច និងធនធានធម្មជាតិរបស់រាជរដ្ឋាភិបាល ព្រមទាំងនគរដែលទ្រង់តំណាងឲ្យនោះជាអ្នកគាំទ្រ។

ប្រសិនបើលោកអ្នកគិតពីនគរបាលសម្រួលចរាចរណ៍ គាត់នឹងបញ្ជាឡានកុងតឺន័រធំមួយថា «ចូរឈប់ភ្លាមនៅចំពោះមុខច្បាប់។» មែនហើយ ឡានកុងតឺន័រធំជាងបុរសនោះឆ្ងាយណាស់ ហើយបុរសនោះផ្ទាល់ពុំមានកម្លាំងស្មើនឹងឡាននោះទេ ប៉ុន្តែឡានប្រាកដជាឈប់។ វាមិនមែនឈប់ដោយសារតែបុរសនោះទេ ប៉ុន្តែគឺដោយសារតែស្លាកដែលនគរបាលពាក់នៅលើអាវ។ នៅក្នុងករណីនេះ រដ្ឋាភិបាលគឺធំជាងបុរសដែលពាក់ស្លាកនគរបាលឆ្ងាយណាស់។ សម្រាប់អ្នកបើកឡានកុងតឺ-ន័រវិញ គាត់មិនខ្លាចបុរសនោះទេ ប៉ុន្តែគាត់កោតខ្លាចដល់រដ្ឋាភិបាលដែលនគរបាលនោះតំណាងឲ្យ។ វាក៏ជាការពិតដូចគ្នាទៅនឹងការសិក្សារបស់យើង។ លោកអដាំបានត្រួតត្រានៅលើអ្វីៗទាំងប៉ុន្មានដែលព្រះជាម្ចាស់បានបង្កើតមកលើផែនដី។ ឫទ្ធានុភាព និងការត្រួតត្រារបស់ព្រះជាម្ចាស់ ដែលតំណាងដោយមកុដនៃសិរីរុងរឿង និងកិត្តិយសផ្តល់ឲ្យបុរសនោះនូវការធានាអះអាងដែលថាពាក្យរបស់គាត់មានអំណាច ឬត្រួតត្រាជំនួសឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់។

ជាការសំខាន់ក្នុងការកត់ចំណាំថា នៅពេលដែលអដាំបានបាត់បង់សមត្ថភាពក្នុងការត្រួតត្រានៅលើផែនដី ដោយក្បត់នឹងរាជរដ្ឋាភិបាលរបស់ព្រះជាម្ចាស់ គាត់បានបាត់មកុដរបស់ខ្លួន។ ភពផែនដីបានប្រែជាខូច ហើយផ្លាស់ប្តូរ។ សេចក្តីស្លាប់បានចូលមកកាន់ផែនដី ហើយមារសាតាំងមានសិទ្ធិអំណាចនិងឥទ្ធិពលស្របច្បាប់នៅលើកិច្ចការរបស់មនុស្ស។ ជាការចាំបាច់ដែលលោកអ្នកក៏ត្រូវតែយល់

ថាមនុស្សនៅតែជាអ្នកត្រួតត្រាស្របច្បាប់លើភពផែនដី គឺដូចទៅនឹងអ្វីដែលព្រះជាម្ចាស់បានដាក់គាត់មក ប៉ុន្តែនៅពេលនេះគាត់លែងមានសិទ្ធិអំណាចត្រួតត្រានៅលើភពខាងវិញ្ញាណដូចមុនទៀតហើយ។ ទោះបីជាស្ថិតនៅក្នុងស្ថានភាពដែលបានធ្លាក់ចុះក្តី គាត់នៅតែជាអ្នកគ្រប់គ្រងលើផែនដី។ មែនហើយ គាត់លែងមានមកុដនៃរាជរដ្ឋាភិបាលរបស់ព្រះជាម្ចាស់ដើម្បីគាំទ្រ។ គាត់លែងមានសិទ្ធិអំណាចដើម្បីត្រួតត្រាដោយឫទ្ធានុភាព និងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ គាត់បានបាត់បង់មុខតំណែងកិត្តិយស។ ប៉ុន្តែគាត់នៅតែជាទ្វារស្របច្បាប់តែមួយមកកាន់ភពផែនដី។ ហេតុនេះហើយបានជាព្រះជាម្ចាស់ចាំបាច់ប្រើប្រាស់មនុស្សដែលពេញដោយព្រះវិញ្ញាណ ដើម្បីនាំយកនូវព្រះហឫទ័យរបស់ទ្រង់មកកាន់ជីវិតរបស់មនុស្ស។ នៅក្នុងរបៀបដូចគ្នា មារសាតាំងប្រើប្រាស់មនុស្សដែលបានរងឥទ្ធិពលពីអារក្សដើម្បីជះឥទ្ធិពលដល់ភពផែនដី និងសម្រេចផែនការរបស់វានៅលើជីវិតមនុស្ស។ គោលការណ៍នៃដែនសមត្ថកិច្ចរបស់មនុស្សនៅលើភពផែនដីនេះ ជាការសំខាន់ដែលអ្នកត្រូវយល់ទាក់ទងនឹងព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយនៅពេលដែលលោកអ្នកបានយល់ពីគោលការណ៍នេះហើយ នោះវានឹងឆ្លើយនូវសំណួរជាច្រើនដែលលោកអ្នកមាននាពេលខាងមុខ ថាហេតុអ្វីបានជាមានរឿងនេះ ឬរឿងនោះកើតឡើង ឬហេតុអ្វីបានជាមានរឿងមួយកើតឡើង ឬមិនបានកើតឡើងនៅក្នុងភពខាងវិញ្ញាណ។

**ហេតុនេះហើយបានជាព្រះជាម្ចាស់ចាំបាច់ប្រើប្រាស់មនុស្សដែលពេញដោយព្រះវិញ្ញាណដើម្បីនាំយកនូវព្រះហឫទ័យរបស់ទ្រង់មកកាន់ជីវិតរបស់មនុស្ស។**

លោកអ្នកប្រហែលថា «ប៉ុន្តែ ខ្ញុំគិតថាព្រះជាម្ចាស់ជាម្ចាស់នៃផែនដី និងអ្វីៗដែលមាននៅលើផែនដី?» ជាការពិត គឺទ្រង់។ ខ្ញុំសង្ឃឹមថាឧទាហរណ៍នេះនឹងជួយលោកអ្នកឲ្យយល់ពីអត្ថន័យរបស់ខ្ញុំ។ ប្រសិនបើខ្ញុំជួលផ្ទះរបស់ខ្ញុំឲ្យលោកអ្នក ទោះបីជាខ្ញុំជាម្ចាស់ផ្ទះស្របច្បាប់ក្តី ក៏ខ្ញុំបានលះបង់សិទ្ធិស្របច្បាប់ក្នុងការដែលខ្ញុំ

ចេញចូលផ្ទះនោះពេលណាក៏បាន។ មានលក្ខខណ្ឌនៅក្នុងកិច្ចសន្យាជួលផ្ទះភាគច្រើនដែលបញ្ជាក់ថា ម្ចាស់ផ្ទះអាចចូលក្នុងបរិវេណផ្ទះដែលត្រូវបានជួលនោះ ឧទាហរណ៍ដូចជាដោះស្រាយជាមួយនឹងបញ្ហាបន្ទាន់ ឬធ្វើការជួសជុល ហើយតម្រូវឲ្យគាត់ប្រាប់ដល់អ្នកជួលជាមុនក្នុងពេលជាក់លាក់ដែរ។ ប្រសិនបើខ្ញុំព្យាយាមចូលក្នុងផ្ទះនោះក្រៅពីកិច្ចសន្យា ខ្ញុំនឹងត្រូវបានចាត់ទុកថាគាស់ផ្ទះចូល ទោះបីជាខ្ញុំជាម្ចាស់ដី និងផ្ទះនោះក្ដី។ ប្រសិនបើខ្ញុំល្មើសនឹងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា ខ្ញុំអាចនឹងត្រូវគេបណ្ដេញចេញពីផ្ទះនោះភ្លាមទាំងស្របច្បាប់ ទោះបើខ្ញុំជាម្ចាស់ផ្ទះនោះក្ដី។ ឧទាហរណ៍នេះពន្យល់ថាហេតុអ្វីបានជាមារសាតាំងចាំបាច់ត្រូវឆ្លងកាត់លោកអដាំ ដើម្បីឲ្យមានសិទ្ធិនៅលើភពផែនដី។ មានតែលោកអដាំប៉ុណ្ណោះដែលមានកូនសោ! មារសាតាំងចាំបាច់ត្រូវឆ្លងកាត់លោកអដាំ ដែលជាទ្វារសិន។ ប្រសិនបើមារសាតាំងព្យាយាមដើរវាងពីអដាំដែលជាទ្វារ នោះវានឹងត្រូវបានបណ្ដេញចេញដោយស្របច្បាប់ជាមិនខាន។

*អារក្សសាតាំងក៏នាំព្រះអង្គទៅ ហើយបង្ហាញឲ្យព្រះអង្គឃើញនគរទាំងអស់នៅក្នុងពិភពលោកក្នុងមួយរយៈពេលដ៏ខ្លី ហើយអារក្សសាតាំងទូលព្រះអង្គថា៖ «ខ្ញុំនឹងឲ្យសិទ្ធិអំណាច ព្រមទាំងសិរីរុងរឿងនៃនគរទាំងអស់នោះដល់អ្នក ដ្បិតទាំងអស់នោះត្រូវបានប្រគល់មកឲ្យខ្ញុំហើយ ខ្ញុំចង់ឲ្យទៅអ្នកណាក៏បាន ដូច្នេះប្រសិនបើអ្នកថ្វាយបង្គំខ្ញុំ នោះអ្វីៗទាំងអស់នឹងក្លាយជារបស់អ្នកហើយ»។*

លូកា ៤៖៥-៧ (ព្រះគម្ពីរគ្រិស្ដបរិស័ទខ្មែរ)

អ្នកអាចឃើញតាមរយៈខគម្ពីរនេះថា មារសាតាំងប្រកាសថាសិទ្ធិអំណាច និងសិរីរុងរឿង (ភោគទ្រព្យ) នៃនគរនានារបស់មនុស្ស ត្រូវបានប្រគល់ដល់វា

ហើយ។ តើនរណាបានប្រគល់សិទ្ធិអំណាចទាំងនេះដល់វា? គឺជាអ្នកដែលបានកាន់កាប់សិទ្ធិអំណាចនោះ គឺលោកអដាំ! ហេតុដូច្នេះហើយ ព្រះជាម្ចាស់មិនអាចគ្រាន់តែលូកដៃក្នុងកិច្ចការរបស់មនុស្សដោយមិនបានឆ្លងកាត់ទ្វារស្របច្បាប់សិនទេ។ ប្រសិនបើទ្រង់ធ្វើដូច្នេះមែន នោះមារសាតាំងនឹងថាព្រះជាម្ចាស់ធ្វើខុសច្បាប់មិនខាន។ អត់ទេ ព្រះជាម្ចាស់ចាំបាច់ត្រូវចូលទៅតាមទ្វារដដែលដែលមារសាតាំងបានប្រើប្រាស់ដើម្បីនាំនូវរដ្ឋាភិបាល និងសិទ្ធិអំណាចរបស់ទ្រង់មកកាន់ផែនដី ហើយទ្វារនោះគឺមនុស្ស។ ប៉ុន្តែតើមានមនុស្សបែបនេះទេ?

> *ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកអាប់រ៉ាមថា៖ «ចូរចាកចេញពីស្រុករបស់អ្នក ចាកចេញពីញាតិសន្តាន និងចាកចេញពីក្រុមគ្រួសារឪពុករបស់អ្នក តម្រង់ឆ្ពោះទៅស្រុកដែលយើងនឹងបង្ហាញអ្នក ។ យើងនឹងឲ្យប្រជាជាតិមួយដ៏ធំកើតចេញពីអ្នក ហើយយើងនឹងឲ្យពរអ្នក។ យើងនឹងធ្វើឲ្យអ្នកមានឈ្មោះល្បី។ ដូច្នេះ ចូរធ្វើជាអ្នកផ្តល់ពរដល់អ្នកដទៃចុះ!។ យើងនឹងឲ្យពរដល់ជនទាំងឡាយណាដែលឲ្យពរអ្នក យើងក៏នឹងដាក់បណ្តាសាដល់ជនទាំងឡាយណា ដែលដាក់បណ្តាសាអ្នកដែរ <u>ក្រុមគ្រួសារទាំងអស់នៅលើផែនដីនឹងបានទទួលពរដោយសារអ្នក</u>» ។*
>
> លោកុប្បត្តិ ១២៖១-៣ (ព្រះគម្ពីរខ្មែរបច្ចុប្បន្ន)

លោកអប្រាហាំត្រូវបានហៅថាជាឪពុកនៃជំនឿរបស់យើងរាល់គ្នា ដោយសារតែគាត់ជាមនុស្សម្នាក់ដែលបានបើកទ្វារនៃភពផែនដីសម្រាប់ព្រះជាម្ចាស់ ជាតិសាសន៍ទាំងប៉ុន្មានបានទទួលពរតាមរយៈគាត់។ ជាការពិតណាស់ នៅពេលដែលខនេះចែងអំពីការដែលជាតិសាសន៍នានាបានទទួលពរ ខនេះចែងអំពីព្រះយេស៊ូ

**«ដូច្នេះ ជំនឿកើតមកពីសេចក្ដីដែលយើងបានស្ដាប់ រីឯសេចក្ដីដែលយើងបានស្ដាប់នោះកើតមកពីព្រះបន្ទូលរបស់ព្រះគ្រិស្ដ ។»**

- **រ៉ូម ១០:១៧**

គ្រិស្តដែលនឹងរៀបចំផ្លូវសម្រាប់រដ្ឋាភិបាលរបស់ព្រះជាម្ចាស់ឲ្យអាចមានសិទ្ធិស្របច្បាប់ម្តងទៀតនៅលើភពផែនដីតាមរយៈជំនឿរបស់លោកអប្រាហាំ។ ជំនឿរបស់លោកអប្រាហាំបានបើកទ្វារស្របច្បាប់សម្រាប់ស្ថានសួគ៌ ដែលព្រះជាម្ចាស់បានបើកទ្វារនេះទាំងស្រុងដោយធ្វើកិច្ចព្រមព្រៀងស្របច្បាប់ (សម្ពន្ធមេត្រី) ជាមួយលោកអប្រាហាំ និងកូនចៅ ឬអ្នកស្នងមរតកពីគាត់។

សូមអនុញ្ញាតឲ្យខ្ញុំបកស្រាយអ្វីដែលខ្ញុំនិយាយ។ រាជរដ្ឋាភិបាលនៃស្ថានសួគ៌អាចចូលមកកាន់ផែនដីបានតាម
រយៈបុរស ឬស្ត្រីនៅលើផែនដីប៉ុណ្ណោះ ព្រោះពួកគេមានដែនសមត្ថកិច្ចស្របច្បាប់នៅទីនេះ។ ភាពស្របច្បាប់នេះអាចសម្រេចបានលុះត្រាតែបុរស ឬស្ត្រីនោះជឿប្រាកដនៅក្នុងចិត្តពីអ្វីដែលព្រះជាម្ចាស់មានបន្ទូល (ជំនឿ)។

យើងអាចនិយាយបានម្យ៉ាងទៀតថា ស្ថានសួគ៌អាចប៉ះពាល់ដល់បុរស ឬស្ត្រីណាម្នាក់នៅលើភពផែនដីដោយស្របច្បាប់បាន លុះត្រាតែពួកគេមានបំណង ព្រមទាំងជ្រើសរើសចុះចូលនឹងការត្រួតត្រា និងសិទ្ធិអំណាចរបស់ព្រះជាម្ចាស់។ នេះក៏ជាគោលការណ៍ដដែលដែលមារសាតាំងបានប្រើដើម្បីឲ្យមានសិទ្ធិត្រួតត្រាផែនដី គឺដោយប្រើប្រាស់លោកអដាំផ្ទាល់។ វាបានបញ្ចុះបញ្ចូលឲ្យអដាំជឿថាព្រះជាម្ចាស់មិនគួរឲ្យទុកចិត្ត ហើយបង្វែរចិត្តអដាំឲ្យងាកចេញពីការយល់ស្របនឹងព្រះជាម្ចាស់។ ជាលទ្ធផល លោកអដាំបានជ្រើសរើសជឿមារសាតាំង ហើយបដិសេធសិទ្ធិអំណាចរបស់ព្រះជាម្ចាស់។

នេះជាគោលការណ៍ដដែលដែលព្រះជាម្ចាស់ប្រើប្រាស់នាពេលនេះ ដើម្បីនាំរាជរដ្ឋាភិបាល និងសិទ្ធិអំណាចរបស់ទ្រង់ត្រលប់មកកាន់ភពផែនដីវិញតាមរយៈ

លោកអប្រាហាំ។ លោកអប្រាហាំបានជឿលើព្រះជាម្ចាស់ និងការយល់ស្របរបស់គាត់ត្រូវបានព្រះជាម្ចាស់រាប់ថាសុចរិត មានន័យថាគឺមានការព្រមព្រៀងស្របច្បាប់ដែលគេត្រូវការហើយ។ ការព្រមព្រៀងដោយភាគីទាំងសងខាងនេះ គឺរវាងព្រះជាម្ចាស់ និងលោកអប្រាហាំបានអនុញ្ញាតឲ្យព្រះជាម្ចាស់ដាក់នូវកិច្ចសន្យាស្របច្បាប់ (សម្ពន្ធមេត្រី) នៅលើលក្ខខណ្ឌមួយដែលធានាថាស្ថានសួគ៌មានសិទ្ធិស្របច្បាប់នៅលើភពផែនដី។ ប៉ុន្តែ ជាការចាំបាច់ដែលយើងត្រូវកត់សម្គាល់ថា សម្ពន្ធមេត្រីនេះមានសុពលភាពតែនៅលើលោកអប្រាហាំ និងពូជពង្សរបស់លោកប៉ុណ្ណោះ ដែលនោះគឺជាការកាត់ស្បែក។ ការកាត់ស្បែកសំដៅលើការកាត់ស្បែកចុងលិង្គរបស់មនុស្សប្រុស។ នៅពេលដែលបុរសបង្ហូរពូជ (មេជីវិត) របស់គាត់ទៅក្នុងរាងកាយរបស់ស្ត្រី មេជីវិតរបស់គាត់ត្រូវតែឆ្លងកាត់តាមរយៈលិង្គដែលត្រូវបានកាត់ស្បែកនោះ ដែលជាការប្រកាសដល់មារសាតាំង និងបុគ្គលជាឪពុកម្តាយនោះថានៅចំពោះស្ថានសួគ៌ ក្មេងនេះមានឋានៈជាអ្នកស្នងមរតកដែលរួមក្នុងកិច្ចព្រមព្រៀងស្របច្បាប់ដែលព្រះជាម្ចាស់បានចងជាមួយលោកអប្រាហាំ។

ទោះជាយ៉ាងណាក៏ដោយ តាមដែលយើងបានអាននៅមុននេះ បុរសឬស្ត្រីនីមួយៗ ទោះបីជាពួកគេមានកិច្ចព្រមព្រៀងនោះ ដែលត្រូវបានរៀបចំសម្រាប់ខ្លួនក្តី ក៏តែចាំបាច់ត្រូវបំពេញតាមលក្ខខណ្ឌច្បាប់ គឺជាការដែលគេជឿប្រាកដនៅក្នុងចិត្តអំពីអ្វីដែលព្រះជាម្ចាស់មានបន្ទូល ដើម្បីឲ្យគេអាចទទួលបានប្រយោជន៍ពីកិច្ចព្រមព្រៀងដែលព្រះជាម្ចាស់ និងលោកអប្រាហាំចងដែរ។ និយាយរួមទៅ សម្ពន្ធមេត្រីប្រៀបបាននឹងខ្សែភ្លើងដែលតភ្ជាប់ទៅដល់ផ្ទះរបស់ពួកគេ ប៉ុន្តែពួកគេនៅតែចាំបាច់ចុចកុងតាក់ដោយជឿ និងប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ផ្ទាល់។

មែនហើយ នៅពេលនេះយើងបានយល់ហើយថាជំនឿជាអ្វី ហើយហេតុអ្វីបានជាយើងត្រូវការជំនឿបើគិតតាមច្បាប់។ នៅពេលនេះ ជាការសំខាន់ដែលយើងដឹងពីរបៀបទទួលជំនឿ និងរបៀបដើម្បីឲ្យដឹងថាតើយើងពិតជាមានជំនឿមែន។

## តើយើងទទួលបានជំនឿដោយរបៀបណា?

នេះជាតម្រុយ៖ យើងមិនអាចអធិស្ឋានទូលសុំជំនឿបានទេ។ ភ្ញាក់ផ្អើលមែនទេ? ខ្ញុំក៏គិតអញ្ចឹងដែរ។

*ដូច្នេះ ជំនឿកើតមកពីសេចក្តីដែលយើងបានស្តាប់ រីឯសេចក្តីដែលយើងបានស្តាប់នោះកើតមកពីព្រះបន្ទូលរបស់ព្រះគ្រិស្ត ។*

រ៉ូម ១០៖១៧ (ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ)

តើជំនឿកើតឡើងដោយការស្តាប់ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយរបៀបណា? តើមានតែប៉ុណ្ណឹងឬ? តើវាមានដំណើរការបែបណា? តើគ្រាន់តែស្តាប់ឮព្រះបន្ទូលនោះនឹងបណ្តាលឲ្យមានជំនឿរីកចម្រើនឡើងនៅក្នុងវិញ្ញាណរបស់មនុស្សឬ? ដើម្បីស្វែងយល់ពីរបៀបដែលជំនឿកើតឡើង និងអ្វីដែលគម្ពីររ៉ូម ១០៖១៧ ចែង យើងអាចមើលទៅកាន់ម៉ាកុសជំពូក៤។ ជំពូកនេះជាជំពូកដ៏សំខាន់! ព្រះយេស៊ូមានព្រះបន្ទូលនៅម៉ាកុស ៤៖១៣។ ប្រសិនបើលោកអ្នកមិនយល់ពីអ្វីដែលទ្រង់កំពុងតែបង្រៀននៅក្នុងជំពូកនេះទេ នោះលោកអ្នកក៏នឹងមិនអាចយល់ពីប្រស្នាផ្សេងៗទៀតនៅក្នុងព្រះគម្ពីរបានដែរ។ ខ្ញុំសូមនិយាយថា នោះជាការសំខាន់ណាស់!

ហេតុអ្វីបានជាជំពូកនេះសំខាន់ម្ល៉េះ? គឺដោយសារតែជំពូកនេះប្រាប់យើងពីរបៀបដែលស្ថានសួគ៌ធ្វើការទាក់ទងជាមួយនឹងភពផែនដី របៀបដែលស្ថានសួគ៌ទទួលបានសិទ្ធិស្របច្បាប់ និងទីកន្លែងដែលហេតុការណ៍នេះកើតឡើង។ ពុំមានអ្វីដែលសំខាន់សម្រាប់ជីវិតរបស់លោកអ្នកជាងការដែលយល់ពីជំពូកទាំងមូលទេ។ លោកអ្នកប្រហែលជាសួរថា «តើព្រះរាជ្យរបស់ព្រះជាម្ចាស់មានប្រតិបត្តិការដោយរបៀបណាទៅ?» សូមអានម៉ាកុស ជំពូក ៤! នៅក្នុងជំពូកនេះ ព្រះយេស៊ូប្រាប់យើងពីប្រស្នាបីដែលទាក់ទងនឹងរបៀបដែលជំនឿកើតឡើងនៅក្នុងវិញ្ញាណរបស់មនុស្ស

គឺដូចដែលលោកអ្នកបានដឹងនៅពេលនេះហើយថា យើងត្រូវការជំនឿដើម្បី ឲ្យស្ថានសួគ៌មានអំណាចនៅលើផែនដីដោយស្របច្បាប់។

នៅក្នុងសាច់រឿងទាំងបីនៃជំពូកនេះ មានដូចជាប្រស្នាអំពីពូជស្រូវ ប្រស្នាអំពីគ្រាប់ពូជដុះ និងប្រស្នាអំពីគ្រាប់ពូជល្អិត (ឬគ្រាប់មូតា)។

ចូរយើងចាប់ផ្តើមដោយពិនិត្យមើលសាច់រឿងទីពីរដែលព្រះយេស៊ូមានបន្ទូលប្រាប់នៅម៉ាកុស ជំពូក ៤ សិន គឺជាសាច់រឿងអំពីគ្រាប់ពូជដុះ។

*ព្រះអង្គមានបន្ទូលទៅគេថា៖ «នគរព្រះជាម្ចាស់ប្រៀបបាននឹងមនុស្សម្នាក់ ព្រោះគ្រាប់ពូជទៅលើដី ហើយគាត់ដេកនៅពេលយប់ ក្រោកឡើងនៅពេលថ្ងៃ គាត់មិនបានដឹងថា គ្រាប់ពូជនោះចេញពន្លកដុះឡើងតាមរបៀបណាទេ។ ដីបង្កើតផលដោយខ្លួនឯង មុនដំបូងជាពន្លក បន្ទាប់មក ចេញជាកួរ ហើយក្រោយមកទៀតចេញជាគ្រាប់ស្រូវពេញលេញ ប៉ុន្តែនៅពេលស្រូវទុំ គាត់ក៏យកកណ្តៀវមកច្រូតភ្លាម ព្រោះដល់រដូវច្រូតកាត់ហើយ»។*

ម៉ាកុស ៤៖២៦-២៩ (ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ)

មុនពេលដែលយើងពិនិត្យមើលលើអត្ថបទគម្ពីរនេះ ចូរយើងស្វែងយល់ពីនិយមន័យនៃពាក្យគន្លឹះសិន។ តើគ្រាប់ពូជដែលព្រះយេស៊ូមានបន្ទូល គឺសំដៅលើអ្វី? ចុះដីវិញ? តាមពិត ព្រះយេស៊ូកំណត់និយមន័យនៃពាក្យទាំងនោះនៅក្នុងប្រស្នាមុនៗអំពីអ្នកសាបព្រោះគ្រាប់ពូជនៅក្នុងជំពូកដដែល។ គ្រាប់ពូជតំណាងឲ្យព្រះបន្ទូល ហើយដីតំណាងឲ្យចិត្តរបស់មនុស្ស ឬវិញ្ញាណរបស់មនុស្ស។ ដូច្នេះ នៅក្នុងប្រស្នានេះ ដោយប្រើប្រាស់និយមន័យរបស់ព្រះយេស៊ូផ្ទាល់អំពីពាក្យទាំងពីរនេះ យើងអាចនិយាយបានថា ព្រះយេស៊ូកំពុងមានបន្ទូលថា មានបុរសម្នាក់សាបព្រោះ

ព្រះបន្ទូលចូលមកក្នុងដួងចិត្តរបស់គាត់។ បន្ទាប់មក ដី ឬដួងចិត្តរបស់គាត់ក៏បង្កើតផលជាជំនឿ (ការយល់ស្របជាមួយនឹងស្ថានសួគ៌) នៅក្នុងភពផែនដី។

មុនពេលដែលខ្ញុំបន្តទៅមុខ ជាការចាំបាច់ដែលលោកអ្នកចាំពីនិយមន័យរបស់យើងស្ដីអំពីជំនឿ៖ ជាដួងចិត្តរបស់បុរស ឬស្ត្រីដែលជឿប្រាកដជាក់ច្បាស់ពីអ្វីដែលស្ថានសួគ៌ថ្លែង។ អត្ថបទគម្ពីរនេះប្រាប់យើងថា ទោះបីជាមនុស្សមិនដឹងថាធ្វើការនេះដោយរបៀបណាក្ដី ក៏ព្រះបន្ទូលដែលត្រូវបានសាបព្រោះចូលទៅក្នុងចិត្តរបស់គាត់បានចាប់ផ្ដើមដុះឡើង ហើយបង្កើតជាការព្រមព្រៀងដោយខ្លួនឯងដែរ។ មិនថាគាត់គេងលក់ ឬភ្ញាក់ ការនេះនៅតែកើតឡើង។ វាមិនសំខាន់ទេ ដំណើរការនៃព្រះបន្ទូលនឹងចម្រើនឡើងជានិច្ច។ នៅពេលដែលបុរសនេះរក្សាព្រះបន្ទូលនៅក្នុងចិត្ត បន្តិចម្ដងៗដួងចិត្តរបស់គាត់បានយល់ស្របជាមួយនឹងអ្វីដែលស្ថានសួគ៌ប្រកាស ហើយក៏បង្កើតបានជាជំនឿ។

គម្ពីរម៉ាកុស ជំពូក ៤ ដែលយើងទើបតែបានអានប្រាប់យើងថា ដួងចិត្តរបស់មនុស្សបង្កើតឲ្យមានការយល់ស្របជាមួយនឹងស្ថានសួគ៌តាមរយៈដំណើរការមួយ។ សាច់រឿងខាងលើប្រាប់យើងថា លើកដំបូង នៅពេលដែលដួងចិត្តរបស់យើងបានទទួលព្រះបន្ទូល នោះជំនឿក៏ចាប់ផ្ដើមកកើតឡើង។ ព្រះយេស៊ូប្រៀបធៀបឃ្លានេះទៅនឹងការដុះពន្លក។ ពន្លកក៏ដុះឡើង ហើយបន្តរហូតដល់បែកចេញជាកួរ។ មិនយូរប៉ុន្មាន ស្រូវក៏ផើម ប៉ុន្តែទោះបីដល់ដំណាក់កាលចុងក្រោយនេះក្ដី ក៏មិនទាន់មានផលផ្លែ ការយល់ស្រប និងការផ្លាស់ប្ដូរនៅលើភពខាងធម្មជាតិនៅឡើយដែរ។ បន្ទាប់មក ព្រះយេស៊ូមានបន្ទូលថាដំណើរការនេះក៏បន្តរហូតដល់ស្រូវដែលផើមនោះមានគ្រាប់ពេញលក្ខណៈ។ នៅពេលដែលដំណើរការឈានដល់ចំណុចនោះ គឺនៅពេលមានគ្រាប់ស្រូវពេញលក្ខណៈ គឺមានន័យថាគេមាននូវការយល់ស្របហើយក៏មានជំនឿនៅទីនោះដែរ ដែលអាចអនុញ្ញាតឲ្យបុរស ឬស្ត្រីធ្វើការច្រូតកាត់នូវអ្វីដែលស្ថានសួគ៌បានដាំនៅក្នុងចិត្តរបស់មនុស្សលើភពផែនដីនេះ។

សូមយកចិត្តទុកដាក់នៅត្រង់នេះ។ ចូរឲ្យយើងពិនិត្យលើអ្វីដែលបានកើតឡើងពិតប្រាកដវិញ។ ស្ថានសួគ៌សាបព្រោះព្រះបន្ទូលរបស់ព្រះជាម្ចាស់ចូលមកកាន់ភពផែនដី គឺចូលមកកាន់ដួងចិត្តរបស់បុរស និងស្ត្រីដែលត្រូវការការយល់ស្រប។ នៅពេលនោះ ដួងចិត្តរបស់មនុស្សគឺមិនទាន់បានយល់ស្របជាមួយនឹងស្ថានសួគ៌នៅឡើយទេ ប៉ុន្តែដំណើរការនេះបានកើតឡើងនៅក្នុងដួងចិត្តមនុស្ស ហើយនាំឲ្យចិត្តមនុស្សធ្វើការយល់ស្របជាមួយនឹងអ្វីដែលស្ថានសួគ៌បានសាបព្រោះដោយខ្លួនឯង។ ព្រះយេស៊ូប្រើប្រាស់ឧទាហរណ៍ដ៏អស្ចារ្យនេះដើម្បីបង្ហាញយើងពីដំណើរការនេះ។ ដោយប្រៀបធៀបដំណើរការនេះទៅនឹងកសិករសាបព្រោះគ្រាប់ពូជ និងរបៀបដែលដំណាំដុះលូតលាស់រហូតដល់ប្រមូលផល ព្រះយេស៊ូផ្តល់ឲ្យយើងនូវរូបភាពពីជំនឿ។ នៅក្នុងភពខាងធម្មជាតិ នៅពេលដែលស្រូវដែលដាក់គ្រាប់នោះពេញលក្ខណៈហើយ វានឹងមាន**<u>រូបរាងដូច</u>**គ្រាប់ស្រូវដែលត្រូវបានសាបព្រោះទៅក្នុងដីអញ្ចឹង។ សូមអនុញ្ញាតឲ្យខ្ញុំនិយាយម្តងទៀត។

**នៅពេលដែលស្រូវដែលដាក់គ្រាប់នោះពេញលក្ខណៈហើយ វានឹងមាន<u>រូបរាងដូច</u>គ្រាប់ស្រូវដែលត្រូវបានសាបព្រោះទៅក្នុងដីអញ្ចឹង។**

ប្រសិនបើលោកអ្នកដាំពោត នៅពេលដែលផ្លែពោតធំពេញគ្រាប់ គ្រាប់នោះនឹងដូចជាគ្រាប់ដែលលោកអ្នកបានដាំ។ ទាំងគ្រាប់ដែលបានសាបព្រោះ និងគ្រាប់ដែលចេញពីផ្លែគឺមានលក្ខណៈដូចគ្នា មានរូបរាងដូចគ្នា និងមានរសជាតិដូចគ្នា។ ពុំមានអ្វីដែលខុសគ្នារវាងគ្រាប់ទាំងពីរនេះឡើយ វាគឺមានលក្ខណៈដូចគ្នាបេះបិត។

ដូច្នេះ សូមអនុញ្ញាតឲ្យខ្ញុំបកស្រាយនូវអ្វីដែលព្រះយេស៊ូមានព្រះបន្ទូល។ នៅពេលដែលយើងឮព្រះបន្ទូល (រ៉ូម ១០៖១៧) មានន័យថាយើងកំពុងសាបព្រោះព្រះបន្ទូលចូលមកក្នុងវិញ្ញាណ និងដួងចិត្តរបស់យើង។ ប្រសិនបើយើងរក្សាព្រះបន្ទូលនោះនៅក្នុងចិត្ត ព្រះបន្ទូលនឹងចម្រើនឡើងពេញលក្ខណៈ ហើយនៅពេលដែលព្រះបន្ទូលចម្រើនបានពេញលក្ខណៈ រូបភាពនៅក្នុងដួងចិត្តរបស់យើង (ភពផែនដី) នឹងស្របទៅតាមអ្វីដែលស្ថានសួគ៌ថ្លែង។ ប្រសិនបើយើងនិយាយម្យ៉ាងទៀត គឺនៅ

ពេលដែលអ្នកសាបព្រោះព្រះបន្ទូលសន្យាណាមួយពីស្ថានសួគ៌ចូលមកកាន់ដួងចិត្តរបស់លោកអ្នក នោះព្រះបន្ទូលនោះនឹងបង្កើតជាទំនុកចិត្តនៅលើអ្វីដែលព្រះជាម្ចាស់មានបន្ទូលដោយខ្លួនឯង។ មិនយូរប៉ុន្មាន ដួងចិត្តរបស់លោកអ្នកនឹងជឿជាក់ប្រាកដពីអ្វីដែលស្ថានសួគ៌ថ្លែង ហើយការយល់ស្របនឹងកើតឡើង។ ឧទាហរណ៍ ប្រសិនបើលោកអ្នកកំពុងតែមានជំងឺ កាលៈទេសៈនៅក្នុងរូបកាយលោកអ្នកកំពុងប្រាប់លោកអ្នកថា លោកអ្នកឈឺហើយ។ នៅពេលដែលលោកអ្នកសាបព្រោះព្រះបន្ទូលដែលប្រកាសថាព្រះជាម្ចាស់បានបង់ថ្លៃសម្រាប់ការជាសះស្បើយរបស់លោកអ្នកតាមរយៈកិច្ចការដែលព្រះយេស៊ូបានធ្វើ នោះដួងចិត្តរបស់លោកអ្នកនឹងចាប់ផ្តើមជឿប្រាកដនូវអ្វីដែលព្រះជាម្ចាស់មានបន្ទូល ដោយឯកឯងបន្តិចម្តងៗ។

នៅពេលដែលព្រះបន្ទូលចម្រើនឡើងពេញលក្ខណៈនៅក្នុងដួងចិត្តរបស់លោកអ្នក នោះទំនុកចិត្តថាលោកអ្នកបានជាសះស្បើយ នឹងប្រែក្លាយជាអ្វីដែល **លោកអ្នក**ជឿ និងប្រកាសចេញមក។ លោកអ្នកលែងគ្រាន់តែដកស្រង់នូវអ្វីដែលស្ថានសួគ៌ថ្លែង យកមកនិយាយទៀតហើយ។ នៅពេលនេះ គឺដួងចិត្តរបស់អ្នកជឿជាក់យ៉ាងប្រាកដ។ នៅពេលដែលលោកអ្នកនិយាយថា «ខ្ញុំបានជាសះស្បើយ» ពាក្យនេះមិនមែនជារូបមន្តដែលលោកអ្នកលើកយកមកនិយាយទេ ប៉ុន្តែវាជាអ្វីដែលលោកអ្នកជឿ ហើយដឹងថាជាការពិត។ អ្វីដែលស្ថានសួគ៌និយាយ បានក្លាយជាទស្សនៈរបស់លោកអ្នកស្តីអំពីភាពពិតជាក់ស្តែង។

ហេតុនេះហើយបានជាគម្ពីរហេប្រឺ ១១៖១ ចែងថា៖

*រីឯជំនឿ គឺជាការជឿជាក់លើអ្វីដែលបានសង្ឃឹម និងជាការប្រាកដអំពីអ្វីដែលមើលមិនឃើញ។*

មានការធានាអះអាងដ៏អស្ចារ្យអំពីអ្វីដែលស្ថានសួគ៌ប្រកាស នៅពេលដែលជំនឿមានសកម្មភាព។ យ៉ាងណាមិញ នៅក្នុងដំណើរការនេះនៅមានជំហានមួយទៀត។

នៅពេលនេះ មនុស្សត្រូវតែយកកណ្ដៀវមកច្រូត ដែលសំដៅលើការនាំឲ្យអ្វីដែលគាត់ប្រាកដជាក់ច្បាស់នៅក្នុងចិត្ត បានកើតឡើងនៅលើជីវិតជាក់ស្ដែង។

*ប៉ុន្តែនៅពេលស្រូវទុំ **<u>គាត់ក៏យកកណ្ដៀវមកច្រូតភ្លាម</u>** ព្រោះដល់រដូវច្រូតកាត់ហើយ»។*

ម៉ាកុស ៤៖២៩ (ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ)

សូមកត់ចំណាំថា ទោះបីជាមនុស្សមានដួងចិត្តដែលយល់ស្របជាមួយនឹងស្ថានសួគ៌ ហើយសេចក្តីពិតនៃស្ថានសួគ៌បានក្លាយជាសេចក្តីពិតរបស់បុរស ឬស្ត្រីនោះក្ដី ក៏ពុំទាន់មានការផ្លាស់ប្ដូរពិតប្រាកដកើតឡើងនៅលើភពខាងរូបកាយដែរ។ ដោយសារតែមនុស្សជាអ្នកដែលមានដែនសមត្ថកិច្ចនៅលើភពផែនដីនេះ គាត់ជាមនុស្សតែម្នាក់ដែលចាំបាច់ស្រាយសិទ្ធិអំណាចនៃស្ថានសួគ៌នោះ ចូលមកកាន់ពិភពរបស់គាត់។ ព្រះជាម្ចាស់មិនអាចធ្វើកិច្ចការនោះបានដោយគ្មានបុរស ឬស្ត្រីទេ។ ខ្ញុំអាចបង្ហាញលោកអ្នកពីសេចក្តីនេះនៅក្នុងអត្ថបទគម្ពីរមួយដែលយើងបានឮជាញឹកញាប់ ហើយក៏បានពិភាក្សានៅគ្រាមុនដែរ។

*ដ្បិតបើចិត្តយើងជឿ យើងនឹង**<u>បានសុចរិត</u>** ហើយបើមាត់យើង**<u>ប្រកាស</u>**ជំនឿនោះយើងនឹងទទួលការសង្គ្រោះ។*

រ៉ូម ១០៖១០

ការដែលមនុស្សជឿលើព្រះបន្ទូលនៅក្នុងចិត្ត បង្កើតឲ្យមានជំនឿ ហើយគេបានសុចរិត។ ភាពសុចរិតជាពាក្យបែបច្បាប់ដែលសំដៅលើរដ្ឋបាលនៃច្បាប់។ ដូច្នេះ នៅពេលដែលដួងចិត្តរបស់មនុស្សម្នាក់យល់ស្របជាមួយស្ថានសួគ៌ ហើយគាត់ជឿប្រាកដនៅក្នុងចិត្តពីអ្វីដែលស្ថានសួគ៌ប្រកាស នោះគាត់បានសុចរិត។ នៅពេលនេះ ជាការស្របច្បាប់ក្នុងការដែលស្ថានសួគ៌ហូរចូលមកក្នុងជីវិតរបស់គាត់ និងចូលមកក្នុងភពផែនដី។ ប៉ុន្តែការដែលបានសុចរិតតែម្យ៉ាងមិនស្រាយនូវឫទ្ធានុភាពរបស់ព្រះជាម្ចាស់ទេ។ គឺដូចជាផ្ទះដែលបានភ្ជាប់អគ្គិសនីពីស្ថាននីយ៍អគ្គិសនីរួចហើយក្តី ក៏មានជំហានមួយទៀតដែលគេត្រូវធ្វើ នោះគឺចុចកុងតាក់បើកដើម្បីស្រាយឫទ្ធានុភាពរបស់ព្រះជាម្ចាស់មក ហើយភ្លើងក៏នឹងភ្លឺ។ ហេតុអ្វីទៅ? ដោយសារតែគម្ពីររ៉ូម ១០៖១០ បង្ហាញមកកាន់យើងថា មានជំហានមួយទៀតបន្ទាប់ពីបានរាប់ជាសុចរិតហើយ។

បុរសស្ត្រីដែលឈរនៅចំពោះស្ថានសួគ៌ និងផែនដីក្នុងនាមជាមនុស្សសុចរិតក៏ត្រូវប្រកាស ឬប្រព្រឹត្តដោយតាមការយល់ស្របនោះ ដើម្បីស្រាយឫទ្ធានុភាព និងការចាក់ប្រេងតាំងរបស់ព្រះជាម្ចាស់ចូលមកកាន់ភពផែនដី។ សូមអានខគម្ពីរនោះម្តងហើយម្តងទៀតរហូតដល់លោកអ្នកយល់ពីអ្វីដែលខ្ញុំកំពុងនិយាយទាំងស្រុង។ នេះជារបៀបដែលវាដំណើរការ! នេះជារបៀបដែលស្ថានសួគ៌បានទទួលនូវសិទ្ធិស្របច្បាប់នៅលើភពផែនដី ដែលដួងចិត្តរបស់យើងផ្សារភ្ជាប់ស្ថានសួគ៌មកកាន់ផែនដី ហើយពាក្យសម្តី និងសកម្មភាពរបស់យើងជាកុងតាក់ដែលស្រាយនូវឫទ្ធានុភាពនៃស្ថានសួគ៌។ សូមយកចិត្តទុកដាក់ឲ្យមែនទែនលើខនោះ៖ យើងជាអ្នកដែលចាំបាច់ស្រាយសិទ្ធិអំណាចនៃស្ថានសួគ៌មកលើផែនដីនេះ។

គោលគំនិតនៃការដែលស្ថានសួគ៌រង់ចាំបុរសស្ត្រីណាម្នាក់ក្នុងការផ្តល់នូវសិទ្ធិស្របច្បាប់ ហើយទីពីរគឺផ្តល់ដែនសមត្ថកិច្ចនៅលើភពផែនដីនេះ អាចស្តែងឡើងតាមរយៈព្រះបន្ទូលរបស់ព្រះយេស៊ូនៅក្នុងគម្ពីរម៉ាថាយ ជំពូក ១៦ និងជំពូក ១៨។

*ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នករាល់គ្នាចងទុកអ្វីៗនៅផែនដី នោះនឹងត្រូវចងទុកនៅស្ថានសួគ៌ដែរ ហើយបើស្រាយអ្វីៗនៅផែនដី នោះក៏នឹងត្រូវស្រាយនៅស្ថានសួគ៌ដែរ។*

ម៉ាថាយ ១៨៖១៨ (ព្រះគម្ពីរបរិសុទ្ធ)

ព្រះយេស៊ូមានបន្ទូលត្រង់ខនេះថា ទ្រង់នឹងប្រទានដល់ក្រុមជំនុំនូវកូនសោ (សិទ្ធិអំណាច) នៃព្រះរាជ្យនៃស្ថានបរមសុខនៅក្នុងភពផែនដី។ ទ្រង់មានបន្ទូលថា បើអ្នករាល់គ្នាចងទុកអ្វីៗនៅផែនដី នោះនឹងត្រូវបានចងទុកនៅស្ថានសួគ៌ដែរ ហើយបើស្រាយអ្វីៗនៅផែនដី នោះក៏នឹងត្រូវបានស្រាយនៅស្ថានសួគ៌ដែរ។ ជាថ្មីម្តងទៀត សូមគិតពីមន្ត្រីនគរបាលម្នាក់។ គាត់មានសិទ្ធិអំណាច ប៉ុន្តែរាជរដ្ឋាភិបាលជាអ្នកមានអំណាច។ មន្ត្រីនគរបាលមានកូនសោ ឬសិទ្ធិអំណាចនៃរាជរដ្ឋាភិបាល ព្រោះគាត់បានសច្ចាថាជាអ្នកតំណាងឲ្យរាជរដ្ឋាភិបាលនោះ។ ពាក្យទាំងប៉ុន្មានដែលគាត់ស្រដី មានរាជរដ្ឋាភិបាលជាអ្នកគាំទ្រ។ សូមចាំថា មានតែបុរស ឬស្ត្រីប៉ុណ្ណោះដែលមានដែនសមត្ថកិច្ចស្របច្បាប់នៅលើផែនដីនេះ ហើយហេតុដូច្នេះហើយ មានតែបុរស ឬស្ត្រី ប៉ុណ្ណោះដែលអាចប្រគល់ដែនសមត្ថកិច្ចស្របច្បាប់នោះដល់ស្ថានសួគ៌។

**នេះជារបៀបដែលស្ថានសួគ៌បានទទួលនូវសិទ្ធិស្របច្បាប់នៅលើភពផែនដី ដែលដួងចិត្តរបស់យើងផ្សារភ្ជាប់ស្ថានសួគ៌មកកាន់ផែនដី ហើយពាក្យសម្តី និងសកម្មភាពរបស់យើងជាកុងតាក់ដែលស្រាយនូវឫទ្ធានុភាពនៃស្ថានសួគ៌។**

មានចំណុចដ៏សំខាន់មួយទៀតដែលលោកអ្នកចាំបាច់ត្រូវតែដឹងអំពីជំនឿ។ សូមអនុញ្ញាតឲ្យខ្ញុំលើកយកខគម្ពីរនៅក្នុងម៉ាកុសជំពូក ៤ មកនិយាយមួយភ្លែត។

***ដ្បិតដីធ្វើឲ្យពូជបង្កើតផលដោយខ្លួនឯង** ដំបូងមានពន្លកលេចឡើង បន្ទាប់មក ក៏បែកជាគួរ ហើយចេញជាគ្រាប់ស្រូវ។*

ម៉ាកុស ៤៖២៨ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

សូមចាំថា ព្រះយេស៊ូបានប្រាប់ថាដីនៅក្នុងរឿងប្រស្នានេះតំណាងឲ្យដួងចិត្តរបស់មនុស្ស ឬវិញ្ញាណរបស់មនុស្ស ដូចដែលខ្ញុំបានលើកឡើងពីខាងដើម។ សូមកត់ចំណាំត្រង់កន្លែងដែលជំនឿត្រូវបានបង្កើតឡើង តើវាធ្វើឲ្យលោកអ្នកភ្ញាក់ផ្អើលដែរឬទេ? វាមិនមែនជាផលិតផលរបស់ស្ថានសួគ៌ ដូចដែលមនុស្សភាគច្រើនជឿទេ ប៉ុន្តែវាត្រូវបានបង្កើតឡើងនៅលើផែនដីនេះ ហើយគឺជាសមិទ្ធផលនៃចិត្តរបស់លោកអ្នក។ លោកអ្នកមិនអាចអធិស្ឋានឲ្យបានជំនឿ ឬទូលសុំព្រះជាម្ចាស់ឲ្យប្រទានជំនឿទេ។ ព្រះជាម្ចាស់មិនត្រូវការជំនឿនៅស្ថានសួគ៌ឡើយ។ យើងក៏នឹងមិនត្រូវការការយល់ស្របនៅស្ថានសួគ៌ដែរ។ អត់ទេ យើងត្រូវការជំនឿនៅលើផែនដីនេះប៉ុណ្ណោះ ហើយជំនឿអាចកើតឡើងនៅក្នុងដួងចិត្តរបស់បុរស និងស្ត្រីដែលនៅលើផែនដីនេះ។ ដូចដែលប្រស្នានៅម៉ាកុស ៤ បង្រៀន មានរបៀបតែមួយដើម្បីឲ្យបានជំនឿ គឺដោយការដាក់ព្រះបន្ទូលរបស់ព្រះជាម្ចាស់មកក្នុងដួងចិត្តរបស់លោកអ្នក ហើយអនុញ្ញាតឲ្យដំណើរការនៃការយល់ស្របនោះកើតឡើង។ ដូច្នេះ ប្រសិនបើខ្ញុំត្រូវការជំនឿ តើខ្ញុំនឹងធ្វើអ្វី? ខ្ញុំនឹងសាបព្រោះព្រះបន្ទូលចូលមកកាន់ដួងចិត្ត ហើយអនុញ្ញាតឲ្យព្រះបន្ទូលដុះឡើងរហូតដល់មានជំនឿ។ នេះឯងជារបៀបតែមួយដែលជំនឿកើតឡើង។

មុនពេលដែលយើងចាកចេញពីម៉ាកុស ជំពូក ៤ ខ្ញុំចង់និយាយអំពីកណ្ដៀវដែលត្រូវបានលើកឡើងនៅត្រង់ខនោះម្តងទៀត។

*ប៉ុន្តែនៅពេលស្រូវទុំ* ***<u>គាត់ក៏យកកណ្ដៀវមកច្រូតភ្លាម</u>*** *ព្រោះដល់រដូវច្រូតកាត់ហើយ»។*

ម៉ាកុស ៤៖២៩ (ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ)

ខ្ញុំជឿថានៅក្នុងពិភពគ្រិស្តបរិស័ទ គ្មាននរណាបានបង្រៀនពីរបៀបប្រើប្រាស់កណ្ដៀវទេ។ មានន័យថា ពួកគេពុំមាននរណាបង្រៀនអំពីរបៀបច្រូតនូវអ្វីដែលគេត្រូវការឡើយ។ ក្រុមជំនុំជាទូទៅត្រូវបានបង្រៀនពីរបៀបថ្វាយតង្វាយ ប៉ុន្តែមិនបានទទួលការបង្រៀនពីរបៀបបណ្ដុះ និងច្រូតកាត់ពីគ្រាប់ពូជដែលគេបានសាបព្រោះឡើយ។ ព្រះយេស៊ូមានបន្ទូលបញ្ជាក់យ៉ាងជាក់លាក់នៅខនេះថា នៅពេលដល់រដូវចម្រូតនៃជំនឿរបស់យើងហើយ **យើង**ត្រូវតែយកកណ្ដៀវទៅច្រូត។ ទោះបីជាយើងប្រហែលជាធ្វើបានល្អនៅក្នុងការស្រោយគ្រាប់ពូជរបស់យើងដោយជំនឿក្ដី តែបើយើងមិនចេះពីរបៀបកាន់កណ្ដៀវច្រូតទេនោះ នោះយើងនឹងមិនបានទទួលផលពីចម្រូតឡើយ។ និយាយឲ្យចំទៅ ខ្ញុំក៏មិនបានយល់ពីការនេះដែរ រហូតដល់ព្រះអម្ចាស់បានចាប់ផ្ដើមបង្រៀនខ្ញុំពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ធ្វើប្រតិបត្តិការ។ សូមអនុញ្ញាតឲ្យខ្ញុំផ្ដល់ឧទាហរណ៍មួយចំនួនទៀតអំពីតថភាពនេះ។

ខ្ញុំត្រូវបានគេអញ្ជើញឲ្យទៅបង្រៀននៅក្នុងក្រុមជំនុំមួយនៅទីក្រុងអាត្លង់តា។ ពេលនោះជាការប្រជុំក្រុមជំនុំល្ងាចថ្ងៃពុធ ហើយក្រុមជំនុំក៏មិនសូវជាធំណាស់ណាដែរ ប៉ុន្តែខ្ញុំមិនមានបញ្ហាអីទេ។ ខ្ញុំពេញចិត្តក្នុងការបង្រៀនមនុស្សអំពីព្រះរាជ្យ។ នៅពេលដែលខ្ញុំទៅដល់ក្រុមជំនុំ ខ្ញុំបានឃើញថាជាការចម្លែកណាស់ដែលទ្វារជាប់សោ ហើយពុំមាននរណានៅទីនោះឡើយ។ នៅពេលនោះគឺសល់តែ ១០នាទីប៉ុណ្ណោះការប្រជុំនឹងចាប់ផ្ដើម។ ខ្ញុំបានឮឡានមួយបើកពីក្រោយខ្ញុំដោយសំឡេងលាន់ឮៗ ស្ដាប់ទៅដូចជាគ្មានបំពង់ស៊ីម៉ាំងទាល់តែសោះ។ នៅពេលដែលខ្ញុំក្រឡេកមើលទៅ ក៏ឃើញឡានដឹកទំនិញដ៏ចាស់មួយគ្រឿង ដែលខូចខ្ទេចខ្ទីកំពុង

តែបើកមកចតនៅខាងក្រោយច្រកផ្លូវក្រុមជំនុំ។ ខ្ញុំមិនបានខ្វល់ពីវាទេ ណាមួយដឹងថាខ្ញុំកំពុងនៅក្នុងទីប្រជុំជននៃក្រុងអាត្លង់តាហើយ។ នៅពេលដែលខ្ញុំកំពុងតែរង់ចាំ មានបុរសម្នាក់បានដើរពីក្រោយអគារក្រុមជំនុំ ហើយណែនាំខ្លួនគាត់ថាជាគ្រូគង្វាល។ គាត់ពោលថា គាត់សុំទោសក្នុងការដែលមកយឺត ប៉ុន្តែឡានចាស់នេះបញ្ឆេះមិនឆេះសោះ។ គាត់បានប្រាប់ខ្ញុំថា ដើម្បីឲ្យឡាននេះឆេះ គាត់ត្រូវរុញឡាននេះ ហើយបើកសសៀរៗតាមជម្រាលភ្នំ បន្ទាប់មកពេលដែលវាទៅលឿនគួរសមហើយ នោះគាត់ក៏ជាន់អំប្រាយ៉ាស ដោយសារតែដុំដេរខូច។ គាត់បាននិយាយថា មានពេលជាច្រើនលើកឡាននោះមិនឆេះទាល់តែសោះ ហើយគាត់ត្រូវដើរចម្ងាយផ្លូវប្រមាណជា ៨ គីឡូម៉ែត្រមកកាន់ក្រុមជំនុំ។

នៅពេលដែលគាត់បន្តប្រាប់ខ្ញុំពីក្រុមជំនុំរបស់គាត់ គាត់បានប្រាប់ខ្ញុំថា ទោះបីជាគាត់ជាគ្រូគង្វាលប្រចាំក្រុមជំនុំក្តី តែព័ន្ធកិច្ចសំខាន់របស់ក្រុមជំនុំគឺចែកអាហារដល់មនុស្សដែលនៅក្នុងទីក្រុង។ ពួកគេចែកអាហារដល់មនុស្សជាង ១០000 នាក់នៅក្នុងមួយខែនៅកន្លែងនោះ។ នៅពេលដែលគ្រូគង្វាលកំពុងតែនិយាយ ខ្ញុំប្រែជាមិនសប្បាយចិត្ត។ ខ្ញុំគិតថា នេះជាវីរៈបុរសរបស់ព្រះជាម្ចាស់ដែលចែកអាហារដល់មនុស្សជាង ១០000 នាក់ក្នុងមួយខែ ប៉ុន្តែមិនមានសូម្បីតែឡានល្អផង? គាត់គឺជារូបភាពតែមួយតំណាងឲ្យព្រះជាម្ចាស់ ដែលមនុស្សទទួលអាហារពីគាត់នោះបានឃើញ។ ប្រសិនបើគេឃើញថាគាត់រកប្រាក់សឹងតែមិនបានផងហើយត្រូវដើរមកក្រុមជំនុំជាង ៨ គីឡូម៉ែត្រនៅក្នុងអាកាសធាតុជាង ៣៨ អង្សារសេ តើអាចឲ្យពួកគេមានទំនុកចិត្តថាព្រះជាម្ចាស់អាចជួយពួកគេបានដោយរបៀបណា? ខ្ញុំអាចជួយគាត់បាន។ ខ្ញុំមានឡានមួយដែលទើបតែជិះបាន ៣២២០០ គីឡូម៉ែត្រនៅឯផ្ទះ ដែលអាចជូនដល់គាត់។ ខ្ញុំបានប្រាប់គាត់ពីផែនការរបស់ខ្ញុំ ហើយខ្ញុំក៏នឹងចាត់បុគ្គលិកម្នាក់បើកឡាននោះមកឯក្រុងអាត្លង់តា។ ជាការពិតណាស់ គាត់ពិតជារំភើបមែនទែន។ ខ្ញុំបានចំណាយពេលពេញមួយយប់នោះ

បង្រៀនគាត់ និងក្រុមជំនុំតូចរបស់គាត់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងរបៀបដែលព្រះរាជ្យប្រតិបត្តិការទាក់ទងនឹងលុយកាក់។

នៅពេលដែលខ្ញុំត្រលប់ទៅផ្ទះវិញ ខ្ញុំក៏បានរៀបចំឲ្យគេបើកឡានមកក្រុងអាត្លង់តា។ នៅពេលដែលបុគ្គលិករបស់ខ្ញុំមកយកឡាននៅឯផ្ទះខ្ញុំ ខ្ញុំដឹងថាខ្ញុំកំពុងតែធ្វើប្រតិបត្តិការខាងវិញ្ញាណនៅឯស្ថានសួគ៌។ ខ្ញុំដឹងថា នៅពេលដែលខ្ញុំស្រាយឡាននោះចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ខ្ញុំអាចជឿលើព្រះជាម្ចាស់សម្រាប់ឡានដែលខ្ញុំត្រូវការដែរ។ ខ្ញុំមិនមែនជាមនុស្សស្រឡាញ់ឡានទេ ដែលមានន័យថាខ្ញុំមិនមែនជាអ្នកដែលពេញចិត្ត ឬតាមដានម៉ូតឡាននោះឡើយ។ មានមនុស្សមួយចំនួនមានលក្ខណៈបែបនេះ ប៉ុន្តែខ្ញុំមិនមែនទេ។ ឡានគ្រាន់តែជាឧបករណ៍សម្រាប់ខ្ញុំប៉ុណ្ណោះ។ ខ្ញុំពេញចិត្តក្នុងការដែលមានឡានស្អាត ប៉ុន្តែជាទូទៅខ្ញុំជិះឡានទាល់តែដាំខ្ទីម។

នៅពេលដែលបុគ្គលិករបស់ខ្ញុំមកដល់ ខ្ញុំក៏បានចូលទៅក្នុងយានដ្ឋានហើយដាក់ដៃនៅលើឡាននោះទាំងនិយាយថា «ព្រះបិតា ខ្ញុំសូមស្រាយឡាននេះចូលទៅកាន់កិច្ចការនៃព័ន្ធកិច្ចរបស់ទ្រង់ ហើយនៅពេលដែលខ្ញុំថ្វាយឡាននេះទៅ ខ្ញុំក៏ទទួលបានឡានមួយមកវិញដែរ...» ខ្ញុំស្ទាក់ស្ទើរ។ ខ្ញុំដឹងថា ព្រះរាជ្យរបស់ព្រះជាម្ចាស់មានភាពជាក់លាក់យ៉ាងណា ហើយខ្ញុំដឹងថាគ្រាន់តែប្រើពាក្យថា «ឡាន» គឺមិនបង្ហាញពីភាពជាក់លាក់ទេ។ ខ្ញុំក៏បានដឹងដែរថា ខ្ញុំចាំបាច់ត្រូវតែមានភាពជាក់លាក់ ហើយឌ្រិនដានិងខ្ញុំត្រូវតែព្រមព្រៀងគ្នានៅលើភាពជាក់លាក់នៃអ្វីដែលយើងបានទទួល។ នៅពេលដែលខ្ញុំឈរនៅទីនោះ ភ្លាមៗនោះខ្ញុំក៏បានដឹងថា ខ្ញុំមិនទាន់ដឹងច្បាស់ពីឡានដែលខ្ញុំចង់បាននៅឡើយទេ។ ដូច្នេះ ខ្ញុំក៏ប្រកាសម្តងទៀតថា «ព្រះអម្ចាស់អើយថ្ងៃនេះខ្ញុំសូមស្រាយឡាននេះចូលទៅកាន់ព័ន្ធកិច្ចរបស់ទ្រង់ ហើយខ្ញុំជឿថាខ្ញុំទទួលបានឡានដ៏ល្អមួយគ្រឿងដូចដែលខ្ញុំបានសាបព្រោះ ប៉ុន្តែខ្ញុំសូមប្រាប់ទ្រង់តាមក្រោយពីម៉ូដែល និងប្រភេទឡាននៅពេលដែលខ្ញុំដឹងហើយ។»

គឺប៉ុណ្ណឹងឯង ហើយខ្ញុំក៏ឲ្យឡាននោះទៅ។ ខ្ញុំមិនមានឡានអ្វីដែលខ្ញុំនឹកឃើញហើយថា «ហ្នឹងហើយ គឺឡានហ្នឹងហើយ!» នៅឡើយទេ។

រយៈពេលជាច្រើនខែក៏បានកន្លងផុតទៅ។ ជាការពិតណាស់ ឌ្រិនដានិងខ្ញុំបានព្រមព្រៀងគ្នានៅពេលដែលយើងបរិច្ចាគឡាននោះ ហើយនាងក៏ដូចជាខ្ញុំដែរ ដែលយើងទាំងពីរមិនដឹងថាយើងចង់បានឡានអ្វីនោះទេ។ នៅក្នុងពេលពីរខែក្រោយមក យើងបាននិយាយអំពីឡាន ហើយនៅចុងបញ្ចប់ ថ្ងៃមួយនាងបាននិយាយថា «បងដឹងទេ អូនគិតថាអូនចង់បានឡានដែលអាចបើកដំបូលបាន។» ខ្ញុំក៏បានប្រាប់នាងថា ខ្ញុំយល់ស្របហើយបន្ថែមថា ស្តាប់ទៅពិតជាសប្បាយណាស់។ ប៉ុន្តែតើម៉ូដែលអ្វីដែរ។ នៅលើកនេះទៀត យើងមិនបានទាំងដឹងថាតើមានឡានបើកដំបូលបានប្រភេទអ្វីខ្លះ ដែលកំពុងដាក់លក់នៅលើទីផ្សារនោះទេ។ ប៉ុន្តែថ្ងៃមួយនៅពេលដែលយើងកំពុងបើកឡានទៅញ៉ាំអាហារថ្ងៃត្រង់ ភរិយារបស់ខ្ញុំស្រាប់តែឧទានឡើងថា «ហ្នឹងហើយ!» ខ្ញុំពោលថា «ស្អីគេអូន?» «គឺហ្នឹងហើយ!» នាងនិយាយបណ្តើរ ដៃចង្អុលទៅកន្លែងចតឡាននៅឯភោជនីយដ្ឋានដែលយើងកំពុងតែរកកន្លែងចត។ ខ្ញុំថា «តើស្អី អូន?» «ឡាននោះឯង នោះឯងជាឡានដែលអូនចង់បាន!» បន្ទាប់មក ខ្ញុំក៏ឃើញឡានបើកដំបូលបានដ៏ស្អាតមួយគ្រឿង ចតនៅក្នុងចំណតរថយន្ត។ ខ្ញុំក៏ថា «តោះយើងទៅមើលថាឡាននោះម៉ាកអ្វីដែរ។» ដូច្នេះ យើងក៏បើកទៅជិតឡាននោះ ហើយចតនៅក្រោយវា។

មែនហើយ អញ្ចឹងបានជាយើងពេញចិត្តនឹងវា។ វាជាឡានម៉ាក BMW 645Ci ជាឡានបើកដំបូលបានដ៏ស្រស់ស្អាត ហើយក៏ជាឡានដែលថ្លៃក្រាស់ក្រែលដែរ។ បើនិយាយតាមត្រង់ទៅ នៅពេលដែលខ្ញុំបានឃើញឡាននោះ ខ្ញុំគិតក្នុងចិត្តថា «បាទ ព្រះអម្ចាស់អើយ សូមបង្ហាញថាតើយើងគួរធ្វើអ្វីខ្លះ។» ខ្ញុំមិនចង់ចំណាយលុយ ១១៥000 ដុល្លារ ដើម្បីទិញឡាន BMW ថ្មីទេ ប៉ុន្តែខ្ញុំក៏ដឹងថាព្រះជាម្ចាស់អាចធ្វើកិច្ចការដ៏អស្ចារ្យជាច្រើនដែរ។ ឌ្រិនដានិងខ្ញុំមិនបានប្រាប់នរណាអំពីរឿងឡាន ឬថាយើងកំពុងរកទិញឡានមួយគ្រឿងទេ។

ប្រហែលជាពីរសប្ដាហ៍ក្រោយមក បងប្រុសរបស់ឌ្រិនដាបានទូរស័ព្ទមកយើងថា «ខ្ញុំបានរកឃើញឡានរបស់ឌ្រិនដាហើយ!» ខ្ញុំថា «បងមានន័យថាម៉េចដែលថារកឃើញឡានរបស់ឌ្រិនដា?» គាត់តបថា «ខ្ញុំបានឃើញឡាននេះដាក់លក់ ហើយរំពេចនោះខ្ញុំស្រាប់តែមានអារម្មណ៍ថា ឡាននេះត្រូវបានទៅលើឌ្រិនដាហើយខ្ញុំត្រូវតែប្រាប់ហ្គារីឯងពីរឿងនេះ។» ខ្ញុំក៏សួរថា «តើឡាននោះម៉ាកអ្វីដែរ?» «ឡាននោះគឺម៉ាក BMW 645Ci ហើយវាល្អឥតខ្ចោះតែម្ដង គឺល្អឥតទាស់។ ឡាននេះត្រូវបានប្រើត្រឹមតែជាងពីរបីឆ្នាំ គឺឡូកុងទ័រតិច ហើយគ្មានស្នាមឆូតអ្វីទាំងអស់នៅលើតួ។ វាល្អឥតខ្ចោះ។ ក្រៅពីនោះ ប្អូនស្គាល់បុរសដែលលក់ឡាននោះ។» ខ្ញុំតបថា «ខ្ញុំស្គាល់មែន?» «មែនហើយ គាត់ថាអញ្ចឹង។ ប្អូនគួរទូរស័ព្ទទៅសួរគាត់ពីរឿងនោះទៅ។» មែនហើយ នៅពេលដែលគាត់បានប្រាប់ខ្ញុំពីម៉ាក និងម៉ូដែលរបស់ឡានហើយថែមទាំងប្រាប់ថាគឺជាឡានដែលឌ្រិនដានិងខ្ញុំបាននិយាយគ្នាថាយើងទាំងពីរពេញចិត្តនៅក្នុងពេលប៉ុន្មានសប្ដាហ៍មុន ខ្ញុំដឹងថាព្រះជាម្ចាស់កំពុងតែធ្វើការអ្វីម្យ៉ាង។

ខ្ញុំបានទូរស័ព្ទទៅកាន់បុរសជាម្ចាស់ឡាន។ បាទ ខ្ញុំពិតជាស្គាល់គាត់ ហើយយើងបាននិយាយគ្នាបន្តិចអំពីឡាននោះ។ គាត់ក៏ប្រាប់ខ្ញុំថាឡាននេះមានសភាពល្អយ៉ាងណា។ បន្ទាប់មក គាត់បាននិយាយពាក្យទាំងនេះមកកាន់ខ្ញុំថា «លោកដឹងទេ តាំងពីពេលដែលយើងបាននិយាយទូរស័ព្ទអំពីឡាននេះ ខ្ញុំស្រាប់តែមានអារម្មណ៍ថានេះត្រូវជាឡានរបស់ឌ្រិនដា។» ខ្ញុំមិនបានទាំងប្រាប់គាត់ថា ខ្ញុំរកមើលឡាននោះឲ្យឌ្រិនដាទេ។ បុរសនោះបានបន្តដោយនិយាយថា «ឥឡូវអញ្ចេះចុះ។ ខ្ញុំនឹងលក់វាជូនលោកក្នុងតម្លៃ ២៨០០០ដុល្លារ។» ខ្ញុំសឹងតែមិនជឿលើអ្វីដែលខ្ញុំទើបតែបានឮ។ ឡាននោះមានតម្លៃថ្លៃជាងនោះឆ្ងាយណាស់។ នៅពេលដែលខ្ញុំប្រាប់ឌ្រិនដាពីរឿងនោះ នាងពិតជារំភើបណាស់។ យើងបានទិញវាដោយប្រាក់សុទ្ធហើយក៏នៅតែប្រើវាមកទល់សព្វថ្ងៃ។ វានៅតែដំណើរការល្អ ហើយមានរូបរាងល្អដែរ។ ឡាននោះនៅតែមិនទាន់មានស្នាមឆ្កូតណាមួយ ហើយយើងបានបើកវាជា

ច្រើនលើកច្រើនសាដោយបើកដំបូល បើកចំរៀងៗ ហើយស្រូបពន្លឺព្រះអាទិត្យនៅថ្ងៃដែលយើងនឿយហត់ អស់កម្លាំង។

ការធ្វើដំណើរដែលយើងជាប់ចិត្តមិនភ្លេច គឺនៅពេលដែលយើងបើកឡាននោះកាត់ជួរភ្នំកូឡូរ៉ាដូ ទាំងដាក់សម្ភារៈបោះជំរុំរបស់យើងនៅលើឡាន។ កូនស្រីរបស់យើងឃើស្ទែន ក៏បានទៅជាមួយយើងដែរនៅពេលនោះ ហើយខ្ញុំចាំបានពេលដែលយើងបើកកាត់រដ្ឋខេនសាស នៅលើផ្លូវជាតិ I-70 នៅពេលយប់ទាំងបើកដំបូល។ នៅពេលដែលខ្ញុំកំពុងតែបើក ឃើស្ទែនទម្រេតខ្លួនគេងលក់នៅខាងក្រោយ។ ដួងតារានៅលើមេឃរះភ្លឺចិញ្ចែងចិញ្ចាច ហើយផ្លូវទាំងមូលទូលាយណាស់ ព្រោះយូរៗម្តងមានឡានមួយ ឬពីរបើកកាត់យើងប៉ុណ្ណោះ។ នៅរាត្រីនោះជារាត្រីដ៏ល្អឥតខ្ចោះ វាយោបក់រំភើយៗ ហើយបរិយាកាសក៏ល្អស្រស់សោភា។ យើងបានចំណាយពេលពីរសប្តាហ៍បើកកាត់ជួរភ្នំរ៉ុកគី ហើយខ្ញុំបានរកឃើញថាឡាននោះមានគុណភាពល្អប៉ុណ្ណា ក្នុងការដែលវាអាចធ្វើដំណើរកាត់តំបន់ទាំងនោះបាន។ មានពាក្យមួយដែលខ្ញុំអាចបរិយាយពីវាបានគឺ អស្ចារ្យណាស់!

ប៉ុន្តែនេះជាសំណួរដ៏សំខាន់។ តើយើងបានទទួលឡាននោះដោយរបៀបណា? តើហេតុអ្វីបានជាវាជាឡានដែលដូចទៅនឹងឡានដែលឌ្រិនដាបាននិយាយថា «គឺឡានហ្នឹងហើយ!»? ខ្ញុំដឹងថាគឺព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលបាននាំឡាននោះចូលមកកាន់ជីវិតរបស់យើង។ ខ្ញុំដឹងថា នៅពេលដែលខ្ញុំសាបព្រោះឡានរបស់ខ្ញុំទៅកាន់គ្រូគង្វាលរូបនោះ ខ្ញុំកំពុងតែអនុវត្តតាមច្បាប់ខាងវិញ្ញាណ។ ខ្ញុំចាំពេលមួយដែលខ្ញុំធ្លាប់និយាយថា ខ្ញុំនឹងទទួលបានឡានមួយមកវិញ ហើយមិនមែនជាឡានកាពីតាស់ (SUV) មិនមែនជាឡាន Jeep ទេ ប៉ុន្តែជាឡានតូចវិញ។ ខ្ញុំចាំថាពេលនោះខ្ញុំនិយាយថា គឺនឹងបានឡានស្អាតមួយគ្រឿង។ ប៉ុន្តែឌ្រិនដានិងខ្ញុំត្រូវយកកណ្តៀវមកច្រូត។ ឡាននោះនឹងមិនបង្ហាញខ្លួនឡើយ រហូតដល់យើងនិយាយថា «ហ្នឹងហើយ!»។ ទោះបីជាខ្ញុំមានជំនឿនៅពេលដែលខ្ញុំស្រាយឡាននោះ យើង

មិនបានយកកណ្ដៀវមកច្រូតឡើយរហូតដល់ពេលដែលឱ្រិនដានិយាយថា «គឺឡានហ្នឹងហើយ។»

មានភាពចៃដន្យមួយទៀតដែលបានឲ្យខ្ញុំកាន់តែយល់ពីគោលការណ៍នេះ។ ដូចដែលលោកអ្នកបានដឹងហើយថា ខ្ញុំចូលចិត្តបរបាញ់សត្វ។ ខ្ញុំរស់នៅក្នុងតំបន់ជនបទដែលអំណោយផលដល់ការបរបាញ់ ហើយខ្ញុំពិតជាមានព្រះពរដែលមានដីធ្លីសម្រាប់ឲ្យខ្ញុំអាចបរបាញ់បាន។ នៅលើផ្ទៃដីជាង ២៥ ហិកតារបស់ខ្ញុំ មានព្រៃក្រាស់ប្រហែលជា ៧,៥ហិកតា និងទំនាបបឹងប្រមាណជា ៤ហិកតា។ ជារៀងរាល់ឆ្នាំខ្ញុំបរបាញ់សត្វក្ដាន់ និងកំប្រុកទាំងបានជោគជ័យច្រើន។ មានសត្វទា និងក្ងានហើរមកក្បែរៗនោះដែរ ប៉ុន្តែមិនដឹងជាយ៉ាងម៉េច ខ្ញុំមិនធ្លាប់នឹកចង់ប្រមាញ់ពួកវាសោះ។ អូហ៎ មានពេលម្ដងម្កាលក្នុងពេលប៉ុន្មានឆ្នាំមកនេះ ខ្ញុំនិងកូនប្រុសៗដើរទៅទំនាបបឹង ហើយក៏បាញ់បានសត្វក្ងានពីរបីក្បាលយកមកចម្អិនអាហារពេលល្ងាច។ ប៉ុន្តែ យើងមិនដែលបរបាញ់សត្វទាឡើយ។

យ៉ាងណាមិញ នៅពេលពីរបីឆ្នាំមុន ខ្ញុំបានឃើញសត្វទារាប់សិបក្បាលហើរមកកាន់ទំនាបបឹងនោះ ហើយខ្ញុំគិតថានឹងសាកប្រមាញ់សត្វទា។ អស្ចារ្យណាស់! ខ្ញុំមានអារម្មណ៍រំភើបណាស់! ខ្ញុំជាប់ចិត្តនឹងការបរបាញ់ហើយ។ នៅអំឡុងពេលបរបាញ់សត្វទានារដូវស្លឹកឈើជ្រុះនោះ ខ្ញុំបានដឹងថាខ្ញុំត្រូវអនុវត្តការបរបាញ់ឲ្យបានល្អជាងមុនមែនទែនដើម្បីបាញ់ឲ្យត្រូវសត្វទា។ ខ្ញុំបាញ់បានសត្វទាពីរបីក្បាលហើយទើបដឹងថាវាមានឱជារសឆ្ងាញ់។ ខ្ញុំបានសម្គាល់ឃើញថា ជាច្រើនលើកច្រើនសាដែលសត្វទានៅឆ្ងាយពេក ឬគ្រាប់កាំភ្លើងខ្ញុំហោះបញ្ចិតៗវា។ ខ្ញុំជឿថាកត្តាទាំងនេះហើយបានធ្វើឲ្យខ្ញុំចេះតែបាញ់ខុស។ ខ្ញុំប្រើកាំភ្លើងធម្មតាដែលខ្ញុំប្រើដើម្បីបាញ់សត្វទាំងអស់ រាប់ចាប់ពីសត្វទន្សាយ រហូតដល់សត្វក្ដាន់ គឺកាំភ្លើងម៉ាក Remington ម៉ូដែល 11-87។ សូមកុំយល់ច្រឡំ។ ខ្ញុំពេញចិត្តកាំភ្លើងនោះណាស់ ហើយវាជាកាំភ្លើងដ៏ល្អ។ ប៉ុន្តែខ្ញុំបានឮថាគេបានផលិតកាំភ្លើងម៉ូដែលថ្មីសម្រាប់ការបរបាញ់សត្វទា។ កាំភ្លើងទាំងនោះ មានផ្ទៃខាងក្រៅប៉ារ៉ា និងប្រើគ្រាប់ ៣,៥ អ៊ីញ

ដែលខ្ញុំដឹងថាវានឹងជួយដល់ការបាញ់ចម្ងាយឆ្ងាយ។ ខ្ញុំមានគម្រោងថានឹងរកទិញវាមួយ មុនរដូវប្រមាញ់សត្វទាឆ្នាំក្រោយចូលមកដល់។

នៅពេលរដូវបរបាញ់សត្វទាឆ្នាំនោះបានកន្លងផុតទៅ ខែមករាក៏បានចូលមកដល់។ ខ្ញុំបានដើរកាត់ហាងលក់សម្ភារៈបរបាញ់ឈ្មោះថា Cabela's ហើយក៏គិតថាខ្ញុំនឹងដើរមើលផ្នែកកាំភ្លើង ដើម្បីឲ្យឃើញថាតើវាមានរូបរាងយ៉ាងណា។ នៅពេលដែលខ្ញុំដើរទៅកាន់ផ្នែកលក់កាំភ្លើង ខ្ញុំបានឃើញថាផ្នែកនោះទាំងមូលត្រូវបានដាក់សុទ្ធតែកាំភ្លើងប្រមាញ់សត្វទា។ ខ្ញុំបានមើលកាំភ្លើងពីរបី ហើយគិតថានឹងទិញកាំភ្លើងមួយដែលខ្ញុំពេញចិត្ត ប៉ុន្តែវាមានតម្លៃជាង ២០០០ដុល្លារ ហើយរដូវបរបាញ់ឆ្នាំថ្មីនេះនៅសល់ពេលប៉ុន្មានខែទៀតទើបចូលដល់។ ខ្ញុំគិតថា «ខ្ញុំនឹងចាំសិន»។ ប៉ុន្តែ ខ្ញុំបានធ្វើអ្វីម្យ៉ាងចម្លែកនៅពេលដែលរៀបចាកចេញពីហាងនោះ។ ពេលដែលខ្ញុំធ្វើនោះ ខ្ញុំមិនបានដឹងថាខ្លួនឯងកំពុងតែធ្វើអ្វីនោះទេ។ ខ្ញុំគ្រាន់តែធ្វើដោយមិនបានគិតច្រើន។ ខ្ញុំបានចង្អុលទៅកាន់កាំភ្លើងវែងដែលខ្ញុំចង់បាន ហើយនិយាយឮៗថា «ខ្ញុំនឹងបានកាំភ្លើងនោះនៅក្នុងព្រះនាមព្រះយេស៊ូ។» នៅលើកនេះទៀត ខ្ញុំមិនបានគិតគូរច្រើនទេ ខ្ញុំគ្រាន់តែធ្វើការប្រកាសថាខ្ញុំនឹងបានកាំភ្លើងនោះ។ ខ្ញុំបានឃើញរូបភាពកាំភ្លើងបាញ់ទាដែលខ្ញុំចង់បានយ៉ាងច្បាស់លាស់។

នៅក្នុងពេលពីរបីសប្ដាហ៍ក្រោយមក មានគេអញ្ជើញខ្ញុំឲ្យទៅចែកចាយនៅក្នុងសន្និបាតអាជីវកម្មមួយ ហើយមានអ្វីម្យ៉ាងកើតឡើងដែលបានចាប់ចិត្តខ្ញុំ។ បន្ទាប់ពីខ្ញុំនិយាយចប់ ម្ចាស់ក្រុមហ៊ុននោះបានដើរមកជួបខ្ញុំហើយថា ពួកគេចង់ជូនអំណោយមួយដល់ខ្ញុំជាការអរគុណដល់វត្តមានរបស់ខ្ញុំ។ គាត់និយាយថា «យើងដឹងថាលោកចូលចិត្តបរបាញ់ ដូច្នេះយើងបានទិញកាំភ្លើងវែងនេះដល់លោក។» ខ្ញុំភ្ញាក់ផ្អើលជាខ្លាំង នៅពេលដែលគេយកកាំភ្លើងបាញ់ទាពាក់កណ្ដាលស្វ័យប្រវត្តិម៉ាក Benelli គឺដូចទៅនឹងកាំភ្លើងដែលខ្ញុំបានឃើញនៅក្នុងហាងបេះបិទ ជាកាំភ្លើង

**ព្រះជាម្ចាស់ចង់បង្ហាញខ្ញុំថាទ្រង់ស្រឡាញ់ខ្ញុំឡើយ។ ទ្រង់បានបង្ហាញខ្ញុំថាទ្រង់ស្រឡាញ់ខ្ញុំ នៅពេលដែលទ្រង់ចាត់ព្រះយេស៊ូឲ្យយាងមកសម្រាប់ខ្ញុំ និងប្រទានព្រះរាជ្យដល់ខ្ញុំ!**

ដែលខ្ញុំបានចង្អុលនោះ! តើលោកអ្នកយល់ពីសេចក្តីនេះទេ? តើកាំភ្លើងមួយដើមនោះអាចបង្ហាញខ្លួនឡើងដោយរបៀបណា? ខ្ញុំបានឲ្យកាំភ្លើងខ្ញុំទៅគេជាច្រើននៅក្នុងពេលប៉ុន្មានឆ្នាំនេះ ប៉ុន្តែមិនដែលបានយកកណ្តៀវមកច្រូតទេ។ យើងអាចនិយាយបានថា ខ្ញុំបានសាបព្រោះកាំភ្លើងនោះដោយជំនឿ និងចិត្តសប្បុរស ប៉ុន្តែមិនដែលយកកណ្តៀវមកច្រូតសោះ។ ខ្ញុំមិនដែលនិយាយថា «ព្រះអម្ចាស់អើយ គឺកាំភ្លើងមួយហ្នឹងហើយដែលខ្ញុំចង់បាន! គឺមួយហ្នឹងហើយ។» ប៉ុន្តែ នៅនាទីដែលខ្ញុំធ្វើដូច្នេះ ចម្រូត(កាំភ្លើង)នោះក៏បានបង្ហាញខ្លួនភ្លាម!

ខ្ញុំបានប្រាប់រឿងកាំភ្លើងនេះទៅកាន់ព័ន្ធការីដែលជាមិត្តរបស់ខ្ញុំម្នាក់។ គាត់និយាយថា «មែនហើយ ខ្ញុំជឿថាព្រះជាម្ចាស់ពិតជាធ្វើបែបនោះមែនជួនកាល។ ទ្រង់នឹងគ្រាន់តែប្រទានពរលោកជាមួយអំណោយពិសេសបន្តិចបន្តួចដើម្បីប្រាប់លោកថា ទ្រង់ស្រឡាញ់លោក។» នៅពេលដែលខ្ញុំគិតពីអ្វីដែលគាត់និយាយ ខ្ញុំយល់ឃើញថា «អត់ទេ នោះមិនពិតទេ។ មែនហើយ ព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ ប៉ុន្តែទ្រង់មិនគ្រាន់តែចង់ធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលជាមួយនឹងអំណោយបន្តិចបន្តួចឡើយ។» ផ្ទៃត្រី ក្តាន់ដែលមកទៅតាមលំដាប់លំដោយច្បាស់លាស់ ឡាន និងអ្វីៗដែលខ្ញុំបានទទួលមិនមែនដោយសារតែព្រះជាម្ចាស់ចង់បង្ហាញខ្ញុំថាទ្រង់ស្រឡាញ់ខ្ញុំឡើយ។ ទ្រង់បានបង្ហាញខ្ញុំថាទ្រង់ស្រឡាញ់ខ្ញុំ នៅពេលដែលទ្រង់ចាត់ព្រះយេស៊ូឲ្យយាងមកសម្រាប់ខ្ញុំ និងប្រទានព្រះរាជ្យដល់ខ្ញុំ!

ខ្ញុំសូមប្រាប់លោកអ្នកនូវសាច់រឿងមួយទៀតអំពីចម្រូត។ ដូចដែលខ្ញុំបានប្រាប់លោកអ្នករួចមកហើយ ខ្ញុំមិនមែនជាអ្នកស្រឡាញ់ ឬតាមដានម៉ូតឡានទេ។ យើងបើកឡានរហូតទាល់តែដាំខ្ទឹម។ ឧទាហរណ៍ដូចជាឡានហុនដា Pilot ចាស់

របស់យើងដែលយើងប្រើអស់រយៈពេល៨ឆ្នាំ។ យើងពេញចិត្តនឹងឡាននោះ វាមានប្រយោជន៍សម្រាប់យើង ម៉ាស៊ីនដំណើរការល្អ មើលទៅនៅថ្មី ហើយដូច្នេះយើងក៏ទុកវា។ ប៉ុន្តែយើងក៏ឧស្សាហ៍គិតពីការទិញឡានកាពីតាស់ SUV ដែលធំជាងនោះ ដើម្បីដឹកអ្នកដំណើរ និងភ្ញៀវរបស់យើង។ នៅពេលមុន យើងធ្លាប់តែជួលឡាន Cadillac Escalade នៅពេលដែលយើងមានព្រឹត្តិការណ៍ម្តងៗនៅឯក្រុមជំនុំ Now Center ហើយឌ្រិនជាព្រមទាំងខ្ញុំជាអ្នកបើកឡាននោះ។ យើងពេញចិត្តនឹងវាណាស់។ យើងចូលចិត្តដែលវាមានពណ៌សស្រដៀងនឹងគុជខ្យង ហើយយើងចូលចិត្តឡាន Escalade ខ្លីជាជាងឡានវែងៗ។ យើងនិយាយថា «នេះជាឡានដែលយើងចង់បាន គឺឡាន Cadillac Escalade ពណ៌សស៊េរីខ្លី។ យើងចាំបាច់ត្រូវទិញឡានស៊េរីនោះ។» ជីវិតរបស់យើងមានភាពមមាញឹកណាស់ ហើយយើងគ្មានពេលដើរមើលឡាន និងគិតពីការទិញវានៅឡើយទេ។

ប្រហែលជាមួយខែក្រោយមក ខ្ញុំទើបតែឈានជើងចេញពីទ្វារផ្ទះ ដោយដើរសំដៅទៅយកកាសែតដែលខ្ញុំអានជារៀងរាល់ព្រឹកនៅតាមផ្លូវខាងមុខផ្ទះ ទូរស័ព្ទរបស់ខ្ញុំក៏រោទ៍ឡើង។ មានបុរសម្នាក់និយាយថា «លោកគ្រូ ខ្ញុំចង់ទិញឡាន Cadillac Escalade ជូនលោកគ្រូមួយ។ តើលោកគ្រូចង់បានពណ៌អ្វី?» ដោយការភ្ញាក់ផ្អើល ខ្ញុំក៏តបថា «អស្ចារ្យណាស់។ ឌ្រិនដានិងខ្ញុំចង់បានពណ៌ស។» គាត់តបថា «អូខេ។ ចាំខ្ញុំដើរមើលសិនអញ្ចឹង។» ដោយរំភើបពេក ខ្ញុំក៏ភ្លេចប្រាប់គាត់ថាយើងពិតជាពេញចិត្តនឹងស៊េរីខ្លីជាង។ គាត់មានបំណងរកឡានដែលគេទើបតែជិះបានមួយឆ្នាំ ឬពីរឆ្នាំ ហើយនៅល្អអត់ទាស់ និងមានគីឡូតិច។

យ៉ាងណាមិញ យើងមិនបានឮពីបុរសនេះនៅក្នុងពេលប្រហែលជាមួយខែ។ ចុងក្រោយបំផុត គាត់ក៏បានទូរស័ព្ទមកខ្ញុំ ហើយថា «ខ្ញុំរកបានឡាន Escalade ឲ្យលោកគ្រូហើយ សូមជួបខ្ញុំនៅកន្លែងនេះ ម៉ោងនេះ ហើយលោកគ្រូអាចបើកវាមកផ្ទះបាន។» ដូច្នេះ យើងបានទៅជួបគាត់ ហើយគាត់រកបានឡាន Escalade ពណ៌សស៊េរីខ្លី។ វាស្អាតណាស់! គាត់ថា «ខ្ញុំសុំទោសដែលត្រូវចំណាយពេលយូរដើម្បី

ទាក់ទងមកលោកគ្រូវិញ។ ខ្ញុំពិតជាព្យាយាមរកឡានស៊េរីវែង ប៉ុន្តែដោយសារតែវាពេញនិយមពេករហូតដល់ខ្ញុំរកមិនបានឡើយ។ ខ្ញុំរកបានត្រឹមតែឡានស៊េរីខ្លីប៉ុណ្ណោះ។ ខ្ញុំសង្ឃឹមថាលោកគ្រូមិនយល់ទាស់ទេ។» មែនហើយ តាមពិតទៅ នោះជាឡានដែលយើងចង់បាន ហើយវាដូចទៅនឹងអ្វីដែលយើងបាននិយាយអញ្ចឹង។

នៅលើកនេះម្តងទៀត ខ្ញុំក៏សួរសំណួរថា៖ តើឡាន Escalade ដែលយើងចង់បាននោះបង្ហាញខ្លួនដោយរបៀបណាទៅ? ជាបឋម ខ្ញុំបានបរិច្ចាគឡានចំនួន ៨ ក្រៅពីឡានដែលខ្ញុំឲ្យដល់គ្រូគង្វាលដែលខ្ញុំបាននិយាយមុននេះ។ ប៉ុន្តែ យើងមិនដែលនិយាយថា «គឺហ្នឹងហើយ!» អំពីឡានពីមុនមកទេ រហូតដល់ឌ្រិនដាបានធ្វើបែបនោះជាមួយនឹងឡាន BMW។ នៅលើកនេះម្តងទៀត ទាំងឌ្រិនដានិងខ្ញុំចាំបាច់ត្រូវយល់ស្របជាមួយគ្នា ហើយប្រកាសព្មៗថា «គឺហ្នឹងហើយ!» ខ្ញុំបាននិយាយថា នៅក្នុងពេលជាច្រើនឆ្នាំកន្លងមកនេះ ក្រុមជំនុំបានធ្វើកិច្ចការយ៉ាងល្អក្នុងការបង្រៀនអំពីការថ្វាយ ប៉ុន្តែក៏ធ្វើមិនបានល្អក្នុងការបង្រៀនមនុស្សអំពីរបៀបច្រូតផលដែរ។ ដូច្នេះតាមរយៈសាច់រឿងខាងលើ តើលោកអ្នកដឹងថាអ្វីទៅជាកណ្តៀវដែរឬទេ? ខ្ញុំសង្ឃឹមថាលោកអ្នកបានឃើញវាច្បាស់។ ខ្ញុំបានសាបព្រោះឡានជាច្រើនគ្រឿងដោយជំនឿថានឹងទទួលបានត្រលប់មកវិញ ប៉ុន្តែឌ្រិនដានិងខ្ញុំមិនដែលយល់ស្របគ្នាអំពីឡានថ្មីណាមួយឡើយ។ នៅលើកនេះទៀត យើងបានបើកឡានរបស់យើងមួយរយៈពេល។ ប៉ុន្តែ នៅនាទីដែលយើងនិយាយថា «គឺហ្នឹងហើយ!» ឡាននោះក៏បង្ហាញខ្លួនឡើង។ កណ្តៀវគឺជាពាក្យសម្តីរបស់យើង!

*ទោះទាំងសេចក្តីស្លាប់ ហើយនឹងជីវិតក៏នៅក្នុងអំណាចនៃអណ្តាតដែរ អ្នកណាដែលចូលចិត្តប្រើ នោះនឹងស៊ីផលនៃអណ្តាតនោះឯង។*

សុភាសិត ១៨៖២១ (ព្រះគម្ពីរបរិសុទ្ធ)

មានរដូវកាលមួយដែលក្រុមជំនុំរបស់យើងហាក់ដូចជាបង្រៀនច្រើនអំពីពាក្យសម្ដី និងការដែលយើងប្រកាសចេញមក។ ខ្ញុំធ្លាប់ចំណាយពេលជាមួយមនុស្សដែលនិយាយអ្វីមួយ ហើយក៏ខ្ទប់មាត់របស់គេ ទាំងឧទានថា «ខ្ញុំចាំបាច់ប្រយ័ត្នអំពីពាក្យដែលខ្ញុំនិយាយចេញមក» ហើយខ្ញុំជឿថាលោកអ្នកក៏ធ្លាប់ជួបមនុស្សបែបនេះដែរ។ ស្ដាប់មើលទៅ វាហាក់ដូចជាកិច្ចការដ៏ល្អណាស់ ហើយខ្ញុំជឿថាការនោះនឹងជួយរក្សាព្រះបន្ទូលនៅក្នុងដួងចិត្តរបស់លោកអ្នក។ ទោះជាយ៉ាងណាក៏ដោយ ការប្រយ័ត្នពាក្យសម្ដីមិនមានអ្វីពាក់ព័ន្ធជាមួយនឹងការច្រូតផលដែលយើងបានសាបព្រោះទេ។ ថាម៉េច? ប៉ុន្តែ លោកគ្រូទើបតែនិយាយថាកណ្ដៀវជាពាក្យសម្ដីរបស់យើង? មែនហើយ ខ្ញុំពិតជាបាននិយាយអញ្ចឹងមែន ប៉ុន្តែប្រសិនបើគ្រាន់តែនិយាយអ្វីដែលត្រឹមត្រូវមិនទាន់គ្រប់គ្រាន់ទេ។

*ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា បើអ្នកណាម្នាក់**និយាយ**ទៅកាន់ភ្នំនេះថា "ចូរចេញពីទីនេះធ្លាក់ក្នុងសមុទ្រទៅ!" ហើយបើអ្នកនោះ**ជឿជាក់**ក្នុងចិត្ត ដោយឥតសង្ស័យថា**ពាក្យរបស់ខ្លួន**នឹងបានសម្រេច នោះព្រះជាម្ចាស់នឹងប្រទានឲ្យបានសម្រេចតាមពាក្យគេមែន។*

ម៉ាកុស ១១៖២៣

ជាថ្មីម្ដងទៀត កណ្ដៀវនៅក្នុងម៉ាកុស ជំពូក៤ គឺជាពាក្យសម្ដីរបស់លោកអ្នក! នៅពេលដែលម៉ាកុសជំពូក៤ពិភាក្សាអំពីកណ្ដៀវ ជំពូកនេះបានពិភាក្សាអំពីដំណើរការនៃជំនឿ និងរបៀបដែលយើងអាចមានជំនឿរួចស្រេចទៅហើយ។ ជំពូកនេះចែងថា នៅពេលស្រូវទុំល្មមច្រូតហើយ លោកអ្នកនឹងយកកណ្ដៀវមកច្រូតព្រោះដល់រដូវចម្រូត។ ចម្រូតបានមកដល់ដោយសារតែលោកអ្នកមានជំនឿ និងយល់ស្របជាមួយស្ថានសួគ៌នៅក្នុងចិត្ត។ ខគម្ពីរដែលនៅក្នុងម៉ាកុសជំពូក១១ខាងលើបង្ហាញ

ពីគោលការណ៍ដូចគ្នា។ លោកអ្នកជឿលើព្រះបន្ទូលនៅក្នុងចិត្ត ហើយក៏និយាយ ឬប្រកាសចេញមក ព្រមទាំងស្រាយនូវសិទ្ធិអំណាចនៃស្ថានសួគ៌។ ប៉ុន្តែសូមកត់ចំណាំត្រង់ឃ្លា *«ជឿជាក់ក្នុងចិត្តដោយឥតសង្ស័យថាពាក្យរបស់ខ្លួននឹងបានសម្រេច»។* ការល្បងលនៃជំនឿគឺថា ប្រសិនបើលោកអ្នកជឿនូវអ្វីដែលលោកអ្នកកំពុងតែនិយាយ។ បើគ្រាន់តែនិយាយ ឬប្រកាសនូវព្រះបន្ទូលមិនមែនជាជំនឿទេ។ ប្រសិនបើលោកអ្នកមិនយល់ស្របជាមួយនឹងស្ថានសួគ៌នៅក្នុងចិត្តទេ ទោះបើលោកអ្នកខំប្រឹងប្រកាសរហូតដល់ជ្រុះធ្មេញអស់ក៏ពុំមានអ្វីកើតឡើងដែរ។ ដូច្នេះតើយើងគួរពិនិត្យមើលលើពាក្យសម្តីរបស់យើង ឬដួងចិត្តរបស់យើង?

*មនុស្សល្អតែងប្រព្រឹត្តអំពើល្អ ព្រោះចិត្តរបស់គេល្អ រីឯមនុស្សអាក្រក់ តែងប្រព្រឹត្តអំពើអាក្រក់ ព្រោះចិត្តរបស់គេអាក្រក់ ដ្បិតមាត់របស់មនុស្សតែងស្រដីចេញមកនូវសេចក្តីណា ដែលមានពេញហូរហៀរនៅក្នុងដួងចិត្តរបស់ខ្លួន»។*

លូកា ៦៖៤៥ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

*ចូរកូនថែរក្សាចិត្តគំនិតដោយប្រុងប្រយ័ត្ន ដ្បិតចិត្តគំនិតរបស់កូនយ៉ាងណា ជីវិតរបស់កូនក៏យ៉ាងនោះដែរ។ ចូរទប់មាត់កុំឲ្យពោលពាក្យអាស្រូវឡើយ ហើយក៏កុំគ្រលាស់អណ្តាតពោលពាក្យមួលបង្កាច់គេដែរ។*

សុភាសិត ៤៖២៣-២៤ (ព្រះគម្ពីរបរិសុទ្ធ)

យើងអាចឃើញយ៉ាងច្បាស់ថាអ្វីដែលយើងស្រដីចេញមក គឺមកពីដួងចិត្តរបស់យើង និងអ្វីដែលយើងជឿលើ។ តាមរយៈដំណើរការខាងក្រោមនៅក្នុងម៉ាកុស ជំពូក ៤ យើងដឹងពីរបៀបផ្លាស់ប្តូរអ្វីដែលចិត្តរបស់យើងជឿលើ ហើយឲ្យវាស្របទៅតាមស្ថានសួគ៌ដោយជំនឿហើយ។ បន្ទាប់មក នៅពេលដែលយើងជឿប្រាកដ

ទាំងស្រុង យើងអាចប្រើប្រាស់ពាក្យសម្ដី និងសកម្មភាពរបស់យើងជាកណ្ដៀវ។ តើលោកអ្នកយល់ដែរឬទេ? ល្អណាស់ អញ្ចឹងយើងទៅមុខទៀត។

នៅពេលដែលយើងបន្តការពិភាក្សារបស់យើងស្ដីអំពីជំនឿ ខ្ញុំចង់លើកយកសំណួរមួយដែលលោកអ្នកចាំបាច់ត្រូវតែឆ្លើយ។

## តើខ្ញុំអាចដឹងថា ខ្ញុំពិតជាមានជំនឿដោយរបៀបណា?

នោះជាសំណួរដ៏ល្អ ហើយជាសំណួរដែលលោកអ្នក<u>**ត្រូវតែ**</u>ដឹង ព្រោះថាវាមិនអាចទៅរួចទេក្នុងការអធិស្ឋាននូវពាក្យអធិស្ឋាននៃជំនឿ ដោយមិនបានមានជំនឿជាមុនសិននោះ។ មានរបៀបជាច្រើនដែលលោកអ្នកអាចដឹងថា តើលោកអ្នកពិតជាមានជំនឿមែន ឬយ៉ាងណា ហើយមានសញ្ញាជាច្រើនដែលលោកអ្នកចាំបាច់ត្រូវតែដឹង និងរកមើល។ លោកអ្នកអាចធ្វើការសម្រេចចិត្តដែលផ្អែកលើភាពភ័យខ្លាចអពមង្គលជាច្រើន នៅពេលដែលលោកអ្នកមិនមានជំនឿ។ ការសម្រេចចិត្តដែលចេញពីភាពភ័យខ្លាចនឹងតែងតែឃុំលោកអ្នកឲ្យជាប់ជាចំណាប់ខ្មាំងនៃបណ្ដាសាផែនដី ហើយវានឹងនាំឲ្យលោកអ្នកខកខានមិនបានទទួលអ្វីដែលព្រះជាម្ចាស់ចង់ប្រទានដល់លោកអ្នក។ ដូច្នេះ តើមានតឹកតាងអ្វីដែលបញ្ជាក់ថាលោកអ្នកពិតជាមានជំនឿ? សញ្ញាសម្គាល់ទីមួយគឺងាយស្រួលទេះ លោកអ្នកអាចរំឭកពីនិយមន័យនៃជំនឿដែលយើងបានពិភាក្សា ហើយយល់ថាគន្លឹះសំខាន់គឺជឿជាក់ប្រាកដនៅក្នុងចិត្ត។ ប៉ុន្តែជាច្រើនលើកច្រើនសាយើងគិតថា យើងជឿជាក់យ៉ាងប្រាកដ ប៉ុន្តែគ្រាន់តែយល់ស្របជាមួយនឹងព្រះបន្ទូលប៉ុណ្ណោះត្រឹមគំនិតប៉ុណ្ណោះ គឺមិនបានដល់ជម្រៅចិត្តរបស់យើងឡើយ។ លោកអ្នកចាំបាច់ត្រូវយល់អំពីភាពខុសគ្នារវាងការទាំងពីរនេះ។ នៅពេលដែលលោកអ្នកពិតជាជឿប្រាកដនៅក្នុងចិត្ត ជាការពិតណាស់ ថ្វីបើគំនិតរបស់លោកអ្នកយល់ស្របជាមួយនឹងអ្វីដែលព្រះបន្ទូលចែងក៏

ពិតមែន ប៉ុន្តែលោកអ្នកក៏ដឹងយ៉ាងប្រាកដ។ វាជាទំនុកចិត្តដែលនាំសេចក្តីសុខសាន្ត និងការរំពឹងទុក។

*រីឯជំនឿ គឺជាការជឿជាក់លើអ្វីដែលបានសង្ឃឹម និងជាការប្រាកដអំពីអ្វីដែលមើលមិនឃើញ។*

ហេប្រឺ ១១៖១ (ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ)

ប្រសិនបើលោកអ្នកមានភស្តុតាងថាលោកអ្នកមានអ្វីមួយ តើលោកអ្នកនឹងនៅតែត្រូវការការបញ្ជាក់អះអាងថាលោកអ្នកមានវាដែរឬទេ? ជាការពិតណាស់លោកអ្នកមិនត្រូវការទេ។ ជាថ្មីម្តងទៀត នៅពេលដែលលោកអ្នកមានជំនឿ លោកអ្នកនឹងមានការយល់ដឹង សេចក្តីសុខសាន្ត និងទំនុកចិត្តថាលោកអ្នកមាននូវអ្វីដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ចែងហើយ ទោះបីជាលោកអ្នកមិនទាន់មើលឃើញវាក៏ដោយ។ មានមនុស្សជាច្រើននិយាយបែបនេះថា៖ «ខ្ញុំដឹង ខ្ញុំដឹង ខ្ញុំដឹង ខ្ញុំដឹងថាខ្ញុំមានវាមែន។» ការដឹងបែបនេះគឺចេញមកពីខាងក្នុងចិត្ត ឬវិញ្ញាណរបស់គេ ហើយមិនមែនមកពីអ្វីដែលកាលៈទេសៈនៅជុំវិញប្រាប់លោកអ្នកឡើយ។ វាគឺនៅក្នុងវិញ្ញាណ ឬដួងចិត្តរបស់លោកអ្នក។ ភាពភ័យខ្លាចរសាត់បាត់ ហើយគ្មានគំនិតដែលរំអុកលោកអ្នកឲ្យខ្វល់ខ្វាយទៀតឡើយ គឺលោកអ្នកដឹងថាកិច្ចការនោះបានសម្រេចហើយ។

ទិដ្ឋភាពមួយទៀតនៃការដែលមានជំនឿគឺជាការដែលមានអំណរ និងការរំពឹងទុក។ ចម្លើយរបស់លោកអ្នកគឺនៅត្រង់នេះ។ លោកអ្នកមានវាហើយ! ជំនឿគឺលើសពីអារម្មណ៍ដែលមានភាពសុខសាន្ត ឬទំនុកចិត្ត ទោះបីជាពេលដែលលោកអ្នកមានជំនឿ លោកអ្នកមានអារម្មណ៍បែបនោះក៏ដោយ។ លោកអ្នកក៏គួរតែអាចការពារមុខតំណែងខាងវិញ្ញាណរបស់លោកអ្នកដែរ។ នៅពេលដែលខ្ញុំនិយាយបែបនេះ សូមគិតពីសាលសវនាការមួយ ហើយលោកអ្នកមាននាទីជាមេធាវីដែលកំពុងតែធ្វើការ

សាកសួរដល់សាក្សី។ តើហេតុអ្វីបានជាលោកអ្នកជឿលើអ្វីដែលលោកអ្នកជឿនេះ អំពីស្ថានការណ៍របស់លោកអ្នក? តើលោកអ្នកនឹងការពារមុខតំណែងរបស់លោកអ្នកដោយរបៀបណា? មានចម្លើយតែមួយប៉ុណ្ណោះ គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ឧទាហរណ៍ ប្រសិនបើមាននរណាម្នាក់មកផ្ទះរបស់លោកអ្នកហើយពោលថា «អ្ហ៎ ចេញពីផ្ទះរបស់ខ្ញុំភ្លាម» តើលោកអ្នកនឹងថា «អូហ៎ ខ្ញុំសុំទោស សូមទុកពេលឲ្យយើងមួយថ្ងៃទៀត យើងនឹងចេញភ្លាម» ដែរឬទេ? អត់ទេ លោកអ្នកនឹងមិនធ្វើបែបនេះទេ។ លោកអ្នកប្រហែលជានឹងសើចជាមិនខាន។ ប្រសិនបើបុគ្គលនោះនិយាយថា «អត់ទេ នេះជាផ្ទះរបស់ខ្ញុំ ចូរចេញភ្លាមទៅ បើមិនដូច្នោះទេ ខ្ញុំនឹងប្ដឹងអ្នកឡើងតុលាការ។» លោកអ្នកនឹងតបវិញថា «ខ្ញុំនឹងរីករាយនៅពេលជួបអ្នកនៅឯតុលាការ!» នៅក្នុងពេលសាកសួរ លោកអ្នកនឹងបង្ហាញចៅក្រមពីអ្វីដែលលោកអ្នកធ្វើ ទាំងរមទម្យ។ គាត់នឹងពិនិត្យមើលពីភ័ស្តុតាងរបស់លោកអ្នក ហើយចាប់ខ្លួនបុគ្គលម្នាក់នោះពីបទរុកគួន ហើយតម្រូវឲ្យគាត់បង់ប្រាក់ពិន័យ។ លោកអ្នកមានទំនុកចិត្តរឹងប៉ឹងមិនមែនដោយសារតែអារម្មណ៍របស់លោកអ្នកទេ ប៉ុន្តែគឺដោយសារតែច្បាប់ និងតថភាពដែលថាលោកអ្នកជាម្ចាស់ផ្ទះនោះស្របច្បាប់។

នៅពេលដែលយើងនិយាយដល់ការដែលមានជំនឿ ខ្ញុំបានរកឃើញថាមានពេលជាច្រើនលើកមនុស្សមិនយល់ថាតើជំនឿជាអ្វី ហើយងាយច្រឡំដោយការផ្ញើទំនុកចិត្តនៅលើសកម្មភាពរបស់ពួកគេ ជាជាងប្រភពនៃជំនឿដែលខ្លួនមាន ដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ យើងអាចងាយនឹងច្រឡំណាស់រវាងសកម្មភាព ឬរូបមន្តនៃការប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាមួយនឹងឫទ្ធានុភាពដ៏ពិតនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលកើតឡើងចេញពីដួងចិត្តដែលជឿជាក់យ៉ាងប្រាកដ។ ឧទាហរណ៍ ប្រសិនបើលោកអ្នកសាបព្រោះថវិកាចូលទៅកាន់ព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយខ្ញុំសួរលោកអ្នកថាហេតុអ្វីបានជាលោកអ្នកជឿថាលោកអ្នកនឹងទទួលបានផលតបស្នងពីការថ្វាយនោះ លោកអ្នកមិនគួរឆ្លើយថា «ដោយហេតុថានៅថ្ងៃនេះ ថ្ងៃនោះខ្ញុំបានថ្វាយប្រាក់ជាចំនួនជាក់លាក់ប៉ុននេះ» នោះទេ។

នៅពេលដែលលោកអ្នកនិយាយបែបនេះ លោកអ្នកគ្រាន់តែមើលទៅកាន់សកម្មភាពរបស់ខ្លួន និងរូបមន្ត ហើយការនេះពុំមានអ្វីដែលជាយុត្តាឲ្យយើងអាចបញ្ជាក់អះអាងបានឡើយ។ ការប្រាកដជាក់ច្បាស់ ឬការធានាអះអាងរបស់លោកអ្នកអាចមកពីព្រះបន្ទូលរបស់ព្រះជាម្ចាស់តែមួយប៉ុណ្ណោះ។

មានមនុស្សជាច្រើនរាប់មិនអស់ ដែលខ្ញុំបានអធិស្ឋានឲ្យ នៅពេលដែលខ្ញុំសួរគេថា ហេតុអ្វីបានជាគេជឿថាគេនឹងទទួល នៅពេលដែលខ្ញុំអធិស្ឋាន គេគ្រាន់តែសម្លឹងមើលមុខខ្ញុំ ដោយគ្មានចម្លើយអ្វីសោះ។ នៅពេលដែលខ្ញុំសួរ ខ្ញុំកំពុងតែរកមើលជំនឿរបស់ពួកគេ និងការដែលគេយល់ស្របជាមួយនឹងស្ថានសួគ៌។ ខ្ញុំចង់ឮពួកគេនិយាយថា «ខ្ញុំដឹងថាខ្ញុំនឹងទទួល ព្រោះព្រះជាម្ចាស់បានសន្យានឹងខ្ញុំថាយ៉ាងដូច្នេះ នៅក្នុងកណ្ឌគម្ពីរនេះ ជំពូកនេះ ខនេះ ហើយព្រះបន្ទូលនោះជារបស់ខ្ញុំ។» ប្រសិនបើពួកគេមិនអាចប្រាប់នូវអត្ថបទគម្ពីរដែលព្រះជាម្ចាស់បានសន្យាមកកាន់ខ្ញុំទេ នោះមានន័យថាពួកគេគ្មានយុត្តាមាំទាំ ហើយពួកគេមិនដឹងទាល់តែសោះថាទូករបស់ខ្លួនកំពុងតែទៅណា។

សូមចាំថា លោកអ្នកអាចមានជំនឿលុះត្រាតែលោកអ្នកស្គាល់នូវព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ហេតុអ្វី? ដោយសារតែជំនឿអាចកើតឡើងបានលុះត្រាតែដួងចិត្តរបស់អ្នកយល់ស្របជាមួយនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ ខ្ញុំជឿថា មានមនុស្សជាច្រើនគិតថា ពួកគេមានជំនឿ តែតាមពិតមិនមែនទេ។ ជាថ្មីម្តងទៀត ពួកគេប្រហែលជាមានគំនិតយល់ស្របជាមួយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ថាពិតប្រាកដ និងល្អប្រសើរ ប៉ុន្តែគេមានជំនឿលុះត្រាតែដួងចិត្តរបស់គេពិតជាជឿប្រាកដជាក់ច្បាស់។ សម្រាប់មនុស្សជាច្រើន គំនិតរបស់គេយល់ស្របជាមួយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប៉ុន្តែដួងចិត្តរបស់គេនៅមិនទាន់ប្រាកដនៅឡើយទេ។

នេះជាឧទាហរណ៍ដ៏ល្អមួយ ដើម្បីពន្យល់ពីអ្វីដែលខ្ញុំកំពុងតែនិយាយ។ ឧទាហរណ៍នេះនឹងបង្ហាញថាមានមនុស្សជាច្រើនមិនទាន់មានជំនឿនៅឡើយទេ

នៅពេលដែលគេគិតថាខ្លួនមានជំនឿហើយ។ ប្រសិនបើខ្ញុំប្រាប់លោកអ្នកថា ខ្ញុំទើបតែដឹងថាមេឃមិនមានពណ៌ខៀវ ដូចដែលមនុស្សជាច្រើននិយាយ ប៉ុន្តែពណ៌ខៀវដែលពួកគេហៅនោះ តាមពិតជាពណ៌លឿង? បើនិយាយមួយបែបទៀត ខ្ញុំបានប្រាប់លោកអ្នកថា យើងត្រូវបានបង្រៀនឲ្យហៅខុស ឬជឿខុសនៅពេញមួយជីវិតរបស់យើងនេះអំពីពណ៌ ហើយពណ៌ខៀវនេះតាមពិតមិនមែនជាពណ៌ខៀវទេ គឺជាពណ៌លឿងវិញ។ តើលោកអ្នកនឹងភ្ញាក់ផ្អើល ហើយទូរស័ព្ទទៅគ្រូបង្រៀនថ្នាក់ទីមួយ រួចស្រែកសម្លុតឲ្យគាត់ដោយចោទគាត់ថាបានបង្រៀនពណ៌ខុស ធ្វើឲ្យជីវិតរបស់លោកអ្នករញ៉េរញ៉ៃដែរឬទេ? ខ្ញុំគិតថាលោកអ្នកនឹងមិនធ្វើអញ្ចឹងទេ។ លោកអ្នកនឹងមិនមានប្រតិកម្មផ្លូវអារម្មណ៍ដែលមានភាពភ័យខ្លាច ឬការបាក់ស្បាតឡើយ។ លោកអ្នកប្រហែលជាដឹងថាខ្ញុំជាមនុស្សឡប់សតិ ហើយគិតថាពាក្យដែលខ្ញុំនិយាយនេះមិនសមហេតុផល ព្រមទាំងទៅធ្វើកិច្ចការប្រចាំថ្ងៃដូចធម្មតា ដោយមិនខ្វល់ពីអ្វីដែលខ្ញុំប្រាប់។ ហេតុអ្វីទៅ? ព្រោះលោកអ្នកជឿជាក់យ៉ាងប្រាកដថាពណ៌ខៀវនោះគឺជាពណ៌ខៀវមែន!

នៅពេលនេះ ចូរយើងធ្វើការប្រៀបធៀបនូវឧទាហរណ៍របស់ខ្ញុំជាមួយនឹងការពិភាក្សារបស់យើងស្ដីអំពីជំនឿ។ ចុះប្រសិនបើលោកអ្នកជឿជាក់យ៉ាងប្រាកដអំពីអ្វីដែលព្រះជាម្ចាស់មានបន្ទូលពីការជាសះស្បើយរបស់លោកអ្នក ហើយគ្រូពេទ្យប្រាប់លោកអ្នកថាលោកអ្នកនឹងស្លាប់ដោយសារជំងឺមហារីក? លោកអ្នកនឹងមើលមុខគ្រូពេទ្យហើយគិតថាគាត់ជាមនុស្សឡប់សតិ ព្រោះលោកអ្នកបានដឹងថា គ្មានផ្លូវទេ។ ហេតុអ្វីទៅ? ដោយសារតែលោកអ្នកជឿជាក់យ៉ាងប្រាកដពីការប្រោសឲ្យជាដែលព្រះយេស៊ូបានបង់ថ្លៃរួចហើយ។ តើលោកអ្នកយល់ពីការនេះទេ? ជាការពិតណាស់មានមនុស្សជាច្រើនអធិស្ឋាន ប៉ុន្តែបើពិនិត្យមើលឲ្យល្អិតល្អន់ទៅ ខ្ញុំបានឃើញថាពាក្យអធិស្ឋានរបស់ពួកគេមិនមែនជាពាក្យអធិស្ឋាននៃជំនឿទេ ប៉ុន្តែជាពាក្យអធិស្ឋាននៃសេចក្ដីសង្ឃឹម ព្រោះពួកគេមិនប្រាកដថានឹងមានលទ្ធផលបែបណា។ មិត្តសម្លាញ់អើយ ហេតុនេះបានជាវាសំខាន់ដែលយើងកសាងខ្លួនឯងឡើង

ជាមួយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ យើងត្រូវស្គាល់ថាតើព្រះហឫទ័យរបស់ព្រះជាម្ចាស់ជាអ្វី ដើម្បីឲ្យយើងអាចមានទំនុកចិត្តនៅលើអ្វីដែលទ្រង់មានបន្ទូល ហើយក៏ដើម្បីឲ្យយើងអាចបដិសេធនូវអ្វីដែលមិនមែនជាព្រះហឫទ័យរបស់ទ្រង់ដែរ។ សូមអនុញ្ញាតឲ្យខ្ញុំប្រាប់នូវឧទាហរណ៍មួយទៀតពីជីវិតរបស់ខ្ញុំផ្ទាល់ ដែលបង្ហាញពីសារៈសំខាន់នៃការដែលយើងត្រូវបញ្ចុកខ្លួនឯងនូវអ្វីដែលព្រះជាម្ចាស់មានបន្ទូលអំពីជីវិត។

ខ្ញុំមានការនឿយហត់ណាស់ ព្រោះនៅពេលពីរបីសប្តាហ៍ជាប់ៗគ្នាជាពេលដ៏ពិបាកក្នុងនាមជាម្ចាស់អាជីវកម្ម (រឿងនេះកើតឡើងមុនកាលដែលខ្ញុំធ្វើជាគ្រូគង្វាល)។ កាលវិភាគរបស់ខ្ញុំរវល់ស្ទះជាមួយនឹងការទូរស័ព្ទរកអតិថិជន រួមទាំងសម្ពាធផ្នែកថវិកាពីការរស់នៅដោយកម្រៃជើងសារដែរ។ ខ្ញុំបានទៅជួបពេទ្យធ្មេញដើម្បីប៉ះធ្មេញដូចសព្វដង។ អ្វីៗទាំងអស់មានភាពធម្មតា រហូតដល់ពេទ្យធ្មេញបានចាក់ថ្នាំស្ពឹក Novocaine។ នៅពេលដែលគាត់ស៊កម្ជុលចូល ក៏ស្រាប់តែញ័ររញ្ជួយភ្លាម ហើយថ្គាមរបស់ខ្ញុំស្រាប់តែស្ពឹក ព្រោះតាមពិតវាគួរតែស្ពឹកបន្តិចម្តងៗ។ គាត់និយាយថា «អូហ៎ ខ្ញុំគិតថាខ្ញុំចាក់ចំសសៃប្រសាទហើយ។» ខ្ញុំក៏សួរគាត់ថា «តើនោះជាការធម្មតាឬអត់?» គាត់ថា «បាទ ប្រមាណជា ៨០ ទៅ ៨៥% វានឹងបានជាសះ ដោយគ្មានផលប៉ះពាល់អវិជ្ជមានអចិន្ត្រៃយ៍ឡើយ។»

ថាម៉េច? ភ្លាមៗនោះខ្ញុំស្រាប់តែមានអារម្មណ៍ភ័យខ្លាច។ នៅក្នុងគំនិតខ្ញុំ ចាប់ផ្តើមមានគំនិតនៃភាពភ័យខ្លាចចូលមក ហើយខ្ញុំគិតថា «ចុះឥឡូវ? តើវានឹងជាដែរឬទេ? បន្ទាប់ពីចេញពីការណាត់ជួបជាមួយពេទ្យ មុខរបស់ខ្ញុំនៅស្ពឹកមិនដូចជាការណាត់ជួបជាមួយពេទ្យធ្មេញរាល់ដងដែលភាពស្ពឹកនោះបានបាត់ទៅបន្តិចម្តងៗ។ នៅពេលនោះ ខ្ញុំកំពុងធ្វើដំណើរទៅជួបជាមួយអតិថិជនប្រហែលជាមួយម៉ោងទៀត បន្ទាប់ពីការជួបជាមួយពេទ្យធ្មេញ ដូច្នេះខ្ញុំមានពេលច្រើនដើម្បីគិតពីអ្វីដែលទើបតែបានកើតឡើង។ ប៉ុន្តែនៅតាមផ្លូវទៅជួបជាមួយអតិថិជន ខ្ញុំពិតជាតានតឹងក្នុងចិត្ត

ណាស់។ ខ្ញុំមិនមែនតានតឹងដោយសារតែការឈឺចាប់ទេ ប៉ុន្តែដោយសារតែកង្វះសេចក្ដីសុខសាន្ត និងភាពភ័យខ្លាចដែលកំពុងនៅរេរាជុំវិញគំនិតរបស់ខ្ញុំ។

នៅពេលដែលចេញពីការប្រជុំ ហើយកំពុងធ្វើដំណើរមកផ្ទះវិញនៅថ្ងៃនោះ ខ្ញុំក៏បានឆៀងចូលផ្ទះមិត្តភក្ដិម្នាក់។ មុខរបស់ខ្ញុំនៅស្ពឹកមិនទាន់បាត់ ហើយខ្ញុំកំពុងតែរកមើលឲ្យបានការធានាអះអាងខ្លះពីមនុស្សណាម្នាក់ថា មុខរបស់ខ្ញុំនឹងបានជា។ សូមកត់សម្គាល់ពីកំហុសរបស់ខ្ញុំៈ ដើម្បីទទួលបានទំនុកចិត្ត ខ្ញុំមិនបានមើលទៅកាន់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប៉ុន្តែបែរជាមើលទៅកាន់មនុស្សដែលមិនទាន់ជាអ្នកជឿរឹងមាំ។ ខ្ញុំបានប្រាប់មិត្តភក្ដិម្នាក់នេះពីអ្វីដែលបានកើតឡើង ហើយក៏រង់ចាំគេនិយាយថា «អាហ្នឹងមិនអីទេហ្កាវី។ វានឹងបានជា!» ផ្ទុយទៅវិញ គេបែរជានិយាយថា «អូហ៎ អត់ទេ! ខ្ញុំមានមិត្តភក្ដិម្នាក់ដែលធ្លាប់មានរឿងនេះកើតឡើងដែរ ហើយមុខរបស់គាត់មិនដែលបានជាសោះ។ ចាប់តាំងពីពេលនោះមក មុខរបស់គាត់ក៏ពិការ។ ខ្ញុំសឹងតែមិនជឿនូវអ្វីដែលខ្លួនបានឮ! នៅលនេះ គំនិតរបស់ខ្ញុំមានពេញដោយភាពភ័យខ្លាច។ ខ្ញុំធ្វើខ្លួនដូចជាដឹងថា វាមិនអីទេ ហើយក៏អរគុណសម្រាប់ពេលវេលារបស់គាត់។ ដោយការអស់សង្ឃឹម ខ្ញុំក៏បានឆៀងចូលផ្ទះមិត្តភក្ដិម្នាក់ទៀត ហើយសួរសំណួរដដែល។ ដោយអារម្មណ៍តក់ស្លុត ខ្ញុំបានឮចម្លើយដដែល។ ពួកគេថា «អូហ៎ អត់ទេ។ ខ្ញុំមានមិត្តម្នាក់ដែលមានរឿងនេះកើតឡើងដែរ ហើយមុខរបស់គេមិនបានជាឡើយ។ ផ្ទុយទៅវិញ មុខរបស់គេប្រែជាពិការមកទល់សព្វថ្ងៃ។»

**នៅពេលនោះ ខ្ញុំបានដឹងថាក្ដីសង្ឃឹមរបស់ខ្ញុំគឺមានតែព្រះបន្ទូលរបស់ព្រះជាម្ចាស់**

បន្ទាប់ពីចេញពីផ្ទះមិត្តភក្ដិខ្ញុំ ខ្ញុំមិនទាន់អស់ចិត្តឡើយ។ ខ្ញុំដឹងថាព្រះជាម្ចាស់ទ្រង់ប្រោសឲ្យជា (នៅក្នុងគំនិតខ្ញុំគិតអញ្ចឹង) ប៉ុន្តែខ្ញុំមិនអាចកម្ចាត់ភាពភ័យខ្លាចនោះសោះ។ ដួងចិត្តរបស់ខ្ញុំមិនទាន់ជឿជាក់ប្រាកដនៅឡើយទេ។ នៅយប់នោះ ខ្ញុំតប់ប្រមល់ជាខ្លាំង! គំនិតរបស់ខ្ញុំមានពេញទៅដោយភាពភ័យខ្លាច ហើយមុខរបស់

ខ្ញុំនៅស្ពឹកដូចកាលទៅជួបនឹងគ្រូពេទ្យអញ្ចឹង។ នៅពេលដែលខ្ញុំព្យាយាមគេងឲ្យលក់ ខ្ញុំចាប់ផ្តើមអារម្មណ៍ឈឺបន្តិចនៅក្រោមត្រចៀកខាងស្តាំ។ តើអាចដូចជាពាក្យគេថាមែនឬ?

ឪពុករបស់ខ្ញុំបានតយុទ្ធជាមួយនឹងជំងឺសសៃទាញនៅលើមុខ (bell's palsy) នៅពេលមួយឆ្នាំ ពីរឆ្នាំមុននេះ ហើយគាត់បានប្រាប់ខ្ញុំថាវាបានចាប់ផ្តើមដំបូងឡើងដោយឈឺក្រោមត្រចៀក។ ជំងឺសសៃទាញនៅលើមុខនេះកើតឡើងនៅពេលដែលសសប្រសាទដែលគ្រប់គ្រងលើសាច់ដុំផ្ទៃមុខ ដែលសសៃប្រសាទទាំងនោះធ្វើដំណើរឆ្លងកាត់ប្រហោងតូចៗនៅក្នុងឆ្អឹងក្រោមត្រចៀកត្រូវបានតឿ្យតដោយសារដំបៅ ឬការរលាក។

នៅពេលដែលខ្ញុំទម្រេតខ្លួនសំងំគេង ខ្ញុំឮតែពាក្យទាំងនោះនៅពេញត្រចៀកគឺ «អ្នកនឹងមានជំងឺសសៃទាញនៅលើផ្ទៃមុខដូចជាឪពុករបស់អ្នកជាមិនខាន។» នៅពេលដែលខ្ញុំភ្ញាក់ឡើងនាពេលព្រឹក ខ្ញុំបានកើតរោគសញ្ញាជំងឺសសៃទាញនៅលើផ្ទៃមុខមែន! នៅពេលនោះ ថ្គាមខ្ញុំមិនត្រឹមតែស្ពឹកប៉ុណ្ណោះទេ ប៉ុន្តែផ្ទៃមុខខ្ញុំទាំងមូលនៅផ្នែកខាងស្តាំក៏ស្ពឹកដែរ ហើយខ្ញុំមិនអាចបិទភ្នែក ឬបិទមាត់ជិតឡើយ។ វាពិតជារញ៉េរញ៉ៃណាស់។

ខ្ញុំបានទៅជួបគ្រូពេទ្យនៅក្នុងតំបន់ដើម្បីបញ្ជាក់ពីការសង្ស័យ។ បន្ទាប់ពីបានពិនិត្យរួចហើយ គាត់បានមើលមុខខ្ញុំហើយនិយាយថា ខ្ញុំពិតជាមានករណីជំងឺសសៃទាញមែន។ ខ្ញុំក៏សួរថា «ចុះបន្ទាប់មកទៀត តើមានអ្វីកើតឡើង?» គាត់និយាយថា «នៅក្នុងអត្រាពី ៨០ ទៅ ៨៥ %នៃករណីសរុប វានឹងបានជាដោយគ្មានការពិការអចិន្ត្រៃយ៍។» «តើអ្វីដែលខ្ញុំបានឮគាត់និយាយនេះ ជាការពិតដែរឬទេ?»

នៅពេលនោះ ខ្ញុំដឹងថាខ្ញុំកំពុងជួបនឹងបញ្ហា។ ខ្ញុំដឹងថាអារក្សនឹងមិនឈប់ត្រឹមនោះទេ ហើយខ្ញុំក៏មិនចង់ឃើញថាមានអ្វីកើតឡើងបន្ទាប់ពីនោះដែរ។ ខ្ញុំបានដឹងច្រើនគួរសមអំពីសង្គ្រាមខាងវិញ្ញាណ ហើយក៏យល់ថាខ្ញុំកំពុងតែដើរផ្លូវខុស។

សូមចាំថា រឿងនេះបានកើតឡើងជាច្រើនឆ្នាំមុនពេលដែលខ្ញុំបានយល់ច្បាស់អំពីកិច្ចការទាំងអម្បាលម៉ាននេះ។ ប៉ុន្តែ ខ្ញុំដឹងល្មមគ្រប់គ្រាន់ក្នុងការសម្គាល់ឃើញថា ខ្ញុំត្រូវប្រឈមមុខជាមួយនឹងបញ្ហានេះនៅក្នុងភពខាងវិញ្ញាណ ប្រសិនបើខ្ញុំចង់មានជោគជ័យលើវា។ ខ្ញុំក៏បានទទួលស្គាល់ថា វាជាការរៀបចំរបស់អារក្សដើម្បីឲ្យខ្ញុំធ្លាក់ចុះ នៅពេលដែលខ្ញុំនឿយហត់ ហើយមិនរំពឹងថានឹងមានបញ្ហាណាមួយនោះ។

នៅពេលនោះ ខ្ញុំបានដឹងថាក្តីសង្ឃឹមរបស់ខ្ញុំគឺមានតែព្រះបន្ទូលរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ ខ្ញុំផ្ទាល់ពុំមានសមត្ថភាពដើម្បីបញ្ឈប់ភាពភ័យខ្លាចដែលកំពុងតែយាយីដល់គំនិតរបស់ខ្ញុំឡើយ។ ដូច្នេះខ្ញុំបានសរសេរអត្ថបទគម្ពីរអំពីការប្រោសឲ្យជានៅលើកាតជាច្រើនដែលមានទំហំ ៣ x ៥ ហើយបិតកាតទាំងនោះនៅពេញជញ្ជាំងផ្ទះ។ ខ្ញុំបានកែប្រែចិត្តគំនិតនៅចំពោះព្រះអម្ចាស់ ហើយក៏បានចាប់ផ្តើមដំណើរការនៃការអភិវឌ្ឍជំនឿនៅក្នុងដួងចិត្ត។ ខ្ញុំបានដឹងថា ខ្ញុំចាំបាច់ត្រូវសាបព្រោះនៅក្នុងចិត្តរបស់ខ្ញុំ ដើម្បីឲ្យជំនឿអាចអភិវឌ្ឍបាន ដូច្នេះខ្ញុំក៏បានសញ្ជឹងគិតនៅលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ពេញមួយថ្ងៃ។

នៅពេលដំបូង ពុំមានអ្វីប្រែប្រួលឡើយ។ មុខរបស់ខ្ញុំនៅតែស្ពឹក ហើយខ្ញុំតែងតែតយុទ្ធជាមួយនឹងវិញ្ញាណនៃភាពភ័យខ្លាច។ វាគ្មានអ្វីកើតឡើងរហូតដល់ខ្ទង់មួយសប្តាហ៍ក្រោយមក វាក៏កើតឡើង! ដូចជាដំណើរការរបស់យើងនៅក្នុងគម្ពីរម៉ាកុស ៤៖២៦បង្រៀន គឺនៅពេលដែលខ្ញុំសាបព្រោះព្រះបន្ទូលចូលមកក្នុងចិត្តរបស់ខ្ញុំ ជំនឿបានដុះដាលឡើងដែលដំបូងវាជាពន្លក បន្ទាប់មកក៏ចេញក្បួរ ដាក់គ្រាប់ ហើយក៏ទុំដែលយើងអាចច្រូតបាន។

នៅក្នុងដំណើរការនេះទាំងមូល ពុំទាន់មានការយល់ស្រប និងជំនឿនៅឡើយទេ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនបានឃើញការផ្លាស់ប្តូរ ឬដឹងពីរបៀបដែលដំណើរការនេះធ្វើការដោយយោងតាមបទគម្ពីរម៉ាកុស ជំពូក ៤ គឺពិតជាមានការផ្លាស់ប្តូរមែន។ ការផ្លាស់ប្តូរដែលខ្ញុំកំពុងតែនិយាយនេះគឺមិនទាន់កើតឡើងនៅលើភពខាងធម្មជាតិនៅឡើយទេ ប៉ុន្តែការផ្លាស់ប្តូរគឺកើតឡើងនៅលើដួងចិត្តរបស់

យើង។ ប្រសិនបើយើងកាន់ជាប់នឹងព្រះបន្ទូល នោះព្រះបន្ទូលនឹងចាប់ផ្ដើមផ្លាស់ប្ដូរប្រព័ន្ធជំនឿនៃដួងចិត្តរបស់យើងពីដួងចិត្តនៃការមិនជឿ ទៅជាដួងចិត្តដែលយល់ស្របជាមួយស្ថានសួគ៌ដោយឯកឯង។ ដូច្នេះ នៅក្នុងករណីនេះ ខ្ញុំបានកាន់ជាប់នឹងព្រះបន្ទូល ដោយដឹងថានោះជាចម្លើយរបស់ខ្ញុំ។

ភ្លាមៗនោះ នៅថ្ងៃមួយដែលខ្ញុំដើរពេញផ្ទះរបស់ខ្ញុំដែលមានបិតកាត ៣x៥ ពេញជញ្ជាំងផ្ទះ ខ្ញុំក៏មើលចំកាតមួយដែលខ្ញុំបានឃើញរាប់រយដងមកហើយ។ ប៉ុន្តែលើកនេះ នៅពេលដែលខ្ញុំមើលទៅកាន់កាតនោះ វាបានទាក់ចិត្តខ្ញុំភ្លាម! ភ្លាមៗនោះ មានប្រេងតាំងហូរមកលើខ្ញុំ ភាពភ័យខ្លាចបានចាកចេញភ្លាម ហើយខ្ញុំ**បានដឹង**ថា ខ្ញុំបានជាហើយ។ មែនហើយ មុខរបស់ខ្ញុំនៅតែស្ពឹក។ មិនទាន់មានអ្វីប្រែប្រួលនៅឡើយ ប៉ុន្តែខ្ញុំដឹងថាខ្ញុំបានជាហើយ។ នៅពេលប៉ុន្មានម៉ោងក្រោយមក មុខរបស់ខ្ញុំបានប្រែជាធម្មតាទាំងស្រុង ហើយភាពស្ពឹកទាំងប៉ុន្មានក៏បានបាត់អស់។ សូមសរសើរព្រះជាម្ចាស់! ព្រះបន្ទូលពិតជាធ្វើការមែន!

ទោះបីជាខ្ញុំបានអនុញ្ញាតឲ្យជីវិតខាងវិញ្ញាណរបស់ខ្ញុំចុះទន់ខ្សោយដោយការព្រងើយកន្តើយ និងមានភាពមមាញឹក មិនយូរប៉ុន្មានខ្ញុំបានដឹងពីកំហុសរបស់ខ្ញុំ ហើយកែប្រែចិត្តគំនិតពីភាពល្ងង់ខ្លៅដែលខ្ញុំមាន។ ការនេះបានកើតឡើងតាំងពីពេលដែលខ្ញុំទើបនឹងរៀនពីរបៀបដែលជំនឿដំណើរការ ហើយខ្ញុំមិនទាន់មានបទពិសោធន៍ច្រើននៅលើផ្នែកនេះនៅឡើយទេ។ ខ្ញុំមើលទៅកាន់អ្វីដែលខ្ញុំបានធ្វើនៅពេលនោះ ដោយសួរមនុស្សឲ្យប្រាប់អំពីអនាគតរបស់ខ្ញុំនៅពេលដែលជួបបញ្ហា ជាជាងទៅរកព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយផ្ទាល់ ដែលការនេះជាទង្វើលេលាណាស់។ នៅពេលដែលខ្ញុំបានយល់ពីអ្វីដែលកំពុងតែកើតឡើង ខ្ញុំក៏បានបើកទៅព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយទំនុកចិត្ត។ គួរឲ្យសោកស្ដាយ មនុស្សជាច្រើនមិនមានទំនុកចិត្តនៅលើដំណើរការនេះទេ ព្រោះពួកគេមិនធ្លាប់មាននរណាបង្រៀនអំពីជំនឿ និងរបៀបដែលជំនឿកើតឡើងឡើយ។ ដោយហេតុថាពួកគេមិនបានដឹង

ពីដំណើរការនេះ នៅពេលដែលគេរងសម្ពាធ ពួកគេបានបោះបង់ចោលព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយគិតថាព្រះបន្ទូលមិនធ្វើការទេ។

## ការស្វែងយល់ពីការវាយប្រហាររបស់មារសាតាំង

អ្នកនាងគ្រីស្ទីនបានចូលមកក្រុមជំនុំរបស់យើងទាំងមិនបានដឹងច្រើនអំពីព្រះជាម្ចាស់ទេ។ នាងបានកើតជាថ្មីនៅក្នុងការប្រជុំពេលព្រឹកថ្ងៃអាទិត្យរបស់យើងមួយ ហើយជីវិតរបស់នាងបានផ្លាស់ប្រែគួរឲ្យកត់សម្គាល់។ នៅក្នុងក្រុមជំនុំរបស់យើង យើងមានថ្នាក់ដែលបង្រៀនអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ផ្នែកមួយដែលយើងបង្រៀនគឺអំពីសិទ្ធិស្របច្បាប់ក្នុងការទទួលការប្រោសឲ្យជា។ គ្រីស្ទីនមានបញ្ហាជាមួយនឹងការស្តាប់អស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ។ តាមពិត នាងបានពាក់ឧបករណ៍ជំនួយការស្តាប់អស់រយៈពេល ៤០ឆ្នាំ ហើយក៏បានបាត់បង់ការស្តាប់ខ្ទង់៥០%ដែរ។ ម្តាយរបស់នាងថ្លង់ ហើយបងប្រុសរបស់នាងក៏ជួបនឹងបញ្ហាថ្លង់នេះដែរ។ នៅពេលដែលគ្រីស្ទីនបានឮថាក្នុងនាមជាអ្នកជឿ នាងមានសិទ្ធិស្របច្បាប់ដើម្បីទទួលការជាសះស្បើយ នាងពិតជារំភើបណាស់!

នៅក្នុងថ្នាក់សិក្សានោះ ភរិយារបស់ខ្ញុំបានដាក់ដៃនៅលើនាង ហើយអធិស្ឋានឲ្យការស្តាប់របស់នាងបានបើកឡើង ហើយរំពេចនោះ នាងអាចឮបានយ៉ាងច្បាស់តែម្តង។ គ្រីស្ទីនបានចាប់ផ្តើមស្រែកផង យំផង លើកតម្កើងព្រះជាម្ចាស់ផង។ នៅពេលដែលភរិយារបស់ខ្ញុំឌ្រិនដានិងគ្រីស្ទីនបានមកប្រាប់ខ្ញុំពីដំណឹងល្អនោះ ខ្ញុំពិតជាមានអារម្មណ៍ថាចង់ដាស់តឿននាងអំពីការវាយប្រហាររបស់មារសាតាំង
ណាស់។ ខ្ញុំបានប្រាប់ឌ្រិនដាឲ្យបង្រៀនគ្រីស្ទីនថា ប្រសិនបើមានរោគសញ្ញាចាស់ចាប់ផ្តើមរើឡើងវិញ នោះនាងត្រូវប្រកាសដោយចិត្តក្លាហានទៅកាន់បញ្ហានោះ ហើយប្រកាសថានាងបានជាហើយ ហើយមារសាតាំងត្រូវថយចេញឲ្យឆ្ងាយ។ នៅព្រឹកបន្ទាប់ ការល្បងលក៏បានកើតឡើងមែន។ ការស្តាប់របស់នាងបានត្រលប់ទៅកាន់បញ្ហាចាស់ គឺនាងមិនអាចស្តាប់ឮបានច្បាស់ទេ។ ដូច្នេះ នាងបានធ្វើតាមអ្វីដែលយើងនិយាយគឺ «អត់ទេ មារសាតាំង ខ្ញុំមិនព្រមទទួលបញ្ហានេះឡើយ។ ខ្ញុំជា

សះស្បើយ ហើយខ្ញុំ*បាន*ជាសះស្បើយនៅក្នុងព្រះនាមព្រះយេស៊ូ!» ស្រាប់តែត្រចៀករបស់នាងបានបើកឡើង ហើយនាងអាចស្តាប់ឮតាំងពីពេលនោះមក។

សូមចាំថា មារសាតាំងនឹងវាយប្រហាររារាំង និងព្យាយាមកាន់កាប់ទឹកដីវិញ។ សូមកុំបណ្តោយឲ្យវាធ្វើដូច្នេះបានឲ្យសោះ។ សូមឈរមាំនៅលើព្រះបន្ទូលរបស់ព្រះបន្ទូលរបស់ព្រះជាម្ចាស់!

នៅក្នុងជំពូកនេះ ខ្ញុំបានចំណាយពេលខ្លះដើម្បីធ្វើការពន្យល់ដល់លោកអ្នកអំពីមូលដ្ឋានគ្រឹះនៃជំនឿ របៀបដែលជំនឿប្រតិបត្តិការ របៀបដែលដឹងថាលោកអ្នកពិតជាមានជំនឿឬយ៉ាងណា និងកន្លែងដែលយើងអាចទទួលបានជំនឿ។ ដើម្បីឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់ធ្វើប្រតិបត្តិការនៅក្នុងជីវិតរបស់លោកអ្នក លោកអ្នកចាំបាច់ត្រូវដឹងយ៉ាងនេះ។ សូមចាំថា ព្រះយេស៊ូបានប្រាប់ស្រ្តីនោះថា «កូនស្រីអើយ! ជំនឿរបស់នាងធ្វើឲ្យនាងជាសះស្បើយហើយ» ហើយដូច្នេះ សូមឲ្យសេចក្តីនេះសម្រាប់លោកអ្នកដែរ៖ ជំនឿរបស់លោកអ្នក ដួងចិត្តរបស់លោកអ្នកជឿជាក់យ៉ាងប្រាកដទាំងស្រុងអំពីអ្វីដែលស្ថានសួគ៌ប្រកាស ហើយយកកណ្តៀវមកច្រូតដែលក្លាយជាចម្លើយសម្រាប់បញ្ហា ឬតម្រូវការទាំងឡាយដែលលោកអ្នកអាចនឹងប្រឈមមុខនៅក្នុងជីវិត។

## ជំពូកទី៦

# ព្រះពររបស់ព្រះអម្ចាស់

ខ្ញុំនិងភរិយាកំពុងតែអង្គុយញ៉ាំអាហារពេលល្ងាចនៅក្នុងភោជនីយដ្ឋានមួយ ជាមួយនឹងគ្រូអធិប្បាយដែលមកអធិប្បាយនៅក្រុមជំនុំរបស់យើង។ នៅពេលនោះ ម៉ោងប្រហែលជា ១០ យប់ ហើយយើងទើបនឹងចប់ការប្រជុំក្រុមជំនុំពេលល្ងាចមួយ ដែលប្រកបដោយឫទ្ធានុភាពរបស់ព្រះជាម្ចាស់។ អ្នករត់តុបានដើរមកដើម្បីឲ្យយើង កុម្ម៉ង់អាហារ ហើយយើងក៏ចាប់ផ្ដើមជជែកលេង។ គ្រូអធិប្បាយដែលអង្គុយជាមួយ ខ្ញុំបានចាប់ផ្ដើមប្រាប់គាត់ថាការប្រជុំក្រុមជំនុំមានលក្ខណៈល្អយ៉ាងណា ហើយក៏ បានប្រាប់ពីក្រុមជំនុំរបស់យើងដែរ។ បន្ទាប់មកខ្ញុំក៏ពោលទៅកាន់អ្នករត់តុថា «តើ លោកចូលចិត្តបរបាញ់សត្វទេ?» គាត់ថាគាត់ចូលចិត្តការបរបាញ់ខ្លាំងណាស់។ គ្រូ អធិប្បាយនោះតែងតែរំភើបចង់ស្ដាប់ពីសាច់រឿងដែលទាក់ទងនឹងការបរបាញ់ ណាស់ ហើយតាមពិត ខ្ញុំបានជូនសៀវភៅរបស់ខ្ញុំដែលមានចំណងជើងថា Faith Hunt ដល់នាងនៅយប់នោះដែរ ដើម្បីជូនដល់មិត្តភក្ដិរបស់នាង។ ខ្ញុំបានទុក សៀវភៅដែលខ្ញុំនឹងផ្ញើជូនដល់នាងនៅលើកម្រាលឥដ្ឋក្បែរកៅអីរបស់ខ្ញុំ។

អ្នករត់តុនោះបានរៀបរាប់ជាបន្តបន្ទាប់ពីការដែលគាត់ធ្លាប់បរបាញ់ជាច្រើន លើកច្រើនសា ប៉ុន្តែមិនដែលបានក្ដាន់មួយក្បាលសោះ។ ភ្ញៀវរបស់ខ្ញុំ និងខ្ញុំបាន

ចាប់ផ្តើមពន្យល់ពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការ ហើយគាត់អាចរំពឹងថានឹងទទួលបានក្តាន់របស់គាត់នៅរាល់លើកដែលគាត់ចេញទៅបរបាញ់។ គាត់ពិតជាមិនសូវយល់ពីអ្វីដែលយើងបាននិយាយទេ។ ប៉ុន្តែ ខ្ញុំចាំថាខ្ញុំបានឲ្យសៀវភៅដែលនៅក្បែរខ្ញុំនោះទៅកាន់គាត់។ ខ្ញុំបានប្រាប់គ្រូអធិប្បាយដែលជាភ្ញៀវថា ខ្ញុំនឹងជូនសៀវភៅមួយច្បាប់ផ្សេង ហើយនាងក៏យល់ព្រម។ អ្នករត់តុបានអរគុណខ្ញុំ ហើយសន្យាថានឹងអានសៀវភៅ។ ខ្ញុំស្មានថាខ្ញុំនឹងលែងជួបគាត់ទៀតហើយ ប៉ុន្តែតាមពិតគឺមិនមែនអញ្ចឹងទេ។

មួយឆ្នាំក្រោយមក ភ្ញៀវអធិប្បាយដដែលបានមកក្រុមជំនុំរបស់យើងម្តងទៀត ហើយនាងបានប្រាប់ថានាងចូលចិត្តភោជនីយដ្ឋានដែលយើងបានទៅឆ្នាំមុន ហើយក៏សុំយើងឲ្យទៅទីនោះ។ ដូច្នេះ យើងក៏បានទៅភោជនីយដ្ឋាននោះ។ នៅពេលដែលយើងអង្គុយចុះ យើងក៏ភ្ញាក់ផ្អើលព្រោះបានជួបនឹងអ្នករត់តុដដែលដែលយើងបានជួបនៅឆ្នាំមុន។ នៅពេលដែលយើងដើរចូលទៅ គាត់បានមើលមុខយើង ហើយឧទានថា «អ្ហូ អ្នកទាំងបីបានមកទីនេះនៅឆ្នាំមុន ហើយយើងបានជជែកគ្នាពីការបរបាញ់សត្វក្តាន់។» យើងក៏ពោលថា «មែនហើយ យើងនៅចាំ។» គាត់ថា «ខ្ញុំបានអានសៀវភៅដែលលោកគ្រូឲ្យដល់ខ្ញុំ ហើយខ្ញុំបានធ្វើតាមអ្វីដែលសៀវភៅនោះចែង។ ខ្ញុំបាញ់បានក្តាន់ពីរក្បាលនៅឆ្នាំមុន ហើយក៏រំពឹងថានឹងទទួលបានក្តាន់របស់ខ្ញុំនៅឆ្នាំនេះដែរ។» យើងពិតជារំភើបនៅពេលដែលស្តាប់ឮពីសាច់រឿងរបស់គាត់ ប៉ុន្តែយើងក៏មិនបានភ្ញាក់ផ្អើលដែរ។ ព្រះរាជ្យដំណើរការនៅគ្រប់ពេលវេលា!

មានពេលមួយ ខ្ញុំបានរៀបចំការជួបជុំសម្រាប់គ្រូគង្វាលជាង ២៥ នាក់ ដោយបានពន្យល់ពួកគេពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងរបៀបដែលព្រះរាជ្យដំណើរការ។ វាជាការជួបជុំដ៏ល្អ។ នៅពេលដែលខ្ញុំហៀបនឹងចេញពីបន្ទប់ប្រជុំ ហើយបុគ្គលិករបស់ខ្ញុំកំពុងតែធ្វើការបោសសម្អាត មានគ្រូគង្វាលម្នាក់បានដើរចូលមកវិញ។ គាត់និងភរិយារបស់គាត់បានមកជួបប្រពន្ធរបស់ខ្ញុំ ហើយចង់និយាយជាមួយយើង។ គ្រូគង្វាលបានប្រាប់យើងថា ផ្ទះរបស់គាត់នឹងត្រូវគេរឹបអូសយកនៅចុងសប្តាហ៍នេះ

ប្រសិនបើគាត់គ្មានប្រាក់៦៩០០ដុល្លារទេនោះ។ គាត់បានពន្យល់ថា គាត់គ្មានប្រាក់សោះលើកលែងតែប្រាក់ ១០០ដុល្លារ ដែលគាត់កំពុងកាន់នៅក្នុងដៃ។ គាត់ពោលថា «ខ្ញុំមានប្រាក់តែប៉ុណ្ណឹងទេ តែខ្ញុំចង់សាបព្រោះវាដូចដែលលោកគ្រូបានបង្រៀននៅយប់នេះ ហើយចង់ឲ្យលោកគ្រូ និងអ្នកគ្រួយល់ស្របជាមួយខ្ញុំសម្រាប់ប្រាក់ដែលយើងត្រូវការនៅសប្ដាហ៍នេះ។» យើងបានរួមចិត្តគ្នា ហើយអធិស្ឋាន និងអរព្រះគុណព្រះជាម្ចាស់សម្រាប់ប្រាក់ដែលគាត់ត្រូវការ។

ជាងមួយខែក្រោយមក ខ្ញុំបានឃើញគ្រូគង្វាលដដែលនៅក្នុងព្រឹត្តិការណ៍មួយទៀត។ គាត់បានរត់មកជួបខ្ញុំទាំងក្ដីរំភើប ហើយពោលថា «ខ្ញុំចង់ប្រាប់លោកគ្រូពីអ្វីដែលបានកើតឡើង។ ខ្ញុំមិនបានប្រាប់លោកគ្រូពីរឿងនេះ នៅពេលដែលយើងបាននិយាយគ្នាលើកមុន ប៉ុន្តែខ្ញុំនិងភរិយាមានអាជីវកម្មបោះពុម្ពអាវយឺតតូចមួយដែលយើងធ្វើនៅឯក្នុងយានដ្ឋានរបស់យើងម្ដងម្កាល។ យើងមិនសូវជាកាក់កបជាមួយវាប៉ុន្មានទេ ប៉ុន្តែយូរម្ដងៗមានគេបញ្ជាទិញពីយើង។ នៅថ្ងៃដែលយើងបានអធិស្ឋានជាមួយលោកគ្រូ យើងបានទទួលការកុម្ម៉ង់មួយចំនួនដែលសរុបជាទឹកប្រាក់ស្មើនឹង ៨៩០០ដុល្លារ ដែលយើងត្រូវការដើម្បីលោះផ្ទះមកវិញ។ សូមអរគុណ!»

ខ្ញុំបានចូលរួមនៅឯសន្និបាតរបស់គ្រូគង្វាលក្នុងរដ្ឋណត្សស៍ ការ៉ូលីណា ដែលមានគ្រូគង្វាលជាង៥០០នាក់ចូលរួម។ ខ្ញុំមិនបង្រៀនអីទេ គឺគ្រាន់តែចូលរួមប៉ុណ្ណោះ។ មានបុរសម្នាក់បានដើរមកជួបខ្ញុំ ហើយថា «ខ្ញុំត្រូវការនិយាយជាមួយលោក។» គាត់ជាគ្រូគង្វាលមកពីប្រទេសអាល្លឺម៉ង់ ហើយគាត់ថាមានរឿងរ៉ាវគួរឲ្យចាប់អារម្មណ៍មួយចង់ប្រាប់ដល់ខ្ញុំ។

មិនដឹងជាដោយរបៀបណា កូនប្រុសរបស់គាត់ដែលមានវ័យជំទង់មានស៊ីឌីរបស់យើង។ បន្ទាប់ពីស្ដាប់ស៊ីឌីទាំងនោះចាប់ គាត់ (កូនប្រុស) បានសម្រេចចិត្តថានឹងទទួលឧបករណ៍ចាក់ PlayStation 3 ដោយជំនឿ ព្រោះគាត់ពុំមានលទ្ធភាពទិញវា។ ខ្ញុំជឿថាគ្រប់គ្នាស្គាល់ PlayStation 3 ប៉ុន្តែក្រែងលោលោកអ្នកមិនស្គាល់ វាគឺជាឧបករណ៍សម្រាប់លេងហ្គេមអេឡិចត្រូនិច។ គ្រូគង្វាលបានប្រាប់ខ្ញុំពីរបៀប

ដែលកូនប្រុសរបស់គាត់បានដើរចូលមកក្នុងការិយាល័យរបស់គាត់នៅថ្ងៃមួយ ហើយសុំឲ្យគាត់យល់ព្រមជាមួយខ្លួនថានឹងទទួលបានឧបករណ៍ PlayStation 3 មែន។ កូនប្រុសបានពន្យល់ទៅកាន់ឪពុកពីអ្វីដែលគាត់បានរៀនតាមរយៈការស្តាប់ស៊ីឌីមេរៀនរបស់ខ្ញុំ ហើយគាត់ចង់សាបព្រោះគាត់ពូជ និងអធិស្ឋានជាមួយឪពុករបស់គាត់ទាក់ទងនឹងការនេះ។ ដូច្នេះគ្រូគង្វាលក៏បានប្រាប់ខ្ញុំថា គាត់មិនបានគិតច្រើនពីវាឡើយ ប៉ុន្តែក្នុងនាមជាគ្រូគង្វាលប្រចាំក្រុមជំនុំ គាត់បានទទួលនូវគ្រាប់ពូជដែលកូនប្រុសបានសាបព្រោះ គឺជាតង្វាយផ្នែកថវិកាដែលកូនប្រុសនោះបានថ្វាយដល់ក្រុមជំនុំ។ គាត់និងកូនប្រុសបានអធិស្ឋានជាមួយគ្នា ហើយយល់ស្របថានៅពេលនេះកូនប្រុសនោះបានទទួល PlayStation 3 ហើយ។ ពួកគេក៏បានសន្មតថាបញ្ហានោះបានចប់សព្វគ្រប់ដែរ។

នៅថ្ងៃបន្ទាប់ មានបុរសម្នាក់នៅក្នុងក្រុមជំនុំបានទូរស័ព្ទមកគ្រូគង្វាលនោះ ហើយសួរថាតើកូនប្រុសរបស់គាត់ចង់រកប្រាក់បន្ថែមខ្លះដែរឬទេ ព្រោះគាត់មានការងាររយៈពេលខ្លីមួយដែលគាត់ត្រូវការអ្នកជួយ។ កូនប្រុសនោះរីករាយជាខ្លាំង ហើយបានរកប្រាក់ល្មមគ្រប់គ្រាន់នៅក្នុងពេលធ្វើការពីរថ្ងៃនោះដើម្បីទិញឧបករណ៍ PlayStation 3។

ការនេះបានធ្វើឲ្យយុវជននោះកាន់តែចាប់អារម្មណ៍ឡើង ហើយពីរបីសប្តាហ៍ក្រោយមក គ្រូគង្វាលបាននិយាយថាកូនប្រុសរបស់គាត់បានត្រលប់មកការិយា-ល័យគាត់ម្តងទៀត ហើយសុំឲ្យគាត់យល់ស្របជាមួយខ្លួននៅលើកិច្ចការមួយទៀត។ គ្រូគង្វាលក៏បានប្រាប់ខ្ញុំថា «ប្រាកដណាស់» ប៉ុន្តែគាត់ហាក់ដូចជាភ្ញាក់ផ្អើលបន្តិចនៅពេលដែលបានឮកូនប្រុសសុំឲ្យគាត់យល់ស្របថា ព្រះជាម្ចាស់នឹងប្រទានឲ្យគាត់មានសាច់ដុំធំជាងមុន។ គ្រូគង្វាលបានប្រាប់ខ្ញុំថា គាត់មិនដឹងថាត្រូវឆ្លើយទៅកាន់កូនប្រុសយ៉ាងណាទេនៅលើរឿងនេះ។ ប៉ុន្តែមិនយូរប៉ុន្មាន គាត់បានប្រាប់កូនប្រុសថាគាត់ត្រូវធ្វើកិច្ចការដែលគាត់គួរធ្វើនៅពេលទូលសុំសាច់ដុំពីព្រះជាម្ចាស់ គឺគាត់នឹងយល់ស្របជាមួយកូនដរាបណាកូនយល់ពីរឿងនោះ។ កូនប្រុសក៏បាន

យល់ព្រម។ ដូច្នេះ នៅលើកនេះទៀតកូនប្រុសក៏បានសាបព្រោះគ្រាប់ពូជ ហើយពួកគេក៏បានអធិស្ឋានយល់ស្របពីការនេះ។

នៅថ្ងៃស្អែកឡើង មានឡានមួយបានមកឈប់នៅមាត់ទ្វារផ្ទះគ្រូគង្វាល។ នៅក្នុងឡាននោះ គឺជាក្រុមគ្រួសារមួយដែលចូលរួមក្រុមជំនុំរបស់ពួកគេ។ នៅពេលដែលគ្រូគង្វាលចេញទៅនិយាយជាមួយពួកគេ គេពោលថាពួកគេបានបោសសម្អាតយានដ្ឋានក្នុងផ្ទះ ហើយឃើញដុំដែកមួយឈុតដែលគេគិតថាកូនប្រុសរបស់គ្រូគង្វាលប្រហែលជាចង់បាន។ បើកូនប្រុសមិនចង់បានទេ គ្រូគង្វាលប្រហែលជាស្គាល់នរណានៅក្នុងក្រុមជំនុំដែលចង់បានវា។ គ្រូគង្វាលបានប្រាប់ខ្ញុំថា ពុំមាននរណាបានដឹងថាកូនប្រុសរបស់គាត់ចង់បានសាច់ដុំធំជាងមុន ហើយពួកគេទើបតែបានអធិស្ឋានពីការនេះនៅយប់មិញប៉ុណ្ណោះ។ គ្រូគង្វាលបាននិយាយថា គាត់ពិតជាភ្ញាក់ផ្អើលណាស់! គាត់បានចូលទៅក្នុងផ្ទះហើយនិយាយទៅកាន់កូនប្រុសថា «តើស៊ីឌីទាំងនោះនៅឯណា?»

សាច់រឿងបែបនេះជារឿងធម្មតា។ ខ្ញុំឧស្សាហ៍ឮពីវាញឹកញាប់ណាស់ ហើយខ្ញុំក៏ចង់ឲ្យសាច់រឿងបែបនេះក្លាយជារឿងធម្មតានៅក្នុងជីវិតរបស់លោកអ្នកដែរ។ មកដល់ចំណុចនេះ យើងបានបកស្រាយ និងពិភាក្សាពីទិដ្ឋភាពសំខាន់ៗមួយចំនួនពីរបៀបដែលច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការ ក៏ដូចជារបៀបដែលការយល់ស្រប ឬជំនឿជាការចាំបាច់ដើម្បីឲ្យស្ថានសួគ៌ទទួលបានសិទ្ធិស្របច្បាប់នៅលើភពផែនដី។ នៅពេលនេះ ចូរយើងមើលកាន់តែស៊ីជម្រៅជាងមុនពីរបៀបដែលច្បាប់នៃព្រះរាជ្យអាចជួយដល់សេចក្តីត្រូវការរបស់យើងនៅលើថវិកា។

*អំណោយពរនៃព្រះយេហូវ៉ា នោះធ្វើឲ្យទៅជាមាន ហើយទ្រង់មិនបន្ថែមសេចក្តីទុក្ខព្រួយផងទេ។*

- សុភាសិត ១០៖២២ (ព្រះគម្ពីរបរិសុទ្ធ)

នៅពេលដែលខ្ញុំទើបនឹងបានឃើញខគម្ពីរនេះ ខ្ញុំគិតថា «តើខគម្ពីរនេះមិនមែនចង់បានថាអញ្ចឹងទេ មែនទេ?» ប៉ុន្តែ ខ្ញុំបានឃើញថា ខគម្ពីរនេះពិតជាមានន័យបែបហ្នឹងមែន! ដើម្បីយល់ពីអត្ថន័យនៃអត្ថបទគម្ពីរនេះ យើងត្រូវមើលទៅកាន់ដើមដំបូងកាលដែលព្រះជាម្ចាស់ទើបបង្កើតមនុស្សសិន។

*ផ្ទុយទៅវិញ មានម្នាក់បានផ្តល់សក្ខីភាពនៅក្នុងវគ្គមួយដែលចែងថា៖*

*«តើមនុស្សមានឋានៈអ្វីបានជាព្រះអង្គនឹកដល់គេដូច្នេះ? តើបុត្រមនុស្សជាអ្វីដែរបានជាព្រះអង្គយកព្រះហឫទ័យទុកដាក់នឹងគេយ៉ាងនេះ»? «ព្រះអង្គបានធ្វើឲ្យគេមានឋានៈទាបជាងទេវតាតែមួយរយៈប៉ុណ្ណោះ ព្រះអង្គប្រទានសិរីរុងរឿង និងកិត្តិយសដល់គេទុកជាមកុដរាជ្យ ព្រះអង្គបានបង្ក្រាបអ្វីៗទាំងអស់ឲ្យនៅក្រោមជើងរបស់គេ» ។*

*ព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ ឥតទុកឲ្យមានអ្វីមួយនៅសល់ដែលពុំបានចុះចូលនោះឡើយ។ ក៏ប៉ុន្តែ នៅពេលនេះ យើងពុំឃើញថា អ្វីៗសព្វសារពើសុទ្ធតែបានចុះចូលនឹងអំណាចរបស់មនុស្សហើយនោះទេ។*

ហេប្រឺ ២៖៦-៨ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

យើងបានអានអត្ថបទគម្ពីរនេះពីមុនម្តងរួចមកហើយ ប៉ុន្តែវាជាការចាំបាច់សម្រាប់ការពិភាក្សារបស់យើងនៅពេលនេះ។ ជាការរំឭកឡើងវិញ នៅពេលដែលព្រះជាម្ចាស់បានបង្កើតមនុស្សមក អ្វីៗទាំងអស់ត្រូវបានដាក់ក្រោមការត្រួតត្រារបស់គាត់។ ពុំមានអ្វីមួយដែលមិនបានចុះចូលនឹងគាត់ឡើយ។ គាត់បានត្រួតត្រានៅលើផែនដីដោយមុខតំណែងមួយដែលព្រះជាម្ចាស់បានផ្ទេរសិទ្ធិអំណាចដល់

គាត់ ហើយក៏ពាក់មកុដនៃរាជរដ្ឋាភិបាលដែលគាត់តំណាងឲ្យដែរ។ គាត់ត្រូវបានបំពាក់ដោយការចាក់ប្រេងតាំង ហើយទទួលកិត្តិយសជាមួយនឹងសិទ្ធិអំណាចដែលគាត់បានទទួល។ មារសាតាំងដែលបានបះបោរប្រឆាំងនឹងព្រះជាម្ចាស់ត្រូវបានបោះមកលើផែនដីមុនពេលដែលអដាំបានមានវត្តមាន។ មារសាតាំងស្អប់មនុស្ស នៅពេលដែលវាបានរកឃើញថាវាត្រូវបានត្រួតត្រាដោយមនុស្ស ជាអ្នកដែលបានទទួលមកុដនៃសិទ្ធិអំណាចរបស់ព្រះជាម្ចាស់។ នៅពេលនេះ មារសាតាំងត្រូវចុះចូលនឹងមនុស្សលោកដែលជាស្នាព្រះហស្តព្រះជាម្ចាស់។ បើគិតតាមផ្នែកធម្មជាតិ មនុស្សលោកមានកម្លាំងខាងឯរូបកាយទន់ខ្សោយជាងវាឆ្ងាយណាស់។ បើគិតតាមខាងវិញ្ញាណវិញ ពាក្យទាំងប៉ុន្មានដែលអដាំនិយាយគឺមានសិទ្ធិអំណាចស្មើនឹងព្រះជាម្ចាស់មានបន្ទូលផ្ទាល់ដែរ។ លោកអដាំ ក្នុងនាមជាកូនប្រុសរបស់ព្រះជាម្ចាស់បានត្រួតត្រានៅលើផែនដីចេញពីមុខតំណាងដ៏ខ្ពង់ខ្ពស់ ដែលមានសិទ្ធិអំណាច និងភាពរុងរឿង។

**«អំណោយពរនៃព្រះយេហូវ៉ា នោះធ្វើឲ្យទៅជាមាន ហើយទ្រង់មិនបន្ថែមសេចក្តីទុក្ខព្រួយផងទេ។»**

ដូច្នេះ មារសាតាំងស្អប់មនុស្សរូបនេះ ហើយចង់បានសិទ្ធិអំណាចដែលគាត់មាននៅលើផែនដី។ ដំណោះស្រាយដែលវាគិតគឺមានតែលួចយកមកុដ ដែលតំណាងឲ្យមុខតំណែងដែលមនុស្សមានប៉ុណ្ណោះ។ មានបញ្ហាបន្តិចនៅត្រង់នេះ គឺមារសាតាំងពុំមានអំណាចដើម្បីលួចមកុដពីអដាំទេ។ តាមពិត វាសង្ឃឹមថាវាអាចបញ្ឆោតអដាំឲ្យដោះមកុដដោយខ្លួនឯង។ ដោយការបញ្ឆោតនាងអេវ៉ាថាពួកគេមិនគួរទុកចិត្តលើព្រះជាម្ចាស់ ហើយជីវិតរបស់គេគឺមានច្រើនជាងការដែលព្រះជាម្ចាស់បានប្រទានមក លោកអដាំនិងនាងអេវ៉ាបានជ្រើសរើសជឿលើមារសាតាំងជាជាងព្រះជាម្ចាស់ ហើយបានក្បត់នឹងព្រះជាម្ចាស់។ នៅចុងបញ្ចប់ លោកអដាំនិងនាងអេវ៉ាបានបាត់បង់នូវមុខតំណែងស្របច្បាប់របស់ខ្លួន ដែលជាមុខតំណែងមាននូវសិទ្ធិ

អំណាចក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយមារសាតាំងបានក្លាយជាព្រះនៃលោកីយ៍នេះ ដូចដែលយើងបានឃើញលោកប៉ូលបរិយាយនៅក្នុងគម្ពីរកូរិនថូសខ្សែទី២។

*ជាអ្នកមិនជឿដែលត្រូវព្រះនៃលោកីយ៍នេះធ្វើឲ្យចិត្តគំនិតរបស់គេទៅជាងងឹត មិនឲ្យគេឃើញពន្លឺរស្មីដ៏រុងរឿងនៃដំណឹងល្អរបស់ព្រះគ្រិស្ត ជាតំណាងរបស់ព្រះជាម្ចាស់នោះឡើយ។*

២កូរិនថូស ៤៖៤ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

មុនពេលដែលលោកអដាំបានបះបោរ គាត់បានរីករាយនឹងប្រយោជន៍ក្នុងឋានៈជាកូនប្រុស។ អ្វីៗទាំងប៉ុន្មានដែលព្រះជាម្ចាស់មានគឺជារបស់គាត់ ហើយគាត់មិនដែលជួបថ្ងៃណាមួយដែលខ្វះខាត ឬភ័យខ្លាចសោះឡើងនៅក្នុងឆាកជីវិត។ អ្វីៗដែលគាត់ត្រូវការដើម្បីរស់នៅលើភពផែនដី ត្រូវបានប្រទានមកនៅចំពោះមុខគាត់មុនពេលដែលគាត់កើតមកទៅទៀត។

ប្រសិនបើយើងឆ្លុះបញ្ចាំងត្រលប់ទៅកាន់ថ្ងៃទីប្រាំមួយដែលព្រះជាម្ចាស់បានបង្កើតសកលលោកនៅក្នុងគម្ពីរលោកុប្បត្តិ យើងឃើញថាព្រះជាម្ចាស់បានបង្កើតបុរសនៅចុងថ្ងៃទីប្រាំមួយ គឺជាផ្នែកចុងក្រោយនៃផែនការបង្កើតរបស់ព្រះជាម្ចាស់។ ព្រះអង្គបានរៀបចំជោគវាសនាឲ្យគាត់រស់នៅក្នុងថ្ងៃទីប្រាំពីរ ជាថ្ងៃដែលព្រះជាម្ចាស់បានប្រកាសថាថ្ងៃសម្រាក។ នេះមិនមែនដោយសារតែព្រះជាម្ចាស់ទ្រង់ហត់នឿយទេ ប៉ុន្តែដោយសារតែទ្រង់បានបញ្ចប់កិច្ចការ ហើយអ្វីៗទាំងអស់ចប់សព្វគ្រប់ហើយ។ សូមគិតមួយភ្លែតពីអ្វីដែលព្រះជាម្ចាស់បានបង្កើតមក និងផែនការដ៏រុងរឿងដែលទ្រង់បានរៀបចំសម្រាប់មនុស្ស។ គួរឲ្យសោកស្តាយ លោកអដាំបាន

ប្រគល់អ្វីៗដែលគាត់ធ្លាប់មានទៅឲ្យមារ ហើយគាត់បានបាត់បង់សិទ្ធិនៅក្នុងការឈរស្របច្បាប់ក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់បន្តិចម្តងៗ។

នៅពេលដែលព្រះជាម្ចាស់បានចូលទៅជួបគាត់ បន្ទាប់ពីគាត់បានសម្រេចចិត្តក្នុងការមិនស្តាប់បង្គាប់ទ្រង់ ព្រះជាម្ចាស់បានមានបន្ទូលទៅកាន់អដាំថា៖

> *ដីនឹងត្រូវបណ្តាសា ព្រោះតែអ្នក។ ដូច្នេះ អ្នកនឹងកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនាជារៀងរាល់ថ្ងៃ អស់មួយជីវិត។ ដីនឹងដុះចេញជាបន្លា និងអញ្ចាញ ហើយអ្នកនឹងបរិភោគតិណជាតិទាំងឡាយដែលដុះនៅតាមទីវាល។ អ្នកត្រូវរកស៊ីចិញ្ចឹមជីវិតទាំងបង្ហូរញើស រហូតដល់ថ្ងៃដែលអ្នកត្រលប់ទៅជាដីវិញ ដ្បិតអ្នកមានកំណើតមកពីដី។ អ្នកកើតពីធូលីដី អ្នកត្រូវតែត្រលប់ទៅជាធូលីដីវិញ»។*

លោកុប្បត្តិ ៣៖១៧-១៩ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

រឿងទីមួយដែលខ្ញុំចង់ឲ្យលោកអ្នកយល់គឺ ព្រះជាម្ចាស់មិនបានដាក់បណ្តាសាផែនដីទេ តែជាអដាំទេដែលបានដាក់បណ្តាសាផែនដី។ គាត់មានសិទ្ធិត្រួតត្រាពេញលេញនៅលើផែនដី។ គាត់គឺជាអ្នកមើលថែរក្សាផែនដី។ លោកអដាំដែលមានសិទ្ធិត្រួតត្រាពេញលេញ និងទាំងស្រុងនៅលើផែនដី បានក្បត់នឹងរាជរដ្ឋាភិបាលរបស់ព្រះជាម្ចាស់ ហើយបើនិយាយឲ្យចំទៅ គាត់បានដេញព្រះជាម្ចាស់ចេញ។ ការសម្រេចចិត្តមួយនេះមិនត្រឹមតែមានលទ្ធផលអាក្រក់សម្រាប់អដាំប៉ុណ្ណោះទេ ប៉ុន្តែក៏នៅលើផែនដីទាំងមូល និងមនុស្សគ្រប់ៗរូបដែលរស់នៅលើផែនដីចាប់តាំងពីគ្រានោះដែរ។ ទោះបីជាគាត់នៅតែមានសិទ្ធិនៅលើភពផែនដីដែលព្រះជាម្ចាស់បានប្រទានដល់គាត់ នៅពេលនេះគាត់លែងមានអំណាចដើម្បីត្រួតត្រានៅក្នុងនាមជាអ្នកដែលមានមកុដ និងរាជរដ្ឋាភិបាលដែលគាត់ធ្លាប់តែតំណាងឲ្យ

និងគាំទ្រដល់ការគ្រប់គ្រងរបស់គាត់ហើយ។ លោកអដាំមិនបានយល់ពីការបែកចេញពីជីវិតឬសេចក្តីស្លាប់ទេ ហើយសេចក្តីស្លាប់បានក្លាយជាអ្នកត្រួតត្រាវិញ។

ព្រះជាម្ចាស់បានកែតម្រូវអដាំជាមួយនឹងអ្វីដែលគាត់បានធ្វើ ហើយប្រាប់ដល់អដាំថានៅពេលនេះ គឺតាមរយៈអំពើបាបរបស់គាត់ គាត់បានបាត់បង់មុខតំណែងស្របច្បាប់នៅក្នុងរាជរដ្ឋាភិបាលរបស់ព្រះជាម្ចាស់។ ទីមួយ ដោយហេតុថាអដាំជាអ្នកតំណាងឲ្យរាជរដ្ឋាភិបាលនោះនៅលើផែនដី ស្ថានសួគ៌បានបាត់បង់នូវអ្នកតំណាងស្របច្បាប់របស់ខ្លួន ដែលតាមរយៈអ្នកតំណាងនោះទើបស្ថានសួគ៌មានសិទ្ធិស្របច្បាប់នៅលើភពផែនដី។ ទីពីរ ភពផែនដីផ្ទាល់បានរងនូវផលប៉ះពាល់ ហើយលែងបង្កើតឲ្យមានជាការផ្គត់ផ្គង់ដូចកាលនៅសួនអេដែនទៀតហើយ។ នៅពេលនេះ អដាំត្រូវកាប់គាស់រកស៊ីចិញ្ចឹមជីវិតនៅលើផែនដីទាំងវេទនា និងបង្ហូរញើស ដើម្បីឲ្យផែនដីបង្កើតផលផ្លែដែលគាត់ត្រូវការ និងចិញ្ចឹមជីវិត។ គឺនៅពេលនេះ មានបន្លា និងអញ្ចាញដុះពាសពេញវាលដំណាំ ហើយជីវិតរបស់មនុស្សប្រែជាពិបាក ដោយគេព្យាយាមធ្វើយ៉ាងណាឲ្យបានរស់រានមានជីវិត។

ខ្ញុំហៅការនេះថាជារបៀបដ៏លំបាកលំបិននៃជីវិត និងជាផ្នត់គំនិតត្រដររស់។ នេះជាផ្នត់គំនិតដែលត្រូវបានបង្ខូចដោយសារឥទ្ធិពលនៃភាពភ័យខ្លាច និងសេចក្តីស្លាប់ដែលជាបន្ទុកនៅលើមនុស្សគ្រប់ៗរូបដែលកើតចេញពីលោកអដាំ និងរស់នៅក្នុងប្រព័ន្ធនៃផែនដីដែលរងបណ្តាសា។ លោកអ្នក ហើយនិងខ្ញុំផ្ទាល់បានចម្រើនវ័យឡើងនៅលើផែនដីនេះ ហើយយើងក៏ស្គាល់ច្បាស់ពីប្រព័ន្ធត្រដររស់នេះដែរ។ ស្តេចដាវីឌហៅវាថាជាជ្រលងភ្នំនៃម្លប់សេចក្តីស្លាប់ នៅក្នុងទំនុកតម្កើង ២៣៖

> *អើ ទោះបើទូលបង្គំដើរកាត់ច្រកភ្នំនៃម្លប់សេចក្តីស្លាប់ក៏ដោយ គង់តែមិនខ្លាចសេចក្តីអាក្រក់ណាឡើយ ដ្បិតទ្រង់គង់នៅជាមួយនឹងទូលបង្គំ។*
>
> ទំនុកតម្កើង ២៣៖៤ (ព្រះគម្ពីរបរិសុទ្ធ)

វាជាភពមួយដែលមនុស្សមានចិត្តគំនិតខ្លាចស្លាប់។ ប៉ុន្តែក៏មានលទ្ធផលអវិជ្ជមានមួយទៀតដែរ។ មនុស្សបានបាត់បង់ទំនាក់ទំនងជាមួយព្រះជាម្ចាស់ ហេតុនេះហើយ ជាលទ្ធផលយើងមិនបានស្គាល់ខ្លួនឯង។ យើងបានបាត់បង់នូវគោលបំណង និងជោគវាសនាដែលព្រះជាម្ចាស់បានបង្កើតយើងមក។ នៅពេលដែលព្រះជាម្ចាស់បង្កើតមនុស្ស ទ្រង់បានប្រទានគោលបំណង ឬបេសកកម្មដល់មនុស្ស។ គាត់ត្រូវត្រួតត្រានៅលើផែនដីតំណាងឲ្យព្រះជាម្ចាស់។ យើងអាចនិយាយបានថាគាត់មានបេសកកម្ម និងគោលបំណងពីព្រះជាម្ចាស់សម្រាប់ជីវិតរបស់គាត់។ ប៉ុន្តែនៅពេលនេះផ្នត់គំនិតរបស់មនុស្សទាំងមូលបានផ្លាស់ប្តូរទៅផ្តោតលើការខិតខំត្រដររស់វិញ។ ការខិតខំត្រដររស់បានក្លាយជាគោលបំណងរបស់គាត់ ហើយគោលបំណងថ្មីនោះបានក្លាយជាបេសកកម្មថ្មីរបស់គាត់។

**នៅលើប្រព័ន្ធបណ្តាសាផែនដីនៃការត្រដររស់ មនុស្សគ្រប់ៗរូបមានភាពនឿយណាយនឹងការរត់ណាស់។**

នៅពេលនេះ ការសម្រេចចិត្តទាំងអម្បាលម៉ានដែលមនុស្សធ្វើគឺបានកើតឡើងដោយឆ្លុះបញ្ចាំងចេញពីបណ្តាសានៃការត្រដររស់នេះ។ ការសម្រេចចិត្តបែបនោះអាចទាក់ទងនឹងការស្វែងរក ឬលាក់បាំងនូវការផ្គត់ផ្គង់។ ពួកគេពុំមានសុខសន្តិភាពទេ។ ជារៀងរាល់ថ្ងៃគឺពោរពេញដោយការធ្វើការលំបាកៗ ធ្ងន់ៗដោយក្តីវេទនា និងបង្ហូរញើសឈាម។ ច្រកចេញតែមួយដែលគេអាចរួចផុតពីជីវិតដែលត្រដររស់ជាជីវិតដែលមនុស្សនៅសម័យនេះហៅថាលានប្រណាំងកណ្តុរ គឺគេត្រូវធ្វើយ៉ាងណារក្សាទុកនូវស្បៀងអាហារ និងការផ្គត់ផ្គង់គ្រប់គ្រាន់ដើម្បីកុំឲ្យយើងខិតខំរត់នៅលើលាននោះទៀត។ នេះហើយជាក្តីសុបិនរបស់បុរស និងស្ត្រីគ្រប់ៗរូបចាប់តាំងពីពេលដែលមនុស្សបានធ្លាក់ចុះ។ នេះជាគោលដៅលេខមួយរបស់ពួកគេ គឺខំធ្វើយ៉ាងណាលែងរត់ប្រណាំងទៀត។ អ្នកណាដែលមាន

សំណាងទទួលបានការទំនុកបម្រុងច្រើនលើសលប់ គេក៏ត្រូវលាក់វាទុក ទាំងការពារ និងថែរក្សាវាឲ្យបានល្អផង។ ពួកគេខំទុកវាទាំងភ័យខ្លាចពីការបាត់បង់វា ព្រោះបើគេបាត់វានោះគេនឹងត្រូវបានបង្ខំ ឬជាប់ជាខ្ញុំបម្រើក្នុងការត់នៅលើជីវិតដែលវេទនា និងបង្ហូរញើសម្តងទៀតមិនខាន។

ក្តីសុបិនរបស់មនុស្ស ជាគោលដៅនៃការរស់រានរបស់គេ គឺដូចជាខ្ញុំបាននិយាយអញ្ចឹង គេខំធ្វើយ៉ាងណាស្វែងរកឲ្យខ្លួនបានទទួលការផ្គត់ផ្គង់គ្រប់គ្រាន់ដើម្បីឲ្យខ្លួនលែងរត់ជាខ្ញុំបម្រើនៃការត្រដររស់ និងទទួលបានការសម្រាក។ ខ្ញុំចង់ប្រាកដថា លោកអ្នកយល់បានច្បាស់ពីការពិតនេះ៖ នៅលើប្រព័ន្ធបណ្តាសាផែនដីនៃការត្រដររស់ មនុស្សគ្រប់ៗរូបមានភាពនឿយណាយនឹងការរត់ណាស់។

ខ្ញុំចាំពេលមួយដែលខ្ញុំអង្គុយជជែកជាមួយគ្រូគង្វាលម្នាក់នៅព្រឹកមួយ។ គាត់បានប្រាប់ខ្ញុំថា គាត់ពេញចិត្តនឹងព័ន្ធកិច្ចណាស់។ នៅរៀងរាល់ព្រឹក គាត់ក្រោកឡើងទាំងនឹកចាំពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។ គាត់ដឹងថា ខ្លួននៅជំពាក់បំណុលគេ ហើយមានការខ្វះខាតថវិកា។ គាត់បន្ថែមទៀតថា បញ្ហាថវិការបស់គាត់គឺដូចជាគេបានយកភួយក្រាស់ដែលសើមជោកមកដណ្តប់ធ្វើឲ្យគាត់ថប់ដង្ហើម ហើយលួចអំណរទាំងប៉ុន្មាននៅលើកិច្ចការដែលគាត់ធ្វើ។ មិនមែនមានតែគ្រូគង្វាលទេដែលបានប្រឈមមុខនឹងបញ្ហានេះ។ វាជារបៀបរស់នៅរបស់ក្រុមគ្រួសារភាគច្រើននៅពេលដែលរស់នៅដោយជំពាក់បំណុល និងត្រដាបត្រដួស។

មនុស្សគ្រប់ៗរូបកំពុងតែរកច្រកចេញ ហើយច្រកចេញតែមួយគឺទ្រព្យសម្បត្តិ។ គេធ្វើយ៉ាងណាឲ្យមានទ្រព្យសម្បត្តិលើសពីគ្រប់គ្រាន់។ នៅក្រោមប្រព័ន្ធបណ្តាសានៃផែនដី អត្តសញ្ញាណរបស់មនុស្សត្រូវបានកំណត់ដោយទ្រព្យសម្បត្តិដែលលោកអ្នកមាន និងលុយដែលលោកអ្នករកបាន។

ទីមួយ មនុស្សបានព្យាយាមលៃលកគ្របបាំងភាពអាក្រាតរបស់ខ្លួន។ នេះជារូបភាពតំណាងឲ្យការដែលមនុស្សបានបាត់បង់នូវគោលបំណង និងអត្តសញ្ញាណ

ដ៏ពិតដែលព្រះជាម្ចាស់បានបង្កើតគេមក ហើយគេបានចាប់យករបស់ក្លែងក្លាយវិញ។ នៅពេលនេះ មនុស្សបានព្យាយាមជំនួសការចាក់ប្រេងតាំងរបស់ព្រះជាម្ចាស់ដែលបានហ៊ុំព័ទ្ធនៅលើគាត់ដោយសិរីរុងរឿង និងទ្រព្យសម្បត្តិ។ ទីពីរ គាត់ក៏បានព្យាយាមជំនួសមុខតំណែង និងមកុដរបស់គាត់ ជាមកុដនៃកិត្តិយសដែលគាត់បានត្រួតត្រានៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយចាប់យកអំណួតនៃជីវិត និងការត្រួតត្រានៅលើមនុស្សដទៃទៀត។ នៅពេលនេះ មនុស្សមានសេចក្ដីមួយដែលគេប្រាថ្នា គឺការរកទ្រព្យសម្បត្តិ ហើយលាក់វាទុក។ គាត់បានទទួលអត្តសញ្ញាណតាមរយៈទ្រព្យសម្បត្តិដែលគាត់រកបាន និងអំណាចដែលគាត់អាចប្រើប្រាស់នៅលើមនុស្សដទៃទៀត។ មុខតំណែង និងកេរ្តិ៍ឈ្មោះនៅក្នុងសង្គមមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីឲ្យមនុស្សដែលបានធ្លាក់ចុះ មានអារម្មណ៍ពីតម្លៃរបស់ខ្លួន។

សូមគិតពីការនេះ។ តើនៅពេលដែលមនុស្សជួបគ្នា គេសួរសំណួរបែបណាមុនគេ? «តើអ្នកធ្វើការអីដែរ?» ហេតុអ្វីទៅ? តើយើងពិតជាចាប់អារម្មណ៍ ឬខ្វល់ខ្វាយពីគាត់ដល់ថ្នាក់ហ្នឹងឬ? មិនមែនទេ ប៉ុន្តែយើងសួរសំណួរនេះគឺដើម្បីឲ្យដឹងថា យើងគួរគោរពគាត់នៅក្នុងកម្រិតណា។ យើងអាចនិយាយបានថា យើងកំពុងតែសួរខ្លួនឯងថា «តើបុរសម្នាក់នេះជានរណា? តើគាត់មានមុខតំណែង ឬកេរ្តិ៍ឈ្មោះបែបណានៅលើភពផែនដី? តើខ្ញុំត្រូវផ្ដល់កិត្តិយស និងការគោរពដល់គាត់ខ្លាំងប៉ុណ្ណា?» នៅពេលនេះ ខ្ញុំគ្រាន់តែនិយាយពីទស្សនៈរបស់បុរសប៉ុណ្ណោះ។ សម្រាប់លោកអ្នកដែលជាស្ត្រី ខ្ញុំដឹងថាលោកអ្នកមានទស្សនៈខុសគ្នាស្រលះទាក់ទិននឹងអត្តសញ្ញាណ។

នៅសព្វថ្ងៃនេះ ប្រព័ន្ធផែនដីដែលបានរងបណ្ដាសានេះក៏នៅតែមានឥទ្ធិពលដែរ! មនុស្សបានធ្វើការសម្រេចចិត្តតាមរយៈផ្នត់គំនិតបែបរកប្រាក់ ឬលាក់ប្រាក់។ មានអ្នកខ្លះបានរើផ្ទះទៅរស់នៅស្រុកផ្សេង ដើម្បីទទួលបានការងារដែលបានប្រាក់ចំណូលខ្ពស់ជាងមុន ទាំងពុំបានគិតពីគោលបំណងនៃជីវិតរបស់ខ្លួន។ មនុស្ស

គ្រប់ៗរូបចង់ធ្វើជាតារាល្បី។ ហេតុអ្វីទៅ? ដោយសារតែអត្តសញ្ញាណ (មុខតំណែង) និងទ្រព្យសម្បត្តិ។

មានការស្ទង់មតិមួយដែលត្រូវបានធ្វើឡើងនៅក្នុងចំណោមសិស្សសាលាអនុវិទ្យាល័យរាប់ពាន់នាក់ទាក់ទងនឹងការងារដែលពួកគេចង់ធ្វើ នៅពេលដែលគេធំឡើង។ ៦៥%ក្នុងចំណោមសិស្សទាំងអស់ឆ្លើយថា គោលដៅរបស់គេគឺចង់ក្លាយជាអ្នកល្បី។ ល្បី? នៅលើកចុងក្រោយដែលខ្ញុំបានធ្វើការពិនិត្យមើល ការដែលមានកេរ្តិ៍ឈ្មោះល្បីគឺនៅលើកេរ្តិ៍ឈ្មោះខ្លួនឯង មិនមែនអាស្រ័យលើការងារទេ។

មានការសិក្សាមួយទៀតបានរកឃើញថា បុគ្គលិកជាង ៣០% ស្អប់ការងាររបស់ខ្លួនណាស់ ហើយ ៤០% ទៀតមិនពេញចិត្តនឹងការងាររបស់ខ្លួនទេ។ ដូច្នេះមានបុគ្គលិក ៧០% នៅក្នុងសហរដ្ឋអាមេរិកទាំងមូលមិនពេញចិត្តនឹងអ្វីដែលពួកគេធ្វើ! ចុះបើមិនពេញចិត្ត ហេតុអ្វីបានជាគេធ្វើការងារនោះ? គឺដោយសារតែគេជាខ្ញុំបម្រើនឹងផ្នត់គំនិតគ្រោងរស់ ដោយខិតខំរស់នៅលើជីវិតដែលមានបន្លា និងអញ្ចាញដើម្បីឲ្យបានរស់រាន។ ក្នុងចំណោមបុគ្គលិកទាំងនេះ ភាគច្រើនពុំមាននូវគោលបំណង និងចិត្តឆេះឆួលសម្រាប់ការងារឡើយ។ កត្តាតែមួយដែលជំរុញគេឲ្យធ្វើការគឺដើម្បីរកប្រាក់។ ការដែលជាប់ជាខ្ញុំបម្រើនៃសេចក្តីត្រូវការ និងការរកប្រាក់ពុំបានទុកឲ្យគេមានជម្រើសច្រើនឡើយ។ អ្នកណាដែលសុខចិត្តជួលគេដោយឲ្យប្រាក់ឈ្នួលថ្លៃជាងគេ ជាអ្នកឈ្នះ។ ការនេះត្រូវបានហៅថា លានប្រណាំងកណ្ដុរ! វាជាកន្លែងដែលលោកអ្នក ហើយនិងខ្ញុំរស់នៅ។ សូមស្រមៃមើលថា បើមានសត្វកណ្ដុរបារាំងមួយខំប្រឹងរត់ដោយអស់ពីលទ្ធភាព ប៉ុន្តែដោយវារត់នៅក្នុងកង់បង្វិលមួយ គឺទោះបីវារត់លឿនប៉ុណ្ណា ក៏មិនទៅកន្លែងណាផ្សេងក្រៅពីក្នុងកងបង្វិលនោះដែរ។ យើងសើច ហើយគិតថាវាគួរឲ្យស្រឡាញ់។ ប៉ុន្តែនៅលើសង្គមជាក់ស្តែង វាមិនគួរឲ្យស្រឡាញ់ទេ គឺមិនគួរឲ្យស្រឡាញ់ទាល់តែសោះ។ មនុស្សបានស្លាប់នៅក្នុងកងបង្វិលនោះ ហើយមិនអាចទៅដល់ទីដៅដែលគេសង្ឃឹមថានឹងទៅដល់បានឡើយ។

*ដូច្នេះ ចូរអ្នករាល់គ្នាកុំគិតតែពីស្វែងរកគ្រឿងបរិភោគនោះឡើយ ដ្បិតមានតែសាសន៍ដទៃប៉ុណ្ណោះ ដែលខំស្វះស្វែងរករបស់ទាំងនោះ។ រីឯអ្នករាល់គ្នាវិញ ព្រះបិតារបស់អ្នករាល់គ្នាទ្រង់ជ្រាបនូវអ្វីៗដែលអ្នករាល់គ្នាត្រូវការ។ ចូរខំស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់វិញ ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀតផង» ។*

លូកា ១២៖២៩-៣១ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

ការដែលខិតខំត្រដររស់នៅក្នុងជីវិតដោយវេទនា និងបង្ខូរញើសជាប្រព័ន្ធនៃការរស់នៅតែមួយដែលយើងដឹង។ ប្រសិនបើខ្ញុំប្រាប់លោកអ្នកថា លោកអ្នកត្រូវតែសងបំណុលគេឲ្យអស់ គឺខ្ញុំមានន័យថា លោកអ្នក**ត្រូវតែ**សងបំណុលគេឲ្យអស់នៅក្នុងពេល១២ខែ បើមិនដូច្នោះទេ ក្រុមគ្រួសាររបស់លោកអ្នកទាំងមូលនឹងត្រូវគេនិរទេសទៅប៉ូលខាងជើងជារៀងរហូត (ខ្ញុំសូមប្រើឧទាហរណ៍ធ្ងន់ៗនេះដើម្បីពន្យល់) តើលោកអ្នកនឹងធ្វើអ្វី? ខ្ញុំនឹងប្រាប់លោកអ្នកពីអ្វីដែលលោកអ្នកនឹងធ្វើ។ លោកអ្នកនឹងចាប់ផ្ដើមរៀបចំផែនការ ដើម្បីធ្វើការរកប្រាក់ឲ្យបានច្រើនជាងមុន។ លោកអ្នកនឹងពោលថា «ខ្ញុំអាចធ្វើការងារក្រៅម៉ោងពីរបីទៀតបានតើ! ប្រពន្ធខ្ញុំក៏អាចរកការងារក្រៅម៉ោងពីរបីទៀតធ្វើ ហើយកូនៗខ្ញុំក៏អាចជួយខ្ញុំបានដែរ។» លោកអ្នកឃើញទេថា លោកអ្នកបានរៀនពីប្រព័ន្ធនៃការផ្គត់ផ្គង់តែមួយនេះប៉ុណ្ណោះ គឺជាប្រព័ន្ធនៃការចិញ្ចឹមជីវិតទាំងវេទនា និងបង្ហូរញើស។ សូមអនុញ្ញាតឲ្យខ្ញុំបង្ហាញពីរូបភាពនៃប្រព័ន្ធមួយទៀត។

សូមសន្មតថាខ្ញុំកំពុងតែរត់នៅតាមផ្លូវមុខផ្ទះរបស់លោកអ្នក ហើយក៏រើសបានស្រោមសំបុតគគីរមួយនៅខាងមុខផ្ទះរបស់លោកអ្នកដែលមានប្រាក់ ១លានដុល្លារ ។ ខ្ញុំពិតជារំភើបណាស់ ប៉ុន្តែខ្ញុំដឹងថា ខ្ញុំត្រូវតែរាយការណ៍ទៅប៉ូលីសពីប្រាក់នោះ។ ដូច្នេះ ដោយហេតុថាខ្ញុំស្គាល់លោកអ្នក ខ្ញុំក៏រត់ទៅផ្ទះរបស់លោកអ្នកដើម្បីសុំខ្ចី

ទូរស័ព្ទប្រើ។ ខ្ញុំបានទូរស័ព្ទទៅកាន់នាយកដ្ឋានផ្នែកតម្រួត នៅខណៈដែលលោកអ្នកកំពុងឈរស្តាប់ក្បែរនោះ។ ខ្ញុំបានប្រាប់ពួកគេពីអ្វីដែលខ្ញុំបានរកឃើញ និងអ្វីដែលបានកើតឡើង។ បន្ទាប់ពីគេបានពិនិត្យលើកំណត់ត្រាមួយភ្លែត ពួកគេបានប្រាប់ខ្ញុំថាពុំមានកំណត់ត្រាណាមួយដែលបង្ហាញថាមានលុយបាត់ក្នុងចំនួនប៉ុននោះ ហើយខ្ញុំអាចទុកលុយនោះបាន។ (ខ្ញុំគិតថា គេប្រហែលជានឹងមិននិយាយបែបនេះទេ ប៉ុន្តែនេះជាឧទាហរណ៍ដែលខ្ញុំគិត)។ នៅពេលដែលគេបានប្រាប់ខ្ញុំបែបនោះ ខ្ញុំក៏លោតឡើងទាំងស្រែកហ៊ោដោយអំណរ។ ខ្ញុំក៏បានប្រាប់លោកអ្នកពីអ្វីដែលគេបាននិយាយ ហើយខ្ញុំពិតជារីករាយយ៉ាងខ្លាំង។

លោកអ្នកក៏ញញឹមយ៉ាងរមទម្យនៅខណៈដែលខ្ញុំកំពុងតែត្រេកអរ និងបកស្រាយនូវដំណើរដើមទងប្រាប់ដល់លោកអ្នក។ ប៉ុន្តែ តើលោកអ្នកគិតថាលោកអ្នកនឹងធ្វើអ្វីនៅពេលញ៉ាំអាហារពេលល្ងាចជាមួយគ្រួសារនៅថ្ងៃនោះ? គឺនៅពេលដែលលោកអ្នករៀបរាប់សាច់រឿងនោះប្រាប់ដល់ប្រពន្ធ? ញញឹម? ខ្ញុំមិនគិតដូច្នេះទេ។ លោកអ្នកនឹងពោលថា **«រឿងនោះមិន________ ទេ!»** លោកអ្នកបំពេញចន្លោះនោះដោយខ្លួនឯង មែនទេ? តើលោកអ្នកដឹងថាពាក្យ ស្មើភាព ជាពាក្យដែលលោកអ្នកនឹងបំពេញនៅក្នុងចន្លោះដោយរបៀបណា? ខ្ញុំនឹងប្រាប់ដល់លោកអ្នក។ ព្រោះនេះជារបៀបដែលលោកអ្នកត្រូវបានចិញ្ចឹមបីបាច់មក។ នោះជាប្រព័ន្ធដែលលោកអ្នកធំឡើង ហើយរៀនបាន គឺរស់នៅដោយការចិញ្ចឹមជីវិតទាំងវេទនា និងបង្ហូរញើសយ៉ាងលំបាកលំបិន។

នៅក្នុងឧទាហរណ៍របស់ខ្ញុំ ខ្ញុំរើសបានប្រាក់ជាច្រើន ហើយដោយរបៀបនេះ គឺជាការដែលខុសពីប្រព័ន្ធនៃពិភពលោកនេះ។ វាមិនស្មើភាពទេ។ វាមិនស្មើភាពព្រោះថាខ្ញុំមិនបានធ្វើការអ្វី ដើម្បីទទួលបានប្រាក់នោះឡើយ គឺខ្ញុំគ្រាន់តែរើសបានវា។ ដោយដឹងថាលោកអ្នកប្រហែលជាមិនមានសំណាងបែបនេះ លោកអ្នកប្រហែលជាមានអារម្មណ៍ច្រណែន និងចិត្តជូរចត់ ព្រោះលោកអ្នកដឹងថាជីវិតរបស់លោកអ្នកនៅតែត្រូវការធ្វើការងារលំបាកលំបិនដូចជាខ្ញុំបម្រើដើម្បីឲ្យបានរស់។

ជាការប្រៀបធៀប ប្រសិនបើមានថ្ងៃមួយខ្ញុំមកក្រុមជំនុំទាំងស្លៀកពាក់ដាច់រហែក គគ្រិច ហើយក៏ឡើងទៅលើឆាកនិយាយជាមួយមនុស្សថា «យើងធ្វើបានហើយ! ឌ្រិនដានិងខ្ញុំបានធ្វើការ ២២ ម៉ោងក្នុងមួយថ្ងៃនៅក្នុងពេលដប់ឆ្នាំកន្លងមកនេះ ហើយយើងបានបង់ថ្លៃផ្ទះយើងអស់ហើយ» នៅក្រុមជំនុំទាំងមូលនឹងទះដៃសាទរដល់យើង។ តើហេតុអ្វីទៅ? ព្រោះដោយហេតុថាមានមនុស្សបានសម្រេចកិច្ចការនោះ ហើយលោកអ្នកបានទទួលការលើកទឹកចិត្តពេលដែលបានឃើញរឿងនោះ។ មានមនុស្សម្នាក់បានសម្រេចវា ហើយវាបង្ហាញលោកអ្នកថាពិតជាមានច្រកចេញ! ប្រហែលជាយើងគួរខិតខំធ្វើការដើម្បីឲ្យអាចមានសេរីភាពដែរហើយមើលទៅ។ ប៉ុន្តែ ចុះហេតុអ្វីបានជាមនុស្សគ្រប់គ្នាមិនបានស្រែកហ៊ោ និងទះដៃនៅពេលដែលខ្ញុំបានរើសបានលុយដែលនៅតាមផ្លូវ? ហើយហេតុអ្វីបានជាងាយស្រួលក្នុងការដែលលោកអ្នកបំពេញចន្លោះនោះម្ល៉េះ? ព្រោះថានេះជារបៀបដែលលោកអ្នកគិត វាក៏ជាអ្វីដែលលោកអ្នកសុបិនដែរ។ ការដែលស្មើភាពគ្នាគឺជាប្រព័ន្ធនៃការចិញ្ចឹមជីវិតទាំងវេទនា និងបង្ហូរញើសដែលយើងបានរៀន។ ការដែលមិនបានប្រាក់ដោយមិនធ្វើការអ្វីសោះ គឺមិនស្មើភាពគ្នាទេ។

ប៉ុន្តែ មនុស្សគ្រប់ៗរូបសុទ្ធតែមានក្ដីសុបិនចង់រួចផុតពីប្រព័ន្ធនៃការចិញ្ចឹមជីវិតទាំងវេទនា និងបង្ហូរញើសនេះ។ ដើម្បីមានទ្រព្យសម្បត្តិ ដើម្បីក្លាយជាមហាសេដ្ឋីគឺជាគំនិតដែលមនុស្សជាច្រើនប្រាថ្នាចង់បាន។ ប្រាក់មួយលានដុល្លារនៅពេលនេះប្រហែលជាមិនមានតម្លៃដូចកាលពីមុនទេ ប៉ុន្តែទោះបីលោកអ្នកមានប្រាក់មួយលានដុល្លារពេលនេះក្ដី ក៏មិនបង្ហាញថាលោកអ្នកមានទ្រព្យសម្បត្តិច្រើនដែរ។ ទ្រព្យសម្បត្តិផ្ដល់ឲ្យមនុស្សមានឱកាសទទួលបានសិទ្ធិសេរីភាពរស់នៅផ្ទុយពីជីវិតរស់នៅក្រោមសម្ពាធ និងការគាបសង្កត់ដែលមនុស្សភាគច្រើនមាន។ មនុស្សគ្រប់ៗរូបហាត់នឿយនឹងការរត់ទាំងត្រដាបត្រដួស ហើយប្រសិនបើគេមានប្រាក់មួយលានដុល្លារនោះមានន័យថាគេអាចឈប់ខំប្រឹង ហើយធ្វើអ្វីដែលគេចង់ធ្វើ។ សូមគិតពីការនេះ៖ តើឆ្នោតមានកន្លែងណាដែលទាក់ចិត្តមនុស្ស? គឺសេរីភាព! សេរីភាពក្នុង

ការមានជម្រើស ការធ្វើការសម្រេចចិត្តដែលគេមិនចាំបាច់ជំពាក់ប្រាក់គេ ឬខិតខំរកស៊ីទៀត។

កម្មវិធីទូរទស្សន៍មួយដែលមានចំណងជើងថា «នរណាចង់ក្លាយជាសេដ្ឋី?» ជាកម្មវិធីដែលមានប្រជាប្រិយភាពណាស់។ វាជាកម្មវិធីដែលមនុស្សជាច្រើនចាប់អារម្មណ៍ ព្រោះគ្រប់ៗគ្នាសុទ្ធតែមានសុបិនចង់បានសេរីភាពនោះ។ នៅពេលដែលគេមើលកម្មវិធីនោះ គេដាក់អារម្មណ៍ និងអបអរសាទរដល់បេក្ខជនព្រមទាំងសង្ឃឹមថាពួកគេនឹងបានឈ្នះការប្រកួត។

ខ្ញុំសូមផ្លាស់ប្តូរប្រធានបទបន្តិច។ បើគិតពីការលួចវិញ ក៏ជាការដែលផ្គត់ផ្គង់ខ្លួនឯងដោយមិនបានខិតខំធ្វើការដែរ។ បើនិយាយតាមបែបម្យ៉ាងទៀត វាផ្តល់ឲ្យមនុស្សមានសេរីភាពពីប្រព័ន្ធបណ្តាសានៃផែនដី។ ចូរយើងយល់ស្របសិនថាមនុស្សគ្រប់ៗរូបចង់មានទ្រព្យសម្បត្តិ ហើយលែងរត់ក្នុងលានប្រណាំងកណ្តុរ! ប៉ុន្តែតើមានច្រកចេញដែរឬទេ? ការឆបោកដើម្បីទទួលបានប្រាក់បានក្លាយជារឿងធម្មតាសម្រាប់មនុស្សជាច្រើន។ ខ្ញុំបានទទួលអ៊ីម៉ែលយ៉ាងហោចណាស់ ១០ ក្នុងមួយថ្ងៃពីមនុស្សនៅប្រទេសក្រៅដែលរៀបរាប់ប្រាប់ខ្ញុំពីសាច់រឿងដ៏ក្រៀមក្រំរបស់ពួកគេ និងការដែលគេត្រូវស្នងមរតកជាង ២០លានដុល្លារ ហើយត្រូវការអ្នកជួយដើម្បីរក្សាកេរមរតកនោះឲ្យមានសុវត្ថិភាព។ ពួកគេថាសុខចិត្តឲ្យខ្ញុំនូវទឹកប្រាក់ពាក់កណ្តាលដរាបណាខ្ញុំគ្រាន់តែស្ម័គ្រចិត្តទទួលប្រាក់របស់គេ ហើយការពារវា។ ជាការពិតណាស់ ពួកគេចង់បានអាសយដ្ឋានអ៊ីម៉ែលរបស់ខ្ញុំ ហើយចង់ឲ្យខ្ញុំចេញប្រាក់ថ្លៃដំណើរការបន្តិចបន្តួច ថ្លៃដឹកជញ្ជូន ថ្លៃធានារ៉ាប់រង និងថ្លៃផ្សេងៗជាច្រើនទៀតតាមដែលគេប្រាប់ ដើម្បីឲ្យគេបានទទួលកេរមរតកនោះ។ ពិតមែនឬ? តើមើលមកខ្ញុំល្ងង់ដល់ថ្នាក់ហ្នឹងឬ?

ខ្ញុំធ្លាប់មានអតិថិជនម្នាក់ទូរស័ព្ទមកកាន់ខ្ញុំ ហើយគាត់ចង់បានដំបូន្មានទាក់ទងនឹងការវិនិយោគ។ ខ្ញុំបានសួរសំណួរដូចរាល់ដង ហើយក៏បានរកឃើញថាគាត់មានប្រាក់៥លានដុល្លារដែលគាត់អាចធ្វើការវិនិយោគ។ គាត់បានប្រាប់ខ្ញុំថាគាត់

មិនមានប្រាក់ទេនោះពេលនោះ ប៉ុន្តែប្រាក់នោះគឺមកពីកេរមរតក។ ខ្ញុំបានសួរគាត់ថា តើគាត់នឹងបានទទួលប្រាក់នៅពេលណា ហើយគាត់ក៏ថានៅពេលជាងពីរសប្តាហ៍ទៀត។ ដូចនេះ ពីរសប្តាហ៍ក្រោយមកខ្ញុំក៏បានទូរស័ព្ទទៅកាន់គាត់ ហើយគាត់ពោលថានឹងត្រូវចំណាយពេលយូរជាងហ្នឹងទៀត។ គាត់កំពុងតែមានបញ្ហាក្នុងការទទួលកេរមរតកដែលត្រូវផ្ទេរមកពីធនាគារអ៊ឺរ៉ុប។ បាទ វាធ្វើឲ្យខ្ញុំកាន់តែចាប់អារម្មណ៍ឡើង ដូច្នេះខ្ញុំក៏ចាប់ផ្តើមសួរសំណួរ។ សាច់រឿងនោះគឺថាបែបនេះ មានគេប្រាប់គាត់ថា គាត់មានពូបង្កើតម្នាក់ដែលបានទទួលអនិច្ចកម្មនៅប្រទេសបារាំង។ លោកពូម្នាក់នេះបានទុកប្រាក់ឲ្យគាត់ ៥លានដុល្លារ។ ទោះជាយ៉ាងនេះក្តី មានបំណុលពន្ធចំនួន ៥ម៉ឺនដុល្លារនៃកេរមរតកដែលគាត់ត្រូវបង់ មុនពេលដែលគេអាចផ្ទេរមរតកឲ្យគាត់បាន។ គាត់បានប្រាប់ខ្ញុំថា គាត់នៅតែព្យាយាមឲ្យបានលុយនោះ ហើយបានស្នើសុំកម្ចីវិនិយោគផ្ទះមួយខ្នង។

ខ្ញុំបានសួរថាតើគាត់មានមេធាវីដែរឬទេ ហើយគាត់ថា «បាទ មេធាវីដែលបានទូរស័ព្ទមកខ្ញុំពីប្រទេសបារាំងនោះកំពុងតែដោះស្រាយរឿងនេះ។» «ដូច្នេះ លោកពុំមានមេធាវីអាមេរិកដែលធ្វើការលើរឿងនេះទេ មែនទេ?» គាត់ថា «អត់ទេ ខ្ញុំមានតែមេធាវីដែលបានទូរស័ព្ទមកខ្ញុំពីប្រទេសបារាំងប៉ុណ្ណោះ។» គាត់បានពន្យល់បន្តថា ដោយសារតែគាត់មិនទាន់រកប្រាក់បាន ៥ម៉ឺនដុល្លារ មេធាវីនៅប្រទេសបារាំងនោះបាននិយាយថា គាត់អាចបង់ត្រឹមពាក់កណ្តាលសិន ហើយអាចសងទៅគាត់វិញនៅពេលដែលគេផ្ទេរលុយចូលមកឲ្យគាត់។ ខ្ញុំពោលថា «អត់ទេ! នេះជាការបោកប្រាស់ទេ!» ថ្វីបើគាត់មិនធ្លាប់បានឮពីពូម្នាក់នេះពីមុនមក គាត់ជឿថានេះជាការពិត។ ខ្ញុំបានទូរស័ព្ទទៅគាត់នៅពីរសប្តាហ៍បន្ទាប់ ហើយគាត់បាននិយាយថាគាត់មានប្រាក់ជិតគ្រប់ដើម្បីផ្ទេរទៅកាន់ធនាគារហើយ។ នៅលើកនេះទៀតខ្ញុំបានប្រាប់គាត់ថា «ពួកគេមានលុយ ៥លានដុល្លារនោះ។ ប្រសិនបើពួកគេពិតជាចង់បានលុយថ្លៃពន្ធមែន នោះគេអាចគ្រាន់តែអ៊ីម៉ែលមកលោក ឬផ្ញើទម្រង់បែបបទមួយឲ្យលោកបំពេញ និងចុះហត្ថលេខា ហើយផ្ញើទៅពួកគេវិញដោយអនុម័តឲ្យគេកាត់ទឹក

ប្រាក់ ៥ម៉ឺនដុល្លារពីលុយដែលពួកគេមាននៅក្នុងដៃនោះ។» ប៉ុន្តែ គាត់មិនបានជឿខ្ញុំទេ ហើយគាត់ជឿស្លុងថាពួកគេកំពុងតែប្រាប់ការពិត។

ទើបតែនៅថ្ងៃអាទិត្យមុននេះ គឺនៅឯក្រុមជំនុំមានករណីស្រដៀងគ្នាបានកើតឡើង។ មានយុវជនម្នាក់បានសុំដំបូន្មានផ្នែកវិនិយោគពីខ្ញុំ អំពីប្រាក់មួយចំនួនដែលគាត់ត្រូវទទួលពីកេរមរតកក្រៅប្រទេស។ ខ្ញុំមិនបានបណ្តោយឲ្យគាត់និយាយចប់ចុងចប់ដើមទេ។ ខ្ញុំថា «ខ្ញុំដឹង ខ្ញុំដឹង ពួកគេចង់ឲ្យប្អូនផ្ញើទឹកប្រាក់ជាថ្លៃចំណាយមួយចំនួន ហើយគេនឹងផ្ញើលុយមកមែនទេ?» «មែនហើយ ចុះតើហេតុអ្វីបានជាលោកគ្រូដឹង?» ខ្ញុំបានប្រាប់គាត់ដដែល ដែលថាវាជាការបោកប្រាស់។ ទោះបីជាគាត់មិនបានស្គាល់អ្នកដែលស្លាប់នោះ ហើយគាត់គ្មានមេធាវីនៅសហរដ្ឋអាមេរិកក្តី ក៏គាត់នៅតែប្រកែកជាមួយខ្ញុំទាក់ទងនឹងលុយនោះ។ តើហេតុអ្វីបានជាមនុស្សទាំងនេះបានចាញ់ការបោកប្រាស់នេះ? ព្រោះពួកគេចង់មានសេរីភាព! ពួកគេមិនអាចបោះបង់វាចោល ដោយសារតែនៅក្នុងចិត្តរបស់គេ ទោះបីជាគេមានឱកាសត្រឹមតែ ០.១ នៅក្នុងមួយប៊ីលានឱកាសក្តី ក៏គេនៅតែចង់បានវាដែរ។

សូមអនុញ្ញាតឲ្យខ្ញុំប្រាប់ជាឧទាហរណ៍មួយទៀត។ អាជីវកម្មផ្នែកសេវាកម្មហិរញ្ញវត្ថុដែលខ្ញុំនិងឌ្រិនដាមាន គឺមានប្រតិបត្តិការនៅទូទាំងសហរដ្ឋអាមេរិក។ វាជាអាជីវកម្មដ៏ល្អ! នៅក្នុងក្រុមហ៊ុនរបស់ខ្ញុំពិតជាមានឱកាសល្អប្រសើរណាស់! ខ្ញុំមានមនុស្សដែលរកចំណូលបានរាប់សែនដុល្លារនៅក្នុងមួយឆ្នាំ។ ប៉ុន្តែក៏មានសេចក្តីជាច្រើនទៀតដែលត្រូវរៀននៅក្នុងអាជីវកម្មរបស់ខ្ញុំដែរ។ លោកអ្នកកំពុងតែចាត់ចែងប្រាក់របស់អ្នកដទៃ។ មានច្បាប់ដែលលោកអ្នកត្រូវតែដឹង ហើយលោកអ្នកក៏ត្រូវរៀបចំយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីសិក្សាពីវា។

ខ្ញុំបានធ្វើការផ្សព្វផ្សាយតាមវិទ្យុនៅទីក្រុងកូឡុំបឹស រដ្ឋអូហៃយ៉ូ គឺផ្សព្វផ្សាយតាមរយៈស្ថានីយ៍វិទ្យុគ្រិស្តបរិស័ទមួយអំពីការជ្រើសរើសបុគ្គលិក ព្រោះពេលនោះខ្ញុំកំពុងតែត្រូវការបេក្ខជនល្អៗពីរបីនាក់។ យើងមានមនុស្សប្រហែលជា៥០នាក់ដាក់ពាក្យ។ ជាជាងការដែលរៀបចំការសម្ភាសន៍ភ្លាម ខ្ញុំបានសម្រេចចិត្តថានឹងធ្វើ

ការប្រជុំណែនាំនៅក្នុងសណ្ឋាគារមួយដែលនៅក្បែរនោះ ដើម្បីជួយឲ្យខ្ញុំអាចសម្រិតសម្រាំងដល់បេក្ខជន។ ការប្រជុំនោះមានការបង្ហាញអំពីសក្តានុពលដ៏ធំសម្បើមដែលក្រុមហ៊ុនរបស់យើងមាននៅលើអាជីវកម្ម របៀបដែលយើងបង្ហាញខ្លួនថាយើងមិនគ្រាន់តែបង្ហាញមនុស្សពីរបៀបដែលហិរញ្ញវត្ថុដំណើរការ ប៉ុន្តែក៏ដាក់ដំបូន្មាននេះទៅក្នុងទស្សនៈបែបគ្រិស្តបរិស័ទដែរ។ យើងក៏បានរៀបរាប់ពីរបៀបដែលក្រុមហ៊ុនដំណើរការទាក់ទងនឹងនិតិវិធី សំណង ការបណ្តុះបណ្តាល និងសេចក្តីតម្រូវដើម្បីទទួលបានអាជ្ញាប័ណ្ណ។ តាមរយៈបទពិសោធន៍ ខ្ញុំដឹងថានឹងមានបេក្ខជនជាច្រើននឹងដកខ្លួនចេញ នៅពេលដែលគេឃើញថាការដែលរកប្រាក់បាន ២០០,០០០ ដុល្លារក្នុងមួយឆ្នាំ ត្រូវការឲ្យគេធ្វើការច្រើនប៉ុណ្ណា។

បន្ទាប់ពីការប្រជុំចប់ ខ្ញុំបានដើរនៅក្នុងសាលសណ្ឋាគារ ហើយបានឃើញថាសាលធំនៅក្នុងសណ្ឋាគារនោះមានមនុស្សជាង១០០០នាក់។ មនុស្សគ្រប់ៗរូបបានមកដោយហេតុផលដូចគ្នា។ មានក្រុមហ៊ុនបណ្តាញទីផ្សារដ៏ពេញនិយមមួយបានធ្វើបទបង្ហាញស្តីពីការចូលរួមក្នុងក្រុមហ៊ុនរបស់គេ។ ប៉ុន្តែ តើហេតុអ្វីបានជាមានមនុស្សច្រើនម្ល៉េះ បើធៀបទៅនឹងមនុស្ស៥០នាក់នៅក្នុងបន្ទប់របស់ខ្ញុំ? ចម្លើយគឺសាមញ្ញទេ៖ លុយ! គួរឲ្យសោកស្តាយ ហើយនេះមិនមែនជាអ្វីដែលក្រុមហ៊ុនបណ្តាញទីផ្សារទាំងនោះប្រាប់យើងឡើយ ប៉ុន្តែគេបង្ហាញទស្សនៈថា «ប្រសិនបើខ្ញុំចូល ហើយខ្ញុំអាចនាំមនុស្សបីនាក់ទៀតឲ្យចូលដែរ នោះខ្ញុំនឹងក្លាយជាមហាសេដ្ឋីមិនខាន។» នៅពេលនេះ ខ្ញុំបានស្វែងយល់ល្មមគ្រប់គ្រាន់នឹងដឹងថា អ្នកដែលរកប្រាក់បានច្រើននៅក្នុងក្រុមហ៊ុនបណ្តាញទីផ្សារពិតជាត្រូវខិតខំប្រឹងប្រែងណាស់! មែនហើយ គេមានសក្តានុពលមែន ប៉ុន្តែគេមានទស្សនៈថានេះជាការរកប្រាក់ដោយស្រួល ហើយ «ប្រសិនបើខ្ញុំបណ្តោយឲ្យឱកាសនេះកន្លងផុតទៅ ចូរមើលមនុស្សនៅទីនេះចុះ ខ្ញុំនឹងបាត់បង់ឱកាសប្រចាំជីវិតមិនខាន!» សូមកុំយល់ច្រឡំលើពាក្យរបស់ខ្ញុំ។ ខ្ញុំមានមិត្តភក្តិល្អៗជាច្រើនដែលបានរកប្រាក់រាប់លានដុល្លារពីក្រុមហ៊ុនបែបនេះ ហើយមានក្រុមហ៊ុនបណ្តាញទីផ្សារ (ហៅកាត់ថា MLM) ល្អៗជាច្រើន។

ប៉ុន្តែ ខ្ញុំគ្រាន់តែបង្ហាញពីទស្សនៈដែលអ្នកចូលរួមក្រុមហ៊ុន MLM មានជាទូទៅ។ ដោយការលក់ផលិតផល ហើយទទួលបានប្រាក់ដោយស្រួលជារឿងដ៏សំខាន់ ដែលមនុស្សចង់ធ្វើនៅលើប្រព័ន្ធភពផែនដីដែលត្រូវបណ្តាសានេះ។

ប្រសិនបើលោកអ្នកផ្អាកមួយភ្លែត ហើយសួរខ្លួនឯងថាតើលោកអ្នកគិតពីរឿងលុយច្រើនប៉ុណ្ណា អាចជាការរកលុយ ឬការពារលុយកុំឲ្យបាត់បង់ លោកអ្នកនឹងភ្ញាក់ផ្អើលជាមិនខាន។ ខ្ញុំសូមបញ្ជាក់ម្តងទៀត ដើម្បីឲ្យលោកអ្នកយល់៖ មនុស្សគ្រប់ៗគ្នាចង់សម្រាកពីការរត់ក្នុងទីប្រណាំងកណ្តុរ ហើយពួកគេធុញទ្រាន់នឹងការខិតខំត្រដររស់នៅណាស់! នៅថ្ងៃចុងសប្តាហ៍ គេចង់តែឈប់សម្រាកពីការងារ។ នៅពេលវិស្សមកាល គេក៏ចង់តែឈប់សម្រាកពីការងារ ហើយនៅពេលចូលនិវត្តន៍ជាពេលដែលយើងពិតជាអាចឈប់សម្រាកពីការងារមែន ហើយធ្វើអ្វីដែលយើងចង់ធ្វើ។ សូមកុំយល់ច្រឡំ។ មនុស្សភាគច្រើនមិនមានទស្សនៈថា ពួកគេគ្រាន់តែចង់អង្គុយលេងទាត់ខ្យល់នោះទេ។ ហើយខ្ញុំក៏មិនមែននិយាយថាការមិនធ្វើអីសោះ ជាព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់លោកអ្នកដែរ។ អត់ទេ យើងត្រូវបានបង្កើតមកឲ្យមានសកម្មភាពនៅលើកិច្ចការរបស់យើង គឺជាគោលបំណងដែលព្រះជាម្ចាស់បានបង្កើតយើងមកយ៉ាងពិសេស។ គួរឲ្យសោកស្តាយ មនុស្សភាគច្រើនរវល់ពេកក្នុងការខិតខំប្រឹងប្រែងធ្វើការចិញ្ចឹមជីវិតធ្វើយ៉ាងណាឲ្យបានរស់រាន រហូតដល់គេបានបោះបង់ក្តីសុបិនរបស់ខ្លួនចោលជាច្រើនឆ្នាំ។

**ប្រសិនបើលោកអ្នកមិនដោះស្រាយបញ្ហាទាក់ទងនឹងលុយកាក់ទេ នោះលោកអ្នកនឹងមិនដែលរកឃើញគោលបំណង ជាគោលបំណងដ៏ពិសេសសម្រាប់ជីវិតរបស់លោកអ្នកឡើយ។**

ខ្ញុំប្រាកដថាលោកអ្នកពិតជាធ្លាប់បានឮមនុស្សនិយាយពាក្យនេះ ឬក៏ប្រហែលជាលោកអ្នកបាននិយាយខ្លួនឯងថា «ខ្ញុំត្រូវតែទៅធ្វើការនៅថ្ងៃនេះ។» មែនហើយ លោកអ្នកប្រហែលជាបានយល់ហើយថា មនុស្សមិនសូវជាសប្បាយចិត្តប៉ុន្មានទេនៅពេលដែលគេនិយាយថាខ្លួន «ត្រូវតែ» ទៅធ្វើទៅការ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេចម្រើនឡើងនៅពេលដែលនិយាយថាពួកគេចង់ទៅធ្វើការជាមួយនឹងចិត្តឆេះឆួល និងការប្ដេជ្ញាចិត្តខ្ពស់នៅលើអ្វីដែលខ្លួនកំពុងតែធ្វើ។ ជារឿយៗមនុស្សភាគច្រើនមិនមានជីវិតបែបនោះឡើយ។ ផ្ទុយទៅវិញ ពួកគេនៅតែថា «ខ្ញុំត្រូវទៅធ្វើការនៅថ្ងៃនេះទៀតហើយ។» គឺគ្រាន់តែធ្វើការដើម្បីចាយឲ្យរួចមួយខែ គឺទ្រាំធ្វើមួយថ្ងៃទៀតទៅ ឬខំរស់ឲ្យបានមួយថ្ងៃទៀត ហើយជីវិតគេមានភាពពិបាកណាស់។ មនុស្សភាគច្រើនបានចាប់ផ្ដើមបានយ៉ាងល្អនៅក្នុងឆាកជីវិត ទាំងពេញដោយការរំភើប។ ពួកគេគិតថាការងារដែលគេធ្វើគឺដើម្បីមានប្រាក់ចាយនៅក្នុងជីវភាពរស់នៅ ហើយគេធ្វើបណ្ដោះអាសន្នប៉ុណ្ណោះ គឺរហូតដល់គេរកបានការងារណាមួយដែលគេពេញចិត្ត។ ប៉ុន្តែ គេបានឃើញថាជីវិតរបស់ខ្លួនបានប្រែជាស្រពិចស្រពិល ហើយនៅពេលចូលដល់អាយុ៤០ឆ្នាំ ពួកគេបានដឹងថាគ្មានច្រកចេញឡើយ។ វាត្រូវបានហៅថាជាវិបត្តិពាក់កណ្ដាលជីវិត ហើយគេទើបតែដឹងថាខ្លួនជាប់អន្ទាក់នៅពេលនោះឯង។

មិត្តសម្លាញ់អើយ នេះមិនមែនជាជីវិតដែលព្រះជាម្ចាស់បានរៀបចំឲ្យលោកអ្នករស់នៅទេ។ លោកអ្នកបានដឹងពីការនេះរួចមកហើយ។ ប៉ុន្តែ ការដែលរត់គេចចេញពីអនាគតដ៏គួរឲ្យអាណិតនេះជាហេតុផលដែលឌ្រិនដានិងខ្ញុំបាននិយាយជាច្រើនឆ្នាំមកហើយថា ប្រសិនបើលោកអ្នកមិនដោះស្រាយបញ្ហាទាក់ទងនឹងលុយកាក់ទេ នោះលោកអ្នកនឹងមិនអាចរកឃើញគោលបំណង ជាគោលបំណងដ៏ពិសេសសម្រាប់ជីវិតរបស់លោកអ្នកឡើយ។ គឺប្រសិនបើមិនបានដោះស្រាយបញ្ហាទាក់ទងនឹងលុយកាក់ទេ លោកអ្នកនឹងមានជោគវាសនារត់ក្រោមប្រព័ន្ធនៃផែនដី

ដែលរងបណ្តាសា ដែលមានផ្នត់គំនិតថាត្រូវធ្វើយ៉ាងណាឲ្យបានមានជីវិតរស់តទៅទៀតនៅពេញមួយជីវិតរបស់លោកអ្នកជាមិនខាន។

## ប្រសិនបើលោកអ្នកមិនដោះស្រាយបញ្ហាទាក់ទងនឹងលុយកាក់ទេ នោះលោកអ្នកនឹងមិនដែលរកឃើញគោលបំណងដែលព្រះជាម្ចាស់បានបង្កើតលោកអ្នកមកឡើយ!

ដោយការប្រៀបធៀប ចូរពិភាក្សាថាតើជីវិតរបស់លោកអ្នកអាចមានសភាពបែបណា។ ចូរយើងពិចារណាពីកិច្ចការដែលលោកអ្នកចូលចិត្តធ្វើ។ ឧបមាថាលោកអ្នកចូលចិត្តលេងកូនហ្គោល។ តើលោកអ្នកធ្លាប់ឮនរណាម្នាក់និយាយថា «ចំមែនហើយ ខ្ញុំត្រូវតែទៅលេងកូនហ្គោលនៅថ្ងៃនេះ។ ខ្ញុំមិនចង់ទៅសោះ» ដែរឬទេ? ឬតើលោកអ្នកធ្លាប់ឮគេនិយាយថា «ចំមែនហើយ ដល់ល្ងាចថ្ងៃសុក្រហើយ ខ្ញុំមិនចង់ឲ្យដល់ល្ងាចថ្ងៃសុក្រសោះ។ ខ្ញុំពិតជាចង់ឲ្យដល់ព្រឹកថ្ងៃច័ន្ទឆាប់ៗណាស់ ដើម្បីឲ្យខ្ញុំអាចត្រលប់ទៅធ្វើការវិញ។» ឬឧបមាថាលោកអ្នកចូលចិត្តស្ទូចត្រី។ តើលោកអ្នកនឹងនិយាយថា «យ៉ាប់ហ្មង ខ្ញុំត្រូវតែទៅស្ទូចត្រីនៅថ្ងៃនេះ» ដែរឬទេ? អត់ទេ ខ្ញុំគិតថានឹងមិនឮពាក្យបែបនោះទេ ព្រោះលោកអ្នកពេញចិត្ត និងឆេះឆួលសម្រាប់កិច្ចការទាំងនោះ។ តើនឹងមានអ្វីកើតឡើងប្រសិនបើលោកអ្នករស់នៅក្នុងជីវិតនេះ ដោយមានចិត្តឆេះឆួល និងការតាំងចិត្តបែបដដែលសម្រាប់អ្វីដែលលោកអ្នកបានធ្វើ ហើយលោកអ្នកអាចផ្តោតលើចិត្តឆេះឆួលដែលលោកអ្នកមាន ព្រមទាំងរកឃើញកន្លែងដែលលោកអ្នកពេញចិត្ត គឺមិនមែនកន្លែងដែលលោកអ្នកម្ជុរម៉ៅបែកញើសរហាមនៅក្នុងជីវិតនេះ? ចុះប្រសិនបើលោកអ្នកមានប្រាក់ផ្គត់ផ្គង់ដល់ក្រុមគ្រួសារ ហើយរស់នៅក្នុងជីវិតមួយដែលមានសេរីភាពពីភាពតានតឹងផ្នែកថវិកាវិញ? តើពិតជាមានរបៀបដែលយើងអាចធ្វើដូច្នេះបានមែនទេ? ឌ្រិនដានិងខ្ញុំបានរកឃើញថាពិតជាមានមែន!

*អំណោយពរនៃព្រះយេហូវ៉ា នោះធ្វើឲ្យទៅជាមាន ហើយទ្រង់មិនបន្ថែមសេចក្តីទុក្ខព្រួយផងទេ។*

សុភាសិត ១០៖២២ (ព្រះគម្ពីរបរិសុទ្ធ)

សូមពិនិត្យមើលខគម្ពីរនេះឲ្យបានហ្មត់ចត់ សន្សឹមៗ។ ភាសាហេប្រឺបកប្រែចំៗថា ជាទ្រព្យសម្បត្តិដែលពុំមានបន្ថែមនូវការខិតខំខ្នះខ្នែងយ៉ាងលំបាកលំបិន។ តើលោកអ្នកឃើញទេ? ព្រះរាជ្យរបស់ព្រះជាម្ចាស់ផ្តល់នូវវិធីដែលយើងអាចគេចចេញពីការខិតខំចិញ្ចឹមជីវិតដ៏លំបាកវេទនា និងហូរញើសដែលលោកអដាំបានបន្សល់ទុកដល់យើង។ តើខគម្ពីរនេះពិតជាមានន័យអញ្ចឹងមែនឬ? ប្រសិនបើអញ្ចឹងមែន លោកអ្នកប្រាកដជាយល់ស្រប នោះលោកអ្នកទើបតែបានអានដំណឹងដ៏ល្អបំផុត។ និយាយដោយសង្ខេប ហេតុនេះហើយបានជាអេសាយ ជំពូក ៦១ បានថ្លែងទុកអំពីព្រះយេស៊ូ និងអ្វីដែលទ្រង់នឹងធ្វើនៅក្នុងព័ន្ធកិច្ចរបស់ទ្រង់ថា៖

*ព្រះវិញ្ញាណនៃព្រះអម្ចាស់យេហូវ៉ា ទ្រង់សណ្ឋិតលើខ្ញុំ ពីព្រោះព្រះយេហូវ៉ាទ្រង់បានចាក់ប្រេងតាំងខ្ញុំឲ្យផ្សាយដំណឹងល្អដល់មនុស្សទាល់ក្រ។*

អេសាយ ៦១៖១ (ព្រះគម្ពីរបរិសុទ្ធ)

តើអ្វីទៅជាដំណឹងល្អចំពោះមនុស្សដែលជាប់ក្នុងបែបផែននៃជីវិតដែលចង់បានត្រឹមតែមានជីវិតរស់ និងប្រព័ន្ធរបស់ផែនដីដែលត្រូវបណ្តាសានេះ? ជាការពិតណាស់ គឺជាសេរីភាពខាងផ្នែកថវិកា។ ព្រះយេស៊ូមានព្រះបន្ទូលចំៗថា ព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រទានឲ្យយើងលើសពីដែនកំណត់នៃប្រព័ន្ធរបស់ភពផែនដីដែលរងបណ្តាសាក្រោមការរកស៊ីចិញ្ចឹមជីវិតដ៏លំបាកវេទនា និងហូរញើសរហាម។ ចូរយើងនិយាយត្រង់ៗ។ អ្វីដែលលោកអ្នកអាចធ្វើបានគឺខិតខំធ្វើការ ហើយសម្រាប់មនុស្សភាគច្រើនពួកគេពិតជាខិតខំធ្វើការណាស់ ហើយនៅតែមិនអាចមានសេរី

ភាពបាន។ ខ្ញុំធ្លាប់បានខិតខំធ្វើការតាមដែលខ្ញុំអាចធ្វើបាន នៅពេលប្រាំបួនឆ្នាំនោះ ដែលខ្រិនដានិងខ្ញុំបានជាប់បំណុលយ៉ាងធ្ងន់ធ្ងរ។ អតិថិជនជាច្រើននាក់រាប់មិនអស់ ដែលក្រុមហ៊ុនរបស់យើងបានបម្រើនៅពេល ២៧ ឆ្នាំនេះក៏បានខិតខំអស់ពីលទ្ធភាពរបស់ពួកគេដែរ។ ប៉ុន្តែ មិនថាគេខិតខំយ៉ាងណា ពួកគេនៅតែជាប់ក្នុងអន្ទាក់នៃទាសភាពហិរញ្ញវត្ថុ។ ពួកគេគ្រប់ៗគ្នាបានទូរស័ព្ទមកកាន់យើង ដោយសារតែគេបានយល់ ទាំងភ័យខ្លាចថាគេអស់សង្ឃឹមហើយនៅលើផ្នែកថវិកា។ ក្តីសុបិនរបស់គេនៅក្នុងការដែលឯករាជ្យផ្នែកថវិកាកាន់តែពិបាកទៅៗក្នុងការសម្រេច ហើយនិមិត្តរបស់គេបានបាត់បង់ នៅសល់ត្រឹមតែការខិតខំធ្វើយ៉ាងណាឲ្យបានរស់រាន។ សូមពិចារណាលើពាក្យអង់គ្លេស Provision ដែលបកប្រែថាផ្គត់ផ្គង់ជាមួយខ្ញុំមួយភ្លែត។

Provision មកពីពាក្យ pro (គាំទ្រ) -vision (និមិត្ត)

បើគ្មានការផ្គត់ផ្គង់ទេ នោះក៏គ្មាននិមិត្តដែរ ព្រោះបើគ្មានការផ្គត់ផ្គង់ទេ គេនឹងបាត់បង់និមិត្តសម្រាប់ជីវិត។ ខ្ញុំសូមបញ្ជាក់ម្តងទៀត នេះជារបៀបដែលមនុស្សភាគច្រើនរស់នៅ គឺជាជីវិតដែលគ្មាននិមិត្ត។ នេះជាភាពជាទាសករនៅក្នុងទម្រង់ដ៏បោកបញ្ឆោតបំផុត។

# ជំពូកទី៧
# ទ្វារនៃផែនដី

សូមចំណាយពេលមួយភ្លែតដើម្បីរំឭកពីអ្វីដែលយើងបានរៀនអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ទីមួយយើងបានរៀនថា ព្រះជាម្ចាស់បានប្រទានតំណែងដល់មនុស្សឲ្យគ្រប់គ្រងលើផែនដីនេះ។ យើងបានឃើញនៅក្នុងគម្ពីរហេប្រឺ ២៖៧-៨ ថា គ្មានអ្វីដែលនៅលើផែនដីនេះមិនស្ថិតនៅក្រោមអំណាចរបស់មនុស្សឡើយ។ ដោយសារតែការនេះហើយ ទើបយើងឃើញថាមនុស្សគឺជាកូនសោ ឬក៏ជាទ្វារទៅកាន់ភពផែនដី។ មារសាតាំងបានដឹងរឿងនេះ ហើយជាដើមចមដែលវារៀបផែនការវាយប្រហារលោកអដាំ និងនាងអេវ៉ាដើម្បីទទួលបានអំណាចនៅលើផែនដីនេះ។ នៅពេលដែលលោកអដាំ និងនាងអេវ៉ាបានចាញ់នៅក្នុងផែនការបោកបញ្ឆោតរបស់វា ពួកគេបានប្រព្រឹត្តអំពើបាប និងកាត់ផ្តាច់សិទ្ធិគ្រប់គ្រងស្របច្បាប់ដែលព្រះជាម្ចាស់បានប្រទានមកលើជីវិតរបស់ពួកគេ។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលបានគ្របបាំងពួកគេនៅក្នុងការបង្កើត ពេលនេះទ្រង់ចាំបាច់ត្រូវចាកចេញ។ ពួកគេចាប់ផ្តើមអាក្រាតមិនត្រឹមតែរូបកាយប៉ុណ្ណោះទេ តែក៏ខាងវិញ្ញាណដែរ។ ខ្ញុំអាចស្រមៃបានពីការភ្ញាក់ផ្អើលរបស់ពួកគេ នៅពេលដែលពួកគេបានជួបប្រទះការដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ចាកចេញពីពួកគេ។ ព្រះគម្ពីរបានចែងថា ភ្លាមនោះ

ពួកគេចាប់ផ្តើមយកស្លឹកល្វាមកខ្ទាស់ធ្វើជាប៉ឹងបិទបាំងកាយ នៅពេលដែលពួកគេមានអារម្មណ៍ថាអាក្រាត។

ទោះបីជាមនុស្សនៅតែស្ថិតក្នុងតំណែងគ្រប់គ្រងលើផែនដី ដូចដែលព្រះជាម្ចាស់បានប្រទានមកឲ្យមនុស្សនៅក្នុងការបង្កើតក៏ដោយ ឥឡូវនេះគេបានបាត់បង់សិទ្ធិអំណាច និងឫទ្ធានុភាពដើម្បីគ្រប់គ្រងផែនដីនៅលើភពខាងវិញ្ញាណទៀត។ ដោយសារតែគេបានជ្រើសរើសបះបោរនឹងព្រះជាម្ចាស់ ព្រមទាំងជ្រើសរើសជឿ ហើយសម្រុះខ្លួនជាមួយនឹងមារសាតាំងជំនួសឲ្យព្រះជាម្ចាស់ មនុស្សបានស្ថិតនៅក្រោមអំណាចរបស់សាតាំង ហើយទទួលបានលទ្ធផលនៃការវិនិច្ឆ័យទោសដែលសាតាំង (លូស៊ីហ្វើរ) ធ្លាប់ជួបប្រទះនៅពេលដែលវាត្រូវបានទម្លាក់មកពីស្ថានបរមសុខ។ ការវិនិច្ឆ័យនោះគឺជាកន្លែងមួយដែលហៅថាស្ថាននរក ជាកន្លែងដែលធ្វើទារុណកម្ម និងត្រូវកាត់ផ្តាច់ចេញពីព្រះវត្តមានរបស់ព្រះជាម្ចាស់ជារៀងរហូត។ សូមចាំថាស្ថាននរក មិនដែលត្រូវបានបង្កើតឡើងសម្រាប់មនុស្សទេ។ ព្រះជាម្ចាស់មិនដែលមានព្រះហឫទ័យឲ្យមនុស្សណាម្នាក់ទៅទីនោះទេ។

> *បន្ទាប់មក ព្រះអង្គនឹងមានព្រះបន្ទូលទៅពួកអ្នកនៅខាងឆ្វេងថា: “ពួកត្រូវបណ្តាសាអើយ! ចូរថយចេញឲ្យឆ្ងាយពីយើង ហើយធ្លាក់ទៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ច ជាភ្លើងបម្រុងទុកសម្រាប់ផ្តន្ទាទោសមារសាតាំង និងបរិវាររបស់វានោះទៅ!*
>
> ម៉ាថាយ ២៥៖៤១ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

ដើម្បីជួយសង្គ្រោះមនុស្សចេញពីជោគវាសនានេះ ព្រះជាម្ចាស់ចាំបាច់ត្រូវរៀបចំសិទ្ធិអំណាចនៃរដ្ឋាភិបាលរបស់ទ្រង់នៅលើផែនដីនេះឡើងវិញ។ ទ្រង់នឹងត្រូវស្វែងរកវិធីមួយដើម្បីដកយកនូវអំណាចដែលសាតាំងកំពុងក្តោបក្តាប់នៅពេលនេះ

។ មានតែវិធីមួយប៉ុណ្ណោះ។ មនុស្សម្នាក់ដែលមិនមានទោសកំហុសនៃអំពើបាបសោះ នឹងត្រូវស្ម័គ្រចិត្តជំនួសកន្លែងរបស់អដាំ ដើម្បីទទួលយកការផ្តន្ទាទោសនៃការស្លាប់។ ប៉ុន្តែវាមានបញ្ហាបន្តិចដើម្បីឲ្យផែនការនោះអាចទៅរួចបាន។ គ្រប់មនុស្សទាំងអស់នៅលើផែនដីនេះ ជាកូនចៅរបស់លោកអដាំ ហើយសុទ្ធតែមានបាប ដូច្នេះពួកគេមិនអាចទទួលយកព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ និងសិទ្ធិអំណាចរបស់ទ្រង់ឡើយ។ ប៉ុន្តែព្រះជាម្ចាស់មានផែនការដើម្បីយកឈ្នះលើបញ្ហានេះបាន។ ផែនការនោះតម្រូវឲ្យមាន សេចក្តីតម្រូវដ៏សុចរិតរបស់ទ្រង់ ក្រឹត្យវិន័យរបស់ទ្រង់ត្រូវបានបង្កើត និងសរសេរឡើងនៅលើភពផែនដី ជាកន្លែងដែលមនុស្សនៅលើផែនដីអាចត្រូវបានវិនិច្ឆ័យថាជាមនុស្សគ្មានទោសដោយក្រឹត្យវិន័យដដែល ប្រសិនបើការនោះអាចទៅរួច។ បន្ទាប់ពីនោះ មានតែមនុស្សម្នាក់នោះស្ម័គ្រចិត្តស្របច្បាប់ដើម្បីឈរជំនួសនៅក្នុងកន្លែងរបស់លោកអដាំ ទទួលយកការពិន័យនិងដាក់ទណ្ឌកម្មរបស់អដាំមកដាក់លើខ្លួនឯង។

ប៉ុន្តែមានបញ្ហាសំខាន់មួយជាមួយនឹងគំនិតនេះ។ មនុស្សដែលអាចស្ម័គ្រចិត្តដើរតាមផែនការលះបង់ជីវិតនេះ មិនអាចជាកូនចៅរបស់អដាំទេ ដោយសារតែពូជពង្សអដាំជាពូជពង្សដែលប្រឡាក់ និងកាច់ផ្តាច់ចេញពីព្រះវត្តមានរបស់ព្រះជាម្ចាស់។ ដូច្នេះ តើផែនការនៃការសង្គ្រោះនេះអាចទៅរួចដោយរបៀបណា? ដើម្បីឲ្យការនេះអាចទៅរួច វាតម្រូវឲ្យព្រះជាម្ចាស់ដាក់មនុស្សម្នាក់នៅលើផែនដី ដែលមិនមែនមកពីពូជពង្សរបស់អដាំ និងហ៊ានលះបង់ខ្លួនគេជំនួសមនុស្ស។ ប៉ុន្តែភពផែនដីត្រូវបានប្រគល់ឲ្យអដាំ និងកូនចៅរបស់គាត់ ដូច្នេះបើស្ថិតនៅក្រោមផ្នែកច្បាប់ ការនេះនឹងមិនស្របច្បាប់នោះទេ។ មានតែវិធីតែមួយប៉ុណ្ណោះដែលអាចឲ្យការនេះកើតឡើងបាន។ ម្នាក់នោះត្រូវតែកើតនៅលើផែនដី ប៉ុន្តែមិនត្រូវជាពូជពង្សរបស់អដាំ។

ដំបូង លោកអ្នកប្រហែលជាយល់ស្របថាការនេះ នឹងមិនអាចទៅរួចនោះទេ។ ប៉ុន្តែបើតាមការពិតនោះ គឺមានផ្លូវមួយ។ ព្រះជាម្ចាស់អាចដាក់មេជីវិតបុរសទៅក្នុងស្ត្រីម្នាក់នៅលើផែនដីនេះដោយស្របច្បាប់ ប្រសិនបើទ្រង់អាចស្វែងរកមនុស្សម្នាក់

ដែលនឹងជឿលើទ្រង់ក្នុងការធ្វើបែបនោះ ដើម្បីអនុញ្ញាតឲ្យទ្រង់ធ្វើបែបនោះដោយស្របច្បាប់។ សូមចាំថា មនុស្សគឺជាកូនសោទៅកាន់ភពផែនដី។ មារសាតាំងបានប្រើប្រាស់កូនសោដូចគ្នានេះ ដើម្បីអាចចូលទៅកាន់ភពផែនដី និងដើម្បីលួចតំណែងខាងវិញ្ញាណរបស់អដាំដែលមានសិទ្ធិអំណាចលើវា។ សម្រាប់ផែនការរបស់ព្រះជាម្ចាស់ដើម្បីធ្វើកិច្ចការ និងបញ្ជាក់ពីភាពស្របច្បាប់នៃផែនការនោះនៅលើភពផែនដីទៅកាន់សាតាំង ដែលវាប្រាកដជានិយាយថាមិនស្មើភាពគ្នាទេ ហើយព្រះជាម្ចាស់នឹងត្រូវស្វែងរកបុរសម្នាក់ និងស្ត្រីម្នាក់ដែលនឹងជឿលើទ្រង់ថាគេនឹងមានកូនម្នាក់ នៅពេលដែលពិតជាមិនអាចទៅរួចទាំងក្នុងការដែលឲ្យពួកគេមានកូន។ ពួកគេត្រូវតែជឿលើព្រះជាម្ចាស់ក្នុងការដែលធ្វើកិច្ចការដែលមិនអាចទៅរួច។

កំណើតរបស់កូននោះនឹងត្រូវតភ្ជាប់ទៅនឹងកំណើតរបស់គាត់ដែលជាព្រះបន្ទូលសន្យានៃជោគវាសនារបស់គាត់ថា តាមរយៈពូជពង្សរបស់គាត់ ប្រជាជាតិទាំងអស់នឹងទទួលពរ ដោយសារតែតាមរយៈពូជពង្សរបស់គាត់ដែលព្រះជាម្ចាស់មានសិទ្ធិស្របច្បាប់ និងសិទ្ធិអំណាចដើម្បីនាំព្រះយេស៊ូមកកាន់ផែនដីនេះ។ ប្រសិនបើមានគូស្រករណាដែលអាចជឿលើព្រះជាម្ចាស់ក្នុងការធ្វើដូច្នោះ ហើយពពោះដល់កូនក្នុងផ្ទៃរបស់ស្ត្រីព្រហ្មចារី ដោយជឿថាតាមរយៈកូននោះ គ្រប់ជាតិសាសន៍ទាំងអស់នឹងទទួលព្រះពរ ហើយតាមរយៈកំណើតរបស់កូននោះនឹងផ្តល់ឲ្យពួកគេមានកូនចៅច្រើនជាងគ្រាប់ខ្សាច់នៅតាមឆ្នេរសមុទ្រ នោះព្រះជាម្ចាស់នឹងមានសិទ្ធិស្របច្បាប់ដែលទ្រង់ត្រូវការដើម្បីដាក់មេជីវិតនោះនៅក្នុងនាងម៉ារី ដែលជាម្តាយរបស់ព្រះយេស៊ូ។ ប៉ុន្តែតើព្រះជាម្ចាស់អាចស្វែងរកបុរសបែបនោះបានដែរឬទេ? គាត់ឈ្មោះអប្រាហាំ ជាឪពុកខាងជំនឿរបស់យើង។

*ទោះបីគ្មានអ្វីជាទីសង្ឃឹមក៏ដោយ ក៏លោកអប្រាហាំនៅតែមានសង្ឃឹម និងមានជំនឿ ហើយលោកក៏បានទៅជាឪពុករបស់ជាតិសាសន៍ជាច្រើន*

*ស្របតាមព្រះបន្ទូលដែលមានថ្លែងទុកមកថា «ពូជពង្សរបស់អ្នកនឹងមានច្រើនយ៉ាងនេះ»។ កាលណោះ លោកមានអាយុជិតមួយរយឆ្នាំហើយ ទោះបីលោកមើលមករូបកាយរបស់លោក ឃើញថាជិតស្លាប់ និងមើលទៅលោកយាយសារ៉ាឃើញថា ពុំអាចបង្កើតកូនបានសោះនោះក៏ដោយ ក៏ជំនឿរបស់លោកមិនអន់ថយដែរ។ លោកមិនបាត់ជំនឿ ហើយក៏មិនសង្ស័យនឹងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ឡើយ ផ្ទុយទៅវិញ ជំនឿរបស់លោកធ្វើឲ្យលោកមានកម្លាំងចិត្តនឹងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះលោកជឿប្រាកដក្នុងចិត្តថា បើព្រះជាម្ចាស់សន្យាធ្វើអ្វី ព្រះអង្គពិតជាមានឫទ្ធានុភាពនឹងសម្រេចតាមបានមិនខាន។*

- រ៉ូម ៤៖១៨-២១ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

**ឥឡូវនេះពួកគេបានរស់នៅលើបណ្ដាសារនៃការចិញ្ចឹមជីវិតយ៉ាងវេទនា និងបង្ខំកញ្ជើសដើម្បីមានជីវិតរស់។**

លោកអប្រាហាំ និងអ្នកស្រីសារ៉ាបានជឿលើព្រះជាម្ចាស់ ព្រមទាំងបានផ្ដល់កំណើតដល់លោកអ៊ីសាកនៅពេលដែលពួកលោកមានវ័យចំណាស់ និងមិនអាចមានកូនបាន។ ដោយសាតែលោកអប្រាហាំជាមនុស្សម្នាក់ដែលបានជឿលើព្រះជាម្ចាស់ ព្រះបន្ទូលសន្យាអាចកើតឡើងបានតែតាមរយៈទ្វារដែលអប្រាហាំបើកតែប៉ុណ្ណោះ។ ព្រះយេស៊ូនឹងត្រូវយាងមកតាមរយៈពូជពង្សរបស់លោកអប្រាហាំ។ ខ្ញុំសូមបញ្ជាក់ត្រង់នេះឲ្យបានច្បាស់បន្តិច។ ដើម្បីឲ្យព្រះជាម្ចាស់នាំព្រះយេស៊ូមកក្នុងផែនដី គឺទ្រង់ត្រូវមកតាមរយៈពូជពង្សរបស់លោកអប្រាហាំ។ គឺទ្រង់ត្រូវតែយាងមកតាមរយៈលោកអប្រាហាំ ដែលជាផ្លូវតែមួយគត់ទើបការនេះអាចស្របច្បាប់

បាន។ នេះជាមូលហេតុដែលលោកអ្នកនឹងឃើញបញ្ជីបុព្វបុរសដ៏វែងអន្លាយនៅ

ពេលដែលមើលនៅក្នុងគម្ពីរម៉ាថាយជំពូក១។ ជំពូកនេះជាជំពូកដំបូងដែលមានមូលហេតុរបស់វា។ ជំពូកនេះបង្ហាញនូវការពិតដែលថានៅក្នុងភពផែនដីនេះ ព្រះយេស៊ូជាពូជពង្សរបស់អប្រាហាំ។ ការនេះត្រូវបានកត់ត្រានៅត្រង់នេះ នៅលើផែនដីជាកន្លែងដែលសាតាំងអះអាងពីការត្រួតត្រា និងសិទ្ធិអំណាចរបស់វា។ ប្រសិនបើបញ្ជីនេះមិនត្រឹមត្រូវ ឬក៏ព្រះយេស៊ូពិតជាមិនបានយាងមកតាមពូជពង្សអប្រាហាំនោះសាតាំងអាចអះអាងថាការប្រសូត និងជីវិតរបស់ព្រះយេស៊ូគឺជាការបោកប្រាស់ ហើយទ្រង់មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីបង់ថ្លៃជួសបាបរបស់យើង។

ប្រសិនបើលោកអ្នកនៅចាំ អ៊ីស្រាអែលមានក្រឹត្យវិន័យជាច្រើនដែលហាមឃាត់អាពាហ៍ពិពាហ៍ក្រៅជាតិសាសន៍របស់ខ្លួន។ ការរៀបការក្រៅពីសាសន៍របស់គេនឹងត្រូវទទួលទោសដល់ស្លាប់។ ឥឡូវនេះលោកអ្នកដឹងពីមូលហេតុដែលពូជពង្សនោះត្រូវតែស្ថិតនៅក្នុងភាពបរិសុទ្ធ និងការដែលពួកគេបានអនុវត្តវាយ៉ាងហ្មត់ចត់។ មែនហើយ លោកអ្នកប្រហែលជារកឃើញករណីលើកលែងសម្រាប់ស្ត្រីមួយចំនួនក្រៅពីជាតិសាសន៍អ៊ីស្រាអែល ដែលរៀបការជាមួយជនជាតិអ៊ីស្រាអែល ដូចជានាងរ៉ាហាប់ដែលរស់នៅក្នុងក្រុងយេរីខូ ហើយបានលាក់អ្នកស៊ើបការណ៍ដែលត្រូវបានបញ្ជូនឲ្យទៅស៊ើបការណ៍នៅស្រុកនោះ។ នាងក៏មាននៅក្នុងបញ្ជីឈ្មោះក្នុងជំពូកទីមួយនៃកណ្ឌគម្ពីរម៉ាថាយដែរ ដោយសារតែនាងបានរៀបការជាមួយជនជាតិអ៊ីស្រាអែល។ ប៉ុន្តែលោកអ្នកត្រូវតែយល់ថា វប្បធម៌របស់សាសន៍យូដា គឺមនុស្សប្រុសជាអ្នកបន្តពូជពង្ស។

ខ្ញុំសូមអនុញ្ញាតនិយាយចាកប្រធានបន្តិច។ មានការពិភាក្សាច្រើនអំពីរយៈពេលដែលមនុស្សបានរស់នៅលើផែនដី។ តើមានវិធីណាដើម្បីដឹងពីចម្លើយទៅនឹងសំណួរនេះបានដែរឬទេ? មាន! ខ្ញុំអាចធានាលោកអ្នកបានពីការពិតមួយនេះ។ បញ្ជីឈ្មោះនៅក្នុងជំពូកទីមួយនៃកណ្ឌគម្ពីរម៉ាថាយប្រាកដជាត្រឹមត្រូវ។ គ្មានមនុស្សណាម្នាក់បាត់ឈ្មោះទេ បើពុំនោះទេលោកអ្នកហើយនិងខ្ញុំប្រហែលជាមិនបានទទួលការសង្គ្រោះដែលយើងមាននេះទេ។ មារសាតាំងនឹងប្រកែកអះអាង។ បញ្ជី

ឈ្មោះនោះត្រូវតែល្អឥតខ្ចោះ! ដោយយោងតាមសេចក្តីនោះ លោកអ្នកអាចធ្វើការប៉ាន់ប្រមាណត្រួសៗពីរយៈពេលដែលមនុស្សរស់នៅលើផែនដីសរុប។ ខ្ញុំសូមបង្ហើបនៅខាងក្រោមនេះ៖

*យើងនឹងឲ្យប្រជាជាតិមួយដ៏ធំកើតចេញពីអ្នក ហើយយើងនឹងឲ្យពរអ្នក។ យើងនឹងធ្វើឲ្យអ្នកមានឈ្មោះល្បី។ ដូច្នេះ ចូរធ្វើជាអ្នកផ្តល់ពរដល់អ្នកដទៃចុះ!។ យើងនឹងឲ្យពរដល់ជនទាំងឡាយណា ដែលឲ្យពរអ្នក យើងក៏នឹងដាក់បណ្តាសា ដល់ជនទាំងឡាយណា ដែលដាក់បណ្តាសាអ្នកដែរ <u>ក្រុមគ្រួសារទាំងអស់នៅលើផែនដីនឹងបានទទួលពរដោយសារអ្នក ។</u>*

- លោកុប្បត្តិ ១២៖២-៣ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

ដូចដែលលោកអ្នកអាចមើលឃើញនៅក្នុងអត្ថបទគម្ពីរនេះ ទ្វារនេះនាំទៅកាន់អាណាចក្រនៃផែនដី ដែលអប្រាហាំបានបង្កើតឲ្យវាជាផ្លូវស្របច្បាប់ដែលអាចឲ្យព្រះយេស៊ូគ្រិស្តរស់នៅ និងប្រទានពរដល់មនុស្សគ្រប់គ្នានៅលើផែនដី។ ទោះបីជាលោកអប្រាហាំ និងកូនចៅរបស់គាត់អនុញ្ញាតឲ្យព្រះជាម្ចាស់មានសិទ្ធិស្របច្បាប់ និងដែនសមត្ថកិច្ចដែលត្រូវការដើម្បីនាំសិទ្ធិអំណាច និងឥទ្ធិពលនៃការគ្រប់គ្រងរបស់ទ្រង់មកលើផែនដីម្តងទៀតក្តី មនុស្សនៅតែជាប់អន្ទាក់ក្រោមបន្ទុកនៃអំពើបាប និងសេចក្តីស្លាប់ខាងវិញ្ញាណ រហូតទាល់តែព្រះជាម្ចាស់អាចនាំព្រះយេស៊ូមកកាន់លោកីយ៍ ជាកន្លែងដែលទ្រង់បង់ថ្លៃជួសអំពើបាបរបស់អដាំ។ ប៉ុន្តែបើនិយាយឲ្យចំទាក់ទងនឹងការផ្គត់ផ្គង់វិញ យើងដឹងថាលោកអប្រាហាំ និងពូជពង្សរបស់គាត់ដែលត្រូវបានដៅសម្គាល់ដោយការកាត់ស្បែក បានចម្រុងចម្រើន។ ឥឡូវនេះពួកគេបានរស់នៅខ្ពស់ ផុតពីបណ្តាសានៃការខិតខំចិញ្ចឹមជីវិតទាំងវេទនា និងបង្ហូរញើសឲ្យគ្រាន់តែមានជីវិតរស់។

*លោកអាប់រ៉ាមមានហ្វូងសត្វ និងមានមាសប្រាក់ជាច្រើន។*

- លោកុប្បត្តិ១៣៖២ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

យើងឃើញនៅក្នុងអត្ថបទគម្ពីរនេះ គឺជាការផ្លាស់ប្តូរយ៉ាងធំថាសម្ពន្ធមេត្រីនេះនាំឲ្យមានការផ្គត់ផ្គង់។ តើលោកអ្នកមានឃើញខុសប្លែកអំពីអ្វីដែលព្រះជាម្ចាស់មានបន្ទូលទៅអប្រាហាំ បើប្រៀបធៀបជាមួយអ្វីដែលទ្រង់មានបន្ទូលទៅកាន់អដាំនៅក្នុងលោកុប្បត្តិ ៣៖១៧ ដែរឬទេ? សូមចាំថា បន្ទាប់ពីអដាំប្រព្រឹត្តអំពើបាប ព្រះជាម្ចាស់បានប្រាប់គាត់ថា ឥឡូវនេះគាត់ត្រូវរកស៊ីចិញ្ចឹមជីវិតដោយកាប់គាស់បង្ហូរញើសយ៉ាងវេទនា។ ប៉ុន្តែចំពោះលោកអប្រាហាំគឺខុសពីលោកអដាំទៅវិញ។ ព្រះជាម្ចាស់មានបន្ទូលថា «យើងនឹងឲ្យ» ចំណុចនេះមិនបានចែងថាលោកអប្រាហាំបានធ្វើកិច្ចការដោយសមត្ថភាពរបស់ខ្លួន ជាមួយនឹងការកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា និងបង្ហូរញើសឡើយ។ ព្រះគម្ពីរចែងថា ព្រះជាម្ចាស់រួមចំណែកក្នុងរឿងនេះ។ ព្រះជាម្ចាស់មានបន្ទូលថា «យើងនឹងឲ្យ»។ ដូច្នេះ តើយើងមើលឃើញថា លោកអប្រាហាំមានការពិបាករស់នៅបន្ទាប់ពីព្រឹត្តិការណ៍នេះដែរឬទេ? គឺអត់ទេ!

**ព្រះយេហូវ៉ាទ្រង់នឹងបើកឃ្លាំងដ៏វិសេសរបស់ទ្រង់ឲ្យដល់ឯង គឺជាផ្ទៃមេឃ ឲ្យមានភ្លៀងធ្លាក់មកសម្រាប់ស្រុកឯងតាមរដូវកាល ហើយនឹងឲ្យពរដល់គ្រប់ទាំងការដែលដៃឯងធ្វើ។**

លោកអប្រាហាំមានទ្រព្យសម្បត្តិពេញបរិបូណ៌! កូនៗរបស់គាត់ក៏មានទ្រព្យសម្បត្តិច្រើនដែរ។ លោកអប្រាហាំបានរស់នៅក្នុងជីវិតក្រោបណ្តាសាផែនដីនេះ។ គាត់មានច្រើនលើសពីគ្រប់គ្រាន់ទៅទៀត! មនុស្សមិនចាំបាច់ចំណាយពេលយូរ

ដើម្បីមើលឃើញពីភាពខុសគ្នានោះទេ។ ភាពខុសគ្នានេះបន្តរហូតដល់ពូជពង្សរបស់គាត់។ តាមពិត គឺមានពីរបីជំនាន់បន្ទាប់លោកអប្រាហាំ ដូចជាចៅរបស់គាត់ឈ្មោះថាយ៉ាកុប ដែលបានធ្វើការឲ្យលោកឡាបាន់ ដែលជាឪពុកក្មេក។ លោកឡាបាន់បានឃើញព្រះពរនៅលើលោកយ៉ាកុប ហើយព្យាយាមបោកប្រាស់កុំឲ្យគាត់បានចម្រុងចម្រើន។ ប៉ុន្តែព្រះជាម្ចាស់បានផ្លាស់ប្តូរផែនការរបស់គាត់ក្នុងការលួចយកព្រះពរនោះ ធ្វើឲ្យមានគ្រោះថ្នាក់ដល់ខ្លួនវិញ ហើយបានប្រទានពរយ៉ាកុបជាមួយនឹងទ្រព្យសម្បត្តិយ៉ាងបរិបូណ៌។ អ្វីដែលខ្ញុំចង់និយាយត្រង់នេះគឺថា ទោះបីជាមនុស្សបានព្យាយាមបញ្ឈប់ព្រះពរក៏ដោយ ក៏ពួកគេមិនអាចធ្វើបានដែរ។ ការនេះអាចកើតឡើងបាន លុះត្រាតែពូជពង្សរបស់ពួកគេបន្តនៅជាប់ជាមួយនឹងសម្ពន្ធមេត្រី ហើយថ្វាយបង្គំព្រះជាម្ចាស់ នោះព្រះអង្គនឹងធ្វើឲ្យពួកគេមានពេញបរិបូណ៌។

សូមគិតអំពីផលប៉ះពាល់នៃអ្វីដែលខ្ញុំកំពុងនិយាយ! ខ្ញុំទទួលបានសំបុត្រ និងអ៊ីម៉ែលគ្រប់ប្រភេទពីមនុស្សជាច្រើនដែលប្រាប់ខ្ញុំថា ខ្ញុំនិយាយច្រើនពេកទាក់ទងនឹងលុយកាក់។ ពួកគេប្រាប់ខ្ញុំថាភាពចម្រុងចម្រើនមិនមែនជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ។ ពួកគេបានបញ្ជាក់ថា យើងទាំងអស់គ្នាត្រូវតែរងទុក្ខលំបាកនៅក្នុងជីវិត គឺត្រូវលះបង់ច្រើនដើម្បីបម្រើព្រះជាម្ចាស់។ ខ្ញុំអាចយល់ស្របពីផ្នែកមួយនៃឃ្លារបស់គេ។ ព្រះយេស៊ូពិតជាមានព្រះបន្ទូលថា ភាពរុងរឿងរបស់យើងធ្វើឲ្យយើងរងទុក្ខក្នុងការបៀតបៀននៅក្នុងគម្ពីរម៉ាកុប ១០៖៣០។ ជាអកុសល មានគ្រិស្តបរិស័ទជាច្រើនជឿថា ព្រះជាម្ចាស់ជាអ្នកចាត់ចែងការងារដ៏តឹងរឹង ហើយយើងត្រូវតែរងទុក្ខនៅក្នុងជីវិតដើម្បីរស់នៅ ទទួលយកពាក្យសច្ចានៃភាពក្រីក្រ និងរងទុក្ខតាមរយៈជំងឺ និងរោគាផ្សេងៗ។ អត់ទេ! នោះគឺជាបណ្តាសាផែនដី។ វាមិនមែនជាព្រះពរទេ! ព្រះជាម្ចាស់ចង់តាំងហិរញ្ញវត្ថុរបស់លោកអ្នកឲ្យបានរឹងមាំ។

## ព្រះជាម្ចាស់ចង់តាំងលោកអ្នកឲ្យបានរឹងមាំ!

**បដិវត្តន៍ហិរញ្ញវត្ថុ** - អំណាចនៃតក្តីភាពនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់

ប្រសិនបើហិរញ្ញវត្ថុរបស់លោកអ្នកមិនរឹងមាំ ឬមានសុវត្ថិភាពទេ នោះលោកអ្នកត្រូវតែបង្ខំខ្លួនឯងឲ្យធ្វើកិច្ចការគ្រប់បែបយ៉ាងដើម្បីមានជីវិតរស់រាន ដោយមិនបានបំពេញកិច្ចការខាងវិញ្ញាណ ជាពិសេសរស់នៅក្នុងជីវិតជាទាសករ។ សូមចំណាយពេលមើលលើអ្វីដែលព្រះជាម្ចាស់មានបន្ទូលទៅកាន់កូនចៅរបស់លោកអប្រាហាំនៅក្នុងគម្ពីរទុតិយកថា ២៨ៈ៨-១៣។

*ព្រះយេហូវ៉ាទ្រង់នឹងបង្គាប់ឲ្យមានពរនៅលើជង្រុកឯង ហើយលើគ្រប់ទាំងការអ្វីដែលឯងនឹងដាក់ដៃធ្វើ។ ទ្រង់នឹងប្រទានពរដល់ឯងនៅក្នុងស្រុកដែលព្រះយេហូវ៉ា ជាព្រះនៃឯង។ ទ្រង់ប្រទានមក ទ្រង់នឹងតាំងឯងសម្រាប់ជារាស្ត្របរិសុទ្ធដល់ទ្រង់ ដូចជាទ្រង់បានស្បថនឹងឯងហើយ គឺបើឯងនឹងកាន់តាមអស់ទាំងបញ្ញត្តរបស់ព្រះយេហូវ៉ា ជាព្រះនៃឯង ព្រមទាំងដើរតាមផ្លូវទ្រង់ផង។ នោះគ្រប់ទាំងសាសន៍នៅផែនដីនឹងឃើញថា ឯងជាអ្នកមានឈ្មោះតាមព្រះនាមព្រះយេហូវ៉ា ហើយគេនឹងកោតខ្លាចដល់ឯង។ ព្រះយេហូវ៉ាទ្រង់ក៏នឹងចំរើនឲ្យឯងមានជាបរិបូរឡើង ដោយផលដែលកើតពីពោះ និងផលកើតពីហ្វូងសត្វ ហើយនឹងផលកើតពីដីឯង នៅក្នុងស្រុកដែលព្រះយេហូវ៉ាបានស្បថនឹងពួកអយ្យកោថា នឹងឲ្យដល់ឯង។*

*ព្រះយេហូវ៉ាទ្រង់នឹងបើកឃ្លាំងដ៏វិសេសរបស់ទ្រង់ឲ្យដល់ឯង គឺជាផ្ទៃមេឃ ឲ្យមានភ្លៀងធ្លាក់មកសម្រាប់ស្រុកឯងតាមរដូវកាល ហើយនឹងឲ្យពរដល់គ្រប់ទាំងការដែលដៃឯងធ្វើ។ នោះឯងនឹងឲ្យសាសន៍ជាច្រើនខ្ចីឥតមានខ្ចីពីគេវិញឡើយ ព្រះយេហូវ៉ាទ្រង់នឹងតាំងឯងទុកជាក្បាល មិនមែនជាកន្ទុយឡើយ ឯងនឹងនៅតែពីលើគេ មិនដែលនៅពីក្រោមទេ គឺបើឯងនឹងស្តាប់តាមអស់ទាំងសេចក្តីបញ្ញត្តផងព្រះយេហូវ៉ា ជាព្រះនៃឯង ដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ ដើម្បីនឹងកាន់ ហើយប្រព្រឹត្តតាមផង។*

*(ដកស្រង់ពីព្រះគម្ពីរបរិសុទ្ធ)*

ចូរកត់សម្គាល់ថា នៅក្នុងទឹកដីថ្មីនេះ ពួកគេមិនទាន់ត្រូវបានតាំងឲ្យរឹងមាំនោះទេ ទោះបីជាពួកគេទទួលបានព្រះបន្ទូលសន្យាក៏ដោយ។ ប៉ុន្តែលោកម៉ូសេប្រាប់ពួកគេថាព្រះជាម្ចាស់នឹងតាំងពួកគេ! ដើម្បីស្វែងយល់ពីលក្ខណៈរបស់វា និងអ្វីដែលព្រះជាម្ចាស់កំពុងតែមានបន្ទូលទៅកាន់ពួកគេ សូមគិតពីដើមជ្រៃមួយដើម។ នៅពេលដែលវាជាកូនឈើមួយដើម វាមិនទាន់ត្រូវបានតាំង ឬរឹងមាំនៅឡើយទេ។ មនុស្សអាចផ្លាស់ប្តូរទីតាំងរបស់វានៅពេលណា និងទីកន្លែងណាក៏បានតាមដែលគេចង់។ ប៉ុន្តែនៅពេលដែលដើមជ្រៃនោះដុះលូតលាស់ និងពេញវ័យ គ្មាននរណាម្នាក់អាចផ្លាស់ប្តូរវាបានឡើយ។ វាត្រូវបានតាំងរួចទៅហើយ។

*ព្រះយេហូវ៉ាទ្រង់នឹងបង្គាប់ឲ្យមានពរនៅលើជង្រុកឯង ហើយលើគ្រប់ទាំងការអ្វីដែលឯងនឹងដាក់ដៃធ្វើ។ ទ្រង់នឹងប្រទានពរដល់ឯងនៅក្នុងស្រុកដែលព្រះយេហូវ៉ាជាព្រះនៃឯង។ ទ្រង់ប្រទានមក ទ្រង់នឹងតាំងឯង...*

- ទុតិយកថា ២៨៖៨-៩ (ព្រះគម្ពីរបរិសុទ្ធ)

ដូច្នេះតើការតាំងហិរញ្ញវត្ថុមានលក្ខណៈបែបណា? ព្រះជាម្ចាស់បានប្រាប់នៅក្នុងនេះ ក្នុងខ១២៖

*នោះឯងនឹងឲ្យសាសន៍ជាច្រើនខ្ចីឥតមានខ្ចីពីគេវិញឡើយ ព្រះយេហូវ៉ាទ្រង់នឹងតាំងឯងទុកជាក្បាល មិនមែនជាកន្ទុយឡើយ។*

ព្រះជាម្ចាស់មានព្រះបន្ទូលថា ទ្រង់នឹងប្រទានពរដល់ពួកគេយ៉ាងច្រើន ដែលពួកគេត្រូវធ្វើជាអ្នកឲ្យខ្ចី (ម្ចាស់បំណុល) ហើយលែងជាអ្នកខ្ចីពីគេ (កូនបំណុល) ទៀតហើយ។ ពួកគេនឹងត្រូវធ្វើជាក្បាល ហើយលែងធ្វើជាកន្ទុយ។ កន្ទុយមិនមែនជាអ្នកសម្រេចពីទីកន្លែងដែលខ្លួនចង់ទៅទេ វាទៅតាមតែក្បាលដឹកនាំប៉ុណ្ណោះ។

*អ្នកមានតែងតែជិះជាន់អ្នកក្រ រីឯកូនបំណុលជាទាសកររបស់ម្ចាស់ប្រាក់។*

- សុភាសិត ២២៖៧ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

កូនបំណុល (អ្នកខ្ចី) មិនត្រូវបានតាំងនោះទេ។ ពួកគេស្ថិតនៅក្រោមសេចក្តីមេត្តាករុណារបស់ម្ចាស់បំណុល ហើយការធ្វើការជាទាសករគ្មានសេរីភាពឡើយ។ ប៉ុន្តែព្រះជាម្ចាស់មានបន្ទូលថា «ទេ! យើងនឹងតាំងអ្នក! គ្មាននរណាម្នាក់អាចប្រាប់អ្នកឲ្យចេញពីផ្ទះរបស់អ្នកបានឡើយ ដោយសារតែវាបានបង់ថ្លៃរួចហើយ។ គ្មាននរណាម្នាក់អាចរឹបអូសយកឡានរបស់អ្នកបានឡើយ ដោយសារតែវាត្រូវបានបង់ថ្លៃហើយ។ ផ្ទះបាយរបស់នឹងពេញដោយគ្រឿងទេស ហើយអ្នកនឹងរស់នៅលើទឹកដីរបស់អ្នកដែលបានបង់ថ្លៃរួច ព្រមទាំងបំពេញកិច្ចការដែលព្រះជាម្ចាស់បានដាក់ឲ្យអ្នកធ្វើនៅក្នុងសន្តិភាពហិរញ្ញវត្ថុយ៉ាងល្អឥតខ្ចោះ។ អ្នកនឹងត្រូវបានតាំង!»

## ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកអ្នកចម្រុងចម្រើន!

ជំពូកទី៨

# អំណាចនៃភក្ដីភាព
# នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់

អ្វីដែលលោកអ្នកនឹងអាន គឺជាគោលការណ៍នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ដ៏មានអនុភាព ហេតុដូច្នេះហើយបានជាខ្ញុំមានអារម្មណ៍ថាវាស័ក្តិសមនឹងធ្វើជាចំណងជើងជំពូកនៅក្នុងសៀវភៅនេះ។ យើងបានរកឃើញវានៅក្នុងសាច់រឿង និងជីវិតរបស់លោកយ៉ូសែប ដែលជាចៅទួតរបស់លោកអប្រាហាំ។ ខ្ញុំសូមប្រាប់ពីប្រវត្តិរបស់គាត់បន្តិចៈ លោកយ៉ូសែបត្រូវបានបងប្អូនស្អប់ ហើយពួកគេចង់ឲ្យយ៉ូសែបបាត់មុខចេញពីពួកគេ។ តាមពិតទៅ ពួកគេចង់សម្លាប់គាត់ ប៉ុន្តែមានបងប្រុសរបស់គាត់ម្នាក់មិនចង់ធ្វើជ្រុលដល់ថ្នាក់នោះទេ ដូច្នេះផ្ទុយទៅវិញពួកគេបានលក់គាត់ទៅឲ្យឈ្មួញដែលបាននាំគាត់យកទៅស្រុកអេស៊ីប ជាកន្លែងដែលគាត់ត្រូវបានគេលក់ឲ្យលោកប៉ូទីផារ ដែលជាមេបញ្ជាការកងរក្សាស្ដេចផារ៉ោន។

*ជនជាតិអ៊ីស្មាអែលបាននាំយ៉ូសែបចុះទៅស្រុកអេស៊ីប ហើយលក់លោកឲ្យជនជាតិអេស៊ីបម្នាក់ឈ្មោះប៉ូទីផារ ជាមន្ត្រីរបស់ព្រះចៅផារ៉ោន និងជាមេ*

*បញ្ជាការកងរក្សាស្ដេច។ ព្រះអម្ចាស់គង់នៅជាមួយលោកយ៉ូសែប ការអ្វីដែលលោកធ្វើសុទ្ធតែបានលទ្ធផលល្អទាំងអស់។ លោករស់នៅក្នុងផ្ទះម្ចាស់របស់លោកដែលជាជនជាតិអេស៊ីបនោះ។ ម្ចាស់របស់លោកឃើញថា ព្រះអម្ចាស់គង់នៅជាមួយលោក ហើយការអ្វីដែលលោកធ្វើ ព្រះអង្គប្រោសប្រទានឲ្យបានលទ្ធផលល្អទាំងអស់។ លោកប៉ូទីផារពេញចិត្តនឹងលោកយ៉ូសែបណាស់ គាត់ក៏ឲ្យលោកធ្វើជាអ្នកបម្រើជំនិតរបស់គាត់ ហើយតែងតាំងលោកឲ្យមើលខុសត្រូវលើផ្ទះសំបែង និងគ្រប់គ្រងលើទ្រព្យសម្បត្តិទាំងប៉ុន្មានរបស់គាត់។*

*ចាប់ពីពេលលោកប៉ូទីផារតែងតាំងលោកយ៉ូសែបឲ្យមើលខុសត្រូវលើផ្ទះសំបែង និងលើទ្រព្យសម្បត្តិរបស់គាត់មក ព្រះអម្ចាស់ប្រទានពរដល់ជនជាតិអេស៊ីបនេះព្រោះតែលោកយ៉ូសែប ហើយព្រះអង្គក៏ប្រទានពរដល់អ្វីៗទាំងអស់ ដែលជាកម្មសិទ្ធិរបស់គាត់ គឺទាំងផ្ទះសំបែង ទាំងស្រែចម្ការ។ គាត់ប្រគល់ឲ្យលោកយ៉ូសែបគ្រប់គ្រងលើអ្វីៗទាំងអស់ដែលគាត់មាន ហើយក្រៅតែពីបរិភោគ គាត់មិនខ្វល់ខ្វាយនឹងកិច្ចការអ្វីទៀតឡើយ។*

- លោកុប្បត្តិ ៣៩៖១-៧ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

សូមមើលខ២ *«ព្រះអម្ចាស់គង់នៅជាមួយលោកយ៉ូសែប ការអ្វីដែលលោកធ្វើសុទ្ធតែបានលទ្ធផលល្អទាំងអស់។»* តើវាមានអត្ថន័យបែបណា? តើព្រះជាម្ចាស់មិនគង់នៅជាមួយមនុស្សគ្រប់គ្នាទេឬអី? ចម្លើយនោះគឺទេ នៅក្នុងបរិបទដែលយើងបានពិភាក្សាគ្នានៅក្នុងជំពូកមុនទាក់ទងនឹងពូជពង្ស។ សូមចាំថា ជំនឿរបស់អប្រាហាំ និងសម្ពន្ធមេត្រីដែលបន្តមក អនុញ្ញាតឲ្យព្រះជាម្ចាស់មានសិទ្ធិស្របច្បាប់ចូលទៅកាន់អប្រាហាំ និងកូនចៅរបស់គាត់តែប៉ុណ្ណោះ។ ដូច្នេះនៅពេលដែលយើងនិយាយអំពីការដែលព្រះជាម្ចាស់គង់នៅជាមួយមនុស្សគ្រប់គ្នា យើងមិនគួរភាន់ច្រឡំជាមួយសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សគ្រប់គ្នាទេ ព្រោះទ្រង់

ស្រឡាញ់មនុស្សគ្រប់គ្នា។ ប៉ុន្តែសម្រាប់អស់អ្នកមិនឈរក្នុងសិទ្ធិស្រប់ច្បាប់ចំពោះព្រះជាម្ចាស់ នោះព្រះអង្គមិនអាចគង់ជាមួយគេបានឡើយ។

> *កាលណោះ បងប្អូននៅឆ្ងាយពីព្រះគ្រិស្ត គ្មានសិទ្ធិចូលជាតិអ៊ីស្រាអែល គ្មានទំនាក់ទំនងអ្វីនឹងសម្ពន្ធមេត្រី ដែលចងឡើងដោយព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ទេ <u>បងប្អូនរស់នៅក្នុងលោកនេះ ដោយគ្មានទីសង្ឃឹម ហើយក៏គ្មានព្រះជាម្ចាស់ដែរ។</u> កាលពីដើមបងប្អូននៅឆ្ងាយមែន ក៏ប៉ុន្តែឥឡូវនេះ ដោយបងប្អូនរួមក្នុងអង្គព្រះយេស៊ូគ្រិស្ត បងប្អូនបានមកនៅជិតដោយសារព្រះលោហិតរបស់ព្រះគ្រិស្ត។*
>
> \- អេភេសូ ២៖១២-១៣

ចូរកត់សម្គាល់ថា អត្ថបទគម្ពីរនេះនិយាយអំពីការគ្មានសម្ពន្ធមេត្រី ដែលមានន័យថាព្រះជាម្ចាស់ និងឫទ្ធានុភាពរបស់ទ្រង់ត្រូវបានកាត់ផ្ដាច់ស្របច្បាប់ចេញពីមនុស្ស។ ហេតុអ្វីទៅ? ដោយសារតែព្រះជាម្ចាស់គ្មានសិទ្ធិស្របច្បាប់ ឬដែលសមត្ថកិច្ចនៅក្នុងអាណាចក្រនៃផែនដី ដោយគ្មានកិច្ចព្រមព្រៀងស្របច្បាប់ ឬសម្ពន្ធមេត្រីជាមួយបុរសឬស្ត្រីណានៅលើផែនដី។ ខគម្ពីរនេះសបញ្ជាក់យ៉ាងច្បាស់ថា នៅពេលដែលគ្មានសម្ពន្ធមេត្រី នោះមនុស្សនឹងគ្មានក្ដីសង្ឃឹម និងគ្មានព្រះជាម្ចាស់នៅក្នុងលោកនេះ។ សូមចាំថា ដោយហេតុថាព្រះយេស៊ូបានរៀបចំសម្ពន្ធ

**ព្រះជាម្ចាស់គ្មានសិទ្ធិស្របច្បាប់ ឬដែលសមត្ថកិច្ចនៅក្នុងអាណាចក្រនៃផែនដី ដោយគ្មានកិច្ចព្រមព្រៀងស្របច្បាប់ ឬសម្ពន្ធមេត្រីជាមួយបុរស ឬស្ត្រីណានៅលើផែនដី។**

មេត្រីសម្រាប់យើង នោះយើងនឹងក្លាយជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ និងជាប្រជារាស្ត្រនៅក្នុងព្រះរាជ្យដ៏អស្ចារ្យរបស់ទ្រង់ (អេភេសូ ២៖១៩)។ ដូច្នេះឥឡូវនេះ សូមត្រលប់ទៅមើលអត្ថបទគម្ពីរនៅក្នុងលោកុប្បត្តិ ៣៩ យើងយល់ថាឃ្លា *«ព្រះអម្ចាស់គង់នៅជាមួយលោកយ៉ូសែប»* មានន័យថា ព្រះជាម្ចាស់មានឥទ្ធិពលស្របច្បាប់នៅក្នុងជីវិតរបស់លោកយ៉ូសែប តាមរយៈសម្ពន្ធមេត្រីរបស់លោកអប្រាហាំជាជីតាដែលបានចងជាមួយទ្រង់។ សម្ពន្ធមេត្រីស្របច្បាប់នេះ អនុញ្ញាតឲ្យព្រះជាម្ចាស់ប្រទានពរ និងជះឥទ្ធិពល ហើយបានគ្រប់គ្រងលើប្រព័ន្ធបណ្តាសានៃការខិតខំធ្វើការទាំងវេទនា និងការបង្ហូរញើសនៅលើផែនដី។ វាជាសិទ្ធិស្របច្បាប់ដែលព្រះជាម្ចាស់ប្រទានពរដល់លោកយ៉ូសែប។

សូមចាំពីអ្វីដែលព្រះជាម្ចាស់មានបន្ទូលទៅលោកអប្រាហាំមុននេះ *«យើងនឹងឲ្យ»។* ដោយសារតែព្រះជាម្ចាស់គង់នៅជាមួយយ៉ូសែប ជួយដល់ជីវិតរបស់គាត់ គាត់ទទួលបានជោគជ័យនៅក្នុងគ្រប់អ្វីដែលគាត់ធ្វើ រហូតដល់លោកប៉ូទីផារជាចៅហ្វាយរបស់គាត់ដែលមិនគោរពបម្រើព្រះអម្ចាស់ បានឃើញការផ្លាស់ប្តូរយ៉ាងច្រើននៅក្នុងសមត្ថភាពរបស់លោកយ៉ូសែប បើធៀបជាមួយមនុស្សជាច្រើនដែលគាត់ធ្លាប់ជួបប្រទះ។ ខ្ញុំគួរតែលើកឡើងនៅត្រង់នេះថានៅពេលដែលយើងបានចម្រុងចម្រើនជាមួយនឹងជំនួយរបស់ព្រះជាម្ចាស់ មនុស្សដែលរស់នៅក្រោមបណ្តាសានៃផែនដីនឹងកត់សម្គាល់ពីភាពខុសប្លែកនេះ! លោកប៉ូទីផារកោតសរសើរខ្លាំងណាស់រហូតដល់គាត់បានដាក់យ៉ូសែបឲ្យចាត់ចែងលើទ្រព្យសម្បត្តិទាំងប៉ុន្មាន។

មានគោលការណ៍នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ជាច្រើនដែលត្រូវបានបង្ហាញនៅក្នុងអត្ថបទគម្ពីរនេះ ប៉ុន្តែមានកូនសោមួយត្រូវបានបង្ហាញនៅទីនេះ។ ខ្ញុំហៅវាថា «អំណាចនៃភក្តីភាពនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់» ឬ ក៏លោកអ្នកអាចហៅវាថា «គោលការណ៍របស់លោកប៉ូទីផារ»។ វាត្រូវបានរកឃើញនៅក្នុង លោកុប្បត្តិ ៣៩៖៥៖

*ហើយចាប់តាំងពីលោកតាំងគាត់ឡើង ឲ្យត្រួតត្រាលើផ្ទះ និងទ្រព្យសម្បត្តិទាំងអស់មក នោះព្រះយេហូវ៉ាទ្រង់ប្រទានពរដល់ផ្ទះនៃសាសន៍អេស៊ីព្ទនោះដោយព្រោះយ៉ូសែប ហើយ<u>ព្រះយេហូវ៉ាក៏ផ្ដល់ព្រះពរ មកលើគ្រប់ទាំងរបស់លោក (ប៉ូទីផារ) ដែលនៅក្នុងផ្ទះ និងនៅស្រែចំការដែរ។</u> (ព្រះគម្ពីរបរិសុទ្ធ)*

**វាត្រូវបានហៅថាថ្ងៃសប្ប័ទ ជារូបភាពនៃថ្ងៃដែលមនុស្សមិនចាំបាច់ខិតខំប្រឹងប្រែង ជាមួយនឹងការចិញ្ចឹមជីវិតយ៉ាងវេទនា និងបង្ហូរញើសរបស់ខ្លួនឯងផ្ទាល់ដោយគ្រាន់តែសម្រាប់រស់នៅទៀតហើយ។**

ខ្ញុំចង់ឲ្យលោកអ្នកទទួលបានរូបភាពច្បាស់ពីអ្វីដែលកំពុងតែកើតឡើងនៅទីនេះ។ ដើមឡើយគាត់មិនទាន់ធ្វើជាអ្នកមើលខុសត្រូវនៅឡើយទេ គឺក្រោយមកទើបគាត់បានក្លាយជាអ្នកមើលខុសត្រូវ។ ព្រះគម្ពីរបានធ្វើការកត់សម្គាល់នៅគ្រាដែលគាត់បានផ្លាស់ប្ដូរ។ ព្រះពរត្រូវបានបង្ហូរមកលើអ្វីៗទាំងអស់ដែលជារបស់លោកប៉ូទីផារ គឺទ្រព្យសម្បត្តិគាត់ទាំងមូល! ប៉ុន្តែគាត់មិនបានស្គាល់ព្រះរបស់លោកយ៉ូសែប ហើយក៏មិនមែនជាសមាជិកនៃជាតិសាសន៍អ៊ីស្រាអែលដែរ។ ដូច្នេះ តើការនេះអាចកើតឡើងដោយរបៀបណា ហើយតើវាមានអត្ថន័យបែបណា? នេះជាចម្លើយ៖ នៅពេលដែលលោកប៉ូទីផារបានដាក់ទ្រព្យសម្បត្តិរបស់គាត់នៅក្រោមសិទ្ធិអំណាចរបស់លោកយ៉ូសែប ទាំងមិនដឹងថាទ្រព្យសម្បត្តិរបស់គាត់ចាប់ផ្ដើមស្ថិតនៅក្រោមសម្ពន្ធមេត្រីរវាងលោកយ៉ូសែប និងព្រះជាម្ចាស់ឡើយ។

**សម្ភារៈ ទ្រព្យសម្បត្តិ និងអចលទ្រព្យទាំងអស់របស់លោកប៉ូទីផារបានផ្លាស់ប្ដូរអាណាចក្រនោះ!**

ដូចដែលលោកអ្នកឃើញថា ទ្រព្យសម្បត្តិរបស់លោកប៉ូទីផារនៅតែបានផ្សារភ្ជាប់នឹងប្រព័ន្ធបណ្ដាសានៅលើផែនដីដោយស្របច្បាប់ រហូតទាល់តែស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកយ៉ូសែប។ នៅពេលដែលលោកប៉ូទីផារបានដាក់ទ្រព្យសម្បត្តិរបស់គាត់នៅក្រោមសិទ្ធិអំណាចរបស់លោកយ៉ូសែបដោយស្របច្បាប់ គាត់មិនបានដឹងថាគាត់ក៏បានដាក់វានៅក្រោមឥទ្ធិពលនៃព្រះពររបស់ព្រះជាម្ចាស់ទេ។ ព្រះគម្ពីរចែងថា ដោយសារតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកយ៉ូសែប លោកប៉ូទីផារមិនបានចាំបាច់ត្រូវខ្វល់ខ្វាយ ឬព្រួយបារម្ភអ្វីឡើយ លើកលែងតែអាហារដែលលោកបរិភោគប៉ុណ្ណោះ។ គាត់មិនព្រួយបារម្ភឡើយ! ដោយគ្មានការព្រួយបារម្ភ លោកប៉ូទីផារផ្ដោតអារម្មណ៍តែទៅលើកិច្ចការ និងគោលបំណងជាមេបញ្ជាការកងរក្សាស្ដេច។ មានកិច្ចការច្រើនណាស់ដែលត្រូវបានបង្ហាញនៅត្រង់នេះ ប៉ុន្តែអ្វីដែលលោកប៉ូទីផារបានជួបប្រទះ ទាំងមិនថានោះជាអ្វីដែលគម្ពីរហេព្រើជំពូក៤ហៅថាជាការសម្រាកថ្ងៃសប្ប័ទ។ មែនហើយ ការសម្រាកថ្ងៃសប្ប័ទនេះមានសម្រាប់អ្នកជឿនៅក្នុងសម្ពន្ធមេត្រីថ្មី។

ប្រសិនបើលោកអ្នកសិក្សាពីថ្ងៃសប្ប័ទ លោកអ្នកនឹងរកឃើញថាព្រះជាម្ចាស់មិនបានអនុញ្ញាតឲ្យប្រជាជនអ៊ីស្រាអែល ធ្វើកិច្ចការអ្វីឡើយនៅថ្ងៃនោះ។ គ្មានការធ្វើការដោយវេទនា ឬបង្ហូរញើសកើតឡើងឡើយ។ តាមពិត ថ្ងៃសប្ប័ទគឺជាថ្ងៃទី៧ក្នុងសប្ដាហ៍នីមួយៗ ហើយវាទាក់ទងនឹងថ្ងៃទី៧នៃការបង្កើត។ លោកអ្នកប្រហែលជាចាំថានៅថ្ងៃទី៧នៃការបង្កើត គឺជាថ្ងៃដែលព្រះជាម្ចាស់ប្រកាសថាជាថ្ងៃសម្រាក។ វាមិនមែនដោយសារតែព្រះជាម្ចាស់ហត់នឿយទេ ប៉ុន្តែគឺដោយសារតែទ្រង់បានបញ្ចប់កិច្ចការរួចទៅហើយ។ អ្វីៗគ្រប់យ៉ាងបានបញ្ចប់ទាំងស្រុង។ ថ្ងៃទី៧គឺជាថ្ងៃដែលមនុស្សត្រូវបានបង្កើតមកដើម្បីរស់នៅ ជាថ្ងៃដែលគ្មានការព្រួយបារម្ភ ហើយអ្វីគ្រប់យ៉ាងដែលមនុស្សត្រូវការ គឺមានរួចរាល់មុនដែលគេត្រូវការទៅទៀត។ ពិតមែនហើយ យើងដឹងថាលោកអដាំបានបាត់បង់ថ្ងៃសម្រាកនោះ នៅពេលដែលគាត់បានប្រឆាំងបះបោរនឹងព្រះជាម្ចាស់។ តាមរយៈការប្រឆាំងបះបោរនឹងព្រះជាម្ចាស់ លោក

អដាំត្រូវបានកាត់ផ្ដាច់ពីការផ្គត់ផ្គង់ដែលទ្រង់មានសម្រាប់គាត់។ ហេតុដូច្នេះហើយបានជាគាត់បានបាត់បង់ការផ្គត់ផ្គង់ដែលព្រះជាម្ចាស់ធ្លាប់ប្រទានកាលពីមុន។ ឥឡូវនេះលោកអដាំត្រូវបានបង្ខំឲ្យផ្គត់ផ្គង់ដល់ខ្លួនឯង ចំណាយពេលវេលារបស់គាត់ធ្វើការជាមួយនឹងការកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា និងបង្ហូរញើសគ្រាន់តែដើម្បីឲ្យបានរស់នៅ។

ប៉ុន្តែព្រះជាម្ចាស់មិនបានបោះបង់មនុស្សចោលដោយគ្មានក្ដីសង្ឃឹមទេ។ ទ្រង់បានប្រទានឲ្យមនុស្សនូវរូបភាពនៃការសម្រាក ដែលនៅថ្ងៃណាមួយទ្រង់នឹងស្ដារវាឡើងវិញ។ វាត្រូវបានហៅថាថ្ងៃសប្ប័ទ ជារូបភាពនៃថ្ងៃដែលមនុស្សមិនចាំបាច់ខិតខំប្រឹងប្រែងជានឹងការកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា និងបង្ហូរញើសរបស់ខ្លួនឯងផ្ទាល់ដោយគ្រាន់តែដើម្បីរស់នៅទៀតហើយ។ នៅពេលដែលលោកប៉ូទីផារបានចូលទៅក្នុងព្រះពររបស់ព្រះអម្ចាស់ដែលលោកយ៉ូសែបបាននាំមកតាមរយៈសម្ពន្ធមេត្រីនោះ គាត់ក៏បានចូលទៅក្នុងសមត្ថភាពរបស់ព្រះជាម្ចាស់ក្នុងការផ្គត់ផ្គង់តាមរយៈលោកយ៉ូសែប ហើយបានរកឃើញការសម្រាកដែរ។ គាត់មិនចាំបាច់ព្រួយបារម្ភនោះឡើយ ព្រោះអ្វីៗគ្រប់យ៉ាងមានព្រះជាម្ចាស់ជាអ្នកថែរក្សា។

> *លោកទុករបស់លោកទាំងអស់នៅក្នុងកណ្ដាប់ដៃយ៉ូសែប ហើយមិនបានដឹងជាមានរបស់ណាមួយទេ លើកតែភោជនាហារដែលលោកពិសាប៉ុណ្ណោះ។*
>
> \- លោកុប្បត្តិ ៣៩៖៦ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

ដើម្បីស្វែងយល់ពីសារៈសំខាន់នៅថ្ងៃសប្ប័ទ និងអ្វីដែលព្រះជាម្ចាស់កំពុងតែបង្ហាញមកកាន់មនុស្ស លោកអ្នកត្រូវតែសួរសំណួរសាមញ្ញមួយ។ តើថ្ងៃសប្ប័ទអាចកើតឡើងបានដោយរបៀបណា? ខ្ញុំចង់មានន័យថា ដោយស្ថិតនៅក្រោមបណ្ដាសានៃផែនដី មនុស្សត្រូវខិតខំធ្វើការជារៀងរាល់ថ្ងៃដើម្បីគ្រាន់តែរស់នៅ។ តើ

វាពិតដែរឬទេ ចុះបើមនុស្សមិនចាំបាច់ត្រូវធ្វើការនៅថ្ងៃសប្ប័ទ? តើគាត់អាចទទួលការផ្គត់ផ្គង់ដោយរបៀបណា ប្រសិនបើគាត់មិនអាចធ្វើការបាន? នេះគឺជាសំណួរដ៏ល្អមួយ ហើយក៏ជាសំណួរមួយដែលត្រូវតែឆ្លើយដែរ ហើយនៅក្នុងចម្លើយយើងរកឃើញបើកសម្តែងទាំងមូលនៃ «ព្រះពររបស់ព្រះជាម្ចាស់» ដែលលោកយ៉ូសេបបានរស់នៅនោះ។

ខ្ញុំគិតថា ឧទាហរណ៍ដ៏ល្អពីគោលការណ៍នេះត្រូវបានរកឃើញនៅក្នុងគម្ពីរលេវីវិន័យជំពូកទី២៥ នៅពេលដែលព្រះជាម្ចាស់កំពុងពន្យល់អំពីឆ្នាំមេត្តាករុណាដែលបានកើតឡើងនៅក្នុងស្រុកអ៊ីស្រាអែល។ ខ្ញុំសូមបង្ហាញពីប្រវត្តិរបស់វាបន្តិច។ ឆ្នាំមេត្តាករុណាកើតឡើងជារៀងរាល់៥០ឆ្នាំម្តង ហើយឆ្នាំនោះគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដែលខ្ញុំមិនបានលើកឡើងនៅទីនេះឡើយ។ តែទោះជាយ៉ាងណា ផ្នែកដែលខ្ញុំចង់ឲ្យលោកអ្នកស្វែងយល់គឺថា ពួកគេមិនអាចសាបព្រោះដំណាំបានទេនៅឆ្នាំនោះ។ តាមពិត ពួកគេមិនអាចសាបព្រោះដំណាំនៅក្នុងឆ្នាំទី៤៩ដែរ ដោយសារតែវាជាឆ្នាំសប្ប័ទ។ ដូច្នេះខ្ញុំចង់ឲ្យលោកអ្នកយល់ពីរូបភាពកាន់តែច្បាស់ពីអ្វីដែលកំពុងតែកើតឡើង៖ ព្រះជាម្ចាស់បានប្រាប់អ៊ីស្រាអែលថា ពួកគេមិនអាចសាបព្រោះដំណាំនៅក្នុងឆ្នាំទី៤៩ និង៥០។ បន្ទាប់មកពួកគេត្រូវតែរង់ចាំរហូតដល់ចុងឆ្នាំទី៥១ ហើយនៅពេលដែលពួកគេបានដាំដំណាំ ពួកគេអាចប្រមូលផលបានលុះត្រាតែដំណាំរបស់ពួកគេទុំសិន។ ជាទូទៅ ព្រះជាម្ចាស់កំពុងតែប្រាប់ពួកគេថា ពួកគេគ្មានការប្រមូលផលរយៈពេល៣ឆ្នាំ។ ចុះប្រសិនបើខ្ញុំប្រាប់លោកអ្នកថា លោកអ្នកនឹងមិនទទួលបានប្រាក់ខែចំនួន៣ឆ្នាំ លោកអ្នកប្រហែលជារៀងព្រួយបារម្ភបន្តិចហើយ។ តាមពិតទៅ អ៊ីស្រាអែលពិតជាបានព្រួយបារម្ភមែន។ បើនិយាយតាមធម្មជាតិ ការនេះនឹងមិនអាចទៅរួចទេ។ ប៉ុន្តែព្រះជាម្ចាស់កំពុងតែបង្ហាញអ្វីមួយទៅកាន់ពួកគេ។

*ប្រសិនបើអ្នករាល់គ្នាពោលថា "នៅឆ្នាំទីប្រាំពីរ តើពួកយើងនឹងបានអ្វីបរិភោគ បើពួកយើងមិនសាបព្រោះ មិនច្រូតកាត់ដូច្នេះ!"។ នៅឆ្នាំទីប្រាំមួយ*

*យើងនឹងឲ្យពរអ្នករាល់គ្នា គឺក្នុងឆ្នាំនោះ អ្នករាល់គ្នានឹងទទួលភោគផលគ្រប់គ្រាន់សម្រាប់បីឆ្នាំ។ អ្នករាល់គ្នាសាបព្រោះសាជាថ្មី នៅឆ្នាំទីប្រាំបី តែអ្នករាល់គ្នាបរិភោគផលដែលប្រមូលបានពីមុន រហូតដល់ឆ្នាំទីប្រាំបួន។ អ្នករាល់គ្នាត្រូវបរិភោគផលចាស់ រហូតទាល់តែបានទទួលភោគផលថ្មី។*

- លេវីវិន័យ ២៥៖២០-២២ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

ថ្ងៃសប្ប័ទអាចកើតឡើងបាន ដោយសារតែព្រះជាម្ចាស់បានប្រទានពរថ្ងៃទី៦ទ្វេគុណ ឬលើសពីគ្រប់គ្រាន់ទៀត។ សូមគិតពីឃ្លានេះបន្តិច។ តើវាមិនមែនជាអ្វីដែលមនុស្សគ្រប់រូបប្រាថ្នាចង់បានទេឬ? លើសពីគ្រប់គ្រាន់? នៅពេលដែលព្រះជាម្ចាស់ប្រទានឲ្យមនុស្សទ្វេដងនៅថ្ងៃទី៦ ទ្រង់កំពុងតែរំឭកគេថា ទ្រង់គឺជាអ្នកផ្គត់ផ្គង់ដល់គេ ហើយទ្រង់តែងតែផ្គត់ផ្គង់លើសពីគ្រប់គ្រាន់ទៅទៀត។ បើនិយាយឲ្យត្រង់ទៅ ការលើសពីគ្រប់គ្រាន់ផ្តល់ឲ្យនូវសេរីភាពចេញពីលានប្រណាំងកណ្តុរ។ វានាំយើងចេញពីទាសភាព ដោយឲ្យមានជម្រើស។ អ្វីដែលសំខាន់ជាងនេះទៅទៀត វាធ្វើឲ្យយើងមានសេរីភាព និងចម្រុងចម្រើនឡើងនៅក្នុងគោលបំណង និងបំណងចិត្តរបស់យើង។ នេះជាអ្វីដែលលោកប៉ូទីផារបានរីករាយនិង គ្មានការព្រួយបារម្ភ។ រាល់តម្រូវការរបស់គាត់ត្រូវបានថែរក្សារួចទៅហើយ។ កិច្ចការតែមួយគត់ដែលគាត់ត្រូវយកចិត្តទុកដាក់នោះគឺគោលបំណងរបស់គាត់។ ជាថ្មីម្តងទៀត ឌ្រិនដានិងខ្ញុំបាននិយាយថា «លុះត្រាតែអ្នកបានដោះស្រាយជាមួយថវិការរបស់អ្នកជាមុនសិន បើមិនដូច្នោះទេ អ្នកនឹងមិនអាចស្វែងរកគោលបំណងរបស់អ្នកបានឡើយ។» ប៉ុន្តែមានដំណឹងល្អមួយ! ថ្ងៃសប្ប័ទក៏មាននៅក្នុងសព្វថ្ងៃនេះដែរ ហើយវាបានផ្តល់កន្លែងមួយដែលបានបំពេញរាល់តម្រូវការរបស់យើង ហើយយើងអាចចម្រុងចម្រើនលើសពីការដែលគ្រាន់តែមានគ្រប់គ្រាន់ដើម្បីរស់នៅ។

*ដូច្នេះ ព្រះជាម្ចាស់បានតម្រូវទុកឲ្យមានថ្ងៃសម្រាកមួយទៀតសម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ ដូចព្រះអង្គសម្រាកនៅថ្ងៃទីប្រាំពីរដែរ ដ្បិតអ្នកណាចូលទៅ*

*សម្រាកជាមួយព្រះជាម្ចាស់ អ្នកនោះបានបង្ហើយកិច្ចការរបស់ខ្លួន (បណ្តាសានៃការកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា និងបង្ហូរញើសដើម្បីរស់នៅ) ដូចព្រះជាម្ចាស់បង្ហើយកិច្ចការរបស់ព្រះអង្គដែរ។*

- ហេប្រឺ ៤៖៩-១០ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

ព្រះរាជ្យរបស់ព្រះជាម្ចាស់បានឲ្យលោកប៉ូទីផារងើបឡើងខ្ពស់ជាងច្បាប់នៃការកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា និងបង្ហូរញើសរបស់អាណាចក្រនៃផែនដី ហើយវាក៏កើតឡើងចំពោះលោកអ្នកដែរ។ នៅពេលដែលយើងរៀនពីរបៀបចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ យើងអាចចម្រុងចម្រើន និងស្វែងរកគោលបំណងរបស់យើងបាន ហើយជីវិតនឹងសប្បាយរីករាយ ពេញដោយបំណងចិត្ត (ភាពឆេះឆួល) និងអំណរ! ជាការពិតមែន!

*អំណោយពរនៃព្រះយេហូវ៉ា នោះធ្វើឲ្យទៅជាមាន ហើយទ្រង់មិនបន្ថែមសេចក្តីទុក្ខព្រួយផងទេ។*

-សុភាសិត ១០៖២២ (ព្រះគម្ពីរបរិសុទ្ធ)

**ឈប់សម្របខ្លួនអ្នកជាមួយនឹងការសង្ស័យ និងការមិនជឿទាំងប៉ុន្មានដែលនៅជុំវិញអ្នក។ ផ្លាស់ប្តូរតក្កីភាពរបស់អ្នក ហើយរីករាយនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។**

អំណោយពរមកពីព្រះអម្ចាស់ ធ្វើឲ្យមនុស្សចម្រុងចម្រើន ហើយព្រះជាម្ចាស់មិនបន្ថែមពលកម្មយ៉ាងលំបាកជាមួយវាទេ!!! យើងអាចរស់នៅខ្ពស់ជាងបណ្តាសានៃការកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា និងបង្ហូរញើសនៅក្នុងគម្ពីរលោកុប្បត្តិ ៣៖១៧ បាន។ ខ្ញុំបានរស់នៅក្នុងបណ្តាសានោះអស់រយៈពេលជាច្រើនឆ្នាំ រហូតដល់ពេលខ្ញុំបានរៀនពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ធ្វើការ។ លោកអ្នកក៏អាចរៀនពីការនោះបានដែរ។ ព្រះជាម្ចាស់គង់នៅជាមួយលោកអ្នក! ហើយទ្រង់អាចជួយ

លោកអ្នក! ដើម្បីឲ្យលោកអ្នកបានចម្រុងចម្រើន។ អត់ទេ ខ្ញុំសូមនិយាយឃ្លានោះម្តងទៀត៖ លោកអ្នកត្រូវតែចម្រុងចម្រើន។ មនុស្សនៅលើលោកដែលមានលក្ខណៈជាប៉ូទីផារ ជាអស់អ្នកដែលមិនស្គាល់ព្រះជាម្ចាស់ ហើយស្ថិតនៅក្រោមបណ្តាសានៃការអស់សង្ឃឹម ការធ្វើពលកម្មយ៉ាងលំបាកវេទនា ការព្យាយាមឲ្យមានជីវិតរស់នៅកំពុងតែមើលមកកាន់យើង។ ពួកគេមិនចាប់អារម្មណ៍នឹងសាសនា អគារក្រុមជំនុំ និងបទគម្ពីររបស់លោកអ្នកទេ ព្រោះថាបើលោកអ្នកគ្មានចម្លើយសម្រាប់ពួកគេ ពួកគេមិនអាចមើលឃើញអ្វីផ្សេងទៀតឡើយ។ លោកអ្នកមិនអាចរំពឹងឲ្យមនុស្សស្តាប់លោកអ្នក នៅពេលដែលលោកអ្នកប្រាប់ពួកគេថាព្រះជាម្ចាស់ល្អប៉ុណ្ណា ប៉ុន្តែបែរជាកំពុងរស់នៅនៅក្នុងបញ្ហាហិរញ្ញវត្ថុដ៏តានតឹង និងគួរឲ្យភ័យខ្លាច ការខ្វះខាត និងខិតខំត្រដររឲ្យបានរស់រានដូចជាគេដែរនោះទេ។ អត់ទេ! លោកអ្នកត្រូវតែបង្ហាញពីលក្ខណៈនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ដូចដែលលោកយ៉ូសែបបានធ្វើ។ ខ្ញុំមិនមែនបានន័យថា វាត្រូវតែពិបាកនោះទេ ប៉ុន្តែមនុស្សក៏មិនល្ងង់ដែរ។ ពួកគេកំពុងតែស្វែងរកចម្លើយ។

ទឹកមាត់របស់ខ្ញុំសាបក្នុងរយៈពេលជាច្រើនឆ្នាំ។ គ្មាននរណាម្នាក់សុំឲ្យខ្ញុំចូលក្នុងកម្មវិធីទូរទស្សន៍ ហើយខ្ញុំក៏មិនបានដឹកនាំក្រុមជំនុំដែលមានមនុស្សរាប់ពាន់នាក់ដែរ។ ហេតុអ្វីទៅ? ដោយសាតែខ្ញុំគ្មានអ្វីត្រូវនិយាយ គ្មានដំណោះស្រាយ គ្មានចម្លើយ គ្មានភ័ស្តុតាងថាទ្រង់មានព្រះជន្មគង់នៅ ហើយគង់នៅជាមួយខ្ញុំឡើយ។ ខ្ញុំធ្លាប់ខ្ចីលុយគ្រួសារគ្រាន់តែដើម្បីរស់នៅ។ ឡានរបស់ខ្ញុំខូច ផ្ទះរបស់ខ្ញុំក៏បែកបាក់ ហើយជីវិតរបស់ខ្ញុំក៏ខ្ទេចខ្ទាំដែរ។ តើនឹងមាននរណាចង់ឮថា ព្រះរបស់ខ្ញុំល្អអស្ចារ្យនោះ? ត្រឹមត្រូវហើយ! ថ្ងៃណាមួយខ្ញុំនឹងទៅស្ថានសួគ៌ ហើយស្ថានសួគ៌ជាកន្លែងដែលល្អបំផុត ប៉ុន្តែមនុស្សនឹងមិនចង់ឮថាស្ថានសួគ៌ល្អអស្ចារ្យប៉ុណ្ណាទេ លុះត្រាតែលោកអ្នកបង្ហាញថាស្ថានសួគ៌គឺនៅត្រង់នេះក្នុងអាណាចក្រនៃផែនដីនេះ។ សូមស្តាប់ខ្ញុំ អ្វីដែលខ្ញុំនិយាយទាំងអម្បាលម៉ាននេះគឺថា ប្រសិនបើព្រះជាម្ចាស់គឺជាព្រះ ហើយព្រះបន្ទូលរបស់ទ្រង់ពិតប្រាកដមែន នោះវាគួរតែអាចទៅរួច។ ជីវិតរបស់យើង

គួរតែមានលក្ខណៈខុសប្លែក ហើយត្រូវតែប្លែកពីគេ! យើងត្រូវឈោងចាប់ជំនាន់នេះជាមួយនឹងសេចក្តីពិតនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ លោកប៉ូទីផារកំពុងតែសង្កេតមើលយើង។

ដូច្នេះ តើហេតុអ្វីបានជាខ្ញុំដាក់ចំណងជើងជំពូកនេះថា *អំណាចនៃតក្តីភាពនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់?* គឺដោយសារតែលោកប៉ូទីផារបានចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយបានរីករាយនឹងថ្ងៃសប្ប័ទដែលគ្មាននូវការរស់នៅតាមបណ្តាសានៃការកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនានិងបង្ខូរញើស គ្មានភាពភ័យខ្លាច តែមានសន្តិភាពផង។ វាជាកន្លែងដែលមនុស្សទទួលបានគោលបំណង និងចិត្តឆេះឆួល ជំនួសឲ្យការខិតខំត្រដររស់ ហើយមានការផ្គត់ផ្គង់ជំនួសឲ្យភាពក្រីក្រ។ តើគាត់អាចធ្វើបែបនេះបានដោយរបៀបណា? គាត់បានយកបញ្ហា និងការខ្វល់ខ្វាយរបស់គាត់មកដាក់នៅក្រោមដែលសមត្ថកិច្ចនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ដោយស្របច្បាប់។ ទោះបីជាគាត់មិនបានដឹងច្បាស់ពីអ្វីដែលគាត់កំពុងធ្វើក៏ដោយ ប៉ុន្តែ<u>គាត់បានសម្រុះខ្លួនគាត់ជាមួយព្រះជាម្ចាស់</u>។ គាត់បានព្រមព្រៀង និងស្ថិតក្រោមព្រះរាជ្យរបស់ព្រះជាម្ចាស់ស្របច្បាប់។ លោកប៉ូទីផារជាមនុស្សឆ្លាត ហើយក៏បានដាក់ទ្រព្យសម្បត្តិរបស់គាត់នៅក្រោមការគ្រប់គ្រងរបស់លោកយ៉ូសែប ដោយសារតែគាត់បានឃើញនូវចម្លើយទាំងនោះ។ លោកអ្នកក៏អាចធ្វើវាបានដែរ នោះហើយជាអ្វីដែលឌ្រិនដានិងខ្ញុំបានធ្វើ។ នោះជារបៀបដែលសត្វក្តាន់បានបង្ហាញខ្លួនលុយកាក់បានបង្ហាញឡើង ឡាន និងផ្ទះដែលយើងត្រូវការក៏បានបង្ហាញឡើង។ ដូច្នេះខ្ញុំសូមផ្តល់ការណែនាំមួយដល់លោកអ្នក។ ប្រសិនបើលោកអ្នកចង់រីករាយជាមួយនឹងអ្វីគ្រប់យ៉ាងដែលព្រះជាម្ចាស់មានសម្រាប់លោកអ្នក ចូរផ្លាស់ប្តូរភក្តីភាពរបស់លោកអ្នក។ ឈប់សម្រុះខ្លួនលោកអ្នកជាមួយនឹងការសង្ស័យ និងការមិនជឿទាំងប៉ុន្មានដែលនៅជុំវិញលោកអ្នក។ ចូរផ្លាស់ប្តូរភក្តីភាពរបស់លោកអ្នក ហើយរីករាយនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់វិញ។

## ជំពូកទី៩

# អ្នកយកម្ហូបអាហារឲ្យគេបរិភោគទៅ!

នៅពេលដែលខ្ញុំទើបតែស្គាល់លោកដន គាត់បានចូលមកក្នុងការិយាល័យរបស់ខ្ញុំទាំងបាក់ទឹកចិត្ត និងជាប់ក្នុងបំណុល។ នៅក្នុងមួយឆាកជីវិតរបស់គាត់ ពុំមានអ្វីមួយដែលហាក់ដូចជាល្អប្រសើរសោះ។ នៅពេលដែលខ្ញុំអង្គុយចុះ ហើយនិយាយជាមួយគាត់ ខ្ញុំបានរកឃើញថា គាត់បានជំពាក់លុយថ្លៃឈ្នួលផ្ទះពីរបីខែ ហើយក៏ជំពាក់បំណុលផ្សេងៗជាច្រើនដែរ។ មានបញ្ហានៅក្នុងអាពាហ៍ពិពាហ៍ ប្រពន្ធរបស់គាត់បានផ្តោតចិត្តនឹងស្ថានភាពថវិការបស់ពួកគេ ហើយក៏ចាប់ផ្តើមបាត់បង់ការគោរពសម្រាប់លោកដន ព្រោះគាត់មិនអាចផ្គត់ផ្គង់ដល់នាង និងកូនៗទាំងប្រាំនាក់។ ការពិតគឺថា លោកដនបានបាត់បង់ការគោរពសម្រាប់ខ្លួនគាត់។ ហើយគាត់មានមន្ទិលជាច្រើននៅក្នុងចិត្ត។

គាត់ធ្វើការទាក់ទងនឹងការលក់ធានារ៉ាប់រងសុខភាពនៅទូទាំងរដ្ឋអូហៃយ៉ូទាំងមូល ប៉ុន្តែកង្វះជោគជ័យនៅក្នុងជីវិតបានធ្វើឲ្យគាត់រស់នៅដោយមានវិបត្តិខាងផ្នែកថវិកាជាទម្ងន់។

ទោះបីជាមានបញ្ហាជាច្រើនបានមកយាយីលោកដនក្តី ក៏ខ្ញុំបានឃើញសក្តានុពលនៅក្នុងគាត់ដែរ។ គាត់មានឆន្ទៈក្នុងការរៀនសូត្រ និងខិតខំធ្វើការ។ ឆន្ទៈទាំង

ពីរនេះ ជាឆន្ទៈដ៏មានអានុភាព ហើយធ្វើឲ្យខ្ញុំចាប់អារម្មណ៍រហូតដល់បានជួលគាត់ និងដាក់ទុនដោយខ្លួនឯង ដើម្បីសុខុមាលភាព និងអនាគតរបស់គាត់។ នៅចុងបញ្ចប់ វាជាការដាក់ទុនមួយដែលបានបង់ថ្លៃភាគលាភដ៏ធំសម្បើមសម្រាប់យើងទាំងពីរ។

ក្រុមហ៊ុនដ៏ក្មេងខ្ចីរបស់យើងទើបតែបានឈ្នះការធ្វើដំណើរមួយទៅកាន់កោះហាវ៉ៃ ពីក្រុមហ៊ុនដែលផ្គត់ផ្គង់ធនធានដល់យើង ហើយខ្ញុំមានអារម្មណ៍ថានេះជាឱកាសដ៏ល្អក្នុងការចែករំលែកអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមួយនឹងដន។ ទោះបីជាដនជាគ្រិស្តបរិស័ទក៏ដោយ គាត់ក៏មិនមានការយល់ដឹងដូចជាខ្ញុំដែរ។ ហើយទោះបីជាខ្ញុំបានព្យាយាមចែករំលែកអំពីគោលការណ៍របស់ព្រះជាម្ចាស់ជាមួយគាត់ទាក់ទងនឹងផ្នែកនេះបួនប្រាំដងក្តី គាត់ហាក់ដូចជាមិនជឿលើអ្វីដែលខ្ញុំនិយាយទេ។

ខ្ញុំបានរកមើលរបៀបណាមួយដើម្បីឲ្យដនចាប់អារម្មណ៍ ព្រោះវាអាចជួយដល់គាត់ឲ្យយល់ថា គាត់ក៏អាចទទួលបានជោគជ័យដោយរៀនពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការ។ ទោះជាយ៉ាងនេះក្តី លោកដនបានបាក់ទឹកចិត្តជាខ្លាំងនៅពេលដែលគាត់មានការពិបាកនៅក្នុងការជឿជាក់លើខ្លួនឯង និងជឿថាការប្រែប្រួលពិតជាអាចកើតឡើងមែន។ ខ្ញុំដឹងថា ការធ្វើដំណើរទៅកោះហាវ៉ៃនេះជាឱកាសដ៏ល្អសម្រាប់ខ្ញុំ។

នៅក្នុងពេលប៉ុន្មានសប្តាហ៍មុនដែលខ្ញុំ ហើយនិងដនត្រូវចេញដំណើរ យើងបាននិយាយពីអ្វីដែលយើងអាចទស្សនា និងធ្វើនៅទីនោះ។ ដនបានចាប់អារម្មណ៍លើសកម្មភាពមួយដែលខុសប្លែកពីអ្នកដទៃ។ គាត់ចង់នេសាទត្រីប្លូម៉ាលីន (blue marlin) នៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិកដ៏ស្រស់ស្អាត។ លោកដនបានប្រាប់ខ្ញុំយ៉ាងរំភើបថា «កោះហាវ៉ៃជាទីក្រុងមួយដែលសម្បូរដោយសត្វត្រីប្លូម៉ាលីន។ ខ្ញុំតែងតែចង់ចាប់ត្រីប្លូម៉ាលីនឲ្យបានមួយក្បាល។ នេះហើយជាក្តីសុបិនរបស់ខ្ញុំ។» នៅក្នុងពេលប៉ុន្មានសប្តាហ៍នោះ ជាលើកដំបូងដែលខ្ញុំបានមើលឃើញពន្លឺនៅក្នុងកែវភ្នែក

របស់លោកដន។ មានអ្វីម្យ៉ាងដែលធ្វើឲ្យគាត់រំភើបជាខ្លាំង ហើយខ្ញុំដឹងថាការរំភើបរបស់គាត់នឹងបើកទ្វារឲ្យគាត់អាចរៀនបាននូវមេរៀនដ៏មានអានុភាពម្យ៉ាង។

ខ្ញុំនិយាយថា «លោកដន តើលោកដឹងទេថា លោកអាចដឹង គឺមិនមែនគ្រាន់តែសង្ឃឹមទេ ប៉ុន្តែ*ដឹង*ថាលោកនឹងចាប់បានត្រីប្លូម៉ាលីនមួយក្បាលនៅកោះហាវ៉ៃ នៅពេលដែលលោកប្រើប្រាស់គោលការណ៍នៃព្រះរាជ្យរបស់ព្រះជាម្ចាស់?» ដោយច្របូកច្របល់ផង និងចាប់អារម្មណ៍ផង លោកដនក៏ចង់ដឹងថែមទៀត ហើយខ្ញុំក៏បានបន្តពន្យល់គាត់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ខ្ញុំបានលើកយកខគម្ពីរម៉ាកុស ១១៖២៤ ដោយថែងថា «*ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្វីក៏ដោយឲ្យតែអ្នករាល់គ្នាអធិស្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជាម្ចាស់នឹងប្រទានឲ្យអ្នករាល់គ្នាជាពុំខាន*»។ សម្រាប់លោកដន គាត់មានការពិបាកនឹងជឿលើការនេះណាស់។ ខ្ញុំបានចំណាយពេលខ្លះជួយដល់គាត់ឲ្យយល់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងរបៀបស្រាយនូវជំនឿ។ ហើយដូច្នេះ មុនពេលដែលយើងបានចេញដំណើរទៅកោះហាវ៉ៃ គាត់និងភរិយារបស់គាត់បានសាបព្រោះដូចដែលខ្ញុំបានធ្វើជាមួយនឹងសត្វក្ដាន់ ដោយអធិស្ឋានទាំងព្រមព្រៀងគ្នា ហើយជឿថាពួកគេបានទទួលត្រីប្លូម៉ាលីនមួយក្បាលមែន។

នៅក្នុងពេលជាមួយគ្នា លោកដនបានធ្វើអ្វីៗដែលគាត់ដឹងថាត្រូវធ្វើ ដើម្បីបំពេញនាទីរបស់គាត់នៅក្នុងការច្រូតកាត់។ គាត់បានធ្វើការស្រាវជ្រាវនៅលើទូកទំនេរៗ និងតម្លៃទូក ហើយជាចុងក្រោយក៏បានកក់ទូកមួយដែលមានអ្នកបើកទូកដែលគាត់ពេញចិត្ត។ អ្វីៗទាំងអស់រួចរាល់ ហើយយើងពិតជារំភើបអំពីការធ្វើដំណើរទៅក្នុងសមុទ្រខៀវនៃកោះហាវ៉ៃណាស់។

ថ្ងៃដែលយើងជិះទូកក៏បានមកដល់ ហើយនៅពេលដែលយើងចេញទូក យើងបានប្រាប់ទៅកាន់នាយនាវាទាំងក្ដីរីករាយថា ថ្ងៃនេះជាថ្ងៃដែលនឹងចាប់ត្រីប្លូម៉ាលីន ។ តាមពិត គាត់រំពឹងថាយើងនឹងចាប់បានត្រីផ្សេងទៀតក្រៅពីត្រីប្លូម៉ាលីនព្រមទាំងបញ្ជាក់ប្រាប់យើងថា យើងប្រហែលជាគ្មានសំណាងចាប់បានត្រីប្លូម៉ាលីននោះថ្ងៃ

នោះឡើយ។ មានទូកពីរគ្រឿងបានដឹកភ្ញៀវទេសចរជារៀងរាល់ថ្ងៃ នៅក្នុងពេលបួនខែនេះ ហើយក្រុមការងាររបស់គាត់ចាប់បានត្រីប្លូម៉ាលីនតែមួយក្បាលប៉ុណ្ណោះ។ ភាគច្រើន នេះគឺដោយសារតែពុំទាន់ដល់រដូវត្រីម៉ាលីននៅឡើយ ដោយហេតុថាពួកវាជាត្រីដែលផ្លាស់ទីរស់នៅតាមរដូវកាល។ ដោយមិនព្រមបាក់ទឹកចិត្ត យើងបានប្រាប់គាត់ទាំងក្តីគោរពថា យើងនឹងចាប់បានត្រីនោះមួយក្បាល ហើយក៏បន្តរៀបចំសម្ភារៈរបស់យើងទៀត។

> **«ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្វីក៏ដោយឲ្យតែអ្នករាល់គ្នាអធិស្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជាម្ចាស់នឹងប្រទានឲ្យអ្នករាល់គ្នាជាពុំខាន។»**
>
> \- **ម៉ាកុស ១១:២៤**

បន្ទាប់ពីធ្វើដំណើរបានប្រាំមួយម៉ោង យើងមិនទាន់ឃើញត្រីនោះស៊ីនុយសោះ ហើយខ្ញុំចាប់ផ្តើមបារម្ភបន្តិចថាដោយមិនមានអ្វីកើតឡើង អាចធ្វើឲ្យជំនឿរបស់ដនចុះទន់ខ្សោយ។ ដោយហេតុតែបារម្ភ ខ្ញុំបានស្រែកសួរគាត់ថា «ដន» ខ្ញុំស្រែកឡើងពីកន្លែងអង្គុយនៅដំបូលខាងលើ «ខ្ញុំសុំសួរមួយ នៅពេលដែលលោកបានទទួលត្រីប្លូម៉ាលីននោះ តើលោកបានទទួលនៅពេលដែលវាបង្ហាញខ្លួន ឬនៅពេលដែលយើងអធិស្ឋាន?» ដោយទំនុកចិត្ត លោកដនបានតបមកវិញថា «លោកហ្គារី សំណួរនេះគឺសាមញ្ញ។ ខ្ញុំបានទទួលវានៅពេលដែលខ្ញុំអធិស្ឋាន។» ខ្ញុំពិតជារំភើប និងមានទំនុកចិត្តនៅពេលដែលខ្ញុំបានឮចម្លើយរបស់គាត់។ នៅពេលនោះទើបខ្ញុំដឹងថា លោកដនបានទទួលការបង្រៀនរបស់ខ្ញុំដោយហ្មត់ចត់ ហើយគាត់ពិតជាតាំងចិត្តធ្វើយ៉ាងណាចាប់ត្រីម៉ាលីននោះឲ្យបាន។

ប៉ុន្មាននាទីក្រោយមក ដុំរ៉ៃខ្សែសន្ទូចរបស់ដនចាប់ផ្តើមវិល នៅពេលដែលដងសន្ទូចកោងចូលទៅក្នុងទឹកសមុទ្រ ហើយអ្នកនៅលើទូកនោះបានស្រែកថា «ត្រីស៊ីសន្ទូចហើយ!»

នាយនាវាបានរំឭកថា «កុំទាន់អាលអរ។ វាជាត្រីធំមែន ប៉ុន្តែមិនមែនជាត្រីប្លូម៉ាលីនទេ។ ជាទូទៅ ត្រីម៉ាលីនឡើងមកដល់ផ្ទៃទឹកខាងលើ ហើយលោតឡើងពីទឹកយ៉ាងខ្ពស់ ប៉ុន្តែត្រីនេះនៅខាងក្រោមជ្រៅទៅវិញ។» នៅក្នុងពេលប៉ុន្មាននាទីនោះ ដនបានបន្តប្រទាញប្រទង់ជាមួយនឹងត្រីដែលមិនទាន់ឡើងមកផ្ទៃទឹកខាងលើ ដើម្បីឲ្យយើងឃើញថាជាត្រីអ្វីនៅឡើយទេ។ នៅពេលដែលដនកាន់តែហត់ ត្រីក៏ហត់ ហើយក៏ព្រមចុះចាញ់។ ដន ហើយនិងខ្ញុំមិនបានភ្ញាក់ផ្អើលឡើយ នៅពេលដែលគាត់ស្ទូចបានត្រីប្លូម៉ាលីនដ៏ធំ និងស្រស់ស្អាតមួយក្បាលនោះ ប៉ុន្តែអ្នកដទៃទៀតដែលនៅលើទូកបានស្រឡាំងកាំង។

**ដូចជាខ្យល់អញ្ចឹង យើងមិនអាចមើលឃើញខ្យល់ទេ ប៉ុន្តែវាអាចមានឥទ្ធិពលនៅលើភពធម្មជាតិដែលយើងអាចមើលឃើញបាន។ ព្រះរាជ្យរបស់ព្រះជាម្ចាស់ក៏ដូចគ្នាដែរ។ ព្រះរាជ្យរបស់ទ្រង់គឺពិតប្រាកដ ហើយមានឥទ្ធិពលនៅលើភពធម្មជាតិ។**

រូបថតរបស់លោកដន និងសត្វត្រីដែលគាត់ស្ទូចបាននៅតែមាននៅក្នុងការិយាល័យរបស់ខ្ញុំមកទល់សព្វថ្ងៃ។ វាជាទីបន្ទាល់ទៅកាន់អ្នកដទៃទៀត និងជាការរំឭកដល់ខ្ញុំពីសេចក្តីពិតនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ បើមើលពីសំបកក្រៅ វាគ្រាន់តែជាត្រីមួយក្បាលប៉ុណ្ណោះ។ ប៉ុន្តែចំពោះលោកដន ត្រីម៉ាលីននោះមានន័យសម្រាប់គាត់ខ្លាំង។ ប្រសិនបើព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការសម្រាប់ត្រីម៉ាលីន ព្រះរាជ្យក៏ដំណើរការសម្រាប់អ្វីៗផ្សេងទៀតដែលគាត់ត្រូវការនៅក្នុងឆាកជីវិតដែរ។ សម្រាប់លោកដន ពេលនោះគ្រាន់តែជាទីចាប់ផ្តើមនៃការដែលគាត់បានយល់ពីឥទ្ធិពលនៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅលើជីវិតរបស់គាត់ប៉ុណ្ណោះ។

នៅពេលដែលយើងពិនិត្យមើលព្រឹត្តិការណ៍មួយដែលបានកើតឡើងជាងពីរបីពាន់ឆ្នាំមុន យើងនឹងរៀនបានអំពីបុរសម្នាក់ឈ្មោះថានីកូដេម ដែលបានសួរព្រះយេស៊ូយ៉ាងជាក់លាក់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ នៅក្នុងជំពូកទី៣ នៃកណ្ឌគម្ពីរយ៉ូហានបានកត់ត្រាពីចម្លើយរបស់ព្រះអម្ចាស់ថា «ខ្យល់ ចង់បក់ទៅទិសណាក៏បាន លោកឮស្នូរវា តែលោកពុំដឹងថាខ្យល់បក់មកពីទីណាទៅទីណាឡើយ រីឯអ្នកដែលកើតមកពីព្រះវិញ្ញាណក៏ដូច្នោះដែរ» (ខ ៨)។ ថ្ងៃដ៏ស្រស់បំព្រងដែលយើងបានចេញទូកជាមួយនឹងលោកដន ជាឧទាហរណ៍ដ៏ស័ក្តិសមអំពីសេចក្តីនេះ។

នៅខណៈដែលខ្ញុំនិងលោកដនមិនអាចមើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់ យើងពិតជាបានឃើញ និងមានអារម្មណ៍អំពីការប៉ះពាល់នៃព្រះរាជ្យរបស់ទ្រង់ដែលត្រីម៉ាលីនដ៏ធំបានមកជាប់សន្ទូចយើងនៅថ្ងៃនោះ។ ដូចជាខ្យល់អញ្ចឹង យើងមិនអាចមើលឃើញខ្យល់ទេ ប៉ុន្តែវាអាចមានឥទ្ធិពលនៅលើភពធម្មជាតិដែលយើងអាចមើលឃើញបាន។ ព្រះរាជ្យរបស់ព្រះជាម្ចាស់ក៏ដូចគ្នាដែរ។ ព្រះរាជ្យរបស់ទ្រង់គឺពិតប្រាកដ ហើយមានឥទ្ធិពលនៅលើភពធម្មជាតិ។ ដោយការដែលស្វែងយល់ច្បាប់ដែលគ្រប់គ្រងលើព្រះរាជ្យរបស់ព្រះជាម្ចាស់ យើងអាចនាំការផ្លាស់ប្តូរនៅក្នុងជីវិតរបស់យើងដូចជាលោកដនបានធ្វើនៅថ្ងៃនោះដែរ។

ខ្ញុំសុំសួរដូច្នេះ។ តើត្រីម៉ាលីនបានបង្ហាញខ្លួនដោយរបៀបណា? មានចម្លើយចំពោះសំណួរនេះ។ លោកអ្នកមិនអាចគ្រាន់តែនិយាយថា ព្រះជាម្ចាស់ជាអ្នកធ្វើប៉ុណ្ណោះទេ។ អត់ទេ យើងត្រូវចាំបាច់ដឹងថា តើយើងបានដឹងថាវានឹងបង្ហាញខ្លួនឡើងដោយរបៀបណា។ លោកអ្នកពិតជាត្រូវការដឹងពីការនេះព្រោះថា ប្រហែលជាមានថ្ងៃណាមួយដែលលោកអ្នកត្រូវការត្រីប្លូម៉ាលីន ឬឡានពណ៌ខៀវ ឬក៏គ្រាន់តែជាគ្រឿងទេស។ សេចក្តីពិតគឺថា ចំណុចសំខាន់នៃសាច់រឿងនេះគឺមិនមែនដើម្បីបង្ហាញពីការស្ទូចត្រី ឬការបរបាញ់សត្វក្តាន់ទេ។ សាច់រឿងខាងលើផ្តល់ឲ្យយើងមានការយល់ដឹងអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងរបៀបដែលព្រះរាជ្យដំណើរការ។ មានហេតុផលដែលត្រីប្លូម៉ាលីនបង្ហាញខ្លួនឡើង! ព្រះយេស៊ូបានចំណាយ

ពេលជាច្រើនបង្រៀនដល់ពួកសិស្សអំពីរបៀបដែលព្រះរាជ្យដំណើរការ ប៉ុន្តែទ្រង់មិនគ្រាន់តែមានបន្ទូលប៉ុណ្ណោះទេ គឺទ្រង់បានថែមទាំងបង្ហាញពួកគេដែរ។

សូមយកចិត្តទុកដាក់ឲ្យមែនទែន។ ព្រះរាជ្យរបស់ព្រះជាម្ចាស់មិនដំណើរការដូចជាភពផែនដីដែលលោកអ្នកចម្រើនវ័យឡើងនោះទេ។ លោកអ្នកប្រាកដជាមិនអាចយល់អស់អំពីព្រះរាជ្យតាមរយៈគំនិតជាមនុស្សនេះបានឡើយ។ ជាការពិតណាស់ ព្រះរាជ្យធ្វើប្រតិបត្តិការតាមរយៈច្បាប់នានា។ នៅលើផែនដីក៏ដូច្នេះដែរ យើងត្រូវគោរពតាមច្បាប់ផ្សេងៗ។ ប៉ុន្តែ យើងអាចរៀនពីច្បាប់នៃព្រះរាជ្យបាន។ ព្រះយេស៊ូបានចំណាយពេលជាច្រើនបង្ហាត់បង្ហាញ និងបង្រៀនអំពីច្បាប់នានានៃព្រះរាជ្យរបស់ព្រះជាម្ចាស់នៅគ្រប់កន្លែងដែលទ្រង់យាងទៅ។ សាច់រឿងមួយដែលខ្ញុំចូលចិត្តគឺនៅពេលដែលព្រះយេស៊ូបានបង្ហាញពីព្រះរាជ្យរបស់ព្រះជាម្ចាស់ នៅក្នុងម៉ាកុសជំពូក ៦។ នេះជាសាច់រឿងដ៏ពេញនិយមស្ដីអំពីព្រះយេស៊ូប្រទានអាហារដល់មនុស្ស ៥០០០ នាក់ តាមរយៈនំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយ។ ទោះបីជាខ្ញុំបានឮសាច់រឿងនេះជាច្រើនដងរាប់មិនភ្លេចកាលដែលខ្ញុំធំឡើងនៅក្នុងក្រុមជំនុំក្ដី ក៏ពុំដែលមាននរណាម្នាក់ធ្លាប់ប្រាប់ខ្ញុំពីរបៀបដែលព្រះយេស៊ូបានធ្វើដូច្នោះដែរ។

> *ពេលនោះ ថ្ងៃកាន់តែជ្រេណាស់ហើយ សិស្សនាំគ្នាចូលមកគាល់ព្រះយេស៊ូ ទូលព្រះអង្គថា៖ «ទីនេះស្ងាត់ណាស់ ថ្ងៃក៏ជិតលិចផង សូមប្រាប់អ្នកទាំងនេះឲ្យត្រលប់ទៅវិញ ទៅរកទិញម្ហូបអាហារបរិភោគតាមផ្ទះ តាមភូមិជិតៗនេះ»។ ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេវិញថា៖ «ចូរអ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ!»។ គេទូលព្រះអង្គថា៖ «តើយើងត្រូវយកប្រាក់ពីររយដួង ទៅទិញម្ហូបអាហារឲ្យគេបរិភោគឬ?»។ ព្រះអង្គមានព្រះបន្ទូលសួរគេថា៖ «ទៅមើលមើល៍ អ្នករាល់គ្នាមាននំប៉័ងប៉ុន្មានដុំ?»។ កាលបានដឹងហើយ គេទូលព្រះអង្គថា៖ «យើងខ្ញុំមាននំប៉័ងប្រាំដុំ និងត្រីងៀតពីរកន្ទុយ»។ ព្រះ*

*យេស៊ូបង្គាប់ពួកសិស្សឲ្យប្រាប់បណ្តាជន អង្គុយជាក្រុមៗនៅលើស្មៅខៀវខ្ចី។ គេអង្គុយជាជួរ ជួរខ្លះមានមួយរយនាក់ ជួរខ្លះមានហាសិបនាក់។ ព្រះយេស៊ូយកនំប៉័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ទ្រង់ងើបព្រះភ័ក្ត្រឡើង សរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់នំប៉័ងប្រទានឲ្យពួកសិស្ស ដើម្បីឲ្យគេចែកបណ្តាជនបរិភោគ ព្រះអង្គក៏ចែកត្រីពីរកន្ទុយនោះឲ្យគេទាំងអស់គ្នាដែរ។ អ្នកទាំងនោះបរិភោគឆ្អែតគ្រប់ៗគ្នា។ ពួកសិស្សប្រមូលនំប៉័ង និងត្រីដែលនៅសល់ ដាក់បានពេញដប់ពីរល្អី។ ក្នុងចំណោមអ្នកដែលបរិភោគនំប៉័ង មានប្រុសៗចំនួនប្រាំពាន់នាក់។*

ម៉ាកុស ៦៖៣៥-៤៤ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

«ព្រះយេស៊ូ យើងមានបញ្ហាធំមួយ។ មនុស្សកំពុងតែឃ្លាន ហើយប្រសិនបើគេមិនចាកចេញនៅពេលនេះទេ ពួកគេនឹងទៅដល់ផ្ទះនៅយប់ជ្រៅជាមិនខាន។ យើងព្រួយបារម្ភណាស់។» ដូច្នេះ តើព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេយ៉ាងដូចម្តេច? «ឱម្ចាស់ថ្លៃអើយ អ្នកនិយាយត្រូវមែន។ ខ្ញុំមិនបានមើលម៉ោងសោះ។ តោះ យើងបញ្ចប់ការប្រជុំនៅពេលនេះភ្លាម។» អត់ទេ គឺទ្រង់គ្រាន់តែមានបន្ទូលថា «ចូរអ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ»។ ថាម៉េច? ព្រះគម្ពីរកត់ត្រាថាមានបុរស ៥០០០ នាក់នៅទីនោះ ប៉ុន្តែបើរាប់ទាំងស្ត្រី និងកុមារអាចមានរហូតដល់ជាង ២០០០០នាក់។ ការចែកអាហារដល់មនុស្សដែលមានចំនួនច្រើនយ៉ាងនេះ ទោះបីជាលោកអ្នកមានធនធាននៅទីនោះហើយក្តី ក៏វាជាកិច្ចការធំសម្បើមណាស់ គឺមិនអាចទៅរួចឡើយ។ ខ្ញុំប្រាកដថា ពួកសិស្សមិនជឿលើអ្វីដែលព្រះយេស៊ូមានបន្ទូលទេ។ ចម្លើយរបស់ពួកគេចំពោះដំណោះស្រាយរបស់ទ្រង់ផ្តល់ឲ្យយើងយល់យ៉ាងច្បាស់អំពីផ្នត់គំនិតជាទូទៅនៅលើភពផែនដី។ «តើយើងត្រូវយកប្រាក់ពីររយដួង (ដែលស្មើនឹងប្រាក់ខែចំនួន៨ខែ) ទៅទិញម្ហូបអាហារឲ្យគេបរិភោគឬ?» ជាបឋម

សូមកត់ចំណាំពីរបៀបដែលគេបានបំលែងបញ្ហារបស់ពួកគេជាមួយនឹងកង្វះការផ្គត់ផ្គង់ ទៅជាប្រព័ន្ធបណ្ដាសាផែនដីនៃសេដ្ឋកិច្ច ភាពវេទនា និងការបង្ខូរញើស បើនិយាយឲ្យចំគឺជាប្រាក់ខែក្នុងពេល ៨ ខែ។

មានថ្ងៃមួយខ្ញុំកំពុងតែអធិស្ឋាន ហើយព្រះជាម្ចាស់បានប្រាប់ខ្ញុំថា ខ្ញុំមានផ្នត់គំនិតបែបសាច់ឈាម។ ខ្ញុំច្របូកច្របល់ជាខ្លាំងថា តើនោះមានន័យថាម៉េច? តើខ្ញុំមានបញ្ហាជាមួយនឹងចិត្តស្រើបស្រាលឬ? អត់ទេ ទ្រង់កំពុងតែចង់សំដៅលើការគិតនិងរបៀបដែលខ្ញុំត្រូវបានកំណត់ដោយសារប្រព័ន្ធបណ្ដាសាផែនដីនៃការគិតកំពុងតែសម្រាំងនូវអនាគតរបស់ខ្ញុំតាមរយៈផ្នត់គំនិតដែលថា តើខ្ញុំអាចរត់លឿនបានប៉ុណ្ណា។ យើងទាំងអស់គ្នាសុទ្ធតែធ្វើបែបនេះ។ ប្រសិនបើយើងត្រូវការផ្ទះថ្មីមួយខ្នងនោះយើងនឹងស៊ើបសួរថាតើវាថ្លៃប៉ុន្មាន ហើយក៏គណនាភ្លាមថា តើយើងមានលទ្ធភាពទិញវាដែរឬទេ។ តើយើងគណនាវាដោយរបៀបណា? តាមរយៈការយល់ដឹងបែបបណ្ដាសានៃផែនដី ជាការគិតថាតើយើងអាចរត់លឿន (ឬរកប្រាក់បានលឿន) បានប៉ុណ្ណា។ ខ្ញុំគិតមើលសិន។ ខ្ញុំរកប្រាក់បាន៤០០ដុល្លារក្នុងមួយខែ... «អូហ៎ ខ្ញុំមិនមានលទ្ធភាពគ្រប់គ្រាន់អាចទិញផ្ទះនោះបានទេ។» ដូច្នេះ លោកអ្នកក៏គិតថាវាមិនអាចទៅរួច។ ប្រសិនបើយើងគិតអំពីអ្វីៗទាំងអស់ ដោយផ្ដោតថាតើយើងអាចរត់លឿនបានប៉ុណ្ណា នោះយើងនឹងមិនអាចចូលទៅកាន់របៀបរស់នៅបែបព្រះរាជ្យរបស់ព្រះជាម្ចាស់បានទេ ដោយសារតែព្រះជាម្ចាស់មិនផ្សារភ្ជាប់ទៅនឹងរបៀបបែបនោះឡើយ។ ព្រះជាម្ចាស់បានប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំចង់ផ្សារភ្ជាប់ទៅកាន់ព្រះរាជ្យ ខ្ញុំនឹងត្រូវចាប់ផ្ដើមគិតតាមគំនិតបែបព្រះរាជ្យ គឺអ្វីៗទាំងអស់សុទ្ធតែអាចកើតឡើងបាន!

នេះជាផ្នត់គំនិតរបស់ពួកសិស្ស នៅពេលដែលគេពោលថា «គេនឹងត្រូវចំណាយអស់ប្រាក់ស្មើនឹងប្រាក់ខែ ៨ ខែ។» និយាយរួម ពួកគេចង់មានន័យថា វាមិនអាចទៅរួចទេក្នុងការផ្គត់ផ្គង់អាហារដល់មនុស្សច្រើនបែបនោះ។

សូមអនុញ្ញាតឲ្យខ្ញុំពន្យល់ថា តើព្រះបន្ទូលរបស់ព្រះយេស៊ូថា «ចូរអ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ» មានន័យយ៉ាងណាសម្រាប់ពួកគេ។ ឧបមាថាខ្ញុំជាគ្រូគង្វាលរបស់លោកអ្នក ហើយលោកអ្នកជួបទុក្ខលំបាកខ្លះៗ រហូតដល់ធ្វើឲ្យលោកអ្នកបង់ថ្លៃកម្ចីទិញផ្ទះមិនបានទាន់ពេល។ លោកអ្នកខានបង់ថ្លៃផ្ទះបីខែមកហើយ ព្រមទាំងអាចនឹងបាត់បង់ផ្ទះផង។ ដូច្នេះ លោកអ្នកក៏មកជួបខ្ញុំហើយសួរថា តើក្រុមជំនុំអាចជួយប្រាក់ដល់លោកអ្នកដើម្បីបង់ថ្លៃផ្ទះទាន់ពេលដែរឬទេ។ ខ្ញុំក៏ពោលទៅកាន់លោកអ្នកយ៉ាងសុភាពថា «ខ្ញុំមានយោបល់មួយដែលប្រសើរជាង។ តើហេតុអ្វីបានជាអ្នកមិនបង់ផ្ដាច់តែម្ដងទៅ ដើម្បីកុំឲ្យជំពាក់គេ ហើយត្រូវសងគេរាល់ខែទៀត?» លោកអ្នកក៏មើលមុខខ្ញុំ ទាំងគិតថា «លោកគ្រូប្រាកដជាមិនយល់ពីអ្វីដែលខ្ញុំនិយាយទេ។» «អត់ទេ លោកគ្រូ ខ្ញុំគិតថាលោកគ្រូស្ដាប់ច្រឡំហើយ។ យើងមិនមានលុយទាល់តែសោះ ហេតុនេះហើយបានជាយើងមកសុំលោកគ្រូឲ្យជួយ។ យើងគ្រាន់តែត្រូវការឲ្យក្រុមជំនុំជួយយើងមួយគ្រានេះ ដើម្បីឲ្យយើងអាចសងថ្លៃផ្ទះទាន់ខែ។» នៅលើកនេះទៀត ខ្ញុំមើលមុខលោកអ្នកទាំងទឹកមុខស្មើ ហើយពោលថា «អត់ទេ ខ្ញុំយល់ពីអ្វីដែលអ្នកនិយាយ ហើយខ្ញុំផ្ដល់ដំណោះស្រាយដ៏ល្អដល់អ្នក។ អ្នកគួរតែបង់ផ្ដាច់ថ្លៃផ្ទះ នោះអ្នកនឹងមិនជំពាក់ប្រាក់គេទៀតទេ។» លោកអ្នកប្រាកដជាគិតថា ខ្ញុំបាត់សតិជាមិនខាន។

មែនហើយ ពួកសិស្សប្រាកដជាមិនអារម្មណ៍បែបនេះមិនខាន។ «ព្រះយេស៊ូទ្រង់និយាយលេងមែនទេ ដែលថាយើងនឹងចែកអាហារដល់មនុស្សជាង ២០០០០ នាក់នេះ? ការនេះមិនអាចទៅរួចទេ។ យើងមិនមានធនធានច្រើនគ្រប់គ្រាន់ដើម្បីធ្វើបែបនេះទេ។ ហើយប្រសិនបើយើងរៀបផែនការទៅធ្វើការឲ្យអស់ពីលទ្ធភាព ដើម្បីឲ្យបានប្រាក់ប៉ុននោះ ដោយរៀបចំរទេះ និងគណៈកម្មការដើម្បីទៅធ្វើការ រកប្រាក់ទិញអាហារ នៅពេលដែលយើងបានអាហារគ្រប់គ្រាន់ ហើយត្រលប់មកវិញនោះ គ្រប់ៗគ្នាប្រាកដជាដាច់ពោះស្លាប់មិនខាន។ ទោះបីយើងមានប្រាក់គ្រប់គ្រាន់ក្ដី ក៏យើងគ្មានពេលដើម្បីធ្វើបែបនេះដែរ។» នេះជារបៀបដែលយើងឆ្លើយតបទៅកាន់

រឿងពិបាកៗនៅលើភពធម្មជាតិ នៅពេលដែលយើងមើលមិនឃើញផ្លូវដើម្បីឲ្យការនោះកើតឡើង។ នៅពេលដែលយើងមិនមានការផ្គត់ផ្គង់ និមិត្តរបស់យើងនឹងស្លាប់។

ព្រះយេស៊ូមិនបានទុកពួកសិស្សឲ្យជាប់ក្នុងផ្នត់គំនិតបែបនោះ ទាំងគ្មានចម្លើយទេ។ ហើយទ្រង់ក៏នឹងមិនប្រាប់ពួកគេឲ្យចែកអាហារដល់បណ្ដាជនដែរ ប្រសិនបើទ្រង់មិនបានដឹងពីរបៀបដើម្បីធ្វើកិច្ចការនេះទេនោះ។ តាមពិត ទ្រង់ហៀបនឹងបង្ហាញពួកគេនូវប្រព័ន្ធមួយទៀត គឺប្រព័ន្ធដំណើរការនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ នៅពេលនេះ ដែលពួកសិស្សកំពុងតែមានអារម្មណ៍ច្របូកច្របល់ ព្រះយេស៊ូមានបន្ទូលម្ដង។

ព្រះយេស៊ូមានបន្ទូលថា «ទៅមើលមើល៍ អ្នករាល់គ្នាមាននំបុ័ងប៉ុន្មានដុំ?»។ ពួកសិស្សក៏ត្រលប់មកវិញ ទាំងពោលថា «យើងខ្ញុំមាននំបុ័ងប្រាំដុំ និងត្រីងៀតពីរកន្ទុយ»។ នៅពេលដែលពួកគេឃើញនំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយនោះហើយ ព្រះយេស៊ូក៏បានប្រាប់ឲ្យពួកសិស្សយកមកឲ្យទ្រង់។ ទ្រង់បានយកនំបុ័ងនិងត្រីមក ហើយប្រទានពរដល់វា បន្ទាប់មកក៏ចែកទៅដល់ពួកគេវិញតែម្ដង។ ចំពោះភ្នែកជាមនុស្សធម្មជាតិ ពុំមានអ្វីបានផ្លាស់ប្ដូរឡើយ ប៉ុន្តែនៅក្នុងភពខាងវិញ្ញាណ មានអ្វីម្យ៉ាងសំខាន់បានកើតឡើត ដែលវាជាគន្លឹះដើម្បីឲ្យយើងយល់អំពីព្រះរាជ្យ។ ព្រះយេស៊ូបានបង្គាប់ដល់ពួកសិស្សឲ្យចែកនំបុ័ងនិងត្រី ហើយពួកគេបានមើលឃើញទាំងចិត្តស្ញប់ស្ញែងនៅពេលដែលអាហារពហុគុណនៅចំពោះមុខពួកគេ ហើយផ្គត់ផ្គង់ដល់មនុស្សជាង ២០០០០នាក់ ថែមទាំងនៅសល់ទៀតផង។ តើមានអ្វីកើតឡើង? តើវាបានកើតឡើងដោយរបៀបណា?

ដើម្បីឲ្យបានដឹង យើងចាំបាច់ត្រូវងាកមើលទៅក្រោយបន្តិច ហើយពិនិត្យលើរឿងលម្អិតនៃហេតុការណ៍នេះដោយយកចិត្តទុកដាក់។ ពាក្យថា «ប្រទានពរ» នៅត្រង់នេះមានន័យចំថាញែកចេញ ឬញែកដាច់ដោយឡែក។ ដូច្នេះ យើងអាចនិយាយថា នៅពេលដែលព្រះយេស៊ូមានបន្ទូលទៅលើអាហារ ហើយប្រទានពរវា

នំប៉ុង និងត្រីត្រូវបានញែកចេញពីរាជ្យមួយ ហើយចូលទៅកាន់រាជ្យមួយផ្សេង។ នៅលើភពផែនដី ការផ្គត់ផ្គង់អាហារដល់មនុស្សជាង ២០០០០ នាក់ដោយនំប៉ុង ៥ ដុំ និងត្រីពីរកន្ទុយគឺមិនអាចទៅរួចទៀយ។ ប៉ុន្តែ នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ អ្វីៗសុទ្ធតែអាចកើតឡើងបាន។ តាមពិត សាច់រឿងនេះមិនទាន់ចប់ត្រឹមហ្នឹងទេ។ មុនពេលដែលរឿងនេះបញ្ចប់ទៅ ពួកសិស្សបានប្រមូលនំប៉ុងដែលនៅសល់ចំនួន ១២ល្អី។ នំប៉ុង៥ដុំ និងត្រី២កន្ទុយបានប្រែពីការដែលមិនមានគ្រប់គ្រាន់ ទៅជាការចម្អែតមនុស្សជាង ២០០០០ នាក់ ហើយក៏នៅសល់លើសពីចំនួនដំបូងដែរ? នោះឯងជារបៀបបែបព្រះរាជ្យ គឺមានលើសពីគ្រប់គ្រាន់!

ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ នៅពេលដែលខ្ញុំពិនិត្យមើលសាច់រឿងខាងលើយ៉ាងយកចិត្តទុកដាក់ ខ្ញុំបានឃើញរូបមន្តដដែល ដែលព្រះជាម្ចាស់បានប្រទានមកខ្ញុំជាមួយនឹងសត្វក្ដាន់។ តាមរយៈការប្រមាញ់ក្ដាន់ ព្រះជាម្ចាស់បានបង្រៀនខ្ញុំឲ្យសាបព្រោះទៅក្នុងព្រះរាជ្យរបស់ព្រះអង្គនូវចំណែកនៃអ្វីៗដែលខ្ញុំត្រូវការនោះជាមុនសិន។ នេះជាអ្វីដែលក្មេងប្រុសនោះបានធ្វើជាមួយនឹងនំប៉ុង និងត្រីដែលគាត់មាន។ គាត់បានដាក់វាក្រោមសិទ្ធិអំណាចនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយវាក៏ពហុគុណឡើង ដោយអាចផ្គត់ផ្គង់ដល់មនុស្សជាង ២០០០០ នាក់ហើយមាននៅសល់១២ល្អីផង។ សូមកត់ចំណាំថានំប៉ុងបានពហុគុណទៅជានំប៉ុង ហើយត្រីបានពហុគុណទៅជាត្រី។ នេះជារបៀបដែលព្រះរាជ្យដំណើរការ។ ខ្ញុំអាចសាបព្រោះត្រីទៅក្នុងព្រះរាជ្យ ហើយវាអាចពហុគុណទៅជាត្រីវិញ។ ប៉ុន្តែចុះប្រសិនបើខ្ញុំត្រូវការត្រី ប៉ុន្តែគ្មានត្រីដើម្បីសាបព្រោះ? ចម្លើយគឺ លុយ! សូមចាំថាលុយជាប្រព័ន្ធដោះដូរ។ លោកអ្នកនិងខ្ញុំ «ដាក់ឈ្មោះ» លុយជារៀងរាល់ថ្ងៃ។ យើងដាក់ឈ្មោះវាថាទឹកដោះគោ ផ្ទះ សម្លៀកបំពាក់ បាយ

**ព្រះជាម្ចាស់បានបង្រៀនខ្ញុំឲ្យសាបព្រោះជាមុនសិន ទៅក្នុងព្រះរាជ្យរបស់ព្រះអង្គនូវចំណែកនៃអ្វីៗដែលខ្ញុំត្រូវការ។**

និងអ្វីៗផ្សេងទៀតដែលយើងត្រូវការរាល់ថ្ងៃ។ លុយបានក្លាយជាអ្វីៗដែលយើងត្រូវការ។ ដូច្នេះនៅពេលដែលយើងសាបព្រោះ យើងអាចដាក់ឈ្មោះលុយបាន។ ជំនួសឲ្យការទៅផ្សារទិញត្រីយកមកសាបព្រោះ យើងអាចគ្រាន់តែដាក់ឈ្មោះលុយនោះ។ ការនេះអាចកើតឡើងជាមួយនឹងការថ្វាយតង្វាយរបស់លោកអ្នក ប៉ុន្តែគឺមិនមែនតង្វាយមួយភាគដប់ទេ ព្រោះព្រះជាម្ចាស់បានប្រទានឈ្មោះដល់តង្វាយមួយភាគដប់ហើយ។ យើងអាចឃើញច្បាប់ដដែលនេះនៅក្នុងកិច្ចការពហុគុណនៅលូកា ជំពូក ៥។

*ថ្ងៃមួយ ព្រះយេស៊ូគង់នៅមាត់បឹងគេនេសារ៉ែត មានបណ្ដាជនជាច្រើនប្រជ្រៀតគ្នានៅជុំវិញព្រះអង្គ ដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះអង្គទតឃើញទូកពីរចតនៅមាត់ច្រាំង រីឯអ្នកនេសាទនាំគ្នាចុះទៅលាងអួនរបស់គេ។ ព្រះយេស៊ូយាងចុះទៅក្នុងទូករបស់លោកស៊ីម៉ូន រួចទ្រង់សុំឲ្យគាត់ចេញទូក ទៅឆ្ងាយពីច្រាំងបន្តិច។ ព្រះអង្គគង់បង្រៀនបណ្ដាជនពីក្នុងទូកនោះ។ លុះព្រះអង្គបង្រៀនគេចប់ហើយ ទ្រង់មានព្រះបន្ទូលទៅកាន់លោកស៊ីម៉ូនថា៖ «ចូរបង្ហួសទូកទៅទឹកជ្រៅ រួចនាំគ្នាទម្លាក់អួនចុះ»។*

*លោកស៊ីម៉ូនតបទៅព្រះយេស៊ូវិញថា៖ «លោកគ្រូ! យើងខ្ញុំបានអូសអួនពេញមួយយប់ហើយ អត់បានត្រីសោះ ប៉ុន្តែ បើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ»។ គេក៏ទម្លាក់អួនទៅក្នុងទឹក ជាប់ត្រីយ៉ាងច្រើនស្ទើរតែធ្លាយអួន។ គេបក់ដៃហៅមិត្តភក្ដិដែលនៅក្នុងទូកមួយទៀតឲ្យមកជួយ។ ពួកនោះមកដល់ ជួយចាប់ត្រីដាក់ពេញទូកទាំងពីរ ស្ទើរតែនឹងលិច។*

លូកា ៥៖១-៧ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

ក្នុងនាមជាអ្នកវិទ្យាសាស្ត្រខាងវិញ្ញាណ ចូរយើងពិនិត្យមើលឲ្យកាន់តែលម្អិតអំពីសាច់រឿងនេះ។ តើត្រីទាំងនោះបង្ហាញខ្លួនឡើងដោយរបៀបណា? តើលោកអ្នកយល់ដែរឬទេ? ព្រះយេស៊ូកំពុងតែយាងដើរតាមមាត់បឹង ហើយក៏ឃើញទូកមួយដែលទ្រង់ចង់ប្រើដើម្បីគង់ក្នុងទូកនោះ ហើយប្រកាសព្រះបន្ទូលដល់បណ្តាជន។ ទ្រង់បានសុំលោកពេត្រុសដែលជាម្ចាស់ទូកថាតើទ្រង់អាចប្រើទូកនោះបានដែរឬទេ ហើយលោកពេត្រុសក៏តបថា «ប្រាកដជាបាន»។ សំខាន់ជាងនេះទៅទៀត ពួកគេលែងប្រើទូកនោះហើយ ព្រោះថាពួកគេបាននេសាទពេញមួយយប់ ហើយមិនបានត្រីមួយក្បាលសោះ។ បន្ទាប់ពីព្រះយេស៊ូបានប្រើទូក ទ្រង់បានប្រាប់លោកពេត្រុសឲ្យត្រលប់ទៅវិញ ហើយនេសាទនៅឯទឹកជ្រៅដើម្បីឲ្យបានត្រី។ ខ្ញុំប្រាកដថា សំណើនេះបានធ្វើឲ្យលោកពេត្រុសភ្ញាក់ផ្អើល ព្រោះគាត់បានតបថា «លោកគ្រូ! យើងខ្ញុំបានអូសអួនពេញមួយយប់ហើយ អត់បានត្រីសោះ»។ លោកពេត្រុសជាអ្នកនេសាទអាជីព ហើយគាត់ស្គាល់ច្បាស់ពីរបៀបនេសាទ។ ដោយផ្អែកលើបទពិសោធន៍របស់គាត់ គឺមិនមានត្រីនៅទីនោះទេ។ បើគិតតាមបែបធម្មជាតិ ការដែលចុះទូកទៅកន្លែងចាស់នោះមិនសមហេតុផលទាល់តែសោះ។ ពួកគេបានទុកដាក់ឧបករណ៍ និងលាងអួនរបស់ខ្លួន។

ខ្ញុំមិនជឿថាលោកពេត្រុសបានធ្វើវានោះទេ លើកលែងតែគាត់ប្រហែលជាទើបតែបានឮនូវមេរៀនដែលព្រះយេស៊ូបានបង្រៀនជាងមួយម៉ោងមុននេះ ដែលបានប៉ះពាល់គាត់នៅក្នុងរបៀបមួយដែលមិនធ្លាប់មាន។ ដូច្នេះ គាត់ក៏ថា «ប៉ុន្តែ បើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ»។ លោកពេត្រុសក៏ចុះទូកទៅវិញ ហើយចាប់បានត្រីជាច្រើនរហូតដល់សឹងតែធ្លាយអួន ហើយទូករបស់គាត់ក៏ហៀបនឹងលិចផង។ គាត់បានស្រែកហៅទៅកាន់ដៃគូរបស់គាត់ដែលកំពុងនៅមាត់ច្រាំងឲ្យជួយ។ ពួកគេក៏បានចុះទូកមក អួនរបស់ពួកគេក៏ហៀបនឹងធ្លាយ ហើយទូករបស់គេក៏សឹងតែលិចដែរ។ ព្រះគម្ពីរកត់ត្រានូវប្រតិកម្មរបស់លោកពេត្រុសថាគាត់ភ័យស្លប់ស្លែងជាខ្លាំង!

តើការនេះកើតឡើងដោយរបៀបណា? មានតម្រុយណាមួយឲ្យយើងដឹងដែរឬទេ? និយាយដោយសង្ខេប នេះជាឫទ្ធានុភាពនៃគោលការណ៍ភក្ដីភាពដែលយើងបាននិយាយនៅខាងដើម។ នៅពេលដែលលោកពេត្រុសអនុញ្ញាតឲ្យព្រះយេស៊ូប្រើទូកនេសាទ ទូក និងការរកស៊ីនោះបានផ្លាស់ប្ដូររាជ្យនានា។ អាជីវកម្មនោះបានកើតចេញពីដែនសមត្ថកិច្ចនៃប្រព័ន្ធបណ្ដាសាបស់ផែនដី ហើយបានចូលមកក្រោមដែនសមត្ថកិច្ចនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ ដោយការដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ព្រះអង្គមានសិទ្ធិស្របច្បាប់ដើម្បីទាញយកនូវពាក្យដែលយល់ដល់គម្រោងការលាក់កំបាំង ហើយប្រទានឲ្យព្រះយេស៊ូបានជ្រាបពីកន្លែងដែលមានត្រី «ចូរបង្អួសទូកទៅទឹកជ្រៅ»។

ដូច្នេះ ចូរយើងពិចារណាពីព្រឹត្តិការណ៍នេះ។ ព្រះយេស៊ូខ្ចីទូកនេសាទពីលោកពេត្រុសដែលទើបតែនេសាទពេញមួយយប់ ហើយមិនបានត្រីសោះ។ នៅក្នុងការដោះដូរនេះ ទូកទាំងនោះបានមកក្រោមដែនសមត្ថកិច្ចនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ នៅពេលនេះ ព្រះយេស៊ូមានចំណេះដឹងពីទីតាំងជាក់លាក់ដែលមានត្រីច្រើន តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។ បន្ទាប់មក ព្រះយេស៊ូក៏តម្រង់ទិសទូករបស់លោកពេត្រុសទៅកាន់កន្លែងជាក់លាក់នោះ។ ក្រោយមក ទូករបស់លោកពេត្រុសមានត្រីពេញស្ទើរតែលិច។ ទូករបស់គូកនគាត់ក៏មានត្រីពេញដែរ។ ដូច្នេះ តើពួកគេចាប់បានត្រីដោយរបៀបណា? បើនិយាយឲ្យសាមញ្ញ គឺតាមរយៈពាក្យបង្គាប់ដោយផ្ទាល់ពីស្ថានសួគ៌។ ចូរទទួលស្គាល់ពីការនេះ អ្នកណាក៏អាចនេសាទត្រីបានដែរ ឲ្យតែគេដឹងថាត្រីនោះនៅកន្លែងណា។ សូមគិតពីអ្វីដែលយើងទើបបាននិយាយ។ ព្រះជាម្ចាស់ជ្រាបសព្វគ្រប់ទាំងអស់ ទ្រង់អាចជួយលោកអ្នក និងប្រាប់លោកអ្នកពីអ្វីដែលត្រូវធ្វើបាន។

នៅពេលដែលខ្រិនដានិងខ្ញុំដាច់ថ្លៃ ហើយបានចាប់ផ្ដើមរៀនពីព្រះរាជ្យ ព្រះជាម្ចាស់បានប្រទានក្ដីសុបិនមួយដល់ខ្ញុំនៅពេលយប់ ដើម្បីចាប់ផ្ដើមអាជីវកម្មដែលខ្ញុំមិនដឹងថាចាប់ផ្ដើមដោយរបៀបណាឡើយ។ រយៈពេល ២៨ ឆ្នាំកន្លងមកនេះ អាជីវ

កម្មនេះនៅតែដំណើរការ ដោយរកចំណូលបានរាប់សែនដុល្លារក្នុងមួយឆ្នាំ។ នៅក្នុងពេលជាង២៨ឆ្នាំនេះ វាបានអនុញ្ញាតឲ្យខ្ញុំសាបព្រោះប្រាក់រាប់លានដុល្លារចូលទៅកាន់ព័ន្ធកិច្ច និងការជួយមនុស្ស។ តើដោយរបៀបណាទៅ? ខ្ញុំបានស្តាប់ឮពីស្ថានសួគ៌ ហើយលោកអ្នកក៏អាចស្តាប់ឮបានដែរ! សូមអនុញ្ញាតឲ្យខ្ញុំប្រាប់ឧទាហរណ៍មួយ។

ជាងពីរបីឆ្នាំមុន ខ្ញុំកំពុងតែបង្រៀននៅក្នុងសន្និបាតមួយដែលមានរយៈពេល៥យប់ជាប់ៗគ្នា ស្តីអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ បន្ទាប់ពីចប់យប់ទីពីរ មានបុរសម្នាក់ឈ្មោះថាគ្រីសបានចូលមកកាន់ខ្ញុំ ហើយសុំខ្ញុំឲ្យអធិស្ឋានឲ្យគាត់។ ខ្ញុំបានសួរគាត់ថា តើគាត់ត្រូវការឲ្យខ្ញុំអធិស្ឋានអំពីអ្វី។ គាត់ក៏បានប្រាប់ខ្ញុំពីសាច់រឿងរបស់គាត់។ គាត់បានដាក់ទុនរកស៊ីជាមួយនឹងបុរសម្នាក់ដែលបានបន្លំលួចប្រាក់ពីក្រុមហ៊ុននោះ ធ្វើឲ្យក្រុមហ៊ុននោះធ្លាក់ចុះ។ ពេលនោះ គាត់ក៏ស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍ទីបួន ហើយជីវិតអាពាហ៍ពិពាហ៍ក៏មិនល្អកល្អិនសោះ។ មួយវិញទៀត គាត់មានអាយុ៤០ឆ្នាំប៉ុណ្ណោះ។ គាត់បានប្រាប់ខ្ញុំថា គាត់ធ្លាក់ទឹកចិត្តជាខ្លាំងរហូតដល់គាត់យកកាំភ្លើងខ្លីមួយដើមដែលមានគ្រាប់ពេញបង់ ហើយបើកឡានមួយស្របក់ រួចទៅឈប់នៅកន្លែងស្ថានីយ៍ប្រេងឥន្ធនៈមួយដែលគេបោះបង់ចោលដើម្បីសម្លាប់ខ្លួន។

នៅពេលនោះ គឺម៉ោង៣ព្រឹកព្រលឹម ហើយនៅពេលដែលគាត់អង្គុយនៅស្ថានីយ៍នោះទាំងកាន់កាំភ្លើងខ្លី ទូរស័ព្ទក៏បានរោទ៍ឡើង។ គាត់បានស្គាល់លេខទូរស័ព្ទនោះភ្លាម ដែលគឺជាដៃគូរកស៊ីចាស់របស់គាត់។ ជាការប្រាកដណាស់ គាត់មិនចង់និយាយជាមួយបុរសនោះទេ ដូច្នេះគាត់ក៏មិនបានលើកទូរស័ព្ទឡើយ។ វាក៏រោទ៍ឡើងម្តងហើយ ម្តងទៀត។ តាមពិតវារោទ៍ឡើង ១១ ដងរហូតដល់លោកគ្រីសបានសម្រេចចិត្តលើកទូរស័ព្ទ។ ពាក្យដំបូងដែលដៃគូរកស៊ីចាស់របស់គាត់បាននិយាយគឺ «តើលោកនៅកន្លែងណា? ហើយកំពុងធ្វើអ្វី?» នៅពេលដែលលោកគ្រីសប្រាប់គាត់ បុរសនោះក៏ពោលថា «កុំទៅណាឲ្យសោះ ខ្ញុំទៅទីនោះនៅពេលនេះ

ហើយ!» តាមពិត ដៃគូចាស់របស់គាត់ទើបតែបានថ្វាយជីវិតទៅកាន់ព្រះជាម្ចាស់ ហើយចង់ចែករំលែកពីការនេះជាមួយលោកគ្រីស។ អស្ចារ្យណាស់ គាត់មានអារម្មណ៍ថាចង់ទៅជួបលោកគ្រីសនៅម៉ោង ៣ ព្រឹកជាបន្ទាន់ ហើយនៅពេលដែលលោកគ្រីសមិនលើកទូរស័ព្ទ គាត់នៅតែព្យាយាមទូរស័ព្ទមកម្តងហើយម្តងទៀត។

នៅពេលដែលដៃគូរបស់លោកគ្រីសបង្ហាញខ្លួន គាត់បាននាំលោកគ្រីសឲ្យថ្វាយជីវិតទៅកាន់ព្រះអម្ចាស់ ហើយជីវិតរបស់លោកគ្រីសបានផ្លាស់ប្តូរគួរឲ្យកត់សម្គាល់។ អ្វីៗក៏បានប្រសើរឡើង។ គាត់បានរកឃើញក្រុមជំនុំដ៏ល្អមួយ អាពាហ៍ពិពាហ៍របស់គាត់ក៏បានប្រសើរឡើង។ អ្វីៗបានប្រសើរឡើង លើកលែងតែប្រាក់ចំណូលរបស់គាត់មួយ។ លោកគ្រីសមិនមានការងារធ្វើ ហើយនេះហើយជាតម្រូវការដែលគាត់សុំខ្ញុំឲ្យអធិស្ឋានឲ្យ។ នៅក្នុងសន្និបាតនោះ ខ្ញុំបានបង្រៀនដូចជាអ្វីដែលខ្ញុំបានប្រាប់លោកអ្នកនៅក្នុងសៀវភៅនេះអញ្ចឹង គឺរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់អាចធ្វើការអស្ចារ្យជាច្រើនលើសពីសមត្ថភាពរបស់យើង។

នៅពេលដែលលោកគ្រីសបានគិតពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធអាចដឹកនាំយើង និងជួយប្រទានទិសដៅ និងយោបល់នានា គាត់ក៏ស្រាប់តែមានគំនិតមួយភ្លាម។ បើគិតខាងផ្នែកហិរញ្ញវត្ថុ គាត់មិនសូវជាមានជម្រើសច្រើនទេ។ ប៉ុន្តែ គាត់ចេះធ្វើនំឈីសខេកបានឆ្ងាញ់។ ជំនាញរបស់គាត់គឺធ្វើនំឈីសខេកសុខភាព ដែលគាត់ដឹងថាជាអ្វីដែលគាត់ពូកែបំផុត។ តាមពិត នៅក្នុងចំណោមមិត្តភក្តិរបស់គ្រីសសុទ្ធតែដឹងថា គាត់ជាមនុស្សដែលពូកែធ្វើនំឈីសខេកបំផុត។ គាត់បានទៅហាងលក់អាហារសុខភាពនៅក្នុងតំបន់ជាច្រើនលើក ហើយក៏បានភ្លក់នំដែលគេធ្វើដែរ ប៉ុន្តែសុទ្ធតែមិនសូវឆ្ងាញ់។ លោកគ្រីសមិនសូវមានជម្រើសច្រើនទេ ប៉ុន្តែគាត់មានអារម្មណ៍ថានេះជាជម្រើសដែលគាត់មាន គឺការលក់នំឈីសខេក។ គាត់ប្រាកដថា ប្រសិនបើគាត់យកនំឈីសខេកដែលគាត់ធ្វើទៅលក់នៅក្នុងហាងអាហារសុខភាពនោះ ហើយពួកគេភ្លក់វា នោះពួកគេប្រាកដជាចង់លក់នំនោះមិនខាន។ គាត់ក៏ប្រាកដទៀតថានំនោះនឹងលក់ដាច់ជាងនំរបស់ពួកគេ។ ដូច្នេះ នេះជាអ្វីដែលគាត់

បានធ្វើ។ គាត់បានធ្វើនំឈើសខេក ហើយក៏យកទៅហាងលក់អាហារសុខភាពទាំង មិនបានប្រាប់គេជាមុន។ ពេលនោះជាពេលដ៏ពិសេស គឺនាយកប្រតិបត្តិប្រចាំក្រុមហ៊ុនដែលបើកហាងអាហារសុខភាពនោះកំពុងតែចុះមើលសាខារបស់ពួកគេ នៅពេលដែលលោកគ្រីសទៅដល់។ នាយកប្រតិបត្តិក៏បានយល់ព្រមថានឹងភ្លក់នំឈើសខេក ហើយនឹងប្រាប់ដល់គាត់ឲ្យបានដឹងវិញ។

នៅយប់នោះ លោកគ្រីសបានឡើងមកខាងមុខម្តងទៀតបន្ទាប់ពីចប់ការប្រជុំ ហើយក៏និយាយជាមួយខ្ញុំ។ គាត់បានប្រាប់ខ្ញុំពីអ្វីដែលគាត់បានធ្វើ ហើយសុំឲ្យខ្ញុំអធិស្ឋានឲ្យគាត់ម្តងទៀតថាគាត់នឹងជាប់កិច្ចសន្យាជាមួយនឹងហាងអាហារសុខភាពនោះ។ មែនហើយ នៅថ្ងៃបន្ទាប់ លោកគ្រីសក៏ទៅទីនោះម្តងទៀត ហើយគាត់ពិតជារំភើបណាស់! គាត់បានប្រាប់ខ្ញុំថា នាយកប្រតិបត្តិចង់ឲ្យគាត់មិនគ្រាន់តែដុតនំឈើសខេកសម្រាប់ហាងតែមួយទេ ប៉ុន្តែក៏សម្រាប់ហាងទាំងអស់នៅក្រោមក្រុមហ៊ុនទាំងមូល។ គាត់ក៏បានសួរលោកគ្រីសថាតើគាត់ចេះដុតនំអ្វីខ្លះទៀត។ លោកគ្រីសពិតជាភ្ញាក់ផ្អើលណាស់! ជាការអស្ចារ្យ នាយកប្រតិបត្តិបានមកចូលរួមនៅយប់ចុងក្រោយនៃសន្និបាត ហើយនៅយប់នោះគាត់បានឡើងមកខាងមុខ ហើយថ្វាយជីវិតទៅកាន់ព្រះអម្ចាស់ ព្រមទាំងបានជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ពីរសប្តាហ៍ក្រោយមក ខ្ញុំបានទទួលសំបុត្រមួយពីគាត់ដែលបានថែងថា គាត់ចង់សាបព្រោះមកកាន់ព្រះរាជ្យរបស់ព្រះជាម្ចាស់វិញ។ បន្ទាប់មក គាត់ក៏បានថ្វាយភាគហ៊ុនរបស់គាត់ ១០% មកកាន់ព័ន្ធកិច្ច Faith Life Now របស់យើង។ ពិតជាមិនគួរឲ្យជឿ! ព្រះជាម្ចាស់អាចយកគំនិតមួយរបស់មនុស្ស ហើយធ្វើអ្វីម្យ៉ាងដែលធំអស្ចារ្យចេញពីចំណុចសូន្យ។

## ជំពូកទី១០

# ចូរប្រមូល កុំខិតខំធ្វើការយ៉ាងវេទនា!

តើលោកអ្នកធ្លាប់ឃើញសត្វសេះនៅពេលរដូវក្តៅ បន្ទាប់ពីរត់ក្នុងចម្ងាយដ៏ឆ្ងាយដែរឬទេ? វាបែកញើសជោក គឺបែកញើសដូចពពុះសាប៊ូអញ្ចឹងនៅលើខ្លួន។ នៅពេលដែលឃើញ លោកអ្នកប្រាកដជាដឹងថាវាទើបតែបានខិតខំរត់មែនទែន។ មានគេសួរខ្ញុំរាល់លើកថា «លោកហ្គារី តើលោកកំពុងមានន័យថា ខ្ញុំមិនចាំបាច់ធ្វើការទេ មែនទេ?» អត់ទេ ខ្ញុំមិនចង់មានន័យបែបនេះទេ ហើយព្រះបន្ទូលក៏មិនថែងអញ្ចឹងដែរ។ ប៉ុន្តែមានភាពខុសគ្នាយ៉ាងខ្លាំងនៅលើរបៀបដែលលោកអ្នកធ្វើការ។ ឧទាហរណ៍ សូមយកសាច់រឿងអំពីលោកពេត្រុស និងសហការីរបស់គាត់ដែលចាប់ត្រីបានពីរទូកពេញរហូតដល់សឹងតែលិចទូកមកពិចារណា។ ពួកគេបានធ្វើការនៅពេញមួយយប់ ដោយព្យាយាមចាប់ត្រី ប៉ុន្តែមិនបានទទួលជោគជ័យសោះ។ បន្ទាប់មក ជាការពិតណាស់ ព្រះយេស៊ូក៏បានយាងមកជួបពួកគេ ហើយបង្ហាញលោកអ្នកទាំងនោះនៅកន្លែងដែលពួកគេត្រូវនេសាទដោយពាក្យដែលយល់គម្រោងការលោកកំបាំង។ នៅត្រង់នោះ ពួកគេក៏បានធ្វើការដែរ ប៉ុន្តែវាជាការងារបែបខុសពីការងារ

មុនទាំងស្រុង។ ពួកគេបានធ្វើការនៅពេលដែលអូសអួនដែលជាប់ត្រីពេញឡើងមកលើទូក។ ប៉ុន្តែ តើពួកគេកំពុងតែនេសាទឬ?

ខ្ញុំដឹងថា ខ្ញុំដូចជាលេងពាក្យបន្តិចនៅត្រង់នេះ។ យើងប្រើពាក្យថា នេសាទនៅលើកិច្ចការជាច្រើន។ នៅក្នុងភាសាអង់គ្លេស យើងអាចប្រើពាក្យថានេសាទ (fishing) នៅពេលដែលស្ត្រីស្វែងរកការសរសើរ។ បុរសម្នាក់អាចលូកហោប៉ៅហើយរាវរកកូនសោ។ ភាសាអង់គ្លេសប្រើពាក្យថា fishing សម្រាប់សំដៅលើការព្យាយាមរកមើលអ្វីម្យ៉ាង។ ដូច្នេះ តើលោកពេត្រុសកំពុងតែព្យាយាមរកអ្វី? នៅពេលដែលខ្ញុំបរបាញ់ ខ្ញុំបានប្រាប់លោកអ្នកហើយថាខ្ញុំបាញ់បានក្តាន់នៅក្នុងពេលជាង ៤០ នាទី។ តើខ្ញុំកំពុងបរបាញ់ឬ? យើងអាចសួរម្យ៉ាងទៀតថា ប្រសិនបើលោកអ្នកដឹងថាត្រីនៅទីណា តើលោកអ្នកនឹងចាំបាច់ត្រូវនេសាទ (ខិតខំស្វែងរក) ទៀតឬ? ប្រសិនបើខ្ញុំដឹងថា ខ្ញុំប្រាកដជាបានក្តាន់ តើនោះជាការបរបាញ់ឬ? ខ្ញុំនិយាយបែបនេះគឺដើម្បីឲ្យលោកអ្នកយល់ពីភាពខុសគ្នាប៉ុណ្ណោះ។ ពិតមែនហើយ ខ្ញុំធ្វើការមែន ប៉ុន្តែខ្ញុំមិនមែនធ្វើការពេញមួយយប់ ហើយមិនបានផលនោះទេ។ និយាយរួមទៅដោយការដែលទទួលបាននូវអ្វីដែលខ្ញុំត្រូវការនៅក្នុងជីវិត នោះខ្ញុំអាចធ្វើការនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយនោះឯងជាកិច្ចការនៃព្រះបិតារបស់ខ្ញុំ និងជាគោលបំណងខ្ញុំ។

## ខ្ញុំហៅការនោះថាជាការប្រមូល!

នៅពេលដែលលោកពេត្រុសមកជួបព្រះយេស៊ូ ដោយសួរទ្រង់ថាត្រូវបង់ពន្ធដោយរបៀបណា នៅក្នុងម៉ាថាយ ១៧៖២៧ ព្រះយេស៊ូមានបន្ទូលថា៖

*ចូរទៅស្ទូចត្រីសមុទ្រ ហើយយកត្រីដែលស្ទូចបានមុនគេ មកបើកមាត់ អ្នកនឹងឃើញកាក់មួយ ចូរយកកាក់នោះទៅបង់ពន្ធឲ្យខ្ញុំ និងឲ្យអ្នកចុះ!*

សូមកត់ចំណាំថាព្រះយេស៊ូមិនបានមានបន្ទូលថា «មែនពេត្រុស យើងត្រូវបង់ពន្ធ។ ខ្ញុំសូមប្រាប់លោកអ្នកបែបនេះថា ចូរចូលទៅក្នុងទីក្រុងប្រហែលជាបីខែទៅ ហើយរកការងារមួយធ្វើ។ ចូរសន្សំប្រាក់ ហើយសឹមត្រលប់មកចូលរួមក្នុងក្រុមយើងវិញបន្ទាប់ពីរកប្រាក់បានបង់ពន្ធសម្រាប់យើងគ្រប់ចំនួនហើយ។» អត់ទេ ព្រះយេស៊ូមិនបានមានបន្ទូលបែបនោះទេ។ ហេតុអ្វីទៅ? ដោយព្រោះថាលោកពេត្រុសនឹងចាំបាច់ត្រូវចាកចេញពីកិច្ចការដែលគាត់ត្រូវធ្វើ ហើយរត់ដេញតាមលុយប្រសិនបើគាត់ងាកទៅរកការគិតបែបប្រព័ន្ធបណ្តាសានៃផែនដីវិញ។ ផ្ទុយទៅវិញ ព្រះយេស៊ូបង្ហាញយើងពីរបៀបដែលព្រះរាជ្យដំណើរការ និងរបៀបដែលយើងគួរបំពេញមុខងារនៅលើភពផែនដីនេះ។ ចម្លើយរបស់លោកពេត្រុសក៏ជាចម្លើយរបស់លោកអ្នកដែរ។ ព្រះយេស៊ូគ្រាន់តែប្រាប់លោកពេត្រុសថាមានការផ្គត់ផ្គង់នៅកន្លែងណាវិធីដែលគាត់ត្រូវការដើម្បីច្រូតកាត់វា និងអ្វីដែលគាត់គួររកមើលជាក់លាក់។ អ្វីដែលលោកពេត្រុសត្រូវធ្វើគឺទៅប្រមូលវាប៉ុណ្ណោះ។

នៅពេលដែលយើងមើលព្រះយេស៊ូជាមួយនឹងពួកសិស្ស ជាទូទៅពួកគេកោតស្ញប់ស្ញែង និងតក់ស្លុតនៅពេលដែលគេបានឃើញព្រះរាជ្យដំណើរការ។ នៅពេលដែលព្រះយេស៊ូបានសម្លាប់ដើមឧទុម្ពរដោយព្រះបន្ទូលរបស់ទ្រង់នៅម៉ាកុស ជំពូក ១១ ព្រះគម្ពីរចែងថាលោកពេត្រុសកោតស្ញប់ស្ញែងជាខ្លាំង។ នៅពេលដែលលោកឡាសារដើរចេញពីផ្នូរ បន្ទាប់ពីបានស្លាប់រយៈពេលបួនថ្ងៃមកហើយ ពួកគេក៏កោតស្ញប់ស្ញែងទៀត។ នៅពេលដែលលោកពេត្រុស លោកយ៉ាកុប និងលោកយ៉ូហានចាប់បានត្រីទាំងប៉ុន្មាន ពួកគេកោតស្ញប់ស្ញែង។ ឌ្រិនដានិងខ្ញុំកោតស្ញប់ស្ញែងជាខ្លាំងរហូតដល់យើងចំហមាត់ទាំងនិយាយថា «តើអូន/បងឃើញទេ?» ជាបន្តបន្ទាប់នៅក្នុងពេលប៉ុន្មានឆ្នាំកន្លងមកនេះ នៅពេលដែលយើងបន្តរៀនកាន់តែច្រើនថែមទៀតអំពីរបៀបដែលព្រះរាជ្យដំណើរការ។ នៅពេលដែលយើងនិយាយអំពីការប្រមូល ជាមួយនឹងជំនួយមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ខ្ញុំចាំបាច់ត្រូវយកលោកអ្នកទៅ

មើលម៉ាថាយ ជំពូក ៦។ ព្រះគម្ពីររបស់ខ្ញុំមានចំណងជើងនៅលើអត្ថបទគម្ពីរនេះថា «ចូរកុំខ្វល់ខ្វាយ» ហើយខ្ញុំពេញចិត្តណាស់។

*«គ្មានអ្នកណាម្នាក់អាចបម្រើម្ចាស់ពីរបានទេ ព្រោះអ្នកនោះនឹងស្អប់មួយ ស្រឡាញ់មួយ ស្មោះត្រង់នឹងម្នាក់ មើលងាយម្នាក់ទៀតជាពុំខាន។ អ្នករាល់គ្នាក៏ពុំអាចគោរពបម្រើព្រះជាម្ចាស់ផង ហើយគោរពបម្រើទ្រព្យសម្បត្តិទុកជាព្រះផងបានឡើយ»។*

*«ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នា កុំឲ្យខ្វល់ខ្វាយអំពីម្ហូបអាហារសម្រាប់ចិញ្ចឹមជីវិត ឬសម្លៀកបំពាក់សម្រាប់បិទបាំងកាយឡើយ។ ជីវិតមានតម្លៃលើសម្ហូបអាហារ ហើយរូបកាយក៏មានតម្លៃលើសសម្លៀកបំពាក់ទៅទៀត។ ចូររំពៃមើលបក្សាបក្សីនៅលើមេឃ វាមិនដែលសាបព្រោះ មិនដែលច្រូតកាត់ មិនដែលប្រមូលស្រូវដាក់ជង្រុកឡើយ ប៉ុន្តែ ព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានបរមសុខ ទ្រង់ចិញ្ចឹមវា។ រីឯអ្នករាល់គ្នា អ្នករាល់គ្នាមានតម្លៃលើសបក្សាបក្សីទាំងនោះទៅទៀត។ ក្នុងចំណោមអ្នករាល់គ្នា ទោះបីខំខ្វល់ខ្វាយយ៉ាងណាក៏ដោយ ក៏គ្មាននរណាអាចនឹងបង្កើនអាយុរបស់ខ្លួនឲ្យវែងបានដែរ សូម្បីតែបន្តិចក៏មិនបានផង។*

*ហេតុដូចម្ដេចបានជាអ្នករាល់គ្នាខ្វល់ខ្វាយអំពីសម្លៀកបំពាក់? ចូរសង្កេតមើលផ្កានៅតាមវាល វាដុះឡើងយ៉ាងណា។ វាមិនដែលធ្វើការនឿយហត់ ឬត្បាញរវៃឡើយ ប៉ុន្តែខ្ញុំសុំប្រាប់អ្នករាល់គ្នាថា សូម្បីតែព្រះបាទសាឡូម៉ូនកាលពីជំនាន់ដែលទ្រង់មានសិរីរុងរឿងដ៏ប្រសើរបំផុតនោះក៏ដោយ ក៏ទ្រង់គ្មានព្រះភូសាល្អស្មើនឹងផ្កាមួយទងនេះផង។ មនុស្សមានជំនឿតិចអើយ! ប្រសិនបើព្រះជាម្ចាស់ផ្ដល់សម្រស់ឲ្យផ្កាដែលរីកនៅតាមវាលថ្ងៃនេះ តែថ្ងៃស្អែកត្រូវគេដុតចោលយ៉ាងហ្នឹងទៅហើយ តើព្រះអង្គនឹងទំនុកបម្រុងអ្នករាល់*

*គ្នាលើសនេះយ៉ាងណាទៅទៀត? ហេតុនេះ កុំខ្វល់ខ្វាយដោយពោលថា "យើងនឹងមានអ្វីបរិភោគ មានអ្វីស្លៀកពាក់" នោះឡើយ ដ្បិតមានតែសាសន៍ដទៃប៉ុណ្ណោះទេ ដែលខំស្វះស្វែងរករបស់ទាំងនោះ។ រីឯព្រះបិតាដែលគង់នៅស្ថានបរមសុខ ទ្រង់ជ្រាបនូវអ្វីៗដែលអ្នករាល់គ្នាត្រូវការ។ ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និងសេចក្ដីសុចរិតរបស់ព្រះអង្គជាមុនសិន ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀត។ កុំខ្វល់ខ្វាយអំពីហេតុការណ៍ដែលនឹងកើតមាននៅថ្ងៃស្អែកឡើយ ចាំស្អែកសឹមគិតពីរឿងថ្ងៃស្អែកទៅ! បើមានការលំបាកកើតឡើងនៅថ្ងៃណា ត្រូវដោះស្រាយសម្រាប់តែថ្ងៃនោះបានហើយ»។*

ម៉ាថាយ ៦៖២៤-៣៤ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

ព្រះយេស៊ូមានបន្ទូលថា លោកអ្នកមិនអាចបម្រើម្ចាស់ពីរបានទេ។ លោកអ្នកប្រហែលជាគិតថាអាច ប៉ុន្តែការពិតគឺមិនអាចទេ។ លោកអ្នកនឹងស្រឡាញ់ម្នាក់ ហើយស្អប់ម្នាក់ទៀតជាពុំខាន។ ខ្ញុំអាចប្រាប់លោកអ្នកថា ម្ចាស់គឺមួយណា។ ម្ចាស់នោះគឺជាអ្នកដែលលោកអ្នកទុកចិត្តថានឹងអាចបំពេញសេចក្តីត្រូវការរបស់លោកអ្នកបាន។ នៅពេលដែលព្រះអម្ចាស់មានបន្ទូលមកកាន់ខ្ញុំនៅក្នុងផ្ទះកសិដ្ឋានចាស់អំពីការដែលខ្ញុំមិនដែលចំណាយពេលរៀនពីរបៀបដែលព្រះរាជ្យរបស់ទ្រង់ប្រតិបត្តិការ ទ្រង់កំពុងមានបន្ទូលថាខ្ញុំមិនបានដាក់ទ្រង់ជាម្ចាស់របស់ខ្ញុំទេ។ ទ្រង់មិនមែនជាព្រះតែមួយដែលខ្ញុំផ្ញើទំនុកចិត្តរបស់ខ្ញុំទាំងស្រុង ហើយខ្ញុំក៏មិនមែនបម្រើ និងទុកចិត្តលើទ្រង់ដែរ។ ជាការពិតណាស់ ខ្ញុំទៅក្រុមជំនុំជាទៀងទាត់ ខ្ញុំមានចិត្តសប្បុរស ស្រឡាញ់ព្រះជាម្ចាស់ និងខ្ញុំដឹងថាខ្ញុំនឹងទៅស្ថានសួគ៌។ ប៉ុន្តែ ខ្ញុំមិនដែលធ្លាប់ចំណាយពេលរៀនពីប្រព័ន្ធហិរញ្ញវត្ថុរបស់ព្រះ និងរបៀបដែលព្រះរាជ្យរបស់ទ្រង់ដំណើរការឡើយ។

*ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នានៅកន្លែងណា ចិត្តរបស់អ្នករាល់គ្នាក៏នៅកន្លែងនោះដែរ។*

លូកា ១២៖៣៤ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

សូមអានយឺតៗ *«ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នានៅកន្លែងណា ចិត្តរបស់អ្នករាល់គ្នាក៏នៅកន្លែងនោះដែរ»* ។ មានមនុស្សជាច្រើនចូលចិត្តបង្វែរឃ្លានោះ ហើយថា «ចិត្តរបស់អ្នករាល់គ្នានៅកន្លែងណា ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នាក៏នៅកន្លែងនោះដែរ។» ប៉ុន្តែ នោះមិនមែនជាអត្ថន័យរបស់ខនោះឡើយ ហើយវាក៏មិនមែនជារបៀបដែលវាមានប្រសិទ្ធិភាពដែរ។ មនុស្សជាច្រើនគិតថា ខនោះចង់មានន័យថា ពួកគេអាចស្រឡាញ់ព្រះជាម្ចាស់នៅព្រឹកថ្ងៃអាទិត្យ ហើយទ្រព្យសម្បត្តិគេគឺនឹងនៅទីនោះឯង។ **ខុសហើយ**! ប្រព័ន្ធដែលលោកអ្នកទុកចិត្តថានឹងបំពេញសេចក្តីត្រូវការរបស់លោកអ្នក គឺជាកន្លែងដែលមានទ្រព្យសម្បត្តិរបស់លោកអ្នកហើយ។

ព្រះយេស៊ូមានបន្ទូលថា យើងបានបញ្រ្ចាសខនោះ!

ព្រះជាម្ចាស់ចង់ធ្វើជាទីមួយនៅក្នុងជីវិតរបស់យើង គឺមិនមែនលុយទេ។ ប្រសិនបើលុយជាទ្រព្យសម្បត្តិរបស់យើង នោះវានឹងជាទីមួយ ដែលតម្រូវឲ្យយើងចំណាយពេលវេលា អាទិភាព និងការស្រឡាញ់ថ្នាក់ថ្នម។ ហេតុនេះហើយបានជាលោកពេត្រុសមិនត្រូវចាកចេញពីបេសកកម្មរបស់លោក ហើយទៅរកប្រាក់នៅពេលដែលត្រូវដល់ពេលបង់ពន្ធ។ ហេតុនេះហើយបានជាព្រះជាម្ចាស់ត្រូវហ្វឹកហ្វឺនយើងឲ្យប្រមូល ហើយមិនមែនខិតខំធ្វើការយ៉ាងវេទនា។ ព្រះយេស៊ូត្រូវចាំបាច់បង្រៀនយើងតាមរបៀបនៃព្រះរាជ្យ របៀបទុកចិត្តលើព្រះជាម្ចាស់សម្រាប់ការផ្គត់ផ្គង់របស់យើង ដើម្បីឲ្យយើងអាចមានដួងចិត្តដែលមានសេរីភាពក្នុងការស្រឡាញ់ព្រះជាម្ចាស់ដោយអស់ពីចិត្ត! ព្រះយេស៊ូមានបន្ទូលថា *«ជីវិតមានតម្លៃលើសម្លូប*

*អាហារ ហើយរូបកាយក៏មានតម្លៃលើសសម្លៀកបំពាក់ទៅទៀត»* ទ្រង់កំពុងមានន័យថា ជីវិតមិនមែនអំពីការមានរបស់របរច្រើននោះទេ។ គោលបំណងនៃជីវិតគឺថារបស់របរទាំងនោះបម្រើលោកអ្នក និងបេសកកម្មរបស់លោកអ្នកនៅលើផែនដី។

**ប្រសិនបើលុយជាទ្រព្យសម្បត្តិរបស់យើង នោះវានឹងជាទីមួយដែលតម្រូវឲ្យយើងចំណាយពេលវេលា អាទិភាព និងការស្រឡាញ់ថ្នាក់ថ្នម។**

នៅឡើយ តើយើងឃើញអ្វី? មនុស្សភាគច្រើនខិតខំរត់ឥតឈប់សោះ ដោយព្យាយាមបម្រើរបស់ទាំងនោះ។ មនុស្សកំពុងតែព្យាយាមរត់ត្រហេបត្រហបដោយព្យាយាមបង់ថ្លៃផ្ទះប្រចាំខែ បង់ថ្លៃឡាន បង់ចំណាយផ្សេងៗ។ ព្រះយេស៊ូមានបន្ទូលថា នោះគឺមិនមែនជីវិតទេ! នៅពេលនេះ សូមកុំទាន់ឈប់ស្តាប់ពាក្យខ្ញុំ ហើយចាប់ផ្តើមប្រាប់ខ្ញុំថា
«ឃើញទេ ព្រះយេស៊ូផ្ទាល់ក៏មានបន្ទូលថាការមានរបស់របរជាការមិនល្អទេ។» អត់ទេ ទ្រង់មិនបានមានបន្ទូលបែបនេះទេ។ ទ្រង់មានបន្ទូលនៅខ ៣៣ ថា ប្រសិនបើលោកអ្នកស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និងសេចក្តីសុចរិតរបស់ទ្រង់ជាមុនសិន នោះរបស់ទាំងនោះនឹងត្រូវបានបន្ថែមមកកាន់ជីវិតរបស់លោកអ្នក។ សំខាន់ត្រង់ថាមិនមែនយើងឃើញបញ្ហានៅត្រង់ណាទេ ប៉ុន្តែគឺជាចិត្តរបស់យើងវិញ។ ប្រសិនបើព្រះជាម្ចាស់មិនចង់ឲ្យយើងមានរបស់របរ នោះព្រះយេស៊ូនឹងមានបន្ទូលដូច្នេះមិនខាន។ ផ្ទុយទៅវិញ ទ្រង់មានបន្ទូលថាអ្វីៗដែលលោកីយ៍រត់ដេញតាមនឹងត្រូវបានបន្ថែមចូលមកកាន់ជីវិតរបស់យើង ប្រសិនបើយើងរស់នៅតាមរបៀបរបស់ព្រះជាម្ចាស់។

យើងអាចនិយាយបានថា ជីវិតគឺមិនមែនអំពីការបម្រើរបស់របរទេ ប៉ុន្តែគួរឲ្យសោកស្តាយ មនុស្សភាគច្រើនកំពុងរស់នៅបែបនោះឯង។ ពួកគេមិនមានជម្រើសទេ។ ពួកគេជាខ្ញុំបម្រើតែម្តង។ វាមិនអាចទៅរួចទេ ក្នុងការបម្រើម្ចាស់ពីរ ហើយការ

បម្រើសម្ភារៈគឺមិនមែនជាជីវិតដ៏មានសុភមង្គលឡើយ។ ព្រះយេស៊ូបន្តដោយពន្យល់ថាមានប្រព័ន្ធមួយទៀត ជាកន្លែងដែលមានសន្តិភាព និងការផ្គត់ផ្គង់ខាងផ្នែកថវិកាដែលឲ្យលោកអ្នកមានសេរីភាពដើម្បីរស់នៅ។ កន្លែងនោះហៅថា ព្រះរាជ្យរបស់ព្រះជាម្ចាស់។

ព្រះយេស៊ូប្រទានឲ្យយើងនូវឧទាហរណ៍ពីរអំពីលក្ខណៈនៃព្រះរាជ្យនៅក្នុងសេចក្ដីបង្រៀនរបស់ទ្រង់នៅម៉ាថាយជំពូក ៦។ ទ្រង់មានបន្ទូលថា «*ចូរមើលក្អែក វាមិនដែលសាបព្រោះ មិនដែលច្រូតកាត់ គ្មានឃ្លាំង គ្មានជង្រុកសោះ ប៉ុន្តែ ព្រះជាម្ចាស់ចិញ្ចឹមវា*» (ខ ២៦)។

## បក្សីគ្មានកសិដ្ឋានចិញ្ចឹមដង្កូវទុកជាចំណីទេ!

ពួកវាមិនទម្លាក់បន្ទុកនៃការផ្គត់ផ្គង់លើសេចក្ដីត្រូវការរបស់ខ្លួនមកលើខ្លួនឯងឡើយ។ អត់ទេ គឺព្រះបិតាទេតើជាអ្នកចិញ្ចឹមវា។ ពួកវាគ្រាន់តែត្រូវប្រមូលនូវអ្វីដែលវាត្រូវការជារៀងរាល់ថ្ងៃប៉ុណ្ណោះ។ តើលោកអ្នកយល់ទេ? ពួកវាមិនដែលបែកញើសដោយខិតខំកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនា និងការឈឺចាប់សម្រាប់ជីវិតរបស់ខ្លួនឡើយ។ វាគ្រាន់តែប្រមូល!

## ផ្កាមិនដែលនឿយហត់ធ្វើការ ត្បាញរវៃឡើយ!

*ចូរគិតមើល ផ្កាដុះឡើងយ៉ាងណា វាមិនដែលនឿយហត់នឹងធ្វើការ ឬត្បាញរវៃឡើយ។ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា សូម្បីតែព្រះបាទសាឡូម៉ូន កាលពីជំនាន់ដែលទ្រង់មានសិរីរុងរឿងដ៏ប្រសើរបំផុតនោះ ក៏ទ្រង់គ្មានព្រះភូសាល្អស្មើនឹងផ្កាមួយទងនេះផង។ (ខ ២៧)*

ផ្កាមិនចាំបាច់ស្លៀកពាក់ឲ្យខ្លួនឯងមានសម្រស់ស្រស់ស្អាត ដោយខិតខំយ៉ាងវេទនា និងបង្ហូរញើសឡើយ។ អត់ទេ គឺជាព្រះបិតាដែលប្រទានសម្រស់ឲ្យផ្កាទាំងនោះ។ ព្រះយេស៊ូក៏បន្តដោយប្រាប់លោកអ្នកនិងខ្ញុំអំពីចម្លើយរបស់យើង។ មានរបៀបមួយទៀតដើម្បីរស់នៅ គឺរបៀបបែបព្រះរាជ្យរបស់ព្រះជាម្ចាស់! ព្រះយេស៊ូមានបន្ទូលថា *«ចូរខំស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់វិញ ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀតផង»* (ខ៣១)។ តើពាក្យថា «ស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់» មានន័យដូចម្ដេច? ឃ្លានោះមានន័យថា ព្យាយាមស្វែងយល់ថាតើព្រះរាជ្យទ្រង់ដំណើរការដោយរបៀបណា! ចូរសិក្សាពីច្បាប់ដែលគ្រប់គ្រងលើព្រះរាជ្យនោះ! ចូររៀនពីរបៀបដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ដំណើរការ!

ប្រសិនបើខ្ញុំត្រូវទម្លាក់លោកអ្នកពីយន្ដហោះ ទៅលើប្រទេសមួយដែលលោកអ្នកមិនធ្លាប់ទៅពីមុនមក បេសកកម្មដំបូងដែលលោកអ្នកនឹងព្យាយាមបំពេញគឺរៀនពីរបៀបដែលនគរនោះដំណើរការៈ របៀបដែលគេញ៉ាំអាហារ របៀបដែលគេទិញ និងលក់ ច្បាប់ដែលគ្រប់គ្រងនៅលើទឹកដីរបស់គេ។ កិច្ចការដដែលក៏ពិតនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ដែរ។ លោកអ្នកចាំបាច់ត្រូវរៀនពីរបៀបដែលព្រះរាជ្យដំណើរការដើម្បីឲ្យអាចទទួលបានប្រយោជន៍ជាទីរីករាយក្នុងនាមជាពលរដ្ឋនៃព្រះរាជ្យនេះ។ តាមរយៈបទពិសោធន៍ផ្ទាល់ខ្លួន ខ្ញុំដឹងថាខ្ញុំបានខកខានជាច្រើននៅពេលដែលខ្ញុំមិនបានដឹងពីរបៀបដែលព្រះរាជ្យដំណើរការ។ ចម្លើយរបស់លោកអ្នកគឺសាមញ្ញទេ។ លោកអ្នកត្រូវការបដិវត្តន៍ហិរញ្ញវត្ថុ។ នៅក្នុងបដិវត្តន៍ មនុស្សកំពុងធ្វើការប្រឆាំងនឹងរដ្ឋាភិបាលដែលកំពុងគ្រប់គ្រងលើខ្លួន ហើយរៀបចំដាក់រដ្ឋាភិបាលថ្មីវិញ។ លោកអ្នកចាំបាច់ត្រូវធ្វើដូចគ្នា។ លោកអ្នកចាំបាច់ត្រូវបោះរដ្ឋាភិបាលនៃប្រព័ន្ធបណ្ដាសាផែនដីនោះចោល ជាប្រព័ន្ធដែលមានការខ្វះខាត ការអស់សង្ឃឹម ហើយរីករាយនឹងរបៀបរស់នៅថ្មីវិញ ដែលជារបៀបរស់នៅក្នុងព្រះរាជ្យរបស់ព្រះរាជ្យរបស់ព្រះជាម្ចាស់ ជាមួយនឹងច្បាប់ថ្មី ដែលគ្មានការខ្វះខាត និងមានអំណរដ៏ធំធេង!

ជំពូកទី១១

# ហោះស្រួលជាងដើរ!

ប្រសិនបើលោកអ្នករស់នៅសម័យមុន ហើយលោកអ្នកចង់ធ្វើដំណើរពីក្រុងញូវយ៉កទៅកាន់ក្រុងសាន់ហ្វ្រាន់ស៊ីសស្កូ លោកអ្នកចាំបាច់ត្រូវធ្វើដំណើរតាមទូក។ ការធ្វើដំណើរមុនពេលដែលព្រែកជីកផាណាម៉ា ខាណាល់ (Panama Canal) បើក អាចត្រូវចំណាយពេលមួយឆ្នាំ ក្នុងការធ្វើដំណើរជុំវិញទ្វីបអាហ្វ្រិកខាងត្បូង។ ក្រោយមកទៀត នៅពេលដែលផ្លូវលំសម្រាប់រទេះ Oregon Trail ត្រូវបានដាក់ឲ្យប្រើប្រាស់ លោកអ្នកអាចធ្វើដំណើរកាត់ប្រទេសអាមេរិកក្នុងពេលបួនខែ ប៉ុន្តែនៅពេលនេះ លោកអ្នកអាចធ្វើដំណើរត្រឹមបួនម៉ោងប៉ុណ្ណោះ។ តើដោយរបៀបណា? គឺដោយការប្រើប្រាស់ច្បាប់ថ្មី ជាច្បាប់នៃការលើកឡើង។ ច្បាប់នៃការលើកឡើងនេះតែងមានវត្តមានតាំងពីដើម ហើយបក្សាបក្សីប្រើប្រាស់ច្បាប់នេះជារៀងរាល់ថ្ងៃ ប៉ុន្តែមនុស្សមិនបានយល់ពីវាទេ។ ដូចជាច្បាប់ធម្មជាតិនៃការហោះហើរ គ្រិស្តបរិស័ទភាគច្រើនមិនបានដឹងពីច្បាប់ទាំងប៉ុន្មាននៃព្រះរាជ្យ ទោះបីជាពួកគេបានអានអំពីវានៅសឹងពេញមួយជីវិតហើយក្តី។ ព្រះរាជ្យរបស់ព្រះជាម្ចាស់មាននៅទីនេះ គឺនៅក្នុងលោកអ្នក ហើយលោកអ្នកមានសិទ្ធិស្របច្បាប់ដើម្បីទទួលបានប្រយោជន៍ដ៏ជាទីរីករាយរបស់វា។ នៅក្នុងភពធម្មជាតិ ច្បាប់នៃការហោះហើរមិនលុបចោលនូវច្បាប់នៃទំនាញផែនដីឡើយ ប៉ុន្តែច្បាប់នៃការហោះហើរគឺជំនួសច្បាប់ទំនាញផែនដី។

ពាក្យម្យ៉ាងទៀត ដរាបលោកអ្នកធ្វើប្រតិបត្តិការដោយយោងតាមច្បាប់ដែលគ្រប់គ្រងលើការហោះហើរ នោះលោកអ្នកនឹងហោះ ទោះបីជាលោកអ្នកកំពុងស្ថិតក្នុងដែនទំនាញផែនដីក៏ដោយ។ លោកអ្នកចាំបាច់ត្រូវយល់ស្របថា ជាការងាយស្រួលដោយហោះហើរត្រឹម ៤ ម៉ោង ជាជាងជិះទូកក្នុងពេលមួយឆ្នាំ! មែនហើយ បើដូច្នេះចូរចាប់ផ្ដើមធ្វើកិច្ចការដោយរបៀបលឿន ហើយចាកចេញពីរបៀបយឺតរបស់លោកអ្នកពីមុននោះទៅ។

តើលោកអ្នកធ្លាប់ឃើញមេអំបៅស្ដេច (Monarch butterfly) ដែរឬទេ? នៅរដ្ឋអូហៃយ៉ូនេះ នារដូវស្លឹកឈើជ្រុះ លោកអ្នកនឹងឃើញមេអំបៅស្ដេចរាប់រយក្បាលហោះទៅភាគខាងត្បូងសម្រាប់រដូវរងារ។ ពួកវានឹងធ្វើដំណើរទៅប្រទេសម៉ិកស៊ិក ជាការធ្វើដំណើរមួយប្រមាណជា ៣២០០ គ.ម។ ប៉ុន្តែ អ្វីដែលគួរឲ្យចាប់អារម្មណ៍គឺបែបនេះ។ ពួកវាមិនដែលទៅទីនោះពីមុនទេ! តើអាចឲ្យពួកវាដឹងថាទៅដោយរបៀបណា ឬនៅពេលណាដោយរបៀបណាវិញ? ប្រសិនបើព្រះជាម្ចាស់រៀបចំផ្លូវឲ្យមេអំបៅស្ដេចអាចរស់រានបាន នោះទ្រង់ក៏មានផ្លូវសម្រាប់លោកអ្នកដែរ។ តើមេអំបៅធ្វើបែបនេះដោយរបៀបណា?

គេប្រើពាក្យថាផ្លាស់ប្រែដើម្បីបរិយាយពីការនេះ។ ពាក្យដើមគឺ «ផ្លាស់ប្ដូរ»។ មនុស្សភាគច្រើនដឹងថា មេអំបៅស្ដេចមិនកើតឡើងជាមេអំបៅភ្លាមៗនោះទេ។ ផ្ទុយទៅវិញ ពួកវាចាប់ផ្ដើមឡើងជាដង្កូវមេអំបៅ។ នៅពេលដែលវាស្ថិតក្នុងដំណាក់កាលជាដង្កូវមេអំបៅ វារស់នៅលើរុក្ខជាតិដែលមានជ័រ ហើយក៏ធំធាត់ឡើងរហូតដល់ចុងក្រោយ ពួកវាត្រៀមខ្លួនរួចរាល់សម្រាប់ការផ្លាស់ប្ដូរដ៏ខ្លាំងក្លា។ បន្ទាប់ពីធំឡើងដល់ទំហំមួយ វានឹងបង្កើតជាសំបុកនាង ដែលជាសំបកម្យ៉ាងសម្រាប់ឲ្យដង្កូវមេអំបៅនៅសំងំក្នុងពេលពី ៧ ទៅ ១៥ ថ្ងៃ។ បន្ទាប់ពីនោះមក សត្វមេអំបៅក៏នឹងហោះឡើងចេញពីសំបុកនាង ទាំងមើលឃើញ និងប្រព្រឹត្តខុសប្លែកពីកាលដែលវានៅជាដង្កូវទាំងស្រុង។ វារស់នៅ និងមានជីវិតក្នុងកម្រិតមួយខុសប្លែកពីមុនទាំងស្រុង។ វាហើរ! ជំនួសឲ្យការមានដែនកំណត់ និងអាចនៅលើរុក្ខជាតិតែមួយដើម

នៅពេលនេះវាអាចហើរបានទៅកន្លែងណាដែលវាចង់ទៅ។ វាមានរូបរាងស្រស់ស្អាត និងគួរជាទីពេញចិត្ត ហើយពុំមានអ្វីនៅក្នុងចំណោមបណ្ដាធម្មជាតិអាចប្រៀបប្រដូចបានឡើយ។

ប៉ុន្តែ រឿងដ៏អស្ចារ្យបំផុតដែលវាអាចធ្វើបានគឺសមត្ថភាពក្នុងការហោះចេញពីបញ្ហា។ លោកអ្នកឃើញទេ មេអំបៅស្ដេចមិនអាចរស់នៅក្នុងរដូវរងារជាច្រើនខែ នៅភាគខាងជើងបានទេ។ វាប្រាកដជាងាប់មិនខាន។ ប៉ុន្តែ ព្រះជាម្ចាស់បានរៀបចំផ្លូវឲ្យសត្វនេះហោះចេញពីបញ្ហា គឺដោយហោះជាង ៣២០០ គម ទៅកាន់កន្លែងមួយដែលវាមិនធ្លាប់បានទៅពីមុនមក។ តើវាអាចសូម្បីតែស្គាល់ផ្លូវទៅទីនោះដោយរបៀបណា? តើវាធ្វើដូច្នេះដោយរបៀបណា? គឺដោយការផ្លាស់ប្រែ។ ហើយព្រះគម្ពីរចែងថា តាមរយៈដំណើរការដដែល លោកអ្នកអាចហោះខ្ពស់ជាងបញ្ហារបស់លោកអ្នកដែរ សូម្បីតែនៅក្នុងស្ថានការណ៍ដែលលោកអ្នកពុំមានតម្រុយថាត្រូវដោះស្រាយវាដោយរបៀបណា ដូចជាមេអំបៅស្ដេចអញ្ចឹង។

ខ្ញុំមានមិត្តម្នាក់ឈ្មោះថាស្ទីវ។ នៅយប់មួយ គាត់កំពុងតែបើករថយន្តត្រលប់ទៅផ្ទះវិញ ហើយក៏បុកនឹងក្ដាន់មួយក្បាល។ វាបានធ្វើឲ្យរថយន្តខូចខាតយ៉ាងខ្លាំងរហូតដល់ថ្លៃជួសជុលថ្លៃជាងទិញឡានថ្មីទៅទៀត។ គួរឲ្យសោកស្ដាយ គាត់មានឡានមួយទៀតដែលមាន ១២ កៅអីសម្រាប់ដឹកក្រុមគ្រួសារ ក៏ផ្ទុះម៉ាស៊ីននៅពេលមួយសប្ដាហ៍បន្ទាប់ពីហេតុការណ៍នោះកើតឡើង។ ក្រុមហ៊ុនធានារ៉ាប់រងរបស់លោកស្ទីវបានឲ្យលោកស្ទីវខ្ចីឡានមួយយកមកប្រើក្នុងពេលពីរសប្ដាហ៍ដោយឥតគិតថ្លៃ សម្រាប់ការបាត់បង់ឡានរបស់គាត់ ប៉ុន្តែឡាន ១២ កៅអីមិនស្ថិតក្រោមធានារ៉ាប់រងណាមួយឡើយ។ លោកស្ទីវ និងអ្នកស្រីខេរិនមិនបានដឹងថាត្រូវធ្វើអ្វីទេ។ អាជីវកម្មរបស់លោកតម្រូវឲ្យគាត់មានរថយន្ត ព្រោះគាត់ធ្វើការផ្នែកលក់ ហើយគាត់បើករថយន្តទៅជួបអតិថិជន ដើម្បីធ្វើការលក់នៅរាល់ល្ងាច។

ពួកគេបានឮពីសេចក្ដីបង្រៀនអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់យូរល្មមគ្រប់គ្រាន់ ហើយក៏ដឹងថាមានតែទ្រង់ទេទើបជាចម្លើយ។ នៅពេលនោះ ពួកគេពុំមានប្រាក់

បន្ថែមដើម្បីយកទៅជួសជុលរថយន្តឡើយ។ ដូច្នេះ ពួកគេដឹងថាព្រះជាម្ចាស់ និងព្រះរាជ្យរបស់ទ្រង់ជាចម្លើយតែមួយសម្រាប់ពួកគេ។ រយៈពេលពីរសប្ដាហ៍សម្រាប់ការខ្ចីរថយន្តក៏បានកន្លងផុតទៅយ៉ាងលឿន ហើយពួកគេនៅតែពុំមានចម្លើយ។ ជាការអស្ចារ្យ នៅយប់មុនដែលលោកស្ទីវត្រូវយកឡានខ្ចីនោះទៅប្រគល់ដល់គេវិញ លោកស្ទីវបានទទួលទូរស័ព្ទមួយហៅចូលពីបុរសម្នាក់ដែលនិយាយថា គាត់មានឡានមួយគ្រឿងដែលគាត់ចង់ឲ្យគេ ហើយដោយព្រោះគាត់ដឹងថាលោកស្ទីវបានចូលរួមក្នុងក្រុមជំនុំរបស់ខ្ញុំ គាត់ក៏បានទូរស័ព្ទមកលោកស្ទីវហើយសួរថាតើលោកស្ទីវស្គាល់ក្រុមគ្រួសារណាមួយនៅក្នុងក្រុមជំនុំដែលត្រូវការរថយន្តជិះដែរឬទេ។ លោកស្ទីវក៏បានពន្យល់ពីស្ថានការណ៍របស់គាត់ភ្លាមៗ ហើយនិយាយថាគាត់ពិតជាអរគុណខ្លាំងណាស់ប្រសិនបើទទួលបានរថយន្តនោះសម្រាប់ខ្លួនគាត់ និងក្រុមគ្រួសារ។ នោះគឺល្អណាស់ ប៉ុន្តែលោកស្ទីវមានកូន ៦ នាក់ ហើយឡានតូចមិនអាចដឹកក្រុមគ្រួសារគាត់អស់ទេ។ ទោះជាយ៉ាងនេះក្ដី ដោយបានដឹងថានឹងបានទទួលឡាននេះបានលើកទឹកចិត្តពួកគេយ៉ាងខ្លាំង។

នៅថ្ងៃអាទិត្យបន្ទាប់ ពួកគេទាំងពីរបានមកខាងមុខក្រុមជំនុំ ហើយសុំខ្ញុំឲ្យជួយអធិស្ឋានជាមួយពួកគេ អំពីឡានបន្ទាប់។ អ្នកស្រីខេរិនពោលថា «លោកគ្រូយើងជឿថាយើងទទួលបានឡាន ១២ កៅអីម៉ាក Honda Odyssey ដោយជំនឿ ហើយយើងចង់សុំលោកគ្រូឲ្យយល់ស្របជាមួយយើងនៅពេលដែលយើងសាបព្រោះគ្រាប់ពូជសម្រាប់ឡាននោះ។» ខ្ញុំពោលថា «ប្រាកដណាស់ ខ្ញុំនឹងយល់ស្របជាមួយអ្នកទាំងពីរ» ដូច្នេះយើងក៏អធិស្ឋាន។ មកទល់ពេលនោះ ខ្ញុំចាំមិនបានថាវាបានកន្លងទៅប៉ុន្មានសប្ដាហ៍ទេ ប៉ុន្តែមិនច្រើនទេ គឺប្រហែលជាបីទៅបួនសប្ដាហ៍ប៉ុណ្ណោះ រហូតដល់ថ្ងៃមួយដែលយើងចូលលេងផ្ទះពួកគេ។ នៅពេលដែលយើងចូលលេង យើងបានដើរសំដៅទៅផ្ទះបាយរបស់ពួកគេ ហើយនៅលើទ្វារទូទឹកកកគឺជារូបថតឡាន Honda Odyssey។ អ្នកស្រីខេរិនពោលថា រៀងរាល់ថ្ងៃនៅពេលដែល

នាងបើកទូរទឹកកកនោះ នាងតែងដាក់ដៃនៅលើរូបថតនោះ ទាំងអរព្រះគុណព្រះជាម្ចាស់សម្រាប់ឡាន ១២ កៅអីនោះ។

ប្រហែលជាមួយសប្តាហ៍ក្រោយមក លេខារបស់ខ្ញុំបានទូរស័ព្ទមកខ្ញុំហើយថា «លោកគ្រូ យើងមានទូរស័ព្ទហៅចូលមួយដែលគួរឲ្យចាប់អារម្មណ៍នៅថ្ងៃនេះ»។ មានបុរសម្នាក់ចង់បរិច្ចាគរថយន្ត១២កៅអីមួយគ្រឿងដល់ក្រុមជំនុំ។ នៅពេលនោះ ពុំមាននរណាដឹងថាតើស្ទីវនិងខេរិនបានស្រាយជំនឿរបស់ពួកគេសម្រាប់ឡាន ១២ កៅអីថ្មី ឬម៉ូតឡានដែលគេចង់បានយ៉ាងណាទេ។ ដូច្នេះ ខ្ញុំក៏សួរលេខាថា «តើឡាននោះម៉ាកអ្វីដែរ?» នាងពោលថា «គឺម៉ាក Honda Odyssey» «តើវាមានស្ថានភាពបែបណាដែរ?» នាងពោលថា បុរសនោះនិយាយថាវាមានស្ថានភាពល្អឥតខ្ចោះ ដោយគ្មានស្នាមឆ្កូតសោះ ហើយទើបតែជិះបានជាង ១១២៥០០ គមប៉ុណ្ណោះ។ ខ្ញុំពោលទៅនាងថា ខ្ញុំដឹងហើយថាត្រូវចាត់ចែងឡាននោះទៅណា។ ខ្ញុំក៏ប្រាប់ឌ្រិនដាអំពីវា ហើយសុំឲ្យនាងទូរស័ព្ទទៅខេរិន។ នៅពេលដែលឌ្រិនដាទូរស័ព្ទទៅ នាងបានសួរសុខទុក្ខខេរិន ហើយថាតើពួកគេបានឃើញតម្រុយអ្វីទាក់ទងនឹងឡានដែលពួកគេត្រូវការដែរឬទេ។ ពាក្យដំបូងដែលខេរិននិយាយគឺ «ចាស៎ យើងជិតបានហើយ គឺសល់តែមួយថ្ងៃទៀតទេ!» ឌ្រិនដាក៏តបថា «មែនហើយ តាមពិតវាកៀកជាងអ្វីដែលនាងគិតទៅទៀត។ ឥឡូវមកយកឡានមក។»

ខ្ញុំចូលចិត្តសាច់រឿងអញ្ចឹងៗ ចុះលោកអ្នកវិញ? សាច់រឿងនេះបន្តទៅដោយលោកស្ទីវ និងអ្នកស្រីខេរិនបានកាន់តែមានទំនុកចិត្តនៅលើព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលនឹងផ្គត់ផ្គង់ដល់ពួកគេ។

នៅក្នុងពេលនោះ លោកស្ទីវ និងនាងខេរិនចង់បានផ្ទះមួយខ្នង។ ពួកគេបានជួលផ្ទះនៅក្នុងពេលពីរបីឆ្នាំ ហើយក៏មានអារម្មណ៍ថាដល់ពេលដែលត្រូវមានផ្ទះផ្ទាល់ខ្លួន។ ប៉ុន្តែ ពួកគេក៏មិនមានប្រាក់គ្រប់គ្រាន់ដើម្បីបង់រំលោះផ្ទះ។ ពួកគេបានទៅកាន់ធនាគារជាច្រើនដើម្បីសាកសួរពីការទិញដី ហើយធនាគារទាំងនោះតម្រូវដូចគ្នា គឺពួកគេត្រូវមានប្រាក់ ៥០%។ ត្រង់រឿងនេះ នៅក្នុងជីវិតក្រុមគ្រួសារវ័យក្មេង

**មានពេលជាច្រើនលើក យើងកំណត់ខ្លួនឯងដោយថ្លឹងថ្លែងអនាគតរបស់យើងតាមរយៈអ្វីដែលយើងគិតថាអាចទៅរួច។ ប៉ុន្តែ ជាមួយនឹងព្រះជាម្ចាស់ អ្វីៗសុទ្ធតែអាចកើតឡើងបាន ប្រសិនបើយើងគ្រាន់តែអនុញ្ញាតឲ្យព្រះបន្ទូលរបស់ព្រះអង្គផ្លាស់ប្តូរការគិតរបស់យើង។**

នេះ មិនទាន់មានប្រាក់ច្រើននៅក្នុងដៃ ដើម្បីឲ្យអាចបង់រំលោះដីបានទេ។ អ្នកស្រីខេរិនបានបាក់ទឹកចិត្ត ហើយក៏សួរយោបល់ខ្ញុំពីរឿងនេះ។ យើងបានយល់ស្របថា ព្រះជាម្ចាស់នឹងរៀបចំផ្លូវ។ ដូច្នេះ ពួកគេបានចាប់ផ្តើមរកមើលដី និងផ្ទះផ្សេងៗគ្នាទៀត។

មានដីមួយកន្លែងដែលគេមើលបានទាក់ភ្នែកអ្នកទាំងពីរ។ វានៅក្នុងតំបន់ដែលគេចង់សង់ផ្ទះ ហើយមានតម្លៃត្រឹម ៥៥០០០ដុល្លារប៉ុណ្ណោះសម្រាប់ផ្ទៃដី២២ហិកតា។ នៅលើកនេះទៀត ពួកគេនៅតែពុំមានប្រាក់កក់ដដែល។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានឮពីធនាគារជនបទតូចមួយ ដែលមិននៅក្នុងតំបន់របស់ពួកគេទេ ប៉ុន្តែមានចម្ងាយជាង ២ ម៉ោង ដែលធនាគារនោះនឹងទទួលតម្លៃអចលនទ្រព្យដែលជាផ្នែកមួយនៃការបង់ប្រាក់កក់ថ្លៃដី។ វាពិតជាចម្លែកណាស់សម្រាប់ដីធម្មតា។ ខ្ញុំបានប្រាប់ពួកគេពីរឿងនេះ ហើយពួកគេបានលៃពេលទៅជួបជាមួយនឹងធនាគារនោះ។ ដីនោះត្រូវបានវាយតម្លៃឃើញថា មានតម្លៃជាង ១០០ ០០០ ដុល្លារ ហើយធនាគារក៏និយាយថាពួកគេមិនត្រូវការប្រាក់កក់អ្វីទាំងអស់។ ដូច្នេះ អ្នកទាំងពីរបានទិញដីនោះដោយមិនមានប្រាក់កក់ ហើយបានសង់ផ្ទះដ៏ស្រស់ស្អាតមួយនៅលើដីជនបទប៉ុន្មានហិកតានោះ ដោយមិនមានប្រាក់កក់។ លោកស្ទីវ និងអ្នកស្រីខេរិនបានបន្តចម្រុងចម្រើនមកទល់សព្វថ្ងៃ ដូចជាឌ្រិនដានិងខ្ញុំដែរ ដែលយើងធ្វើកិច្ចការតាមរបៀបនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។

ខ្ញុំតែងតែឮពីសាច់រឿងបែបនេះនៅក្នុងក្រុមជំនុំរបស់ខ្ញុំ ហើយខ្ញុំក៏រំពឹងយ៉ាងមុតមាំថាសាច់រឿងបែបនេះនឹងកើតឡើងនៅក្នុងជីវិតរបស់លោកអ្នកដែរ។ ព្រះជាម្ចាស់អាចធ្វើកិច្ចការដ៏អស្ចារ្យ ហើយជួនកាលក៏ចម្លែកៗដើម្បីបំពេញសេចក្តីត្រូវការរបស់យើង។ មានពេលជាច្រើនលើក យើងកំណត់ខ្លួនឯងដោយថ្លឹងថ្លែងអនាគតរបស់យើងតាមរយៈអ្វីដែលយើងគិតថាអាចទៅរួច។ ប៉ុន្តែ ជាមួយនឹងព្រះជាម្ចាស់ អ្វីៗសុទ្ធតែអាចកើតឡើងបាន ប្រសិនបើយើងគ្រាន់តែអនុញ្ញាតឲ្យព្រះបន្ទូលរបស់ព្រះអង្គផ្លាស់ប្តូរការគិតរបស់យើង។

*មិនត្រូវយកតម្រាប់តាមនិស្ស័យលោកីយ៍នេះឡើយ ត្រូវទុកឲ្យព្រះជាម្ចាស់កែប្រែចិត្តគំនិតបងប្អូន ឲ្យទៅជាថ្មីទាំងស្រុងវិញ ដើម្បីឲ្យបងប្អូនចេះពិចារណាមើលថា ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្វីខ្លះ គឺអ្វីដែលល្អ ដែលគាប់ព្រះហឫទ័យព្រះអង្គ និងគ្រប់លក្ខណៈ។*

រ៉ូម ១២៖២ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

ក្នុងនាមជាអ្នកជឿ យើងមិនត្រូវយកតម្រាប់តាមនិស្ស័យលោកីយ៍នេះទេ។ លោកប៉ូលកំពុងសំដៅលើប្រព័ន្ធបណ្តាសានៃផែនដី និងរបៀបរស់នៅដែលស្របតាមប្រព័ន្ធនេះ ហើយជាពិសេសគឺរបៀបដែលយើងគិត។ តើលោកអ្នកធ្លាប់កាត់រ៉ូប ឬធ្វើអ្វីមួយដោយមានគំនូសប្លង់ដែរឬទេ? ប្រសិនបើលោកអ្នកធ្លាប់ ហើយលោកអ្នកមិនពេញចិត្តពេលដែលវាចេញជារូបរាង តើនឹងមានអ្វីកើតឡើងប្រសិនបើលោកអ្នកព្យាយាមកាត់ ឬធ្វើម្តងទៀតដោយប្លង់ដដែល? លោកអ្នកនឹងទទួលបានលទ្ធផលដដែល។ ដូច្នេះ លោកប៉ូលកំពុងនិយាយថាយើងត្រូវតែផ្លាស់ប្រែដោយកែប្រែចិត្តគំនិតរបស់យើងឲ្យទៅជាថ្មីវិញ។ យើងចាំបាច់ត្រូវផ្លាស់ប្តូររបៀបដែលយើងរស់នៅនេះ។ យើងចាំបាច់ត្រូវគិតខុសពីរបៀបដែលលោកីយ៍គិត។

ពាក្យថា «ផ្លាស់ប្រែ» នោះ គឺជាពាក្យដដែលដែលយើងទើបតែបាននិយាយនៅត្រង់អត្ថបទអំពីមេអំបៅ ជាពាក្យ «ផ្លាស់ប្តូរ» ហើយវាមានន័យថាផ្លាស់ប្តូរ ប្រែប្រួល។ យើងត្រូវការការផ្លាស់ប្រែ! យើងត្រូវគិតដូចជាព្រះជាម្ចាស់។ យើងត្រូវគិតនូវគំនិតបែបព្រះរាជ្យ។ ផ្ទុយពីការគិតពីទស្សនៈដែលកខ្វក់ ជាប់អន្ទាក់ ជាប់ក្នុងសេចក្តីស្លាប់ដូចជាដង្កូវមេអំបៅនៅវដ្តវង្វេង យើងត្រូវទុកចិត្តលើព្រះជាម្ចាស់ជាមួយនឹងរបៀបរស់នៅក្នុងជីវិតថ្មីទាំងស្រុង។ បន្ទាប់មក គឺបន្ទាប់ពីការនោះមកទើបយើងអាចហោះខ្ពស់ជាងបញ្ហារបស់យើង ហើយទទួលការបំពាក់បំប៉នដើម្បីឲ្យបានដឹងថាព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្វីខ្លះ គឺអ្វីដែលល្អ ដែលគាប់ព្រះហឫទ័យព្រះអង្គ និងគ្រប់លក្ខណៈនៅក្នុងស្ថានការណ៍ទាំងឡាយ។ ប្រសិនបើយើងមិនព្រមទទួលការផ្លាស់ប្តូរនៅលើការគិតនោះទេ ផ្នត់គំនិតចាស់របស់យើងនឹងចេះតែរំអុកថា «អត់ទេ អត់ទេ ខ្ញុំមិនអាចធ្វើដូច្នេះបានទេ។ អត់ទេ ខ្ញុំមិនឃើញថាការនេះអាចនឹងកើតឡើងបានឡើយ។»

តើនរណាអាចនឹងស្មានដល់ថា ដង្កូវដ៏គគ្រិចនោះអាចហោះបានដោយមានរូបឆោមលោមពណ៌ស្រស់សោភាបែបនេះ? ចូរមើលដង្កូវមេអំបៅ ហើយគិតអំពីការធ្វើដំណើរជាង ៣២០០ គ.ម.ដែលវាត្រូវធ្វើ លោកអ្នកប្រាកដជាគ្រវីក្បាល ហើយឧទានថា «មិនអាចទៅរួចជាដាច់ខាត!» ប៉ុន្តែ នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ អ្វីៗទាំងអស់សុទ្ធតែអាចទៅរួច។ ចូរមើលមកកាន់ខ្ញុំ។ នៅពេលដែលកម្មវិធីទូរទស្សន៍របស់ខ្ញុំចេញជារូបរាង ខ្ញុំមាននាមថាជាអ្នកជំនាញហិរញ្ញវត្ថុ។ ជួនកាល ខ្ញុំនឹកចាំពីសម័យកាលនៅជាដង្កូវ ហើយពោលថា «ពិតជាអស្ចារ្យណាស់!»

បើនិយាយពីការហោះ នៅពេលដែលខ្រិនដានិងខ្ញុំបានចាប់ផ្តើមរៀនពីរបៀបដែលព្រះរាជ្យធ្វើប្រតិបត្តិការ ខ្ញុំបានសម្រេចចិត្តថាខ្ញុំចង់បានយន្តហោះមួយគ្រឿង។ ខ្ញុំបានធ្វើជាអ្នកបើកយន្តហោះតាំងពីអាយុ១៩ឆ្នាំ ហើយតែងតែជួលយន្តហោះគេបើក ប៉ុន្តែខ្ញុំមិនដែលមានយន្តហោះផ្ទាល់ខ្លួនទេ។ ដូច្នេះ ថ្ងៃមួយខ្ញុំក៏សម្រេចចិត្តថាធ្វើរឿងមិនគួរឲ្យជឿ គឺថាយន្តហោះមួយគ្រឿងមិនពិបាកសម្រាប់ព្រះរាជ្យរបស់ព្រះ

ជាម្ចាស់ឡើយ។ ហេតុអ្វីបានជាខ្ញុំដាក់ដែនកំណត់លើព្រះរាជ្យរបស់ព្រះអង្គ ដោយគិតត្រឹមតែអ្វីដែលខ្ញុំអាចធ្វើបានដូច្នេះ? ដូច្នេះ ខ្ញុំបានសរសេរមូលប្បទានប័ត្រមួយសន្លឹក ដោយនៅលើផ្នែកចំណាំ ខ្ញុំសរសេរថា «សម្រាប់យន្តហោះរបស់ខ្ញុំ» (ហើយខ្ញុំរៀបរាប់លម្អិត)។ ខ្ញុំបានដាក់ដៃលើមូលប្បទានប័ត្រនោះ ហើយផ្ញើវាចេញទៅទាំងជឿជាក់ថាខ្ញុំបានទទួលយន្តហោះនោះនៅពេលអធិស្ឋាន ដោយយោងតាមគម្ពីរម៉ាកុស ១១៖២៤។

> *ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្វីក៏ដោយ ឲ្យតែអ្នករាល់គ្នាអធិស្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជាម្ចាស់នឹងប្រទានឲ្យអ្នករាល់គ្នាជាពុំខាន។*

មួយខែក្រោយមក ខ្ញុំក៏បានទៅជួបគ្រូពេទ្យ ដើម្បីពិនិត្យសុខភាពតាមទម្លាប់។ ខ្ញុំក៏ភ្ញាក់ផ្អើលព្រោះលោកគ្រូពេទ្យស្រាប់តែសួរថា «តើលោកមានស្គាល់នរណាដែលចង់ទិញយន្តហោះដែរឬទេ?» ខ្ញុំគិតថាសំណួរនេះចម្លែកណាស់ ហើយក៏សួរវិញថា «តើយន្តហោះប្រភេទណាដែរ?» ខ្ញុំភ្ញាក់ផ្អើល និងរំភើបព្រោះវាជាយន្តហោះបែបដែលខ្ញុំជឿថានឹងបានទទួល នៅពេលដែលខ្ញុំអធិស្ឋាន។ ដូច្នេះ ខ្ញុំក៏សួរគាត់ថាតើខ្ញុំអាចទៅមើលបាននៅកន្លែងណា ហើយគាត់បានប្រាប់ខ្ញុំថាវានៅអាកាសយានដ្ឋានជនបទជាប់ផ្ទះរបស់ខ្ញុំ។ សូមអនុញ្ញាតឲ្យខ្ញុំពន្យល់។ ផ្ទះរបស់ខ្ញុំនៅខាងចុងអាកាសយានដ្ឋាននោះ។ យន្តហោះទាំងប៉ុន្មានដែលចុះចតចាំបាច់ត្រូវហោះនៅលើផ្ទះខ្ញុំតែម្តង។ ដោយមើលយន្តហោះចុះឡើងៗជារៀងរាល់ថ្ងៃ និងការដែលផ្លូវយន្តហោះរត់ នៅក្បែរផ្ទះខ្ញុំធ្វើឲ្យខ្ញុំចង់បានយន្តហោះជាខ្លាំង!

ដូច្នេះ ខ្ញុំក៏បានទូរស័ព្ទទៅមិត្តភក្តិម្នាក់ដែលបានបើកយន្តហោះនៅពេញមួយជីវិតរបស់គាត់ ហើយក៏ជាគ្រូបង្រៀនបើកយន្តហោះឲ្យទៅជាមួយខ្ញុំដើម្បីមើលយន្តហោះនោះ។ នៅពេលដែលយើងមើលយន្តហោះនោះ ខ្ញុំដឹងថានោះឯងជាយន្ត

ហោះដែលខ្ញុំត្រូវទទួល វាគឺចំម៉ាច់តែម្តង! វាជាយន្តហោះដែលខ្ញុំចង់បាន ឥត ទាស់។ ខ្ញុំមានបញ្ហាតែមួយប៉ុណ្ណោះ ហើយវាជាបញ្ហាដែលខ្ញុំបានជួបជាច្រើនឆ្នាំនៅ ពេលដែលគិតដល់ការទិញយន្តហោះ គឺខ្ញុំមិនមានប្រាក់ទិញវាទេ។ តើធ្លាប់មាន បញ្ហានេះដែរឬទេ? ប៉ុន្តែ នៅលើកនេះខ្ញុំមិនបកក្រោយដោយភាពភ័យខ្លាចទេ។ ខ្ញុំ ដឹងថានេះជាយន្តហោះរបស់ខ្ញុំ ហើយខ្ញុំគ្រាន់តែមិនទាន់ដឹងថាតើព្រះជាម្ចាស់នឹង ប្រទានលុយដល់ខ្ញុំដោយរបៀបណា។

នៅប៉ុន្មានខែមុននេះ ឌ្រិនដានិងខ្ញុំបានរកមើលការិយាល័យសម្រាប់ក្រុមហ៊ុន របស់យើង។ យើងដឹងថា យើងចង់ឲ្យក្រុមហ៊ុនរបស់យើងមានទីតាំងនៅត្រង់នេះ ប៉ុន្តែនៅតំបន់នោះគ្មានកន្លែងណាសម្រាប់លក់សោះ។ ដូច្នេះ យើងក៏ចាប់ផ្តើមរក មើលនៅតំបន់ដទៃទៀត។ យើងបានឃើញអគារពីរបីដែលយើងហៀបនឹងទិញ ប៉ុន្តែយើងមានអារម្មណ៍នៅក្នុងវិញ្ញាណថា មិនត្រូវនឹងអគារទាំងនោះសោះ។ យើង គ្រាន់តែត្រលប់ទៅមើលតំបន់ដែលយើងចង់ដាក់ការិយាល័យ ដោយសង្ឃឹមថានឹង រកបានអគារណាមួយ។ នៅពេលដែលយើងកំពុងតែអធិស្ឋានអំពីការសម្រេចចិត្ត នេះ មានថ្ងៃមួយឪពុករបស់ខ្ញុំបានទូរស័ព្ទមកខ្ញុំ ហើយពោលពាក្យទាំងនេះ «ប៉ាដឹង ថាកូននឹងនិយាយពាក្យនេះទៅកាន់ព្រះជាម្ចាស់ ប៉ុន្តែម៉ាក់របស់កូននិងប៉ាបាន និយាយគ្នា ហើយយើងចង់ឲ្យអគារមួយរបស់យើងសម្រាប់ការិយាល័យរបស់ កូន។» អគារដែលពួកគាត់មាននោះ គឺនៅចំកន្លែងដែលខ្ញុំចង់ដាក់ ការិយាល័យតែម្តង។ ខ្ញុំពិតជាតក់ស្លុតណាស់!

**ជីវិតរបស់ខ្ញុំដែលបាននៅជាប់នឹង ការដែលគ្រាន់តែឲ្យបានរស់រាន និង ភាពភ័យខ្លាច នៅពេលនេះបាន ផ្លាស់ប្រែដោយព្រះរាជ្យរបស់ព្រះ ជាម្ចាស់។ ដោយការចូលទៅកាន់ ច្បាប់នេះ ខ្ញុំអាចរកឃើញជីវិតដែល មានលទ្ធភាពឥតដែនកំណត់។**

ដើម្បីយល់ពីអ្វីដែលខ្ញុំទើបតែ បានរៀបរាប់ លោកអ្នកចាំបាច់ត្រូវ

ដឹងថា ប៉ារបស់ខ្ញុំមិនទាន់ជឿលើព្រះជាម្ចាស់ទេនៅពេលនោះ។ នៅរាល់លើកដែលខ្ញុំនិយាយអំពីព្រះជាម្ចាស់ គាត់តែងតែសង្ស័យជានិច្ច។ តាមការពិត វាធ្ងន់ធ្ងរណាស់រហូតដល់ខ្ញុំមិនអាចនិយាយជាមួយគាត់អំពីព្រះជាម្ចាស់សោះ។ ខ្ញុំថែមទាំងអធិស្ឋានថាព្រះជាម្ចាស់នឹងចាត់នរណាម្នាក់ឲ្យទៅជួបគាត់ ហើយប្រកាសពីព្រះគ្រិស្តទៅកាន់គាត់។ ខ្ញុំដឹងថា ខ្ញុំមិនអាចនាំគាត់ឲ្យជឿលើព្រះយេស៊ូបានទេ ព្រោះគាត់មិនព្រមស្តាប់ខ្ញុំឡើយ។ ប៉ុន្តែ ឪពុករបស់ខ្ញុំបានទទួលការសង្គ្រោះពីរបីឆ្នាំមុននៅអាយុ៨០ឆ្នាំ។ អស្ចារ្យណាស់ គាត់បានទទួលការសង្គ្រោះដោយមើលកម្មវិធីទូរទស្សន៍របស់យើង ហើយឃើញនូវកិច្ចការអស្ចារ្យដែលព្រះជាម្ចាស់កំពុងតែធ្វើ។ គាត់បានចំណាយពេលបីឆ្នាំកន្លះចុងក្រោយនៃឆាកជីវិតក្នុងនាមជាមនុស្សម្នាក់ដែលបានផ្លាស់ប្រែ ហើយចូលរួមនៅក្នុងក្រុមជំនុំជារៀងរាល់សប្តាហ៍។

ថ្ងៃមួយនៅពេលដែលក្រុមជំនុំទើបតែចប់ការប្រជុំ ខ្ញុំបានដើរចេញទៅខាងក្រៅ។ ខ្ញុំក៏ឃើញប៉ារបស់ខ្ញុំនិយាយជាមួយជាមួយបុរសម្នាក់ដែលគាត់បានស្គាល់ជាច្រើនឆ្នាំ ហើយជាសមាជិកក្រុមជំនុំរបស់យើង។ នៅពេលដែលខ្ញុំដើរសំដៅទៅពួកគាត់ ខ្ញុំបានឮបុរសនេះសួរប៉ាខ្ញុំថា ហេតុអ្វីបានជាគាត់ចាប់ផ្តើមមកក្រុមជំនុំ។ ប៉ារបស់ខ្ញុំបានតបថាគាត់បានឃើញកិច្ចការអស្ចារ្យច្រើនពេក រហូតដល់គាត់មិនអាចពន្យល់បាន។ សូមសរសើរព្រះជាម្ចាស់! វាគួរតែកើតឡើងអញ្ចឹង។

ប៉ុន្តែ យើងត្រូវងាកទៅមើលការសន្ទនាតាមទូរស័ព្ទអំពីអគារនោះ មុនពេលដែលប៉ារបស់ខ្ញុំបានសង្គ្រោះវិញ។ ឌ្រិនដានិងខ្ញុំស្ងប់ស្ងែងណាស់ក្នុងការដែលគាត់ប្រគល់អគារនោះឲ្យយើង។ យើងដឹងថាជាព្រះជាម្ចាស់ដែលធ្វើការនេះ គឺជាការពិតណាស់ ហើយយើងក៏នឹងមិនដែលនិយាយទៅកាន់ប៉ានៅពេលដែលគាត់ទូរស័ព្ទមកថា «បាទប៉ា ត្រឹមត្រូវហើយ គឺព្រះជាម្ចាស់ជាអ្នកធ្វើការនេះ!» នោះទេ។

អគារនោះត្រូវធ្វើការជួសជុលតុបតែងច្រើនគួរសម ដើម្បីឲ្យក្លាយជាអគារលំដាប់ពាណិជ្ជកម្ម និងបំពេញសេចក្តីត្រូវការផ្នែកការិយាល័យរបស់យើង។ នៅ

ពេលដែលប៉ារបស់ខ្ញុំប្រគល់អគារនោះដល់ខ្ញុំគឺនៅខែធ្នូ ហើយខ្ញុំនឹងរង់ចាំរហូតដល់រដូវស្លឹកឈើជ្រុះដើម្បីចាប់ផ្ដើមការជួសជុល។ អគារនោះបិទនៅខែរងារ ហើយគ្មាននរណាប្រើវាឡើយ ហើយប៉ារបស់ខ្ញុំថាគាត់បានបិទទឹកហើយ។ ដូច្នេះ វាមានលក្ខណៈបែបនេះឯងនៅពេញមួយរដូវរងារ រហូតដល់ជាងមួយសប្ដាហ៍បន្ទាប់ពីខ្ញុំបានទៅមើលយន្តហោះ។ បងប្រុសរបស់ខ្ញុំបានទូរស័ព្ទមកហើយប្រាប់ថា ខ្ញុំគួរតែទៅមើលអគារ ព្រោះមានទឹកហូរចេញពីអគារទៅពាសពេញផ្លូវ។ ធាតុអាកាសបានប្រែជាក្ដៅបន្ទាប់ពីរដូវរងារ ហើយឪពុករបស់ខ្ញុំស្មានខុស។ តាមពិតគាត់មិនបានបិទទឹកនៅក្នុងរដូវរងារទេ។ ខ្ញុំបានបើកឡានទៅកាន់អគារនោះ ហើយបន្ទប់ទឹកនៅជាន់ខាងលើមានទឹកហូរចោលជាច្រើនថ្ងៃ ឬអាចដល់សប្ដាហ៍ផង។ ម្នាងសិលានៅជាន់ខាងក្រោមបានជ្រុះពីជញ្ជាំងអស់។

ខ្ញុំដឹងថា ស្ដាប់ទៅនេះជារឿងដ៏អាក្រក់ ប៉ុន្តែអ្វីដែលលោកអ្នកមិនដឹង ហើយបងប្រុសខ្ញុំមិនបានដឹងគឺថា ខ្ញុំបានចុះកិច្ចសន្យាឲ្យគេដកម្នាងសិលានៅក្នុងអគារទាំងមូលចេញហើយ បូករួមទាំងការតុបតែងជញ្ជាំងផ្នែកខាងក្រៅ និងការតុបតែងអគារថ្មីទាំងស្រុងដែលនឹងចាប់ផ្ដើមក្នុងពេលពីរបីសប្ដាហ៍ខាងមុខ។ ដូច្នេះ ការខូចខាតនេះមិនមានបញ្ហាអ្វីទាំងអស់ ដោយព្រោះបើវាមិនខូច ខ្ញុំនឹងត្រូវដកវាចេញដដែលហ្នឹង។ ប៉ុន្តែ សូមស្ដាប់ឲ្យទាន់ ក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្ញុំបានផ្ញើមូលប្បទានប័ត្រមួយសន្លឹកមកឲ្យខ្ញុំដែលមានចំនួនទឹកប្រាក់អាចឲ្យខ្ញុំទិញយន្តហោះមួយបាន!

តើខ្ញុំទើបតែបានឃើញមែនទេ? ខ្ញុំគ្រាន់តែទទួលបានយន្តហោះរបស់ខ្ញុំ និងអគារការិយាល័យរបស់ខ្ញុំដោយមិនជំពាក់បំណុលគេ។ មែនហើយ នៅពេលនេះដែលខ្ញុំបើកយន្តហោះនោះ ហើយខ្ញុំបើកសំកាំងនៅពីលើដីកសិដ្ឋាន ខ្ញុំនឹកឃើញថាការបើកយន្តហោះនោះគឺដូចជាព្រះរាជ្យរបស់ព្រះជាម្ចាស់។ ប្រតិបត្តិការ និងច្បាប់នៃព្រះរាជ្យអនុញ្ញាតឲ្យយើងរស់នៅក្នុងជីវិតខុសពីមុនទាំងស្រុង។ ដូចជាដង្កូវមេអំបៅ និងមេអំបៅអញ្ចឹង គឺដង្កូវមេអំបៅនឹងមិនដែលដុះជើងដែលអាចឲ្យវារត់លឿន

ដល់ប្រទេសមិកស៊ិកទេ។ ជីវិតរបស់ខ្ញុំដែលបាននៅជាប់នឹងការដែលគ្រាន់តែឲ្យបានរស់រាន និងភាពភ័យខ្លាច នៅពេលនេះបានផ្លាស់ប្រែដោយព្រះរាជ្យរបស់ព្រះជាម្ចាស់។ ដោយការចូលទៅកាន់ច្បាប់នេះ ខ្ញុំអាចរកឃើញជីវិតដែលមានលទ្ធភាពឥតដែនកំណត់។

នៅពេលដែលខ្ញុំបញ្ចប់សៀវភៅនេះ ខ្ញុំចង់បន្សល់ទុកឲ្យលោកអ្នកនូវអត្ថបទគម្ពីរមួយ។ ខ្ញុំដឹងថាលោកអ្នកប្រាកដជាបានឮពីខនេះនៅពេញមួយជីវិតរបស់លោកអ្នកមកហើយ។ ប៉ុន្តែ ខ្ញុំគិតថានៅពេលនេះ ខនេះនឹងមានអត្ថន័យថ្មីសន្លាងទាំងស្រុងចំពោះលោកអ្នក។

*«អស់អ្នកដែលនឿយហត់ និងមានបន្ទុកធ្ងន់អើយ! ចូរមករកខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាបានសម្រាក។ ចូរយកនឹម របស់ខ្ញុំដាក់លើអ្នករាល់គ្នា ហើយរៀនពីខ្ញុំទៅ អ្នករាល់គ្នាមុខជាបានស្ងប់ចិត្តមិនខាន ដ្បិតខ្ញុំស្លូត និងមានចិត្តសុភាព។ នឹមរបស់ខ្ញុំស្រួល ហើយបន្ទុកដែលខ្ញុំដាក់លើអ្នករាល់គ្នាក៏ស្រាលដែរ»។*

ម៉ាថាយ ១១៖២៨-៣០ (ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន)

ព្រះយេស៊ូបានយាងមកដើម្បីយកនឹមរបស់លោកអ្នក ជាការខិតខំកាប់គាប់ដីចិញ្ចឹមជីវិតយ៉ាងវេទនា និងបង្ហូរញើសនៃប្រព័ន្ធបណ្តាសាផែនដីចេញពីយើង។ នៅពេលនេះ យើងត្រូវទទួលយកនឹមរបស់ទ្រង់ (ជាកិច្ចការដែលទ្រង់បានសម្រេច) និងរកការសម្រាក (ថ្ងៃទីប្រាំពីរជាថ្ងៃសប្ប័ទដ៏ពិត) សម្រាប់ព្រលឹងរបស់យើង។

លោកអ្នកអាចជួបប្រទះនូវបទពិសោធន៍ដ៏អស្ចារ្យជាច្រើននៅក្នុងជីវិតរបស់លោកអ្នក ប្រសិនបើលោកអ្នកគ្រាន់តែធ្វើអ្វីដែលប៉ូទីផារបានធ្វើ គឺប្រតិបត្តិចេញពីរបៀបនៃជីវិតដែលស្របតាមព្រះរាជ្យរបស់ព្រះជាម្ចាស់។ សូមធ្វើការសម្រេចចិត្តនៅ

**បដិវត្តន៍ហិរញ្ញវត្ថុ** - អំណាចនៃតក្តីភាពនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់

ថ្ងៃនេះដើម្បីឲ្យជីវិតរបស់លោកអ្នកស្របទៅតាមច្បាប់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ និងចាប់ផ្តើមទទួលនូវប្បទានុភាពនៃភក្តីភាពរបស់ទ្រង់។ ចូរចាប់ផ្តើមបដិវត្តន៍ថវិការបស់លោកអ្នកនៅថ្ងៃនេះ ដោយបោះចោលនូវរបៀបរស់នៅចាស់ រដ្ឋាភិបាលចាស់ ប្រព័ន្ធបណ្តាសាផែនដីនៃភាពក្រីក្រ ជំងឺ និងភាពអស់សង្ឃឹម។ ចូរចាកចេញពីរបៀបរស់នៅបែបជាដង្កូវ ហើយចាប់ផ្តើមហើរដោយប្រើប្រាស់ច្បាប់នៃព្រះរាជ្យដែលព្រះយេស៊ូបានប្រទានដល់លោកអ្នក។ លោកអ្នកជាពលរដ្ឋនៃព្រះរាជ្យនោះ។

លោកអ្នកមានសិទ្ធិស្របច្បាប់!

ប្រសិនបើលោកអ្នកឃើញថាសៀវភៅនេះគួរឲ្យចាប់អារម្មណ៍ ហើយលោកអ្នកតាំងចិត្តថានឹងក្លាយជាសិស្សនៃព្រះរាជ្យរបស់ព្រះ សូមអនុញ្ញាតឲ្យខ្ញុំបង្ហាញលោកអ្នកអំពីគេហទំព័រ GaryKeesee.com។ នៅទីនោះ លោកអ្នកនឹងឃើញបណ្ណាល័យនៃព័ត៌មានជាច្រើនដែលនឹងជួយលោកអ្នក និងផ្តល់ឱវាទដល់លោកអ្នកនៅក្នុងព្រះរាជ្យ។ ខ្ញុំក៏សូមលើកទឹកចិត្តលោកអ្នកឲ្យក្លាយជាដៃគូ Team Revolution Partner ដែលក្នុងនោះលោកអ្នកក៏អាចចូលទៅមើលព្រឹត្តិការណ៍ពិសេសៗ និងវគ្គបង្វឹកនានាដែរ។

ជ័យជម្នះខាងផ្នែកថវិកាតម្រូវឲ្យមានចំណេះដឹងខាងវិញ្ញាណផង និងចំណេះដឹងនៅលើផែនដី ឬភពខាងធម្មជាតិផង។ សម្រាប់ព័ត៌មានពីការចាកចេញពីបំណុល យើងមានផែនការដើម្បីឲ្យលោកអ្នកមានសេរីភាពពីបំណុល ដែលត្រូវបានរៀបចំសម្រាប់លោកអ្នកដោយក្រុមហ៊ុនរបស់យើងដែលមានឈ្មោះថា Forward Financial Group សូមទូរស័ព្ទមកយើងតាមរយៈលេខ 1-800-815-0818។

ការការពារប្រាក់សោធននិវត្តន៍ដែលលោកអ្នកខិតខំរកទាំងលំបាកគឺសំខាន់ដូចជាការដែលលោកអ្នករកវាដែរ ជាពិសេសនៅពេលដែលលោកអ្នកកំពុងជួបនឹងទុក្ខលំបាកខាងផ្នែកថវិកានេះ។ ក្រុមហ៊ុនរបស់ខ្ញុំផ្តោតលើការជួយមនុស្សឲ្យដាក់ទុនដោយសុវត្ថិភាព។ ដោយមានប្រាក់ជាង ១០០លានដុល្លារដែលយើងបានជួយអតិថិជនរបស់យើងវិនិយោគ ពុំមាននរណាម្នាក់បានបាត់ប្រាក់សូម្បីតែមួយកាក់មួយសេន នៅក្នុងពេល ១៥ ឆ្នាំដែលប្រទេសអាមេរិកមានវិបត្តិសេដ្ឋកិច្ចនេះទេ។ ជាថ្មីម្តងទៀត លោកអ្នកអាចទូរស័ព្ទមកដោយឥតគិតថ្លៃ ហើយយើងនឹងផ្តល់ដំបូន្មានដោយឥតគិតថ្លៃតាមរយៈលេខ 1-800-815-0818។

ឌ្រិនដានិងខ្ញុំប្តេជ្ញាក្នុងការជួយបុគ្គល និងក្រុមគ្រួសារនានាឲ្យមានជ័យជម្នះក្នុងឆាកជីវិត។ ហេតុនេះហើយបានជាឌ្រិនដាបង្កើតកម្មវិធីទូរទស្សន៍ផ្ទាល់ខ្លួនរបស់នាងដែលមានឈ្មោះថា Drenda។ វាជាកម្មវិធីដែលមានគោលបំណងជួយដល់

ជីវិតក្រុមគ្រួសារ និងលើកទឹកចិត្តដល់ស្ត្រីនៅគ្រប់វ័យទាំងអស់។ សូមចូលទៅកាន់គេហទំព័រ Drenda.com សម្រាប់ព័ត៌មានបន្ថែម។

ជាចុងក្រោយឌ្រិនដានិងខ្ញុំសុំឲ្យលោកអ្នកធ្វើការពិចារណាលើការផ្គត់ផ្គង់ដល់ក្រុមជំនុំ និងគ្រូគង្វាលនានានៅជុំវិញពិភពលោក។ គម្រោងឈោងចាប់ H-3 របស់យើងជាគម្រោងដែលយើងចាប់ផ្តើមឡើងដោយទឹកចិត្តស្រឡាញ់ និងជួយដល់មនុស្សនៅខាងផ្នែកជីវិតជាក់ស្តែង។ គម្រោង H-3 ផ្តល់នូវធនធានបង្រៀនរាប់ម៉ឺនធនធានដល់គ្រូគង្វាលនៅជុំវិញពិភពលោកជារៀងរាល់ឆ្នាំ។ យើងក៏ជួយផ្តល់អាហារដល់អ្នកស្រេកឃ្លាន គាំទ្រដល់ព័ន្ធកិច្ចដែលមានគោលបំណងបញ្ឈប់ការជួញដូរមនុស្សនៅក្នុងប្រទេសជាច្រើន ផ្គត់ផ្គង់ដល់ផ្ទះកុមារកំព្រា គាំទ្រផ្នែកថវិកាដល់គ្រូគង្វាលនៅក្នុងបណ្តាប្រទេសជាច្រើន ព្រមទាំងថែទាំផ្ទះស្ត្រីៗនៅរដ្ឋអូហៃយ៉ូនេះដែរ។ យើងមានគោលដៅជួយដល់មនុស្សនៅជុំវិញពិភពលោកឲ្យរៀនអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងរៀនពីសេរីភាព និងការស្កប់ចិត្តដែលព្រះជាម្ចាស់ចង់ឲ្យយើងគ្រប់ៗគ្នាមាន។

សូមអរគុណជាខ្លាំងដែលបានអនុញ្ញាតឲ្យខ្ញុំចែករំលែកនូវសាច់រឿងដ៏អស្ចារ្យរបស់យើងជាមួយលោកអ្នក។ នៅពេលនេះ សូមចេញទៅ ហើយបង្កើតជាសាច់រឿងដ៏អស្ចារ្យពីជីវិតរបស់លោកអ្នកផ្ទាល់ម្តង ជាមួយនឹងព្រះរាជ្យរបស់ព្រះជាម្ចាស់។

ពីខ្ញុំ

ហ្គារី ឃីស៊ី



# បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក

## អំណាចនៃភក្ដីភាពក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់

សូមអានសៀវភៅនេះប្រសិនបើលោកអ្នក...

**មានកង្វល់អំពីស្ថានភាពហិរញ្ញវត្ថុរបស់លោកអ្នក**

**ចង់ចាកចេញពីបំណុល**

**មិនដឹងថាត្រូវចាប់ផ្ដើមនៅត្រង់ណា**

**អស់សង្ឃឹម**

លោកហ្គារី ឃីស៊ីបានឆ្លងកាត់ស្ថានភាពទាំងនោះផ្ទាល់អស់រយៈពេល៩ឆ្នាំ។ ពេលនោះ ជាពេលដ៏លំបាក ហើយភរិយារបស់លោកបានរងសម្ពាធផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ដោយសារស្ថានការណ៍ហិរញ្ញវត្ថុដ៏លំបាកនេះ។ នៅក្នុងជីវិតរបស់លោក តែងមានម្ចាស់បំណុលទូរស័ព្ទមកទារបំណុល ខាងពន្ធដារឃាត់ទ្រព្យសម្បត្តិរបស់ពួកគេទុកដោយសារគ្មានប្រាក់បង់ពន្ធ រងនូវការវិនិច្ឆ័យ និងមានភាពអាម៉ាស់យ៉ាងខ្លាំង។ ប៉ុន្តែ អ្វីៗទាំងអស់បានផ្លាស់ប្ដូរនៅថ្ងៃមួយដែលព្រះជាម្ចាស់បានមានបន្ទូលមកកាន់លោកហ្គារីអំពីហិរញ្ញវត្ថុរបស់លោក ព្រមទាំងប្រទានឲ្យលោកនូវអាថ៌កំបាំងដែលបានផ្លាស់ប្ដូរជីវិតរបស់លោកយ៉ាងខ្លាំង! លោកក៏បានផុតពីបំណុល បង្កើតក្រុមហ៊ុនដែលមានតម្លៃរាប់លានដុល្លារ ហើយថ្មីៗនេះ លោកបានចែករំលែកពីគន្លឹះដែលបានផ្លាស់ប្ដូរជីវិតរបស់លោកតាមរយៈកម្មវិធីទូរទស្សន៍ក្រោមចំណងជើងថា Fixing the Money Thing ដែលចាក់បញ្ចាំងនៅជុំវិញពិភពលោកជារៀងរាល់ថ្ងៃ។ លោកហ្គារីបានបង្រៀនពីគោលគំនិតទាំងនោះទៅកាន់មនុស្សរាប់លាននាក់នៅជុំវិញពិភពលោកតាមអង្គសន្និបាត និងជំនួបផ្ទាល់ខ្លួន។ ប៉ុន្តែ មានមេរៀនដ៏សំខាន់មួយដែលលោកចង់ចែករំលែកខ្លាំងបំផុត។ លោកហ្គារីអញ្ជើញលោកអ្នកឲ្យចូលរួមនៅក្នុងបដិវត្តន៍នេះ ហើយធ្វើការផ្លាស់ប្ដូរស្ថានភាពហិរញ្ញវត្ថុរបស់លោកអ្នកតាមរយៈអំណាចនៃភក្ដីភាពនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។



លោកហ្គារី ឃីស៊ីជាអ្នកនិពន្ធ វាគ្មិន សហគ្រិន អ្នកជំនាញហិរញ្ញវត្ថុ និងគ្រូគង្វាលដែលមានចិត្តឆេះឆួលក្នុងការជួយមនុស្សឲ្យមានជ័យជម្នះក្នុងជីវិត ជាពិសេសទាក់ទងនឹងជំនឿ ក្រុមគ្រួសារ និងហិរញ្ញ-វត្ថុ។ លោកហ្គារី និងអ្នកស្រីឌ្រិនដាជាភរិយាបានបង្កើតអាជីវកម្មដ៏ជោគជ័យជាច្រើន ព្រមទាំងជាស្ថាបនិកនៃព័ន្ធកិច្ច Faith Life Now ដែលនៅពេលនេះបង្កើតនូវកម្មវិធីទូរទស្សន៍ពីរគឺ Fixing the Money Thing និង Drenda, សន្និបាតនៅជុំវិញពិភពលោក ព្រមទាំងធនធានអនុវត្តន៍ជាច្រើន។ ក្រុមគ្រួសារត្រកូលឃីស៊ីក៏ជាគ្រូគង្វាលនៅក្រុមជំនុំ Faith Life Church ក្បែរទីក្រុងកូឡំបឺស រដ្ឋអូហៃយ៉ូ។

ISBN 9780972903592

P.O. Box 779, New Albany, OH 43054
1.888.391.LIFE | garykeesee.com